# ព្រះ

# ត្រៃបិដកបាលី

និង

សេចក្តីប្រែជាភាសាខ្មែរ

# សុត្តន្តបិដក

## មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក

បឋមភាគ

# ២៤

សុត្តន្តបិដក

មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ

បឋមភាគ

---

២៤

ព. ស. ២៥០៤

ផ្តើមធ្វើនៅថ្ងៃ ១១ កើត ខែមាឃ អដ្ឋស័ក ព.ស ២៥៥០

ត្រូវនឹងថ្ងៃច័ន្ទ ទី ២៩ ខែ មករា ឆ្នាំ ២០០៧

ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ឈាយ ចំរើន

" ខេត្ត បាត់ដំបង "

## បរិព្វាជកវគ្គោ

### បឋមំ តេវិជ្ជវច្ឆគោត្តសុត្តំ(១)

[១] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន វច្ឆគោត្តោ បរិព្វាជកោ ឯកបុណ្ឌរីកេ បរិព្វាជការាមេ បដិវសតិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ អថខោ ភគវតោ ឯតទហោសិ អតិប្បគោ ខោ តាវ វេសាលិយំ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន ឯកបុណ្ឌរីកោ បរិព្វាជការាមោ យេន វច្ឆគោត្តោ បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ ភគវា យេន ឯកបុណ្ឌរីកោ បរិព្វាជការាមោ យេន វច្ឆគោត្តោ បរិព្វាជកោ តេនុបសង្កមិ ។ អទ្ទសា ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន(២)

---

១ ឱ. តេវិជ្ជវច្ឆសុត្តន្តិ ... ។
២ ម. យ. ទិស្វាន ។

## បរិព្វាជកវគ្គ

### តេវិជ្ជវច្ឆគោត្តសូត្រ ទី ១

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះ វច្ឆគោត្តបរិព្វាជក អាស្រ័យនៅក្នុងអារាមរបស់បរិព្វាជក ដែលមានឈើស្វាយសមួយដើម ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលី នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែតថាគត ចៀសចូលទៅអារាមរបស់បរិព្វាជកឈ្មោះវច្ឆគោត្ត ឯអារាមរបស់បរិព្វាជកដែលមានដើមស្វាយសមួយដើមនោះ ។ លុះគ្រានោះព្រះមានព្រះភាគ ស្តេចចូលទៅកាន់វច្ឆគោត្តបរិព្វាជក ក្នុងអារាមរបស់បរិព្វាជក ដែលមានដើមស្វាយសមួយដើមហើយ ។ វច្ឆគោត្តបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ បានក្រាប

[illegible]

(២) [illegible]

[illegible]



[illegible] បពិត្រព្រះអង្គដ៏ចំរើន [illegible]

(២) [illegible]

ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។ យេ តេ វច្ឆ ឯវមាហំសុ សមណោ គោតមោ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ច បន មន្តេ[១] អសតា អភូតេនាតិ ។

១ ម. មំ ។



ឥតមានសេសសល់ថា កាលតថាគតដើរក្តី ឈរនៅក្តី លក់ក្តី ភ្ញាក់ក្តី ញាណទស្សនៈរមែងតាំងនៅប្រាកដជាប់រឿយ ៗ មិនដាច់ បពិត្រព្រះអង្គដ៏ចំរើន ជនទាំងនោះ តើឈ្មោះថាជាអ្នកពោលតាមពាក្យដែលព្រះមានព្រះភាគត្រាស់ហើយផង មិនឈ្មោះថា ពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលប្រកបនូវហេតុ (ព្រះសព្វញ្ញុតញ្ញាណ) តាមហេតុ (ពាក្យដែលមហាជនទាំងឡាយប្រកាន់នោះ) ផង មួយទៀត វាទានុវាទ (ពាក្យរបស់ព្រះអង្គនឹងពាក្យដែលអនុលោមតាមវាទៈរបស់ព្រះអង្គ) ណាមួយ ដែលប្រកបដោយហេតុ (តាមហេតុដែលគេពោល) នឹងមិនមកកាន់ឋានៈដែលអ្នកប្រាជ្ញគប្បីតិះដៀលទេឬ ។ ម្នាលវច្ឆៈ ជនទាំងឡាយណាពោលយ៉ាងនេះថា ព្រះសមណគោតម ព្រះអង្គជាសព្វញ្ញូ ព្រះអង្គជ្រាបនូវធម៌ទាំងពួង ទ្រង់ប្តេជ្ញានូវញាណទស្សនៈឥតមានសេសសល់ថា កាលតថាគតដើរក្តី ឈរនៅក្តី លក់ក្តី ភ្ញាក់ក្តី ញាណទស្សនៈរមែងតាំងប្រាកដឡើងជារឿយ ៗ មិនដាច់ ជនទាំងឡាយនោះ មិនមែនពោលតាមពាក្យរបស់តថាគតទេ អ្នកទាំងនោះ ឈ្មោះថាពោលបង្កាច់តថាគតដោយពាក្យមិនពិតទេតើ ។

[៣] កថំ ព្យាករមានា បន មយំ ភន្តេ វុត្តវាទិនោ ចេវ ភគវតោ អស្សាម ន ច ភគវន្តំ អភូតេន អព្ភាចិក្ខេយ្យាម ធម្មស្ស ចានុធម្មំ ព្យាករេយ្យាម ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។ តេវិជ្ជោ សមណោ គោតមោតិ ខោ វច្ឆ ព្យាករមានោ វុត្តវាទី ចេវ មេ អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យ ។ អហញ្ហិ វច្ឆ យាវទេវ អាកង្ខាមិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អហញ្ហិ វច្ឆ យាវទេវ អាកង្ខាមិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ





[៣] បពិត្រព្រះអង្គដ៏ចំរើន ចុះយើងខ្ញុំ កាលឆ្លើយដូចម្តេច ទើបឈ្មោះថាជាអ្នកពោលតាមពាក្យ របស់ព្រះមានព្រះភាគផង ជាអ្នកមិនពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលឆ្លើយនូវហេតុតាមហេតុផង មួយទៀត វាទានុវាទណាមួយ ដែលប្រកបដោយហេតុ នឹងមិនមកកាន់ឋានៈដែលអ្នកប្រាជ្ញ គប្បីតិះដៀលបាន ។ ម្នាលវច្ឆៈ បុគ្គលកាលពោលឆ្លើយថា ព្រះសមណគោតមប្រកបដោយវិជ្ជា ៣ ដូច្នេះ ឈ្មោះថាជាអ្នកពោលតាមពាក្យរបស់តថាគតផង មិនឈ្មោះថាពោលបង្កាច់តថាគត ដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលឆ្លើយនូវហេតុតាមហេតុផង មួយទៀត វាទានុវាទណាមួយ ដែលប្រកបដោយហេតុ ក៏មិនមកកាន់ឋានៈ ដែលអ្នកប្រាជ្ញគប្បីតិះដៀលបាន ។ ម្នាលវច្ឆៈ បើតថាគតចង់រលឹក (ទៅរកជាតិ) ត្រឹមណា តថាគតក៏រលឹកបាននូវបុព្វេនិវាស ជាច្រើនត្រឹមណោះ ការរលឹកបាននោះដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ តថាគតរលឹកបាននូវបុព្វេនិវាស ជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលវច្ឆៈ បើតថាគតចង់ (ឃើញពួកសត្វ) ត្រឹមណា ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងនូវចក្ខុ ជារបស់មនុស្សធម្មតា តថាគតឃើញច្បាស់នូវសត្វទាំងឡាយ

ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាមិ ។ អហំ ហិ វច្ឆ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមិ ។ តេវិជ្ជោ សមណោ គោតមោតិ ខោ វច្ឆ ព្យាករមានោ វុត្តវាទី ចេវ មេ អស្ស ន ច មំ អភូតេន អព្ភាចិក្ខេយ្យ ធម្មស្ស ចានុធម្មំ ព្យាករេយ្យ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆេយ្យាតិ ។

(៤) ឯវំ វុត្តេ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភោ គោតម កោចិ គិហី គិហិសញ្ញោជនំ (១) អប្បហាយ កាយស្ស ភេទា

១ ម. គិហិសំយោជនំ ។



ដែលកំពុងច្យុត ដែលកំពុងកើតឡើង ជាសត្វថោកទាបនឹងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ត្រឹមណា ។ បេ ។ តថាគតដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលវច្ឆៈ ព្រោះតថាគត បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ (អរហត្តផលសមាធិ) នូវបញ្ញាវិមុត្តិ (អរហត្តផលបញ្ញា) មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តទៅ ។ ម្នាលវច្ឆៈ បុគ្គលកាលពោលព្យាករថា ព្រះសមណគោតមប្រកបដោយវិជ្ជា ៣ ដូច្នេះ ឈ្មោះថាជាអ្នកពោលតាមពាក្យរបស់តថាគតផង មិនឈ្មោះថា ពោលបង្កាច់តថាគតដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលព្យាករ នូវហេតុតាមហេតុផង មួយទៀត ឥតមានវាទានុវាទណាមួយ ដែលប្រកបដោយហេតុ ក៏មិនមកកាន់ឋានៈ ដែលអ្នកប្រាជ្ញគប្បីតិះដៀលបាន ។

(៤) លុះព្រះអង្គត្រាស់យ៉ាងនេះហើយ វច្ឆគោត្តបរិព្វាជកបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន បុគ្គលណាមួយដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ (សេចក្តីត្រេកអរក្នុងសង្ខារនិងបរិក្ខាររបស់គ្រហស្ថ ជាគ្រឿងចំណងចិត្ត) លុះបែកធ្លាយរាងកាយ

ទុក្ខស្សន្តករោតិ ។ នត្ថិ ខោ វច្ឆ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ ។ អត្ថិ បន ភោ គោតម កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា សគ្គូបគោតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោវ យេ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា សគ្គូបគាតិ ។ អត្ថិ នុ ខោ ភោ គោតម កោចិ អាជីវកោ កាយស្ស ភេទា ទុក្ខស្សន្តករោតិ ។ នត្ថិ ខោ វច្ឆ កោចិ អាជីវកោ កាយស្ស ភេទា ទុក្ខស្សន្តករោតិ ។ អត្ថិ បន ភោ គោតម កោចិ អាជីវកោ កាយស្ស ភេទា សគ្គូបគោតិ ។ ឥតោ ខោ សោ វច្ឆ ឯកនវុតោ កប្បោ យមហំ អនុស្សរាមិ នាភិជានាមិ កញ្ចិ អាជីវកំ សគ្គូបគំ អញ្ញត្រ



ទៅហើយ រមែងធ្វើនូវទីបំផុតនៃទុក្ខបាន មានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលទីមួយដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ លុះរំលាយខន្ធទៅហើយ រមែងធ្វើនូវទីបំផុតទុក្ខបាន មិនមានទេសោះ ។ បពិត្រព្រះគោតមដ៏ចំរើន ចុះបុគ្គលទីមួយដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ លុះដល់រំលាយខន្ធទៅ ចូលទៅកាន់ឋានសួគ៌ មានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលតាំងពីមួយរយណា ដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈទេ លុះដល់រំលាយខន្ធទៅហើយ ចូលទៅកាន់ឋានសួគ៌ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ នាក់ទេ តាមពិត មានច្រើនលើសប្រមាណណាស់ ។ បពិត្រព្រះគោតមដ៏ចំរើន បុគ្គលទីមួយដែលជាអាជីវក លុះដល់រំលាយខន្ធទៅ រមែងធ្វើនូវទីបំផុតទុក្ខបាន មានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលទីមួយដែលជាអាជីវក លុះដល់រំលាយខន្ធទៅហើយ រមែងធ្វើនូវទីបំផុតទុក្ខបាន មិនមានទេសោះ ។ បពិត្រព្រះគោតមដ៏ចំរើន ចុះបុគ្គលទីមួយដែលជាអាជីវក លុះដល់រំលាយខន្ធទៅ ចូលទៅកាន់ឋានសួគ៌ មានដែរឬ ។ ម្នាលវច្ឆៈ រាប់អំពីភទ្ទកប្បនេះឡើងទៅ ៩១ កប្ប តថាគតនឹកទៅ មិនឃើញ នូវអាជីវកណាមួយ ដែលចូលទៅកាន់ឋានសួគ៌ទេ វៀរ

ឯកេន ។ សោបាសិ(១) កម្មវាទី កិរិយវាទីតិ ។ ឯវំ សន្តេ ភោ គោតម សុញ្ញា តេ តិត្ថាយតនា អន្តមសោ សគ្គូបគេនាបីតិ ។ ឯវំ(២) វច្ឆ សុញ្ញា តេ តិត្ថាយតនា អន្តមសោ សគ្គូបគេនាបីតិ ។ ឥទមវោច ភគវា អត្តមនោ វច្ឆគោត្តោ បរិព្វាជកោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

តេវិជ្ជវច្ឆគោត្តសុត្តំ បឋមំ(៣) និដ្ឋិតំ ។

---

១ ឱ. បាសិ ។ ២ ឱ. សច្ចមេវ ។ ឯវំ សន្តេ ។ ៣ ឱ. ម. តេវិជ្ជវច្ឆគោត្ត-សុត្តំ បឋមំ ។



វៀរលែងតែបុគ្គលមួយពួក ដែលជាកម្មវាទី (អ្នកដែលពោលថាបុណ្យបាបជារបស់អ្នកធ្វើ) កិរិយវាទី (អ្នកពោលថាបុណ្យបាប ដែលអ្នកធ្វើ ឈ្មោះថាបានធ្វើហើយ) ។ បពិត្រព្រះគោតមដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ លទ្ធិរបស់តិរ្ថិយឯណោះ ដោយហោចទៅ ឈ្មោះថាសូន្យ ចាកគុណដែលនាំទៅកាន់ឋានសួគ៌ ។ ម្នាលវច្ឆៈ យ៉ាងហ្នឹងហើយ លទ្ធិរបស់តិរ្ថិយឯណោះ ដោយហោចទៅ ឈ្មោះថាសូន្យចាកគុណដែលនាំទៅកាន់ឋានសួគ៌ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ វច្ឆគោត្តបរិព្វាជក ក៏មានចិត្តត្រេកអរ ត្រេកអរហើយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ តេវិជ្ជវច្ឆគោត្តសូត្រ ទី ១ ។

---

## ទុតិយំ អគ្គិវច្ឆគោត្តសុត្តំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(២) ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច កិន្នុ ខោ ភោ គោតម សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ[១] គោតម អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ

១ ម. កឹ នុ ខោ ភោ ។

## អគ្គិវច្ឆគោត្តសូត្រ ទី ២

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងអារាមឈ្មោះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ បរិព្វាជកឈ្មោះវច្ឆគោត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនូវពាក្យរាក់ទាក់សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

(២) វច្ឆគោត្តបរិព្វាជក លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគត មិនឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីឃើញ យ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគត មិនឃើញ

ឯវំទិដ្ឋី អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កិន្នុ ខោ ភោ គោតម អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ គោតម អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កិន្នុ ខោ ភោ គោតម តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ គោតម អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ



យ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីយល់ឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត

មោឃមញ្ញន្តិ ។ កិន្នុ ខោ ភោ គោតម ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ គោតម ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កិន្នុ ខោ ភោ គោតម ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ កឹ បន ភោ គោតម នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ



ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន នេះឯងជាពាក្យពិត

គោតមោតិ ។ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

(៨) កិន្នុ ខោ ភោ គោតម សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ សស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កិំ បន ភោ គោតម អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ អសស្សតោ លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កិន្នុ ខោ ភោ គោតម អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋិ ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋិ អន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។



ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះទេ ។

(៨) វច្ឆគោត្តបរិព្វាជក ក្រាបទូលថា កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេចក្តីឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។

កឹ បន ភោ គោតម អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី អនន្តវា លោកោ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កិំ នុ ខោ ភោ គោតម តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី តំ ជីវំ តំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ បន ភោ គោតម អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី អញ្ញំ ជីវំ អញ្ញំ សរីរំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កិំ នុ ខោ ភោ គោតម ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ



កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនយល់ឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីយល់ឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេច-ក្តីយល់ឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនយល់ឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើន មានសេចក្តីយល់ឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ

ន ខោ អហំ វច្ឆ ឯវំទិដ្ឋី ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ បន ភោ គោតម ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កិន្នុ ខោ ភោ គោតម ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ ឯវំទិដ្ឋី ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ បន ភោ គោតម នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឯវំទិដ្ឋី ភវំ គោតមោតិ ឥតិ បុដ្ឋោ សមានោ ន ខោ អហំ វច្ឆ



ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក្តី មិនកើតទៀតក្តី នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក្តី មិនកើតទៀតក្តី នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ព្រះគោតមដ៏ចំរើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិន

ឯវំទិដ្ឋី នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណា ឥទមេវ សច្ចំ មោឃមញ្ញន្តិ វទេសិ ។ កឹ បន ភវំ គោតមោ អាទីនវំ សម្បស្សមានោ ឯវំ ឥមានិ សព្វសោ ទិដ្ឋិគតានិ អនុបគតោតិ ។

(៨) សស្សតោ លោកោតិ ខោ វច្ឆ ទិដ្ឋិគតមេតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារំ(១) ទិដ្ឋិវិសូកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ អសស្សតោ លោកោតិ ខោ វច្ឆ ។ បេ ។ អន្តវា លោកោតិ ខោ វច្ឆ ។ បេ ។ អនន្តវា លោកោតិ ខោ វច្ឆ ។ បេ ។ តំ ជីវំ តំ សរីរន្តិ ខោ វច្ឆ ។ បេ ។ អញ្ញំ ជីវំ

១ ម. ទិដ្ឋិកន្តារំ ។



ឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ ព្រះតថាគតមិនកាន់ ទ្រង់ឃើញច្បាស់ទូលាយដូចម្តេច បានជាមិនប្រកាន់នូវទិដ្ឋិទាំងនេះ ដោយប្រការទាំងពួងយ៉ាងនេះ ។

(៨) ម្នាលវច្ឆៈ សេចក្តីឃើញថា លោកទៀងដូច្នេះឯង ជាសេចក្តីឃើញយ៉ាងព្រៃស្បាត ជាសេចក្តីឃើញយ៉ាងឆ្ងាយដាច់ស្រយាល ជាសេចក្តីឃើញយ៉ាងចម្រូងចម្រាស ជាសេចក្តីឃើញឃ្លេងឃ្លោង ជាសេចក្តីឃើញដែលប្រកបសត្វទុកប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនដើម្បីប្រាសចាកតម្រេក មិនដើម្បីសេចក្តីរលត់ មិនដើម្បីសេចក្តីស្ងប់រម្ងាប់ មិនដើម្បីសេចក្តីដឹងច្បាស់ មិនដើម្បីសេចក្តីត្រាស់ដឹង មិនដើម្បីព្រះនិព្វាន ។ ម្នាលវច្ឆៈ សេចក្តីឃើញថាលោកមិនទៀងដូច្នេះឯង ។ បេ ។ ម្នាលវច្ឆៈ សេចក្តីឃើញថាលោកមានទីបំផុតដូច្នេះឯង ។ បេ ។ ម្នាលវច្ឆៈ សេចក្តីឃើញថាលោកមិនមានទីបំផុតដូច្នេះឯង ។ បេ ។ ម្នាលវច្ឆៈ សេចក្តីឃើញថានោះជីវៈ នោះសរីរៈ ដូច្នេះឯង ។ បេ ។ ម្នាលវច្ឆៈ សេចក្តីឃើញថាជីវៈដទៃ

អញ្ញំ សរីរន្តិ ខោ វច្ឆ ។បេ។ ហោតិ តថាគតោ បរម្មរណាតិ ខោ វច្ឆ ។បេ។ ន ហោតិ តថាគតោ បរម្មរណាតិ ខោ វច្ឆ ។បេ។ ហោតិ ច ន ច ហោតិ តថាគតោ បរម្មរណាតិ ខោ វច្ឆ ។បេ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ខោ វច្ឆ ទិដ្ឋិគតមេតំ ទិដ្ឋិគហនំ ទិដ្ឋិកន្តារំ ទិដ្ឋិវិសូកំ ទិដ្ឋិវិប្ផន្ទិតំ ទិដ្ឋិសញ្ញោជនំ សទុក្ខំ សវិឃាតំ សឧបាយាសំ សបរិឡាហំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ ឥមំ ខោ អហំ វច្ឆ អាទីនវំ សម្បស្សមានោ ឯវំ ឥមានិ សព្វសោ ទិដ្ឋិគតានិ អនុបគតោតិ ។ អត្ថិ បន ភោតោ គោតមស្ស កិញ្ចិ ទិដ្ឋិគតន្តិ ។ ទិដ្ឋិគតន្តិ ខោ វច្ឆ អបនីតមេតំ តថាគតស្ស ទិដ្ឋញ្ហេតំ(១) វច្ឆ

---

១ ម. ទិដ្ឋញ្ហិ ។



សរីរៈដទៃឬ ដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្តីឃើញថា សត្វខាងមុខអំពីមរណៈទៅកើតទៀត ដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្តីឃើញថា សត្វខាងមុខអំពីមរណៈទៅមិនកើតទៀតដូច្នេះ ។បេ។ ម្នាលវច្ឆៈ សេចក្តីឃើញថា សត្វខាងមុខអំពីមរណៈទៅកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្តីឃើញថា សត្វខាងមុខអំពីមរណៈទៅកើតទៀត ក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះឯង ជាសេចក្តីឃើញយ៉ាងព្រៃស្បាត ជាសេចក្តីឃើញយ៉ាងឆ្ងាយដាច់ស្រយាល ជាសេចក្តីឃើញយ៉ាងច្របូកច្របល់ ជាសេចក្តីឃើញយ៉ាងឃ្វេងឃ្វាង ជាសេចក្តីឃើញដែលប្រកបសត្វទុកប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនដើម្បីប្រាសចាកតម្រេក មិនដើម្បីសេចក្តីរលត់ មិនដើម្បីសេចក្តីស្ងប់រម្ងាប់ មិនដើម្បីសេចក្តីដឹងច្បាស់ មិនដើម្បីសេចក្តីត្រាស់ដឹង មិនដើម្បីព្រះនិព្វាន ។ ម្នាលវច្ឆៈ តថាគតឃើញច្បាស់នូវទោសដូច្នេះឯង ទើបបានជាមិនប្រកាន់នូវទិដ្ឋិទាំងនេះ ដោយប្រការទាំងពួងយ៉ាងនេះ ។ ចុះសេចក្តីឃើញបន្តិចបន្តួចរបស់ព្រះគោតមដ៏ចំរើនមានខ្លះដែរឬ ។ ម្នាលវច្ឆៈ សេចក្តីឃើញដូច្នេះឯង តថាគតបាននាំចេញហើយ ម្នាលវច្ឆៈ ព្រោះសេចក្តីឃើញ

តថាគតេន ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ តស្មា តថាគតោ សព្វមញ្ញិតានំ សព្វមថិតានំ (១) សព្វាហង្ការមមង្ការមានានុសយានំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា អនុបាទា វិមុត្តោតិ វទាមីតិ ។

(៤) ឯវំ វិមុត្តចិត្តោ បន ភោ គោតម ភិក្ខុ កុហឹ ឧប្បជ្ជតីតិ (២) ។ ឧប្បជ្ជតីតិ ខោ វច្ឆ ន ឧបេតិ ។ តេនហិ ភោ គោតម ន ឧប្បជ្ជតីតិ ។ ន ឧប្បជ្ជតីតិ ខោ វច្ឆ ន ឧបេតិ ។

១ សព្វមថិតានន្តិបិ ។ ២ ម ឧបបជ្ជតីតិបិ ។



នេះ តថាគតឃើញហើយថា រូបដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃរូបដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃវេទនាដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃសញ្ញាដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃវិញ្ញាណដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃវិញ្ញាណដូច្នេះ ព្រោះហេតុនោះ បានជាតថាគតពោលថា តថាគតរួចស្រឡះហើយ ព្រោះមិនប្រកាន់មាំ ព្រោះអស់ទៅ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ទៅ ព្រោះលះបង់ ព្រោះរលាស់ចោល នូវសេចក្តីមើលងាយទាំងពួង នូវសេចក្តីបន្ទាបបន្ថោកទាំងពួង នឹងអហង្ការ មមង្ការមានានុស័យទាំងពួង(១) ។

(៤) បពិត្រព្រះគោតមដ៏ចំរើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ។ ម្នាលវច្ឆៈ ពាក្យថាកើតទៀតដូច្នេះមិនគួរទេ ។ បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែមិនកើតទៀតទេឬ ។ ម្នាលវច្ឆៈ ពាក្យថា មិនកើតទៀតដូច្នេះ ក៏មិនគួរ ។

១ បានដល់ ទិដ្ឋិ តណ្ហា និងមានះ ទាំង ៣ ។ អដ្ឋកថា ។

តេនហិ ភោ គោតម ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ។ ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ខោ វច្ឆ ន ឧបេតិ ។ តេនហិ ភោ គោតម នេវ ឧបបជ្ជតិ ន ន ឧបបជ្ជតីតិ ។ នេវ ឧបបជ្ជតិ ន ន ឧបបជ្ជតីតិ ខោ វច្ឆ ន ឧបេតិ ។

[១០] ឯវំ វិមុត្តចិត្តោ បន ភោ គោតម ភិក្ខុ កុហឹ ឧបបជ្ជតីតិ ឥតិ បុដ្ឋោ សមានោ ឧបបជ្ជតីតិ ខោ វច្ឆ(១) ន ឧបេតីតិ វទេសិ ។ តេនហិ ភោ គោតម ន ឧបបជ្ជតីតិ ឥតិ បុដ្ឋោ សមានោ ន ឧបបជ្ជតីតិ ខោ វច្ឆ ន ឧបេតីតិ វទេសិ ។ តេនហិ ភោ គោតម ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ឥតិ បុដ្ឋោ សមានោ ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ខោ វច្ឆ ន ឧបេតីតិ វទេសិ ។ តេនហិ ភោ គោតម

១ ម. ភោ វច្ឆ ។



បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មិនគួរ ។

[១០] កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថាកើតទៀតដូច្នេះមិនគួរទេ ។ កាលខ្ញុំទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែមិនកើតទៀតទេឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា មិនកើតទៀតដូច្នេះក៏មិនគួរ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះក៏មិនគួរ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចំរើន បើដូច្នោះមានតែ

នេវ ឧប្បជ្ជតិ ន ន ឧប្បជ្ជតីតិ ឥតិ បុដ្ឋោ សមានោ នេវ ឧប្បជ្ជតិ ន ន ឧប្បជ្ជតីតិ ខោ វច្ឆ ន ឧបេតីតិ វទេសិ ។ ឯត្ថាហំ ភោ គោតម អញ្ញាណមាបាទឹ ឯត្ថ សម្មោហមាបាទឹ ។ យាបិ មេ ឯសា ភោតោ គោតមស្ស បុរិមេន កថាសល្លាបេន អហុ បសាទមត្តា សាបិ មេ ឯតរហិ អន្តរហិតាតិ ។

[១១] អលញ្ហិ តេ វច្ឆ អញ្ញាណាយ អលំ សម្មោហាយ គម្ភីរោ ហាយំ(១) វច្ឆ ធម្មោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ និបុណោ បណ្ឌិតវេទនីយោ សោ តយា ទុជ្ជានោ អញ្ញទិដ្ឋិកេន អញ្ញខន្តិកេន អញ្ញរុចិកេន អញ្ញត្រយោគេន(២) អញ្ញត្ថាចរិយកេន(៣) តេនហិ វច្ឆ តំយេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ វច្ឆ

១ ម. ហយំ ។ ២ ឱ. ម. អញ្ញត្រយោគេន ។ ៣ ម. អញ្ញត្រ អាចរិយកេន ។



កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនទេ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គដល់នូវសេចក្តីមិនដឹងក្នុងដំណើរនេះ ដល់នូវសេចក្តីវង្វេងក្នុងដំណើរនេះ ។ ភាពណារបស់ខ្ញុំដែលជាភាពអាចញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតមាន ដោយពាក្យពោលមុនរបស់ព្រះគោតមដ៏ចំរើន ឥឡូវនេះ ភាពនោះរបស់ខ្ញុំក៏បាត់អស់ទៅ ។

[១១] ម្នាលវច្ឆៈ គួរតែអ្នកមិនដឹង គួរតែអ្នកវង្វេង ម្នាលវច្ឆៈ ព្រោះធម៌នេះជាធម៌ជ្រាលជ្រៅ ជាធម៌ដែលបុគ្គលឃើញបានដោយកម្រ ជាធម៌ត្រាស់ដឹងបានដោយកម្រ ជាធម៌ដ៏ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីត្រាច់ចុះនៃតក្កៈបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ធម៌នោះខ្លួនអ្នកដែលមានទិដ្ឋិដទៃ មានសេចក្តីពេញចិត្តដទៃ មានសេចក្តីគាប់ចិត្តដទៃ មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចារ្យក្នុងទីដទៃ នឹងដឹងបានដោយកម្រ ម្នាលវច្ឆៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នកក្នុងដំណើរនេះវិញ ដំណើរនោះគួរដល់អ្នកយ៉ាងណា អ្នកគប្បីដោះស្រាយនូវដំណើរនោះយ៉ាងនោះចុះ ម្នាលវច្ឆៈ អ្នកសំគាល់នូវដំណើរនោះដូចម្តេច

សចេ តេ បុរតោ អគ្គិ ជលេយ្យ ជានេយ្យាសិ ត្វំ អយំ មេ បុរតោ អគ្គិ ជលតីតិ ។ សចេ មេ ភោ គោតម បុរតោ អគ្គិ ជលេយ្យ ជានេយ្យាហំ អយំ មេ បុរតោ អគ្គិ ជលតីតិ ។ សចេ បន តំ វច្ឆ ឯវំ បុច្ឆេយ្យ យោ តេ អយំ បុរតោ អគ្គិ ជលតិ អយំ អគ្គិ កឹ បដិច្ច ជលតីតិ ឯវំ បុដ្ឋោ ត្វំ វច្ឆ កិន្តិ ព្យាករេយ្យាសីតិ ។ សចេ មំ ភោ គោតម ឯវំ បុច្ឆេយ្យ យោ តេ អយំ បុរតោ អគ្គិ ជលតិ អយំ អគ្គិ កឹ បដិច្ច ជលតីតិ ឯវំ បុដ្ឋោ អហំ ភោ គោតម ឯវំ ព្យាករេយ្យំ យោ មេ(១) បុរតោ អគ្គិ ជលតិ អយំ អគ្គិ តិណកដ្ឋុបាទានំ បដិច្ច ជលតីតិ ។ សចេ វច្ឆ បុរតោ សោ អគ្គិ និព្វាយេយ្យ ជានេយ្យាសិ ត្វំ អយំ មេ បុរតោ អគ្គិ និព្វុតោតិ ។ សចេ មេ ភោ គោតម បុរតោ សោ អគ្គិ និព្វាយេយ្យ ជានេយ្យាហំ អយំ មេ បុរតោ អគ្គិ និព្វុតោតិ ។

១ ម. យោ មេ អយំ ។





បើភ្លើងឆេះក្នុងទីចំពោះមុខអ្នក អ្នកគប្បីដឹងថា ភ្លើងនេះឆេះក្នុងទីចំពោះមុខអាត្មាអញដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន បើភ្លើងឆេះក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះឆេះ ក្នុងទីចំពោះមុខអាត្មាអញ ។ ម្នាលវច្ឆៈ បើគេសួរអ្នកយ៉ាងនេះថា ភ្លើងណានេះ ឆេះក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះ ព្រោះអាស្រ័យអ្វី ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះគោតមដ៏ចំរើន បើគេសួរខ្ញុំយ៉ាងនេះថា ភ្លើងណានេះឆេះក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះ ព្រោះអាស្រ័យអ្វី បពិត្រព្រះគោតមដ៏ចំរើន បើគេសួរយ៉ាងនេះ ខ្ញុំគប្បីដោះស្រាយយ៉ាងនេះថា ភ្លើងណានេះឆេះក្នុងទីចំពោះមុខខ្ញុំ ភ្លើងនេះឆេះឡើង ព្រោះអាស្រ័យខ្សៀ កញ្ចមតែស្មៅនិងឈើ ។ ម្នាលវច្ឆៈ បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខ (អ្នក) អ្នកគប្បីដឹងថា ភ្លើងនេះរលត់ហើយក្នុងទីចំពោះមុខអាត្មាអញដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះរលត់ហើយ ក្នុងទីចំពោះមុខអាត្មាអញ ។

សចេ បន តំ វច្ឆ ឯវំ បុច្ឆេយ្យ យោ តេ អយំ បុរតោ អគ្គិ និព្វុតោ សោ អគ្គិ ឥតោ កតមំ ទិសំ គតោ បុរត្ថិមំ វា បច្ឆិមំ វា ឧត្តរំ វា ទក្ខិណំ វាតិ ឯវំ បុដ្ឋោ ត្វំ វច្ឆ កិន្តិ ព្យាករេយ្យាសីតិ ។ ន ឧបេតិ ភោ គោតម យញ្ហិ សោ ភោ គោតម អគ្គិ តិណកដ្ឋុបាទានំ បដិច្ច ជលតិ(១) តស្ស ច បរិយាទានា អញ្ញស្ស ច អនុបហារា អនាហារោ និព្វុតោត្វេវ សង្ខ្យំ គច្ឆតីតិ ។

(១៦) ឯវមេវ ខោ វច្ឆ យេន រូបេន តថាគតំ បញ្ញាបយមានោ បញ្ញាបេយ្យ តំ រូបំ តថាគតស្ស បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ(២) អាយតិំ អនុប្បាទធម្មំ រូបសង្ខាវិមុត្តោ ខោ វច្ឆ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ ។ សេយ្យថាបិ មហាសមុទ្ទោ ឧប្បជ្ជតីតិ ន ឧបេតិ ន ឧប្បជ្ជតីតិ ន ឧបេតិ ឧប្បជ្ជតិ ច ន ច ឧប្បជ្ជតីតិ ន ឧបេតិ នេវ ឧប្បជ្ជតិ ន ន ឧប្បជ្ជតីតិ

១ ម. អជលិ ។ ២ ម. អនភាវកតំ ។



ម្នាលវច្ឆៈ ចុះបើគេសួរយ៉ាងនេះថា ភ្លើងណា ដែលរលត់ហើយក្នុងទីចំពោះមុខអ្នក ភ្លើងនោះទៅអំពីទីនេះទៅហើយ ទៅកាន់ទិសណា ខាងកើតឬខាងលិច ខាងជើងឬខាងត្បូង ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះតើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរនឹងដោះស្រាយបានទេ បពិត្រព្រះគោតមដ៏ចំរើន ដ្បិតថាភ្លើងនោះ ឆេះព្រោះអាស្រ័យនូវកញ្ចុមតិណស្មៅនិងឧសណា ដល់នូវកិរិយារាប់ថា រលត់ទៅមិនមានអាហារដូច្នេះ ព្រោះអស់ទៅនៃកញ្ចុមតិណស្មៅនិងឧសនោះផង ព្រោះមិនមានកិរិយានាំចូលទៅនៃគ្រឿងដទៃផង ។

(១៦) ម្នាលវច្ឆៈ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយរូបណា រូបនោះតថាគត លះបង់ហើយ កាត់ឫសគល់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជារូបមានកិរិយាមិនកើតឡើងតទៅទៀតជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយចាកចំណែកនៃរូប ជាអ្នកជ្រៅ (ដោយគុណ) មានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រយ៉ាងនេះឯង ។ ដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថា មិនកើតទៀតទេក៏មិនគួរ ថា កើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន

ន ឧបេតិ ។ យាយ វេទនាយ តថាគតំ បញ្ញាប-
យមានោ បញ្ញាបេយ្យ សា វេទនា តថាគតស្ស
បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា
អាយតឹ អនុប្បាទធម្មា វេទនាសង្ខាវិមុត្តោ ខោ វច្ឆ
តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ ។
សេយ្យថាបិ មហាសមុទ្ទោ ឧប្បជ្ជតីតិ ន ឧបេតិ ន
ឧប្បជ្ជតីតិ ន ឧបេតិ ឧប្បជ្ជតិ ច ន ច ឧប្បជ្ជតីតិ
ន ឧបេតិ នេវ ឧប្បជ្ជតិ ន ន ឧប្បជ្ជតីតិ ន ឧបេតិ ។
យាយ សញ្ញាយ តថាគតំ បញ្ញាបយមានោ បញ្ញា-
បេយ្យ សា សញ្ញា តថាគតស្ស បហីនា ឧច្ឆិន្នមូលា តា-
លាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា សញ្ញា
សង្ខាវិមុត្តោ ខោ វច្ឆ តថាគតោ គម្ភីរោ អប្បមេយ្យោ
ទុប្បរិយោគាឡ្ហោ ។ សេយ្យថាបិ មហាសមុទ្ទោ ឧប្បជ្ជ-
តីតិ ន ឧបេតិ ន ឧប្បជ្ជតីតិ ន ឧបេតិ ឧប្បជ្ជតិ ច



ក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយវេទនាណា
វេទនានោះ តថាគតលះបង់ហើយ កាត់ឫសគល់ហើយ ធ្វើឲ្យដូច
ជាត្នោតកំបុតហើយ ដល់នូវកិរិយាមិនមាន ជាវេទនាមានកិរិយាមិន
កើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាក
ចំណែកនៃវេទនា ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាប
ស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ ទើបថា កើតទៀតក៏មិនគួរ
ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតផង មិនកើតទៀតផងក៏មិនគួរ ថា
កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាល
បញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយសញ្ញាណា សញ្ញានោះតថាគតលះ
បង់ហើយ កាត់ឫសគល់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតហើយ ដល់
នូវកិរិយាមិនមាន ជាសញ្ញាមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាល
វច្ឆៈ តថាគតរួចស្រឡះហើយចាកចំណែកនៃសញ្ញា ជាអ្នកជ្រៅមាន
ប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហា-
សមុទ្រ ទើបថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើត

ន ច ឧបបជ្ជតីតិ ន ឧបេតិ នេវ ឧបបជ្ជតិ ន ន ឧបបជ្ជតីតិ ន ឧបេតិ ។ យេហិ សង្ខារេហិ តថាគតំ បញ្ញាបយមានោ បញ្ញាបេយ្យ តេ សង្ខារា តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា សង្ខារសង្ខាវិមុត្តោ ខោ វច្ឆ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ ។ សេយ្យថាបិ មហាសមុទ្ទោ ឧបបជ្ជតីតិ ន ឧបេតិ ន ឧបបជ្ជតីតិ ន ឧបេតិ ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ន ឧបេតិ នេវ ឧបបជ្ជតិ ន ន ឧបបជ្ជតីតិ ន ឧបេតិ ។ យេន វិញ្ញាណេន តថាគតំ បញ្ញាបយមានោ បញ្ញាបេយ្យ តំ វិញ្ញាណំ តថាគតស្ស បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ វិញ្ញាណសង្ខាវិមុត្តោ ខោ វច្ឆ តថាគតោ គម្ភីរោ អប្បមេយ្យោ ទុប្បរិយោគាឡ្ហោ ។ សេយ្យថាបិ មហាសមុទ្ទោ ឧបបជ្ជតីតិ ន ឧបេតិ



ទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ជាកើតទៀតក៏មិនមែន ជាមិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយសង្ខារទាំងឡាយណា សង្ខារទាំងឡាយនោះ តថាគតលះបង់ហើយ កាត់ឫសគល់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតហើយ ដល់នូវកិរិយាមិនមាន ជាសង្ខារមានកិរិយាមិនកើតទៀតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃសង្ខារ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថា កើតទៀតក៏មិនមែន ថា មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយវិញ្ញាណណា វិញ្ញាណនោះ តថាគត លះបង់ហើយ កាត់ឫសគល់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតហើយ ដល់នូវកិរិយាមិនមាន ជាវិញ្ញាណមានកិរិយាមិនកើតទៀតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃវិញ្ញាណ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថាកើតទៀតក៏មិនគួរ

ន ឧបបជ្ជតីតិ ន ឧបេតិ ឧបបជ្ជតិ ច ន ច ឧបបជ្ជតីតិ ន ឧបេតិ នេវ ឧបបជ្ជតិ ន ន ឧបបជ្ជតីតិ ន ឧបេតីតិ ។

(១៣) ឯវំ វុត្តេ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច សេយ្យថាបិ ភោ គោតម គាមស្ស វា និគមស្ស វា អវិទូរេ មហាសាលរុក្ខោ តស្ស អនិច្ចតា សាខាបលាសំ បលុជ្ជេយ្យ តចបបដិកា បលុជ្ជេយ្យុំ ផេគ្គុ បលុជ្ជេយ្យ សោ អបរេន សម-យេន អបគតសាខាបលាសោ អបគតតចបបដិកោ អបគតផេគ្គុកោ សុទ្ធោ សារេ(១) បតិដ្ឋិតោ ឯវមេវ(២) ភោតោ គោតមស្ស បាវចនំ អបគតសាខាបលាសំ អបគតតចបបដិកំ អបគតផេគ្គុកំ សុទ្ធំ(៣) សារេ បតិដ្ឋិតំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម

១ ម. សុទ្ធោ អស្ស សារេ ។ ២ ម. ឯវមេវ ខោ ។ ៣ ម. សុទ្ធំ ។



ថា មិនកើតទៀតក៏មិនគួរ ថា កើតទៀតខ្លះ មិនកើតទៀតខ្លះ ក៏មិនគួរ ថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មិនគួរ ។

(១៣) លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វច្ឆគោត្ត-បរិព្វាជក ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ដើមរាំងធំ (ដុះនៅ) ក្នុងទីជិតនៃស្រុកក្តី និគមក្តី មែកនិងស្លឹកនៃដើមរាំងធំនោះ ក៏រោសទៅដោយការមិនទៀង សំបកនិងក្រមរទាំងឡាយក៏រោសទៅ ស្រាយក៏រោសទៅ សម័យតទៅក្រោយមក ដើមរាំងធំនោះ ក៏ប្រាសចាកមែកនិងស្លឹក ប្រាសចាកសំបកនិងក្រមរ ប្រាសចាកស្រាយ ឋិតនៅតែខ្លឹមដ៏ស្អាត យ៉ាងណាមិញ ឯពាក្យជាប្រធាន (ធម្មវិន័យ) របស់ព្រះគោតមដ៏ចំរើន ក៏ប្រាសចាកមែកនិងស្លឹក ប្រាសចាកសំបកនិងក្រមរ ប្រាសចាកស្រាយ ឋិតនៅចំពោះខ្លឹមដ៏ស្អាតយ៉ាងនោះដែរ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន

និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

អគ្គិវច្ឆគោត្តសុត្តំ ទុតិយំ និដ្ឋិតំ ។

---



ធម៌ដែលព្រះគោតមដ៏ចំរើន ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយ យ៉ាងនេះ ដូចជាបុគ្គលផ្ងារវត្ថុដែលផ្កាប់ ឬបើកវត្ថុដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោល ប្រទីបក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានភ្នែក(ភ្លឺ) រមែងបានឃើញ រូបទាំងឡាយដូច្នោះដែរ ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមមានព្រះភាគ ព្រមទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើ ដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមរៀងទៅ ។

ចប់ អគ្គិវច្ឆគោត្តសូត្រ ទី ២ ។

---

## តតិយំ មហាវច្ឆគោត្តសុត្តំ

[១៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ វច្ឆគោត្តោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច ទីឃរត្តាហំ ភោតា គោតមេន សហកថី សាធុ មេ ភវំ គោតមោ សង្ខិត្តេន កុសលាកុសលំ ទេសេតុ ។ សង្ខិត្តេនបិ ខោ តេ អហំ វច្ឆ កុសលាកុសលំ ទេសេយ្យំ វិត្ថារេនបិ ខោ តេ អហំ វច្ឆ កុសលាកុសលំ ទេសេយ្យំ អបិច តេ អហំ វច្ឆ សង្ខិត្តេន កុសលាកុសលំ ទេសេស្សាមិ

## មហាវច្ឆគោត្តសូត្រ ទី ៣

[១៤] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះ វច្ឆគោត្តបរិព្វាជក បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរីករាយសំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ វច្ឆគោត្តបរិព្វាជក លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា ខ្ញុំព្រះអង្គបានចរចានិយាយជាមួយនឹងព្រះគោតមដ៏ចំរើន អស់កាលជាយូរអង្វែងមកហើយ សូមទ្រង់មេត្តាប្រោស សូមព្រះគោតមដ៏ចំរើនសំដែងកុសលធម៌នឹងអកុសលធម៌ដល់ខ្ញុំព្រះអង្គដោយសេចក្តីសង្ខេបចុះ ។ ម្នាលវច្ឆៈ តថាគតនឹងសំដែងកុសលធម៌នឹងអកុសលធម៌ ដល់អ្នកដោយសេចក្តីសង្ខេបបាន ម្នាលវច្ឆៈ តថាគត នឹងសំដែងកុសលធម៌នឹងអកុសលធម៌ ដល់អ្នកដោយសេចក្តីពិស្តារក៏បាន ម្នាលវច្ឆៈ បើដូច្នោះ តថាគតនឹងសំដែងកុសលធម៌នឹងអកុសលធម៌ដល់អ្នកដោយសេចក្តីសង្ខេប

តំ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សា-
មីតិ ។ ឯវំ ភោតិ ខោ វច្ឆគោត្តោ បរិព្វាជកោ
ភគវតោ បច្ចស្សោសិ ។

(១៨) ភគវា ឯតទវោច លោភោ ខោ វច្ឆ
អកុសលំ អលោភោ ខោ វច្ឆ[១] កុសលំ ទោសោ
ខោ វច្ឆ អកុសលំ អទោសោ ខោ វច្ឆ[២] កុសលំ
មោហោ ខោ វច្ឆ អកុសលំ អមោហោ ខោ វច្ឆ[៣]
កុសលំ ឥតិ ខោ វច្ឆ ឥមេ តយោ ធម្មា
អកុសលា តយោ ធម្មា កុសលា ។ បាណាតិ-
បាតោ ខោ វច្ឆ អកុសលំ បាណាតិបាតា វេរមណី
កុសលំ អទិន្នាទានំ ខោ វច្ឆ អកុសលំ អទិន្នា-
ទានា វេរមណី កុសលំ កាមេសុមិច្ឆាចារោ ខោ
វច្ឆ អកុសលំ កាមេសុមិច្ឆាចារា វេរមណី កុសលំ
មុសាវាទោ ខោ វច្ឆ អកុសលំ មុសាវាទា វេរមណី
កុសលំ បិសុណា វាចា ខោ វច្ឆ អកុសលំ បិសុ-
ណាយ វាចាយ វេរមណី កុសលំ ផរុសា វាចា ខោ
វច្ឆ អកុសលំ ផរុសាយ វាចាយ វេរមណី កុសលំ

១.២.៣ ម.ម. ខោ វច្ឆាតិ ន ទិស្សតិ ។



ចូរអ្នកយកចិត្តទុកដាក់ស្តាប់នូវធម៌នោះដោយប្រពៃចុះ តថាគតនឹងសំដែង ។
វច្ឆគោត្តបរិព្វាជក ក៏បានទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា
បពិត្រព្រះគោតមដ៏ចំរើន ព្រះករុណា ព្រះអង្គ ។

[១៨] ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលវច្ឆៈ លោភៈ
ជាអកុសល ម្នាលវច្ឆៈ អលោភៈជាកុសល ម្នាលវច្ឆៈ ទោសៈជា
អកុសល ម្នាលវច្ឆៈ អទោសៈជាកុសល ម្នាលវច្ឆៈ មោហៈជាអកុសល
ម្នាលវច្ឆៈ អមោហៈជាកុសល ម្នាលវច្ឆៈ ធម៌ទាំងអម្បាលនេះ ជា
អកុសល ៣ ជាកុសល ៣ ដោយប្រការដូច្នេះ ។ ម្នាលវច្ឆៈ បាណា-
តិបាត ជាអកុសល ការវៀរចាកបាណាតិបាត ជាកុសល ម្នាលវច្ឆៈ
អទិន្នាទាន ជាអកុសល ការវៀរចាកអទិន្នាទាន ជាកុសល ម្នាលវច្ឆៈ
កាមេសុមិច្ឆាចារ ជាអកុសល ការវៀរចាកកាមេសុមិច្ឆាចារ ជាកុសល
ម្នាលវច្ឆៈ មុសាវាទ ជាអកុសល ការវៀរចាកមុសាវាទ ជាកុសល ម្នាល
វច្ឆៈ បិសុណាវាចា ជាអកុសល ការវៀរចាកបិសុណាវាចា ជាកុសល
ម្នាលវច្ឆៈ ផរុសវាចា ជាអកុសល ការវៀរចាកផរុសវាចា ជាកុសល

សម្ផប្បលាបោ ខោ វច្ឆ អកុសលំ សម្ផប្បលាបា វេរមណី កុសលំ អភិជ្ឈា ខោ វច្ឆ អកុសលំ អនភិជ្ឈា កុសលំ ព្យាបាទោ ខោ វច្ឆ អកុសលំ អព្យាបាទោ កុសលំ មិច្ឆាទិដ្ឋិ ខោ វច្ឆ អកុសលំ សម្មាទិដ្ឋិ កុសលំ ឥតិ ខោ វច្ឆ ឥមេ ទស ធម្មា អកុសលា ទស ធម្មា កុសលា ។ យតោ ខោ វច្ឆ ភិក្ខុនោ តណ្ហា បហីនា ហោតិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតិំ អនុប្បាទធម្មា ហោតិ សោ (១) ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ··· ឱហិតភារោ ··· អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោតិ ។

១ ម. ឆ. សោ ហោតិ ។



ម្នាលវច្ឆៈ សម្ផប្បលាបៈ ជាអកុសល ការវៀរចាកសម្ផប្បលាបៈ ជាកុសល ម្នាលវច្ឆៈ អភិជ្ឈា ជាអកុសល អនភិជ្ឈា ជាកុសល ម្នាលវច្ឆៈ ព្យាបាទ ជាអកុសល ការមិនព្យាបាទ ជាកុសល ម្នាលវច្ឆៈ មិច្ឆាទិដ្ឋិ ជាអកុសល សម្មាទិដ្ឋិ ជាកុសល ម្នាលវច្ឆៈ ធម៌ទាំងឡាយនេះ ជាអកុសល ១០ ជាកុសល ១០ ដោយប្រការដូច្នេះឯង ។ ម្នាលវច្ឆៈ កាលបើភិក្ខុបានលះបង់តណ្ហា បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោតដែលគេកាត់ក្រឡែលរលីង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ភិក្ខុនោះឈ្មោះថា ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយធម៌បាននៅចប់ហើយ មានកិច្ចដែលគួរធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់សព្វគ្រប់ហើយ មានសំយោជនៈដែលប្រព្រឹត្តទៅក្នុងភពអស់ហើយ ជាអ្នកដឹងច្បាស់ដោយប្រពៃ ជាអ្នកមានចិត្តផុតស្រឡះចាកកិលេស ។

[១៦] តិដ្ឋតុ ភវំ គោតមោ អត្ថិ បន ភោតោ គោតមស្ស ឯកភិក្ខុ(១) សាវកោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោ(២) វ យេ ភិក្ខូ មម សាវកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។ តិដ្ឋតុ ភវំ គោតមោ តិដ្ឋន្តុ ភិក្ខូ អត្ថិ បន ភោតោ គោតមស្ស ឯកភិក្ខុនីបិ សាវិកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ

១ ឱ. ម. ឯកភិក្ខុបិ ។ ២ ឱ. ម. អថខោ ភិយ្យោ [illegible] ទិស្សតិ ។



[១៦] វច្ឆគោត្តបរិព្វាជក ក្រាបបង្គំទូលថា ព្រះគោតមដ៏ចំរើន លើកទុកចុះ ចុះភិក្ខុមួយរូបជាសាវ័ករបស់ព្រះគោតមដ៏ចំរើន បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០,២០០,៣០០,៤០០,៥០០ ទេ ម្នាលវច្ឆៈ តាមពិត មានច្រើនលើសប្រមាណណាស់ ពួកភិក្ខុជាសាវ័ករបស់តថាគត ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រះគោតមដ៏ចំរើន លើកទុកចុះ ទាំងពួកភិក្ខុក៏លើកទុកចុះ ចុះភិក្ខុនីមួយរូបដែលជាសាវិការបស់ព្រះគោតមដ៏ចំរើន បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដ៏មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០,២០០,៣០០,៤០០,៥០០ ទេ

អថខោ ភិយ្យោវ យេ ភិក្ខុនិយោ មម សាវិកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

(១៧) តិដ្ឋតុ ភវំ គោតមោ តិដ្ឋន្តុ ភិក្ខូ តិដ្ឋន្តុ ភិក្ខុនិយោ អត្ថិ បន ភោតោ គោតមស្ស ឯកុបាសកោបិ សាវកោ គិហី ឱទាតវសនោ ព្រហ្មចារី(១) បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្ពាយី អនាវត្តិធម្មោ តស្មា លោកាតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោវ យេ ឧបាសកា មម សាវកា គិហី ឱទាតវសនា ព្រហ្មចារិនោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្ពាយិនោ អនាវត្តិធម្មា តស្មា លោកាតិ ។ តិដ្ឋតុ ភវំ គោតមោ តិដ្ឋន្តុ ភិក្ខូ តិដ្ឋន្តុ ភិក្ខុនិយោ តិដ្ឋន្តុ

១ ឱ. ម. ព្រហ្មចារី ។



តាមពិត មានច្រើនលើសប្រមាណណាស់ ពួកភិក្ខុនីដែលជាសាវិការបស់តថាគត បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

(១៧) ព្រះគោតមដ៏ចំរើន លើកទុកចុះ ទាំងពួកភិក្ខុភិក្ខុនីក៏លើកទុកដែរ ចុះគ្រហស្ថជាឧបាសកម្នាក់ ដែលជាសាវ័ករបស់ព្រះគោតមដ៏ចំរើន ស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល ជាឱបបាតិកៈកំណើត និព្វានក្នុងទីនោះ មិនបានត្រឡប់ចាកលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈជាចំណែកខាងក្រោម ៥ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០, ទេ តាមពិត មានច្រើនលើសប្រមាណណាស់ ពួកគ្រហស្ថ ដែលជាឧបាសក ជាសាវ័ករបស់តថាគត ស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល ជាឱបបាតិកៈកំណើតនិព្វានក្នុងទីនោះ មិនបានត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈដែលជាចំណែកខាងក្រោម ៥ ។ ព្រះគោតមដ៏ចំរើន សូមលើកទុកចុះ ពួកភិក្ខុ ភិក្ខុនី ក៏លើកទុកចុះ

ឧបាសកា គិហី ឱទាតវសនា សព្រហ្មចារិនោ អត្ថិ បន ភោតោ គោតមស្ស ឯកូបាសកោបិ សាវកោ គិហី ឱទាតវសនោ កាមភោគី សាសនករោ ឱវាទប្បដិករោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ វិហរតីតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោវ យេ ឧបាសកា មម សាវកា គិហី ឱទាតវសនា កាមភោគិនោ សាសនករា ឱវាទប្បដិករា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិហរន្តីតិ ។ តិដ្ឋតុ ភវំ គោតមោ តិដ្ឋន្តុ ភិក្ខូ តិដ្ឋន្តុ ភិក្ខុនិយោ តិដ្ឋន្តុ ឧបាសកា គិហី ឱទាតវសនា សព្រហ្មចារិនោ តិដ្ឋន្តុ ឧបាសកា គិហី ឱទាតវសនា កាមភោគិនោ អត្ថិ បន ភោតោ គោតមស្ស ឯកុបាសិកាបិ សាវិកា គិហិនី ឱទាតវសនា សព្រហ្មចារិនី



ទាំងពួកគ្រហស្ថ ជាឧបាសក ស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គលក៏លើកទុកផង ចុះគ្រហស្ថជាឧបាសកម្នាក់ ដែលជាសាវ័ករបស់ព្រះគោតមដ៏ចំរើន ស្លៀកសំពត់ស ជាអ្នកបរិភោគកាម តែជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីពោលថាអ្វីៗ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ទេ តាមពិត មានច្រើនលើសប្រមាណណាស់ ពួកគ្រហស្ថដែលជាឧបាសក ជាសាវ័ករបស់តថាគត ស្លៀកសំពត់សនៅបរិភោគកាម តែជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីពោលថាអ្វីៗ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ។ ព្រះគោតមដ៏ចំរើន សូមលើកទុកចុះ ពួកភិក្ខុភិក្ខុនីក៏លើកទុកចុះ ពួកគ្រហស្ថដែលជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គលក៏លើកទុកចុះ ទាំងពួកគ្រហស្ថដែលជាឧបាសកស្លៀកពាក់ស នៅបរិភោគកាមក៏លើកទុកផង ចុះគ្រហស្ថជាឧបាសិកាម្នាក់ ដែលជាសាវិការបស់ព្រះគោតមដ៏ចំរើន ស្លៀកសំពត់ស ជាសព្រហ្មចារិនី

បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនី អនាវត្តិធម្មា តស្មា លោកាតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថ ខោ ភិយ្យោវ យា ឧបាសិកា មម សាវិកា គិហី ឱទាតវសនា សព្រហ្មចារិនិយោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនិយោ អនាវត្តិធម្មា តស្មា លោកាតិ ។ តិដ្ឋតុ ភវំ គោតមោ តិដ្ឋន្តុ ភិក្ខូ តិដ្ឋន្តុ ភិក្ខុនិយោ តិដ្ឋន្តុ ឧបាសកា គិហី ឱទាតវសនា សព្រហ្មចារិនោ តិដ្ឋន្តុ ឧបាសកា គិហី ឱទាតវសនា កាមភោគិនោ តិដ្ឋន្តុ ឧបាសិកា គិហី ឱទាតវសនា សព្រហ្មចារិនិយោ អត្ថិ បន ភោតោ គោតមស្ស ឯកុបាសិកាបិ សាវិកា គិហី ឱទាតវសនា កាមភោគិនី សាសនករា ឱវាទប្បដិករា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា



ជាឱបបាតិកៈកំណើតទីនីបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ទេ តាមពិត មានច្រើនលើសប្រមាណណាស់ គ្រហស្ថដែលជាឧបាសិកា ជាសាវិការបស់តថាគត ស្លៀកដណ្ដប់ស ជាសព្រហ្មចារិនី ជាឱបបាតិកៈកំណើតទីនីបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈជាចំណែកខាងក្រោម ៥ ។ ព្រះគោតមដ៏ចំរើន សូមលើកទុកចុះ ពួកភិក្ខុភិក្ខុនីក៏លើកទុកចុះ ពួកគ្រហស្ថដែលជាឧបាសក ស្លៀកដណ្ដប់ស ជាសព្រហ្មចារីបុគ្គលក៏លើកទុកចុះ ពួកគ្រហស្ថដែលជាឧបាសក ស្លៀកដណ្ដប់ស ជាអ្នកបរិភោគកាមក៏លើកទុកចុះ ទាំងពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្ដប់ស ជាសព្រហ្មចារិនីក៏លើកទុកដែរ ចុះគ្រហស្ថជាឧបាសិកាម្នាក់ ដែលជាសាវិការបស់ព្រះគោតមដ៏ចំរើន ស្លៀកដណ្ដប់សនៅបរិភោគកាម ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ជាអ្នកធ្វើតាមឱវាទ ឆ្លងផុតសេចក្ដីសង្ស័យ ប្រាសចាកសេចក្ដីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្ដាប់បុគ្គលដទៃ

សត្ថុ សាសនេ វិហរន្តីតិ ។ ន ខោ វច្ឆ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោវ យេ ឧបាសិកា មម សាវិកា គិហី ឱទាតវសនា កាមភោគិនិយោ សាសនករា ឱវាទប្បដិករា តិណ្ណវិចិកិច្ឆា វិគតកថំកថា វេសារជ្ជប្បត្តា អបរប្បច្ចយា សត្ថុ សាសនេ វិហរន្តីតិ ។

[១៨] សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវំយេវ គោតមោ អារាធកោ អភវិស្ស នោ ច ខោ ភិក្ខូ អារាធកា អភវិស្សុ ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ តេនង្គេន ។ សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ អភវិស្ស ភិក្ខូ ច អារាធកា អភវិស្សុំសុ នោ ច ខោ ភិក្ខុនិយោ អារាធិកា អភវិស្សុ



គង់សាសនារបស់ព្រះសាស្តា មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០, ២០០, ៣០០, ៤០០, ៥០០ ទេ តាមពិត មានច្រើនលើសប្រមាណណាស់ ពួកគ្រហស្ថ ដែលជាឧបាសិកា ជាសាវិការបស់តថាគត ស្លៀកសំពត់ស នៅបរិភោគកាម ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ប្រាសចាកសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ គង់សាសនារបស់ព្រះសាស្តា ។

[១៨] វច្ឆគោត្តបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន នឹងបំពេញធម៌នេះ តែមួយអង្គឯង ចំណែកខាងពួកភិក្ខុ មិនបានបំពេញ (ធម៌នេះ) ផងទេ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចំរើន លុះតែព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ (ធម៌នេះ) ដែរ កាលបើយ៉ាងនេះ ទើបព្រហ្មចរិយធម៌នេះ បរិបូណ៌ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន នឹងបំពេញធម៌នេះ តែមួយព្រះអង្គឯង ចំណែកខាងពួកភិក្ខុក៏បានបំពេញដែរ តែពួកភិក្ខុនីមិនបានបំពេញផងទេ

ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ភិក្ខុនិយោ ច អារាធិកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ តេនង្គេន ។

(១៩) សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ អភវិស្ស ភិក្ខូ ច អារាធកា អភវិស្សំសុ ភិក្ខុនិយោ ច អារាធិកា អភវិស្សំសុ នោ ច ខោ ឧបាសកា គិហី ឱទាតវសនា សព្រហ្មចារិនោ អារាធកា អភវិស្សំសុ ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ភិក្ខុនិយោ ច អារាធិកា ឧបាសកា ច គិហី ឱទាតវសនា សព្រហ្មចារិនោ អារាធកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ



កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ក៏នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចំរើន ព្រោះតែព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ ទាំងពួកភិក្ខុនីក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។

(១៩) បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន នឹងបានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ ទាំងពួកភិក្ខុនីក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល មិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចំរើន ព្រោះតែព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌

តេនង្គេន ។ សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ អភវិស្ស ភិក្ខូ ច អារាធកា អភវិស្សំសុ ភិក្ខុនិយោ ច អារាធិកា អភវិស្សំសុ ឧបាសកា ច គិហី ឱទាតវសនា សព្រហ្មចារិនោ អារាធកា អភវិស្សំសុ នោ ច ខោ ឧបាសកា គិហី ឱទាតវសនា កាមភោគិនោ អារាធកា អភវិស្សំសុ ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ភិក្ខុនិយោ ច អារាធិកា ឧបាសកា ច គិហី ឱទាតវសនា សព្រហ្មចារិនោ អារាធកា ឧបាសកា ច គិហី ឱទាតវសនា កាមភោគិនោ អារាធកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ តេនង្គេន ។ សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ អភវិស្ស ភិក្ខូ ច អារាធកា អភវិស្សំសុ ភិក្ខុនិយោ ច អារាធិកា អភវិស្សំសុ ឧបាសកា ច គិហី ឱទាតវសនា សព្រហ្មចារិនោ



ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន នឹងបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថ ដែលជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គលក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស នៅបរិភោគកាមមិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចំរើន លុះតែព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គលក៏បានបំពេញ ទាំងពួកគ្រហស្ថ ជាឧបាសកស្លៀកសំពត់ស ជាអ្នកបរិភោគកាម ក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល

អារាធកា អភវិស្សំសុ ឧបាសកា ច គិហី ឱទាតវសនា កាមភោគិនោ អារាធកា អភវិស្សំសុ នោ ច ខោ ឧបាសិកា គិហី ឱទាតវសនា សព្រហ្មចារិនិយោ អារាធិកា អភវិស្សំសុ ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ភិក្ខុនិយោ ច អារាធិកា ឧបាសកា ច គិហី ឱទាតវសនា សព្រហ្មចារិនោ អារាធកា ឧបាសកា ច គិហី ឱទាតវសនា កាមភោគិនោ អារាធកា ឧបាសិកា ច គិហី ឱទាតវសនា សព្រហ្មចារិនិយោ អារាធិកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ តេនង្គេន ។ សចេ ហិ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ អភវិស្ស ភិក្ខូ ច អារាធកា អភវិស្សំសុ ភិក្ខុនិយោ ច អារាធិកា អភវិស្សំសុ



កំពុងបំពេញ ចំណែកពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ទៅបរិភោគកាម ក៏បានបំពេញ តែពួកគ្រហស្ថ ជាឧបាសិកាស្លៀកសំពត់ស ជាសព្រហ្មចារិនីមិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចំរើន លុះតែព្រះគោតមដ៏ចំរើន ក៏បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកសំពត់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ ពួកគ្រហស្ថ ជាឧបាសកស្លៀកសំពត់ស ទៅបរិភោគកាម ក៏បានបំពេញ ចំណែកពួកគ្រហស្ថ ជាឧបាសិកាស្លៀកសំពត់ស ជាសព្រហ្មចារិនីក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើព្រះគោតមដ៏ចំរើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បំពេញ ពួកភិក្ខុនីក៏បំពេញ

ឧបាសកា ច គិហី ឱទាតវសនា ព្រហ្មចារិនោ អារាធកា អភវិស្សំសុ ឧបាសកា ច គិហី ឱទាតវសនា កាមភោគិនោ អារាធកា អភវិស្សំសុ ឧបាសិកា ច គិហិនិយោ ឱទាតវសនា ព្រហ្មចារិនិយោ អារាធិកា អភវិស្សំសុ នោ ច ខោ ឧបាសិកា គិហិនិយោ ឱទាតវសនា កាមភោគិនិយោ អារាធិកា អភវិស្សំសុ ឯវមិទំ ព្រហ្មចរិយំ អបរិបូរំ អភវិស្ស តេនង្គេន យស្មា ច ខោ ភោ គោតម ឥមំ ធម្មំ ភវញ្ចេវ គោតមោ អារាធកោ ភិក្ខូ ច អារាធកា ភិក្ខុនិយោ ច អារាធិកា ឧបាសកា ច គិហី ឱទាតវសនា ព្រហ្មចារិនោ អារាធកា ឧបាសកា ច គិហី ឱទាតវសនា កាមភោគិនោ អារាធកា ឧបាសិកា ច គិហិនិយោ ឱទាតវសនា ព្រហ្មចារិនិយោ អារាធិកា ឧបាសិកា ច គិហិនិយោ ឱទាតវសនា កាមភោគិនិយោ អារាធិកា ឯវមិទំ ព្រហ្មចរិយំ បរិបូរំ តេនង្គេន ។



ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាព្រហ្មចារីបុគ្គល ក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាមក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស ជាព្រហ្មចារិនីក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស ជាអ្នកនៅបរិភោគកាម មិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះមិនបានបរិបូណ៌ដោយអង្គនោះទេ បពិត្រព្រះគោតមដ៏ចំរើន ព្រោះតែព្រះគោតមដ៏ចំរើន ក៏បំពេញធម៌នេះ ពួកភិក្ខុក៏បំពេញ ពួកភិក្ខុនីក៏បំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាព្រហ្មចារីបុគ្គល ក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាម ក៏បានបំពេញ ពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស ជាព្រហ្មចារិនីក៏បានបំពេញទាំងពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស នៅបរិភោគកាមក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។

[៦០] សេយ្យថាបិ ភោ គោតម គង្គា នទី សមុទ្ទនិន្នា សមុទ្ទបោណា សមុទ្ទបព្ភារា សមុទ្ទំ អាហច្ច តិដ្ឋតិ ឯវមេវាយំ ភោតោ គោតមស្ស បរិសា សគហដ្ឋបព្វជិតា និព្វាននិន្នា និព្វានបោណា និព្វានបព្ភារា និព្វានំ អាហច្ច តិដ្ឋតិ ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ[១] ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ វច្ឆ អញ្ញតិត្ថិយបុព្វោ

១ ម. [illegible] ឯវមេវ ។



[៦០] បពិត្រព្រះគោតមដ៏ចំរើន ដូចទន្លេគង្គា រមែងមានទំនាបទៅរកសមុទ្រ មានទីជ្រាលទៅរកសមុទ្រ មានទីទេរទៅរកសមុទ្រ ដល់នឹងសមុទ្រទើបឈប់នៅ (យ៉ាងណា) បរិស័ទរបស់ព្រះគោតមដ៏ចំរើននេះ ព្រមទាំងគ្រហស្ថនិងបព្វជិត រមែងមានទំនាបទៅរកព្រះនិព្វាន មានទីជ្រាលទៅរកព្រះនិព្វាន មានទីទេរទៅរកព្រះនិព្វាន ដរាបដល់នឹងព្រះនិព្វានទើបឈប់បង្អង់ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ធម៌ដែលព្រះគោតមដ៏ចំរើនប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាបុគ្គលផ្ងារនូវរបស់ដែលគេផ្កាប់ចុះ ឬបើកនូវរបស់ដែលគេបិទបាំងទុក ពុំនោះដូចជាគេប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែកភ្លឺ រមែងឃើញរូបទាំងឡាយគង់ដូច្នោះដែរ ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះគោតមផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជានិងឧបសម្បទា ក្នុងសំណាក់នៃព្រះគោតមដ៏ចំរើន ។ ម្នាលវច្ឆៈ បុគ្គលណាដែលធ្លាប់ជាអន្យតិរ្ថិយមកពីមុនហើយ

ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ អបិច មេត្ថ(១) បុគ្គលវេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វា ឥមស្មឹ ធម្មវិនយេ អាកង្ខន្តិ បព្វជ្ជំ អាកង្ខន្តិ ឧបសម្បទំ ចត្តារោ មាសេ បរិវសន្តុ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវាយ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវាយាតិ ។ អលត្ថ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។

(៦១) អចិរូបសម្បន្នោ ខោ បនាយស្មា វច្ឆគោត្តោ អឌ្ឍមាសូបសម្បន្នោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

១ ឱ. ម. ឈ្ល ។



ប្រាថ្នាបព្វជ្ជា ឧបសម្បទា ក្នុងធម្មវិន័យនេះ បុគ្គលនោះ ត្រូវនៅបរិវាសអស់ ៤ ខែសិន លុះកន្លង ៤ ខែទៅ ទើបពួកភិក្ខុដែលមានចិត្តត្រេកអរហើយ ក៏ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បីជាភិក្ខុភាព មួយទៀត ភាពផ្សេងគ្នានៃបុគ្គល (ការដែលនៅបរិវាសឬមិនត្រូវនៅបរិវាស) ក្នុងដំណើរនេះ តថាគតដឹងច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើពួកជនដែលធ្លាប់ជាអន្យតិរ្ថិយមកអំពីមុនហើយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ ត្រូវតែនៅបរិវាសអស់ ៤ ខែសិន លុះកន្លង ៤ ខែទៅ ទើបពួកភិក្ខុដែលមានចិត្តត្រេកអរហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីជាភិក្ខុភាពបាន ខ្ញុំព្រះអង្គនឹងនៅបរិវាសអស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមឲ្យពួកភិក្ខុដែលមានចិត្តត្រេកអរហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីជាភិក្ខុភាពចុះ ។ វច្ឆគោត្តបរិព្វាជក ក៏បាននូវបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់ នៃព្រះមានព្រះភាគ ។

(៦១) ព្រះវច្ឆគោត្តមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន គឺបានឧបសម្បទាកន្លះខែ (ប៉ុណ្ណោះ) ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អា-
យស្មា វច្ឆគោត្តោ ភគវន្តំ ឯតទវោច យាវតកំ ភន្តេ
សេក្ខេន ញាណេន សេក្ខាយ វិជ្ជាយ បត្តព្វំ
អនុប្បត្តំ មយា(១) ឧត្តរិ មេ(២) ភគវា ធម្មំ
ទេសេតូតិ ។ តេនហិ ត្វំ វច្ឆ ទ្វេ ធម្មេ ឧត្តរិ
ភាវេហិ សមថញ្ច វិបស្សនញ្ច ឥមេ ខោ តេ វច្ឆ ទ្វេ
ធម្មា ឧត្តរិ ភាវិតា សមថោ ច វិបស្សនា ច
អនេកធាតុប្បដិវេធាយ សំវត្តិស្សន្តិ ។

(៦៦) សោ ត្វំ វច្ឆ យាវទេ អាកង្ខិស្សសិ
អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ឯកោបិ ហុត្វា
ពហុធា អស្សំ ពហុធាបិ ហុត្វា ឯកោ អស្សំ
អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ
អសជ្ជមានោ គច្ឆេយ្យំ សេយ្យថាបិ អាកាសេ
បថវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករេយ្យំ សេយ្យថាបិ ឧទកេ
ឧទកេបិ អភិជ្ជមានេ គច្ឆេយ្យំ សេយ្យថាបិ
បថវិយំ អាកាសេបិ បល្លង្កេន សង្កមេយ្យំ

១ ម. ម. អនុប្បត្តំ តំ មយា ។ ២ ម. ឧត្តរិ ច មេ ។



អង្គុយនៅក្នុងទីដ៏សមគួរ ។ វច្ឆគោត្តមានអាយុ លុះអង្គុយក្នុងទីដ៏សម-
គួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រ
ព្រះអង្គដ៏ចំរើន សាមញ្ញផល មានប្រមាណប៉ុន្មាន ដែលបុគ្គលគប្បី
ដល់ ដោយញាណជារបស់សេក្ខបុគ្គល ដោយវិជ្ជាជារបស់សេក្ខបុគ្គល
គឺអនាគាមិមគ្គ ខ្ញុំព្រះអង្គដល់ហើយដោយលំដាប់ សូមព្រះមានព្រះ
ភាគ ទ្រង់សំដែងនូវធម៌ឲ្យខ្ពស់ឡើងទៅ (ដើម្បីអរហត្តផល) ដល់ខ្ញុំ
ព្រះអង្គ ។ ម្នាលវច្ឆៈ បើដូច្នោះអ្នកចូរចំរើនធម៌ ២ ប្រការគឺ សមថៈ
និងវិបស្សនាឲ្យខ្ពស់ឡើងទៅចុះ ម្នាលវច្ឆៈ ធម៌ទាំង ២ ប្រការនេះ គឺ
សមថៈនិងវិបស្សនា ដែលអ្នកចំរើនឲ្យខ្ពស់ឡើងហើយ នឹងប្រព្រឹត្តទៅ
ដើម្បីត្រាស់ដឹងនូវធាតុច្រើនប្រការ ។

(៦៦) ម្នាលវច្ឆៈ អ្នកនោះប្រាថ្នាដល់ទីប្រាថ្នាៗ គង់ត្រូវគប្បីបាន
នូវឫទ្ធិច្រើនប្រការ គឺជាមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏
បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ដើរទៅមិនជាប់
ជំពាក់នឹងទីវាល ខាងក្រៅ ខាងក្រៅជញ្ជាំង ខាងក្រៅកំពែង
និងខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការងើបឡើង
ប្រមុជចុះក្នុងផែនដី ដូចជាងើបឡើងប្រមុជចុះក្នុងទឹកក៏បាន ដើរលើទឹក
មិនបែកធ្លាយ ហាក់ដូចជាដើរលើផែនដីក៏បាន ទៅឯអាកាសទាំងពែន

សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសិស្សសិ បរិមជ្ជិស្សសិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេស្សសិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សសិ សតិ សតិ អាយតនេ ។

(៦៣) សោ ត្វំ វច្ឆ យាវទេ អាកង្ខិស្សសិ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុស-កាយ ឧភោ សទ្ទេ សុណេយ្យាសិ សេយ្យថីទំ(១) ទិព្វេ ច មានុសេ ច(២) យេ ទូរេ សន្តិកេ ចាតិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សសិ សតិ សតិ អាយតនេ ។

(៦៤) សោ ត្វំ វច្ឆ យាវទេ អាកង្ខិស្សសិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានេយ្យ

១ ឱ. ម. សេយ្យថីទំ ន ទិស្សតិ ។ ២ ឱ. ម. [illegible] ។



ដូចជាសត្វសកុណជាតិដែលមានស្លាបក៏បាន អាត្មាអញគប្បីស្ទាបអង្អែល ចាប់ពាល់ (មណ្ឌល) ព្រះចន្ទ្រព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះដោយដៃក៏បាន ឬអាត្មាអញគប្បីប្រព្រឹត្តទៅ ទាំងកាយ រហូតដល់ព្រហ្មលោកដោយកាយក៏បាន ។ កាលបើមានហេតុ អ្នកនឹងសម្រេចវិធីជាគ្រឿងសំដែងឫទ្ធិ ជាគុណសម្បត្តិ ដែលត្រូវស័ក្តិក្នុងសមថៈ នឹងវិបស្សនានោះៗ ជាប្រាកដ ។

(៦៣) ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីឮសំឡេងទាំងពីរ ដោយសោតធាតុដ៏បរិសុទ្ធ ដូចជាទិព្វ កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតា សំឡេងទាំងពីរនោះគឺអ្វីះ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលនៅក្នុងទីឆ្ងាយក្តី ទីជិតក្តី ។ កាលបើមានហេតុ អ្នកនឹងសម្រេចទិព្វសោត ជាគុណសម្បត្តិដែលត្រូវស័ក្តិក្នុងសមថៈនឹងវិបស្សនានោះៗ ជាប្រាកដ ។

(៦៤) ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីកំណត់ដឹងនូវចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន គឺចិត្ត (របស់សត្វដទៃ) ដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ

វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានេយ្យំ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានេយ្យំ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានេយ្យំ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានេយ្យំ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានេយ្យំ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានេយ្យំ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានេយ្យំ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានេយ្យំ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានេយ្យំ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានេយ្យំ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានេយ្យំ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានេយ្យំ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានេយ្យំ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានេយ្យំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សសិ សតិ សតិ អាយតនេ ។



ចិត្តដែលប្រាសចាករាគៈ ក៏ដឹងថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលមានអារម្មណ៍មូល ក៏ដឹងច្បាស់ថា ចិត្តមានអារម្មណ៍មូល ចិត្តដែលរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈគឺរូបាវចរៈនិងអរូបាវចរចិត្ត ចិត្តដែលមិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈគឺលោកិយចិត្ត ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈគឺលោកុត្តរចិត្ត ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងនៅស៊ប់ដោយសមាធិ ក៏ដឹងច្បាស់ថា ចិត្តតាំងនៅស៊ប់ដោយសមាធិ ចិត្តដែលមិនតាំងនៅស៊ប់ដោយសមាធិ ក៏ដឹងថាចិត្តមិនតាំងនៅស៊ប់ដោយសមាធិ ចិត្តដែលរួចចាកកិលេស ក៏ដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តដែលមិនបានរួចចាកកិលេស ក៏ដឹងច្បាស់ថា ចិត្តមិនបានរួចចាកកិលេសផុតទេ ។ កាលបើមានហេតុ អ្នកនឹងសម្រេចបរចិត្តវិជ្ជា ជាគុណសម្បត្តិដែលត្រូវសិក្សា គឺសមថៈនិងវិបស្សនា នោះ ៗ ជាប្រាកដ ។

(៤៥) សោ ខ្វំ វច្ឆ យាវទេវ អាកង្ខេយ្យ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាលីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខ-ទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ



(៤៥) ម្នាលវច្ឆៈ អ្នកនោះប្រាកដជាទីទ្រព្យជាក់ អាត្មាអញគប្បីរលឹកឃើញខន្ធបុព្វេនិវាស គឺលំនៅចំនួនដែលសត្វនៅអាស្រ័យមានរបៀបដ៏ច្រើនប្រការ រលឹកខន្ធនោះដូចម្តេចខ្លះ គឺរលឹកបាន ១ជាតិ ២ជាតិ ៣ជាតិ ៤ជាតិ ៥ជាតិ ១០ជាតិ ២០ជាតិ ៣០ជាតិ ៤០ជាតិ ៥០ជាតិ ១០០ជាតិ ១.០០០ជាតិ ១០០.០០០ជាតិ រលឹកនូវសំវដ្តកប្បជាច្រើនក៏បាន វិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្បជាច្រើនក៏បាន ថាអាត្មាអញបាននៅកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏ទៅកើតក្នុងទីឯណោះ លុះអាត្មាអញបានកើតក្នុងទីនោះហើយ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបបាន

ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សតិ សតិ សតិ អាយតនេ ។

(៦៦) សោ ចេ វត យាវទេ អាកង្ខិស្សតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានេយ្យំ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ



មកកើតក្នុងទីនេះ អាត្មាអញគប្បីរលឹកឃើញ នូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ កាលបើមានហេតុ អ្នកនឹងសម្រេចញាណជាគ្រឿងដឹងនូវខន្ធដែលអាស្រ័យនៅហើយក្នុងកាលមុន ជាគុណសម្បត្តិត្រូវស័ក្តិក្នុងសមថៈនិងវិបស្សនា នោះៗ ជាប្រាកដ ។

(៦៦) ម្នាលវក្កៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីមានចក្ខុដូចជាទិព្វ កន្លងផុតវិស័យចក្ខុរបស់មនុស្សធម្មតា ឃើញនូវពួកសត្វ ដែលច្យុតដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ អាត្មាអញគប្បីដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មថា អើហ្ន៎ ពួកសត្វទាំងនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយបុគ្គល ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងអម្បាលនោះ លុះបែកធ្លាយកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកខាងពួកសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនចោទតិះដៀលនូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ ពួកសត្វទាំងនោះ

កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-មានុសកេន សត្តេ បស្សេយ្យាសិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានេយ្យាសីតិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សសិ សតិ សតិ អាយតនេ ។

(៦៧) សោ ខោ ត្វំ វច្ឆ យាវទេ អាកង្ខិស្សសិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាសីតិ ។ តត្រ តត្រេវ សក្ខិភព្វតំ បាបុណិស្សសិ សតិ សតិ អាយតនេ ។



លុះបែកកាយបន្ទាប់អំពីមរណៈទៅ ក៏បានទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ អាត្មាអញគប្បីមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ អាត្មាអញគប្បីដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ដោយប្រការដូច្នេះ ។ កាលបើមានហេតុ អ្នកនឹងសម្រេចទិព្វ-ចក្ខុញាណ ជាគុណសម្បត្តិដែលគួរសិក្សា ក្នុងសមថៈនិងវិបស្សនានោះ ៗ ជាប្រាកដ ។

(៦៧) ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះក្ស័យអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ ។ កាលបើមានហេតុ អ្នកនឹងសម្រេចនូវញាណ ក្នុងការអស់ទៅនៃអាសវៈ ជាគុណសម្បត្តិដែលគួរសិក្សា ក្នុងសមថៈនិងវិបស្សនានោះ ៗ ជាប្រាកដ ។

(៤៨) អថខោ អាយស្មា វច្ឆគោត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អាយស្មា វច្ឆគោត្តោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា វច្ឆគោត្តោ អរហតំ អហោសិ ។

(៤៩) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ភគវន្តំ ទស្សនាយ គច្ឆន្តិ ។ អទ្ទសា ខោ អាយស្មា វច្ឆគោត្តោ តេ ភិក្ខូ ទូរតោ វ គច្ឆន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្ក-



(៤៨) គ្រានោះ ព្រះវច្ឆគោត្តមានអាយុ ត្រេកអររីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ គ្រាកាលដែលព្រះវច្ឆគោត្តមានអាយុ ចៀសចេញទៅតែម្នាក់ឯង ក៏ជាអ្នកមិនមានប្រមាទ ព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មានក៏បានដឹងច្បាស់នូវគុណវិសេសដ៏ប្រសើរ ជាទីបំផុតនៃព្រហ្មចរិយៈធម៌ដែលពួកកុលបុត្រចេញចាកផ្ទះទៅបួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏ធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសនោះ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ទើបដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើក៏បានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានទៀយ ។ បណ្តាពួកព្រះអរហន្តទាំងឡាយ ព្រះវច្ឆគោត្តមានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។

(៤៩) សម័យនោះ ពួកភិក្ខុច្រើនរូប នាំគ្នាទៅគាល់ព្រះមានព្រះភាគ ។ វច្ឆគោត្តមានអាយុ បានឃើញពួកភិក្ខុទាំងនោះ កំពុងដើរទៅពីចម្ងាយ លុះឃើញហើយ ក៏ចូលទៅរកពួកភិក្ខុទាំងនោះ លុះចូល

មិត្វា តេ ភិក្ខូ ឯតទវោច ហន្ទ កហំ បន តុម្ហេ អាយស្មន្តោ គច្ឆថាតិ ។ ភគវន្តំ ខោ មយំ អាវុសោ ទស្សនាយ គច្ឆាមាតិ ។ តេនហាយស្មន្តោ មម វចនេន ភគវតោ បាទេ សិរសា វន្ទថ វច្ឆគោត្តោ ភន្តេ ភិក្ខុ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេថ បរិចិណ្ណោ មេ ភគវា បរិចិណ្ណោ មេ សុគតោតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ វច្ឆគោត្តស្ស បច្ចស្សោសុំ ។ អថខោ តេ ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ អាយស្មា ភន្តេ វច្ឆគោត្តោ ភគវតោ បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ បរិចិណ្ណោ មេ ភគវា បរិចិណ្ណោ មេ សុគតោតិ ។



ទៅដល់ហើយ បាននិយាយនឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ចុះលោកទាំងឡាយ នាំគ្នានិមន្តទៅក្នុងទីណា ។ ពួកភិក្ខុទាំងនោះក៏ប្រាប់ថា ម្នាលអាវុសោ យើងនឹងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ។ វច្ឆគោត្តភិក្ខុក៏បានផ្តាំថា បពិត្រលោកទាំងឡាយមានអាយុ បើដូច្នោះសូមលោកទាំងឡាយ ក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគ ដោយត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុឈ្មោះវច្ឆគោត្ត សូមក្រាបថ្វាយបង្គំព្រះបាទា ព្រះមានព្រះភាគដោយត្បូង វច្ឆគោត្តភិក្ខុក្រាបទូលយ៉ាងនេះថា ព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានបម្រើហើយ ព្រះសុគតខ្ញុំព្រះអង្គបានបម្រើហើយ ។ ពួកភិក្ខុទាំងនោះ ក៏បានទទួលពាក្យវច្ឆគោត្តភិក្ខុមានអាយុថា អើអាវុសោ ។ ទើបពួកភិក្ខុទាំងនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ពួកភិក្ខុទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន វច្ឆគោត្តមានអាយុ សូមក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយត្បូង ហើយក្រាបទូលយ៉ាងនេះទៀតថា ព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានបម្រើហើយ ព្រះសុគតខ្ញុំព្រះអង្គបានបម្រើហើយ ។

បរិព្វាជកវគ្គស្ស មហាវច្ឆគោត្តសុត្តំ វច្ឆគោត្តប្បសំសា

បុព្វេវ មេ ភិក្ខវេ វច្ឆគោត្តោ ភិក្ខុ ចេតសា ចេតោ បរិច្ច វិទិតោ តេវិជ្ជោ វច្ឆគោត្តោ ភិក្ខុ មហិទ្ធិកោ មហានុភាវោតិ ។ ទេវតាបិ មេ ឯតមត្ថំ អារោចេសុំ តេវិជ្ជោ ភន្តេ វច្ឆគោត្តោ ភិក្ខុ មហិទ្ធិកោ មហានុភាវោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាវច្ឆគោត្តសុត្តំ តតិយំ និដ្ឋិតំ ។

---



បរិព្វាជកវគ្គ មហាវច្ឆគោត្តសូត្រ ការស្រង់សរសើរវច្ឆគោត្តភិក្ខុ

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលពីមុនមិញ តថាគត បានកំណត់ដឹងចិត្តវច្ឆគោត្តភិក្ខុ ដោយចិត្តរបស់តថាគតថា វច្ឆគោត្តភិក្ខុ បានត្រៃវិជ្ជា ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ ទាំងពួក ទេវតាក៏បានក្រាបទូលសេចក្ដីនុ៎ះ ដល់តថាគតទៀតថា បពិត្រព្រះអង្គដ៏ចំរើន វច្ឆគោត្តភិក្ខុបានត្រៃវិជ្ជា ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ពួកភិក្ខុទាំង នោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ មហាវច្ឆគោត្តសូត្រ ទី ៣ ។

## បត្តិ ទីឃនខសុត្តំ

(២០) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ សូករខតាយំ (១) ។ អថ ខោ ទីឃនខោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ ទីឃនខោ បរិព្វាជកោ ភគវន្តំ ឯតទវោច អហញ្ហិ ភោ គោតម ឯវំវាទី ឯវំទិដ្ឋិ សព្វំ មេ ន ខមតីតិ ។ យាបិ ខោ តេ ឯសា អគ្គិវេស្សន ទិដ្ឋិ សព្វំ មេ ន ខមតីតិ ឯសាបិ តេ ទិដ្ឋិ ន ខមតីតិ

១ សូករាខតាយន្តិ បត្ថកោ ។

## ទីឃនខសូត្រ ទី ៤

(២០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅ ក្នុងរោងឈ្មោះសូករខតា ជាប់នឹងភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ មានបរិព្វាជកម្នាក់ឈ្មោះទីឃនខៈ (ជាអគ្គិវេស្សនគោត្រ) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ពោលពាក្យរីករាយសំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ។ ទីឃនខបរិព្វាជក លុះឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញ (អាត្មាអញមិនពេញចិត្តទាំងអស់) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ សេចក្តីឃើញណារបស់អ្នកថា របស់ទាំងអស់មិនគួរដល់អាត្មាអញ សេចក្តីឃើញនុ៎ះមិនគួរដល់អ្នកទេ ។

ឯសា ចេ មេ ភោ គោតម ទិដ្ឋិ ខមេយ្យ តំបស្ស(១) តាទិសមេវ តំបស្ស(២) តាទិសមេវាតិ ។ អតោ ខោ តេ អគ្គិវេស្សន ពហូ ហិ ពហុតរា លោកស្មឹ យេ ឯវមាហំសុ តំបស្ស តាទិសមេវ តំបស្ស តាទិស-មេវាតិ តេ តញ្ចេវ ទិដ្ឋឹ នប្បជហន្តិ អញ្ញញ្ច ទិដ្ឋឹ ឧបាទិយន្តិ ។ អតោ ខោ តេ អគ្គិវេស្សន តនូ ហិ តនុតរា លោកស្មឹ យេ ឯវមាហំសុ តំបស្ស តាទិសមេវ តំបស្ស តាទិសមេវាតិ តេ តញ្ចេវ ទិដ្ឋឹ បជហន្តិ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយន្តិ ។

(៣១) សន្តិ អគ្គិវេស្សន(៣) ឯកេ សមណព្រាហ្ម-ណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ខមតីតិ ។ សន្តិ អគ្គិវេស្សន ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ន ខមតីតិ ។ សន្តិ អគ្គិវេស្សន ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ

---

១-២ ឱ. ម. តំបស្ស ។ ៣ ឱ. ម. សន្តិ អគ្គិវេស្សនាតិ ទិស្សតិ ។



បពិត្រព្រះគោតមដ៏ចំរើន ប្រសិនបើសេចក្តីយល់ឃើញនុ៎ះ គួរដល់ខ្ញុំ សោត ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ ពួកជនណាដែលនិយាយយ៉ាងនេះថា ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ពួកជនទាំងនោះក្នុងលោក មានច្រើនជាងនេះទៅទៀត តែពួកជនទាំងនោះមិនលះបង់ទិដ្ឋិនោះបាន ហើយគេប្រកាន់មាំចំពោះទិដ្ឋិដទៃទៅទៀត ។ ម្នាលអគ្គិវេស្សនៈ ពួកជនណានិយាយយ៉ាងនេះថា ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ទោះនោះណា ៗ ក៏ត្រូវឃើញដូច្នោះឯង ពួកជនទាំងនោះក្នុងលោក មានតិចតួចជាងនេះណាស់ តែពួកជនទាំងនោះលះបង់ទិដ្ឋិនោះបានផង មិនប្រកាន់ទិដ្ឋិដទៃទៅទៀតផង ។

(៣១) ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់គាប់អញ (គាប់អញពេញចិត្តទាំងអស់) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់គាប់អញ (គាប់អញមិនពេញចិត្តទាំងអស់) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាង

ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ ។ តត្រ អគ្គិវេស្សន យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ខមតីតិ តេសមយំ ទិដ្ឋិ សារាគាយ(១) សន្តិកេ សំយោគាយ សន្តិកេ អភិនន្ទនាយ សន្តិកេ អជ្ឈោសានាយ សន្តិកេ ឧបាទានាយ សន្តិកេតិ ។ តត្រ អគ្គិវេស្សន យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ន ខមតីតិ តេសមយំ ទិដ្ឋិ អសារាគាយ សន្តិកេ អសំយោគាយ សន្តិកេ អនភិនន្ទនាយ សន្តិកេ អនជ្ឈោសានាយ សន្តិកេ អនុបាទានាយ សន្តិកេតិ ។ ឯវំ វុត្តេ ទីឃនខោ បរិព្វាជកោ ភគវន្តំ ឯតទវោច ឧក្កំសេតិ(២) មេ ភវំ គោតមោ ទិដ្ឋិគតំ សមុក្កំសេតិ(៣) មេ ភវំ គោតមោ ទិដ្ឋិគតន្តិ ។ តត្រ អគ្គិវេស្សន

១ ឱ. ម. សារាគាយ ។ ២ ឱ. ឧក្កំសតិ ។ ៣ ឱ. សមុក្កំសតិ ។ ម. សម្បហំ-សតិ ។



នេះថា របស់ខ្លះគួរ ដល់អាត្មាអញ របស់ខ្លះមិនគួរ ដល់អាត្មាអញ (អាត្មាអញពេញចិត្តខ្លះ មិនពេញចិត្តខ្លះ) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញ ទិដ្ឋិនេះរបស់ពួកសមណព្រាហ្មណ៍នោះ តែងប្រព្រឹត្តទៅក្នុងទីជិត នៃហេតុដែលប្រកបដោយរាគៈ ក្នុងទីជិតនៃសំយោគៈ ក្នុងទីជិតនៃតម្រេក ក្នុងទីជិតនៃសេចក្ដីជាប់ចិត្ត ក្នុងទីជិតនៃសេចក្ដីប្រកាន់មាំ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរ ដល់អាត្មាអញ ទិដ្ឋិនេះរបស់ពួកសមណព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តទៅក្នុងទីជិត នៃហេតុមិនមែនរាគៈ ក្នុងទីជិតនៃហេតុមិនមែនជាសំយោគៈ ក្នុងទីជិតនៃហេតុមិនមែនជាតម្រេក ក្នុងទីជិតនៃសេចក្ដីមិនជាប់ចិត្ត ក្នុងទីជិតនៃសេចក្ដីមិនប្រកាន់មាំ ។ កាលដែលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ ទីឃនខបរិព្វាជក បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា ព្រះគោតមដ៏ចំរើន លើកតំកើងនូវសេចក្ដីឃើញរបស់ខ្ញុំព្រះអង្គ ព្រះគោតមដ៏ចំរើន ទ្រង់លើកតំកើងនូវសេចក្ដីឃើញរបស់ខ្ញុំព្រះអង្គ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ

យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ យា ហិ តេសំ[១] ខមតិ សាយំ ទិដ្ឋិ សារាគាយ សន្តិកេ សំយោគាយ សន្តិកេ អភិនន្ទនាយ សន្តិកេ អជ្ឈោសានាយ សន្តិកេ ឧបាទានាយ សន្តិកេ យា ហិ តេសំ ន ខមតិ សាយំ ទិដ្ឋិ អសារាគាយ សន្តិកេ អសំយោគាយ សន្តិកេ អនភិនន្ទនាយ សន្តិកេ អនជ្ឈោសានាយ សន្តិកេ អនុបាទានាយ សន្តិកេតិ[២] ។

(៣៦) តត្រ អគ្គិវេស្សន[៣] យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ខមតីតិ តត្ថ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ យា ខោ មេ អយំ ទិដ្ឋិ សព្វំ មេ ខមតីតិ ឥមញ្ច អហំ ទិដ្ឋឹ ថាមសា បរាមស្ស អភិនិវិស្ស វោហរេយ្យំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទ្វីហិ មេ អស្ស វិគ្គហោ យោ ចាយំ សមណោ វា ព្រាហ្មណោ វា

១ ម. ឆ. ហិ តេ តេសំ ។ ២ ឱ. ម. សន្តិកេ ។ ៣ ម. ឱ. អគ្គិ- វេស្សនាតិ ទិស្សតិ ។

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE



ពួកសមណព្រាហ្មណ៍ណា មានពាក្យយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ ក៏ទិដ្ឋិណាដែលគួរដល់សមណព្រាហ្មណ៍នោះ ទិដ្ឋិនោះប្រព្រឹត្តទៅក្នុងទីជិតនៃហេតុដែលប្រកបដោយរាគៈ ក្នុងទីជិតនៃសំយោគៈ ក្នុងទីជិតនៃតម្រេក ក្នុងទីជិតនៃសេចក្តីជាប់ចិត្ត ក្នុងទីជិតនៃសេចក្តីប្រកាន់មាំ មួយយ៉ាងទៀត ទិដ្ឋិណាដែលមិនគួរដល់សមណព្រាហ្មណ៍នោះ ទិដ្ឋិនោះរមែងប្រព្រឹត្តទៅក្នុងទីជិតនៃហេតុមិនមែនជារាគៈ ក្នុងទីជិតនៃហេតុ មិនមែនជាសំយោគៈ ក្នុងទីជិតនៃហេតុមិនមែនជាតម្រេក ក្នុងទីជិតនៃសេចក្តីមិនជាប់ចិត្ត ក្នុងទីជិតនៃសេចក្តីមិនប្រកាន់មាំ ។

(៣៦) ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណ- ព្រាហ្មណ៍ណា មានពាក្យយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញ វិញ្ញូបុរស តែងពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាងនេះថា សេចក្តីឃើញរបស់អាត្មាអញណាថា របស់ទាំងអស់គួរដល់អាត្មាអញ ប្រសិនបើអាត្មាអញ ស្ទាបអង្អែលប្រកាន់នូវទិដ្ឋិនេះ ហើយនិយាយតាមកំឡាំងចិត្តដោយមួនមាំថា នេះជារបស់ពិត របស់ដទៃជាមោឃៈ អាត្មាអញក៏នឹងប្រកាន់ខុស ចាកសមណព្រាហ្មណ៍ទាំងពីរ

ឯវំវាទី ឯវំទិដ្ឋិ សព្វំ មេ ន ខមតីតិ យោ ចាយំ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ឯវំទិដ្ឋិ ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ ឥមេហិ មេ (១) អស្ស ទ្វីហិ វិគ្គហោ ។ ឥតិ វិគ្គហេ សតិ វិវាទោ វិវាទេ សតិ វិឃាតោ វិឃាតេ សតិ វិហេសា ។ ឥតិ សោ វិគ្គហញ្ច វិវាទញ្ច វិឃាតញ្ច វិហេសញ្ច អត្តនិ សម្បស្សមានោ តញ្ចេវ ទិដ្ឋឹ បជហតិ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយតិ ។ ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ ឯវមេតាសំ ទិដ្ឋីនំ បដិនិស្សគ្គោ ហោតិ ។ តត្រ អគ្គិវេស្សន យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សព្វំ មេ ន ខមតីតិ តត្រ (២) វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ

១ ម. មេតិ ន ទិស្សតិ ។ ២ ម. យុ. តត្ថ ។





ពួក ១ គឺ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញពួក ១ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញពួក ១ អាត្មាអញនឹងប្រកាន់ខុសពាក្យសមណព្រាហ្មណ៍ទាំងពីរពួកនេះឯង ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលការទាស់ទែងគ្នាមានហើយ សេចក្ដីគុំគួនគ្នាក៏មាន កាលសេចក្ដីគុំគួនគ្នាមានហើយ សេចក្ដីបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរសនោះ ពិចារណាឃើញច្បាស់នូវសេចក្ដីប្រកាន់ខុស សេចក្ដីទាស់ទែងគ្នា សេចក្ដីគុំគួនគ្នា នឹងសេចក្ដីបៀតបៀន ( ជាទោសមាន ) ក្នុងខ្លួនដោយប្រការដូច្នេះហើយ ក៏លះបង់ទិដ្ឋិនោះចេញផង មិនប្រកាន់ទិដ្ឋិដទៃទៀតផង ។ ការលះបង់នូវទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំងនោះ តែងមានដោយប្រការយ៉ាងនេះ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញ វិញ្ញូបុរស តែងពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាង

យា ខោ មេ អយំ ទិដ្ឋិ សព្វំ មេ ន ខមតីតិ ឥមញ្ចេ អហំ ទិដ្ឋឹ ថាមសា បរាមស្ស អភិនិវិស្ស វោហរេយ្យំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទ្វីហិ មេ អស្ស វិគ្គហោ យោ ចាយំ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ឯវំទិដ្ឋី សព្វំ មេ ខមតីតិ យោ ចាយំ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ឯវំទិដ្ឋី ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ ឥមេហិ មេ ទ្វីហិ អស្ស វិគ្គហោ ។ ឥតិ វិគ្គហេ សតិ វិវាទោ វិវាទេ សតិ វិឃាតោ វិឃាតេ សតិ វិហេសា ។ ឥតិ សោ វិគ្គហញ្ច វិវាទញ្ច វិឃាតញ្ច វិហេសញ្ច អត្តនិ សម្បស្សមានោ តញ្ចេវ ទិដ្ឋឹ បជហតិ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយតិ ។ ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ ឯវមេតាសំ ទិដ្ឋីនំ បដិនិស្សគ្គោ ហោតិ ។ តត្រ អគ្គិវេស្សន



នេះជា សេចក្តីយល់របស់គ្នាអញណាថា របស់ទាំងឡាយមិនគួរដល់គ្នាអញ ប្រសិនបើគ្នាអញស្ទាបអង្អែលប្រកាន់ខ្ជាប់ទិដ្ឋិនេះ ហើយនិយាយតាមកំឡាំងចិត្តដោយមាំមួនថា នេះជារបស់ពិត របស់ដទៃជាមោឃៈ គ្នាអញក៏នឹងប្រកាន់ខុស ចាកសមណព្រាហ្មណ៍ទាំងពីរពួក គឺសមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់គ្នាអញពួក ១ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់គ្នាអញ របស់ខ្លះមិនគួរដល់គ្នាអញពួក ១ គ្នាអញក៏នឹងប្រកាន់ខុសចាកសមណ-ព្រាហ្មណ៍ទាំងពីរពួកនេះឯង ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលការទាស់ទែងគ្នាមានហើយ សេចក្តីទុំទួនគ្នាក៏មាន កាលសេចក្តីទុំទួនគ្នាមានហើយ ការបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរសនោះ ពិចារណាឃើញច្បាស់នូវសេចក្តីប្រកាន់ខុស សេចក្តីទាស់ទែងគ្នា សេចក្តីទុំទួនគ្នា នឹងសេចក្តីបៀតបៀនគ្នា ( ជាជាទោសមាន ) ក្នុងខ្លួន ដោយប្រការដូច្នេះហើយ ក៏លះបង់នូវទិដ្ឋិនោះចេញផង មិនប្រកាន់ទិដ្ឋិឯទៀតផង ។ ការលះបង់ទិដ្ឋិទាំងនុ៎ះតែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំងនុ៎ះតែងមានដោយប្រការយ៉ាងនេះ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិទាំងឡាយនោះ

យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ តត្រ វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ យោ ខោ មេ អយំ ទិដ្ឋិ ឯកច្ចំ មេ ខមតិ ឯកច្ចំ មេ ន ខមតីតិ ឥមញ្ចេ អហំ ទិដ្ឋឹ ថាមសា បរាមស្ស អភិនិវិស្ស វោហរេយ្យំ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ទ្វីហិ មេ អស្ស វិគ្គហោ យោ ចាយំ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ឯវំទិដ្ឋី សព្វំ មេ ខមតីតិ យោ ចាយំ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ឯវំទិដ្ឋី សព្វំ មេ ន ខមតីតិ ឥមេហិ មេ អស្ស ទ្វីហិ វិគ្គហោ ។ ឥតិ វិគ្គហេ សតិ វិវាទោ វិវាទេ សតិ វិឃាតោ វិឃាតេ សតិ វិហេសា ។ ឥតិ សោ វិគ្គហញ្ច វិវាទញ្ច វិឃាតញ្ច



ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ វិញ្ញូបុរសតែងពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាងនេះថា សេចក្ដីឃើញរបស់អាត្មាអញណាថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ ប្រសិនបើអាត្មាអញ ស្ទាបអង្អែលប្រកាន់ខ្ជាប់ទិដ្ឋិនេះ ហើយនិយាយតាមកំឡាំងចិត្តដោយមាំមួនថា នេះជារបស់ពិត របស់ដទៃជាមោឃៈ អាត្មាអញគង់នឹងប្រកាន់ខុសពាក្យសមណព្រាហ្មណ៍ទាំងពីរពួក គឺសមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញពួក ១ សមណព្រាហ្មណ៍មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញពួក ១ អាត្មាអញគង់នឹងប្រកាន់ខុសពាក្យសមណព្រាហ្មណ៍ទាំងពីរពួកនេះ ដោយប្រការដូច្នេះ ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលបើការទាស់ទែងគ្នាមានហើយ សេចក្ដីតឹងទ្រូងក៏មាន កាលបើសេចក្ដីតឹងទ្រូងមានហើយ សេចក្ដីបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរសនោះពិចារណាឃើញច្បាស់នូវសេចក្ដីប្រកាន់ខុស សេចក្ដីទាស់ទែងគ្នា សេចក្ដីតឹងទ្រូង

វិហេសញ្ច អត្តនិ សម្បស្សមានោ តញ្ចេវ ទិដ្ឋឹ បជហតិ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយតិ ។ ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ ឯវមេតាសំ ទិដ្ឋីនំ បដិនិស្សគ្គោ ហោតិ ។

(៣៣) អយំ ខោ បន អគ្គិវេស្សន កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសូបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សិតព្វោ ។ តស្សិមំ កាយំ អនិច្ចតោ ទុក្ខតោ រោគតោ គណ្ឌតោ សល្លតោ អឃតោ អាពាធតោ បរតោ បលោកតោ សុញ្ញតោ អនត្តតោ សមនុបស្សតោ យោ កាយស្មិំ កាយច្ឆន្ទោ កាយសិនេហោ (*) កាយន្វយតា សា បហីយតិ ។

---

(*) ម. ម. កាយស្នេហោ ។



នឹងសេចក្ដីបៀតបៀន (ថាជាទោស មាន) ក្នុងខ្លួន ដោយប្រការដូច្នេះ ហើយ ក៏លះបង់នូវទិដ្ឋិនោះចេញផង មិនប្រកាន់ទិដ្ឋិឯទៀតផង ។ ការលះបង់នូវទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ។

(៣៣) ម្នាលអគ្គិវេស្សនៈ ក៏កាយនេះមានរូបជាទីប្រជុំនៃមហាភូតទាំង៤ (ដី ទឹក ភ្លើង ខ្យល់) កើតអំពីមាតាបិតា ចំរើនឡើងដោយបាយនឹងនំកុម្មាស មានការមិនទៀង មានការគក់ច្របាច់ ការដុសខាត់មន្ទិលក្លិនស្អុយ ការបែកធ្លាយនឹងការរាក់រាយទៅជាធម្មតា បុគ្គលគួរពិចារណាឃើញច្បាស់ ដោយសភាពជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបីដូចជាបូស ជាបីដូចជាកូនសរ ជាសេចក្ដីលំបាក ជាជម្ងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ ។ កាលបុគ្គលនោះពិចារណាឃើញច្បាស់នូវកាយនេះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបីដូចជាបូស ជាបីដូចជាកូនសរ ជាសេចក្ដីលំបាក ជាជម្ងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ សេចក្ដីប្រាថ្នាក្នុងកាយ នឹងសេចក្ដីអាល័យកាយ ទាំងកិលេសដែលប្រព្រឹត្តទៅតាមកាយណា កិលេសតណ្ហានោះ គេក៏លះបង់បាន ។

[៣៤] តិស្សោ ខោ ឥមា អគ្គិវេស្សន វេទនា សុខា វេទនា ទុក្ខា វេទនា អទុក្ខមសុខា វេទនា ។ យស្មឹ អគ្គិវេស្សន សមយេ សុខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ ទុក្ខំ វេទនំ វេទេតិ ន អទុក្ខមសុខំ វេទនំ វេទេតិ សុខំយេវ តស្មឹ សមយេ វេទនំ វេទេតិ ។ យស្មឹ អគ្គិវេស្សន សមយេ ទុក្ខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ សុខំ វេទនំ វេទេតិ ន អទុក្ខមសុខំ វេទនំ វេទេតិ ទុក្ខំយេវ តស្មឹ សមយេ វេទនំ វេទេតិ ។ យស្មឹ អគ្គិវេស្សន សមយេ អទុក្ខមសុខំ វេទនំ វេទេតិ នេវ តស្មឹ សមយេ សុខំ វេទនំ វេទេតិ ន ទុក្ខំ វេទនំ វេទេតិ អទុក្ខមសុខំយេវ តស្មឹ សមយេ វេទនំ វេទេតិ ។ សុខា[១] អគ្គិវេស្សន អនិច្ចា[២] សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ ទុក្ខាបិ ខោ អគ្គិវេស្សន អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា

១ ឱ. ម. សុខា បិ ខោ ។ ២ ឱ. ម. អនិច្ចា ។



[៣៤] ម្នាលអគ្គិវេស្សនៈ វេទនានេះមាន ៣ ប្រការគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ គឺសម័យនោះ ទទួលចំពោះតែសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះ ទទួលចំពោះតែទុក្ខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះតែអទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅនឹងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅទាំងមានកិរិយារលត់ទៅវិញជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ តែងអស់ទៅនឹងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅ

និរោធធម្មា ។ អទុក្ខមសុខាបិ ខោ អគ្គិវេស្សន វេទនា អនិច្ចា សង្ខតា បដិច្ចសមុប្បន្នា ខយធម្មា វយធម្មា វិរាគធម្មា និរោធធម្មា ។ ឯវំ បស្សំ អគ្គិវេស្សន សុតវា អរិយសាវកោ សុខាយបិ វេទនាយ និព្វិន្ទតិ ទុក្ខាយបិ វេទនាយ និព្វិន្ទតិ អទុក្ខមសុខាយបិ វេទនាយ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯវំ វិមុត្តចិត្តោ ខោ អគ្គិវេស្សន ភិក្ខុ ន កេនចិ សំវទតិ ន កេនចិ វិវទតិ យញ្ច ខោ[1] លោកេ វុត្តំ តេន វោហរតិ អបរាមសន្តិ ។

១ ឱ. ម. [illegible] ឥតិ ។



តែងមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខមសុខវេទនាក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ តែងអស់ទៅនិងសូន្យទៅជាធម្មតា មានកិរិយាក្លាយទៅនិងរលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវ័កអ្នកបានស្ដាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេស កាលចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅរួចហើយ កិច្ចដែលគួរធ្វើបានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានទៀត ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះយ៉ាងនេះ រមែងមិននិយាយផ្ទុយនឹងអ្នកណា ៗ មិននិយាយទទឹងទាស់នឹងអ្នកណាៗ ពាក្យណាដែលគេនិយាយហើយ ក្នុងលោក ក៏ពោលទៅតាមពាក្យនោះ តែមិនបានស្ទាបអង្អែល (ដោយទិដ្ឋិ) ។

(៣៥) តេន ខោ បន សមយេន អាយស្មា សារីបុត្តោ ភគវតោ បិដ្ឋិតោ ឋិតោ ភគវន្តំ វីជយមានោ[១] ។ អថ ខោ អាយស្មតោ សារីបុត្តស្ស ឯតទហោសិ តេសំ តេសំ កិរ នោ ភគវា ធម្មានំ អភិញ្ញា បហានមាហ តេសំ តេសំ កិរ នោ សុគតោ ធម្មានំ អភិញ្ញា បដិនិស្សគ្គមាហាតិ ។ ឥតិ ហិទំ អាយស្មតោ សារីបុត្តស្ស បដិសញ្ចិក្ខតោ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ ។ ទីឃនខស្ស បរិព្វាជកស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

(៣៦) អថ ខោ ទីឃនខោ បរិព្វាជកោ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ ភគវន្តំ ឯតទវោច

១ ឱ. ម. បិដ្ឋិតោ ឋិតោ ហោតិ ភគវន្តំ វីជមានោតិ ទិស្សតិ ។



(៣៥) សម័យនោះឯង ព្រះសារីបុត្រមានអាយុ ឈរខាងព្រះប្រឹស្ឋាង្គនៃព្រះមានព្រះភាគ បក់ថ្វាយព្រះមានព្រះភាគ ។ ក្នុងលំដាប់នោះ ព្រះសារីបុត្រមានអាយុ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ការលះបង់នូវពួកធម៌នោះ ៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ បានឮថាព្រះសុគតទ្រង់ត្រាស់ការលះចោលនូវពួកធម៌នោះ ៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ ។ កាលព្រះសារីបុត្រមានអាយុ កំពុងពិចារណាហេតុនេះ ស្រាប់តែចិត្តលោកក៏ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំដោយប្រការដូច្នេះ ។ ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិលបានកើតឡើងហើយ ដល់ទីឃនខបរិព្វាជកថា ធម្មជាតិអ្វីមួយ មានសេចក្ដីកើតឡើងជាធម្មតា ធម្មជាតិទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា ។

(៣៦) គ្រានោះ ទីឃនខបរិព្វាជក បានឃើញធម៌ហើយ បានដល់ធម៌ហើយ បានដឹងច្បាស់នូវធម៌ហើយ មានចិត្តចុះស៊ប់ក្នុងធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យហើយ ប្រាសចាកសេចក្ដីងឿងឆ្ងល់ ថាហេតុពោលជាអ្វី ៗ ដល់នូវសេចក្ដីក្លៀវក្លា មិនជឿស្ដាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្ដា បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះ

អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេក-បរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

ទីឃនខសុត្តំ ចតុត្ថំ និដ្ឋិតំ ។



ថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញនូវវត្ថុដែលបិទបាំងទុក ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោតដូចជាមនុស្សកាន់ប្រទីប ក្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក (ក៏) មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចំរើនជ្រាប នូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះតទៅ ។

ចប់ ទីឃនខសូត្រ ទី ៤ ។

## បញ្ចមំ មាគណ្ឌិយសុត្តំ

[៣៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម (១) កុរូនំ និគមោ ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស អគ្យាគារេ តិណសន្ថរកេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ កម្មាសធម្មំ បិណ្ឌាយ បាវិសិ ។ កម្មាសធម្មេ (២) បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន អញ្ញតរោ វនសណ្ឌោ តេនុបសង្កមិ ទិវាវិហារាយ តំ វនសណ្ឌំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

(៣៨) អថខោ មាគណ្ឌិយោ (៣) បរិព្វាជកោ ជង្ឃាវិហារំ (៤) អនុចង្កមមានោ អនុវិចរមានោ យេន ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស អគ្យាគារំ តេនុបសង្កមិ ។ អទ្ទសា ខោ មាគណ្ឌិយោ បរិព្វាជកោ ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស អគ្យាគារេ តិណសន្ថារកំ ទិស្វាន ភារទ្វាជគោត្តំ ព្រាហ្មណំ ឯតទវោច

១ ឱ. ម. កម្មាស្សធម្មំ ។ ២ ម. កម្មាសធម្មំ ។ ៣ ឱ. មាគន្ទិយោ ។ ៤ ម. ជង្ឃាវិហារំ ។

## មាគណ្ឌិយសូត្រ ទី ៥

(៣៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគស្តេចគង់លើកម្រាលស្មៅ ក្នុងរោងសម្រាប់បូជាភ្លើងរបស់ព្រាហ្មណ៍ឈ្មោះភារទ្វាជគោត្ត ក្នុងកម្មាសធម្មនិគម របស់ពួកជនកុរុ ក្នុងដែនកុរុ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ហើយស្តេចចូលទៅកាន់កម្មាសធម្មនិគម ដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ ។ លុះចូលទៅបិណ្ឌបាត ក្នុងកម្មាសធម្មនិគមហើយ ត្រឡប់មកពីបិណ្ឌបាត ក្នុងបច្ឆាភត្ត ក៏ស្តេចតម្រង់ចូលទៅកាន់ដងព្រៃមួយ ទ្រង់គាស្រ័យដងព្រៃនោះ ដើម្បីសម្រាកក្នុងវេលាថ្ងៃ ហើយគង់ទៀបគល់ឈើមួយដើម ក្នុងវេលាថ្ងៃ ។

(៣៨) គ្រានោះ មាគណ្ឌិយបរិព្វាជក កំពុងចង្ក្រមត្រាច់ដើរទៅមក ដើម្បីសម្រាកកំឡាំងស្មង ក៏ចូលទៅកាន់រោង សម្រាប់បូជាភ្លើងរបស់ភារទ្វាជគោត្តព្រាហ្មណ៍ ។ មាគណ្ឌិយបរិព្វាជក បានឃើញកម្រាលស្មៅក្នុងរោងសម្រាប់បូជាភ្លើង របស់ភារទ្វាជគោត្តព្រាហ្មណ៍ លុះឃើញហើយ ទើបនិយាយនឹងភារទ្វាជគោត្តព្រាហ្មណ៍យ៉ាងនេះថា

កស្ស ន្វាយំ សម្ម ភោតោ ភារទ្វាជស្ស អគ្យាគារេ តិណសន្ថារកោ បញ្ញត្តោ សមណសេយ្យានុរូបំ មញ្ញេតិ ។ អត្ថិ ភោ មាគណ្ឌិយ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តស្សេសា ភោតោ គោតមស្ស សេយ្យា បញ្ញត្តាតិ ។ ទុទ្ទិដ្ឋំ វត ភោ ភារទ្វាជ អទ្ទសាម យេ មយំ តស្ស ភោតោ គោតមស្ស ភូនហុនស្ស[១] សេយ្យំ អទ្ទសាមាតិ ។

១ ម. ឆ. ភូនហុនោ ។



នែសំឡាញ់ កម្រាលស្មៅនេះដែលភារទ្វាជគោត្តឯងក្រាលទុកក្នុងរោង សម្រាប់បូជាភ្លើង បម្រុងអ្នកណា ទំនងគួរជាទីសយ្យាយរបស់សមណៈទេដឹង ។ ម្នាលមាគណ្ឌិយៈដ៏ចំរើន មានសមណៈជាគោតមគោត្ត ជាសក្យបុត្រចេញចាកសក្យត្រកូលបួស កិត្តិសព្ទដ៏ល្អនៃព្រះគោតមដ៏ចំ-រើននោះ ខ្ចរខ្ចាយសុសសាយទៅ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយព្រះអង្គឯងប្រពៃ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានព្រះដំណើរល្អ ទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ មិនមានបុគ្គលណាមួយស្មើ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ទំរាលសេយ្យានេះ បម្រុងព្រះគោតមដ៏ចំរើន អង្គនោះ ។ ម្នាលភារទ្វាជៈ ពួកយើងបានឃើញទីសេយ្យារបស់ព្រះគោតមដ៏ចំរើន ជាអ្នកកំចាត់បង់នូវសេចក្ដីចំរើនចោលចេញនោះ ឈ្មោះថាបានឃើញនូវហេតុដែលគេមិនគួរឃើញទេ[១] តើ ។

១ លទ្ធិព្រាហ្មណ៍ថា បុគ្គលឃើញទីកន្លែងព្រះសម្មាសម្ពុទ្ធគង់ ឈ្មោះថាឃើញអកុសល បានជាគេពោលថា ឃើញហេតុដែលគេមិនគួរឃើញទេ ។

រក្ខស្សេតំ មាគណ្ឌិយ វាចំ រក្ខស្សេតំ មាគណ្ឌិយ វាចំ តត្រ ហិ តស្ស[១] ភោតោ គោតមស្ស ខត្តិយបណ្ឌិតាបិ ព្រាហ្មណបណ្ឌិតាបិ គហបតិ-បណ្ឌិតាបិ សមណបណ្ឌិតាបិ អភិប្បសន្នា វិនីតា អរិយេ ញាយេ ធម្មេ កុសលេតិ ។ សម្មុខា ចេបិ មយំ ភោ ភារទ្វាជ តំ ភវន្តំ គោតមំ បស្សេយ្យាម សម្មុខាបិ នំ វទេយ្យាម ភូនហុ[២] សមណោ គោតមោតិ ។ តំ កិស្ស ហេតុ ។ ឯវញ្ហិ នោ សុត្តេ ឱចរតីតិ ។ សចេ តំ ភោតោ មាគណ្ឌិយស្ស អគរុ អារោចេស្សាមិ តស្ស សមណស្ស[៣] គោតមស្សាតិ ។ អប្បោស្សុក្កោ ភវំ ភារទ្វាជោ វុត្តោ ច នំ វទេយ្យាតិ ។

---

១ ឧ. តស្ស ។ ២ ឧ. ម. ភូនហុ ។ ៣ ឧ. អារោចេយ្យាមេតំ សមណស្ស ។ ម. អារោចេយ្យាមិ តំ សមណស្ស ។



ម្នាលមាគណ្ឌិយៈ អ្នកឯងត្រូវរក្សាសំដីនេះ[១] ម្នាលមាគណ្ឌិយៈ អ្នកឯងត្រូវរក្សាទុកពាក្យនេះ[១] ដ្បិតពួកខត្តិយបណ្ឌិត ព្រាហ្មណបណ្ឌិត គហ-បតិបណ្ឌិត និងពួកសមណបណ្ឌិតជាច្រើន បាននាំគ្នាជ្រះថ្លា ចំពោះព្រះសមណគោតមអង្គនោះ ព្រះអង្គទ្រង់ណែនាំក្នុងធម៌ជាកុសល ជាគ្រឿងចេញទៅដ៏ប្រសើរ ។ ម្នាលភារទ្វាជៈ ប្រសិនបើយើងគប្បីឃើញ ព្រះគោតមដ៏ចំរើននោះ ក្នុងទីចំពោះព្រះភក្ត្រសោត យើងគប្បីនិយាយនឹងលោកក្នុងទីចំពោះព្រះភក្ត្រថា ព្រះសមណគោតមកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ សេចក្តីនោះព្រោះហេតុអ្វី ព្រោះចុះសម្រុងគ្នានឹងសូត្ររបស់យើងយ៉ាងនេះ ។ ប្រសិនបើសេចក្តីនោះ មិនទទឹងទាស់ដល់មាគណ្ឌិយៈទេ ខ្ញុំនឹងក្រាបទូលចំពោះព្រះសមណគោតមអង្គនោះ ។ ភារទ្វាជៈដ៏ចំរើន គប្បីមានសេចក្តីខ្វល់ខ្វាយតិច ខ្ញុំនិយាយផ្តើមរួចហើយ ត្រូវនិយាយនឹងព្រះគោតមនោះទៀតចុះ ។

---

១ ត្រូវរក្សាសំដីនេះ ត្រូវរក្សាពាក្យនេះ បានសេចក្តីថា កុំនិយាយ ។

(៣៩) អស្សោសិ ខោ ភគវា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស មាគណ្ឌិយេន បរិព្វាជកេន សទ្ធឹ ឥមំ កថាសល្លាបំ ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស អគ្យាគារំ តេនុបសង្កមិ ឧបសង្កមិត្វា និសីទិ បញ្ញត្តេ(១) តិណសន្ថារកេ ។ អថខោ ភារទ្វាជគោត្តោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ភារទ្វាជគោត្តំ ព្រាហ្មណំ ភគវា ឯតទវោច អហុ បន តេ ភារទ្វាជ មាគណ្ឌិយេន បរិព្វាជកេន សទ្ធឹ ឥមំយេវ តិណសន្ថារំ អារព្ភ កោចិទេវ កថាសល្លាបោតិ ។ ឯវំ វុត្តេ

១ ម. បញ្ញត្ត ។



(៣៩) ព្រះមានព្រះភាគបានទ្រង់ព្រះសណ្តាប់ភារទ្វាជព្រាហ្មណ៍ ដែលកំពុងនិយាយចរចាជាមួយនឹងមាគណ្ឌិយបរិព្វាជក ដោយព្រះសោតធាតុដ៏ជាទិព្វបរិសុទ្ធ កន្លងហួសសោតធាតុរបស់មនុស្សធម្មតា ។ ទើបព្រះមានព្រះភាគទ្រង់ចេញអំពីទីសម្ងំ ( ផលសមាបត្តិ ) ក្នុងសាយណ្ហសម័យ ស្តេចចូលទៅកាន់រោងសម្រាប់បូជាភ្លើង របស់ភារទ្វាជគោត្តព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើកម្រាលស្មៅ ដែលភារទ្វាជគោត្តព្រាហ្មណ៍ក្រាលថ្វាយ ។ គ្រានោះ ភារទ្វាជគោត្តព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ និយាយពាក្យសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភារទ្វាជគោត្តព្រាហ្មណ៍ ដែលអង្គុយក្នុងទីដ៏សមគួរហើយយ៉ាងនេះថា ម្នាលភារទ្វាជៈ ចុះពាក្យចរចាដែលអ្នកបាននិយាយជាមួយនឹងមាគណ្ឌិយបរិព្វាជក ប្រារព្ធរឿងកម្រាលស្មៅនេះ ចុះសម្រេចការដូចម្តេចទៅ ។ កាលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ

ភារទ្វាជគោត្តោ ព្រាហ្មណោ សំវិគ្គោ លោមហដ្ឋជាតោ ភគវន្តំ ឯតទវោច ឯតទេវ ខោ បន មយំ ភោតោ គោតមស្ស អារោចេតុកាមា អហុ ច បន ភវំ គោតមោ អនក្ខាតំយេវ អក្ខាសិ(១) ។ អយញ្ហិ ទំ ភគវតា ភារទ្វាជគោត្តេន ព្រាហ្មណេន សទ្ធិំ អន្តរាកថា វិប្បកតា ហោតិ ។ អថខោ(២) មាគន្ទិយោ បរិព្វាជកោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេន ភារទ្វាជគោត្តស្ស ព្រាហ្មណស្ស អគ្យាគារំ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធិំ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(៦០) ឯកមន្តំ និសិន្នំ ខោ មាគន្ទិយំ បរិព្វាជកំ ភគវា ឯតទវោច ចក្ខុ(៣) ខោ មាគន្ទិយ រូបារាមំ រូបរតំ រូបសម្មុទិតំ តំ តថាគតស្ស ទន្តំ គុត្តំ រក្ខិតំ សំវុតំ តស្ស ច សំវរាយ ធម្មំ ទេសេតិ

១ ម. អនក្ខាតំយេវ អក្ខាសីតិ ។ ២ ម. អថ ។ ៣. ម. ចក្ខុំ ។



ភារទ្វាជគោត្តព្រាហ្មណ៍ ភ្ញាក់ព្រើត កើតសេចក្តីព្រឺរោម ហើយបាន ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា យើងខ្ញុំព្រះអង្គប្រុងនឹងក្រាប ទូលពាក្យនុ៎ះចំពោះព្រះមានព្រះភាគជាម្ចាស់ដែរ ស្រាប់តែព្រះគោតម ជាម្ចាស់ទ្រង់ត្រាស់សួរ នូវពាក្យដែលខ្ញុំព្រះអង្គមិនទាន់ក្រាបទូល ។ ក៏ ឯពាក្យជាចន្លោះនេះ ដែលព្រះមានព្រះភាគ កំពុងតែចរចាជាមួយ នឹងភារទ្វាជគោត្តព្រាហ្មណ៍ ក៏ដាច់ពាក់កណ្តាលទៅ ។ គ្រានោះ មាគន្ទិយបរិព្វាជក កំពុងដើរចង្ក្រមត្រាច់ទៅមក ដើម្បីនឹងសម្រាក ស្ងួន ក៏ចូលទៅសាលព្រះមានព្រះភាគ ឯរោងសម្រាប់បូជាភ្លើងរបស់ ភារទ្វាជគោត្តព្រាហ្មណ៍ លុះចូលទៅដល់ហើយ ទើបក្រាបទូលពាក់ ពាក់សំណេះសំណាល នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែល គួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

(៦០) ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងមាគន្ទិយបរិព្វាជក ដែលអង្គុយក្នុងទីដ៏សមគួរហើយយ៉ាងនេះថា ម្នាលមាគន្ទិយៈ ចក្ខុតែង មានរូបជាទីត្រេកអរ ត្រេកអរក្នុងរូប ត្រេកត្រអាលក្នុងរូប ចក្ខុនោះ ព្រះតថាគត បានទូន្មាន គ្រប់គ្រង រក្សា សង្រួមរួចហើយ មួយយ៉ាងទៀត ព្រះតថាគត បានសំដែងធម៌ ដើម្បីសង្រួមចក្ខុនោះ

ឥទន្នុ តេ ឯតំ មាគណ្ឌិយ សន្ធាយ ភាសិតំ ភូនហុ
សមណោ គោតមោតិ ។ ឯតទេវ ខោ បន មេ ភោ
គោតម សន្ធាយ ភាសិតំ ភូនហុ សមណោ
គោតមោតិ តំ កិស្ស ហេតុ ឯវញ្ហិ នោ សុត្តេ
ឱចរតីតិ ។ សោតំ ខោ មាគណ្ឌិយ សទ្ទារាមំ ។បេ។
ឃានំ ខោ មាគណ្ឌិយ គន្ធារាមំ... ជិវ្ហា ខោ
មាគណ្ឌិយ រសារាមា រសរតា រសសម្មុទិតា សា
តថាគតស្ស ទន្តា គុត្តា រក្ខិតា សំវុតា តស្សា ច
សំវរាយ ធម្មំ ទេសេតិ ឥទន្នុ តេ ឯតំ ខោ មាគណ្ឌិយ
សន្ធាយ ភាសិតំ ភូនហុ សមណោ គោតមោតិ ។
ឯតទេវ ខោ បន មេ ភោ គោតម សន្ធាយ ភាសិតំ
ភូនហុ សមណោ គោតមោតិ តំ កិស្ស ហេតុ
ឯវញ្ហិ នោ សុត្តេ ឱចរតីតិ ។ កាយោ ខោ មាគណ្ឌិយ
ផោដ្ឋព្វារាមោ ។បេ។ មនោ ខោ មាគណ្ឌិយ



ម្នាលមាគណ្ឌិយៈ ពាក្យដែលអ្នកឯងពោលថា ព្រះសមណគោតម
ជាអ្នកកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវគ្រាន់ហេតុនុះទេតើ ។ បពិត្រ
ព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំព្រះអង្គបានពោលថា ព្រះសមណ-
គោតមជាអ្នកកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវគ្រាន់ហេតុនុះដែលហើយ
សេចក្តីនោះព្រោះហេតុអ្វី ព្រោះចុះសម្រុងគ្នានឹងសូត្ររបស់យើងយ៉ាង
នេះ ។ ម្នាលមាគណ្ឌិយៈ ត្រចៀក មានសំឡេងជាទីត្រេកអរ ។បេ។
ម្នាលមាគណ្ឌិយៈ ច្រមុះ មានក្លិនជាទីត្រេកអរ... ម្នាលមាគណ្ឌិយៈ
អណ្តាតមានរសជាទីត្រេកអរ ត្រេកអរក្នុងរស មានរសជាទីត្រេកត្រអាល
អណ្តាតនោះ ព្រះតថាគតបានទូន្មានគ្រប់គ្រងរក្សា សង្រួមរួចហើយ
មួយយ៉ាងទៀត ព្រះតថាគត បានសំដែងធម៌ ដើម្បីសង្រួមអណ្តាតនោះ
ម្នាលមាគណ្ឌិយៈ ពាក្យដែលអ្នកឯងពោលថា ព្រះសមណគោតមជា
អ្នកកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវគ្រាន់ហេតុនុះទេតើ ។ បពិត្រ
ព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំព្រះអង្គពោលថា សមណគោតមជាអ្នក
កំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវគ្រាន់ហេតុនុះដែលហើយ សេចក្តី
នោះព្រោះហេតុអ្វី ព្រោះជាចុះសម្រុងគ្នានឹងសូត្ររបស់យើងយ៉ាងនេះ ។
ម្នាលមាគណ្ឌិយៈ កាយមានផោដ្ឋព្វៈជាទីត្រេកអរ ។បេ។ ម្នាលមាគណ្ឌិយៈ

ធម្មារាមោ ធម្មរតោ ធម្មសម្មុទិតោ សោ តថាគតស្ស ទន្តោ គុត្តោ រក្ខិតោ សំវុតោ តស្ស ច សំវរាយ ធម្មំ ទេសេតិ ឥទំ នុ តេ ឯតំ មាគណ្ឌិយ សន្ធាយ ភាសិតំ ភូនហុ សមណោ គោតមោតិ ។ ឯតទេវ ខោ បន មេ ភោ គោតម សន្ធាយ ភាសិតំ ភូនហុ សមណោ គោតមោតិ ។ តំ កិស្ស ហេតុ ឯវញ្ហិ នោ សុត្តេ ឱចរតីតិ ។

(៦០) តំ កឹ មញ្ញសិ មាគណ្ឌិយ ឥធេកច្ចោ ចក្ខុវិញ្ញេយ្យេហិ រូបេហិ បរិចារិតបុព្វោ អស្ស ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោ អបរេន សមយេន រូបានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា រូបតណ្ហំ បហាយ រូបបរិឡាហំ បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ



ចិត្តមានធម្មារម្មណ៍ជាទីរីករាយ ត្រេកអរក្នុងធម្មារម្មណ៍ ត្រេកត្រអាលក្នុងធម្មារម្មណ៍ ចិត្តនោះព្រះតថាគត បានទូន្មានគ្រប់គ្រងរក្សាសង្រួមរួចហើយ មួយយ៉ាងទៀត ព្រះតថាគតបានសំដែងធម៌ ដើម្បីសង្រួមចិត្តនោះ ម្នាលមាគណ្ឌិយៈ ពាក្យដែលអ្នកពោលថា ព្រះសមណគោតមជាអ្នកកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវត្រង់ហេតុនុ៎ះទេតើ ។ បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំព្រះអង្គពោលថា ព្រះសមណគោតមជាអ្នកកំចាត់បង់នូវសេចក្តីចំរើនដូច្នេះ ត្រូវត្រង់ហេតុនុ៎ះឯងហើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះថាចុះសម្រុងគ្នានឹងសូត្ររបស់យើងខ្ញុំ ។

(៦១) ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្តេច បុគ្គលក្នុងលោកនេះ ធ្លាប់ឲ្យគេបំរើដោយរូបទាំងឡាយ ដែលគួរដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីគាប់ចិត្ត ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីត្រេកអរ លុះគ្រាក្រោយមក បុគ្គលនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់រូបទាំងឡាយ តាមដោយសេចក្តីពិត ហើយក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងរូប បន្ទោបង់នូវសេចក្តីក្តៅក្រហាយ ក្នុងរូប ជាអ្នកប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់តាំងនៅក្នុងសន្តាន

វិហរេយ្យ ឥមស្ស បន តេ មាគណ្ឌិយ កិមស្ស វចនីយន្តិ ។ ន កិញ្ចិ ភោ គោតម ។ តំ កឹ មញ្ញសិ មាគណ្ឌិយ ឥធេកច្ចោ សោតវិញ្ញេយ្យេហិ សទ្ទេហិ ។ បេ ។ ឃានវិញ្ញេយ្យេហិ គន្ធេហិ... ជិវ្ហាវិញ្ញេយ្យេហិ រសេហិ... កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ បរិចារិតបុព្វោ អស្ស ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសំហិតេហិ រជនីយេហិ សោ អបរេន សមយេន ផោដ្ឋព្វានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ផោដ្ឋព្វតណ្ហំ បហាយ ផោដ្ឋព្វ-បរិឡាហំ បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូប-សន្តចិត្តោ វិហរេយ្យ ឥមស្ស បន តេ មាគណ្ឌិយ កិមស្ស វចនីយន្តិ ។ ន កិញ្ចិ ភោ គោតម ។



សម្រាន្តនៅ ម្នាលមាគណ្ឌិយៈ ចុះអ្នកឯងសំគាល់ថាឲ្យបុគ្គលនេះដូចម្ដេច ។ បពិត្រព្រះគោតមដ៏ចំរើន ឥតមានថាអ្វីកើតទេ ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្ដេច បុគ្គលក្នុងលោកនេះ ( ធ្លាប់ឡើងបម្រើ ) ដោយសំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ។ បេ ។ ដោយក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ... ដោយរសទាំងឡាយ ដែលគប្បីដឹងដោយអណ្ដាត ... ធ្លាប់ឡើងបម្រើដោយផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីតម្រេក លុះគ្រាក្រោយមក បុគ្គលនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្ដីវិនាសផង នូវសេចក្ដីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់ផោដ្ឋព្វៈទាំងឡាយ តាមសេចក្ដីពិតហើយ ក៏លះបង់នូវសេចក្ដីប្រាថ្នាក្នុងផោដ្ឋព្វៈ បន្ទោបង់នូវសេចក្ដីក្ដៅក្រហាយក្នុងផោដ្ឋព្វៈ ប្រាសចាកសេចក្ដីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់តាំងនៅក្នុងសន្ដានសម្រាន្តនៅ ម្នាលមាគណ្ឌិយៈ ចុះអ្នកឯងសំគាល់ថាឲ្យបុគ្គលនេះដូចម្ដេច ។ បពិត្រព្រះគោតមដ៏ចំរើន ឥតមានថាអ្វីកើតទេ ។

(៦២) អហំ ខោ បន មាគណ្ឌិយ បុព្វេ អគារិយភូតោ សមានោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេសឹ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោតវិញ្ញេយ្យេហិ សទ្ទេហិ ។ បេ ។ ឃានវិញ្ញេយ្យេហិ គន្ធេហិ... ជិវ្ហាវិញ្ញេយ្យេហិ រសេហិ... កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ ។ តស្ស មយ្ហំ មាគណ្ឌិយ តយោ បាសាទា អហេសុំ ឯកោ វស្សិកោ ឯកោ ហេមន្តិកោ ឯកោ គិម្ហិកោ ។ សោ ខោ អហំ មាគណ្ឌិយ វស្សិកេ បាសាទេ ចត្តារោ មាសេ និប្បុរិសេហិ តុរិយេហិ បរិចារយមានោ ន ហេដ្ឋាបាសាទំ ឱរោហាមិ ។ សោ អបរេន សមយេន កាមានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា កាមតណ្ហំ បហាយ កាមបរិឡាហំ បដិវិនោទេត្វា



(៦៦) ម្នាលមាគណ្ឌិយៈ កាលពីដើម តថាគតនៅជាគ្រហស្ថ ក៏ស្កប់ឆ្អែតឆ្អន់ មូលមិត្ត ឡើងបម្រើដោយកាមគុណទាំង ៥ គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរត្រេកអរ សំឡេងដែលគប្បីដឹងដោយត្រចៀក ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរជាទីត្រេកអរ ។ ម្នាលមាគណ្ឌិយៈ តថាគតនោះមានប្រាសាទ ៣ ខ្នង ប្រាសាទមួយ សម្រាប់នៅក្នុងរដូវភ្លៀង ប្រាសាទមួយសម្រាប់នៅក្នុងរដូវរងា ប្រាសាទមួយសម្រាប់នៅក្នុងរដូវក្តៅ ។ ម្នាលមាគណ្ឌិយៈ តថាគតនោះឡើងបម្រើដោយតន្ត្រីដែលឥតបុរស លើប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀងអស់ ៤ ខែ មិនដែលចុះមកកាន់ក្រោមសោះ ។ លុះគ្រាក្រោយមក តថាគតនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌សម្រាប់រលាស់ចោលផង សុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្តីពិត ហើយក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងកាម បន្ទោបង់នូវសេចក្តីក្តៅក្រហាយក្នុងកាម

វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ វិហរាមិ ។ សោ អញ្ញេ សត្តេ បស្សាមិ កាមេសុ អវីតរាគេ កាមតណ្ហាហិ ខជ្ជមានេ កាមបរិឡាហេន បរិឌយ្ហមានេ កាមេ បដិសេវន្តេ សោ តេសំ ន បិហេមិ ន តត្ថ អភិរមាមិ តំ កិស្ស ហេតុ យា ចាយំ(១) មាគណ្ឌិយ រតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ តាយ រតិយា រមមានោ ហីនស្ស ន បិហេមិ ន តត្ថ អភិរមាមិ ។

(៤៣) សេយ្យថាបិ មាគណ្ឌិយ គហបតិ វា គហបតិបុត្តោ វា អឌ្ឍោ មហទ្ធនោ មហាភោគោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេយ្យ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោតវិញ្ញេយ្យេហិ សទ្ទេហិ ។ បេ ។ ឃានវិញ្ញេយ្យេហិ គន្ធេហិ ។ បេ ។ ជិវ្ហាវិញ្ញេយ្យេហិ រសេហិ ។ បេ ។ កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ

១ ម. យាយំ ។



ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់ល្ងាប់ ក្នុងខាងក្នុងសណ្ឋិតនៅ ។ តថាគតនោះឃើញសត្វទាំងឡាយឯទៀត មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្តីប្រាថ្នាក្នុងកាមកំពុងទំពាស៊ី ជាអ្នកក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយព្រោះកាម កំពុងសេពនូវកាមទាំងឡាយ តថាគតនោះមិនប្រាថ្នាចំពោះជននោះ មិនត្រេកអរក្នុងការសេពកាមនោះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលមាគណ្ឌិយៈ ព្រោះថាកាលបុគ្គលត្រេកអរដោយសេចក្តីត្រេកអរ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាកអកុសលធម៌ទាំងឡាយ ក៏នៅជាអ្នកជោគជ័យ ព្រោះហេតុដូច្នោះ តថាគតទើបមិនប្រាថ្នា មិនត្រេកអរក្នុងការសេពកាមនោះឡើយ ។

(៤៤) ម្នាលមាគណ្ឌិយៈ ដូចជាគហបតី ឬគហបតិបុត្ត ដែលមានទ្រព្យច្រើនស្តុកស្តម្ភ មានសម្បត្តិច្រើន ស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើ ដោយកាមគុណទាំង ៥ គឺដោយរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីត្រេកអរ ដោយសំឡេងដែលគប្បីដឹងដោយសោតៈ ។ បេ ។ ដោយក្លិនដែលគប្បីដឹងដោយឃានៈ ។ បេ ។ ដោយរសដែលគប្បីដឹងដោយជិវ្ហា ។ បេ ។ ដោយផោដ្ឋព្វៈដែលគប្បីដឹងច្បាស់ដោយកាយ ជាទី

កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ ។ សោ កាយេន សុចរិតំ ចរិត្វា វាចាយ សុចរិតំ ចរិត្វា មនសា សុចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ទេវានំ តាវតឹសានំ សហព្យតំ ។ សោ តត្ថ នន្ទនេ វនេ អច្ឆរាសង្ឃបរិវុតោ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេយ្យ ។ សោ បស្សេយ្យ គហបតឹ វា គហបតិបុត្តំ វា បញ្ចហិ កាមគុណេហិ សមប្បិតំ សមង្គីភូតំ បរិចារយមានំ ។ តំ កឹ មញ្ញសិ មាគណ្ឌិយ អបិ នុ សោ ទេវបុត្តោ នន្ទនេ វនេ អច្ឆរាសង្ឃបរិវុតោ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារយមានោ អមុស្ស គហបតិស្ស វា គហបតិបុត្តស្ស វា បិហេយ្យ មានុសកានំ វា បញ្ចន្នំ កាមគុណានំ មានុសកេហិ វា កាមេហិ អាវត្តេយ្យាតិ ។ នោ ហេតំ ភោ គោតម ។ តំ កិស្ស



ប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរជាទីរីករាយ ។ គហបតីនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះទំលាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ក៏បានទៅកាន់ទេវលោកគឺឋានសួគ៌ជាសុគតិ ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ទេវបុត្តនោះមានពួកស្រីអប្សរហែហមចោមរោមក្នុងសួននន្ទនវ័ន ក្នុងទេវលោកនោះស្កប់ស្កល់មូលចិត្ត បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ។ ទេវបុត្រនោះគប្បីឃើញនូវគហបតីឬគហបតិបុត្រ ដែលកំពុងស្កប់ស្កល់មូលចិត្ត បម្រើដោយកាមគុណទាំង ៥ ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្ដេច ចុះទេវបុត្រនោះ មានពួកស្រីអប្សរហែហមចោមរោមក្នុងសួននន្ទនវ័នស្កប់ស្កល់មូលចិត្ត បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ហើយមកប្រាថ្នាគហបតីឬគហបតិបុត្រឯណោះ ហើយវិលត្រឡប់មករកកាមគុណទាំង ៥ ជារបស់មនុស្ស ដោយកាមជារបស់មនុស្សវិញដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន មិនត្រឡប់មកវិញទេ ។ សេចក្ដីនោះព្រោះហេតុអ្វី

ហេតុ មានុសកេហិ ភោ គោតម កាមេហិ ទិព្វកាមា(*) អភិក្កន្តតរា ច បណីតតរា ចាតិ ។ ឯវមេវ ខោ អហំ មាគណ្ឌិយ បុព្វេ អគារិយភូតោ សមានោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេសឹ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោតវិញ្ញេយ្យេហិ សទ្ទេហិ ។ បេ ។ ឃានវិញ្ញេយ្យេហិ គន្ធេហិ ។ បេ ។ ជិវ្ហាវិញ្ញេយ្យេហិ រសេហិ ។ បេ ។ កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ ។ សោ អបរេន សមយេន កាមានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា កាមតណ្ហំ បហាយ កាមបរិឡាហំ បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ វិហរាមិ ។ សោ អហំ អញ្ញេ សត្តេ បស្សាមិ

* ម. ទិព្វា ហិ ។



បពិត្រព្រះគោតមដ៏ចំរើន ព្រោះកាមដ៏ជាទិព្វ កន្លងហួសប្រសើរផុតកាមជារបស់មនុស្ស ។ យ៉ាងនេះមែនហើយ មាគណ្ឌិយៈ កាលពីដើម តថាគតនៅជាគ្រហស្ថ ឆ្អែតស្កប់ស្កល់ព្រមព្រៀង ឲ្យគេបម្រើដោយកាមគុណទាំង៥ គឺដោយរូបដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ដោយសំឡេងដែលគប្បីដឹងដោយសោតៈ ។ បេ ។ ដោយក្លិនដែលគប្បីដឹងដោយឃានៈ ។ បេ ។ ដោយរសដែលគប្បីដឹងដោយជិវ្ហា ។ បេ ។ ដោយផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីគាប់ចិត្ត ជាទីត្រេកអរ មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ។ លុះតទៅក្រោយមក តថាគតនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតផង នូវសេចក្ដីវិនាសផង នូវសេចក្ដីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់កាមទាំងឡាយ តាមសេចក្ដីពិតហើយ ក៏លះបង់នូវសេចក្ដីប្រាថ្នាក្នុងកាម បន្ទោបង់នូវសេចក្ដីក្ដៅក្រហាយក្នុងកាម ប្រាសចាកសេចក្ដីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់តាំងនៅក្នុងសន្តានសម្រាន្តនៅ ។ តថាគតនោះឃើញនូវសត្វទាំងឡាយឯទៀត

កាមេសុ អវីតរាគេ កាមតណ្ហាហិ ខជ្ជមានេ កាមបរិឡាហេន បរិឌយ្ហមានេ កាមេ បដិសេវន្តេ សោ តេសំ ន បិហេមិ ន តត្ថ អភិរមាមិ តំ កិស្ស ហេតុ យា យំ មាគណ្ឌិយ រតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ អបិ ទិព្វំ សុខំ សមធិគយ្ហ តិដ្ឋតិ តាយ រតិយា រមមានោ ហីនស្ស ន បិហេមិ ន តត្ថ អភិរមាមិ ។

[៤៤] សេយ្យថាបិ មាគណ្ឌិយ កុដ្ឋី បុរិសោ អរុគត្តោ បក្កគត្តោ កិមីហិ ខជ្ជមានោ នខេហិ វណមុខានិ វិប្បតច្ឆមានោ អង្គារកាសុយា កាយំ បរិតាបេយ្យ តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋាបេយ្យុំ តស្ស សោ ភិសក្កោ សល្លកត្តោ ភេសជ្ជំ ករេយ្យ សោ ភេសជ្ជំ(១) អាគម្ម កុដ្ឋេហិ បរិមុច្ចេយ្យ អរោគោ អស្ស សុខី សេរី សយំវសី យេនកាមង្គមោ ។ សោ អញ្ញំ កុដ្ឋិំ បុរិសំ បស្សេយ្យ អរុគត្តំ បក្កគត្តំ កិមីហិ ខជ្ជមានំ

១- ម. ឧ. តំ ភេសជ្ជំ ។



មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ី ក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយព្រោះកាម កំពុងសេពកាម តថាគតនោះ មិនប្រាថ្នាពួកជននោះ មិនត្រេកអរក្នុងការសេពកាមនោះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលមាគណ្ឌិយៈ ព្រោះថាកាលបុគ្គលត្រេកអរ ដោយសេចក្តីត្រេកអរ វៀរលែងចាកកាម វៀរលែងចាកអកុសលធម៌ ទោះបីនៅប្រកាន់សុខជាទិព្វនៅឡើយ ក៏ទៅជាអ្នកថោកថយ (ព្រោះហេតុដូច្នោះ) តថាគតទើបមិនប្រាថ្នា មិនត្រេកអរក្នុងការសេពកាម នោះឡើយ ។

[៤៤] ម្នាលមាគណ្ឌិយៈ ដូចជាបុរសឃ្លង់មានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី កោសមុខដំបៅដោយក្រចកទាំងឡាយ ដុតកាយដោយរងើកភ្លើង ពួកមិត្តអាមាត្យទាំងញាតិសាលោហិត របស់បុរសឃ្លង់នោះ គប្បីឲ្យពេទ្យអ្នកវះចូលទៅថែរក្សា ពេទ្យវះនោះក៏បានធ្វើថ្នាំដល់បុរសនោះ បុរសនោះក៏បានជាស្បើយរោគឃ្លង់ ព្រោះអាស្រ័យថ្នាំ (នោះ) ជាបុគ្គលឥតរោគ សុខសប្បាយ នៅជាសេរីភាពបាន នៅតាមអំណាចខ្លួនឯងបាន ទៅណាមកណា បានតាមប្រាថ្នា ។ បុរសឃ្លង់នោះ បានឃើញបុរសឃ្លង់ឯទៀត ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី

នខេហិ វណមុខានិ វិប្បតច្ឆមានំ អង្គារកាសុយា បរិតាបេន្តំ(១) ។ តំ កឹ មញ្ញសិ មាគណ្ឌិយ អបិ នុ សោ បុរិសោ អមុស្ស កុដ្ឋិស្ស បុរិសស្ស បិហេយ្យ អង្គារកាសុយា វា ភេសជ្ជំ បដិសេវនាយ វាតិ ។ នោ ហេតំ ភោ គោតម តំ កិស្ស ហេតុ រោគេ ហិ ភោ គោតម សតិ ភេសជ្ជេន ករណីយំ ហោតិ រោគេ អសតិ ភេសជ្ជេន ករណីយំ ន ហោតីតិ ។ ឯវមេវ ខោ អហំ មាគណ្ឌិយ បុព្វេ អគារិយភូតោ សមានោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេសឹ ចក្ខុវិញ្ញេយ្យេហិ រូបេហិ ឥដ្ឋេហិ កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ សោតវិញ្ញេយ្យេហិ សទ្ទេហិ ។ បេ ។ ឃានវិញ្ញេយ្យេហិ គន្ធេហិ ។ បេ ។ ជិវ្ហាវិញ្ញេយ្យេហិ រសេហិ ។ បេ ។ កាយវិញ្ញេយ្យេហិ ផោដ្ឋព្វេហិ ឥដ្ឋេហិ

១ ឱ. ម. កាយំ បរិតាបេន្តំ ។



ខ្វារបួសដំបៅដោយក្រចកទាំងឡាយ កំពុងឆ្អើរកាយលើរងើកភ្លើង ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្តេច តើបុរសនោះ ប្រាថ្នាបុរសឃ្លង់ឯណោះ ដែលកំពុងឆ្អើរកាយលើរងើកភ្លើង ឬកំពុងផឹកថ្នាំដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនប្រាថ្នាទេ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចំរើន ព្រោះកាលបើរោគមានហើយ កិច្ចដែលត្រូវការដោយថ្នាំក៏ត្រូវមាន កាលបើរោគមិនមានហើយ កិច្ចដែលត្រូវការដោយថ្នាំក៏មិនត្រូវមាន ។ ម្នាលមាគណ្ឌិយៈ យ៉ាងនោះមែនហើយ កាលពីដើម តថាគតនៅជាគ្រហស្ថនៅឡើយ ធ្លាប់ស្កប់ស្កល់មូលមិត្តឲ្យគេបម្រើដោយកាមគុណ ទាំង៥ គឺដោយរូបទាំងឡាយដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ដោយសំឡេងទាំងឡាយ ដែលគប្បីដឹងដោយសោតៈ ។ បេ ។ ដោយក្លិនទាំងឡាយដែលគប្បីដឹងដោយឃានៈ ។ បេ ។ ដោយរសទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយជិវ្ហា ។ បេ ។ ដោយផោដ្ឋព្វទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា

កន្តេហិ មនាបេហិ បិយរូបេហិ កាមូបសញ្ហិតេហិ រជនីយេហិ ។ សោ អបរេន សមយេន កាមានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា កាមតណ្ហំ បហាយ កាមបរិឡាហំ បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ វិហរាមិ ។ សោ អញ្ញេ សត្តេ បស្សាមិ កាមេសុ អវីតរាគេ កាមតណ្ហាហិ ខជ្ជមានេ កាមបរិឡាហេន បរិឌយ្ហមានេ កាមេ បដិសេវន្តេ សោ តេសំ ន បិហេមិ ន តត្ថ អភិរមាមិ ។ តំ កិស្ស ហេតុ យា ហាយំ មាគណ្ឌិយ រតិ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហិ អបិ ទិព្វំ សុខំ សមធិគយ្ហ តិដ្ឋតិ តាយ រតិយា រមមានោ ហីនស្ស ន បិហេមិ ន តត្ថ អភិរមាមិ ។



ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ។ លុះគ្រាក្រោយមក តថាគតនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់កាមទាំងឡាយ តាមសេចក្តីពិត ហើយក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងកាមចេញ បន្ទោបង់នូវសេចក្តីក្តៅក្រហាយក្នុងកាមចេញ ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ក្នុងសន្តានសម្រាន្តនៅ ។ តថាគតនោះឃើញនូវសត្វទាំងឡាយឯទៀត មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ កំពុងទំពាស៊ី កំពុងអន្ទះអន្ទែងដោយសេចក្តីក្តៅក្រហាយព្រោះកាម កំពុងសេពកាម តថាគតនោះមិនប៉ងប្រាថ្នាក្នុងជននោះ មិនរីករាយក្នុងការសេពកាមនោះឡើយ សេចក្តីនោះព្រោះហេតុអ្វី មាគណ្ឌិយៈ ព្រោះជាកាលបុគ្គលត្រេកអរ ដោយសេចក្តីត្រេកអរ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាកអកុសលធម៌ទាំងឡាយ ទោះបីនៅប្រកាន់សុខជាទិព្វនៅឡើយ ក៏ទៅជាអ្នកជោគជ័យ ( ព្រោះហេតុនោះ ) តថាគតទើបមិនប្រាថ្នា មិនត្រេកអរក្នុងការសេពកាមនោះឡើយ ។

(២៨) សេយ្យថាបិ មាគណ្ឌិយ កុដ្ឋី បុរិសោ អរុគត្តោ បក្កគត្តោ កិមីហិ ខជ្ជមានោ នខេហិ វណមុខានិ (១) វិប្បតច្ឆមានោ អង្គារកាសុយា បរិតាបេយ្យ (២) តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋាបេយ្យុំ តស្ស សោ ភិសក្កោ សល្លកត្តោ ភេសជ្ជំ ករេយ្យ សោ ភេសជ្ជំ អាគម្ម កុដ្ឋេហិ បរិមុច្ចេយ្យ អរោគោ អស្ស សុខី សេរី សយំវសី យេនកាមង្គមោ ។ តមេនំ ទ្វេ ពលវន្តោ បុរិសា នានាពាហាសុ គហេត្វា អង្គារកាសុយា (៣) ឧបកឌ្ឍេយ្យុំ ។ តំ កឹ មញ្ញសិ មាគណ្ឌិយ អបិ នុ សោ បុរិសោ ឥតិ ចិតិ ចេវ កាយំ សន្នាមេយ្យាតិ ។ ឯវំ ភោ គោតម ។ តំ កិស្ស ហេតុ ។ អសុ ហិ ភោ គោតម អគ្គិ ទុក្ខសម្ផស្សោ ចេវ មហាភិតាបោ ច មហាបរិឡាហោ ចាតិ ។ តំ កឹ មញ្ញសិ មាគណ្ឌិយ ឥទានិ ចេវ (៤) នុ ខោ សោ អគ្គិ ទុក្ខសម្ផស្សោ ចេវ

១ ម. វណមុខានិ ។ ២ ម. ម. កាយំ បរិតាបេយ្យ ។ ៣ ម. អង្គារកាសុំ ។ ៤ ម. ម. ឥទានេវ ។



(២៨) ម្នាលមាគណ្ឌិយៈ ដូចបុរសឃ្លង់មានខ្លួនដំបៅ មានខ្លួនហើមស្អុយ ពួកដង្កូវកំពុងតែស៊ី ខារមុខដំបៅដោយក្រចកទាំងឡាយ ឆ្អើរកាយលើរងើកភ្លើង ពួកមិត្តអាមាត្យនិងញាតិសាលោហិត របស់បុរសឃ្លង់នោះ បានឲ្យពេទ្យអ្នកវះដែកកា ពេទ្យនោះក៏ធ្វើថ្នាំឲ្យបុរសនោះ បុរសនោះក៏បានជាស្រឡះស្បើយចាករោគឃ្លង់ ព្រោះបានអាស្រ័យថ្នាំ (នោះ) ជាមនុស្សឥតរោគ មានសេចក្តីសុខជាសេរីភាព នៅតាមចំណង់ខ្លួនឯងបាន ទៅណាមកណាបានតាមប្រាថ្នា ។ បុរសពីរនាក់មានកំឡាំង ចាប់បុរសនោះ ត្រង់ដើមដៃម្ខាងម្នាក់ ៗ អូសយកទៅឆ្អើរលើរងើកភ្លើង ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្តេច ចុះបុរសឃ្លង់នោះ បន្ទន់កាយតាមទៅដូច្នេះផង ដូច្នេះផងដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន យ៉ាងហ្នឹងមែនហើយ សេចក្តីនោះ ព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចំរើន ព្រោះថាភ្លើងមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយខ្លាំងផង រោលរាលខ្លាំងពន់ពេកណាស់ផង ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្តេច ចុះភ្លើងនោះមានសម្ផស្សជាទុក្ខផង

មហាភិតាបោ ច មហាបរិឡាហោ ច ឯតរហិ បុព្វេ សោ អគ្គិ ទុក្ខសម្ផស្សោ ចេវ មហាភិតាបោ ច មហាបរិឡាហោ ចាតិ ។ ឯតរហិ ចេវ ភោ គោតម សោ អគ្គិ ទុក្ខសម្ផស្សោ ចេវ មហាភិតាបោ ច មហាបរិឡាហោ ច បុព្វេ សោ អគ្គិ ទុក្ខសម្ផស្សោ ចេវ មហាភិតាបោ ច មហាបរិឡាហោ ច អយំ ច[1] ភោ គោតម កុដ្ឋី បុរិសោ អរុគត្តោ បក្កគត្តោ កិមីហិ ខជ្ជមានោ នខេហិ វណមុខានិ វិប្បតច្ឆមានោ ឧបហតិន្ទ្រិយោ ទុក្ខសម្ផស្សេយេវ អគ្គិស្មឹ សុខមិតិ វិបរីតសញ្ញំ បច្ចលត្ថាតិ ។ ឯវមេវ ខោ មាគណ្ឌិយ អតីតម្បិ អទ្ធានំ កាមា ទុក្ខសម្ផស្សា ចេវ មហាភិតាបា ច មហាបរិឡាហា[2] ច អនាគតម្បិ អទ្ធានំ កាមា ទុក្ខសម្ផស្សា ចេវ មហាភិតាបា ច មហាបរិឡាហា ច ឯតរហិបិ បច្ចុប្បន្នំ អទ្ធានំ កាមា ទុក្ខសម្ផស្សា

១ ម. អយុ ហិ ខោ ។ ២ ម. កាមា ទុក្ខសម្ផស្សោ ចេវ មហាភិតាបោ ច មហាបរិឡាហោ ចាតិ ទិស្សន្តិ ។



ក្តៅក្រហាយខ្លាំងផង ក្រហល់ក្រហាយខ្លាំងផង តែក្នុងកាលឥឡូវនេះផង ឬក៏កាលពីដើមមក ភ្លើងនោះមានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំងផង ក្រហល់ក្រហាយខ្លាំងដែរ ។ បពិត្រព្រះគោតមដ៏ចំរើន ក្នុងកាលឥឡូវនេះ ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ក្រហល់ក្រហាយខ្លាំងដែរ ពីដើមរហូត ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ក្រហល់ក្រហាយខ្លាំងដូចគ្នា បពិត្រព្រះគោតមដ៏ចំរើន ចំណែកខាងបុរសឃ្លង់ឯណោះ ដែលមានខ្លួនដំបៅ មានខ្លួនរលួយស្អុយ ដង្កូវតាំងខ្សាយក៏កុងជញ្ជក់ស៊ី ខារមុខដំបៅដោយក្រចកទាំងឡាយ មានឥន្ទ្រិយដែលរោគនោះកំចាត់បង់ហើយ ក៏មានសេចក្តីសំគាល់ខុស ក្នុងភ្លើងដែលមានសម្ផស្សជាទុក្ខ (នោះ) ថាជាសុខស្រួលវិញ ។ ម្នាលមាគណ្ឌិយៈ យ៉ាងហ្នឹងមែនហើយ ក្នុងអតីតកាលយូរអង្វែងមកហើយ កាមទាំងឡាយមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយខ្លាំងផង ក្រហល់ក្រហាយខ្លាំងផង ក្នុងអនាគតទៅមុខ កាមទាំងឡាយមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយផង ក្រហល់ក្រហាយខ្លាំងផង ក្នុងបច្ចុប្បន្នឥឡូវនេះសោត កាមទាំងឡាយក៏មានសម្ផស្សជា ទុ-

ចេវ មហាភិតាបា ច មហាបរិឡាហា ច ។ ឥមេ ច មាគណ្ឌិយ សត្តា កាមេសុ អវីតរាគា កាមតណ្ហាហិ ខជ្ជមានា កាមបរិឡាហេន បរិឌយ្ហមានា ឧបហតិន្ទ្រិយា ទុក្ខសម្ផស្សេសុយេវ(១) កាមេសុ សុខមិតិ វិបរីតសញ្ញំ បច្ចលត្ថុំ ។

(៤៦) សេយ្យថាបិ មាគណ្ឌិយ កុដ្ឋី បុរិសោ អរុគត្តោ បក្កគត្តោ កិមីហិ ខជ្ជមានោ នខេហិ វណមុខានិ វិប្បតច្ឆមានោ អង្គារកាសុយា កាយំ បរិតាបេតិ យថា យថា ខោ(២) មាគណ្ឌិយ អសុ កុដ្ឋី បុរិសោ អរុគត្តោ បក្កគត្តោ កិមីហិ ខជ្ជមានោ នខេហិ វណមុខានិ វិប្បតច្ឆមានោ អង្គារកាសុយា កាយំ បរិតាបេតិ តថា តថាស្សុ(៣) តានិ វណមុខានិ អសុចិតរានិ ចេវ ហោន្តិ ទុគ្គន្ធតរានិ ច បូតិកតរានិ ច ហោតិ ចេវ កាចិ សាតមត្តា អស្សាទមត្តា យទិទំ វណមុខានំ កណ្ឌូវណហេតុ(៤) ឯវមេវ ខោ មាគណ្ឌិយ សត្តា កាមេសុ អវីតរាគា កាមតណ្ហាហិ ខជ្ជមានា

១. ទុក្ខសម្ផស្សេសុ ។ ម. ទុក្ខសម្ផស្សេសុយេវ ។ ២. ខោ ។ ៣. ម. តថា តថាស្ស ។ ៤. វណមុខានំ កណ្ឌុវណហេតុ ។



ក្ដៅក្រហាយខ្លាំងពន់ពេកពេកខ្លាំងដូច្នោះដែរ ម្នាលមាគណ្ឌិយៈ ចំណែកពួកសត្វទាំងនេះ មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ី រោលរាលដោយសេចក្ដីក្ដៅក្រហាយ ព្រោះកាម មានឥន្ទ្រិយត្រូវកាមគាត់បង់ហើយ ក៏មានសេចក្ដីសំគាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សជាទុក្ខ ថាជាសុខវិញ ។

(៤៦) ម្នាលមាគណ្ឌិយៈ ដូចបុរសឃ្លង់ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងខាំស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ ឡើរដុតកាយលើរណ្ដៅរងើកភ្លើង ម្នាលមាគណ្ឌិយៈ ដូចជាបុរសឃ្លង់ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងខាំស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ ឡើរដុតកាយលើរណ្ដៅរងើកភ្លើង យ៉ាងណាមិញ មុខដំបៅទាំងឡាយនោះរបស់បុរសនោះឯង ក៏រឹងរឹតតែមិនស្អាតផង រឹងរឹតតែមានក្លិនអាក្រក់ផង រឹងរឹតតែស្អុយផង តែជាសេចក្ដីត្រេកត្រអាល នឹងសេចក្ដីរីករាយបន្តិចបន្តួចនៅតែមាន ព្រោះហេតុដំបៅដែលខ្លួនខ្វារត្រង់មុខ ក៏យ៉ាងនោះដែរ (សេចក្ដីនេះដូចម្ដេចមិញ) ម្នាលមាគណ្ឌិយៈ ពួកសត្វដែលមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្ដីប្រាថ្នាក្នុងកាមទាំងឡាយកំពុងទំពាស៊ី

កាមបរិឡាហេន បរិឌយ្ហមានា កាមេ បដិសេវន្តិ យថា យថា(១) មាគណ្ឌិយ សត្តា កាមេសុ អវីតរាគា កាមតណ្ហាហិ ខជ្ជមានា កាមបរិឡាហេន បរិឌយ្ហមានា កាមេ បដិសេវន្តិ តថា តថា តេសំ សត្តានំ កាមតណ្ហា ចេវ បវឌ្ឍតិ កាមបរិឡាហេន បរិឌយ្ហន្តិ ចេវ ហោតិ ចេវ កាចិ សាតមត្តា អស្សាទមត្តា យទិទំ បញ្ច កាមគុណេ បដិច្ច ។

(៤៧) តំ កឹ មញ្ញសិ មាគណ្ឌិយ អបិ នុ តេ ទិដ្ឋោ វា សុតោ វា រាជា វា រាជមហាមត្តោ វា បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារយមានោ កាមតណ្ហំ អប្បហាយ កាមបរិឡាហំ អប្បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ វិហាសិ វា វិហរតិ វា វិហរិស្សតិ វាតិ ។ នោ ហិទំ ភោ គោតម ។ សាធុ មាគណ្ឌិយ មយាបិ ខោ ឯតំ មាគណ្ឌិយ

១. ម. យថា យថា ខោ ។



កំពុងក្រវល់ក្រវាយដោយសេចក្តីក្តៅក្រហាយព្រោះកាម សេពនូវកាមទាំងឡាយ ម្នាលមាគណ្ឌិយៈ សត្វទាំងឡាយមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្តីប្រាថ្នា ក្នុងកាមទាំងឡាយកំពុងទំពាស៊ី កំពុងក្រវល់ក្រវាយដោយសេចក្តីក្តៅក្រហាយព្រោះកាម សេពនូវកាមទាំងឡាយ យ៉ាងណាមិញ កាមតណ្ហារបស់សត្វទាំងឡាយនោះ ក៏ចំរើនឡើង សត្វទាំងនោះ ក៏ក្តៅក្រហាយដោយសេចក្តីក្រហាយព្រោះកាម តែជាសេចក្តីត្រេកអរនឹងសេចក្តីពេញចិត្តបន្តិចបន្តួច ក៏នៅមាន ព្រោះអាស្រ័យនូវកាមគុណទាំង ៥ គឺយ៉ាងនោះឯង ។

(៤៧) ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឃើញ ធ្លាប់បានឮព្រះរាជា ឬរាជមហាមាត្យ ដែលកំពុងស្កប់ស្កល់ស្លុងមិត្តឲ្យគេបម្រើដោយកាមគុណទាំង ៥ មិនទាន់លះបង់នូវកាមតណ្ហា មិនទាន់បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ហើយប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ខាងក្នុងសម្រាន្តនៅហើយក្តី កំពុងសម្រេចសម្រាន្តនៅក្តី នឹងសម្រាន្តនៅក្តី ខ្លះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន មិនដែលបានឃើញ មិនដែលបានឮទេ ។ ត្រូវហើយមាគណ្ឌិយៈ ម្នាលមាគណ្ឌិយៈ សេចក្តីនុះសូម្បីតថាគត ក៏

ទេវ ទិដ្ឋំ ឧ សុតំ រាជា វា រាជមហាមត្តោ វា បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារិយមានោ កាមតណ្ហំ អប្បហាយ កាម-បរិឡាហំ អប្បដិវិនោទេត្វា វិគតបិបាសោ អជ្ឈត្តំ វូបសន្តចិត្តោ វិហាសិ វា វិហរតិ វា វិហរិស្សតិ វា ។ អថខោ មាគណ្ឌិយ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា វិគតបិបាសា អជ្ឈត្តំ វូបសន្តចិត្តា វិហាសុំ វា វិហរន្តិ វា វិហរិស្សន្តិ វា សព្វេ តេ កាមានំយេវ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា កាមតណ្ហំ បហាយ កាមបរិឡាហំ បដិវិនោទេត្វា វិគតបិបាសា អជ្ឈត្តំ វូបសន្តចិត្តា វិហាសុំ វា វិហរន្តិ វា វិហរិស្សន្តិ វាតិ ។



ប៉ុន្តែបានឃើញ បានឮថា ព្រះរាជាឬរាជមហាមាត្យ ដែលកំពុងស្កប់ស្កល់ឬលម្អិតឲ្យគេបម្រើដោយកាមគុណទាំង៥ មិនទាន់លះបង់កាម-តណ្ហា មិនទាន់បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ហើយប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់ម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅហើយផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផងដែរ ។ ម្នាលមាគណ្ឌិយៈ ការបើសមណព្រាហ្មណ៍ណា ដែលប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់ម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផង លុះតែពួកសមណព្រាហ្មណ៍ទាំងអស់នោះ ដឹងច្បាស់នូវហេតុកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់កាមទាំងឡាយ តាមសេចក្តីពិត ទើបលះបង់នូវកាមតណ្ហា បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់ម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅហើយផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផងបាន ។

[៦៨] អថខោ ភគវា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

អារោគ្យបរមា លាភា(១) និព្វានំ បរមំ សុខំ
អដ្ឋង្គិកោ ច មគ្គានំ ខេមំ អមតគាមិនន្តិ ។

ឯវំ វុត្តេ មាគណ្ឌិយោ បរិព្វាជកោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ ភោតា គោតមេន អារោគ្យបរមា លាភា(២) និព្វានំ បរមំ សុខន្តិ មយាបិ ខោ ឯតំ(៣) ភោ គោតម សុតំ បុព្វកានំ បរិព្វាជកានំ អាចរិយបាចរិយានំ ភាសមានានំ អារោគ្យបរមា លាភា និព្វានំ បរមំ សុខន្តិ តយិទំ ភោ គោតម សមេតីតិ ។ យំ បន តេ(៤) មាគណ្ឌិយ សុតំ

១-២ អារោគ្យបរម លាភាតិ បាឋោ ទិស្សតិ ។ ឥទន្តុ ឆន្ទានុលោមត្ថំ ឯវមេវ ។ ៣ ម. មយាបេតំ ។ ៤ ម. យំ បន តេ ឯតំ ។ ម. យំ បន តេ តំ ។



[៦៨] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

លាភទាំងឡាយ មានការមិនមានរោគ ប្រសើរបំផុត
ព្រះនិព្វាន ជាសេចក្ដីសុខដ៏ប្រសើរ មគ្គដែលប្រកបដោយ
អង្គ ៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដើរទៅ
កាន់ព្រះនិព្វាន ឈ្មោះអមតៈ ។

កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយបរិព្វាជក ក៏ក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចំរើន មិនធ្លាប់កើតមានទេ ពាក្យដែលព្រះគោតមដ៏ចំរើន ត្រាស់ហើយដោយប្រពៃថា លាភទាំងឡាយ មានការមិនមានរោគ ប្រសើរបំផុត ព្រះនិព្វានជាសេចក្ដីសុខដ៏ឧត្ដម បពិត្រព្រះគោតមដ៏ចំរើន សេចក្ដីនុ៎ះ ខ្ញុំព្រះអង្គសោតធ្លាប់បានស្ដាប់មកអំពីពួកបរិព្វាជកជាន់ដើម ដែលជាអាចារ្យប្រធានលើអាចារ្យពោលថា លាភទាំងឡាយមានការមិនមានរោគ ប្រសើរបំផុត ព្រះនិព្វានជាសេចក្ដីសុខដ៏ឧត្ដមដូច្នេះដែរ បពិត្រព្រះគោតមដ៏ចំរើន ពាក្យនេះសមគ្នាហើយ ។ ម្នាលមាគណ្ឌិយៈ ក៏ពាក្យណាដែលអ្នកធ្លាប់បាន

បុព្វកានំ បរិព្វាជកានំ អាចរិយបាចរិយានំ ភាស-មានានំ អារោគ្យបរមា លាភា និព្វានំ បរមំ សុខន្តិ កតមន្តំ អារោគ្យំ កតមន្តំ និព្វានន្តិ ។ ឯវំ វុត្តេ មាគណ្ឌិយោ បរិព្វាជកោ សកានេវ សុទំ គត្តានិ បាណិនា អនោមជ្ជតិ ឥទន្តំ ភោ គោតម អារោគ្យំ ឥទន្តំ និព្វានំ អហំ(១) ភោ គោតម ឯតរហិ អរោគោ សុខី ន មំ កិញ្ចិ(២) អាពាធតីតិ ។

[៤៩] សេយ្យថាបិ មាគណ្ឌិយ ជច្ចន្ធោ បុរិសោ សោ ន បស្សេយ្យ កណ្ហសុក្កានិ រូបានិ ន បស្សេយ្យ នីលកានិ រូបានិ ន បស្សេយ្យ បីតកានិ រូបានិ ន បស្សេយ្យ លោហិតកានិ រូបានិ ន បស្សេយ្យ មញ្ជេដ្ឋិកានិ រូបានិ ន បស្សេយ្យ សមវិសមំ ន បស្សេយ្យ តារករូបានិ ន បស្សេយ្យ ចន្ទិមសុរិយេ ។ សោ សុណេយ្យ ចក្ខុមតោ ភាសមានស្ស ឆេកំ វត ភោ ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ។ សោ ឱទាតបរិយេសនំ ចរេយ្យ តមេនំ

១ ឱ. អហំ ហិ ។ ម. សមញ្ញា ។ ២ ម. ន កិញ្ចិ ។



ស្ដាប់មកអំពីពួកបរិព្វាជកជាន់ដើម ដែលជាអាចារ្យជាប្រចាំនៃអាចារ្យ ពោលថា លាភទាំងឡាយ មានការមិនមានរោគ ប្រសើរបំផុត ព្រះនិព្វាន ជាសេចក្ដីសុខដ៏ឧត្ដមដូច្នេះ ពាក្យថា ការមិនមានរោគ នោះ តើដូចម្ដេច ពាក្យថា ព្រះនិព្វាននោះ តើដូចម្ដេច ។ បានឮថា កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយបរិព្វាជក ក៏ស្ទាបខ្លួនរបស់ខ្លួនដោយដៃឯងហើយទូលថា បពិត្រព្រះគោតមដ៏ចំរើន នេះឈ្មោះថា ការមិនមានរោគ នេះឈ្មោះថាព្រះនិព្វាន បពិត្រព្រះគោតមដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គជាអ្នកឥតរោគ បានសេចក្ដីសុខ ឥតមានអ្វីមកបៀតបៀនខ្ញុំឡើយ ។

[៤៩] ម្នាលមាគណ្ឌិយ៖ ដូចបុរសខ្វាក់តាំងពីកំណើត បុរសនោះមិនធ្លាប់បានឃើញរូបពណ៌ខ្មៅនិងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌ហង្ស-បាទ មិនឃើញទីស្មើនិងមិនស្មើ មិនឃើញរូបផ្កាយ មិនឃើញព្រះចន្ទនិងព្រះអាទិត្យ ។ បុរសខ្វាក់តាំងពីកំណើតនោះ ឮបុរសមានភ្នែកភ្លឺនិយាយថា អ្នកដ៏ចំរើន យីអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលទេ ។ បុរសខ្វាក់តាំងពីកំណើតនោះ ក៏ដើរស្វែងរកសំពត់ស

អញ្ញតរោ (១) បុរិសោ តេលមសិកតេន សាហុឡិចីរេន វញ្ចេយ្យ ឥទន្តេ អម្ភោ បុរិស ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ។ សោ តំ បដិគ្គណ្ហេយ្យ បដិគ្គហេត្វា បារុបេយ្យ បារុបេត្វា អត្តមនោ អត្តមនវាចំ និច្ឆារេយ្យ ឯតំ វត ភោ ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ។ តំ កឹ មញ្ញសិ មាគណ្ឌិយ អបិ នុ សោ ជច្ចន្ធោ បុរិសោ ជានន្តោ បស្សន្តោ អមុំ តេលមសិកតំ សាហុឡិចីរំ បដិគណ្ហេយ្យ បដិគ្គហេត្វា បារុបេយ្យ បារុបេត្វា អត្តមនោ អត្តមនវាចំ និច្ឆារេយ្យ ឯតំ វត ភោ ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ឧទាហុ ចក្ខុមតោ សទ្ធាយាតិ ។ អជានន្តោ ហិ ភោ គោតម អបស្សន្តោ អសុ សោ (២) ជច្ចន្ធោ បុរិសោ អមុំ តេលមសិកតំ សាហុឡិចីរំ បដិគ្គណ្ហេយ្យ

១ ម. អាមគព្ភគោ ។ ២ ម. ឥស្សុ ។ ម. តេហ ។



បុរសម្នាក់យកសំពត់ក្រាស់ ដែលធ្វើដោយរោមខៀវទៅ ជ្រលក់ដោយប្រេងលាយប្រេង មកបញ្ឆោតបុរសនោះថា នែបុរសដ៏ចំរើន នេះឯងសំពត់សល្អស្អាត ឥតមានមន្ទិល របស់អ្នកឯង ។ បុរសខ្វាក់ពីកំណើតនោះ ក៏ទទួលយកសំពត់នោះ លុះទទួលហើយយកទៅដណ្តប់ លុះដណ្តប់ហើយ ក៏បញ្ចេញវាចាជាគ្រឿងរីករាយរបស់ខ្លួនថា យីអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់សេចក្តីនោះ ដូចម្តេច តើបុរសខ្វាក់ពីកំណើតនោះ តើដឹងឃើញម្តេច បានជាទទួលសំពត់ក្រាស់ ដែលធ្វើដោយរោមខៀវទៅ ជ្រលក់ប្រេង លាយប្រេងឯណោះ លុះទទួលហើយ យកមកដណ្តប់ ដណ្តប់ហើយ បញ្ចេញវាចាជាគ្រឿងរីករាយរបស់ខ្លួនថា យីអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ឬក៏ដោយជឿតាមបុរសមានភ្នែកភ្លឺទេ ។ បពិត្រព្រះគោតមដ៏ចំរើន បើបុរសមិនដឹងមិនបានឃើញទេ បុរសខ្វាក់ពីកំណើតឯណោះ ទទួលសំពត់សាច់ក្រាស់ដែលធ្វើដោយរោមខៀវទៅ ជ្រលក់ដោយប្រេង លាយប្រេងឯណោះ លុះ

បដិគ្គហេត្វា ធាតុបេយ្យ ធាតុបេត្វា អត្តមនោ អត្តមន-ភាវំ និវេទយ្យ ទេសំ វត ភោ ឧបាតិ វត្តុំ អភិរូបំ និម្មលំ សុចិន្តិ ឧទាហុ(១) ចក្ខុមតោ សទ្ធាយាតិ ។ ឯវមេវ ខោ មាគណ្ឌិយ អញ្ញតិត្ថិយា បរិព្វាជកា អន្ធា អចក្ខុកា អជានន្តា អារោគ្យំ អបស្សន្តា និព្វានំ អថ ច បនិមំ គាថំ ភាសន្តិ អារោគ្យបរមា លាភា និព្វានំ បរមំ សុខន្តិ ។ បុព្វកេហេសា មា-គណ្ឌិយ អរហន្តេហិ សម្មាសម្ពុទ្ធេហិ គាថា ភាសិតា

អារោគ្យបរមា លាភា និព្វានំ បរមំ សុខំ
អដ្ឋង្គិកោ ច មគ្គានំ ខេមំ អមតគាមិនន្តិ

ឯសា(២) ឯតរហិ អនុបុព្វេន បុថុជ្ជនគាថា ។ អយំ ខោ(៣) មាគណ្ឌិយ កាយោ រោគភូតោ គណ្ឌភូតោ សល្លភូតោ អឃភូតោ អាពាធភូតោ

១ ម. ម. ឧទាហុសក្ខិ ។ ២ ម. ម. សា ។ ៣ ម. ម. អយំ ហិ ខោ ។

៨៣


ទទួលហើយក៏ស្លៀកដណ្តប់ លុះដណ្តប់ហើយ បញ្ចេញភាពជាគ្រឿងរីករាយរបស់ខ្លួនថា អើអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ដោយជឿតាមបុគ្គលមានភ្នែកភ្លឺ ( សេចក្តីនេះយ៉ាងណា ) ម្នាលមាគណ្ឌិយៈ ពួកបរិព្វាជក ជាអន្យតិរ្ថិយ ស្មើដោយមនុស្សខ្វាក់ ឥតមានចក្ខុ មិនដឹងនូវការមិនមានរោគ មិនឃើញនូវព្រះនិព្វាន ប៉ុន្តែនាំគ្នាពោលគាថានេះថា លាភទាំងឡាយ មានការមិនមានរោគ ដ៏ប្រសើរបំផុត ព្រះនិព្វាន ជាសុខដ៏ឧត្តម ។ ម្នាលមាគណ្ឌិយៈ គាថានេះ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយជាន់ដើម បានពោលហើយថា

លាភទាំងឡាយ មានការមិនមានរោគ ដ៏ប្រសើរបំផុត
ព្រះនិព្វាន ជាសុខដ៏ឧត្តម មគ្គប្រកបដោយអង្គ ៨ ដ៏ក្សេម
ក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដំណើរ ទៅកាន់ព្រះ
និព្វាន ឈ្មោះអមតៈ

ឥឡូវនេះ គាថានេះ ជាគាថាសម្រាប់បុថុជ្ជនតាមលំដាប់ ។ ម្នាលមាគណ្ឌិយៈ កាយនេះជារោគ ជាបូស ជាកូនសរ ជាទុក្ខ ជាអាពាធ

សោ ត្វំ ឥមំ កាយំ រោគភូតំ គណ្ឌភូតំ សល្លភូតំ អឃភូតំ អាពាធភូតំ ឥទន្តំ ភោ គោតម អារោគ្យំ ឥទន្តំ និព្វានន្តិ វទេសិ ។ តំ ហិ តេ មាគណ្ឌិយ អរិយំ ចក្ខុំ នត្ថិ យេន ត្វំ អរិយេន ចក្ខុនា អារោគ្យំ ជានេយ្យាសិ និព្វានំ បស្សេយ្យាសីតិ ។

[៨០] ឯវំ បសន្នោ អហំ ភោតោ គោតមស្ស បហោតិ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុំ យថាហំ អារោគ្យំ ជានេយ្យំ និព្វានំ បស្សេយ្យន្តិ ។ សេយ្យថាបិ មាគណ្ឌិយ ជច្ចន្ធោ បុរិសោ(១) ន បស្សេយ្យ កណ្ហសុក្កានិ រូបានិ ន បស្សេយ្យ នីលកានិ រូបានិ ន បស្សេយ្យ បីតកានិ រូបានិ ន បស្សេយ្យ លោហិតកានិ រូបានិ ន បស្សេយ្យ មញ្ជិដ្ឋកានិ រូបានិ ន បស្សេយ្យ សមវិសមំ ន បស្សេយ្យ តារករូបានិ ន បស្សេយ្យ ចន្ទិមសុរិយេ ។ តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋាបេយ្យុំ តស្ស សោ ភិសក្កោ សល្លកត្តោ ភេសជ្ជំ ករេយ្យ សោ តំ ភេសជ្ជំ អាគម្ម

១ ឱ. ម. បុរិសោ សោ ។



អ្នកពោលនូវកាយដែលជារោគ ជាបូស ជាកូនសរ ជាទុក្ខ ជាអាពាធ នេះជា បពិត្រព្រះគោតមដ៏ចំរើន នេះឈ្មោះថាការមិនមានរោគ នេះឈ្មោះថាព្រះនិព្វានដូច្នេះវិញ ។ ម្នាលមាគណ្ឌិយៈ អ្នកត្រូវដឹងនូវការមិនមានរោគ ត្រូវឃើញនូវព្រះនិព្វានដោយចក្ខុ(១)ដ៏ប្រសើរណា ចក្ខុប្រសើរនោះ របស់អ្នកមិនមានទេ ។

[៨០] យ៉ាងហ្នឹងហើយ ខ្ញុំព្រះអង្គជ្រះថ្លាព្រះគោតមដ៏ចំរើនហើយ ខ្ញុំព្រះអង្គគប្បីដឹង នូវការមិនមានរោគ យល់នូវព្រះនិព្វានដោយឧបាយណា សូមព្រះគោតមដ៏ចំរើន សំដែងធម៌ដោយឧបាយនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលមាគណ្ឌិយៈ ដូចបុរសខ្វាក់តាំងពីកំណើត បុរសនោះមិនឃើញរូបពណ៌ខ្មៅនិងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌ហង្សបាទ មិនឃើញទីស្មើនិងមិនស្មើ មិនឃើញរូបផ្កាយទាំងឡាយ មិនឃើញព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយទេ ។ មិត្តអាមាត្យញាតិសាលោហិត របស់បុរសខ្វាក់តាំងពីកំណើតនោះ ឲ្យពេទ្យអ្នកកាត់ថែក្សា ពេទ្យអ្នកកាត់ បានធ្វើថ្នាំឲ្យបុរសនោះ បុរសខ្វាក់តាំងពីកំណើតនោះ បានអាស្រ័យថ្នាំនោះ

១ សំដៅយកវិបស្សនាញាណ និងមគ្គញាណ ។ អដ្ឋកថា ។

ន ចក្ខូនិ ឧប្បាទេយ្យ ន[1] ចក្ខូនិ វិសោធេយ្យ ។ តំ កឹ មញ្ញសិ មាគណ្ឌិយ ននុ សោ វេជ្ជោ យាវទេវ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវំ ភោ គោតម ។ ឯវមេវ ខោ មាគណ្ឌិយ អហញ្ចេ តេ ធម្មំ ទេសេយ្យំ ឥទន្តំ អារោគ្យំ ឥទន្តំ និព្វានន្តិ សោ ត្វំ អារោគ្យំ ន ជានេយ្យាសិ និព្វានំ ន បស្សេយ្យាសិ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។

(៨៦) ឯវំ បសន្នោ អហំ ភោតោ គោតមស្ស បហោតិ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុំ យថាហំ អារោគ្យំ ជានេយ្យំ និព្វានំ បស្សេយ្យន្តិ ។ សេយ្យថាបិ មាគណ្ឌិយ ជច្ចន្ធោ បុរិសោ សោ ន បស្សេយ្យ កណ្ហសុក្កានិ រូបានិ ន បស្សេយ្យ នីលកានិ រូបានិ ន បស្សេយ្យ បីតកានិ រូបានិ ន បស្សេយ្យ លោហិតកានិ រូបានិ ន បស្សេយ្យ មញ្ជិដ្ឋកានិ រូបានិ

១ ម. ស្យា. នត្ថិ ។



ហើយ ក៏មិនញុំាងចក្ខុតាំងពីកំណើត ឲ្យកើតឡើង មិនញុំាងចក្ខុតាំងពីកំណើត ឲ្យភ្លឺឡើងវិញបាន ។ ម្នាលមាគណ្ឌិយៈ អ្នកសំគាល់ហេតុនោះដូចម្ដេច ក្រែងលោកពេទ្យនោះគ្រាន់តែបានចំណែកនៃសេចក្ដីលំបាកកាយនឹងចង្អៀតចង្អល់ចិត្តទេឬ ។ បពិត្រព្រះគោតមដ៏ចំរើន យ៉ាងហ្នឹងមែនហើយ ។ ម្នាលមាគណ្ឌិយៈ បើតថាគតនឹងសំដែងធម៌ដល់អ្នកថា នេះជាការមិនមានរោគ នេះជាព្រះនិព្វានមួយនេះ អ្នកក៏មិនដឹងនូវការមិនមានរោគ មិនឃើញនូវព្រះនិព្វាន សេចក្ដីលំបាកនោះក៏នឹងមានដល់តថាគត សេចក្ដីចង្អៀតចង្អល់នោះ ក៏នឹងមានដល់តថាគត មានឧបមេយ្យដូចពេទ្យដែលដូច្នោះឯង ។

(៨៦) យ៉ាងហ្នឹងមែនហើយ ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គគប្បីឃើញនូវការមិនមានរោគ ឃើញព្រះនិព្វានដោយឧបាយណា សូមព្រះគោតមដ៏ចំរើន សំដែងធម៌ដោយឧបាយនោះដល់ខ្ញុំព្រះអង្គចុះ ។ ម្នាលមាគណ្ឌិយៈ ដូចបុរសខ្វាក់តាំងពីកំណើត បុរសខ្វាក់នោះ មិនឃើញរូបពណ៌ខ្មៅនឹងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌

ន បស្សេយ្យ សមវិសមំ ន បស្សេយ្យ តារករូបានិ ន បស្សេយ្យ ចន្ទិមសុរិយេ ។ សោ សុណេយ្យ ចក្ខុមតោ ភាសមានស្ស ឆេកំ វត ភោ ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ។ សោ ឱទាតបរិយេសនំ ចរេយ្យ តមេនំ អញ្ញតរោ បុរិសោ តេលមលិកតេន សាហុឡចីរេន វញ្ចេយ្យ ឥទន្តេ អម្ភោ បុរិស ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ។ សោ តំ បដិគ្គណ្ហេយ្យ បដិគ្គហេត្វា បារុបេយ្យ តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋាបេយ្យុំ តស្ស សោ ភិសក្កោ សល្លកត្តោ ភេសជ្ជំ ករេយ្យ ឧទ្ធំវិរេចនំ អធោវិរេចនំ អញ្ជនំ បច្ចញ្ជនំ នត្ថុកម្មំ ។ សោ តំ ភេសជ្ជំ អាគម្ម ចក្ខូនិ ឧប្បាទេយ្យ ចក្ខូនិ វិសោធេយ្យ តស្ស សហ ចក្ខុប្បាទា យោ អមុស្មិំ (១) តេលមលិកតេ សាហុឡចីរេ ឆន្ទរាគោ សោ បហីយេថ តញ្ចនំ (២) បុរិសំ អមិត្តតោបិ ទហេយ្យ បច្ចត្ថិកតោបិ ទហេយ្យ អបិច

១ ម. ម. អមុស្មឹ ។ ២ ម. ម. តញ្ចនំ ។



ហង្សបាទ មិនឃើញទីស្មើនិងមិនស្មើ មិនឃើញរូបផ្កាយតារាទាំងឡាយ មិនឃើញព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយ ។ បុរសខ្វាក់តាំងពីកំណើតនោះឮបុរសមានភ្នែកភ្លឺនិយាយថា ម្នាលអើ សំពត់សស្អាតល្អបរិសុទ្ធឥតមានមន្ទិលទេ ។ បុរសខ្វាក់តាំងពីកំណើតនោះ ក៏ដើរទៅស្វែងរកសំពត់ស បុរសម្នាក់យកសំពត់សាច់គ្រាស់ ដែលធ្វើដោយកោមចៀមខ្មៅ ប្រឡាក់ដោយខៅប្រេងលាយប្រេង មកបញ្ឆោតបុរសនោះថា នែបុរសដ៏ចំរើន នេះឯងជាសំពត់សល្អបរិសុទ្ធ ឥតមានមន្ទិល របស់អ្នក ។ បុរសខ្វាក់តាំង-ពីកំណើតនោះ ក៏ទទួលសំពត់នោះ យកមកស្លៀកដណ្តប់ មិត្រអាមាត្យញាតិសាលោហិតរបស់បុរសនោះ ឲ្យគេឲ្យអ្នកវះវៃទ្យ ពេទ្យអ្នកវះនោះក៏ធ្វើថ្នាំឲ្យបុរសនោះ គឺថ្នាំធ្វើឲ្យក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ ថ្នាំលាង និងថ្នាំហិត ។ បុរសខ្វាក់តាំងពីកំណើតនោះ លុះបានអាស្រ័យថ្នាំនោះហើយ ក៏បានញុំាងចក្ខុឲ្យកើតឡើង បានញុំាងចក្ខុឲ្យភ្លឺឡើងវិញ បានសេចក្តីពេញចិត្តណា ក្នុងសំពត់សាច់គ្រាស់ ដែលធ្វើដោយកោមចៀមខ្មៅ ប្រឡាក់ដោយខៅប្រេងលាយប្រេងឯណោះ បុរសនោះក៏លះបង់ក្នុងពេលដែលបានជាភ្នែកភ្លឺឡើងវិញ បុរសដែលមានភ្នែកភ្លឺនោះ ក៏ទុកបុរសដែលបញ្ឆោតនោះ ដោយភាពមិនមែនជាមិត្រផង ដោយភាពជាសត្រូវផង មួយ

វិតា វោរោបេតព្វំ មញ្ញេយ្យ ទីឃរត្តំ វត ភោ អហំ ឥមិនា បុរិសេន តេលមសិកតេន សាហុឡចីរេន និក-តោ វញ្ចិតោ បលុទ្ធោ(១) ឥទន្តេ អម្ភោ បុរិស ឱទាតំ វត្ថំ អភិរូបំ និម្មលំ សុចិន្តិ ឯវមេវ ខោ មាគណ្ឌិយ អហញ្ចេ តេ ធម្មំ ទេសេយ្យំ ឥទន្តំ អារោគ្យំ ឥទន្តំ និព្វានន្តិ ។ សោ ត្វំ អារោគ្យំ ជានេយ្យាសិ និព្វានំ បស្សេយ្យាសិ តស្ស តេ សហ ចក្ខុប្បាទា យោ បញ្ចសុបាទា-នក្ខន្ធេសុ ឆន្ទរាគោ សោ បហីយេថ អបិច តេ ឯវ-មស្ស ទីឃរត្តំ វត ភោ អហំ ឥមិនា ចិត្តេន និកតោ វញ្ចិតោ បលុទ្ធោ(២) អហញ្ហិ(៣) រូបំយេវ ឧបាទិយមានោ ឧបាទិយឹ វេទនំយេវ ឧបាទិយមានោ ឧបាទិយឹ សញ្ញំយេវ ឧបាទិយមានោ ឧបាទិយឹ សង្ខារេយេវ(៤) ឧបាទិយមានោ ឧបាទិយឹ វិញ្ញាណំយេវ ឧបាទិយមា-នោ ឧបាទិយឹ តស្ស មេ ឧបាទានបច្ចយា ភវោ

---

១ ២ ម. បលុទ្ធោ ។ ៣. ឱ. អហំ ហិ ។ ៤ ម. សង្ខារេយេវ ។



គប្បីសំគាល់ថាត្រូវសម្លាប់ចោលក៏សឹងតែបាន ដោយគិតថា ឱហ្ន៎ អាត្មាអញត្រូវបុរសនេះ យកសំពត់ក្រាស់ដែលធ្វើដោយរោមចៀមទៅ ជ្រលក់ដោយប្រេងចំណាយប្រេង មកបោកបញ្ឆោតប្រលោម អស់កាលយូរហើយថា នែបុរសដ៏ចំរើន នេះសំពត់សស្អាតល្អបរិសុទ្ធ ឥតមានមន្ទិល របស់អ្នក ( សេចក្តីនេះ យ៉ាងណាវិញ ) ម្នាលមាគណ្ឌិយៈ តថាគតបើនឹងសំដែងធម៌ដល់អ្នកថា នេះជាការមិនមានរោគ នេះជាព្រះនិព្វាន ក៏យ៉ាងដូច្នោះដែរ ។ អ្នកគប្បីដឹងការមិនមានរោគ ឃើញនូវព្រះនិព្វាន ឆន្ទរាគណា ក្នុងឧបាទានក្ខន្ធទាំង ៥ ឆន្ទរាគៈនោះ អ្នកលះបង់បានក្នុងពេលដែលចក្ខុកើតឡើងដល់អ្នក មួយទៀត អ្នកត្រូវមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ចិត្តនេះបោកបញ្ឆោតប្រលោមអាត្មាអញអស់កាលយូរមកហើយ បានជាអាត្មាអញកាលដែលប្រកាន់ ក៏ប្រកាន់ចំពោះរូបហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះវេទនាហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះសញ្ញាហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះសង្ខារហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះវិញ្ញាណហ្នឹងឯង ភពកើតឡើងដល់អាត្មាអញនោះ ព្រោះមានឧបាទាន

ភវប្បច្ចយា ជាតិ ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតីតិ ។

(៨៦) ឯវំ បសន្នោ អហំ ភោតោ គោតមស្ស បហោតិ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុំ យថាហំ ឥមម្ហា អាសនា អនន្ធោ វុដ្ឋហេយ្យន្តិ ។ តេនហិ ត្វំ មាគណ្ឌិយ សប្បុរិសេ ភជេយ្យាសិ យតោ ខោ ត្វំ មាគណ្ឌិយ សប្បុរិសេ ភជិស្សសិ តតោ ត្វំ មាគណ្ឌិយ សទ្ធម្មំ សោស្សសិ យតោ ខោ ត្វំ មាគណ្ឌិយ សទ្ធម្មំ សោស្សសិ តតោ ត្វំ មាគណ្ឌិយ ធម្មានុធម្មំ បដិបជ្ជិស្សសិ យតោ ខោ ត្វំ មាគណ្ឌិយ ធម្មានុធម្មំ បដិបជ្ជិស្សសិ តតោ ត្វំ មាគណ្ឌិយ សាមំយេវ ញស្សសិ សាមំ ទក្ខិស្សសិ(១) ឥមេ រោគា គណ្ឌា សល្លា ឥធ រោគា គណ្ឌា សល្លា អបរិសេសា និរុជ្ឈន្តិ តស្ស មេ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា

១ ម. ទក្ខិស្សសិ ។ ឧ. ភក្ខិស្សសិ ។



ជាបច្ច័យ ជាតិកើតឡើងព្រោះមានភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្សនឹងសេចក្តីចង្អៀតចង្អល់ចិត្ត កើតឡើងព្រោះមានជាតិជាបច្ច័យ ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតឡើងដោយប្រការយ៉ាងនេះ ។

(៨៦) ខ្ញុំព្រះអង្គជ្រះថ្លា ចំពោះព្រះគោតមដ៏ចម្រើនយ៉ាងនេះ ខ្ញុំព្រះអង្គលែងខ្វាក់ គប្បីក្រោកអំពីអាសនៈនេះបាន យ៉ាងណា សូមព្រះគោតមដ៏ចម្រើន សំដែងធម៌យ៉ាងនោះ ដល់ខ្ញុំព្រះអង្គចុះ ។ ម្នាលមាគណ្ឌិយៈ បើដូច្នោះចូរអ្នកសេពគប់នឹងពួកសប្បុរស ម្នាលមាគណ្ឌិយៈ កាលណាអ្នកសេពគប់នឹងពួកសប្បុរសហើយ ម្នាលមាគណ្ឌិយៈ កាលនោះអ្នកនឹងបានស្តាប់នូវព្រះសទ្ធម្ម ម្នាលមាគណ្ឌិយៈ កាលណាអ្នកស្តាប់ព្រះសទ្ធម្មហើយ ម្នាលមាគណ្ឌិយៈ កាលនោះ អ្នកនឹងបានប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ម្នាលមាគណ្ឌិយៈ កាលណាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ហើយ ម្នាលមាគណ្ឌិយៈ កាលនោះអ្នកនឹងដឹងដោយខ្លួនឯង នឹងឃើញច្បាស់ដោយខ្លួនឯងថា នេះជារោគ នេះជាបូស នេះជាកូនសរ រោគបូសនឹងកូនសរ រមែងរលត់ទៅឥតមានសេសសល់ក្នុងទីនេះ ការរលត់ទៅនៃភពរបស់អាត្មាអញនោះ ព្រោះរលត់ឧបាទាន

ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតីតិ ។

(៤៣) ឯវំ វុត្តេ មាគណ្ឌិយោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភោតោ គោតមស្ស សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ យោ ខោ មាគណ្ឌិយ



ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរាមរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រលត់ទៅ ព្រោះរលត់ជាតិ ការរលត់ទៅនៃកងទុក្ខទាំងអស់នេះ រមែងមានដោយប្រការយ៉ាងនេះ ។

(៤៣) កាលដែលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយ-បរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើន ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលបិទបាំងទុក ឬប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក រមែងមើលឃើញរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះគោតមដ៏ចំរើន ។ ម្នាលមាគណ្ឌិយៈ បុគ្គលណាធ្លាប់

អញ្ញតិត្ថិយបុព្វោ ឥមស្មឹ ធម្មវិនយេ អាកង្ខតិ បព្វជ្ជំ អាកង្ខតិ ឧបសម្បទំ សោ ចត្តារោ មាសេ បរិវសតិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ ភិក្ខុភាវាយ អបិច មេត្ថ បុគ្គលវេមត្តតា វិទិតាតិ ។ សចេ ភន្តេ អញ្ញតិត្ថិយបុព្វា ឥមស្មឹ ធម្មវិនយេ អាកង្ខន្តា បព្វជ្ជំ អាកង្ខន្តា ឧបសម្បទំ ចត្តារោ មាសេ បរិវសន្តិ ចតុន្នំ មាសានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តិ ឧបសម្បាទេន្តិ អហំ ចត្តារិ វស្សានិ បរិវសិស្សាមិ ចតុន្នំ វស្សានំ អច្ចយេន អារទ្ធចិត្តា ភិក្ខូ បព្វាជេន្តុ ឧបសម្បាទេន្តុ ភិក្ខុភាវាយាតិ ។ អលត្ថ ខោ មាគណ្ឌិយោ បរិព្វាជកោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អចិរូបសម្បន្នោ ខោ បនាយស្មា មាគណ្ឌិយោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ



ជាអន្យតិរ្ថិយមកពីមុន ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះ ត្រូវនៅបរិវាសអស់ ៤ ខែសិន លុះកន្លង៤ខែហើយ ពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បីភាពជាភិក្ខុបាន មួយទៀត វេមត្តភាពរបស់បុគ្គលផ្សេងគ្នា ( ការដែលនៅបរិវាសឬមិននៅបរិវាស ) ក្នុងរឿងនេះ គឺជាគតិដ៏ច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើបុគ្គលធ្លាប់ជាអន្យតិរ្ថិយមកពីមុន ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ ត្រូវនៅបរិវាសអស់ ៤ ខែសិន លុះកន្លង៤ខែហើយ ពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទាបាន ខ្ញុំព្រះអង្គនឹងនៅបរិវាសអស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមឲ្យភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បីភាពជាភិក្ខុចុះ ។ មាគណ្ឌិយបរិព្វាជក បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លុះមាគណ្ឌិយៈមានអាយុ ឧបសម្បទាហើយមិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទព្យាយាមដុតកំដៅកិលេស បញ្ជូនចិត្តទៅកាន់ព្រះនិព្វាន

ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា មាគណ្ឌិយោ អរហតំ អហោសីតិ ។

មាគណ្ឌិយសុត្តំ បញ្ចមំ និដ្ឋិតំ ។



មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវគុណវិសេសដ៏ប្រសើរ ដ៏ជាទីបំផុតនៃព្រហ្មចរិយៈ ដែលពួកកុលបុត្រចេញចាកផ្ទះដោយប្រពៃ ហើយបួសក្នុងភេទនៃបុគ្គលមិនមានផ្ទះដើម្បីសេចក្ដីត្រូវការហើយសម្រេចសម្រាន្តនៅ បានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើបាន ធ្វើស្រេចហើយ កិច្ចដទៃដើម្បីកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ មាគណ្ឌិយៈ មានអាយុ ក៏បានជាព្រះអរហន្តមួយអង្គដែរ ។

ចប់ មាគណ្ឌិយសូត្រ ទី៥ ។

## ៦. សន្ទកសុត្តំ

[៥៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន សន្ទកោ បរិព្វាជកោ បិលក្ខគុហាយំ បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធិំ បញ្ចមត្តេហិ បរិព្វាជកសតេហិ ។ អថខោ អាយស្មា អានន្ទោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ ភិក្ខូ អាមន្តេសិ អាយាមាវុសោ យេន ទេវកដ-សោព្ភោ តេនុបសង្កមិស្សាម គុហាទស្សនាយាតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ អានន្ទស្ស បច្ចស្សោសុំ ។ អថខោ អាយស្មា អានន្ទោ សម្ពហុលេហិ ភិក្ខូហិ សទ្ធិំ យេន ទេវកដសោព្ភោ តេនុបសង្កមិ ។ តេន ខោ បន សមយេន សន្ទកោ បរិព្វាជកោ មហតិយា បរិព្វាជកបរិសាយ សទ្ធិំ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ[១] អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជ-កថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ

១ ម. ឧច្ចាសទ្ទាយ មហាសទ្ទាយ ។

## សន្ទកសូត្រ ទី ៦

[៥៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង មានបរិព្វាជកម្នាក់ឈ្មោះសន្ទកៈ នាស្រ័យនៅក្នុងបិលក្ខគុហា[១] ជាមួយនឹងបរិព្វាជកបរិស័ទជាច្រើន ចំនួន ៥០០ នាក់ ។ គ្រានោះ ព្រះអានន្ទមានអាយុ ចេញអំពីទីសម្ងំស្ងាត់ ក្នុងសាយណ្ហសម័យ ហើយបបួលភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយមក យើងនឹងចូលទៅឯក្រាំងឈ្មោះទេវកដៈ (ត្រពាំងទឹកដែលកើតឡើងព្រោះ) ដើម្បីមើលគុហា ។ ពួកភិក្ខុទាំងនោះ ក៏ទទួលពាក្យ របស់ព្រះអានន្ទមានអាយុ ថា ករុណា អាវុសោ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅឯក្រាំងទេវកដៈ ជាមួយនឹងពួកភិក្ខុច្រើនរូប ។ ចួនជាពេលនោះ សន្ទកបរិព្វាជក អង្គុយជាមួយនឹងបរិព្វាជកបរិស័ទជាច្រើន ដែលកំពុងនិយាយតិរច្ឆានកថា ច្រើនបែបច្រើនយ៉ាង ដោយសំឡេងឮ សំឡេងខ្លាំង ទ្រហឹងអឺងកង គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីមហាមាត្យ និយាយអំពីសេនាពាហន និយាយអំពីភ័យ

១ គុហានេះ មានដើមល្វា ដុះនៅក្បែរមាត់ទ្វារ បានជាឲ្យឈ្មោះថា បិលក្ខគុហា ។ អដ្ឋកថា ។

យុទ្ធកថំ អន្នកថំ បានកថំ(១) សយនកថំ មាលា-កថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ កុម្ភទាសិកថំ(២) បុព្វ-បេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខា-យិកំ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ សន្ទកោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ទូរតោវ អាគច្ឆន្តំ ទិស្វាន សកំ បរិសំ សណ្ឋាបេសិ អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ សមណស្ស គោតមស្ស សាវកោ អាគច្ឆតិ សមណោ អានន្ទោ យាវតា ខោ បន សមណស្ស គោតមស្ស សាវកា កោសម្ពិយំ បដិវសន្តិ

១ ឱ. ម. ឯត្ថន្តរេ វត្ថកថំ ទិស្សតិ ។ ២ ឱ. ម. កុម្ភទាសិកថំ ន ទិស្សតិ ។



(ពីសង្គ្រាមជាដើម) និយាយអំពីចង្ហាន់ និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីក្រុង និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីមនុស្សក្លៀវក្លា និយាយអំពីច្រកល្ហក និយាយអំពីកំពង់ទឹក និយាយអំពីកុម្ភទាសី និយាយអំពីញាតិ ដែលស្លាប់ទៅកាន់បរលោក និយាយអំពីរឿងផ្សេង ៗ ដែលឥតប្រយោជន៍ និយាយអំពីលោក (រឿងកុហកក្នុងលោក) និយាយអំពីសមុទ្រ និយាយអំពីភវៈ និងអភវៈ(១) ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ៗ ។ សន្ទកបរិព្វាជក ក៏បានឃើញព្រះអានន្ទ មានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយក៏បញ្ឈប់បរិស័ទរបស់ខ្លួនថា អ្នកដ៏ចំរើនទាំងឡាយ ចូរនិយាយតិច ៗ អ្នកដ៏ចំរើនទាំងឡាយ កុំមាត់ឡើយ (ស្ងៀម) សមណៈឈ្មោះអានន្ទនេះ ជាសាវ័ករបស់ព្រះសមណគោតមមកដល់ហើយនេះ ពួកសាវ័កណារបស់ព្រះសមណគោតម ដែលអាស្រ័យនៅក្នុងក្រុងកោសម្ពី

១ ភវៈ គឺសស្សតទិដ្ឋិ អភវៈ គឺឧច្ឆេទទិដ្ឋិ មួយយ៉ាងទៀត ភវៈគឺសេចក្ដីចំរើន អភវៈគឺសេចក្ដីសាបសូន្យ ឬ ភវៈ គឺសេចក្ដីសុខក្នុងកាម អភវៈ គឺសេចក្ដីព្យាយាម ធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ ។ អដ្ឋកថា ។

អយន្តេសំ (១) អញ្ញតរោ សមណោ អានន្ទោ អប្បសទ្ទកាមា ខោ បន តេ អាយស្មន្តោ អប្បសទ្ទវិនីតា អប្បសទ្ទស្ស វណ្ណវាទិនោ អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ អថ ខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។ អថ ខោ អាយស្មា អានន្ទោ យេន ភវំ សន្ទកោ បរិព្វាជកោ តេនុបសង្កមិ ។ អថ ខោ បន សន្ទកោ (២) បរិព្វាជកោ អាយស្មន្តំ អានន្ទំ ឯតទវោច ឯតុ ខោ ភវំ អានន្ទោ ស្វាគតំ (៣) ភោតោ អានន្ទស្ស ចិរស្សំ ខោ ភវំ អានន្ទោ ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភវំ អានន្ទោ ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ខោ អាយស្មា អានន្ទោ បញ្ញត្តេ អាសនេ ។ សន្ទកោបិ ខោ បរិព្វាជកោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។

១ ឱ. ម. អយំ តេសំ ។ ២ ឱ. ម. អថខោ សន្ទកោ ។ ៣ ឱ. សាគតំ ។



បណ្ដាសាវ័កទាំងនោះ អានន្ទនេះឯង លោកជាសមណៈមួយអង្គដែរ ឯពួកលោកមានអាយុទាំងនោះ ចូលចិត្តនៃសំឡេងតិច ៗ និយាយសរសើរនៃសំឡេងតិច ៗ ដែលព្រះសម្ពុទ្ធព្រះអង្គមានសំឡេងតិច [illegible] ហើយ ធ្វើដូចម្ដេច ឲ្យព្រះអានន្ទជ្រាបច្បាស់ថា បរិស័ទមានសំឡេងតិចហើយសំគាល់ថាគួរនឹងចូលមក ។ គ្រានោះ ពួកបរិព្វាជកទាំងនោះក៏ស្ងាត់ស្ងៀម ។ ពេលនោះឯង ព្រះអានន្ទមានអាយុ និមន្តចូលទៅរកទីដែលសន្ទកបរិព្វាជកនៅ ។ គ្រានោះ សន្ទកបរិព្វាជក និយាយពាក្យនេះ នឹងព្រះអានន្ទមានអាយុថា ព្រះអានន្ទដ៏ចំរើន ចូរនិមន្តមកចុះ ព្រះអានន្ទដ៏ចំរើន និមន្តមកស្រួលហើយ ព្រះអានន្ទដ៏ចំរើន ទាន់ធ្វើវេណើដើម្បីមកក្នុងទីនេះយូរណាស់ហើយ សូមព្រះអានន្ទដ៏ចំរើនគង់ចុះ នេះអាសនៈដែលយើងក្រាលទុក ។ ព្រះអានន្ទមានអាយុ ក៏គង់លើអាសនៈដែលពួកបរិព្វាជកក្រាលទុក ។ ចំណែកសន្ទកបរិព្វាជក កាន់យកអាសនៈទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។

(៥៨) ឯកមន្តំ និសិន្នំ ខោ សន្ទកំ បរិព្វាជកំ អាយស្មា អានន្ទោ ឯតទវោច កាយ នុត្ថ សន្ទក ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ តិដ្ឋតេសា ភោ អានន្ទ កថា យាយ មយំ ឯតរហិ កថាយ សន្និសិន្នា នេសា ភវតោ អានន្ទស្ស កថា ទុល្លភា ភវិស្សតិ បច្ឆាបិ សវនាយ សាធុ វត ភវន្តំយេវ អានន្ទំ បដិភាតុ សកេ អាចរិយកេ ធម្មីកថាតិ ។ តេនហិ សន្ទក សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សន្ទកោ បរិព្វាជកោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អាយស្មា អានន្ទោ ឯតទវោច ចត្តារោមេ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អព្រហ្មចរិយវាសា អក្ខាតា



(៥៨) លុះសន្ទកបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ព្រះអានន្ទមានអាយុ បានសួរដូច្នេះថា ម្នាលសន្ទកៈ ចុះអម្បាញ់មិញ ពួកអ្នកអង្គុយប្រជុំគ្នា និយាយអំពីរឿងអ្វីដូចម្ដេច ចុះពាក្យជាចន្លោះ (អំពីគុណធម៌) ដូចម្ដេច ដែលពួកអ្នកនិយាយមិនទាន់ចប់ ។ សន្ទកបរិព្វាជក តបថា បពិត្រព្រះអានន្ទដ៏ចំរើន ពាក្យដែលពួកយើងអង្គុយប្រជុំគ្នា និយាយក្នុងកាលអម្បាញ់មិញ ចូរលើកទុកសិនចុះ ព្រោះពាក្យនុ៎ះ ព្រះអានន្ទដ៏ចំរើន មិនបានជាសល់ក្រោយ ទាំងស្ដាប់ក្នុងកាលខាងក្រោយក៏បាន សូមឲ្យតែព្រះអានន្ទដ៏ចំរើន សំដែងធម្មីកថាក្នុងលទ្ធិអាចារ្យរបស់ខ្លួនឲ្យបាន ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ បើដូច្នោះ អ្នកចូរចាំស្ដាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ អាត្មានឹងសំដែង ។ សន្ទកបរិព្វាជក ទទួលតបពាក្យរបស់ព្រះអានន្ទមានអាយុថា ព្រះករុណាលោកដ៏ចំរើន ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនុ៎ះថា ម្នាលសន្ទកៈ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអព្រហ្មចរិយវាសៈ គឺការមិនប្រព្រឹត្តព្រហ្មចរិយៈ

ចត្តារិ ច អនស្សាសិកានិ ព្រហ្មចរិយានិ អក្ខាតានិ យត្ថ វិញ្ញូ បុរិសោ សសក្កំ(១) ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ(២) ញាយំ ធម្មំ កុសលន្តិ ។ កតមេ បន តេ(៣) អានន្ទ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ អព្រហ្មចរិយវាសា អក្ខាតា យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។

[៩៦] ឥធ សន្ទក ឯកច្ចោ សត្ថា ឯវំវាទី ហោតិ ឯវំទិដ្ឋិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណ-

១ ម. សំសក្កំ ។ ២ ឱ វសន្តោ វា ន អារាធេយ្យាតិ បាឋោ ទិស្សតិ ។ ៣. ឱ. ម. ឯ ភោ ។



ធម៌ ៤ ប្រការនេះឯង បានសំដែងអនស្សាសិកព្រហ្មចរិយៈ គឺព្រហ្មចរិយៈ-ធម៌មិនមានទំនងស្រួល ៤ ប្រការឯង ដែលជាធម៌នាំឲ្យវិញ្ញូបុរស វៀរប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទ ចុះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអព្រហ្មចរិយវាសៈ ៤ ប្រការ ដែលជាធម៌នាំឲ្យវិញ្ញូបុរស វៀរប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលដែលខ្លួនគប្បីដឹងនោះ តើដូចម្តេចខ្លះ ។

[៩៦] ព្រះអានន្ទឆ្លើយតបថា ម្នាលសន្ទកៈ គ្រូណាកនេះ មានវាទៈ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ការប្រតិបត្តិខុសឬត្រូវចំពោះមាតា ក៏មិនមានផល (នៃបុណ្យនិងបាប) ការប្រតិបត្តិខុសឬត្រូវចំពោះបិតា មិនមានផល (នៃបុណ្យនិងបាប) សត្វជាឧបបាតិកៈកើតឡើងមិនមាន ពួកសមណៈនិង

ព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ចាតុម្មហាភូតិកោ អយំ បុរិសោ យទា កាលំ ករោតិ បឋវី បឋវីកាយំ អនុបេតិ អនុបគច្ឆតិ អាបោ អាបោកាយំ អនុបេតិ អនុបគច្ឆតិ តេជោ តេជោកាយំ អនុបេតិ អនុបគច្ឆតិ វាយោ វាយោកាយំ អនុបេតិ អនុបគច្ឆតិ អាកាសំ ឥន្ទ្រិយានិ សង្កមន្តិ អាសន្ទិបញ្ចមា បុរិសា មតំ អាទាយ គច្ឆន្តិ យាវ អាឡាហនា(១) បទានិ បញ្ញាយន្តិ កាបោតកានិ អដ្ឋីនិ ភវន្តិ ភស្សន្តា អាហុតិយោ ទត្តុបញ្ញត្តំ យទិទំ ទានំ តេសំ តុច្ឆំ មុសា វិលាបោ យេ កេចិ អត្ថិកវាទំ វទន្តិ ពាលេ ច បណ្ឌិតេ ច(២) កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរម្មរណាតិ ។

---

១. អាឡាហនា ។ ២. យាវ អាឡាហនា ។ ៣ អត្ថិកវាទំ បទ ពាលេ ច បណ្ឌិតេ ច ទេវ ធិច្ច ។





ព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ហើយធ្វើឲ្យជាក់ច្បាស់ នូវលោកនេះនិងលោកខាងមុខ ដោយបញ្ញារបស់ខ្លួន ហើយអាចសំដែងបាន ក៏មិនមានក្នុងលោកឡើយ បុរសនេះកើតអំពីមហាភូតរូប ៤ លុះធ្វើមរណកាលកិរិយាទៅ បឋវីធាតុខាងក្នុងក៏ប្រែក្លាយទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាតេជោធាតុខាងក្រៅ វាយោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយទាំងឡាយ ក៏វិលត្រឡប់ទៅឯអាកាស ពួកបុរស (៤ នាក់) មានគ្រែជាគំរប់ ៥ សែងយកបុរសស្លាប់ (នោះ) ទៅ ស្នាមជើងគឺគន្លងទីដើរ ក៏ប្រាកដនៅត្រឹមទីឈាបនកិច្ចប៉ុណ្ណោះ សល់នៅតែឆ្អឹងដែលមានសម្បុរ (ប្រផេះ) ដូចជាស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជាមានប្រផេះជាទីបំផុត ទាននេះ ពួកមនុស្សពាលតែងឲ្យ បញ្ញត្តទុកមកទេ ជនទាំងឡាយណា ពោលពាក្យថា អំពើមានទានជាដើម មានផល ពាក្យរបស់ជនទាំងនោះជាពាក្យកុហកទទេ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ រមែងដាច់សូន្យ វិនាសបាត់បង់ មិនកើតទៀតឡើយ ។

[៨៧] តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា ឯវំវាទី ឯវំទិដ្ឋី នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ចាតុម្មហាភូតិកោ អយំ បុរិសោ យទា កាលំ ករោតិ បឋវី បឋវីកាយំ អនុបេតិ អនុបគច្ឆតិ អាបោ អាបោកាយំ អនុបេតិ អនុបគច្ឆតិ តេជោ តេជោកាយំ អនុបេតិ អនុបគច្ឆតិ វាយោ វាយោកាយំ អនុបេតិ អនុបគច្ឆតិ អាកាសំ ឥន្ទ្រិយានិ សង្កមន្តិ អាសន្ទិបញ្ចមា បុរិសា



(៨៧) ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណាក្នុងរឿងនោះដូច្នេះថា គ្រូដ៏ចំរើននេះឯង តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ការប្រតិបត្តិខុស ឬត្រូវ ចំពោះមាតា មិនមានផល ការប្រតិបត្តិខុស ឬត្រូវ ចំពោះបិតា មិនមានផល សត្វជាឧបបាតិកៈកំណើត មិនមាន ពួកសមណៈនិងព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ហើយធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយបញ្ញារបស់ខ្លួន ហើយអាចសំដែងបាន ក៏មិនមានក្នុងលោកឡើយ បុរសនេះកើតអំពីមហាភូតរូប ៤ លុះធ្វើមរណកាលទៅ វេលាណា បឋវីធាតុខាងក្នុង ក៏ប្រែក្លាយទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាតេជោធាតុខាងក្រៅ វាយោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយទាំងឡាយ ក៏ឆ្លងទៅរកអាកាស ពួកបុរស (៤ នាក់) មានគ្រែជាគំរប់ ៥

មតំ អាទាយ គច្ឆន្តិ យាវ អាឡាហនា បទានិ បញ្ញាយន្តិ កាបោតកានិ អដ្ឋីនិ ភវន្តិ ភស្សន្តា អាហុតិយោ ទត្តុបញ្ញត្តំ យទិទំ ទានំ តេសំ តុច្ឆំ មុសា វិលាបោ យេ កេចិ អត្ថិកវាទំ វទន្តិ ពាលេ ច បណ្ឌិតេ ច កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរម្មរណាតិ ។ សចេ ឥមស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អកតេន មេ ឯត្ថ កតំ អវុសិតេន មេ ឯត្ថ វុសិតំ ឧភោបិ មយំ ឯត្ថ សមសមា សាមញ្ញំ បត្តា យោ ចាហំ ន វទាមិ ឧភោបិ កាយស្ស ភេទា ឧច្ឆិជ្ជិស្សាម វិនស្សិស្សាម ន ភវិស្សាម បរម្មរណាតិ ។ អតិរេកំ ខោ បនិមស្ស ភោតោ សត្ថុនោ នគ្គិយំ មុណ្ឌិយំ ឧក្កុដិកប្បធានំ



សែងយកបុរសស្លាប់ (នោះ) ទៅ ស្នាមជើងគឺគុណនឹងទោស ក៏ប្រាកដនៅកំណត់ត្រឹមទីឈាបនកិច្ចប៉ុណ្ណោះ សល់នៅតែឆ្អឹង ដែលមានសម្បុរ (ប្រផេះ) ដូចជាស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជា មានផេះជាទីបំផុត ទានទាំងនេះពួកមនុស្សពាលតម្លើង បញ្ញត្តទុកមកទេ ជនទាំងឡាយណាពោលពាក្យថា អំពើមានទានជាដើមមានផល ពាក្យរបស់ជនទាំងនោះ ជាពាក្យកុហកទទេ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ រមែងដាច់សូន្យវិនាសបាត់បង់ មិនកើតវិញឡើយ ។ ជាបើពាក្យ របស់គ្រូដ៏ចំរើននេះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញបានធ្វើហើយក្តី សម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញ បានប្រព្រឹត្តហើយក្តី សម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំងពីរនាក់ ជាមនុស្សស្មើ ៗ គ្នា ដល់នូវភាពស្មើគ្នានៃសមណធម៌នោះ ប៉ុន្តែអាត្មាអញ ព្រោះតែមិនពោលថា យើងទាំងពីរនាក់ លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ នឹងដាច់សូន្យវិនាស មិនកើតវិញឡើយ ។ ក៏គ្រូដ៏ចំរើននេះ ប្រព្រឹត្តអាក្រាត កោរក្បាលព្យាយាមអង្គុយច្រហោង

កេសមស្សុលោចនំ យោហំ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោ កាសិកចន្ទនំ បច្ចនុភោន្តោ មាលាគន្ធវិលេបនំ ធារេន្តោ ជាតរូបរជតំ សាទិយន្តោ ឥមិនា ភោតា សត្ថារា សមសមគតិកោ ភវិស្សាមិ អភិសម្បរាយំ សោហំ កិំ ជានន្តោ កិំ បស្សន្តោ ឥមស្មឹ សត្ថរិ ព្រហ្មចរិយំ ចរិស្សាមិ សោ អព្រហ្មចរិយវាសោ អយន្តិ ឥតិ វិទិត្វា តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ អយំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមោ អព្រហ្មចរិយវាសោ អក្ខាតោ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ វា នារាធេយ្យ ញាយំ ធម្មំ កុសលំ ។

(៨៨) បុន ចបរំ សន្ទក ឥធេកច្ចោ សត្ថា ឯវំវាទី ហោតិ ឯវំទិដ្ឋី ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បចាបយតោ(១) សោចតោ

១ ឱ. ម. បាចាបយតោ ។



ប្រព្រឹត្តផុសក់នឹងពុកមាត់ពុកចង្កា យ៉ាងនេះ លើសលុប ចំណែកអាត្មាអញដែលអាស្រ័យនឹងទីដេក ចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមកពីដែនកាសីនិងខ្លឹមចន្ទន៍ ប្រដាប់ផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ត្រេកអរចំពោះមាសនិងប្រាក់ គឺគង់ជាអ្នកមានគតិស្មើ ១ គ្នានឹងគ្រូដ៏ចំរើននេះ ក្នុងលោកខាងមុខដែរ កាលអាត្មាអញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើបប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តនោះឯង មិនមែនជាកិរិយាប្រព្រឹត្តព្រហ្មចរិយធម៌ទេ បុរសនោះលុះដឹងច្បាស់ ដូច្នេះហើយ ក៏នឿយណាយ ចាកព្រហ្មចរិយធម៌នោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯង ឈ្មោះថាអព្រហ្មចរិយវាសៈទី ១ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌វិញ្ញូបុរស មិនប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

(៨៨) ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះមានគ្រូខ្លះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុគ្គលធ្វើបាប ឬ ប្រើគេឲ្យធ្វើ កាត់(អវយវៈមានដៃជាដើម) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃ ឲ្យបៀតបៀន ធ្វើគេឲ្យសោយសោក

សោចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ(១) អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ(២) មំសខលំ ឯកំ(៣) មំសបុញ្ជំ ករេយ្យ នត្ថិ តតោ និទានំ បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ(៤) គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បាចេន្តោ(៥) នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ឧត្តរញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ

១ ម. សោចាបយតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោតិ បាឋោ ទិស្សតិ ។ ២-៣ ម. ឯកំ ។ ៤ ម. ទក្ខិណំ ចេបិ ។ ៥ ម. បាចាបេន្តោ ។



ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេសោយសោក ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក ញ័រភ័យ ឬប្រើគេឲ្យញ័រភ័យ សម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់ឡូទី-ត (ផ្ទះ) ប្លន់ឡូព្យអ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំផ្លូវឆ្ងាយ ( ដើម្បីដណ្តើមយកទ្រព្យ ) លួចប្រពន្ធរបស់អ្នកដទៃ និយាយពាក្យកុហក កាលបើធ្វើ (យ៉ាងនេះ) មិនឈ្មោះថាធ្វើបាបឡើយ មួយទៀត បើបុគ្គលណាយកគ្រឿងចក្រមានខ្នងកាំបិតមុតដូចជាកាំបិតកោរ មកធ្វើសត្វទាំងឡាយលើផែនដីនេះ ឲ្យមានគំនរនៃសាច់តែមួយ ឲ្យមានគំនូកនៃសាច់តែមួយ បាបដែលមានគំនរនោះជាហេតុមិនមានទេ គំនរបាបក៏មិនឲ្យផល ទោះបើបុគ្គលនឹងទៅកាន់ត្រើយខាងត្បូងនៃទន្លេគង្គា ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (ខ្លួនឯងរបស់មានដៃជាដើម) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន បាបដែលមានគំនើនោះជាហេតុ មិនមានទេ គំនរបាប ក៏មិនឲ្យផល ទោះបើបុគ្គលនឹងទៅកាន់ត្រើយខាងជើងនៃទន្លេគង្គា ហើយឲ្យទាន ឬប្រើគេឲ្យ ១ បូជា

យជាបេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សញ្ញមេន(១) សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។

[៩៤] តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា ឯវំវាទី ឯវំទិដ្ឋី ករោតោ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចាបយតោ សោចតោ សោចាបយតោ កិលមតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ នត្ថិ តតោនិទានំ បាបំ

១ ម. ម. សំយមេន ។



ឬប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ បុគ្គលធ្វើកុសលដោយឲ្យទាន ដោយទូន្មាននូវឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យដែលមានអំពើនោះជាហេតុ មិនមានទេ អំពើបុណ្យ មិនឲ្យផលឡើយ ។

[៩៤] ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណា ក្នុងរឿងនោះដូច្នេះថា គ្រូដ៏ចំរើនខាងនេះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុគ្គលធ្វើខ្លួន ឬប្រើគេឲ្យធ្វើ កាត់ (អវយវៈមានដៃជាដើម) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន ធ្វើគេឲ្យសោយសោក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោយសោក ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេលំបាក បំភ័យគេ ឬប្រើគេឲ្យបំភ័យ សម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់ខ្ទង់ក (នៃផ្ទះ) ប្លន់ខ្ទេចខ្ទីអ្នកស្រុក ប្លន់យកទ្រព្យនៃផ្ទះ ១ ឈរចាំក្បែរផ្លូវ ( ដើម្បីដណ្ដើមយកទ្រព្យ ) លួចប្រពន្ធរបស់អ្នកដទៃ និយាយពាក្យកុហក កាលបើធ្វើ (យ៉ាងនេះ) មិនឈ្មោះថាធ្វើបាបឡើយ មួយទៀត បើអ្នកណាយកចក្រដ៏ធំ មានខ្នងដ៏មុតដូចជាកាំបិតកោរ មកធ្វើសត្វទាំងឡាយលើផែនដីនេះឲ្យទៅជាគំនរនៃសាច់តែមួយ ឲ្យទៅជាពំនូកនៃសាច់តែមួយ បាបដែលមានអំពើនោះជាហេតុ មិនមានទេ អំពើ

នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បាចេន្តោ នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ឧត្តរញ្ចេបិ[១] គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទាបេន្តោ យជន្តោ យជាបេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សញ្ញមេន សច្ចវជ្ជេន នត្ថិ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ។ សចេ ឥមស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អកតេន មេ ឯត្ថ កតំ អវុសិតេន មេ ឯត្ថ វុសិតំ ឧភោបិ មយំ ឯត្ថ សមសមា សាមញ្ញំ បត្តា យោ ចាហំ ន វទាមិ ឧភិន្នំ កុរុតំ[២] ន ករីយតិ បាបន្តិ ។ អតិរេកំ ខោ បនិមស្ស ភោតោ សត្ថុនោ នគ្គិយំ មុណ្ឌិយំ ឧក្កុដិកប្បធានំ កេសមស្សុលោចនំ

១ ម. ឧត្តរំ ចេបិ ។ ម. ២ កតំ ។



បាបក៏មិនឲ្យផលឡើយ ព្រោះបើបុគ្គលដើរទៅកាន់ត្រើយខាងស្តាំនៃទន្លេគង្គា ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់ (អវយវៈមានដៃជាដើម) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុមិនមានទេ អំពើបាបក៏មិនឲ្យផលឡើយ ព្រោះបើបុគ្គលដើរទៅកាន់ត្រើយខាងឆ្វេងនៃទន្លេគង្គា ហើយឲ្យទាន ឬប្រើគេឲ្យឲ្យ បូជាឬប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ បុគ្គលធ្វើកុសល ដោយឲ្យទាន ដោយទូន្មានឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ ។ បើពាក្យរបស់គ្រូដឹកនាំនោះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញ បានធ្វើហើយក្នុងសម័យនុ៎ះ ក៏ដូចជាមិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញ បានប្រព្រឹត្តហើយក្នុងសម័យនុ៎ះ ក៏ដូចជាអាត្មាអញ មិនបានប្រព្រឹត្ត ឯយើងទាំងពីរនាក់ ជាមនុស្សស្មើ ៗ គ្នា ដល់នូវការស្មើគ្នាក្នុងសាមញ្ញធម៌នុ៎ះ ប៉ុន្តែអាត្មាអញគ្រាន់តែមិនបាននិយាយថា យើងទាំងពីរនាក់ កាលធ្វើបាប ក៏ឈ្មោះថាមិនធ្វើ ។ ក៏គ្រូដឹកនាំនោះ ប្រព្រឹត្តអាក្រាត កោរក្បាល ព្យាយាមអង្គុយច្រហោង ប្រព្រឹត្តដកសក់នឹងពុកមាត់ពុកចង្កា យ៉ាងនេះលើសលុប

យោហំ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោ កាសិក-
ចន្ទនំ បច្ចនុភោន្តោ មាលាគន្ធវិលេបនំ ធារេន្តោ
ជាតរូបរជតំ សាទិយន្តោ ឥមិនា ភោតា សត្ថារា
សមសមគតិកោ ភវិស្សាមិ អភិសម្បរាយំ សោហំ
កឹ ជានន្តោ កឹ បស្សន្តោ ឥមស្មឹ សត្ថរិ ព្រហ្មចរិយំ
ចរិស្សាមិ សោ អព្រហ្មចរិយវាសោ អយន្តិ ឥតិ វិទិត្វា
តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ អយំ ខោ
សន្ទក តេន ភគវតា ជានតា បស្សតា អរហតា
សម្មាសម្ពុទ្ធេន ទុតិយោ អព្រហ្មចរិយវាសោ អក្ខាតោ
យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ
វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលំ ។

[៦០] បុន ចបរំ សន្ទក ឥធេកច្ចោ សត្ថា
ឯវំវាទី ហោតិ ឯវំទិដ្ឋី នត្ថិ ហេតុ នត្ថិ បច្ចយោ
សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា
សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ
វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ



ចំណែកខាងអញ ដែលអាស្រ័យនៅទីដ៏ចង្អៀតដោយកូន ប្រើ
ប្រាស់សំពត់ដែលបានមក អំពីដែនកាសីនិងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រង
និងគ្រឿងក្រអូបគ្រឿងលាបផ្សេង ៗ ត្រេកអរចំពោះមាសនិងប្រាក់ គង់
ជាអ្នកមានគតិស្មើ ៗ គ្នានឹងគ្រូដ៏ចំរើននេះ ក្នុងលោកខាងមុខដែរ ខាង
អញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើបប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំ-
ណាក់គ្រូនេះ ការប្រព្រឹត្តនោះឯង មិនមែនជាកិរិយាប្រព្រឹត្តព្រហ្មចរិយ-
ធម៌ទេ ដូច្នេះ លុះដឹងដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយ-
ធម៌នោះហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯង ឈ្មោះថា
អព្រហ្មចរិយវាសៈទី ២ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ
នោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌ជា
ឲ្យវិញ្ញូបុរសវៀរលែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយគោរពស្រឡះ ទុកជាកាល
ប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[៦០] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូ
ខ្លះ ពោលនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ហេតុបច្ច័យដើម្បី
សត្វទាំងឡាយសៅហ្មងមិនមានឡើយ សត្វទាំងឡាយ រមែងសៅហ្មង
ដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យដើម្បីសត្វទាំងឡាយ បរិសុទ្ធ
មិនមានឡើយ សត្វទាំងឡាយ រមែងបរិសុទ្ធ ដោយឥតហេតុ ឥតបច្ច័យ

នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសថាមោ នត្ថិ បុរិសបរក្កមោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា អវសា អពលា អវីរិយា និយតិសង្គតិភាវបរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តិ ។

(៦៨) តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា ឯវំវាទី ឯវំទិដ្ឋី នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ សង្កិលេសាយ អហេតូ អប្បច្ចយា សត្តា សង្កិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ នត្ថិ ពលំ នត្ថិ វីរិយំ នត្ថិ បុរិសថាមោ នត្ថិ បុរិសបរក្កមោ សព្វេ សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា



កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងនៃបុរសក៏មិនមាន ការប្រឹងប្រែងនៃបុរសក៏មិនមាន សត្វទាំងអស់ (មានសត្វឧដ្ឋ គោ លា ជាដើម) ប្រាណៈ(១) ទាំងអស់ ភូតទាំងអស់ (មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ជីវៈគឺព្រឹក្សជាតិទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម (ក្នុងការកើតឡើងសៅហ្មងឬបរិសុទ្ធ)ទេ មានសេចក្តីប្រែប្រួលដោយនិយតិនិងសង្គតិ និងសភាវៈ(២) ទាំងនៅក្នុងអភិជាតិទាំង ៦ ហើយរមែងសោយសុខនិងទុក្ខ ។

(៦៩) ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណា ក្នុងរឿងនោះដូច្នេះថា គ្រូដ៏ចំរើននេះឯង តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយសៅហ្មង មិនមានឡើយ សត្វទាំងឡាយ រមែងសៅហ្មង ដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យ នាំឲ្យសត្វទាំងឡាយ បរិសុទ្ធមិនមានឡើយ សត្វទាំងឡាយ រមែងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងនៃបុរសក៏មិនមាន សេចក្តីប្រឹងប្រែងនៃបុរសក៏មិនមាន សត្វទាំងអស់ (មានឧដ្ឋ គោ លា ជាដើម) ប្រាណៈទាំងអស់ ភូតទាំងអស់ (មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ជីវៈគឺព្រឹក្សជាតិទាំងអស់

១-២ ចូរមើលប្រែសាមញ្ញផលសូត្រ ក្នុងសៀវភៅទី ១២ ទំព័រ ១០១ ។

អវសា អពលា អវីរិយា និយតិសង្គតិភាវបរិណតា ឆស្វេវាភិជាតីសុ សុខទុក្ខំ បដិសំវេទេន្តីតិ ។ សចេ ឥមស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អកតេន មេ ឯត្ថ កតំ អវុសិតេន មេ ឯត្ថ វុសិតំ ឧភោបិ មយំ ឯត្ថ សមសមា សាមញ្ញំ បត្តា យោ ចាហំ ន វទាមិ ឧភោ អហេតូ អប្បច្ចយា វិសុជ្ឈិស្សាមាតិ ។ អតិរេកំ ខោ បនិមស្ស ភោតោ សត្ថុនោ នគ្គិយំ មុណ្ឌិយំ ឧក្កុដិកប្បធានំ កេសមស្សុលោចនំ យោហំ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោ កាសិកចន្ទនំ បច្ចនុភោន្តោ មាលាគន្ធវិលេបនំ ធារេន្តោ ជាតរូបរជតំ សាទិយន្តោ ឥមិនា ភោតា សត្ថារា សមសមគតិកោ ភវិស្សាមិ អភិសម្បរាយំ សោហំ កិំ ជានន្តោ



ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម (ក្នុងការធ្វើឲ្យសៅហ្មងឬបរិសុទ្ធ)ទេ មានសេចក្តីប្រែប្រួល ដោយនិយតិ និងសង្គតិ និងសភាវៈតាំងនៅក្នុងអភិជាតិទាំង ៦ ហើយរមែងទទួលសុខនិងទុក្ខ ។ បើពាក្យរបស់គ្រូដ៏ចំរើននេះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញបានធ្វើហើយក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញ បានប្រព្រឹត្តហើយក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានប្រព្រឹត្ត និងយើងទាំងពីរនាក់ជាមនុស្សស្មើគ្នា ដល់នូវភាពស្មើគ្នាក្នុងសមណធម៌នុ៎ះ ប៉ុន្តែអាត្មាអញគ្រាន់តែមិននិយាយថា យើងទាំងពីរនាក់នឹងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ ។ ក៏គ្រូដ៏ចំរើននេះប្រព្រឹត្តអាក្រាត កោរក្បាល ព្យាយាមអង្គុយច្រហោង ប្រព្រឹត្តដកសក់និងពុកមាត់ពុកចង្កា យ៉ាងនឹងលើសលុប ចំណែកអាត្មាអញដែលអាស្រ័យនៅនឹងទីដេកចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមកអំពីដែនកាសីនិងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ត្រេកអរចំពោះមាសនិងប្រាក់ ក៏គង់ជាអ្នកមានគតិស្មើ ៗ គ្នានឹងគ្រូដ៏ចំរើននេះក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វី

កឹ បស្សន្តោ ឥមស្មឹ សត្ថរិ ព្រហ្មចរិយំ ចរិស្សាមិ សោ អព្រហ្មចរិយវាសោ អយន្តិ ឥតិ វិទិត្វា តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ អយំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តតិយោ អព្រហ្មចរិយវាសោ អក្ខាតោ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលំ ។

(៦៦) បុន ចបរំ សន្ទក ឥធេកច្ចោ សត្ថា ឯវំវាទី ហោតិ ឯវំទិដ្ឋី សត្តិមេ កាយា អកដា អកដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា(១) តេ ន ឥញ្ជន្តិ ន វិបរិណាមេន្តិ នាញ្ញមញ្ញំ(២) ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា កតមេ សត្ត បឋវីកាយោ អាបោកាយោ តេជោកាយោ វាយោកាយោ

១ ឯសិកដ្ឋាយិដ្ឋិតាតិ បាឋោ ។ ២ ឱ. ន វិបរិណាមេន្តិ ន អញ្ញមញ្ញំ ។ ម. ន វិបរិណាមេន្តិ ន អញ្ញមញ្ញំ ។



ឃើញអ្វី ទើបមកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តនោះ មិនមែនជាកិរិយាប្រព្រឹត្តព្រហ្មចរិយធម៌ទេ បុរសនោះ លុះដឹងច្បាស់ហើយ ក៏នឿយណាយចាកព្រហ្មចរិយធម៌នោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈទី ៣ ដែលព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ឃើញច្បាស់ បានសំដែងហើយ ជាធម៌នាំឲ្យវិញ្ញូបុរសមិនប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាការប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

(៦៦) ម្នាលសន្ទកៈ ប្រការមួយទៀត គ្រូណាក្នុងលោកនេះមានវាទៈតែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា កាយគឺពួកទាំង ៧ នេះ គ្មានអ្នកណាធ្វើកើត គ្មានវិធីធ្វើកើត គ្មានអ្នកណានិម្មិតដោយឫទ្ធិបាន គ្មានអ្នកណាសាងកើត ជាសភាពអារ (គ្មានកូនតទៅទៀត) តាំងនៅខ្ជាប់ជាកំពូលភ្នំ ស្ថិតនៅមាំដូចជាសសរគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខឬបានទុក្ខ ឬបានទាំងសុខទាំងទុក្ខបានឡើយ កាយគឺពួកទាំង ៧ តើដូចម្តេចខ្លះ គឺពួកធាតុដី ១ ពួកធាតុទឹក ១ ពួកធាតុភ្លើង ១ ពួកធាតុខ្យល់ ១

សុខេ ទុក្ខេ ជីវេ សត្តមេ(១) ឥមេ សត្ត កាយា អកដា អកដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ ន វិបរិណាមេន្តិ ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា តត្ថ នត្ថិ ហន្តា វា ឃាតេតា វា សោតា វា សាវេតា វា វិញ្ញាតា វា វិញ្ញាបេតា វា យោបិ តិណ្ហេន សត្ថេន សីសំ ឆិន្ទតិ ន កោចិ កញ្ចិ ជីវិតា វោរោបេតិ សត្តន្នំ ត្វេវ កាយានមន្តរេន សត្ថំ វិវរមនុបតតិ ។ ចុទ្ទស ខោ បនិមានិ យោនិប្បមុខសតសហស្សានិ សដ្ឋិញ្ច(២) សតានិ ឆ ច សតានិ បញ្ច ច កម្មុនោ សតានិ បញ្ច ច កម្មានិ តីណិ ច កម្មានិ កម្មេ ច អឌ្ឍកម្មេ ច ទ្វដ្ឋិប្បដិបទា ទ្វដ្ឋន្តរកប្បា ឆឡាភិជា-តិយោ អដ្ឋ បុរិសភូមិយោ ឯកូនបញ្ញាស អាជីវសតេ

១ ម. សីំ ។ ឱ. សត្តមេ ។ ២ ឱ. ម. យោនិបមុខសតសហស្សានិ សដ្ឋិ ច ។



សេចក្តីសុខ ១ សេចក្តីទុក្ខ ១ ជីវិត ១ ត្រូវជា ៧ កាយទាំង ៧ នេះ គ្មានអ្នកណាធ្វើកើត គ្មានវិធីធ្វើកើត គ្មានអ្នកណានិម្មិតដោយឫទ្ធិបាន គ្មានអ្នកណាសាងកើត ជាសភាពឥតផល តាំងនៅដូចជាកំពូលភ្នំ ឬក៏នៅនឹងដូចជាសសរគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ បុគ្គលសម្លាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី ស្តាប់ខ្លួនឯងក្តី ប្រើគេឲ្យស្តាប់ក្តី ដឹងច្បាស់ខ្លួនឯងក្តី ញុំាងគេឲ្យដឹងច្បាស់ក្តី មិនមានក្នុងកាយទាំងនោះទេ ទុកជាបុគ្គលកាត់សីសៈដោយសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មានអ្នកណា ផ្តាច់ជីវិតអ្នកណា ឲ្យចាកជីវិតបាន ឯសស្ត្រាគ្រាន់តែចូលតាមចន្លោះនៃកាយទាំង ៧ ប៉ុណ្ណោះឯង ។ ឯកំណើតដែលជាប្រធាន(១) មានចំនួន១លាន ៤ សែន ៦ ពាន់ ៦ រយ ទាំងនេះក្តី កម្មទាំង ៥ រយក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្មគឺកាយកម្មនិងវចីកម្មក្តី កម្មពាក់កណ្តាលគឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី អន្តរកប្ប(២) ទាំង ៦២ ក្តី អភិជាតិ(៣) ទាំង ៦ បុរិសភូមិ(៤) ទាំង ៨ ពួកអាជីវកទាំង ៤៩

១-២-៣-៤ ចូរមើលត្រង់សាមញ្ញផលសូត្រក្នុងសៀវភៅទី ១៤ ទំព័រ ១៣២ ។

ឯកូនបញ្ញាស បរិព្វាជកសតេ ឯកូនបញ្ញាស នាគាវាសសតេ វីសេ ឥន្ទ្រិយសតេ តឹសេ និរយសតេ ឆត្តឹស រជោធាតុយោ សត្ត សញ្ញីគព្ភា សត្ត អសញ្ញីគព្ភា សត្ត និគណ្ឋិគព្ភា សត្ត ទេវា សត្ត មានុសា សត្ត បិសាចា សត្ត សរា សត្ត បវុដា(១) សត្ត ចាសាណា (២) សត្ត បបាតា សត្ត បបាតសតានិ សត្ត សុបិនា សត្ត សុបិនសតានិ ចុល្លាសីតិ មហាកប្បិនោ សតសហស្សានិ យានិ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តិ ។ តត្ថ នត្ថិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា អបរិបក្កំ វា កម្មំ បរិបាចេស្សាមិ បរិបក្កំ វា កម្មំ ផុស្ស ផុស្ស ព្យន្តិ.(៣) ករិស្សាមីតិ ហេវំ នត្ថិ ទោណមិតេ(៤) សុខទុក្ខេ បរិយន្តកតេ សំសារេ នត្ថិ ហាយនវឌ្ឍនេ

១ ម. សតុដា ។ ២. ម. សត្ត បាសាណសតានិ ។ ទំព្យន្តិ ។ ៣ ម. ព្យន្តឹ ។ ៤ ម. ខ. ទោណមិតេ ។



ពួកបរិព្វាជកចំនួន ៤៩ លំនៅនៃនាគចំនួន ៤៩ ឥន្ទ្រិយចំនួន ១២០ នរកចំនួន ១៣០ ធាតុដែលប្រកបដោយធូលី (មានធូលីនៃធូលីជើងជាដើម) ចំនួន ៣៦ ពួកគភ៌នៃសត្វដែលមានសញ្ញា(១) ចំនួន ៧ ពួកគភ៌នៃ (បញ្ញជាតិ) ដែលគ្មានសញ្ញាចំនួន ៧ ពួកគភ៌នៃជាតិដែលផុះអំពីថ្នាំង (មានអំពៅជាដើម) ចំនួន ៧ ពួកទេវតាចំនួន ៧ ពួកមនុស្សចំនួន ៧ ពួកបិសាចចំនួន ៧ ស្រះចំនួន ៧ គោនក្ចុំចំនួន ៧ ថ្មចំនួន ៧ ជ្រោះធំចំនួន ៧ ជ្រោះតូចចំនួន ៧០០ សុបិនធំចំនួន ៧ សុបិនតូចចំនួន ៧០០ ជនពាលក្តី ជនជាបណ្ឌិតក្តី អន្ទោលទៅ ត្រាច់ទៅ (កើតស្លាប់ក្នុងសង្សារ) អស់ចំនួន ៨៤ លានចូឡមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។ បុគ្គលកំណត់ទុកថា អាត្មាអញនឹងញ៉ាំងកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយ ៗ នូវកម្មដែលចាស់ស្រាប់ហើយ ៗ ធ្វើឲ្យអស់ទៅផង ដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី ក្នុងកប្បចំនួនឡាយនោះមិនមានទេ សេចក្តីសុខទុក្ខដែលធ្វើឲ្យមានទីបំផុតដូចគេវាល់របស់ (ឲ្យអស់ទៅ) ដោយទោណៈ មិនមានក្នុងសង្សារវដ្តដោយប្រការយ៉ាងនេះឡើយ សេចក្តីសាបសូន្យ (នៃសង្សាររបស់ជនជាបណ្ឌិត) នឹងសេចក្តីចំរើន (នៃសង្សាររបស់ជនពាល) មិនមានទេ

១ ត្រូវមើលក្រុមសារគណ្ឋិសរសេរក្នុងសៀវភៅទី ៤៤ ទំព័រ ១៣៦ ។

នត្ថិ ឧក្កំសាវកំសេ ។ សេយ្យថាបិ នាម សុត្តគុឡេ ខិត្តេ និព្វេឋិយមានមេវ បលេតិ ឯវមេវ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តីតិ ។

(២៣) តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា ឯវំវាទី ឯវំទិដ្ឋី សត្តិមេ កាយា អកដា អកដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ ន វិបរិណាមេន្តិ ន អញ្ញ-មញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា កតមេ សត្ត បឋវីកាយោ អាបោកាយោ តេជោកាយោ វាយោ-កាយោ សុខេ ទុក្ខេ ជីវេ សត្តមេ ឥមេ សត្ត កាយា អកដា អកដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ



សេចក្ដីល្អតលាស់ឡើងនិងសេចក្ដីថោកថយចុះមិនមានឡើយ ។ ដូចដុំនៃអម្បោះ ដែលគេបោះចោលទៅ តែងរសាយអស់ (ត្រឹមតែកំណត់អម្បោះប៉ុណ្ណោះ) យ៉ាងណាមិញ ជនពាលក្ដី ជនជាបណ្ឌិតក្ដី ដែលអន្ទោលទៅ ត្រាច់ទៅ (ក្នុងសង្សារតាមកំណត់នេះហើយ) នឹងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នោះឯង ។

(២៣) ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណា ក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចំរើននេះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា កាយនីពួកទាំង ៧ នេះ គ្មានអ្នកណាធ្វើកើត គ្មានវិធីធ្វើកើត គ្មានអ្នកណានិម្មិតដោយឫទ្ធិបាន គ្មានអ្នកណាសាងកើត ជាសភាពអារ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅទាំងដូចជាសសរគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ កាយនីពួកទាំង ៧ តើដូចម្ដេចខ្លះ គឺពួកធាតុដី ១ ពួកធាតុទឹក ១ ពួកធាតុភ្លើង ១ ពួកធាតុខ្យល់ ១ សេចក្ដីសុខ ១ សេចក្ដីទុក្ខ ១ ជីវិត ១ គ្រប់ជា ៧ កាយនីពួកទាំង ៧ នេះ គ្មានអ្នកណាធ្វើកើត គ្មានវិធីធ្វើកើត គ្មានអ្នកណានិម្មិតដោយឫទ្ធិបាន គ្មានអ្នកណាសាងកើត ជាសភាពអារ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅទាំងដូចសសរគោល កាយទាំងនេះ មិនញាប់ញ័រ មិន

ន វិបរិណាមេន្តិ ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា តត្ថ នត្ថិ ហន្តា វា ឃាតេតា វា សោតា វា សាវេតា វា វិញ្ញាតា វា វិញ្ញាបេតា វា យោបិ តិណ្ហេន សត្ថេន សីសំ ឆិន្ទតិ ន កោចិ កញ្ចិ ជីវិតា វោរោបេតិ សត្តន្នំ ត្វេវ កាយានមន្តរេន សត្ថំ វិវរមនុបតតិ ។ ចុទ្ទស ខោ បនិមានិ យោនិប្បមុខសតសហស្សានិ សដ្ឋិ ច សតានិ ឆ ច សតានិ បញ្ច ច កម្មុនោ សតានិ បញ្ច ច កម្មានិ តីណិ ច កម្មានិ កម្មេ ច អឌ្ឍកម្មេ ច ទ្វដ្ឋិប្បដិបទា ទ្វដ្ឋន្តរកប្បា ឆឡាភិជាតិយោ អដ្ឋ បុរិសភូមិយោ ឯកូនបញ្ញាស អាជីវសតេ ឯកូនបញ្ញាស បរិព្វាជកសតេ ឯកូនបញ្ញាស នាគាវាសសតេ វីសេ ឥន្ទ្រិយសតេ តឹសេ និរយសតេ ឆត្តឹស រជោធាតុយោ សត្ត សញ្ញីគព្ភា សត្ត អសញ្ញីគព្ភា សត្ត និគណ្ឋីគព្ភា សត្ត ទេវា សត្ត មានុសា



ប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ បុគ្គលសម្លាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី ស្តាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យស្តាប់ក្តី ដឹងច្បាស់ខ្លួនឯងក្តី ញុំាងគេឲ្យដឹងច្បាស់ក្តី មិនមានក្នុងកាយទាំង ៧ នោះទេ ទុកជាបុគ្គលកាត់សីសៈ ដោយសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មានអ្នកណាផ្តាច់ផ្តិលអ្នកណាឲ្យចាកជីវិតបានទេ សស្ត្រាគ្រាន់តែចូលទៅតាមចន្លោះនៃកាយទាំង ៧ ប៉ុណ្ណោះឯង ។ កំណើតដែលជាប្រធាន មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយ ទាំងនេះក្តី កម្មទាំង ៥ រយក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្មគឺកាយកម្មនិងវចីកម្មក្តី កម្មពាក់កណ្តាលគឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី អន្តរកប្បទាំង ៦២ ក្តី អភិជាតិទាំង ៦ ក្តី បុរិសភូមិទាំង ៨ ក្តី ពួកអាជីវកទាំង ៤៩០០ ពួកបរិព្វាជកទាំង ៤៩០០ លំនៅនៃនាគទាំង ៤៩០០ ឥន្ទ្រិយទាំង ២០០០ នរកទាំង ៣០០០ ធាតុដែលប្រកបដោយធូលី (មានខ្លួនមិនមែនខ្លួនជាដើម) ទាំង ៣៦ ពួកគភ៌នៃសត្វដែលមានសញ្ញាទាំង ៧ ពួកគភ៌នៃ (សញ្ញាជាតិ) ដែលគ្មានសញ្ញាទាំង ៧ ពួកគភ៌នៃជាតិដែលផុះអំពីថ្នាំងទាំង ៧ ពួកទេវតាទាំង ៧ ពួកមនុស្សទាំង ៧

សត្ត បិសាចា សត្ត សរា សត្ត បវុដា សត្ត បាសាណា សត្ត បបាតា សត្ត បបាតសតានិ សត្ត សុបិនា សត្ត សុបិនសតានិ ចុល្លាសីតិ មហាកប្បិនោ សតសហស្សានិ យានិ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តិ ។ តត្ថ នត្ថិ ឥមិនាហំ សីលេន វា វតេន វា តបេន វា ព្រហ្មចរិយេន វា អបរិបក្កំ វា កម្មំ បរិបាចេស្សាមិ បរិបក្កំ វា កម្មំ ផុស្ស ផុស្ស ព្យន្តីករិស្សាមីតិ ហេវំ នត្ថិ ទោណមិតេ សុខទុក្ខេ បរិយន្តកតេ សំសារេ នត្ថិ ហាយនវឌ្ឍនេ នត្ថិ ឧក្កំសាវកំសេ ។ សេយ្យថាបិ នាម សុត្តគុឡេ ខិត្តេ និព្ពេឋិយមានមេវ បលេតិ ឯវមេវ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តីតិ ។



ភូតបិសាចចំនួន ៧ ស្រះចំនួន ៧ គោនក្ដួចំនួន ៧ ថ្មចំនួន ៧ ជ្រោះធំចំនួន ៧ ជ្រោះតូចចំនួន ៧០០ សុបិនធំចំនួន ៧ សុបិនតូចចំនួន ៧០០ ជនពាលក្ដី ជនជាបណ្ឌិតក្ដី អន្ទោលទៅ ត្រាច់ចរទៅ (ក្នុងវដ្ដសង្សារ) អស់កាលចំនួន ៨៤ លានចុល្លមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។ បុគ្គលកំណត់ទុកថា អាត្មាអញ នឹងញុំាងកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយ ៗ នូវកម្មដែលចាស់ស្រាប់ហើយ ៗ ធ្វើឲ្យអស់ទៅផង ដោយសីលនេះក្ដី ដោយវត្តនេះក្ដី ដោយតបៈនេះក្ដី ដោយព្រហ្មចរិយៈនេះក្ដី ក្នុងលទ្ធិទាំងឡាយនោះ មិនមានទេ សេចក្ដីសុខទុក្ខដែលធ្វើឲ្យមានទីបំផុត ដូចគេវាល់របស់ (ឲ្យអស់ទៅ) ដោយតោណៈ មិនមានគេនឹងសំរេចផ្លាស់ដោយប្រការយ៉ាងនេះឡើយ សេចក្ដីសាបសូន្យ (នៃសង្សាររបស់ជនជាបណ្ឌិត) នឹងសេចក្ដីចំរើន (នៃសង្សាររបស់ជនពាល) មិនមានទេ សេចក្ដីល្អលើសលប់ឡើងនឹងសេចក្ដីថោកទាប មិនមានឡើយ ។ ដូចខ្សែនៃអម្បោះដែលគេបោះចោលទៅ តែងរសាយអស់ (ត្រឹមតែកំណត់អម្បោះប៉ុណ្ណោះ) យ៉ាងណាមិញ ជនពាលក្ដី ជនជាបណ្ឌិតក្ដី ដែលអន្ទោលទៅ ត្រាច់ចរទៅ (ក្នុងសង្សារអស់កំណត់នេះហើយ) នឹងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នោះឯង ។

សចេ បន ឥមស្ស ភោតោ សត្ថុនោ សច្ចំ វចនំ អកតេន មេ ឯត្ថ កតំ អវុសិតេន មេ ឯត្ថ វុសិតំ ឧភោបិ មយំ ឯត្ថ សមសមា សាមញ្ញំ បត្តា យោ ចាហំ ន វទាមិ ឧភោ សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សាមាតិ ។ អតិរេកំ ខោ(១) បនិមស្ស ភោតោ សត្ថុនោ នគ្គិយំ មុណ្ឌិយំ ឧក្កុដិកប្បធានំ កេសមស្សុលោចនំ យោហំ បុត្តសម្ពាធសយនំ អជ្ឈាវសន្តោ កាសិកចន្ទនំ បច្ចនុភោន្តោ មាលាគន្ធវិលេបនំ ធារេន្តោ ជាតរូបរជតំ សាទិយន្តោ ឥមិនា ភោតា សត្ថារា សមសមគតិកោ ភវិស្សាមិ អភិសម្បរាយំ សោហំ កឹ ជានន្តោ កឹ បស្សន្តោ ឥមស្មឹ សត្ថរិ ព្រហ្មចរិយំ ចរិស្សាមិ សោ អព្រហ្មចរិយវាសោ អយន្តិ ឥតិ វិទិត្វា

១ ម. អតិរេកតោ ។



បើពាក្យរបស់គ្រូដ៏ចំរើននេះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញបានធ្វើហើយ ក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញ មិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញបានប្រព្រឹត្តហើយ ក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំងពីរនាក់ ជាមនុស្សស្មើ ៗ គ្នា ដល់នូវភាពស្មើគ្នាក្នុងសមណធម៌នុ៎ះ ប៉ុន្តែអាត្មាអញគ្រាន់តែមិននិយាយថា យើងទាំងពីរនាក់នឹងអន្ទោលទៅ ត្រាច់ទៅ (ក្នុងសង្សារវដ្ត) ហើយនឹងធ្វើនូវទីបំផុតទុក្ខបាន ។ ក៏គ្រូដ៏ចំរើននេះប្រព្រឹត្តអាក្រាត កោរក្បាល ព្យាយាមអង្គុយច្រហោង ប្រព្រឹត្តដកសក់ទាំងពុកមាត់ពុកចង្កា យ៉ាងនេះលើសលុប ចំណែកអាត្មាអញ ដែលអាស្រ័យនៅនឹងទីដេកចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមកអំពីដែនកាសី នឹងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រងនឹងគ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ត្រេកអរចំពោះមាសនឹងប្រាក់ ក៏នឹងជាអ្នកមានគតិស្មើគ្នានឹងគ្រូដ៏ចំរើននេះ ក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើបប្រព្រឹត្តព្រហ្មចរិយៈក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តនោះឯង មិនមែនជាកិរិយាប្រព្រឹត្តព្រហ្មចរិយធម៌ទេ បុរសនោះ លុះដឹងដូច្នេះហើយ ក៏

តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ អយំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចតុត្ថោ អព្រហ្មចរិយវាសោ អក្ខាតោ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលំ ។ ឥមេ ខោ តេ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ អព្រហ្មច-រិយវាសា អក្ខាតា យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។

(៦៤) អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ អព្រហ្មចរិយវាសា ច អព្រហ្មចរិយវាសាតិ អក្ខាតា យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច



នឿយណាយចាកព្រហ្មចរិយធម៌ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈទី ៤ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយធម៌ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈ ៤ ប្រការ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

(៦៤) សន្ទកបរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះចំឡែកណាស់ ព្រោះថា ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអព្រហ្មចរិយវាសៈ ទាំង ៤ ប្រការនេះថា ជាអព្រហ្មចរិយវាសៈ ដោយពិតប្រាកដមែន ជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត

នារាធេយ្យ ញាយំ ធម្មំ កុសលំ ។ កតមានិ បន តានិ ភោ អានន្ទ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារិ អនស្សាសិកានិ ព្រហ្មចរិយានិ អក្ខាតានិ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។

[៦៨] ឥធ សន្ទក ឯកច្ចោ សត្ថា សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ សុញ្ញម្បិ អគារំ បវិសតិ បិណ្ឌម្បិ ន លភតិ កុក្កុរោបិ ឌំសតិ ចណ្ឌេនបិ ហត្ថិនា សមាគច្ឆតិ ចណ្ឌេនបិ អស្សេន សមាគច្ឆតិ ចណ្ឌេនបិ គោណេន សមាគច្ឆតិ ឥត្ថិយាបិ បុរិសស្សបិ នាមម្បិ គោត្តម្បិ បុច្ឆតិ គាមស្សបិ និគមស្សបិ នាមម្បិ មគ្គម្បិ បុច្ឆតិ ។ សោ កិមិទន្តិ បុដ្ឋោ សមានោ សុញ្ញំ



ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអនស្សាសិកព្រហ្មចរិយៈ ៤ ប្រការ ដែលជាធម៌នាំឲ្យវិញ្ញូបុរស វៀរប្រព្រឹត្តព្រហ្មចរិយៈ ដោយគាប់ស្រឡះខ្លួន ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ ដែលខ្លួនគប្បីដឹង តើដូចម្តេចខ្លះ ។

[៦៨] ព្រះអានន្ទតបថា ម្នាលសន្ទកៈ ក្នុងលោកនេះ មានគ្រូខ្លះ ដឹងសព្វ ឃើញសព្វ តែងប្តេជ្ញាខ្លួនថា ញាណទស្សនៈមិនមានសេសសល់ថា អាត្មាអញកាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈ រមែងតែកើតសព្វៗជាប់ជានិច្ច ។ គ្រូនោះ ចូលទៅកាន់ផ្ទះស្ងាត់ ក៏មាន មិនបានដុំបាយក៏មាន ឆ្កែខាំក៏មាន ជួបប្រទះនឹងដំរីកាចក៏មាន ជួបប្រទះនឹងសេះកាចក៏មាន ជួបប្រទះនឹងគោកាចក៏មាន សួរនាមនឹងគោត្ររបស់ស្ត្រី បុរសក៏មាន សួរឈ្មោះនឹងផ្លូវនៃស្រុកនិងនិគមក៏មាន ។ គ្រូនោះកាលបើមានគេសួរថា ហេតុនេះតើដូចម្តេច ក៏ប្រាប់គេថាផ្ទះស្ងាត់

មេ អគារំ បវិសិតុំ អហោសិ តេន បាវិសិំ បិណ្ឌំ មេ អលទ្ធំ(*) អហោសិ តេនាលទ្ធំ កុក្កុរេន ឌំ-សិតុំ អហោសិ តេនម្ហិ ទដ្ឋោ ចណ្ឌេន ហត្ថិនា សមាគន្តុំ អហោសិ តេន សមាគមិំ ចណ្ឌេន អស្សេន សមាគន្តុំ អហោសិ តេន សមាគមិំ ចណ្ឌេន គោណេន សមាគន្តុំ អហោសិ តេន សមាគមិំ ឥត្ថិយាបិ បុរិសស្សបិ នាមម្បិ គោត្តម្បិ បុច្ឆិតុំ អហោសិ តេន បុច្ឆិំ គាមស្សបិ និគមស្សបិ នាមម្បិ មគ្គម្បិ បុច្ឆិតុំ អហោសិ តេន បុច្ឆិន្តិ ។ តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ សុញ្ញម្បិ អគារំ បវិសតិ បិណ្ឌម្បិ ន លភតិ កុក្កុរោបិ ឌំសតិ ចណ្ឌេន ហត្ថិនា សមាគច្ឆតិ

* ម. បិណ្ឌំបិ អលទ្ធំ ។



ដែលខ្ញុំត្រូវចូលទៅបាន ខ្ញុំក៏ចូលទៅកាន់ផ្ទះស្ងាត់នោះហើយ ដុំបាយដែលខ្ញុំមិនគួរបាន ខ្ញុំក៏មិនបានដុំបាយនោះហើយ ឆ្កែដែលគួរខាំខ្ញុំបាន ឆ្កែនោះក៏ខាំខ្ញុំហើយ ខ្ញុំត្រូវជួបនឹងដំរីកាច ខ្ញុំក៏ជួបនឹងដំរីកាចនោះហើយ ខ្ញុំត្រូវជួបនឹងសេះកាច ខ្ញុំក៏ជួបនឹងសេះកាចនោះហើយ ខ្ញុំត្រូវជួបនឹងគោកាច ខ្ញុំក៏ជួបនឹងគោកាចនោះហើយ ខ្ញុំត្រូវសួរនាមនិងគោត្ររបស់ស្រីឬប្រុស ខ្ញុំក៏សួរនាមនិងគោត្ររបស់ស្រីឬប្រុសនោះហើយ ខ្ញុំត្រូវសួរឈ្មោះនិងផ្លូវនៃស្រុកឬនិគម ខ្ញុំក៏សួរឈ្មោះនិងផ្លូវនៃស្រុកឬនិគមនោះរួចហើយ ។ ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណាឃើញដំណើរនោះថា គ្រូដ៏ចំរើននេះដឹងសព្វ ឃើញសព្វ តែងប្តេជ្ញានូវញាណទស្សនៈ មិនមានសេសសល់ថា កាលអាត្មាអញកំពុងដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈ រមែងតាំងនៅជាប់ជានិច្ច ។ គ្រូនោះចូលទៅកាន់ផ្ទះស្ងាត់ក៏មាន មិនបានដុំបាយក៏មាន ឆ្កែខាំក៏មាន ជួបប្រទះនឹងដំរីកាច

ចណ្ហោនបិ អស្សុតំ សមាគច្ឆតិ ចណ្ហោនបិ កោណេន សមាគច្ឆតិ ឥត្ថិយាបិ បុរិសស្សបិ នាមម្បិ គោត្តម្បិ បុច្ឆតិ កាមស្សបិ និគមស្សបិ នាមម្បិ មគ្គម្បិ បុច្ឆតិ ។ សោ ការិមិនត្ថំ បុដ្ឋោ សមានោ សុញ្ញំ អគារំ បវិសិតុំ អហោសិ តេន ជាវិសី មិណ្ហំ មេ អសុត្តំ អហោសិ តេនាលត្ថំ ការក្ការេន និសិតុំ អហោសិ តេនម្ហិ ឆដ្ឋោ ចណ្ហោន ហត្ថិកា សមាគន្តុំ អហោសិ តេន សមាគមី ចណ្ហោន អស្សុតេន សមាគន្តុំ អហោសិ តេន សមាគមី ចណ្ហោន កោណេន សមាគន្តុំ អហោសិ តេន សមាគមី ឥត្ថិយាបិ បុរិសស្សបិ នាមម្បិ គោត្តម្បិ បុច្ឆិតុំ អហោសិ តេន បុច្ឆិ កាមស្សបិ និគមស្សបិ នាមម្បិ មគ្គម្បិ បុច្ឆិតុំ អហោសិ តេន បុច្ឆិន្តិ ។ សោ អនស្សាសិកោ ឥតិ ព្រហ្មចរិយន្តិ ឥតិ វិធិញ្ញា ធស្មា ព្រហ្មចរិយា ចវិតុំ



ក៏មាន ចូលប្រាថ្នាទីស្រះកាបក៏មាន ចូលប្រាថ្នាទីរោគកាចក៏មាន សួរនាមទីនគររបស់ស្រីឬប្រុសក៏មាន សួរឈ្មោះនិគមផ្លូវទៅស្រុកឬនិគមក៏មាន ។ គ្រានោះកាលបើមានសេចក្តីហេតុនេះកើតឡើង ក៏ប្រាប់ថា ផ្ទះស្ងាត់ដែលខ្ញុំគួរចូលទៅបាន ខ្ញុំក៏ចូលទៅកាន់ផ្ទះស្ងាត់នោះហើយ ដំណាយដែលខ្ញុំមិនគួរបាន ខ្ញុំក៏មិនបានដំណាយនោះហើយ ខ្ញុំដែលគួរទាំងខ្ញុំបាន ខ្ញុំនោះក៏ទាំងខ្ញុំហើយ ខ្ញុំគួរចូលទីនគរកាប ខ្ញុំក៏ចូលទីនគរកាបនោះហើយ ខ្ញុំគួរចូលទីស្រះកាប ខ្ញុំក៏ចូលទីស្រះកាបនោះហើយ ខ្ញុំគួរចូលទីរោគកាច ខ្ញុំក៏ចូលទីរោគកាចនោះហើយ ខ្ញុំគួរសួរនាមទីនគររបស់ស្រីឬប្រុស ខ្ញុំក៏សួរនាមទីនគររបស់ស្រីឬប្រុសនោះហើយ ខ្ញុំគួរសួរឈ្មោះនិគមផ្លូវទៅស្រុកឬនិគម ខ្ញុំក៏សួរឈ្មោះនិគមផ្លូវទៅស្រុកឬនិគមនោះរួចហើយ ។ បុរសនោះលុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះមិនមានទំនងស្រួលផ្ទួនឡើងហើយ ក៏ទៀតណាយចាកព្រហ្មចរិយៈនោះ

បក្កមតិ ។ ឥទំ ខោ សន្ធក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមំ អនស្សាសិកំ ព្រហ្មចរិយំ អក្ខាតំ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ វា នារាធេយ្យ ញាយំ ធម្មំ កុសលំ ។

(៦៦) បុន ចបរំ សន្ធក ឥធេកច្ចោ សត្ថា អនុស្សវិកោ ហោតិ អនុស្សវសច្ចោ ។ សោ អនុស្សវេន ឥតិហីតិហបរម្បរាយ បិដកសម្បទាយ ធម្មំ ទេសេតិ ។ អនុស្សវិកស្ស ខោ បន សន្ធក សត្ថុនោ អនុស្សវសច្ចស្ស សុស្សុតម្បិ ហោតិ ទុស្សុតម្បិ ហោតិ តថាបិ ហោតិ អញ្ញថាបិ ហោតិ ។ តត្រ សន្ធក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា អនុស្សវិកោ អនុស្សវសច្ចោ ។ សោ អនុស្សវេន ឥតិហីតិហបរម្បរាយ បិដកសម្បទាយ ធម្មំ ទេសេតិ ។ អនុស្សវិកស្ស ខោ បន សត្ថុនោ អនុស្សវសច្ចស្ស សុស្សុតម្បិ ហោតិ ទុស្សុតម្បិ ហោតិ តថាបិ ហោតិ អញ្ញថាបិ ហោតិ ។



ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះជាអនស្សាសិកព្រហ្មចរិយ ទី ១ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាទីមិនគួរវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានក្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

(៦៦) ម្នាលសន្ទកៈ ប្រការ ១ ទៀត ក្នុងលោកនេះ មានគ្រូជាអ្នកឮតៗ គ្នាមក ប្រកាន់យកពាក្យដែលឮតៗ ជាជាពាក្យពិត ។ គ្រូនោះឯង តែងសំដែងធម៌តាមពាក្យដែលឮតៗ តាមពាក្យបរម្បរាថាដូច្នេះៗ តាមក្បួនគម្ពីរ ។ ម្នាលសន្ទកៈ ឯគ្រូជាអ្នកឮតៗ គ្នាមក ប្រកាន់យកពាក្យដែលឮតៗ ជាជាពាក្យពិត (នោះ) រមែងឮពាក្យល្អខ្លះ ឮពាក្យអាក្រក់ខ្លះ ពិតខ្លះ មិនពិតខ្លះ ។ ម្នាលសន្ទកៈ វិញ្ញូបុរសរមែងពិចារណាក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចំរើននេះជាអ្នកឮតៗ គ្នាមក ប្រកាន់យកពាក្យដែលឮតៗ ជាជាពាក្យពិត ។ គ្រូនោះឯង តែងសំដែងធម៌តាមពាក្យដែលឮតៗ តាមពាក្យបរម្បរាថាដូច្នេះៗ តាមក្បួនគម្ពីរ ។ ឯគ្រូជាអ្នកឮតៗ គ្នាមក ប្រកាន់យកពាក្យដែលឮតៗ ជាជាពាក្យពិត (នោះ) រមែងឮពាក្យល្អខ្លះ ឮពាក្យអាក្រក់ខ្លះ ពិតខ្លះ មិនពិតខ្លះ ។

សោ អនស្សាសិកំ ឥទំ ព្រហ្មចរិយន្តិ ឥតិ វិទិត្វា តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ ឥទំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយំ អនស្សាសិកំ ព្រហ្មចរិយំ អក្ខាតំ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលំ ។

(៦៨) បុន ចបរំ សន្ទក ឥធេកច្ចោ សត្ថា តក្កី ហោតិ វីមំសី ។ សោ តក្កបរិយាហតំ វីមំសានុចរិតំ សយំបដិភានំ ធម្មំ ទេសេតិ ។ តក្កិតស្ស ខោ បន សន្ទក សត្ថុនោ វីមំសិតស្ស សុតក្កិតម្បិ ហោតិ ទុត្តក្កិតម្បិ ហោតិ តថាបិ ហោតិ អញ្ញថាបិ ហោតិ ។ តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា



បុរសនោះ លុះដឹងច្បាស់ថាព្រហ្មចរិយៈនេះ មិនមានទំនុកស្រួលដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈទី ២ ដែលព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលមិនប្រព្រឹត្ត ក៏មិនបានត្រេកអរ នឹងកុសលធម៌ដែលគួរយល់ដឹងឡើយ ។

(៦៨) ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូខ្លះ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួន ។ ម្នាលសន្ទកៈ ក៏គ្រូអ្នកមានសេចក្តីត្រិះរិះពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ ម្នាលសន្ទកៈ វិញ្ញូបុរសរមែងពិចារណា ក្នុងធម៌នោះដូច្នេះថា គ្រូនេះ

តក្កី វីមំសី ។ សោ តក្កបរិយាហតំ វីមំសានុចរិតំ សយំបដិភានំ ធម្មំ ទេសេតិ ។ តក្កិស្ស ខោ បន សត្ថុនោ វីមំសិស្ស សុតក្កិតម្បិ ហោតិ ទុត្តក្កិតម្បិ ហោតិ តថាបិ ហោតិ អញ្ញថាបិ ហោតិ ។ សោ អនស្សាសិកំ ឥទំ ព្រហ្មចរិយន្តិ ឥតិ វិទិត្វា តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ ឥទំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តតិយំ អនស្សាសិកំ ព្រហ្មចរិយំ អក្ខាតំ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ វា ន អារាធេយ្យ ញាយំ ធម្មំ កុសលំ ។

(៦៨) បុន ចបរំ សន្ទក ឥធេកច្ចោ សត្ថា មន្ទោ មោមូហោ ។ សោ មន្ទត្តា មោមូហត្តា តថា តថា បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ ឯវម្បិ មេ នោ តថាតិបិ មេ នោ



ចំរើននេះ ជាអ្នកមានសេចក្តីត្រិះរិះពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមាន ដោយប្រាជ្ញារបស់ខ្លួន ។ ក៏គ្រូជាអ្នកមានសេចក្តីត្រិះរិះពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ បុរសនោះលុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះ មិនមានទំនុកស្រួលខ្លួនហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈទី ៣ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ឬក៏កាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

(៦៨) ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូជាមនុស្សមានប្រាជ្ញាខ្ទន់ ជាមនុស្សល្ងង់ទៀត ។ គ្រូនោះ ព្រោះតែខ្លួនមានប្រាជ្ញាខ្ទន់ ព្រោះតែខ្លួនល្ងង់ទៀត កាលបើមានអ្នកផងសាកសួរប្រស្នាផ្សេងៗ ហើយ ក៏ដល់នូវការផ្សាយវាចា ផ្សាយសំដីមិនឲ្យស្ទាប់ខ្លួនថា ខ្ញុំយល់ឃើញថា យ៉ាងនេះក៏មិនមែន ខ្ញុំយល់ឃើញថា យ៉ាងនោះក៏មិនមែន

អញ្ញថាតិបិ មេ នោ នោតិបិ មេ នោ នោតិបិ មេ នោតិ ។ តត្រ សន្ទក វិញ្ញូ បុរិសោ ឥតិ បដិសញ្ចិក្ខតិ អយំ ខោ ភវំ សត្ថា មន្ទោ មោមូហោ ។ សោ មន្ទត្តា មោមូហត្តា តថា តថា បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ ឯវន្តិបិ មេ នោ តថាតិបិ មេ នោ អញ្ញថាតិបិ មេ នោ នោតិបិ មេ នោ នោ នោតិបិ មេ នោតិ ។ សោ អនស្សាសិកំ ឥទំ ព្រហ្មចរិយន្តិ ឥតិ វិទិត្វា តស្មា ព្រហ្មចរិយា និព្វិជ្ជ បក្កមតិ ។ ឥទំ ខោ សន្ទក តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចតុត្ថំ អនស្សាសិកំ ព្រហ្មចរិយំ អក្ខាតំ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ វា នារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។ ឥមានិ ខោ សន្ទក



ខ្ញុំយល់ឃើញថា យ៉ាងដទៃក៏មិនមែន ខ្ញុំយល់ឃើញថា មិនមែនក៏ទេ ខ្ញុំយល់ឃើញថា មិនមែនជាមិនមែនក៏ទេ ។ ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណាឃើញដំណើរនោះដូច្នេះថា គ្រូដ៏ចំរើននេះ ជាមនុស្សមានប្រាជ្ញាទន់ ជាមនុស្សល្ងង់ទៀត ។ គ្រូនោះ ហេតុតែខ្លួនមានប្រាជ្ញាទន់ ហេតុតែខ្លួនល្ងង់ទៀត កាលបើមានអ្នកផងសាកសួរប្រស្នាដូច្នោះ ៗ ហើយ ក៏ដល់នូវការផ្សាយវាចា ផ្សាយសំដីមិនឲ្យស្លាប់ខ្លួនថា ខ្ញុំយល់ឃើញថា យ៉ាងនេះក៏មិនមែន ខ្ញុំយល់ឃើញថា យ៉ាងនោះក៏មិនមែន ខ្ញុំយល់ឃើញថាយ៉ាងដទៃក៏មិនមែន ខ្ញុំយល់ឃើញថាមិនមែនក៏ទេ ខ្ញុំយល់ឃើញថា មិនមែនជាមិនមែនក៏ទេ ។ បុរសនោះ លុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះ មិនមានទំនងស្រួលទេដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិក-ព្រហ្មចរិយធម៌ទី ៤ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាទីដែលវិញ្ញូបុរស មិនប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ ម្នាលសន្ទកៈ នេះឯង

តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារិ អនស្សាសិកានិ ព្រហ្មចរិយានិ អក្ខាតានិ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។

(៦៤) អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារិ អនស្សាសិកានេវ ព្រហ្មចរិយានិ អនស្សាសិកានិ ព្រហ្មចរិយានីតិ អក្ខាតានិ យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ ន វសេយ្យ វសន្តោ ច នារាធេយ្យ ញាយំ ធម្មំ កុសលំ ។ សោ បន ភោ អានន្ទ សត្ថា កឹវាទី កិមក្ខាយី យត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។



ឈ្មោះថា អនស្សាសិកព្រហ្មចរិយៈ ៤ ប្រការ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[៦៤] សន្ទកបរិព្វាជក ពោលថា បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះចំឡែកណាស់ ព្រោះថា ព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអនស្សាសិកព្រហ្មចរិយៈ ៤ ប្រការនេះ ថា ជាអនស្សាសិកព្រហ្មចរិយៈពិតប្រាកដមែន ជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះគ្រូនោះនិយាយដូចម្តេច ពោលដូចម្តេច ទើបជាហេតុនាំឲ្យវិញ្ញូបុរស ប្រព្រឹត្តព្រហ្មចរិយៈបានដោយស៊ប់ចិត្ត កាលបើប្រព្រឹត្តហើយ ក៏រមែងត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

[៧០] ឥធ សន្ទក តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ។ បេ ។ សោ ឥមេ បញ្ចនីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មិំ ខោ បន(១) សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារំ វិសេសំ អធិគច្ឆតិ អទ្ធា វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។ បុន

១ ម. សព្វត្ថ បាឋេសុ អយំ បាឋោ នត្ថិ ។



[៧០] ព្រះអានន្ទមានថេរដីកាថា ម្នាលសន្ទកៈ ព្រះតថាគតកើតឡើងក្នុងលោកនេះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវគឺកិលេស ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ គឺទៅកាន់សុខ-ស្ថាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិ-គុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង ព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ ។ បេ ។ ព្រះអង្គបានលះបង់នីវរណធម៌ទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើប្រាជ្ញាឲ្យមានកំឡាំងខ្សោយ ព្រះអង្គស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ។ ម្នាលសន្ទកៈ ចំណែកខាងសាវ័ក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបាន ដោយស្មោះចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏គ្រេកអរនឹង

ចបរំ សន្ទក ភិក្ខុ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ ខោ បន សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។ បុន ចបរំ សន្ទក ភិក្ខុ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ ខោ បន សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។ បុន ចបរំ សន្ទក ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យស្មឹ ខោ បន សន្ទក សត្ថរិ អរិយសាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។



កុសលធម៌ដែលខ្លួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈបានហើយ ។បេ។ ក៏ចូលទុតិយជ្ឈាន ។ ម្នាលសន្ទកៈ សាវ័ក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយសិប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ។បេ។ ក៏ចូលតតិយជ្ឈាន ។ ម្នាលសន្ទកៈ សាវ័ក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះក្នុងសំណាក់គ្រូណា វិញ្ញូបុរស គប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយសិប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ។បេ។ ចូលចតុត្ថជ្ឈាន ។ ម្នាលសន្ទកៈ អរិយសាវ័ក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរស គប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយសិប់ចិត្ត ក្នុងសំណាក់គ្រូនោះ ។ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

[៧១] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ យស្មឹ ខោ បន សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ



[៧១] ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារ ជាចិត្តនឹងនួន ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ រមែងបង្អោនចិត្តទៅរកបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញាលើកឃើញនូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ។ ភិក្ខុនោះរមែងរលឹកនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រលឹកឃើញនូវជាតិដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះឯង ។ ម្នាលសន្ទកៈ សាវក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបាន ដោយស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ គប្បីត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។ ភិក្ខុនោះកាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារ ជាចិត្តនឹងនួន ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ រមែងបង្អោនចិត្តទៅរកចុតូបបាតញ្ញាណ គឺប្រាជ្ញាជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិនៃពួកសត្វ ( ចុតូបបាតញាណ ) ។ ភិក្ខុនោះ

ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ យស្មិំ ខោ បន សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលំ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ



មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុ របស់មនុស្សធម្មតា រមែងឃើញនូវពួកសត្វដែលច្យុតដែលកើតឡើង ថោកទាប ខ្ពង់ខ្ពស់ មានវណ្ណៈល្អ មានវណ្ណៈអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ តែងដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួន ។ ម្នាលសន្ទកៈ សាវក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយស៊ប់ ចំពោះគ្រូក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ ដែលខ្លួនគប្បីដឹង ។ ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារ ជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រយ៉ាងនេះហើយ រមែងបង្អោនចិត្តទៅកាន់អាសវក្ខយញាណ គឺប្រាជ្ញាដឹង នូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ។ ភិក្ខុនោះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីប្រជុំកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិ ជាដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាផ្លូវប្រតិបត្តិ ជាដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ

កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មិំ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ យស្មិំ ខោ បន សន្ទក សត្ថរិ សាវកោ ឯវរូបំ ឧឡារវិសេសំ អធិគច្ឆតិ តត្ថ វិញ្ញូ បុរិសោ សសក្កំ ព្រហ្មចរិយំ វសេយ្យ វសន្តោ ច អារាធេយ្យ ញាយំ ធម្មំ កុសលន្តិ ។

(៧៦) យោ បន សោ ភោ អានន្ទ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ បរិភុញ្ជេយ្យ សោ កាមេ ។ យោ សោ សន្ទក ភិក្ខុ អរហំ ខីណាសវោ



ហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតចាកភវាសវៈផង ចិត្តផុតចាកអវិជ្ជាសវៈផង កាលបើចិត្តភិក្ខុនោះផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងដល់ភិក្ខុនោះថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលសន្ទកៈ សាវកនៃមនុស្សណា ដឹងនូវគុណវិសេសដ៏ល្អលើសលុបមានសភាពយ៉ាងនេះ គួរសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបាន ដោយស៊ប់ចិត្តគួរសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

(៧៦) សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ភិក្ខុណា ជាព្រះអរហន្ត ខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ចំពាក់ ក្នុងភពអស់ហើយ មានចិត្តផុត (ចាកអាសវៈទាំងឡាយ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះនៅបរិភោគកាមទាំងឡាយដែរឬ ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ ភិក្ខុណា ជាព្រះអរហន្ត ខីណាស្រព

វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តស-
ទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា វិមុត្តោ
អភព្វោ សោ បញ្ច ឋានានិ អជ្ឈាចរិតុំ អភព្វោ
ខីណាសវោ ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេតុំ
អភព្វោ ខីណាសវោ ភិក្ខុ អទិន្នំ ថេយ្យសង្ខាតំ
អាទាតុំ អភព្វោ ខីណាសវោ ភិក្ខុ មេថុនំ
ធម្មំ បដិសេវិតុំ អភព្វោ ខីណាសវោ ភិក្ខុ
សម្បជានមុសា ភាសិតុំ អភព្វោ ខីណាសវោ ភិក្ខុ
សន្និធិការកំ កាមេ បរិភុញ្ជិតុំ សេយ្យថាបិ បុព្វេ
អាគារិយភូតោ ។ យោ សោ សន្ទក ភិក្ខុ អរហំ
ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ
អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា
វិមុត្តោ អភព្វោ សោ ឥមានិ បញ្ច ឋានានិ
អជ្ឈាចរិតុន្តិ ។



បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួច
ហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយ
លំដាប់ហើយ មានធម៌ជាគ្រឿងជាប់ចំពាក់ក្នុងភពអស់ហើយ មានចិត្ត
ផុត (ចាកអាសវៈទាំងឡាយ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនដែល
ប្រព្រឹត្តល្មើសនូវហេតុ ៥ យ៉ាងឡើយ គឺភិក្ខុជាព្រះខីណាស្រព មិនដែល
ក្លែងធ្វើសត្វឲ្យដាច់ចាកជីវិត ១ ភិក្ខុជាព្រះខីណាស្រព មិនដែលកាន់យក
ទ្រព្យដែលគេមិនបានឲ្យ គោលគឺការលួច ១ ភិក្ខុជាព្រះខីណាស្រព
មិនដែលសេពមេថុនធម្ម ១ ភិក្ខុជាព្រះខីណាស្រព មិនដែលពោល
កុហកទាំងដឹងសេចក្តីច្បាស់ ១ ភិក្ខុជាព្រះខីណាស្រព មិនដែលធ្វើនូវ
ការសន្សំទុក (នូវវត្ថុទាំងឡាយមានស្លជាដើម) បរិភោគនូវកាមទាំងឡាយ
ដូចកាលដែលខ្លួនទៅជាគ្រហស្ថ ក្នុងកាលពីដើម ១ ។ ម្នាលសន្ទកៈ
ភិក្ខុណា ជាព្រះអរហន្ត ខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌
គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចស្រេចហើយ បានដាក់ចុះ
ភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ
មានធម៌ជាគ្រឿងជាប់ចំពាក់ ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះ
(ចាកអាសវៈទាំងឡាយ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនដែល
ប្រព្រឹត្តល្មើសនូវហេតុទាំង ៥ យ៉ាងនេះឡើយ ។

(៧៣) យោ បន សោ ភោ អានន្ទ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ តស្ស ចរតោ ច តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតំ ខីណា មេ អាសវាតិ ។ តេនហិ សន្ទក ឧបមន្តេ ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ សេយ្យថាបិ សន្ទក បុរិសស្ស ហត្ថបាទា ឆិន្នា តស្ស ចរតោ ចេវ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ឆិន្នាវ ហត្ថបាទា អបិច ខោ បន បច្ចវេក្ខមានោ ជានាតិ ឆិន្នា មេ ហត្ថបាទាតិ ។ ឯវមេវ ខោ សន្ទក យោ សោ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ



[៧៣] សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ចុះភិក្ខុណា ជាព្រះអរហន្ត ខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌ គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចស្រេចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ចំពាក់ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះ (ចាកអាសវៈទាំងឡាយ) ព្រោះដឹងដោយប្រពៃ តើភិក្ខុនោះ កាលដើរក្ដី ឈរក្ដី ដេកលក់ក្ដី ភ្ញាក់ឡើងក្ដី ញាណទស្សនៈកើតមិនដាច់ជានិច្ចថា អាសវៈទាំងឡាយរបស់អញអស់ហើយដូច្នេះឬទេ ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ បើដូច្នោះ អាត្មានឹងធ្វើពាក្យឧបមាឲ្យអ្នក (ស្ដាប់) ដ្បិតវិញ្ញូបុរសពួកខ្លះក្នុងលោកនេះ រមែងយល់សេចក្ដីនៃភាសិតបានដោយពាក្យឧបមា ។ ម្នាលសន្ទកៈ មានបុរសម្នាក់កំបុតដៃ កំបុតជើង បុរសនោះ កាលដើរក្ដី ឈរក្ដី ដេកលក់ក្ដី ភ្ញាក់ឡើងក្ដី ដៃនិងជើងក៏នៅតែកំបុតដាច់ជានិច្ចដដែល តែកាលបើបុរសនោះពិចារណាទើបដឹងថា អាត្មាអញកំបុតដៃ កំបុតជើង សេចក្ដីនេះមានឧបមាយ៉ាងណា ម្នាលសន្ទកៈ មានឧបមេយ្យដូចភិក្ខុ ដែលជាព្រះអរហន្ត ខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចហើយ

ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ តស្ស ចរតោ ចេវ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ខីណាវ អាសវា អបិច ខោ បន បច្ចវេក្ខមានោ ជានាតិ ខីណា មេ អាសវាតិ ។

(៧៦) កីវ(១) ពហុកា បន ភោ អានន្ទ ឥមស្មឹ ធម្មវិនយេ និយ្យាតារោតិ ។ ន ខោ សន្ទក ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ច សតានិ អថខោ ភិយ្យោវ យេ ឥមស្មឹ ធម្មវិនយេ និយ្យាតារោតិ ។ អច្ឆរិយំ ភោ អានន្ទ អព្ភុតំ ភោ អានន្ទ ន ច នាម សធម្មោក្កំសនា ភវិស្សតិ ន បរធម្មវម្ភនា អាយតនេវ ធម្មទេសនា តាវ ពហុកា ច និយ្យាតារោ បញ្ញាយិស្សន្តិ ។ ឥមេ បន អាជីវកា

១ ម. កិំ ។



បានដាក់ភារៈចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ មានធម៌ជាគ្រឿងចំណងក្នុងភពអស់ហើយ មានចិត្តផុតស្រឡះ (ចាកអាសវៈទាំងឡាយ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះកាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី អាសវៈទាំងឡាយ ក៏នៅតែអស់ដាច់ជានិច្ចជួបដើម តែកាលបើភិក្ខុនោះពិចារណាទើបដឹងថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ។

(៧៦) សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ចុះពួកបុគ្គលអ្នកស្រោចស្រង់សត្វក្នុងធម្មវិន័យនេះ មានច្រើនប៉ុន្មាននាក់ទៅ ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ មិនមែនមានត្រឹមតែ ១០០ នាក់ ២០០ នាក់ ៣០០ នាក់ ៤០០ នាក់ ឬ ៥០០ នាក់ទេ តាមពិតនោះ ពួកបុគ្គលដែលជាអ្នកស្រោចស្រង់សត្វក្នុងធម្មវិន័យនេះ មានច្រើនណាស់ ។ សន្ទកបរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចំរើន ហេតុនេះចំឡែកណាស់ ព្រោះថាការលើកតំកើងធម៌របស់ខ្លួនមិនមាន ការបន្តុះបង្អាប់ធម៌របស់អ្នកដទៃ ក៏មិនមាន មានតែការសំដែងធម៌ សំដៅយកព្រះនិព្វានតែម្យ៉ាង ទាំងបុគ្គលអ្នកស្រោចស្រង់សត្វក៏មានច្រើនប្រាកដពិត ចំណែកឯពួកអាជីវក ជា

បុត្តមតាយ បុត្តា អត្តានញ្ចេវ ឧក្កំសេន្តិ បរេ ច វម្ភេន្តិ តយោ ចេវ និយ្យាតារោ បញ្ញាបេន្តិ សេយ្យថីទំ នន្ទំ វច្ឆំ កិសំ សង្កិច្ចំ មក្ខលិំ គោសាលន្តិ ។ អថខោ សន្ទកោ បរិព្វាជកោ សកំ បរិសំ អាមន្តេសិ ចរន្តុ ភោន្តោ សមណេ គោតមេ ព្រហ្មចរិយវាសោ ន ទានិ សុករំ អម្ហេហិ លាភសក្ការសិលោកោ បរិច្ចជិតុន្តិ ។ ឥតិ ហិទំ សន្ទកោ បរិព្វាជកោ សកំ បរិសំ ឧយ្យោជេសិ ភគវតិ ព្រហ្មចរិយេតិ ។

សន្ទកសុត្តំ ឆដ្ឋំ ។

---



កូនមែស្រីស្លាប់កូន[1]នេះ តែងលើកតំកើងខ្លួនឯងផង បន្ទាបបង្អាប់អ្នកដទៃផង តាំងបញ្ញត្តបុគ្គលអ្នកស្រោចស្រង់សត្វចាកទៃ ៣ នាក់ គឺព្រះឈ្មោះនន្ទវច្ឆៈ ១ កិសសង្កិច្ចៈ ១ មក្ខលិគោសាល ១ ។ លំដាប់នោះ សន្ទកបរិព្វាជកហៅបរិស័ទរបស់ខ្លួនមក ហើយប្រាប់ថា អ្នកដ៏ចំរើនទាំងឡាយ ចូរប្រព្រឹត្តចុះ (ព្រោះថា) ការប្រព្រឹត្តិព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម (រមែងមានប្រាកដ) ឥឡូវនេះមិនងាយនឹងលះបង់លាភៈ សក្ការៈ និងសេចក្ដីសរសើរ ក្នុងកាលឥឡូវនេះបានទេ ។ សន្ទកបរិព្វាជក តែងបញ្ជូនបរិស័ទរបស់ខ្លួននេះ ទៅក្នុងព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

ចប់ សន្ទកសូត្រ ទី ៦ ។

---

[1] សន្ទកបរិព្វាជក លុះបានស្ដាប់ធម៌របស់ព្រះអានន្ទ ហើយក៏សំគាល់ថា ពួកអាជីវកទាំងឡាយសុទ្ធតែជាមនុស្សស្លាប់ (ព្រោះគេជាអ្នកស្លាប់ចាកគុណ ឬស្លាប់ប្រយោជន៍ដែលត្រូវបាន) ឯម្ដាយរបស់ពួកអាជីវកទាំងនោះ ទើបឈ្មោះថាជាស្រីស្លាប់កូន និងជាកូនរបស់ស្រីនោះកើតមកឥតប្រយោជន៍ ។ អដ្ឋកថា ។

## សត្តមំ មហាសកុលុទាយិសុត្តំ

(៧៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា មោរនិវាបេ បរិព្វាជការាមេ បដិវសន្តិ សេយ្យថីទំ អន្នភារោ វរតរោ(១) សកុលុទាយី ច បរិព្វាជកោ អញ្ញេ ច អភិញ្ញាតា អភិញ្ញាតា បរិព្វាជកា ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អថខោ ភគវតោ ឯតទហោសិ អតិប្បគោ ខោ តាវ រាជគហេ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន មោរនិវាបោ បរិព្វាជការាមោ យេន សកុលុទាយី ច(២) បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ ភគវា យេន មោរនិវាបោ បរិព្វាជការាមោ តេនុបសង្កមិ ។

១ ឱ. អន្នភារោ វរធរោ ។ ម. អន្នភារោ វរធរោ ។ ២ ឱ. ម. ចសទ្ទោ នត្ថិ ។

## មហាសកុលុទាយិសូត្រ ទី ៧

(៧៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានពួកបរិព្វាជកជាច្រើន សុទ្ធតែមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅអាស្រ័យក្នុងបរិព្វាជការាម ជាមោរនិវាបស្ថាន (កន្លែងសម្រាប់ឲ្យចំណីដល់ពួកសត្វក្ងោក) បរិព្វាជកទាំងនោះ គឺ អន្នភារ-បរិព្វាជក ១ វរតរបរិព្វាជក ១ សកុលុទាយីបរិព្វាជក ១ និងពួកបរិព្វាជកដទៃទៀត សុទ្ធតែមានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ក្នុងវេលាបុព្វណ្ហសម័យ ។ ទើបព្រះមានព្រះភាគទ្រង់ បរិវិតក្កយ៉ាងនេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ព្រឹកណាស់នៅឡើយ បើដូច្នោះ គួរតែតថាគតចូលទៅកាន់សកុលុទាយីបរិព្វាជក ក្នុងបរិព្វាជការាម ជាមោរនិវាបស្ថានសិន ។ ហើយក៏ព្រះមានព្រះភាគ ទ្រង់ក៏ធ្វើដំណើរចូលសំដៅទៅឯបរិព្វាជការាម មោរនិវាបស្ថាន ។

(៧៦) តេន ខោ បន សមយេន សកុលុទាយិ បរិព្វាជកោ មហតិយា បរិព្វាជកបរិសាយ សទ្ធិំ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ(១) សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ កុម្ភដាសីកថំ(២) បុព្វេបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ សកុលុទាយិ បរិព្វាជកោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន សកំ បរិសំ សណ្ឋាបេសិ(៣) អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ សមណោ គោតមោ អាគច្ឆតិ

១ ឱ. បុរិសកថំ ឥត្ថីកថំ ទិស្សតិ ។ ២ ឱ. ម កុម្ភទាសីកថំ ឥ ទិស្សតិ ។ ៣ ឱ. សណ្ឋាបេសិ ។



(៧៦) ក៏សម័យនោះឯង សកុលុទាយិបរិព្វាជក កំពុងអង្គុយជាមួយ នឹងបរិព្វាជកបរិស័ទជាច្រើន ដែលមានសំឡេងហ៊ឺ សំឡេងខ្លាំង កំពុងតែនិយាយនូវតិរច្ឆានកថាផ្សេងៗជាច្រើន គឺរាជកថា ចោរកថា មហាមត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា សយនកថា មាលាកថា គន្ធកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា កុម្ភទាសីកថា បុព្វេបេតកថា នានត្តកថា លោកក្ខាយិកកថា សមុទ្ទក្ខាយិកកថា ឥតិភវាភវកថា(១) ដូច្នេះខ្លះ ដូច្នោះខ្លះ ។ សកុលុទាយិបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ឃាត់បរិស័ទរបស់ខ្លួនថា អ្នកដ៏ចំរើនទាំងឡាយ ចូរមានសំឡេងតិចៗ អ្នកដ៏ចំរើនទាំងឡាយ កុំនិយាយខ្លាំងឡើយ នេះ ព្រះសមណគោតម កំពុងស្តេចមក ក៏

១ ឬមើលសេចក្តីប្រែក្នុងវិន័យបិដក ភាគ ៦ ទំព័រ ៤៣៧ ឬសុត្តន្តបិដក ភាគ ៤៤ ទំព័រ ១៧ ផង ។

អប្បសទ្ទកាមោ ខោ បន សោ អាយស្មា អប្បសទ្ទវណ្ណវាទី(១) អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ អថខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។ អថខោ ភគវា យេន សកុលុទាយិ បរិព្វាជកោ តេនុបសង្កមិ ។ អថខោ សកុលុទាយិ បរិព្វាជកោ ភគវន្តំ ឯតទវោច ឯតុ ខោ ភន្តេ ភគវា ស្វាគតំ ភន្តេ ភគវតោ ចិរស្សំ ខោ ភន្តេ ភគវា ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភន្តេ ភគវា ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ សកុលុទាយិបិ ខោ បរិព្វាជកោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សកុលុទាយឹ បរិព្វាជកំ ភគវា ឯតទវោច កាយ នុត្ថ ឧទាយិ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។

១ ឱ. អប្បសទ្ទស្ស វណ្ណវាទី ។ ម. អប្បសទ្ទវិនីតោ អប្បសទ្ទស្ស វណ្ណវាទី ។



លោកមានអាយុនោះ ត្រូវការតែនឹងសំឡេងតិច ៗ សរសើរតែសំឡេងតិច ៗ ទេ បើដឹងត្រូវតែផ្លូវម្ដេច ឲ្យព្រះសមណគោតមនោះជ្រាបថា បរិស័ទមានសំឡេងតិច ៗ ហើយនឹងសំគាល់ខ្លួនថា ជាទីដែលគួរចូលមកទេ ។ គ្រានោះឯង ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាស្ងៀម ។ ទើបព្រះមានព្រះភាគ ស្ដេចចូលសំដៅទៅត្រង់ទី ដែលសកុលុទាយិបរិព្វាជកនៅ ។ លំដាប់នោះឯង សកុលុទាយិបរិព្វាជក ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគស្ដេចចូលមកចុះ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគយាងស្ដេចមកស្រួលហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគមានស្ដេចមកក្នុងទីនេះយូរណាស់ហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគស្ដេចគង់ លើអាសនៈបុគ្គលក្រាលស្រេចហើយ ។ ព្រះមានព្រះភាគក៏គង់លើអាសនៈ ដែលបរិព្វាជកក្រាលថ្វាយ ។ ចំណែកខាងសកុលុទាយិបរិព្វាជក កាន់យកនូវអាសនៈទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសកុលុទាយិបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលឧទាយិ អ្នកទាំងឡាយ អង្គុយប្រជុំគ្នានិយាយរឿងអ្វីអម្បាញ់មិញនេះ ចុះរឿងអ្វីជាចន្លោះ ផ្លូវម្ដេច ដែលអ្នកទាំងឡាយនិយាយចំពាក់ទៅ ។

[៧៧] តិដ្ឋតេសា ភន្តេ កថា យាយ មយំ ឯតរហិ កថាយ សន្និសិន្នា នេសា ភន្តេ កថា ភគវតោ ទុល្លភា ភវិស្សតិ បច្ឆាបិ សវនាយ បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ នានាតិត្ថិយានំ សមណព្រាហ្មណានំ កុតូហលសាលាយ[១] សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ លាភា វត ភោ អង្គមគធានំ សុលទ្ធំ វត ភោ អង្គមគធានំ យត្រិមេ[២] សមណព្រាហ្មណា សង្ឃិនោ គណិនោ គណាចរិយា ញាតា យសស្សិនោ តិត្ថករា សាធុសម្មតា ពហុជនស្ស រាជគហំ វស្សាវាសំ ឱសដា[៣] ។ អយម្បិ ខោ បូរណោ កស្សបោ សង្ឃី ចេវ គណី ច គណាចរិយោ[៤] ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស

១ កោតូហលសាលាយន្តិបិ បាឋោ ។ ២ ម. យត្ថិមេ ។ ម. គត្រិមេ ។ ៣ ឱ. ម. វុសិតា ។ ៤ ម. គណាចរិយោ ច ។



(៧៧) បពិត្រព្រះអង្គដ៏ចំរើន សំដីដែលយើងខ្ញុំ អង្គុយប្រជុំគ្នានិយាយសព្វថ្ងៃនេះ សូមលើកទុកសិនចុះ បពិត្រព្រះអង្គដ៏ចំរើន សំដីនុះ ព្រះមានព្រះភាគ នឹងមិនបានទ្រង់ព្រះសណ្ដាប់ក្នុងកាលជាខាងក្រោយទេ បពិត្រព្រះអង្គដ៏ចំរើន ថ្ងៃកន្លងទៅមុនៗ ពួកសមណព្រាហ្មណ៍មានលទ្ធិផ្សេងៗ មកប្រជុំគ្នាក្នុងកុតូហលសាលា[១] សំដីជាចន្លោះនេះក៏កើតឡើងថា អើហ្ន៎ ជាលាភរបស់អ្នកស្រុកអង្គៈនិងអ្នកស្រុកមគធៈហើយតើ អើហ្ន៎ អ្នកស្រុកអង្គៈនិងអ្នកស្រុកមគធៈ បានល្អហើយតើ ព្រោះពួកសមណព្រាហ្មណ៍ទាំងនេះ មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកត្រឹមត្រូវ បានចូលមកនៅចាំវស្សាក្នុងក្រុងរាជគ្រឹះនេះ ។ បូរណកស្សបនេះ មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកត្រឹមត្រូវ

១ ជាឈ្មោះសាលាសាធារណៈ សំរាប់ពួកសមណព្រាហ្មណ៍ ដែលមានលទ្ធិផ្សេងៗគ្នា មកប្រជុំជជែកគ្នា ដែលជាទីកើតសេចក្ដីកង្វល់រាល់ថ្ងៃ ។ ហេតុនោះហៅថា កុតូហលសាលា ព័ត៌មាន ។ អដ្ឋកថា ។

សោបិ រាជគហំ វស្សាវាសំ ឧបគតោ ។ អយម្បិ ខោ មក្ខលិ គោសាលោ... អជិតោ កេសកម្ពលោ... បកុធោ កច្ចាយនោ... សញ្ជយោ បេលដ្ឋបុត្តោ... និគណ្ឋោ នាដបុត្តោ សង្ឃី ចេវ គណី ច គណាចរិយោ ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស សោបិ រាជគហំ វស្សាវាសំ ឧបគតោ ។ អយម្បិ ខោ សមណោ គោតមោ សង្ឃី ចេវ គណី ច គណាចរិយោ ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស សោបិ រាជគហំ វស្សាវាសំ ឧបគតោ ។ កោ នុ ខោ ឥមេសំ ភវតំ សមណព្រាហ្មណានំ សង្ឃីនំ គណីនំ គណាចរិយានំ ញាតានំ យសស្សីនំ តិត្ថករានំ សាធុសម្មតានំ ពហុជនស្ស សាវកានំ សក្កតោ គរុកតោ មានិតោ បូជិតោ កញ្ច (១) បន សាវកា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តីតិ

---

១ ម. កំ ចន ម ពិត្យ ។





ឥឡូវ បូរណកស្សបនោះឯង ក៏បានចូលមកនៅចាំវស្សាក្នុងក្រុងរាជគ្រឹះដែរ ។ ចំណែកឈ្មោះមក្ខលិគោសាលនោះឯង .. អជិតកេសកម្ពល... បកុធកច្ចាយនៈ... សញ្ជយវេលដ្ឋបុត្ត .. និគណ្ឋនាដបុត្ត មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកប្រសើរ និគណ្ឋនាដបុត្តនោះឯង ក៏បានចូលមកនៅចាំវស្សា ក្នុងក្រុងរាជគ្រឹះដែរ ។ ចំណែកព្រះសមណគោតមនេះ មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកប្រសើរ ព្រះសមណគោតមអង្គនោះឯង ទ្រង់បានចូលមកចាំវស្សា ក្នុងក្រុងរាជគ្រឹះដែរ ។ បណ្ដាពួកសមណព្រាហ្មណ៍ដ៏ចំរើន ដែលមានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាសប្បុរសទាំងអម្បាលនេះ តើបុគ្គលណាដែលពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា តើពួកសាវ័ក ធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យនឹងបុគ្គលណា ។

(៧៨) តត្រេកច្ចេ ឯវមាហំសុ អយំ ខោ បូរណោ កស្សបោ សង្ឃី ចេវ គណី ច គណាចរិយោ ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស សោ ខោ សាវកានំ ន សក្កតោ ន គរុកតោ ន មានិតោ ន បូជិតោ ន ច បន បូរណំ កស្សបំ សាវកា សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។ ភូតបុព្វំ បូរណោ កស្សបោ អនេកសតាយ បរិសាយ ធម្មំ ទេសេសិ ។ តត្រ អញ្ញតរោ(*) បូរណស្ស កស្សបស្ស សាវកោ សទ្ទមកាសិ មា ភោន្តោ បូរណំ កស្សបំ ឯតមត្ថំ បុច្ឆិត្ថ នេសោ ឯតំ ជានាតិ មយមេតំ ជានាម អម្ហេ ឯតមត្ថំ បុច្ឆថ មយមេតំ ភវន្តានំ ព្យាករិស្សាមាតិ ។ ភូតបុព្វំ បូរណោ កស្សបោ ពាហា បគ្គយ្ហ កន្ទន្តោ ន លភតិ អប្បសទ្ទា ភោន្តោ ហោថ មា ភោន្តោ សទ្ទមកត្ថ នេតេ ភវន្តេ បុច្ឆន្តិ អម្ហេ ឯតេ បុច្ឆន្តិ មយមេតេសំ ព្យាករិស្សាមាតិ ។

* ម. តត្រញ្ញតរោ ។ ឧ. តត្រាញ្ញតរោ ។



(៧៨) បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា គ្រូឈ្មោះបូរណកស្សបនេះឯង មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាម្ចាស់លទ្ធិ ដែលជនច្រើនសន្មតហើយថាជាអ្នកត្រឹមត្រូវ (តែពិតមែន តែ) បូរណកស្សបនោះឯង ពួកសាវ័ក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ ទាំងពួកសាវ័ក មិនធ្វើសក្ការៈ គោរព នៅអាស្រ័យនឹងបូរណកស្សបឡើយ ។ ព្រោះធ្លាប់មានរឿងថា បូរណកស្សប បានសំដែងធម៌ដល់បរិស័ទច្រើនរយ ។ បណ្ដាសាវ័កទាំងនោះ មានសាវ័កម្នាក់របស់បូរណកស្សប បានស្រែកឡើងថា ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយ កុំសួរសេចក្ដីនុ៎ះ នឹងបូរណកស្សបឡើយ បូរណកស្សបនោះ មិនដឹងសេចក្ដីនុ៎ះទេ ពួកយើងទើបដឹងសេចក្ដីនុ៎ះ អ្នកទាំងឡាយ សួរសេចក្ដីនុ៎ះនឹងយើងហើយ ពួកយើងនឹងព្យាករសេចក្ដីនុ៎ះ ដល់ពួកអ្នកដ៏ចំរើនបាន ។ ធ្លាប់មានរឿងថា បូរណកស្សបផ្គងនូវដើមដៃទាំងឡាយ កន្ទក់កន្ទេញហើយមិនបានពាក្យសំដីថា អ្នកដ៏ចំរើនទាំងឡាយ ចូរមានសំឡេងតិច ៗ អ្នកដ៏ចំរើនទាំងឡាយ កុំស្រែកខ្លាំងឡើយ ពួកជនទាំងនុ៎ះ មិនសួរចំពោះអ្នកដ៏ចំរើនទាំងឡាយទេ ពួកជនទាំងនុ៎ះ សួរតែយើងទេ យើងនឹងព្យាករដល់ពួកជនទាំងនោះបាន ។

ពហូ ខោ បន បូរណស្ស កស្សបស្ស សាវកា វាទំ អារោបេត្វា អបក្កន្តា ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតំ តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណន្តេ(១) វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ ចរ វាទប្បមោក្ខាយ និព្វេឋេហិ វា សចេ បហោសីតិ ។ ឥតិ បូរណោ កស្សបោ សាវកានំ ន សក្កតោ ន គរុកតោ ន មានិតោ ន បូជិតោ ន ច បន បូរណំ កស្សបំ សាវកា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរន្តិ អក្កុដ្ឋោ ច បន បូរណោ កស្សបោ ធម្មក្កោសេនាតិ ។ ឯកច្ចេ ឯវមាហំសុ អយម្បិ ខោ មក្ខលិ គោសាលោ.. អជិតោ

១ ឱ. ស៊ីចិណ្ណន្តេ ។

ចំណែកពួកសាវ័កជាច្រើន លើកវាទៈ ( ពោលប្រកាន់លទ្ធិ ) ដល់បូរណកស្សប ហើយចៀសចេញទៅដោយពាក្យថា អ្នកមិនដឹងច្បាស់នូវធម្មវិន័យនេះទេ ខ្ញុំទើបដឹងច្បាស់នូវធម្មវិន័យនេះ អ្នកដឹងច្បាស់នូវធម្មវិន័យនេះ ដូចម្តេចបាន បើអ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យខ្ញុំប្រកបដោយប្រយោជន៍ ពាក្យអ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកបែរជានិយាយមុន អ្នកឯងសន្សំនៅក្តីខុសមកច្រើនហើយ ខ្ញុំលើកវាទៈដល់អ្នកហើយ អ្នកត្រូវយើងសង្កត់សង្កិនហើយ អ្នកចូរទៅដោះវាទៈចេញ បើអ្នកឯងល្មមដោះខ្លួនឯងបាន ចូរដោះមកចុះ ។ ពួកសាវ័ក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាបូរណកស្សប ទាំងពួកសាវ័ក មិនធ្វើសក្ការៈគោរព នៅអាស្រ័យនឹងបូរណកស្សបទេ ដោយប្រការដូច្នេះឯង មួយទៀត បូរណកស្សបត្រូវគេជេរ ដោយពាក្យជេរប្រកបដោយធម៌ ។ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា មក្ខលិគោសាលនេះ ក៏ដែរ... អជិត-

កេសកម្ពលោ... បកុធោ កច្ចាយនោ... សញ្ច-
យោ ពេលដ្ឋបុត្តោ... និគណ្ឋោ នាដបុត្តោ សង្ឃី ចេវ
គណី ច គណាចរិយោ ញាតោ យសស្សី តិត្ថ-
ករោ សាធុសម្មតោ ពហុជនស្ស សោបិ សាវកានំ
ន សក្កតោ ន គរុកតោ ន មានិតោ ន បូជិតោ
ន ច បន[១] និគណ្ឋំ នាដបុត្តំ សាវកា សក្កត្វា
គរុកត្វា ឧបនិស្សាយ វិហរន្តិ ។ ភូតបុព្វំ និគណ្ឋោ
នាដបុត្តោ អនេកសតាយ បរិសាយ ធម្មំ ទេសេសិ ។
តត្រ អញ្ញតរោ និគណ្ឋស្ស នាដបុត្តស្ស សាវកោ
សទ្ទមកាសិ មា ភោន្តោ និគណ្ឋំ នាដបុត្តំ ឯតមត្ថំ
បុច្ឆិត្ថ នេសោ ឯតំ ជានាតិ មយមេតំ ជានាម
អម្ហេ ឯតមត្ថំ បុច្ឆថ មយមេតំ ភវន្តានំ ព្យាករិស្សា-
មាតិ ។ ភូតបុព្វំ និគណ្ឋោ នាដបុត្តោ ពាហា
បគ្គយ្ហ កន្ទន្តោ ន លភតិ អប្បសទ្ទា ភោន្តោ
ហោន្តុ មា ភោន្តោ សទ្ទមកត្ថ នេមេ ភវន្តេ បុច្ឆន្តិ

១ ម. ន បន ។



កេសកម្ពល... បកុធកច្ចាយនៈ...សញ្ជយវេលដ្ឋបុត្ត...និគន្ឋនាដបុត្ត មាន
ពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជា
មេលទ្ធិ ដែលជនច្រើនសន្មតហើយថាជាអ្នកត្រឹមត្រូវល្អ និគន្ឋនាដបុត្ត
នោះ ក៏ពួកសាវ័ក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ
ពួកសាវ័ក មិនធ្វើសក្ការៈគោរព នៅអាស្រ័យនឹងនិគន្ឋនាដបុត្តឡើយ ។
ធ្លាប់មានរឿងថា និគន្ឋនាដបុត្ត បានសំដែងធម៌ដល់បរិស័ទច្រើនរយ ។
ក្នុងបរិស័ទនោះ មានសាវ័កម្នាក់របស់និគន្ឋនាដបុត្ត បានស្រែកឡើង
ថា អ្នកទាំងឡាយដ៏ចំរើន កុំសួរនូវសេចក្តីនុះនឹងនិគន្ឋនាដបុត្តឡើយ
និគន្ឋនាដបុត្តនោះ មិនដឹងសេចក្តីនុះទេ យើងទើបដឹងសេចក្តីនុះ
អ្នកទាំងឡាយ សួរសេចក្តីនុះនឹងយើងហើយ យើងនឹងព្យាករសេចក្តីនុះ
ដល់អ្នកដ៏ចំរើនទាំងឡាយបាន ។ ធ្លាប់មានរឿងថា និគន្ឋនាដបុត្ត
ផ្គងនូវដើមដៃទាំងឡាយ កន្ទក់កន្ទេញហើយមិនបាននូវពាក្យថា អ្នកដ៏
ចំរើនទាំងឡាយ ចូរមានសំឡេងតិច ។ អ្នកដ៏ចំរើនទាំងឡាយ កុំ
និយាយខ្លាំងឡើយ ពួកជនទាំងនុះ មិនសួរនូវអ្នកដ៏ចំរើនទាំងឡាយទេ

អម្ហេ ឯតេ បុច្ឆន្តុ មយមេតេសំ(១) ព្យាករិស្សាមាតិ ។ ពហូ ខោ បន និគណ្ឋស្ស នាដបុត្តស្ស សាវកា វាទំ អារោបេត្វា អបក្កន្តា ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតំ តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណំ តេ វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ ចរ វាទប្បមោក្ខាយ និព្ពេឋេហិ វា សចេ បហោសីតិ ។ ឥតិ និគណ្ឋោ នាដបុត្តោ សាវកានំ ន សក្កតោ ន គរុកតោ ន មានិតោ ន បូជិតោ ន ច បន និគណ្ឋំ នាដបុត្តំ សាវកា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរន្តិ អក្កុដ្ឋោ ច បន និគណ្ឋោ នាដបុត្តោ ធម្មក្កោសេនាតិ ។

១ ម. ឥមេសំ ។



ពួកជនទាំងនុ៎ះ ស្គាល់នូវយើងទេតើ យើងនឹងព្យាករណ៍ពួកជនទាំងនោះបាន ។ ចំណែកខាងពួកសាវ័កជាច្រើនរបស់និគន្ថនាដបុត្ត លើកឡើងនូវជំទាស់ហើយចៀសចេញទៅ ដោយពាក្យថា អ្នកមិនដឹង មិនដឹងធម៌វិន័យនេះទេ ខ្ញុំទើបដឹងច្បាស់ធម៌វិន័យនេះ អ្នកនឹងដឹងធម៌វិន័យនេះ ដូចម្តេចកើត អ្នកប្រតិបត្តិខុសហើយ ខ្ញុំទើបប្រតិបត្តិត្រូវ សំដីខ្ញុំប្រកបដោយប្រយោជន៍ សំដីអ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយ ពាក្យដែលគេនិយាយក្រោយ អ្នកបែរជានិយាយមុន អ្នកប្រកាន់កែក្តីខុសមកច្រើនហើយ ខ្ញុំលើកទោសដល់អ្នកហើយ អ្នកត្រូវយើងសង្កត់សង្កិនហើយ ចូរអ្នកទៅគេចវាទទោះចុះ ឬជាបើអ្នកល្មមដោះរួច ចូរដោះចេញចុះ ។ និគន្ថនាដបុត្ត ពួកសាវ័ក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ ចំពោះពួកសាវ័ក មិនធ្វើសក្ការៈគោរព ហើយនៅអាស្រ័យនឹងនិគន្ថនាដបុត្តឡើយ ដោយប្រការដូច្នេះឯង មួយទៀត និគន្ថនាដបុត្តក៏ត្រូវគេជេរ ដោយពាក្យដែលប្រកបដោយធម៌ ។

(៨៤) ឯកច្ចេ ឯវមាហំសុ អយម្បិ ខោ(១) សមណោ គោតមោ សង្ឃី ចេវ គណី ច គណា-ចរិយោ ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស សោ ច ខោ សាវកានំ សក្កតោ គរុកតោ មានិតោ បូជិតោ សមណញ្ច បន គោតមំ សាវកា សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរន្តិ ។ ភូតបុព្វំ សមណោ គោតមោ អនេក-សតាយ បរិសាយ ធម្មំ ទេសេតិ ។ តត្រញ្ញតរោ សមណស្ស គោតមស្ស សាវកោ ឧក្កាសិ ។ តមេន-មញ្ញតរោ(២) សព្រហ្មចារី ជណ្ណុកេន ឃដ្ដេសិ អប្ប-សទ្ទោ អាយស្មា ហោតុ មា អាយស្មា សទ្ទមកាសិ សត្ថា នោ ភគវា ធម្មំ ទេសេតីតិ ។ យស្មិំ សមយេ សមណោ គោតមោ អនេកសតាយ បរិសាយ ធម្មំ ទេសេតិ នេវ តស្មិំ សមយេ សមណស្ស គោតមស្ស សាវកានំ ខិបិតសទ្ទោ វា ហោតិ ឧក្កាសិតសទ្ទោ វា

១ ម. អយំ ហោ ។ ២ ម. តមេនញ្ញតរោ ។



(៨៤) សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណគោតមនេះឯង ព្រះអង្គមានពួក មានគណៈ ជាគណាចារ្យ ព្រះអង្គមានកេរ្តិ៍ឈ្មោះល្បីល្បាញ ព្រះអង្គមានយស ព្រះអង្គជាមេលទ្ធិ ដែលពួកជនច្រើនសន្មតហើយថាជាសប្បុរស ក៏ព្រះសមណគោតមនោះឯង ពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា ចំនែកពួកសាវ័ក ធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យនឹងព្រះសមណគោតមដែរទៀត ។ ព្រោះធ្លាប់ឮថា ព្រះសមណគោតម បានសំដែងធម៌ដល់បរិស័ទជាច្រើនរយ ។ គ្រាបរិស័ទនោះ មានសាវ័កម្នាក់ របស់ព្រះសមណគោតម ក្អកហើយ ។ មានសព្រហ្មចារីបុគ្គលម្នាក់ យកជង្គង់ទង្គិចសាវ័កនោះថា លោកមានអាយុ ចូរមានសំឡេងតិច ។ លោកមានអាយុ កុំធ្វើឮសូរឡើយ ព្រោះព្រះមានព្រះភាគ ជាសាស្តារបស់យើងទាំងឡាយ កំពុងសំដែងធម៌ ។ ព្រះសមណគោតមសំដែងធម៌ ដល់បរិស័ទច្រើនរយ ក្នុងសម័យណា ក្នុងសម័យនោះ សំឡេងកណ្តាស់ក្តី សំឡេងក្អកក្តី នៃពួកសាវ័ក របស់ព្រះសមណគោតម រកមានដល់តិចឡើយ

តមេវំ មហាជនកាយោ បញ្ចសីលសមាទិន្នោ បច្ចុ-
បដ្ឋិតោ ហោតិ យញ្ញោ កតោ ធម្មំ ភាសិស្សតិ
តញ្ញោ សោស្សាមាតិ ។ សេយ្យថាបិ នាម
បុរិសោ ចាតុម្មហាបថេ ខុទ្ទំ មធុំ អនេលកំ
បីឡេយ្យ តមេនំ មហាជនកាយោ បច្ចាសីសមា-
នរូបោ បច្ចុបដ្ឋិតោ អស្ស ឯវមេវ យស្មឹ សមយេ
សមណោ គោតមោ អនេកសតាយ បរិសាយ ធម្មំ
ទេសេតិ នេវ តស្មឹ សមយេ សមណស្ស គោតមស្ស
សាវកានំ ខិបិតសទ្ទោ វា ហោតិ ឧក្កាសិតសទ្ទោ
វា តមេនំ មហាជនកាយោ បច្ចាសីសមានរូបោ
បច្ចុបដ្ឋិតោ ហោតិ យញ្ញោ កតោ ធម្មំ ភាសិស្សតិ
តញ្ញោ សោស្សាមាតិ ។ យេបិ សមណស្ស គោតមស្ស
សាវកា សព្រហ្មចារីហិ សម្បយោជេត្វា សិក្ខំ បច្ច-
ក្ខាយ ហីនាយាវត្តន្តិ តេបិ សត្ថុ ចេវ វណ្ណវាទិនោ
ហោន្តិ ធម្មស្ស ច វណ្ណវាទិនោ ហោន្តិ សង្ឃស្ស ច
វណ្ណវាទិនោ ហោន្តិ អត្តគរហិនោយេវ ហោន្តិ អនញ្ញ-
គរហិនោ មយមេវម្ហា អលក្ខិកា មយំ អប្បបុញ្ញា



ពពួកមហាជន មានសេចក្តីសង្ឃឹម ប្រុងតាំងស្តាប់ធម៌នោះថា ព្រះ
មានព្រះភាគនឹងសំដែងធម៌ណា ដល់យើងទាំងឡាយ យើងទាំងឡាយ
នឹងស្តាប់នូវធម៌នោះ ។ ដូចជាបុរសច្របាច់ឃ្មុំតាំងបន្ទុំ ដែលល្អឥតឃ្មុំ
តូច ១ ច្រើហើយជារបស់ឥតទោស ត្រង់ផ្លូវធំបែកជា ៤ ពពួកមហាជន
មានសេចក្តីសង្ឃឹម ប្រុងយកទឹកឃ្មុំនោះ មានឧបមាយ៉ាងណាមិញ
ព្រះសមណគោតម សំដែងធម៌ដល់បរិស័ទច្រើនរយ ក្នុងសម័យណា
សម័យនោះ សំឡេងកណ្តាស់ក្តី សំឡេងក្អកក្តី នៃពួកសាវ័ករបស់ព្រះ
សមណគោតម ឥតមានដល់គ្នាឡើយ ពពួកមហាជន មានសេចក្តី
សង្ឃឹម ប្រុងតាំងស្តាប់ធម៌នោះថា ព្រះមានព្រះភាគនឹងសំដែងធម៌ណា
ដល់ពួកយើង ពួកយើងនឹងស្តាប់ធម៌នោះ ។ ចំណែកពួកសាវ័កណា
របស់ព្រះសមណគោតម បានសំរេចបន្តិចបន្តួចនឹងពួកសព្រហ្មចារីហើយ
បោះបង់សិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាប សាវ័កទាំងនោះ
នៅតែសរសើរគុណព្រះសាស្តាផង សរសើរគុណព្រះធម៌ផង សរសើរ
គុណព្រះសង្ឃផង ជាអ្នកតិះដៀលចំពោះតែខ្លួនឯង មិនតិះដៀលគេ
ថា យើងទាំងឡាយ ជាអ្នកឥតភព្វ យើងទាំងឡាយ ជាអ្នកឥតបុណ្យ

យេ មយំ ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិត្វា ន សក្ខិម្ហា យាវជីវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុន្តិ ។ តេ អារាមិកភូតា វា ឧបាសកភូតា វា បញ្ចសុ សិក្ខាបទេសុ សមាទាយ វត្តន្តិ ។ ឥតិ សមណោ គោតមោ សាវកានំ សក្កតោ គរុកតោ មានិតោ បូជិតោ សមណញ្ច បន គោតមំ សាវកា សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តីតិ ។ កតិ បន ត្វំ ឧទាយិ មយិ ធម្មេ សមនុបស្សសិ យេហិ មមំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តីតិ ។

[៨០] បញ្ច ខោ អហំ ភន្តេ ភគវតិ ធម្មេ សមនុបស្សាមិ យេហិ ភគវន្តំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ កតមេ បញ្ច



ព្រោះថា ពួកយើងបានបួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគសំដែងហើយ ដោយប្រពៃយ៉ាងនេះ ហើយមិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធ បរិបូណ៌ ដរាបដល់អស់ជីវិតបាន ។ ពួកសាវ័កទាំងនោះ គង់នៅជាអ្នកវត្តក្តី ជាឧបាសកក្តី ប្រព្រឹត្តសមាទានក្នុងសិក្ខាបទ ៥ ។ ព្រះសមណគោតម ពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា ទាំងពួកសាវ័ក ធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យនឹងព្រះសមណ-គោតមដែរទៀត ដោយប្រការដូច្នេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧទាយិ ចុះអ្នកពិចារណាឃើញនូវធម៌ក្នុងតថាគត ប៉ុន្មានយ៉ាង ដែលជាធម៌នាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា (តថាគត) លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងតថាគត) ។

(៨០) សកុលុទាយិបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ពិចារណាឃើញធម៌ ក្នុងព្រះមានព្រះភាគមាន ៥ ប្រការ ដែលជាធម៌នាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា នូវព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ធម៌ ៥ ប្រការ តើដូចម្តេច

ភគវា ហិ ភន្តេ អប្បាហារោ អប្បាហារតាយ ច វណ្ណវាទី យម្បិ ភន្តេ ភគវា អប្បាហារោ អប្បាហារតាយ ច វណ្ណវាទី ឥមំ ខោ អហំ ភន្តេ ភគវតិ បឋមំ ធម្មំ សមនុបស្សាមិ យេន ភគវន្តំ សាវកា សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ ។

[៨១] បុន ចបរំ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី យម្បិ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទី ឥមំ ខោ អហំ ភន្តេ ភគវតិ ទុតិយំ ធម្មំ សមនុបស្សាមិ យេន ភគវន្តំ សាវកា សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ ។



បពិត្រព្រះអង្គដ៏ចំរើន ស្រេចតែពិតថា ព្រះមានព្រះភាគ មានអាហារតិចផង សរសើរពីបែបភាពនៃបុគ្គលអ្នកមានអាហារតិចផង បពិត្រព្រះអង្គដ៏ចំរើន ត្រង់ការណ៍ដែលព្រះមានព្រះភាគ ព្រះអង្គមានអាហារតិចផង សរសើរពីបែបភាពនៃបុគ្គលអ្នកមានអាហារតិចផង ណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ជាធម៌ទី ១ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជានូវព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។

[៨១] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះមានព្រះភាគ ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយចីវរតាមមានតាមបានផង បពិត្រព្រះអង្គដ៏ចំរើន ត្រង់ការណ៍ដែលព្រះមានព្រះភាគ ទ្រង់សន្តោសដោយចីវរ តាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយចីវរតាមមានតាមបានផង ណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ជាធម៌ទី ២ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។

(៨២) បុន ចបរំ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី យម្បិ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទី ឥមំ ខោ អហំ ភន្តេ ភគវតិ ទុតិយំ ធម្មំ សមនុបស្សាមិ យេន ភគវន្តំ សាវកា សក្កោន្តិ គរុំ ករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរន្តិ ។

(៨៣) បុន ចបរំ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន សេនាសនេន ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទី យម្បិ ភន្តេ ភគវា សន្តុដ្ឋោ ឥតរីតរេន សេនាសនេន ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទី



[៨២] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះមានព្រះភាគ ទ្រង់សន្តោស ដោយបច្ច័យគឺបិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយបច្ច័យគឺបិណ្ឌបាត តាមមានតាមបានផង បពិត្រព្រះអង្គដ៏ចំរើន ព្រោះការណ៍ដែលព្រះមានព្រះភាគ ទ្រង់សន្តោស ដោយបច្ច័យគឺបិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយបច្ច័យគឺបិណ្ឌបាត តាមមានតាមបានផង ណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ពិចារណាឃើញច្បាស់នូវធម៌នេះឯង ជាធម៌ទី ២ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។

[៨៣] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះមានព្រះភាគ ទ្រង់សន្តោស ដោយសេនាសនៈ តាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយសេនាសនៈ តាមមានតាមបានផង បពិត្រព្រះអង្គដ៏ចំរើន ព្រោះការណ៍ ដែលព្រះមានព្រះភាគ ទ្រង់សន្តោស ដោយសេនាសនៈ តាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយសេនាសនៈ តាមមានតាមបានផង ណា

ឥទំ ខោ អហំ ភន្តេ ភគវតោ ចតុត្ថំ ធម្មំ សមនុបស្សាមិ យេន ភគវន្តំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។

[៨៤] បុន ចបរំ ភន្តេ ភគវា ឧបសន្តោ ឧបសន្តស្ស ច វណ្ណវាទី យម្បិ ភន្តេ ភគវា ឧបសន្តោ ឧបសន្តស្ស ច វណ្ណវាទី ឥទំ ខោ អហំ ភន្តេ ភគវតោ បញ្ចមំ ធម្មំ សមនុបស្សាមិ យេន ភគវន្តំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។ ឥមេ ខោ អហំ ភន្តេ ភគវតោ បញ្ច ធម្មេ សមនុបស្សាមិ យេហិ ភគវន្តំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តីតិ ។



បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ជាធម៌ទី ៤ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរព ហើយ នៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។

[៨៤] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះមានព្រះភាគ ទ្រង់ស្ងប់ស្ងាត់[១] សរសើរសេចក្ដីស្ងប់ស្ងាត់ បពិត្រព្រះអង្គដ៏ចំរើន ទ្រង់ការណ៍ដែលព្រះមានព្រះភាគ ទ្រង់ស្ងប់ស្ងាត់ផង សរសើរសេចក្ដីស្ងប់ស្ងាត់ផង ណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ជាធម៌ទី ៥ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់នូវធម៌ទាំង ៥ នេះឯង ក្នុងព្រះមានព្រះភាគ ដែលជាធម៌នាំឲ្យពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា នូវព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពរួចហើយ នៅអាស្រ័យ (នឹងព្រះមានព្រះភាគ) ។

---

១ សព្ទសុតាយ័តវិញ្ញាណិក សរសើរចំពោះការមេរៀនគំការស្ងប់ស្ងាត់កាយ ។ ប៉ុន្តែព្រះមានព្រះភាគ មានសេចក្ដីស្ងប់ស្ងាត់ ៣ យ៉ាង គឺស្ងប់ស្ងាត់កាយ ១ ស្ងប់ស្ងាត់ចិត្ត ១ ស្ងប់ស្ងាត់កិលេស ១ ។ អដ្ឋកថា ។

(៨៨) អប្បាហារោ សមណោ គោតមោ អប្បាហារតាយ ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ សន្តិ ខោ បន មេ ឧទាយិ សាវកា កោសកាហារាបិ អឌ្ឍកោសកាហារាបិ ពេលុវាហារាបិ អឌ្ឍពេលុវាហារាបិ អហំ ខោ បនុទាយិ អប្បេកទា ឥមិនា បត្តេន សមតិត្តិកម្បិ ភុញ្ជាមិ ភិយ្យោបិ ភុញ្ជាមិ ។ អប្បាហារោ សមណោ គោតមោ អប្បាហារតាយ ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ យេ តេ ឧទាយិ មម សាវកា កោសកាហារាបិ អឌ្ឍកោសកាហារាបិ ពេលុវាហារាបិ អឌ្ឍពេលុវាហារាបិ



(៨៨) ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧទាយិ បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ព្រះអង្គមានអាហារតិចផង សរសើរនូវភាពរបស់បុគ្គលអ្នកមានអាហារតិចផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត មានអាហារត្រឹម១កូនផ្ដិលខ្លះ មានអាហារកន្លះកូនផ្ដិលខ្លះ មានអាហារ១សម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ ក៏មានដែរ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនកាលបរិភោគអាហារពេញស្មើដោយបាត្រនេះក៏មាន បរិភោគអាហារច្រើនជាងនោះទៅក៏មាន ។ ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ(នឹងតថាគត)ដោយគិតថា ព្រះសមណគោតម ព្រះអង្គមានអាហារតិចផង សរសើរនូវភាពរបស់បុគ្គលអ្នកមានអាហារតិចផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័កណារបស់តថាគត ដែលមានអាហារត្រឹម១កូនផ្ដិលខ្លះ មានអាហារកន្លះកូនផ្ដិលខ្លះ មានអាហារ ១ សម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ

ន មំ តេ ឥមិនា ធម្មេន សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ ។

[៤៦] សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ សន្តិ ខោ បន មេ ឧទាយិ សាវកា បំសុកូលិកា លូខចីវរធរា តេ សុសានា វា សង្ការកូដា វា បាប-ណិកា វា នន្តកានិ ឧច្ចិនិត្វា សង្ឃាដឹ ករិត្វា ធារេន្តិ អហំ ខោ បនុទាយិ អប្បេកទា គហបតិចីវរានិ ធារេមិ ទឡ្ហានិ សុត្តលូខានិ(១) អលាពុលោមសានិ សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន ចីវរេន ឥតរីតរចីវរសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ យេ តេ ឧទាយិ មម សាវកា បំសុកូលិកា

---

១ ឱ. យុត្តលូខានិ ។ ម. សត្ថលូខានិ ។



ពួកសាវ័កទាំងនោះ សមគួរមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយធម៌នេះ លុះ(មិន)ធ្វើសក្ការៈ គោរពហើយ នឹងមិននៅអាស្រ័យ (នឹងតថាគត) ឡើយ ។

[៤៦] ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយចីវរតាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត ប្រើប្រាស់ត្រឹមសំ-ពត់បង្សុកូល ទ្រទ្រង់ចីវរសៅហ្មង គឺមានដែរ ពួកនោះរើសយកកំណាត់សំពត់ពីទីព្រៃស្មសានខ្លះ អំពីគំនរសម្រាមខ្លះ អំពីរានផ្សារខ្លះ ធ្វើជាសង្ឃាដី ហើយប្រើប្រាស់គ្រង ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណាប្រើប្រាស់គហបតិចីវរទាំងឡាយ ដ៏ជាប់សៅហ្មងដោយកាំបិត មានរោមល្អិតដូចរោមឃ្លោក ម្នាលឧទាយិ បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័កណា របស់តថាគត ដែលប្រើប្រាស់ត្រឹមតែសំពត់បង្សុកូល

លូខចីវរធរា តេ សុសានា ច សង្ការកូដា ច អាបណិកា ច នន្តកានិ ឧច្ចិនិត្វា សង្ឃាដឹ ករិត្វា ធារេន្តិ ន មំ តេ ឥមិនា ធម្មេន សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ ។

(៨៧) សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ សន្តិ ខោ បន មេ ឧទាយិ សាវកា បិណ្ឌបាតិកា សបទានចារិនោ ឧញ្ឆាបត្តេ(១) វតេ(២) រតា តេ អន្តរឃរំ បវិដ្ឋា សមានា អាសនេនបិ និមន្តិយមានា ន សាទិយន្តិ អហំ ខោ បនុទាយិ អប្បេកទា និមន្តនេបិ ភុញ្ជាមិ សាលីនំ ឱទនំ វិចិតកាឡកំ អនេកសូបំ

១. ឧញ្ឆេ បត្តេ ។ ២. ឧញ្ឆាសកេ ។ ៣ អដ្ឋកថាយំ ការុញ្ញំ បាឋោ ទិស្សតិ ។



ទ្រទ្រង់ចីវរសៅហ្មង ពួកនេះរើសនូវកំណាត់សំពត់ អំពីព្រៃស្មសានខ្លះ អំពីគំនរសម្រាមខ្លះ អំពីកន្លែងផ្សារខ្លះ មកធ្វើជាសង្ឃាដិប្រើប្រាស់ ពួកសាវ័កទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយធម៌នេះទេ លុះមិនធ្វើសក្ការៈ គោរពហើយ នឹងមិនទៅអាស្រ័យ (នឹងតថាគត) នៅឡើយ ។

(៨៧) ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្ដោសដោយបច្ច័យបិណ្ឌបាតតាមមានតាមបានផង ទ្រង់សរសើរសេចក្ដីសន្ដោស ដោយបច្ច័យបិណ្ឌបាតតាមមានតាមបានផង សមតាមពាក្យគេថាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត ប្រព្រឹត្តតែបិណ្ឌបាត ត្រាច់ទៅតាមលំដាប់ត្រកូល ត្រេកអរហើយក្នុងវត្ត គឺការរើសគោមតាមផ្ទះត្រកូលខ្ពស់និងទាប ក៏មានដែរ សាវ័កទាំងនោះ ដែលចូលទៅកាន់ចន្លោះនៃផ្ទះ បើគេនិមន្តដោយអាសនៈក៏មិនត្រេកអរ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនកាលនាំបាយស្រូវសាលីដ៏ល្អ ច្រាសចាកកណ្ដៀរខ្មៅ មានសម្លច្រើនមុខ មាន

អនេកព្យញ្ជនំ សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន បិណ្ឌបាតេន ឥតរីតរបិណ្ឌបាតសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុំករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរេយ្យុំ យេ តេ ឧទាយិ មម សាវកា បិណ្ឌបាតិកា សបទានចារិនោ ឧញ្ឆាបកេ វត្តេ រតា តេ អន្តរឃរំ បវិដ្ឋា សមានា អាសនេនបិ និមន្តិយមានា ន សាទិយន្តិ ន មំ តេ ឥមិនា ធម្មេន សក្ករេយ្យុំ គរុំករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរេយ្យុំ ។

(៨៨) សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន សេនាសនេន ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុំករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរេយ្យុំ សន្តិ ខោ បន មេ ឧទាយិ សាវកា



ម្ហូបច្រើនមុខ ក្នុងពេលដែលគេនិមន្តក៏មាន ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយបិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយបិណ្ឌបាតតាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់តថាគត ប្រព្រឹត្តបិណ្ឌបាត ត្រាច់ទៅតាមលំដាប់ច្រក ត្រេកអរហើយក្នុងវត្ត គឺការឈរតាមទ្វារផ្ទះត្រកូលខ្ពស់នឹងទាប សាវកទាំងនោះ កាលចូលទៅកាន់ចន្លោះផ្ទះ បើទុកជាគេនិមន្តដោយអាសនៈ ក៏មិនត្រេកអរ សាវកទាំងនោះ សមថាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយធម៌នេះ លុះមិនធ្វើសក្ការៈ គោរពហើយ នឹងមិននៅអាស្រ័យ (នឹងតថាគត) ឡើយ ។

(៨៨) ម្នាលឧទាយិ បើពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយសេនាសនៈ តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់តថាគត នៅ

រុក្ខមូលិកា អព្ភោកាសិកា តេ អដ្ឋ មាសេ ឆន្នំ ន ឧបេន្តិ អហំ ខោ បនុទាយិ អប្បេកទា កូដាគារេសុបិ វិហរាមិ ឧល្លិត្តាវលិត្តេសុ និវាតេសុ ផុសិតគ្គឡេសុ បិហិតវាតបានេសុ សន្តុដ្ឋោ សមណោ គោតមោ ឥតរីតរេន សេនាសនេន ឥតរីតរសេនាសនសន្តុដ្ឋិយា ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុំ ករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យុំ យេ តេ ឧទាយិ មម សាវកា រុក្ខមូលិកា អព្ភោកាសិកា តេ(១) អដ្ឋ មាសេ ឆន្នំ ន ឧបេន្តិ ន មំ តេ ឥមិនា ធម្មេន សក្ករេយ្យុំ គរុំ ករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំ កត្វា ឧបនិស្សាយ វិហរេយ្យុំ ។

១ ម. តេតិ បទំ ន ទិស្សតិ ។



ត្រើមក្បែរគល់ឈើជានិច្ច នៅក្នុងទីវាលស្មោះកំសិងជានិច្ច សាវ័កទាំងនោះ មិនចូលទៅជ្រកក្រោមដំបូលអស់ ៨ ខែ(១)ឡើយ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនកាលនៅក្នុងផ្ទះកំពូលទាំងឡាយ ដែលគេលាបពាំងពីខាងក្នុងពាំងខាងក្រៅ មិនមានខ្យល់ចូល មានទ្វារបិទស្និទ្ធ មានបង្អួចបិទជិតហើយ ម្នាលឧទាយិ បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ព្រោះធ្វើសក្ការៈគោរព ហើយនៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ត្រេកអរដោយសេនាសនៈតាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបានផង សមតាមពាក្យគួរជាមែន ម្នាលឧទាយិ ពួកសាវ័កណា របស់តថាគត ដែលនៅត្រើមក្បែរគល់ឈើ នៅក្នុងទីវាលស្មោះ សាវ័កទាំងនោះ មិនចូលទៅនៅជ្រកក្រោមដំបូលអស់ ៨ ខែជានិច្ច ពួកសាវ័កនោះសមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយធម៌នេះទេ សូម្បីមិនធ្វើសក្ការៈគោរពហើយ នឹងមិននៅអាស្រ័យ ( នឹងតថាគត ) ឡើយ ។

១ អដ្ឋកថា ថាគឺខែ ៨ ក្នុងហេមន្តរដូវ និងគិម្ហរដូវ ។ ចំណែកក្នុង... ត្រូវចូលមកជ្រកក្រោមទីដែលមានដំបូល ឬ ម្លប់ ដើម្បីរក្សាត្រៃចីវរ

បណ្ណាល័យ LIBRARY

(៨៩) បវិវិត្តោ សមណោ គោតមោ បវិវេកស្ស ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ សន្តិ ខោ បន មេ ឧទាយិ សាវកា អារញ្ញកា បន្តានិ សេនាសនានិ អរញ្ញវនបត្ថានិ (១) អជ្ឈោគាហេត្វា វិហរន្តិ តេ អន្វឌ្ឍមាសំ សង្ឃមជ្ឈេ ឱសរន្តិ បាតិមោក្ខុទ្ទេសាយ ។ អហំ ខោ បនុទាយិ អប្បេកទា អាកិណ្ណោ វិហរាមិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រញ្ញា រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ បវិវិត្តោ សមណោ គោតមោ បវិវេកស្ស ច វណ្ណវាទីតិ ឥតិ ចេ មំ ឧទាយិ សាវកា សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុំ យេ តេ ឧទាយិ មម សាវកា អារញ្ញកា បន្តានិ សេនាសនានិ អរញ្ញវនបត្ថានិ អជ្ឈោគាហេត្វា វិហរន្តិ

---

១ ឱ. ម. អារញ្ញកា បន្តសេនាសនា អារញ្ញវនបត្ថានិ បន្តានិ សេនាសនានិ ទិស្សន្តិ ។



(៨៩) ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈគោរពហើយ នៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ព្រះអង្គស្ងប់ស្ងាត់ផង សរសើរសេចក្តីស្ងប់ស្ងាត់ផង សមតាមពាក្យអ្នកជាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត នៅក្នុងព្រៃ ចូលទៅកាន់ព្រៃតូចនឹងព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ ហើយសម្រេចសម្រាន្តនៅ សាវ័កទាំងនោះ មកប្រជុំគ្នាក្នុងកណ្តាលសង្ឃ ដើម្បីសំដែងបាតិមោក្ខរាល់ ១ កន្លះខែ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនកាលនៅច្របូកច្របល់ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច រាជមហាមាត្រ តិរ្ថិយ នឹងពួកសាវ័កនៃតិរ្ថិយ ម្នាលឧទាយិ បើពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរព ហើយ នៅអាស្រ័យ (នឹងតថាគត) ដោយគិតថា ព្រះសមណគោតម ព្រះអង្គស្ងប់ស្ងាត់ហើយផង សរសើរសេចក្តីស្ងប់ស្ងាត់ផង សមតាមពាក្យអ្នកជាមែន ម្នាលឧទាយិ ពួកសាវ័កណា របស់តថាគតដែលនៅក្នុងព្រៃ ចូលទៅកាន់ព្រៃតូចនឹងព្រៃធំ ជាសេនាសនៈស្ងាត់ហើយ សម្រេចសម្រាន្ត

តេ អន្វឌ្ឍមាសំ សង្ឃមជ្ឈេ ឱសរន្តិ បាតិមោក្ខុទ្ទេ-សាយ ន មំ តេ ឥមិនា ធម្មេន សក្ករេយ្យុំ គរុំករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរេយ្យុំ ។ ឥតិ ខោ ឧទាយិ ន មំ សាវកា ឥមេហិ បញ្ចហិ ធម្មេហិ សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ ។

(៤០) អត្ថិ ខោ ឧទាយិ អញ្ញេ ច បញ្ច ធម្មា យេហិ បញ្ចហិ ធម្មេហិ(១) មមំ សាវកា សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ កតមេ បញ្ច ឥធុទាយិ មមំ សាវកា អធិសីលេ សម្ភាវេន្តិ សីលវា សមណោ គោតមោ បរមេន

១ ម. បញ្ចហិ ធម្មេហិ ឥតិ ន ទិស្សតិ ។



ទៅ សាវ័កទាំងនោះ ប្រជុំគ្នាក្នុងកណ្ដាលសង្ឃ ដើម្បីសំដែងបាតិមោក្ខ រាល់ៗកន្លះខែ សាវ័កទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយធម៌នេះទេ លុះមិនធ្វើសក្ការៈគោរពហើយ នឹងមិននៅអាស្រ័យ (នឹងតថាគត) ឡើយ ។ ម្នាលឧទាយិ ពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ (នឹងតថាគត) មិនមែនដោយសារធម៌ទាំង ៥ ប្រការនេះដូចពាក្យអ្នកទាំងនោះទេ ។

(៤០) ម្នាលឧទាយិ ធម៌ ៥ ដោយឡែកទៀត ដែលជាធម៌នាំឲ្យពួកសាវ័ក របស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈគោរពហើយ នៅអាស្រ័យ (នឹងតថាគត) ធម៌ទាំង ៥ តើដូចម្ដេចខ្លះ ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត ក្នុងសាសនានេះ សរសើរចំពោះអធិសីលថា ព្រះសមណគោតម ព្រះអង្គមានសីល

សីលក្ខន្ធេន សមន្នាគតោតិ ។ យម្បុទាយិ(១) មម សាវកា អធិសីលេ សម្ភាវេន្តិ សីលវា សមណោ គោតមោ បរមេន សីលក្ខន្ធេន សមន្នាគតោតិ ។ អយំ ខោ ឧទាយិ បឋមោ ធម្មោ យេន មម សាវកា សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ ។

(៤១) បុន ចបរំ ឧទាយិ មម សាវកា អភិក្កន្តេ ញាណទស្សនេ សម្ភាវេន្តិ ជានំយេវាហ សមណោ គោតមោ ជានាមីតិ បស្សំយេវាហ សមណោ គោតមោ បស្សាមីតិ អភិញ្ញាយ សមណោ គោតមោ ធម្មំ ទេសេតិ នោ អនភិញ្ញាយ សនិទានំ សមណោ គោតមោ ធម្មំ ទេសេតិ នោ អនិទានំ សប្បាដិហារិយំ សមណោ គោតមោ ធម្មំ ទេសេតិ នោ អប្បាដិហារិយន្តិ ។ យម្បុទាយិ(២) មម សាវកា

១-២ ម. យំ បនុទាយិ ។



ព្រះអង្គប្រកបព្រមហើយដោយសីលក្ខន្ធដ៏ប្រសើរបំផុត ។ ម្នាលឧទាយិ គ្រឿងការណ៍ដែលពួកសាវ័ក របស់តថាគត សរសើរចំពោះអធិសីលថា ព្រះសមណគោតម ព្រះអង្គមានសីល ព្រះអង្គប្រកបព្រមហើយដោយសីលក្ខន្ធដ៏ប្រសើរបំផុត ណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ១ ដែលនាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ (នូវតថាគត) ។

(៤១) ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត សរសើរចំពោះញាណទស្សនៈដ៏រុងរឿងថា ព្រះសមណគោតម កាលបើដឹង ទើបនិយាយថា តថាគតដឹង ព្រះសមណគោតម កាលបើឃើញ ទើបនិយាយថា តថាគតឃើញ ព្រះសមណគោតម តែងសំដែងធម៌ដើម្បីឲ្យត្រាស់ដឹង មិនសំដែងដើម្បីមិនឲ្យត្រាស់ដឹងទេ ព្រះសមណគោតម តែងសំដែងធម៌ប្រកបដោយហេតុ មិនមែនសំដែងធម៌ឥតហេតុទេ ព្រះសមណគោតម តែងសំដែងធម៌ប្រកបដោយបាដិហារ្យ មិនមែនសំដែងធម៌ឥតបាដិហារ្យទេ ។ ម្នាលឧទាយិ គ្រឿងការណ៍ដែលពួកសាវ័ករបស់តថាគត

អភិក្កន្តេ ញាណទស្សនេ សម្ភាវេន្តិ ជានំយេវាហ សមណោ គោតមោ ជានាមីតិ បស្សំយេវាហ សមណោ គោតមោ បស្សាមីតិ អភិញ្ញាយ សមណោ គោតមោ ធម្មំ ទេសេតិ នោ អនភិញ្ញាយ សនិទានំ សមណោ គោតមោ ធម្មំ ទេសេតិ នោ អនិទានំ សប្បាដិហារិយំ សមណោ គោតមោ ធម្មំ ទេសេតិ នោ អប្បាដិហារិយន្តិ ។ អយំ ខោ ឧទាយិ ទុតិយោ ធម្មោ យេន មម សាវកា សក្ករោន្តិ គរុំករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុំកត្វា ឧបនិស្សាយ វិហរន្តិ ។

(៤៦) បុន ចបរំ ឧទាយិ មម សាវកា អធិបញ្ញាយ សម្ភាវេន្តិ បញ្ញវា សមណោ គោតមោ បរមេន បញ្ញាក្ខន្ធេន សមន្នាគតោ តំ វត អនាគតំ វា វាទបថំ ន ទក្ខតិ ឧប្បន្នំ វា បរប្បវាទំ ន សហធម្មេន សុនិគ្គហិតំ និគ្គហិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ តំ កិំ មញ្ញសិ ឧទាយិ



សរសើរចំពោះញាណទស្សនៈដ៏ប្រសើរថា ព្រះសមណគោតម កាលបើដឹង ទើបនិយាយថា តថាគតដឹង ព្រះសមណគោតម កាលបើឃើញ ទើបនិយាយថា តថាគតឃើញ ព្រះសមណគោតម តែងសំដែងធម៌ដើម្បីសេចក្តីត្រាស់ដឹង មិនមែនសំដែងធម៌ដើម្បីសេចក្តីមិនត្រាស់ដឹងទេ ព្រះសមណគោតម តែងសំដែងធម៌ប្រកបដោយហេតុ មិនមែនសំ-ដែងធម៌ឥតហេតុទេ ព្រះសមណគោតម តែងសំដែងធម៌ប្រកបដោយបាដិហារ្យ៍ មិនមែនសំដែងធម៌ឥតបាដិហារ្យ៍ទេ ណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ២ ដែលនាំឲ្យពួកសាវ័ក របស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈគោរព ហើយនៅអាស្រ័យ (នឹងតថាគត) ។

(៤៦) ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត សរសើរចំពោះអធិបញ្ញាថា ព្រះសមណគោតម ព្រះអង្គមានប្រាជ្ញា ប្រកបដោយបញ្ញាខន្ធដ៏ប្រសើរបំផុត ឯពាក្យថា ព្រះសម-ណគោតម មិនឃើញនូវគន្លងនៃវាទៈនោះ ដែលមិនទាន់មានមក ឬ ថាព្រះសមណគោតម មិនមែនសង្កត់សង្កិននូវបរប្បវាទដែលកើតឡើង ហើយ ឲ្យជាការសង្កត់សង្កិនដោយល្អ ប្រកបដោយហេតុបានទេ ដូច្នេះ មិនមានហេតុឡើយ ។ ម្នាលឧទាយិ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច

អបិ នុ មេ សាវកា ឯវំ ជានន្តា ឯវំ បស្សន្តា អន្តរន្តរា កថំ ឱបាតេយ្យុន្តិ (១) ។ នោ ហេតំ ភន្តេ ។ ន ខោ បនាហំ ឧទាយិ សាវកេសុ អនុសាសនិំ បច្ចាសីសាមិ អញ្ញទត្ថុ (២) មមំយេវ សាវកា អនុសាសនិំ បច្ចាសីសន្តិ ។ យម្បុទាយិ មម សាវកា អធិប្បញ្ញាយ សម្ភាវេន្តិ បញ្ញវា សមណោ គោតមោ បរមេន បញ្ញាក្ខន្ធេន សមន្នាគតោ តំ វត អនាគតំ វា វាទបថំ ន បស្សតិ ឧប្បន្នំ វា បរប្បវាទំ ន សហធម្មេន សុនិគ្គហិតំ និគ្គហិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ អយំ ខោ ឧទាយិ ចតុត្ថោ ធម្មោ យេន មមំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។

១ ម. កថំ ឱបាតេយ្យុំ ។ ២ ឱ. ម. អញ្ញទត្ថុ ។



ចុះពួកសាវ័ករបស់តថាគត កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះហើយ និយាយបញ្ចៀត (តថាគត) ក្នុងពាក្យជាចន្លោះៗ ដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ការនុ៎ះមិនមានសោះឡើយ ។ ម្នាលឧទាយិ មួយទៀត តថាគតមិនដែលទុកឲ្យពួកសាវ័ក ជួយប្រៀនប្រដៅសោះឡើយ តែពួកសាវ័កតែងទុកចិត្ត ឲ្យតថាគតប្រៀនប្រដៅដោយពិត ។ ម្នាលឧទាយិ ត្រង់ការណ៍ដែលពួកសាវ័ករបស់តថាគត សរសើរចំពោះអធិប្បញ្ញាថា ព្រះសមណគោតម ព្រះអង្គមានប្រាជ្ញា ទ្រង់ប្រកបព្រមហើយដោយបញ្ញាខន្ធដ៏ប្រសើរបំផុត ឯពាក្យថា ព្រះសមណគោតមមិនឃើញនូវគន្លងនៃវាទៈនោះ ដែលមិនទាន់មានមក ឬថាព្រះសមណគោតម មិនដែលសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាការសង្កត់សង្កិនដោយល្អ ប្រកបដោយហេតុ ដូច្នេះ មិនមានសោះទេ ណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ៤ ដែលនាំឲ្យពួកសាវ័ករបស់តថាគត តែងធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈគោរព ហើយនៅអាស្រ័យ (នឹងតថាគត)។

(៩១) បុន ចបរំ ឧទាយិ មម សាវកា យេន ទុក្ខេន ទុក្ខាភិណ្ណា ទុក្ខបរេតា តេ មំ ឧបសង្កមិត្វា ទុក្ខំ អរិយសច្ចំ បុច្ឆន្តិ តេសាហំ ទុក្ខំ អរិយសច្ចំ បុដ្ឋោ ព្យាករោមិ តេសាហំ ចិត្តំ អារាធេមិ បញ្ហស្ស វេយ្យាករណេន តេ មំ ឧបសង្កមិត្វា (១) ទុក្ខសមុទយំ... ទុក្ខនិរោធំ... ទុក្ខនិរោធគាមិនិំ បដិបទំ (២) អរិយសច្ចំ បុច្ឆន្តិ តេសាហំ ទុក្ខនិរោធគាមិនិំ បដិបទំ អរិយសច្ចំ បុដ្ឋោ ព្យាករោមិ តេសាហំ ចិត្តំ អារាធេមិ បញ្ហស្ស វេយ្យាករណេន ។ យម្បុទាយិ មម សាវកា យេន ទុក្ខេន ទុក្ខាភិណ្ណា ទុក្ខបរេតា តេ មំ ឧបសង្កមិត្វា ទុក្ខំ អរិយសច្ចំ បុច្ឆន្តិ តេសាហំ ទុក្ខំ អរិយសច្ចំ បុដ្ឋោ ព្យាករោមិ តេសាហំ ចិត្តំ អារាធេមិ បញ្ហស្ស វេយ្យាករណេន តេ មំ ឧបសង្កមិត្វា ទុក្ខសមុទយំ... ទុក្ខនិរោធំ... ទុក្ខនិរោធគាមិនិំ បដិបទំ អរិយសច្ចំ បុច្ឆន្តិ

១ ម. ឧបសង្កមិត្វា ។ ២ ម. ទុក្ខនិរោធគាមិនីបដិបទំ ។



(៩៣) ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត មានទុក្ខរឿតរឿនហើយ មានទុក្ខគ្របសង្កត់ហើយ ព្រោះសេចក្តីទុក្ខណា ពួកសាវ័កទាំងនោះ ចូលមករកតថាគត ហើយសួរនូវទុក្ខអរិយសច្ច លុះសួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខអរិយសច្ច ដល់ពួកសាវ័កទាំងនោះ តថាគតញុំាងចិត្តរបស់សាវ័កទាំងនោះឲ្យត្រេកអរ ដោយការដោះស្រាយនូវប្រស្នាបាន ពួកសាវ័កទាំងនោះ ចូលមករកតថាគតសួរនូវទុក្ខសមុទយ... ទុក្ខនិរោធ... សួរនូវទុក្ខនិរោធគាមិនីបដិ-បទាអរិយសច្ច លុះសួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខនិរោធគា-មិនីបដិបទាអរិយសច្ច ដល់ពួកសាវ័កទាំងនោះ តថាគតញុំាងចិត្តរបស់ពួកសាវ័កទាំងនោះឲ្យត្រេកអរបាន ដោយការដោះស្រាយនូវប្រស្នា ។ ម្នាលឧទាយិ ព្រោះការណ៍ដែលពួកសាវ័ករបស់តថាគត មានទុក្ខរឿតរឿនហើយ មានទុក្ខគ្របសង្កត់ហើយ ព្រោះសេចក្តីទុក្ខណា ពួកសាវ័កទាំងនោះតែងចូលមករកតថាគតហើយ សួរនូវទុក្ខអរិយសច្ច លុះសួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខអរិយសច្ចដល់ពួកសាវ័កទាំងនោះ តថាគតញុំាងចិត្តរបស់ពួកសាវ័កទាំងនោះ ឲ្យត្រេកអរបានដោយការដោះស្រាយនូវប្រស្នា ពួកសាវ័កទាំងនោះ ចូលមករកតថាគតហើយ សួរនូវទុក្ខសមុទយ... ទុក្ខនិរោធ... សួរនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច

តេសាហំ ទុក្ខនិរោធគាមិនិំ បដិបទំ អរិយសច្ចំ បុដ្ឋោ ព្យាករោមិ តេសាហំ ចិត្តំ អារាធេមិ បញ្ហស្ស វេយ្យាករណេន ។ អយំ ខោ ឧទាយិ បញ្ចមោ ធម្មោ យេន មមំ សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។

(៥៦) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ចត្តារោ សតិប្បដ្ឋានេ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ... ចិត្តេ ចិត្តានុបស្សី វិហរតិ... ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។



សួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដល់ពួកសាវ័កទាំងនោះ តថាគតញ៉ាំងចិត្តរបស់សាវ័កទាំងនោះឲ្យត្រេកអរ បាន ដោយការដោះស្រាយនូវប្រស្នា ណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ៥ ដែលនាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈគោរពហើយ នៅអាស្រ័យ (នឹងតថាគត) ។

(៥៦) ម្នាលឧទាយិ មួយវិញទៀត តថាគតបានសំដែងនូវបដិបទា ដល់ពួកសាវ័ក ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិ ហើយ ចំរើននូវសតិប្បដ្ឋានទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនា នេះ ពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី... ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី... ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយជា ប្រក្រតី មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស មានប្រាជ្ញាស្មារតី កំចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក សម្រេចសម្រាន្តនៅដោយ ឥរិយាបថទាំង ៤ ។ ក៏ពួកសាវ័ករបស់តថាគតជាច្រើន បានដល់ហើយ នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងសតិប្បដ្ឋានទាំងនេះ ។

(៤៨) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ចត្តារោ សម្មប្បធានេ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។





(៤៨) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់ពួកសាវ័ក ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិ ហើយចំរើននូវសម្មប្បធានទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ញុំាងសេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតំកល់ចិត្ត ដើម្បីញុំាងពួកធម៌ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងសេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតំកល់ចិត្ត ដើម្បីលះបង់នូវពួកធម៌ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ញុំាងសេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតំកល់ចិត្ត ដើម្បីញុំាងពួកធម៌ ជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ញុំាងសេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតំកល់ចិត្ត ដើម្បីញុំាងពួកធម៌ជាកុសលដែលកើតឡើងហើយឲ្យតាំងនៅបាន ដើម្បីមិនឲ្យវិនាសទៅ ឲ្យជាភិយ្យោភាព ធំទូលាយ ចំរើនបរិបូណ៌ឡើង ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងសម្មប្បធានធម៌ទាំងនោះ ។

(៥៦) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ចត្តារោ ឥទ្ធិបាទេ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(៥៧) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា បញ្ចិន្ទ្រិយានិ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ សទ្ធិន្ទ្រិយំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ វីរិយិន្ទ្រិយំ ភាវេតិ... សតិន្ទ្រិយំ ភាវេតិ





(៥៦) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវក របស់តថាគត ប្រតិបត្តិហើយ ចំរើនឥទ្ធិបាទទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិនិងបធានសង្ខារ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិនិងបធានសង្ខារ ចំរើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ចំរើននូវឥទ្ធិបាទ ប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងឥទ្ធិបាទទាំងនោះ ។

(៥៧) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់ពួកសាវក ដែលជាហេតុឲ្យពួកសាវករបស់តថាគតប្រតិបត្តិ ហើយចំរើននូវឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើននូវសទ្ធិន្ទ្រិយ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ចំរើននូវវីរិយិន្ទ្រិយ... ចំរើននូវសតិន្ទ្រិយ...

សមាធិន្ទ្រិយំ ភាវេតិ... បញ្ញិន្ទ្រិយំ ភាវេតិ ឧប. សមគាមឹ សម្ពោធគាមឹ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(៤៨) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា បញ្ច ពលានិ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ សទ្ធាពលំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ វីរិយពលំ ភាវេតិ... សតិពលំ ភាវេតិ.. សមាធិពលំ ភាវេតិ... បញ្ញាពលំ ភាវេតិ ឧបសមគាមឹ សម្ពោធគាមឹ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(៤៩) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា សត្ត ពោជ្ឈង្គេ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ



ចំរើននូវសមាធិន្ទ្រិយ .. ចំរើននូវបញ្ញិន្ទ្រិយ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងឥន្ទ្រិយទាំង ៥ នោះ ។

(៤៨) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិ ហើយ ចំរើននូវពលធម៌ទាំង ៥ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើននូវសទ្ធាពលៈ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ចំរើនវីរិយពលៈ... ចំរើននូវសតិពលៈ... ចំរើននូវសមាធិពលៈ... ចំរើននូវបញ្ញាពលៈ... ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ឯពួកសាវ័ករបស់តថាគត ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងពលធម៌ទាំង ៥ ប្រការនោះ ។

(៤៩) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិ ហើយចំរើននូវសម្ពោជ្ឈង្គធម៌ ៧ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនា

សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ។ បេ ។ វិរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

[១០០] បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អរិយំ អដ្ឋង្គិកំ មគ្គំ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ សម្មាទិដ្ឋឹ ភាវេតិ សម្មាសង្កប្បំ ភាវេតិ សម្មាវាចំ ភាវេតិ សម្មាកម្មន្តំ ភាវេតិ សម្មាអាជីវំ ភាវេតិ សម្មាវាយាមំ ភាវេតិ សម្មាសតឹ ភាវេតិ សម្មាសមាធឹ ភាវេតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។



នេះ ចំរើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមទៅកាន់សេចក្តីលះបង់ ចំរើននូវធម្មវិចយសម្ពោជ្ឈង្គ ។ បេ ។ ចំរើននូវវិរិយសម្ពោជ្ឈង្គ... ចំរើននូវបីតិសម្ពោជ្ឈង្គ... ចំរើននូវបស្សទ្ធិសម្ពោជ្ឈង្គ... ចំរើននូវសមាធិសម្ពោជ្ឈង្គ... ចំរើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យ នូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមទៅកាន់សេចក្តីលះបង់ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងសម្ពោជ្ឈង្គធម៌ទាំង ៧ នោះ ។

[១០០] ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិ ហើយចំរើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចំរើននូវសម្មាទិដ្ឋិ ចំរើននូវសម្មាសង្កប្បៈ ចំរើននូវសម្មាវាចា ចំរើននូវសម្មាកម្មន្តៈ ចំរើននូវសម្មាអាជីវៈ ចំរើននូវសម្មាវាយាមៈ ចំរើននូវសម្មាសតិ ចំរើននូវសម្មាសមាធិ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនោះ ។

(១០១) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អដ្ឋ វិមោក្ខេ ភាវេន្តិ ។ រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។



(១០១) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយចំរើននូវវិមោក្ខទាំងឡាយ ៨ ប្រការ ។ (វិមោក្ខទាំង ៨ ប្រការគឺ) បុគ្គលបាននូវរូបជ្ឈាន ឃើញរូបទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសំគាល់នូវរូបជ្ឈានខាងក្នុង ឃើញរូបទាំងឡាយខាងក្រៅ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់ក្នុងឈានក្នុងវណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ ភិក្ខុព្រោះកន្លងនូវពួករូបសញ្ញាដោយប្រការទាំងពួង ព្រោះរម្ងាប់នូវពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ក៏ចូលដល់អាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ ភិក្ខុព្រោះកន្លងអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ក៏ចូលដល់វិញ្ញាណញ្ចាយតនៈដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះជាវិមោក្ខទី ៥ ។ ភិក្ខុព្រោះកន្លងវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង ក៏ចូលដល់អាកិញ្ចញ្ញាយតនៈដោយបរិកម្មថា វត្ថុតិចតួចមិនមាន នេះជាវិមោក្ខទី ៦ ។ ភិក្ខុព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង ក៏ចូលដល់នេវសញ្ញានាសញ្ញាយតនៈ នេះជាវិមោក្ខទី ៧ ។

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១០៦) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អដ្ឋ អភិភាយតនានិ ភាវេន្តិ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភាយតនំ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ



ភិក្ខុព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ក៏ចូលដល់សញ្ញាវេទយិតនិរោធ នេះជាវិមោក្ខទី៨ ។ ឯសាវ័កទាំងឡាយរបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងវិមោក្ខទាំង ៨ នោះ ។

(១០៦) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ក របស់តថាគតបានប្រតិបត្តិ ហើយចំរើននូវអភិភាយតនៈ[១] ៨ ប្រការ ។ អភិភាយតនៈ៨ ប្រការ គឺបុគ្គលពួកខ្លះ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបបន្តិចបន្តួច មានពណ៌ល្អឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកខ្លះ មានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបធំប្រមាណមិនបាន មានពណ៌ល្អឬពណ៌អាក្រក់ គ្របសង្កត់រូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ

១ ហេតុសម្រាប់គ្របសង្កត់នូវបច្ចនិកធម៌ (ធម៌ជាសត្រូវ) និងអារម្មណ៍ ។

ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ តតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ ។ សេយ្យថាបិ នាម ឧមាបុប្ផំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ នីលំ នីលវណ្ណំ នីលនិទស្សនំ នីលនិភាសំ ឯវមេវ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ



នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់ក្នុងរូបខាងក្នុង ឃើញរូបខាងក្រៅដែលជារូបតិចតួច មានពណ៌ល្អឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបធំប្រមាណមិនបាន ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ខៀវ មានពន្លឺខៀវ ។ ដូចជាផ្កាត្រកៀត ជាផ្កាជាតិខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា ផ្កានេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោតដូចសំពត់កើតក្នុងក្រុងពារាណសីនោះ រលីងរលើបទាំងពីរខាង ជាសំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា សំពត់នេះមានពណ៌ខៀវ មានពន្លឺខៀវ សេចក្តីទាំងនេះមានឧបមាយ៉ាងណាមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបខៀវ

នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ ។ សេយ្យថាបិ នាម កណ្ណិការបុប្ផំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ បីតំ បីតវណ្ណំ បីតនិទស្សនំ បីតនិភាសំ ឯវមេវ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។



មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី៥ ។ បុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅជារូបលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌លឿង មានពន្លឺលឿង ។ ដូចផ្កាកណ្ណិការ ជាបុប្ផជាតិលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា ផ្កានេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោតដូចសំពត់កើតក្នុងក្រុងពារាណសីនោះ ដែលគេលើបទាំងពីរខាង ជាសំពត់លឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា សំពត់នេះមានពណ៌លឿង មានពន្លឺលឿង សេចក្តីនេះមានឧបមាដូចម្តេចមិញ បានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី៦ ។

អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ ។ សេយ្យថាបិ នាម ពន្ធុជីវកបុប្ផំ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ លោហិតកំ លោហិតកវណ្ណំ លោហិតកនិទស្សនំ លោហិតកនិភាសំ ឯវមេវ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ ។ សេយ្យថាបិ នាម ឱសធីតារកា ឱទាតា ឱទាតវណ្ណា ឱទាតនិទស្សនា ឱទាតនិភាសា



បុគ្គលពួកខ្លះ មិនមានសេចក្ដីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា រូបនេះ មានពណ៌ក្រហម មានពន្លឺក្រហម ។ ដូចជាផ្កាចង្កុរ ជាផ្កាក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា ផ្កានេះ មានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត ដូចសំពត់កើតក្នុងក្រុងពារាណសីនោះ មានសាច់រលីងរលើបទាំងពីរខាង ជាសំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា សំពត់នេះ មានពណ៌ក្រហម មានពន្លឺក្រហម សេចក្ដីនេះមានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្ដីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលបង្ហាញថា រូបនេះ មានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ មានសេចក្ដីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកខ្លះ មិនមានសេចក្ដីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ជារូបស មានពណ៌ស ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ស មានពន្លឺស ។ ដូចជាផ្កាយព្រឹក ជាផ្កាយស មានពណ៌ស ជាទីចង្អុលបង្ហាញថា ផ្កាយនេះ មានពណ៌ស មានពន្លឺស

សេយ្យថាបិ វា បន តំ វត្ថំ ពារាណសេយ្យកំ ឧភតោភាគវិមដ្ឋំ ឱទាតំ ឱទាតវណ្ណំ ឱទាតនិទស្សនំ ឱទាតនិភាសំ ឯវមេវ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១០៣) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ទស កសិណាយតនានិ ភាវេន្តិ បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធមធោ តិរិយំ អទ្វយំ[១]

---
១ ម. អទ្វយំ ។



ភ្លឺរលោង ដូចសំពត់កើតក្នុងក្រុងពារាណសីនោះ មានសាច់ល្មើង ល្មើបទាំងពីរខាង ជាសំពត់ស មានពណ៌ស ជាទីចង្អុលបង្ហាញថា សំពត់នេះមានពណ៌ស មានពន្លឺស សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសំគាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបស មានពណ៌ស ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ នេះជាអភិភាយតនៈទី ៨ ។ ឯសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងអភិភាយតនៈទាំងនោះ ។

(១០៣) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិហើយ ចំរើននូវកសិណាយតនៈ១០ ប្រការ ។ (កសិណាយតនៈទាំង ១០ នោះគឺ) បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវបឋវីកសិណ ខាងលើ[១] ខាងក្រោម[២] ទីទទឹង[៣] ជាកសិណតែមួយ ឥតមានលាយឡំ

---
១ កសិណដែលត្រូវចំរើន ងើយមើលទៅខាងលើ ។ ២ កសិណដែលត្រូវចំរើន ដាក់ចុះមកខាងផែនដី ។ ៣ កសិណដែលត្រូវចំរើន ជុំវិញទៅក្នុងមណ្ឌល ។ អដ្ឋកថា ។

អប្បមាណំ អាបោកសិណមេកោ សញ្ជានាតិ ។ បេ ។ តេជោកសិណមេកោ សញ្ជានាតិ... វាយោកសិណមេកោ សញ្ជានាតិ... នីលកសិណមេកោ សញ្ជានាតិ... បីតកសិណមេកោ សញ្ជានាតិ... លោហិតកសិណមេកោ សញ្ជានាតិ... ឱទាតកសិណមេកោ សញ្ជានាតិ... អាកាសកសិណមេកោ សញ្ជានាតិ... វិញ្ញាណកសិណមេកោ សញ្ជានាតិ ឧទ្ធមធោ តិរិយំ អទ្វយំ អប្បមាណំ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១០៥) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ចត្តារិ ឈានានិ ភាវេន្តិ ។ ឥធុទាយិ ភិក្ខុ



(ទឹកកសិណឯទៀត) ថាឥតប្រមាណមិនបាន ១ បុគ្គលពួកខ្លះស្គាល់ច្បាស់នូវអាបោកសិណ ។ បេ ។ បុគ្គលពួកខ្លះស្គាល់ច្បាស់នូវតេជោកសិណ... បុគ្គលពួកខ្លះស្គាល់ច្បាស់នូវវាយោកសិណ... បុគ្គលពួកខ្លះស្គាល់ច្បាស់នូវនីលកសិណ...បុគ្គលពួកខ្លះស្គាល់ច្បាស់នូវបីតកសិណ... បុគ្គលពួកខ្លះស្គាល់ច្បាស់ នូវលោហិតកសិណ... បុគ្គលពួកខ្លះស្គាល់ច្បាស់នូវឱទាតកសិណ...បុគ្គលពួកខ្លះស្គាល់ច្បាស់នូវអាកាសកសិណ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ខាងលើ ខាងក្រោម និងទទឹង ជាកសិណតែមួយ ឥតមានលាយឡំ (ទឹកកសិណឯទៀត) ប្រមាណមិនបាន ១ ។ ឯសាវ័កទាំងឡាយរបស់តថាគតជាច្រើន ក៏បាន ដល់នូវបារមីញ្ញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងកសិណាយតនៈទាំង ១០នោះ ។

(១០៥) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិហើយចំរើននូវឈានទាំង៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនា

វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ(១) បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ឧទាយិ ទក្ខោ ន្ហាបកោ វា ន្ហាបកន្តេវាសី វា កំសថាលេ ន្ហានីយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ សន្នេយ្យ(២) សាស្ស(៣) ន្ហានីយបិណ្ឌិ ស្នេហានុគតា ស្នេហបរេតា សន្តរពាហិរា ផុដា(៤) ស្នេហេន ន ច បគ្ឃរិណី ឯវមេវ ខោ ឧទាយិ ភិក្ខុ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។

១ ឱ. អភិសន្ទេតិ បរិសន្ទេតីតិ ឯវំ ទិស្សតិ ។ ២ ឱ. បរិប្ផោសកំ សន្នេយ្យាតិ ទិស្សតិ ។ ៣ ម. សាយំ ។ ៤ ឱ. សន្តរពាហិរា ផុដា ។ ម. សមន្តរពាហិរា ផុដា ។



នេះ ស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកធម៌ទាំងឡាយជាអកុសល ក៏បានចូលបឋមជ្ឈានប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ភិក្ខុនោះញ៉ាំងកាយនេះឯង ឲ្យជ្រួតជ្រាប ជោគជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយ ទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ។ ម្នាលឧទាយិ ដូចជាអ្នកកាត់សក់ក្ដី កូនសិស្សរបស់នាយជាងកាត់សក់ក្ដី ដែលឈ្លាសវៃ ដាក់លំអិតសំរាប់ងូតទៅក្នុងលោហភាជន៍(១) ហើយយកទឹកប្រោះព្រំប្រឡាក់ពួតឲ្យជាដុំ ឯដុំលំអិតសំរាប់ងូតនោះ ជ្រួតជ្រាបស្អិតដោយទឹក ជោគជាំស្អិតដោយទឹក សើបស្អិតដោយទឹក ទាំងខាងក្នុង ទាំងខាងក្រៅ ទាំងមិនហូរបញ្ចេញតំណក់ផង សេចក្ដីនេះមានឧបមាយ៉ាងណា ម្នាលឧទាយិ ភិក្ខុញ៉ាំងកាយឲ្យជ្រួតជ្រាប ជោគជាំ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ មានឧបមេយ្យដូច្នោះឯង ។

១ ពាក្យថា លោហៈ ជាឈ្មោះធាតុដែក ស្ពាន់ ទង់ដែងជាដើម លើកលែងតែធាតុដ៏ចេញ ។

(១០៨) ពុន ចបរំ ឧទាយិ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ឧទាយិ ឧទករហទោ គម្ភីរោ ឧព្ភិទោទកោ(១) តស្ស នេវស្ស បុរត្ថិមាយ ទិសាយ ឧទកស្សាយមុខំ ន បច្ឆិមាយ ទិសាយ ឧទកស្សាយមុខំ ន ឧត្តរាយ ទិសាយ ឧទកស្សាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្សាយមុខំ ទេវោ ច កាលេន កាលំ សម្មាធារំ នានុប្បវេច្ឆេយ្យ អថខោ តម្ហា ឧទករហទា សីតា វារិធារា ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ ឧទាយិ ភិក្ខុ ឥមមេវ កាយំ

---

១ ម. ឧទករហទោ ឧព្ភិទោទកោ ទិស្សតិ ។



(១០៨) ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានចូលទុតិយជ្ឈាន ភិក្ខុនោះញ៉ាំងកាយនេះឯងឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិនិងសុខ ដែលកើតអំពីសមាធិ ។ ម្នាលឧទាយិ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកផុសឡើង ខាងក្នុងមិនមានផ្លូវទឹកអំពីទិសខាងកើតនៃអន្លង់នោះទេ មិនមានផ្លូវទឹកអំពីទិសខាងលិចទេ មិនមានផ្លូវទឹកអំពីទិសខាងជើងទេ មិនមានផ្លូវទឹកអំពីទិសខាងត្បូងទេ ភ្លៀងសោត ក៏មិនបង្អុរនូវទឹកដោយល្អម្តង ៗ មានតែទឹកដ៏ត្រជាក់ ផុសចេញអំពីអន្លង់ទឹកនោះ ញ៉ាំងអន្លង់ទឹកនោះឯង ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយទឹកត្រជាក់ ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកនោះទាំងអស់ សុទ្ធតែជ្រួតជ្រាបដោយទឹកត្រជាក់ សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលឧទាយិ ភិក្ខុញ៉ាំងកាយនេះឯង

សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។

(១០៦) បុន ចបរំ ឧទាយិ ភិក្ខុ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ឧទាយិ ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសិតានិ តានិ យាវ ច អគ្គា យាវ ច មូលា តេន[1] វារិនា អភិសន្នានិ បរិសន្នានិ បរិបូរានិ បរិប្ផុតានិ នាស្ស កិញ្ចិ សព្វាវតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា

១ ឱ. ម. សីតេន ។



ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខ ដែលកើតអំពីសមាធិនៃបឋមជ្ឈាន ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិនិងសុខ ដែលកើតអំពីសមាធិ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។

(១០៦) ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ។បេ។ ចូលតតិយជ្ឈាន ភិក្ខុនោះញុំាងកាយនេះឯងឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយសេចក្តីសុខដែលគ្មានបីតិ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវ ដោយសេចក្តីសុខដែលគ្មានបីតិ ។ ម្នាលឧទាយិ ដូចជាផ្កាដែលជាតក្លុក ខ្លះ នៃផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី ដែលកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅខាងក្នុងទឹក ដែលទឹកកំពុងចិញ្ចឹមនៅឡើយ ផ្កាដែលជាតទាំងនោះ រមែងជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយទឹកនោះ រហូតដល់ចុងរហូតដល់គល់ ប្រទេសបន្តិចបន្តួចនៃផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តីទាំង

តេន វារិនា អប្ផុតំ អស្ស ឯវមេវ ខោ ឧទាយិ ភិក្ខុ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុតំ ហោតិ ។

[១០៧] បុន ចបរំ ឧទាយិ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុតំ ហោតិ ។ សេយ្យថាបិ ឧទាយិ បុរិសោ ឱទាតេន វត្ថេន សសីសំ បារុបិត្វា និសិន្នោ អស្ស នាស្ស កិញ្ចិ សព្វាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុតំ អស្ស ឯវមេវ ខោ ឧទាយិ ភិក្ខុ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ



អស់ សូម្បីតែពាល់ត្រូវដោយទឹកនោះ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ ភិក្ខុញ៉ាំងកាយនេះឯង ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយសេចក្តីសុខដែលគ្មានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សូម្បីតែពាល់ត្រូវដោយសេចក្តីសុខដែលគ្មានបីតិ មានឧបមេយ្យយ៉ាងនោះដែរ ។

[១០៧] ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះលះបង់សេចក្តីសុខផង ។ បេ ។ ចូលចតុត្ថជ្ឈាន ភិក្ខុនោះអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តបរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សូម្បីតែពាល់ត្រូវដោយចិត្តបរិសុទ្ធផូរផង់ ។ ម្នាលឧទាយិ ដូចជាបុរស អង្គុយខ្លុំក្បាល ដោយសំពត់ស ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់បុរសនោះ សូម្បីតែប៉ះពាល់ ដោយសំពត់ស សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ ភិក្ខុអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយ

សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

[១០៨] បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ឯវំ បជានន្តិ អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសូបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ សិតំ ឯត្ថ បដិពទ្ធំ ។ សេយ្យថាបិ ឧទាយិ មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រស្ស(១) សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតំ វា ឱទាតំ វា បណ្ឌុសុត្តំ វា

១ ម. តត្រិទំ ។



ទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយចិត្តដ៏បរិសុទ្ធផូរផង់ មានទំហំមួយយ៉ាងនោះដែរ ។ ពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងឈានទាំង ៤ នោះ ។

[១០៨] ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ក របស់តថាគតបាន ប្រតិបត្តិ ហើយក៏ដឹងច្បាស់យ៉ាងនេះថា រូបកាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូបទាំង ៤ កើតអំពីមាតានិងបិតា ចំរើនដោយបាយនិងនំ ជាសភាវៈមិនទៀងគឺកាត់មិនឋិតថេរ មានការដុសខាត់បំបាត់ក្លិនអាក្រក់ គក់ច្របាច់ច្របាច់ខ្លួន បែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ឯវិញ្ញាណ របស់អាត្មាអញនេះសោត ក៏អាស្រ័យនៅនឹងរូបកាយនេះ ជាប់ចំពាក់នៅនឹងរូបកាយនេះឯង ។ ម្នាលឧទាយិ ដូចជាកែវពិទូរ្យដែលល្អស្អាត មានជាតិដ៏បរិសុទ្ធ មានជ្រុង ៨ ដែលបុគ្គលខាត់ហើយដោយប្រពៃ គឺបាននាំយកជាតិថ្មនិងក្រួសចេញអស់ហើយ មានសម្បុរភ្លឺថ្លាយ៉ាងវិសេស បរិបូណ៌ដោយអាការទាំងពួងមានដុសលាងជាដើម ទើបបុរសនោះយកខ្សែខៀវក្តី លឿងក្តី ក្រហមក្តី សសុទ្ធក្តី ស្លេកក្តី

តមេនំ ចក្ខុមា បុរិសោ ហត្ថេ ករិត្វា បច្ចវេក្ខេយ្យ អយំ ខោ មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រិទំ សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតំ វា ឱទាតំ វា បណ្ឌុសុត្តំ វាតិ ។ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ឯវំ បជានន្តិ[១] អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសូបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំ-សនធម្មោ ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ សិតំ ឯត្ថ បដិពទ្ធន្តិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១០៩) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនន្តិ រូបឹ

១ ម. ជានន្តិ ។



ទៅរវាងត្បូងកែវនោះ បុរសមានភ្នែកភ្លឺដាក់កែវនោះក្នុងដៃ ហើយពិ-ចារណាមើលក៏ស្គាល់ច្បាស់ថា នេះឯងជាកែវពិទូរ្យល្អស្អាត មានជាតិបរិសុទ្ធ មានជ្រុង ៨ ដែលគេខ្នៃហើយដោយប្រពៃ មានសម្បុរភ្លឺថ្លាយ៉ាងវិសេស បរិបូណ៌ដោយអាការគ្រប់យ៉ាង នេះជាខ្សែដែលមានសម្បុរខៀវ ឬលឿង ក្រហម សសុទ្ធ ឬស្ករ ដែលគេដោតទៅក្នុងកែវនោះ យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូបទាំង ៤ កើតអំពីមាតានឹងបិតា ចំរើនដោយបាយនឹងនំ ជាសភាវៈមិនទៀងទាត់ មិនឋិតថេរ មានការដុសខាត់បំបាត់ក្លិនអាក្រក់ គក់ច្របាច់ ឬពាប់ខ្លួន បែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ឯវិញ្ញាណ របស់អាត្មាអញនេះ ក៏អាស្រ័យនៅនឹងកាយនេះ ជាប់ចំពាក់នៅនឹងកាយនេះ គឺយ៉ាងនេះដែរ ។ ពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

(១០៩) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវក របស់តថាគតបានប្រតិបត្តិ ហើយនិមិត្តនូវកាយដទៃចេញអំពីកាយនេះ ឲ្យជាកាយមានរូប

មនោមយំ សព្វង្គប្បច្ចង្គឹ អហីនិន្ទ្រិយំ ។ សេយ្យថាបិ ឧទាយិ បុរិសោ មុញ្ជម្ហា ឦសិកំ ឧព្វាហេយ្យ[១] តស្ស ឯវមស្ស អយំ ឦសិកា អយំ មុញ្ជោ អញ្ញោ មុញ្ជោ អញ្ញា ឦសិកា មុញ្ជម្ហាត្វេវ ឦសិកា ឧព្វាឡ្ហាតិ[២] សេយ្យថាបិ វា[៣] បនុទាយិ បុរិសោ អសឹ កោសិយា ឧព្វាហេយ្យ តស្ស ឯវមស្ស អយំ អសិ អយំ កោសិ អញ្ញោ អសិ អញ្ញា កោសិ កោសិយាត្វេវ អសិ ឧព្វាឡ្ហោតិ សេយ្យថាបិ វា បនុទាយិ បុរិសោ អហឹ ករណ្ឌា ឧទ្ធរេយ្យ តស្ស ឯវមស្ស អយំ អហិ អយំ ករណ្ឌោ អញ្ញោ អហិ អញ្ញោ ករណ្ឌោ ករណ្ឌាត្វេវ អហិ ឧព្ភតោតិ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនន្តិ រូបឹ មនោមយំ សព្វង្គប្បច្ចង្គឹ អហីនិន្ទ្រិយំ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

១ ឱ. សីហ. ឧព្វហេយ្យ ។ ២ ឱ. បព្វាឡ្ហាតិ ។ ម. បព្វូឡ្ហាតិ ។ ៣ ឱ. ម. សេយ្យថា វា ។



ជាកាយសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនវិកលខូចខាត ។ ដូចបុរសដកហូតបណ្តូលស្មៅយាប្លង់ចេញអំពីដើមស្មៅនោះ បុរសនោះក៏យល់ច្បាស់យ៉ាងនេះថា នេះជាបណ្តូល នេះជាស្មៅយាប្លង់ ស្មៅយាប្លង់ផ្សេង បណ្តូលផ្សេង នេះជាបណ្តូលដែលអញដកចេញអំពីស្មៅយាប្លង់នេះឯង ម្នាលឧទាយិ ពុំនោះសោត ដូចជាបុរសហូតដាវចេញអំពីស្រោម បុរសនោះក៏យល់ច្បាស់យ៉ាងនេះថា នេះដាវ នេះស្រោម ដាវផ្សេង ស្រោមផ្សេង នេះជាដាវដែលអញហូតចេញអំពីស្រោមនេះឯង ម្នាលឧទាយិ ពុំនោះសោត ដូចបុរសដកពស់ចេញអំពីស្រោម បុរសក៏យល់ច្បាស់យ៉ាងនេះថា នេះពស់ នេះស្រោម ពស់ផ្សេង ស្រោមផ្សេង នេះពស់ដែលអញហូតចេញអំពីស្រោមនេះឯង សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយនិម្មិតកាយដទៃចេញអំពីកាយនេះ ឲ្យជាកាយមានរូប ជាកាយសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនវិកលខូចខាត មានឧបមេយ្យដូច្នោះឯង ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

(១១០) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តិ ឯកោបិ ហុត្វា ពហុធា ហោន្តិ ពហុធាបិ ហុត្វា ឯកោ ហោន្តិ អាវិភាវំ តិរោភាវំ តិរោកុដ្ដំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា គច្ឆន្តិ សេយ្យថាបិ អាកាសេ ។ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោន្តិ សេយ្យថាបិ ឧទកេ ។ ឧទកេបិ អភិជ្ជមានេ គច្ឆន្តិ សេយ្យថាបិ បឋវិយំ(១) ។ អាកាសេបិ បល្លង្កេន កមន្តិ សេយ្យថាបិ បក្ខី សកុណា(២) ។ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសន្តិ បរិមជ្ជន្តិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេន្តិ ។ សេយ្យថាបិ ឧទាយិ ទក្ខោ កុម្ភការោ វា កុម្ភការន្តេវាសី វា សុបរិកម្មកតាយ មត្តិកាយ យំយទេវ ភាជនវិកតឹ អាកង្ខេយ្យ តន្តទេវ ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថា វា បនុទាយិ ទក្ខោ ទន្តការោ វា ទន្តការន្តេវាសី វា

១ ម. បឋវិយា ។ ២. ម. សកុណោ ។



(១១០) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិ-បត្តិ ហើយតាក់តែងឫទ្ធិដែលឫទ្ធិមានច្រើនប្រការ គឺកាយតែមួយ ធ្វើឲ្យជាកាយច្រើនក៏បាន ឬកាយច្រើនធ្វើឲ្យត្រឡប់ទៅជាកាយតែមួយវិញក៏បាន ធ្វើអាវិភាវបាដិហារិយ៍(១)ក៏បាន ធ្វើតិរោភាវបាដិហារិយ៍(២) ក៏បាន វៀរចេញទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំក៏បាន ដូចគេដើរលើអាកាស ។ មុជងើបក្នុងផែនដី ដូចក្នុងទឹកក៏បាន ។ ដើរលើទឹកមិនបែកធ្លាយ ដូចដើរលើផែនដីក៏បាន ។ អណ្តែតទៅលើអាកាសទាំងភ្នែន ដូចសកុណបក្សីក៏បាន ។ យកដៃទៅស្ទាបអង្អែលព្រះចន្ទ្រព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិ មានអានុភាពធំយ៉ាងនេះក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅរហូតដល់ព្រហ្មលោកដោយកាយក៏បាន ។ ម្នាលឧទាយិ ដូចជាស្មូនឆ្នាំង ឬកូនសិស្សរបស់ស្មូនឆ្នាំង ដែលឈ្លាសប្រ-សប់ គេប្រាថ្នានូវភាជនៈណា ៗ ដោយដីដែលបានធ្វើបរិកម្មល្អហើយ ក៏គេធ្វើភាជនៈនោះ ៗ ឲ្យសម្រេចបាន ម្នាលឧទាយិ ពុំនោះដូចជាងភ្លុក កូនសិស្សរបស់ជាងភ្លុក ដែលឈ្លាសប្រសប់ គេ

១ ធ្វើទីងងឹតឲ្យភ្លឺ ធ្វើទីកំបាំងឲ្យទៅជាវាល ឬធ្វើទីដែលមើលមិនឃើញឲ្យឃើញ ។
២ ត្រឡប់ធ្វើទីភ្លឺឲ្យងងឹត ធ្វើទីវាលឲ្យទៅជាទីកំបាំង ឬទីដែលមើលឃើញ ធ្វើឲ្យទៅជាទីមើលមិនឃើញ (វិសុទ្ធិមគ្គ ឥទ្ធិវិធនិទ្ទេស) ។

សុបរិកម្មកតស្មឹ ទន្តស្មឹ យំយទេវ ទន្តវិកតឹ អាកង្ខេយ្យ តន្តទេវ ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថា វា បនុទាយិ ទក្ខោ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា សុបរិកម្មកតស្មឹ សុវណ្ណស្មឹ យំយទេវ សុវណ្ណវិកតឹ អាកង្ខេយ្យ តន្តទេវ ករេយ្យ អភិនិប្ផាទេយ្យ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តិ ឯកោបិ ហុត្វា ពហុធា ហោន្តិ ពហុធាបិ ហុត្វា ឯកោ ហោន្តិ អាវិភាវំ តិរោភាវំ តិរោកុដ្ដំ តិរោបាការំ តិរោបព្វតំ អសជ្ជមានា គច្ឆន្តិ សេយ្យថាបិ អាកាសេ ។ បថវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោន្តិ សេយ្យថាបិ ឧទកេ ។ ឧទកេបិ អភិជ្ជមានេ គច្ឆន្តិ សេយ្យថាបិ បថវិយំ ។ អាកាសេបិ បល្លង្កេន កមន្តិ សេយ្យថាបិ បក្ខី សកុណោ ។



ប្រាថ្នានឹងច្នៃទន្តណា ៗ ដោយភ្លុកដែលធ្វើបរិកម្មល្អហើយ ក៏អាចនឹងច្នៃទន្តនោះ ៗ ឲ្យសម្រេចបាន ម្នាលឧទាយិ ពុំនោះសោត ដូចជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តី ដែលឈ្លាសប្រសប់ តែងប្រាថ្នានឹងច្នៃមាសណា ៗ ដោយមាសដែលធ្វើបរិកម្មល្អហើយ ក៏អាចនឹងច្នៃមាសនោះ ៗ ឲ្យសម្រេចបាន សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយសំដែងឫទ្ធិបានច្រើនប្រការ គឺកាយតែមួយធ្វើឲ្យទៅជាកាយច្រើនក៏បាន ឬកាយច្រើនធ្វើឲ្យត្រឡប់ទៅជាកាយតែមួយវិញក៏បាន ធ្វើអាវិភាវបាដិហារិយ៍ក៏បាន ធ្វើតិរោភាវបាដិហារិយ៍ក៏បាន ដើរចេញទៅកាន់ក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំក៏បាន ដូចគេដើរទៅលើអាកាស ។ មុជរើបក្នុងផែនដីដូចក្នុងទឹកក៏បាន ។ ដើរលើទឹកមិនមានបែកធ្លាយ ដូចដើរលើផែនដីក៏បាន ។ អណ្តែតទៅលើអាកាសទាំងភ្នែន ដូចសកុណបក្សីក៏បាន ។

ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១១១) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណន្តិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ សេយ្យថាបិ ឧទាយិ ពលវា សង្ខធមោ អប្បកសិរេន[១] ចតុទ្ទិសា វិញ្ញាបេយ្យ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណន្តិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

---
១ ឱ. ម. អប្បកសិរេនេវ ។



យកដៃទៅស្ទាបអង្អែល នូវព្រះចន្ទព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិធំ មានអានុភាពធំយ៉ាងនេះក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកដោយកាយក៏បាន មានឧបមេយ្យដូច្នេះឯង ។ ពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

(១១១) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ក របស់តថាគតបានប្រតិបត្តិ ហើយមានត្រចៀកទិព្វដ៏បរិសុទ្ធ កន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វ សំឡេងមនុស្ស ទាំងឆ្ងាយ ទាំងជិត ។ ម្នាលឧទាយិ ដូចបុរសអ្នកផ្លុំស័ង្ខ មានកំឡាំងខ្លាំង ញុំាងសំឡេងស័ង្ខឲ្យលាន់ឮទៅក្នុងទិសទាំង ៤ ឲ្យអ្នកផងដឹងបាន ដោយមិនលំបាក យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយមានត្រចៀកទិព្វដ៏បរិសុទ្ធ កន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វ សំឡេងមនុស្ស ទាំងឆ្ងាយ ទាំងជិត ក៏យ៉ាងនោះដែរ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[១០៦] បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានន្តិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានន្តិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានន្តិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានន្តិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានន្តិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានន្តិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានន្តិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានន្តិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានន្តិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានន្តិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានន្តិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានន្តិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានន្តិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានន្តិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានន្តិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានន្តិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានន្តិ ។



(១០៦) ម្នាលឧទាយី មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិហើយ អាចកំណត់ដឹងនូវចិត្តដោយចិត្តរបស់សត្វដទៃ បុគ្គលដទៃ ចិត្តដែលប្រកបដោយរាគៈ ក៏ដឹងថាចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈ ក៏ដឹងថាចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងថាចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងថាចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ ក៏ដឹងថាចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈ ក៏ដឹងថាចិត្តប្រាសចាកមោហៈ ចិត្តដែលមានអារម្មណ៍មួយ ក៏ដឹងថាចិត្តមានអារម្មណ៍មួយ ចិត្តដែលរាយមាយ ក៏ដឹងថាចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរនិងអរូបាវចរ ក៏ដឹងថាចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ ក៏ដឹងថាចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈគឺលោកិយចិត្ត ក៏ដឹងថាចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈគឺលោកុត្តរចិត្ត ក៏ដឹងថាចិត្តជាអនុត្តរៈ ចិត្តដែលតាំងមាំ ក៏ដឹងថាចិត្តតាំងមាំ ចិត្តដែលមិនតាំងមាំ ក៏ដឹងថាចិត្តមិនតាំងមាំ ចិត្តដែលរួចស្រឡះចាកកិលេសាសវៈ ក៏ដឹងថាចិត្តរួចស្រឡះចាកកិលេសាសវៈ ចិត្តដែលមិនបានរួចស្រឡះ ក៏ដឹងថាចិត្តមិនបានរួចស្រឡះ ។

សេយ្យថាបិ ឧទាយិ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ (១) អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខមានោ សកណិកំ វា សកណិកន្តិ បជានេយ្យ អកណិកំ វា អកណិកន្តិ បជានេយ្យ ឯវមេវ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានន្តិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានន្តិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានន្តិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានន្តិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានន្តិ សមោហំ វា ចិត្តំ... វីតមោហំ វា ចិត្តំ... សង្ខិត្តំ វា ចិត្តំ... វិក្ខិត្តំ វា ចិត្តំ... មហគ្គតំ វា ចិត្តំ... អមហគ្គតំ វា ចិត្តំ... សឧត្តរំ វា ចិត្តំ... អនុត្តរំ វា ចិត្តំ... សមាហិតំ វា ចិត្តំ... អសមាហិតំ

១ ម. មណ្ឌនជាតិកោ ។



ម្នាលឧទាយិ ដូចស្ត្រីក្តី បុរសក្តី ដែលនៅក្មេង ពេញក្រមុំ ពេញកំលោះ ក៏កំពុងចូលចិត្តនឹងការប្រដាប់ស្អិតស្អាងកាយ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងកញ្ចក់ ដែលបរិសុទ្ធផូរផង់ក្តី ក្នុងភាជន៍ទឹកដែលថ្លាល្អក្តី បើមុខប្រកបដោយទោស (មានប្រជ្រុយ ដំបៅ មុនពងបួសជាដើម) ក្តី ក៏ដឹងថា មុខប្រកបដោយទោស បើមុខឥតមានទោសក្តី ក៏ដឹងថាមុខឥតមានទោស យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយក៏កំណត់ដឹងចិត្តដោយចិត្តរបស់សត្វដទៃ បុគ្គលដទៃ ចិត្តដែលប្រកបដោយរាគៈ ក៏ដឹងថាចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈ ក៏ដឹងថាចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងថាចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងថាចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ... ចិត្តដែលប្រាសចាកមោហៈ... ចិត្តដែលមានអារម្មណ៍រួម... ចិត្តដែលមានអារម្មណ៍រាយមាយ... ចិត្តដែលជាមហគ្គតៈ... ចិត្តដែលមិនមែនជាមហគ្គតៈ... ចិត្តដែលជាសឧត្តរៈ... ចិត្តដែលជាអនុត្តរៈ... ចិត្តដែលតាំងមាំ... ចិត្តដែលមិនតាំងមាំ...

វា ចិត្តំ... វិមុត្តំ វា ចិត្តំ... អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១១៣) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរន្តិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី



ចិត្តដែលរួចស្រឡះ... ចិត្តដែលមិនរួចស្រឡះ... ក៏ដឹងថាចិត្តមិនរួចស្រឡះ ក៏ដូច្នោះឯង ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

(១១៣) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយរឭកឃើញនូវបុព្វេនិវាស (លំដាប់ខន្ធដែលសន្ធានអាស្រ័យនៅក្នុងកាលមុន) គឺរឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ជាតិខ្លះ ១០ជាតិខ្លះ ២០ជាតិខ្លះ ៣០ជាតិខ្លះ ៤០ជាតិខ្លះ ៥០ជាតិខ្លះ ១០០ ជាតិខ្លះ ១.០០០ជាតិខ្លះ ១០០.០០០ ជាតិខ្លះ រឭកឃើញនូវសំវដ្ដកប្បជាច្រើនខ្លះ វិវដ្ដកប្បជាច្រើនខ្លះ នូវសំវដ្ដវិវដ្ដកប្បជាច្រើនខ្លះថា អាត្មាអញបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានវណ្ណៈយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខនិងទុក្ខយ៉ាងនោះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះហើយ ក៏ទៅកើតក្នុងទីឯណោះទៀត លុះអាត្មាអញបានទៅកើតក្នុងទីនោះហើយ ក៏មានឈ្មោះយ៉ាងនោះ មានគោត្រកូលយ៉ាងនោះ មានវណ្ណៈយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខនិងទុក្ខ

ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរន្តិ ។ សេយ្យថាបិ ឧទាយិ បុរិសោ សកម្ហា គាមា អញ្ញំ គាមំ គច្ឆេយ្យ តម្ហាបិ គាមា អញ្ញំ គាមំ គច្ឆេយ្យ សោ តម្ហា គាមា សកំយេវ គាមំ បច្ចាគច្ឆេយ្យ តស្ស ឯវមស្ស អហំ ខោ សកម្ហា គាមា អមុំ គាមំ អាគច្ឆឹ តត្រ ឯវំ អដ្ឋាសឹ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ តម្ហាបិ គាមា អមុំ គាមំ អាគច្ឆឹ តត្រាបិ ឯវំ អដ្ឋាសឹ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ សោម្ហិ តម្ហា គាមា សកំយេវ គាមំ បច្ចាគតោតិ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា



យ៉ាងនោះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះហើយ ទើបបានមកកើតក្នុងទីនេះ ។ ពួកសាវ័ក រឭកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការ (រូបនិងអាហារជាដើម) ព្រមទាំងឧទ្ទេស (ឈ្មោះនិងគោត្រត្រកូល) ដោយប្រការដូច្នេះ ។ ម្នាលឧទាយិ ដូចជាបុរសចេញអំពីស្រុករបស់ខ្លួន ហើយទៅកាន់ស្រុកដទៃ លុះចេញអំពីស្រុកនោះហើយ ទៅស្រុកដទៃទៀត បុរសនោះលុះចេញអំពីស្រុកនោះហើយ ត្រឡប់មកកាន់ស្រុកខ្លួនដដែលវិញ បុរសនោះ រំពឹងយ៉ាងនេះថា អាត្មាអញបានចេញអំពីស្រុករបស់ខ្លួនហើយ មកដល់ស្រុកឯណោះ កាលនៅក្នុងស្រុកនោះ អាត្មាអញឈរយ៉ាងនោះ អង្គុយយ៉ាងនោះ និយាយយ៉ាងនោះ នៅស្ងៀមយ៉ាងនោះ លុះចេញអំពីស្រុកនោះហើយ បានមកដល់ស្រុកឯណោះទៀត កាលដែលនៅក្នុងស្រុកនោះឯង អាត្មាអញបានឈរយ៉ាងនោះ អង្គុយយ៉ាងនោះ និយាយយ៉ាងនោះ នៅស្ងៀមយ៉ាងនោះ អាត្មាអញនោះ លុះចេញអំពីស្រុកនោះហើយ ទើបបានត្រឡប់មកដល់ស្រុករបស់ខ្លួនដដែល យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ

យថាបដិបន្នា ច សាវកា អនេកវិហិតំ បុព្វេនិវាសំ អនុស្សរន្តិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរន្តិ ។ តេ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១១៦) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សន្តិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានន្តិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា



ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិ ហើយរឭកឃើញនូវបុព្វេនិវាស គឺរឭកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ ពួកសាវ័ក រឭកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ យ៉ាងនេះឯង ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់បារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះ ។

(១១៦) ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយបានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញនូវពួកសត្វដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានវណ្ណៈល្អខ្លះ មានវណ្ណៈអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ក៏ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្ម របស់ខ្លួនថា អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏រមែងទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកសត្វពួកនេះវិញ ប្រកប

កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នា-
គតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុប-
វាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-
មានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ
ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ
យថាកម្មូបគេ សត្តេ បជានាតិ ។ សេយ្យថាបិ[១]
ឧទាយិ ទ្វេ អគារា សទ្វារា តត្រ[២] ចក្ខុមា
បុរិសោ មជ្ឈេ ឋិតោ បស្សេយ្យ មនុស្សេ គេហេ
បវិសន្តេបិ និក្ខមន្តេបិ អនុសំចរន្តេបិ អនុវិចរន្តេបិ
ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ
បដិបទា យថាបដិបន្នា មេ សាវកា ទិព្វេន ចក្ខុនា
វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សន្តិ
ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ

១ ម. សេយ្យថាបិ ។ ២ ម. តត្ថ ។



ដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត
ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់យក
អំពើតាមសេចក្តីយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់
អំពីសេចក្តីស្លាប់ ក៏តែងទៅកាន់សុគតិសួគ៌ទេវលោក ។ ពួកសាវ័ក
មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញនូវ
ពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មាន
វណ្ណៈល្អខ្លះ មានវណ្ណៈអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ កំណត់
ដឹងនូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។
ម្នាលឧទាយិ ដូចជាផ្ទះពីរខ្នង មានទ្វារ បុរសមានចក្ខុ ឈរនៅត្រង់
កណ្តាលផ្ទះទាំងពីរខ្នងនោះ ក៏មើលឃើញពួកមនុស្ស ដែលកំពុងចូល
មកក្តី ចេញទៅក្តី ដើរទៅក្តី ដើរមកក្តី យ៉ាងណា ម្នាលឧទាយិ
បដិបទាដែលតថាគត បានសំដែងហើយ ដល់សាវ័កទាំងឡាយ ដែល
ជាហេតុនាំពួកសាវ័ក របស់តថាគត បានប្រតិបត្តិហើយបាននូវចក្ខុទិព្វ
ដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែល
កំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានវណ្ណៈល្អខ្លះ

ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានន្តិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១១៨) បុន ចបរំ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា យថាបដិបន្នា មេ សាវកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ សេយ្យថាបិ ឧទាយិ បព្វតសង្ខេបេ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្រ(១) ចក្ខុមា បុរិសោ តីរេ ឋិតោ បស្សេយ្យ សិប្បិកសម្ពុកម្បិ សក្ខរកឋលម្បិ មច្ឆគុម្ពម្បិ ចរន្តម្បិ តិដ្ឋន្តម្បិ តស្ស ឯវមស្ស អយំ ខោ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្រិមេ(២) សិប្បិកសម្ពុកាបិ សក្ខរកឋលាបិ មច្ឆគុម្ពាបិ ចរន្តិបិ តិដ្ឋន្តិបីតិ ឯវមេវ ខោ ឧទាយិ អក្ខាតា មយា សាវកានំ បដិបទា

១ ម. ឋ តត្ថ ។ ២ ម. តត្ថិមេ ។



មានវណ្ណៈអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ។ បេ ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ក៏យ៉ាងនោះដែរ ។ ឯសាវ័កទាំងឡាយ របស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះ ។

[១១៨] ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ក របស់តថាគត បានប្រតិបត្តិ ហើយធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះ ដោយបញ្ញារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅ ។ ម្នាលឧទាយិ ដូចជាអន្លង់ទឹកដែលថ្លាយង់យ៉ាងវិសេស មិនល្អក់ នៅលើកំពូលភ្នំ បុរសមានចក្ខុឈរនៅត្រើយអន្លង់ទឹកនោះ មើលឃើញខ្ចៅខ្យងនិងសម្រាមផង ក្រួសនិងអំបែងផង ហ្វូងត្រីផង កំពុងហែលខ្លះ កំពុងសំកាំងនៅខ្លះ បុរសបានដឹងយ៉ាងនេះថា អន្លង់ទឹកនេះឯង ថ្លាយង់យ៉ាងវិសេស មិនមានល្អក់ នេះឯង ជាខ្ចៅខ្យងនិងសម្រាម ក្រួសនិងអំបែងក្នុងអន្លង់នោះ ហ្វូងត្រីទាំងឡាយកំពុងហែលខ្លះ កំពុងសំកាំងនៅខ្លះ យ៉ាងណាមិញ ម្នាលឧទាយិ បដិបទាដែលតថាគតបានសំដែងហើយដល់សាវ័ក

យថាបដិបន្នា មេ សាវកា អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ តត្រ ច បន មេ សាវកា ពហូ អភិញ្ញាវោសានបារមិប្បត្តា វិហរន្តិ ។

(១១៦) អយំ ខោ ឧទាយិ បញ្ចមោ ធម្មោ យេន មម សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តិ ។ ឥមេ ខោ ឧទាយិ បញ្ច ធម្មា យេហិ មម សាវកា សក្ករោន្តិ គរុករោន្តិ មានេន្តិ បូជេន្តិ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរន្តីតិ ។ ឥទមវោច ភគវា អត្តមនោ សកុលុទាយិ បរិព្វាជកោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាសកុលុទាយិសុត្តំ សត្តមំ និដ្ឋិតំ ។

---



ទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះ ដោយបញ្ញារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅយ៉ាងនោះដែរ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងធម៌ទាំងនោះ ។

(១១៦) ម្នាលឧទាយិ នេះឯងធម៌ទី ៥ ដែលជាធម៌នាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈគោរពហើយ ក៏អាស្រ័យនៅ (នឹងតថាគត) ។ ម្នាលឧទាយិ ធម៌ទាំង ៥ នេះឯង ដែលជាធម៌នាំឲ្យពួកសាវ័ក របស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ ក៏អាស្រ័យនៅ (នឹងតថាគត) ។ លុះព្រះមានព្រះភាគ សំដែងភាសិតនេះចប់ហើយ សកុលុទាយិបរិព្វាជក មានចិត្តត្រេកអរ រីករាយហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាសកុលុទាយិសូត្រ ទី ៧ ។

## អដ្ឋមំ សមណមុណ្ឌិកសុត្តំ

(១០៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ បញ្ចមត្តេហិ បរិព្វាជកសតេហិ ។ អថ ខោ បញ្ចកង្គោ ថបតិ សាវត្ថិយា និក្ខមិ ទិវាទិវស្ស ភគវន្តំ ទស្សនាយ ។ អថ ខោ បញ្ចកង្គស្ស ថបតិស្ស ឯតទហោសិ អកាលោ ខោ តាវ ភគវន្តំ ទស្សនាយ បដិសល្លីនោ ភគវា មនោភាវនិយានម្បិ ភិក្ខូនំ អស-មយោ ទស្សនាយ បដិសល្លីនា មនោភាវនីយា ភិក្ខូ

## សមណមុណ្ឌិកសូត្រ ទី៨

(១០៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គាហមានៈ ជាសមណ-មុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងការាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សាលទ្ធិ ជាមួយនឹងបរិព្វាជកបរិស័ទជាច្រើន ចំនួន ៥០០ នាក់ ។ គ្រានោះ នាយជាងឈើឈ្មោះបញ្ចកង្គៈ ចេញអំពីក្រុងសាវត្ថី ដើម្បីទៅគាល់ព្រះមានព្រះភាគតាំងពីថ្ងៃ ។ បញ្ចកង្គៈនាយជាងឈើ មានសេចក្តីត្រិះរិះដូច្នេះថា (កាលនេះ) ជាកាលមិនគួរនឹងគាល់ព្រះមានព្រះភាគនៅឡើយ ដ្បិតព្រះមានព្រះភាគ កំពុងសម្ងំ ទាំងពួកភិក្ខុអ្នកមានការទាជាប់ក្នុងចិត្ត ក៏មិនទាន់ជាវេលាគួរនឹងទៅជួប ព្រោះពួកភិក្ខុអ្នកបានការទាជាប់ក្នុង

យន្នូនាហំ យេន សមយប្បវាទកោ តិន្ទុកាចីរោ ឯកសាលកោ មល្លិកាយ អារាមោ យេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ តេនុបសង្កមេយ្យន្តិ ។ អថខោ បញ្ចកង្គោ ថបតិ យេន សមយប្បវាទកោ តិន្ទុកាចីរោ ឯកសាលកោ មល្លិកាយ អារាមោ តេនុបសង្កមិ ។

(១១៨) តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ(១) អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ កុម្ភទាសីកថំ(២) បុព្វបេតកថំ

១ ឱ. ឧច្ចាសទ្ទាយ មហាសទ្ទាយ ។ ២ ឱ. ម. កុម្ភទាសីកថន្តិ ន ទិស្សតិ ។



ចិត្ត ក៏កំពុងសម្ងំនៅ បើដូច្នោះ គួរតែអញ ចូលទៅរកឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ ឯអារាមរបស់ព្រះនាងមល្លិកា ដែលមានសាលាមួយ មានដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ ។ បញ្ចកង្គៈនាយជាងឈើ ក៏ចូលទៅកាន់អារាមរបស់ព្រះនាងមល្លិកា ដែលមានសាលាមួយ មានដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ ។

(១១៨) សម័យនោះឯង ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ អង្គុយជាមួយនឹងពួកបរិព្វាជកបរិស័ទជាច្រើន ដែលកំពុងបន្លឺសំឡេងខ្ពស់ សំឡេងខ្លាំង និយាយតិរច្ឆានកថាច្រើនប្រការ គឺ និយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីមហាមាត្រ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាជើងក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីទាសីអ្នកដងទឹក និយាយអំពីញាតិដែលទៅក

ជនបទកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ បញ្ចកង្គំ ថបតឹ ទូរតោ អាគច្ឆន្តំ ទិស្វាន សកំ បរិសំ សណ្ឋបេសិ អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ(១) សមណស្ស គោតមស្ស សាវកោ អាគច្ឆតិ បញ្ចកង្គោ ថបតិ យាវតា ខោ បន សមណស្ស គោតមស្ស សាវកា គិហី ឱទាតវសនា សាវត្ថិយំ បដិវសន្តិ អយំ តេសំ អញ្ញតរោ បញ្ចកង្គោ ថបតិ អប្បសទ្ទកាមា ខោ បន តេ អាយស្មន្តោ អប្បសទ្ទវិនីតា អប្បសទ្ទស្ស វណ្ណវាទិនោ អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ(២) ។ អថខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។ អថខោ បញ្ចកង្គោ ថបតិ យេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា

១ ឱ. ម. ឯត្តកេសុ បទេសុ ទិស្សតិ ។ ២ មញ្ញេយ្យាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ជនទៅ និយាយអំពីគ្រឿងផ្សេង ៗ ដែលឥតប្រយោជន៍ និយាយអំពីលោក និយាយអំពីរឿងដីកសមុទ្រ និយាយអំពីសេចក្តីចំរើននិងមិនចំរើន ដែលជាហេតុឥតប្រយោជន៍ជាដើមនុ៎ះៗ ដូច្នោះៗ ។ ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ បានឃើញបញ្ចកង្គៈនាយជាងឈើមកអំពីចម្ងាយ លុះឃើញហើយ ក៏ឃាត់បរិស័ទរបស់ខ្លួនថា ចូរអ្នកដ៏ចំរើនទាំងឡាយមានសំឡេងតិច ៗ ចូរអ្នកដ៏ចំរើនទាំងឡាយកុំមាត់ឡើយ ព្រោះបញ្ចកង្គៈនាយជាងឈើ ជាសាវ័ករបស់ព្រះសមណគោតមមក ពួកសាវ័ករបស់ព្រះសមណគោតម ជាគ្រហស្ថស្លៀកដណ្តប់សំពត់ស អាស្រ័យនៅក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន បណ្តាសាវ័កទាំងនោះ បញ្ចកង្គៈនាយជាងឈើនេះ ក៏ជាសាវ័កមួយដែរ លោកដ៏មានអាយុទាំងនោះ សុទ្ធតែជាអ្នកត្រូវការសំឡេងតិច ព្រោះព្រះសមណគោតមទូន្មានឲ្យជាអ្នកមានសំឡេងតិច ពោលសរសើរសំឡេងតិច យើងធ្វើដូចម្តេច ឲ្យតែគេដឹងច្បាស់ថា បរិស័ទមានសំឡេងតិច ហើយសំគាល់ថាគួរចូលមក ។ បរិព្វាជកទាំងនោះ ក៏នៅស្ងៀម ។ លំដាប់នោះ បញ្ចកង្គៈនាយជាងឈើ ចូលទៅរកឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ លុះចូលទៅដល់ហើយ

ឧគ្គាហមានេន បរិព្វាជកេន សមណមុណ្ឌិកាបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(១១៩) ឯកមន្តំ និសិន្នំ ខោ បញ្ចកង្គំ ថបតឹ ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ ឯតទវោច ចតូហិ ខោ អហំ ថបតិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមបត្តិបត្តំ សមណំ អយោជ្ឈំ កតមេហិ ចតូហិ ឥធ ថបតិ ន កាយេន បាបកំ កម្មំ ករោតិ ន បាបិកំ វាចំ ភាសតិ ន បាបកំ សង្កប្បំ សង្កប្បេតិ ន បាបកំ អាជីវំ អាជីវតិ ឥមេហិ ខោ អហំ ថបតិ ចតូហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមបត្តិបត្តំ សមណំ អយោជ្ឈន្តិ ។ អថខោ បញ្ចកង្គោ ថបតិ ឧគ្គាហមានស្ស បរិព្វាជកស្ស សមណមុណ្ឌិកាបុត្តស្ស ភាសិតំ នេវ អភិនន្ទិ នប្បដិក្កោសិ



ក៏និយាយពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ លុះបញ្ចប់ពាក្យរាក់ទាក់សំណេះសំណាល នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

(១១៩) លុះបញ្ចកង្គៈនាយជាងឈើ អង្គុយក្នុងទីសមគួរហើយ ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ ក៏និយាយដូច្នេះថា ម្នាលនាយជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការ ថាជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈ ឥតមានសេចក្តីញាប់ញ័រ ធម៌ ៤ ប្រការ តើអ្វីខ្លះ ម្នាលនាយជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើអំពើអាក្រក់ដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១ ម្នាលនាយជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការនេះឯង ថាជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈ ឥតមានសេចក្តីញាប់ញ័រ ។ ឯបញ្ចកង្គៈនាយជាងឈើ មិនបានត្រេកអរ មិនបានឃាត់ភាសិតរបស់ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រទេ

អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ ភគវតោ សន្តិកេ ឯតស្ស ភាសិតស្ស អត្ថំ អាជានិស្សាមីតិ ។ អថខោ បញ្ចកង្គោ ថបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ បញ្ចកង្គោ ថបតិ យាវតកោ អហោសិ ឧគ្គាហមានេន បរិព្វាជកេន សមណមុណ្ឌិកាបុត្តេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។

(១៦០) ឯវំ វុត្តេ ភគវា បញ្ចកង្គំ ថបតឹ ឯតទវោច ឯវំ សន្តេ ខោ ថបតិ ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ សម្បន្នកុសលោ ភវិស្សតិ បរមកុសលោ ឧត្តមប្បត្តិបត្តោ សមណោ អយោជ្ឈោ យថា ឧគ្គាហមានស្ស បរិព្វាជកស្ស សមណមុណ្ឌិ-កាបុត្តស្ស វចនំ ។ ទហរស្ស ហិ ថបតិ កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស កាយោតិបិ ន ហោតិ



លុះមិនបានត្រេកអរ មិនបានឃាត់ហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ដោយមានគំនិតថា អាត្មាអញនឹងដឹងនូវសេចក្ដីនៃភាសិតនេះច្បាស់លាស់ក្នុងសំណាក់ព្រះមានព្រះភាគ ។ បញ្ចកង្គៈនាយជាងឈើក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះបញ្ចកង្គៈនាយជាងឈើអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ តាមពាក្យទាំងប៉ុន្មាន ដែលបាននិយាយ ជាមួយនឹងឧគ្គាហមានបរិព្វាជកសមណមុណ្ឌិកាបុត្រ ដោយសព្វគ្រប់ ។

(១៦០) កាលបញ្ចកង្គៈនាយជាងឈើនិយាយយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងបញ្ចកង្គៈនាយជាងឈើដូច្នេះថា ម្នាលនាយជាងឈើ បើដូចពាក្យដែលឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រនិយាយយ៉ាងនោះមែន កូនក្មេងតូចខ្ចីដេកផ្ងារ (មិនទាន់ចេះក្រឡាប់នៅឡើយ) ក៏ជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំ-ណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្ដីញាប់ញ័រផង ។ ម្នាលនាយជាងឈើ ព្រោះកូនក្មេងតូចខ្ចីដេកផ្ងារ នឹងថាមិនមានកាយក៏បាន

កុតោ បន កាយេន បាបកំ កម្មំ ករិស្សតិ អញ្ញត្រ ផន្ទិតមត្តា ។ ទហរស្ស ហិ ថបតិ កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស វាចាតិបិ ន ហោតិ កុតោ បន បាបិកំ វាចំ ភាសិស្សតិ អញ្ញត្រ រោទិតមត្តា ។ ទហរស្ស ហិ ថបតិ កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស សង្កប្បោតិបិ ន ហោតិ កុតោ បន បាបកំ សង្កប្បំ សង្កប្បិស្សតិ អញ្ញត្រ វិកូជិតមត្តា ។ ទហរស្ស ហិ ថបតិ កុមារស្ស មន្ទស្ស ឧត្តានសេយ្យកស្ស អាជីវោតិបិ ន ហោតិ កុតោ បន បាបកំ អាជីវំ អាជីវិស្សតិ អញ្ញត្រ មាតុ ថញ្ញា ។ ឯវំ សន្តេ ខោ ថបតិ ទហរោ កុមារោ មន្ទោ ឧត្តាន-សេយ្យកោ សម្បន្នកុសលោ ភវិស្សតិ បរមកុ-សលោ ឧត្តមបត្តិបត្តោ សមណោ អយោជ្ឈោ យថា ឧគ្គាហមានស្ស បរិព្វាជកស្ស សមណ-មុណ្ឌិកាបុត្តស្ស វចនំ ។



ព្រោះថានឹងធ្វើអំពើអាក្រក់ ដោយកាយណាកើត វៀរលែងតែការបម្រាស់ប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងជាមិនមានវាចាក៏បាន ព្រោះថានឹងពោលវាចាអាក្រក់ណាកើត វៀរលែងតែការយំប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងជាមិនមានសេចក្តីត្រិះរិះក៏បាន ព្រោះថានឹងត្រិះរិះតម្រិះអាក្រក់ណាកើត វៀរលែងតែថ្ងូរខ្សឹបប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងជាមិនមានអាជីវៈក៏បាន ព្រោះថានឹងប្រព្រឹត្តចិញ្ចឹមជីវិតអាក្រក់ណាកើត វៀរលែងតែការបៅដោះម្ដាយប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ បើដូចជាពាក្យដែលឧគ្គាហមានបរិ-ព្វាជកសមណមុណ្ឌិកាបុត្រ និយាយហើយនោះមែន កូនក្មេងតូចខ្ចីដេកផ្ងារ ក៏ជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈ ឥតមានសេចក្តីញាប់ញ័រដែរ ។

(១៦១) ចតូហិ ខោ អហំ ថបតិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ ន ចេវ សម្បន្នកុសលំ ន បរមកុសលំ ន ឧត្តមប្បត្តិបត្តំ សមណំ អយោជ្ឈំ អបិចិមំ ទហរំ កុមារំ មន្ទំ ឧត្តានសេយ្យកំ សមធិគ្គយ្ហ តិដ្ឋតិ កតមេហិ ចតូហិ ឥធ ថបតិ ន កាយេន បាបកំ កម្មំ ករោតិ ន បាបកំ វាចំ ភាសតិ ន បាបកំ សង្កប្បំ សង្កប្បេតិ ន បាបកំ អាជីវំ អាជីវតិ ឥមេហិ ខោ អហំ ថបតិ ចតូហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ ន ចេវ សម្បន្នកុសលំ ន បរមកុសលំ ន ឧត្តមប្បត្តិបត្តំ សមណំ អយោជ្ឈំ អបិចិមំ ទហរំ កុមារំ មន្ទំ ឧត្តានសេយ្យកំ សមធិគ្គយ្ហ តិដ្ឋតិ ។

(១៦២) ទសហិ ខោ អហំ ថបតិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមប្បត្តិបត្តំ សមណំ អយោជ្ឈំ ។ ឥមេ អកុសលា សីលា វទាមិ(១) ថបតិ

១ ម. ឥមេ អកុសលសីលា វទន្តិ ទិស្សន្តិ ។



[១៦១] ម្នាលនាយជាងឈើ តថាគតបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ទាំង ៤ ប្រការថា មិនទាន់ជាអ្នកមានកុសលពេញលេញ មិនទាន់ជាអ្នកមានកុសលដ៏ប្រសើរ មិនទាន់ជាអ្នកដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ មិនទាន់ជាសមណៈ ឥតមានសេចក្ដីញាប់ញ័រនៅឡើយទេ បុរសបុគ្គលនោះ គ្រាន់តែវិសេសជាងកូនក្មេងតូចខ្ចីដេកផ្ងារនេះបន្តិចទេតើ ធម៌ ៤ ប្រការតើអ្វីខ្លះ ម្នាលនាយជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើអំពើអាក្រក់ដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះគ្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១ ម្នាលនាយជាងឈើ តថាគតបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការនេះថា មិនទាន់ជាអ្នកមានកុសលពេញលេញ មិនទាន់ជាអ្នកមានកុសលដ៏ប្រសើរ មិនទាន់ជាអ្នកដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ មិនទាន់ជាសមណៈ ឥតមានសេចក្ដីញាប់ញ័រនៅឡើយទេ បុរសបុគ្គលនោះ គ្រាន់តែវិសេសជាងកូនក្មេងតូចខ្ចីដេកផ្ងារបន្តិចប៉ុណ្ណោះ ។

(១៦២) ម្នាលនាយជាងឈើ លុះតែបុរសបុគ្គលដែលប្រកបដោយអង្គ ១០ ទើបតថាគតបញ្ញត្តថាជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈ ឥតមានសេចក្ដីញាប់ញ័រមែន ។ នេះពួកសីលជាអកុសល ម្នាលនាយជាងឈើ តថាគត

វេទិតព្វន្តិ វទាមិ ។ យតោ សមុដ្ឋានា អកុសលា សីលា តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យត្ថ អកុសលា សីលា អបរិសេសា និរុជ្ឈន្តិ តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យថា បដិបន្នោ អកុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ ឥមេ កុសលា សីលា តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យតោ សមុដ្ឋានា កុសលា សីលា តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យត្ថ កុសលា សីលា អបរិសេសា និរុជ្ឈន្តិ តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យថា បដិបន្នោ កុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ ឥមេ អកុសលា សង្កប្បា តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។ យតោ សមុដ្ឋានា អកុសលា សង្កប្បា តមហំ ថបតិ វេទិតព្វន្តិ វទាមិ ។



តែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាអកុសល កើតអំពីអកុសលចិត្ត (ទាំង១៦) នេះ ម្នាលនាយជាងឈើ តថាគត តែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាអកុសល ក្នុងលោកនេះ រលត់ឥតមានសេសសល់ ម្នាលនាយជាងឈើ តថាគត តែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិដើម្បីរលត់សីលជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ នេះពួកសីលជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាកុសល កើតមកអំពីកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាកុសលក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះឈ្មោះថាប្រតិបត្តិដើម្បីរលត់សីលជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។ នេះពួកសង្កប្បៈជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ សង្កប្បៈជាអកុសលកើតមកអំពីអកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ

ឥធ អកុសលា សង្កប្បា អបរិសេសា និរុជ្ឈន្តិ តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ។ ឯវំ បដិបន្នោ អកុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ។ ឥមេ កុសលា សង្កប្បា តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ឥតោ សមុដ្ឋានា កុសលា សង្កប្បា តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ។ ឥធ កុសលា សង្កប្បា អបរិសេសា និរុជ្ឈន្តិ តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ។ ឯវំ បដិបន្នោ កុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ តមហំ ថបតិ វេទិតព្ពន្តិ វទាមិ ។

(១៦៣) កតមេ ច ថបតិ អកុសលា សីលា ។ អកុសលំ កាយកម្មំ អកុសលំ វចីកម្មំ បាបកោ អាជីវោ ឥមេ វុច្ចន្តិ ថបតិ អកុសលា សីលា ។ ឥមេ ច ថបតិ អកុសលា សីលា កឹសមុដ្ឋានា ។



សង្កប្បៈទាំងឡាយជាអកុសលក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិដើម្បីរលត់សង្កប្បៈទាំងឡាយជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។ នេះពួកសង្កប្បៈជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ សង្កប្បៈទាំងឡាយជាកុសលកើតមកអំពីកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ សង្កប្បៈទាំងឡាយជាកុសលក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិ ដើម្បីរលត់សង្កប្បៈទាំងឡាយជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។

(១៦៣) ម្នាលនាយជាងឈើ ចុះសីលទាំងឡាយជាអកុសល តើដូចម្តេច ។ កាយកម្មជាអកុសល វចីកម្មជាអកុសល អាជីវៈជាបាប ម្នាលនាយជាងឈើ នេះតថាគតហៅថា សីលជាអកុសល ។ ម្នាលនាយជាងឈើ ចុះសីល ជាអកុសលទាំងនេះ តើមានអ្វីជាសមុដ្ឋាន ។

សមុដ្ឋានម្បិ នេសំ វុត្តំ ។ ចិត្តសមុដ្ឋានាតិស្ស វចនីយំ ។ កតមំ ចិត្តំ ។ ចិត្តម្បិ ហិ ពហុ អនេកវិធំ នានប្បការកំ យំ ចិត្តំ សរាគំ សទោសំ សមោហំ ឥតោ សមុដ្ឋានា អកុសលា សីលា ។ ក្វេ ច ថបតិ អកុសលា សីលា កុហឹ អបរិសេសា និរុជ្ឈន្តិ ។ និរោធោបិ នេសំ វុត្តោ ។ ឥធ ថបតិ ភិក្ខុ កាយទុច្ចរិតំ បហាយ កាយសុចរិតំ ភាវេតិ វចីទុច្ចរិតំ បហាយ វចីសុចរិតំ ភាវេតិ មនោទុច្ចរិតំ បហាយ មនោសុចរិតំ ភាវេតិ មិច្ឆាជីវំ បហាយ សម្មាជីវេន ជីវិតំ កប្បេតិ ឯត្ថេតេ អកុសលា សីលា អបរិសេសា និរុជ្ឈន្តិ ។ កថំ បដិបន្នោ ថបតិ អកុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ ។ ឥធ ថបតិ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ



ឯសមុដ្ឋានរបស់សីលជាអកុសលទាំងនោះ ធ្លាប់ពោលរួចហើយ ។ គួរពោលថា មានចិត្តជាសមុដ្ឋាន ។ ចុះចិត្តដូចម្តេច ។ ចិត្តមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺចិត្តប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ សីលជាអកុសលទាំងឡាយ កើតអំពីចិត្តនេះ ។ ម្នាលនាយជាងឈើ ចុះសីល ជាអកុសលទាំងនេះ រលត់ឥតសេសសល់ក្នុងទីណា ។ ឯការរលត់របស់សីលទាំងនោះ ធ្លាប់ពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ លះបង់កាយទុច្ចរិត ចំរើនកាយសុចរិត លះបង់វចីទុច្ចរិត ចំរើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត លះបង់មិច្ឆាជីវៈ ចិញ្ចឹមជីវិតដោយសម្មាជីវៈ សីលជាអកុសលទាំងនោះ តែងរលត់ឥតសេសសល់ក្នុងសោតាបត្តិផលនុ៎ះឯង ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិដូចម្តេច ទើបឈ្មោះថាប្រតិបត្តិ ដើម្បីរលត់សីលទាំងឡាយជាអកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាង

ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ បដិបន្នោ ខោ ថបតិ អកុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ ។

(១៦៦) កតមេ ច ថបតិ កុសលា សីលា ។ កុសលំ កាយកម្មំ កុសលំ វចីកម្មំ អាជីវបរិសុទ្ធិំបិ ខោ អហំ ថបតិ សីលស្មឹ វទាមិ ឥមេ វុត្តិ ថបតិ កុសលា សីលា ។ ឥមេ ច ថបតិ កុសលា សីលា កឹសមុដ្ឋានា ។ សមុដ្ឋានម្បិ នេសំ វុត្តំ ។ ចិត្តសមុដ្ឋានាតិស្ស វចនីយំ ។ កតមំ ចិត្តំ ។ ចិត្តម្បិ ហិ ពហុ អនេកវិធំ នានប្បការកំ យំ ចិត្តំ វីតរាគំ វីតទោសំ វីតមោហំ



ឆន្ទៈឲ្យកើតឡើង ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់ធម៌ទាំងឡាយជាអកុសលដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើតឡើង ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅវិញ ឲ្យរឹងរឹតតែធំទូលាយ ចម្រើន ពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិ ដើម្បីរលត់សីលទាំងឡាយជាអកុសល ។

(១៦៦) ម្នាលនាយជាងឈើ ចុះសីលទាំងឡាយជាកុសលតើដូចម្តេច ។ ម្នាលនាយជាងឈើ តថាគតពោលនូវកាយកម្ម ជាកុសល វចីកម្ម ជាកុសល ទាំងអាជីវបារិសុទ្ធិផង ថាជាសីល ម្នាលជាងឈើ ទាំងនេះហៅថា សីលជាកុសល ។ ម្នាលនាយជាងឈើ ចុះសីលជាកុសលទាំងនេះ មានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សីលជាកុសលទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានចិត្តជាសមុដ្ឋាន ។ ចុះចិត្តដូចម្តេច ។ ចិត្តមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺចិត្តប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ

ឯតេ សមុដ្ឋានា កុសលា សីលា ។ ឯតេ ច ថបតិ កុសលា សីលា កុហឹ អបរិសេសា និរុជ្ឈន្តិ ។ និរោធោបិ នេសំ វុត្តោ ។ ឥធ ថបតិ ភិក្ខុ សីលវា ហោតិ នោ ច សីលមយោ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ យថាភូតំ បជានាតិ យត្ថស្ស តេ កុសលា សីលា អបរិសេសា និរុជ្ឈន្តិ ។ ឯវំ បដិបន្នោ ខោ ថបតិ កុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ ។ ឥធ ថបតិ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ បដិបន្នោ ខោ ថបតិ កុសលានំ សីលានំ និរោធាយ បដិបន្នោ ហោតិ ។



សីលជាកុសលកើតអំពីចិត្តនេះ ។ ម្នាលនាយជាងឈើ ចុះសីលជាកុសលទាំងនេះ រលត់ឥតសេសសល់ ក្នុងទីណា ។ ការរលត់របស់សីលទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ប៉ុន្តែមិនទាន់សម្រេចត្រឹមសីលប៉ុណ្ណោះទេ រមែងដឹងច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះផង តាមសេចក្តីពិតថា សីលជាកុសលទាំងនោះ របស់ភិក្ខុនោះ រមែងរលត់ឥតសេសសល់ក្នុងអរហត្តផល ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិយ៉ាងណា ទើបហៅថា ប្រតិបត្តិ ដើម្បីរលត់សីលទាំងឡាយជាកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់ពួកធម៌ជាអកុសលដ៏លាមកដែលកើតឡើងហើយ ។ បេ ។ ដើម្បីញុំាងពួកធម៌ជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។ បេ ។ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងពួកធម៌ជាកុសលដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាស ឲ្យរឹតតែធំទូលាយ ចំរើន ពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ទើបហៅថា ប្រតិបត្តិ ដើម្បីរលត់សីលទាំងឡាយ ជាកុសល ។

[១៦៨] កតមេ ច ថបតិ អកុសលា សង្កប្បា ។ កាមសង្កប្បោ ព្យាបាទសង្កប្បោ វិហឹសាសង្កប្បោ ឥមេ វុច្ចន្តិ ថបតិ អកុសលា សង្កប្បា ។ ឥមេ ច ថបតិ អកុសលា សង្កប្បា កឹសមុដ្ឋានា ។ សមុដ្ឋានម្បិ នេសំ វុត្តំ ។ សញ្ញាសមុដ្ឋានាតិស្ស វចនីយំ ។ កតមា សញ្ញា ។ សញ្ញាបិ ហិ ពហុ អនេកវិធា នានប្បការកា ។ យា កាមសញ្ញា ព្យាបាទសញ្ញា វិហឹសាសញ្ញា ឥតោសមុដ្ឋានា អកុសលា សង្កប្បា ។ ឥមេ ច ថបតិ អកុសលា សង្កប្បា កុហឹ អបរិសេសា និរុជ្ឈន្តិ ។ និរោធោបិ នេសំ វុត្តោ ។ ឥធ ថបតិ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថេតេ អកុសលា សង្កប្បា អបរិសេសា និរុជ្ឈន្តិ ។ កថំ បដិបន្នោ ច ថបតិ



(១៦៨) ម្នាលនាយជាងឈើ សង្កប្បៈទាំងឡាយជាអកុសលតើដូចម្តេច ។ កាមសង្កប្បៈ ១ ព្យាបាទសង្កប្បៈ ១ វិហឹសាសង្កប្បៈ ១ ម្នាលនាយជាងឈើ ទាំងនេះ ហៅថា សង្កប្បៈជាអកុសល ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈជាអកុសលទាំងនេះ មានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានសញ្ញាជាសមុដ្ឋាន ។ ចុះសញ្ញាដូចម្តេច ។ សញ្ញាមានច្រើន មានបែបមិនមែនមួយ មានប្រការផ្សេងៗ គឺកាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហឹសាសញ្ញា ១ សង្កប្បៈជាអកុសលកើតមកអំពីសញ្ញាទាំងនេះ ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈ ជាអកុសលទាំងនេះ រលត់ឥតសេសសល់ក្នុងទីណា ។ ឯការរលត់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលនៅកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈកើតអំពីវិវេក សង្កប្បៈជាអកុសលទាំងនោះ រលត់ឥតសេសសល់ក្នុងឋានបឋមជ្ឈាននេះ ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិយ៉ាងណា ទើប

អកុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ ។ ឥធ ថបតិ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ បដិបន្នោ ខោ ថបតិ អកុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ ។

(១៦៦) កតមេ ច ថបតិ កុសលា សង្កប្បា ។ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ ឥមេ វុច្ចន្តិ ថបតិ កុសលា សង្កប្បា ។ ឥមេ ច ថបតិ កុសលា សង្កប្បា កឹសមុដ្ឋានា ។ សមុដ្ឋានម្បិ នេសំ វុត្តំ ។ សញ្ញាសមុដ្ឋានាតិស្ស វចនីយំ ។ កតមា សញ្ញា ។ សញ្ញាបិ ហិ ពហុ



ហៅថាប្រតិបត្តិ ដើម្បីរលត់សង្កប្បៈទាំងឡាយជាអកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងពួកធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់ធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ។ បេ ។ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសល ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។ បេ ។ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅវិញ ឲ្យរឹតតែធំទូលាយ ចំរើន ពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ហៅថាប្រតិបត្តិ ដើម្បីរលត់សង្កប្បៈទាំងឡាយជាអកុសល ។

(១៦៦) ម្នាលនាយជាងឈើ ចុះសង្កប្បៈទាំងឡាយជាកុសល តើដូចម្តេច នេក្ខម្មសង្កប្បៈ១ អព្យាបាទសង្កប្បៈ១ អវិហឹសាសង្កប្បៈ១ ម្នាលនាយជាងឈើ ទាំងនេះ ហៅថា សង្កប្បៈជាកុសល ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈទាំងឡាយជាកុសលនេះ មានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានសញ្ញាជាសមុដ្ឋាន ។ ចុះសញ្ញាដូចម្តេច ។ សញ្ញាមានច្រើន មានបែប

អនេកវិធា នានប្បការកា យា(១) នេក្ខម្មសញ្ញា អព្យាបាទសញ្ញា អវិហឹសាសញ្ញា ឥតោសមុដ្ឋានា កុសលា សង្កប្បា ។ ឥមេ ច ថបតិ កុសលា សង្កប្បា កុហឹ អបរិសេសា និរុជ្ឈន្តិ ។ និរោធោបិ នេសំ វុត្តោ ។ ឥធ ថបតិ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្ថេតេ កុសលា សង្កប្បា អបរិសេសា និរុជ្ឈន្តិ ។ កថំ បដិបន្នោ ច ថបតិ កុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ ។ ឥធ ថបតិ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វិរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ។ បេ ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ

១ ម. ប. យាតិ ន ទិស្សតិ ។



មិនតែមួយ មានប្រការផ្សេងៗ គឺ នេក្ខម្មសញ្ញា ១ អព្យាបាទសញ្ញា ១ អវិហឹសាសញ្ញា ១ សង្កប្បៈ ទាំងឡាយជាកុសល កើតមកអំពីសញ្ញាទាំងនេះ ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈទាំងឡាយ ជាកុសលនេះ រលត់ឥតសេសសល់ ក្នុងទីណា ។ ឯការរលត់របស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ។ បេ ។ ចូលទុតិយជ្ឈាន សង្កប្បៈជាកុសលទាំងនេះ រលត់ឥតមានសេសសល់ ក្នុងទុតិយជ្ឈាននុ៎ះឯង ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិដូចម្តេច ទើបហៅថា ប្រតិបត្តិ ដើម្បីរលត់សង្កប្បៈទាំងឡាយជាកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ទំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់ធម៌ទាំងឡាយជាអកុសលដ៏លាមកដែលកើតឡើងហើយ ។ បេ ។ ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន

។ បេ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឯវំ បដិបន្នោ ខោ ថបតិ កុសលានំ សង្កប្បានំ និរោធាយ បដិបន្នោ ហោតិ ។

(១៦៧) កតមេហិ ថបតិ ទសហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមបត្តិបត្តំ សមណំ អយោជ្ឈំ ។ ឥធ ថបតិ ភិក្ខុ អសេក្ខាយ សម្មាទិដ្ឋិយា សមន្នាគតោ ហោតិ អសេក្ខេន សម្មាសង្កប្បេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាវាចាយ សមន្នាគតោ ហោតិ អសេក្ខេន សម្មាកម្មន្តេន សមន្នាគតោ ហោតិ អសេក្ខេន សម្មាអាជីវេន សមន្នាគតោ ហោតិ អសេក្ខេន សម្មាវាយាមេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាសតិយា សមន្នាគតោ ហោតិ អសេក្ខេន សម្មាសមាធិនា សមន្នាគតោ ហោតិ



។ បេ ។ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅវិញ ឲ្យកើតកាន់តែច្រើនឡើង ចំរើន ពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ហៅថា ប្រតិបត្តិ ដើម្បីរំលត់សង្កប្បៈទាំងឡាយជាកុសល ។

(១៦៧) ម្នាលនាយជាងឈើ តថាគត បញ្ញត្តបុរសបុគ្គល ប្រកបដោយធម៌ ១០ ប្រការ ថាជាអ្នកមានកុសលដ៏បរិបូណ៌ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈ ឥតមានសេចក្តីញាប់ញ័រ តើអ្វីខ្លះ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសម្មាទិដ្ឋិជាអសេក្ខៈ ១ ប្រកបដោយសម្មាសង្កប្បៈជាអសេក្ខៈ ១ ប្រកបដោយសម្មាវាចាជាអសេក្ខៈ ១ ប្រកបដោយសម្មាកម្មន្តៈជាអសេក្ខៈ ១ ប្រកបដោយសម្មាអាជីវៈជាអសេក្ខៈ ១ ប្រកបដោយសម្មាវាយាមៈជាអសេក្ខៈ ១ ប្រកបដោយសម្មាសតិជាអសេក្ខៈ ១ ប្រកបដោយសម្មាសមាធិជាអសេក្ខៈ ១

អសេក្ខេន សម្មាញាណេន សមន្នាគតោ ហោតិ អសេក្ខាយ សម្មាវិមុត្តិយា សមន្នាគតោ ហោតិ ។ ឥមេហិ ខោ អហំ ថបតិ ទសហិ ធម្មេហិ សមន្នាគតំ បុរិសបុគ្គលំ បញ្ញាបេមិ សម្បន្នកុសលំ បរមកុសលំ ឧត្តមបត្តិបត្តំ សមណំ អយោជ្ឈំ ។ ឥទមវោច ភគវា អត្តមនោ បញ្ចកង្គោ ថបតិ ភគវតោ ភាសិតំ អភិនន្ទីតិ ។

សមណមុណ្ឌិកសុត្តំ អដ្ឋមំ និដ្ឋិតំ ។

---





ប្រកបដោយសម្មាញាណៈជាអសេក្ខៈ ១ ប្រកបដោយសម្មាវិមុត្តិជាអសេក្ខៈ ១ ។ ម្នាលនាយជាងឈើ តថាគត បញ្ញត្តបុរសបុគ្គល ប្រកបដោយធម៌ទាំង ១០ ប្រការនេះឯង ថាជាអ្នកមានកុសលដ៏បរិបូណ៌ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ឧត្តម ជាសមណៈ ឥត មានសេចក្តីញាប់ញ័រ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះ ចប់ហើយ បញ្ចកង្គៈនាយជាងឈើ ក៏ត្រេកអររីករាយ ហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ សមណមុណ្ឌិកសូត្រ ទី ៨ ។

## នវមំ ចូឡសកុលុទាយិសុត្តំ

(១៦៨) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន សកុលុទាយិ បរិព្វាជកោ មោរនិវាបេ បរិព្វាជការាមេ បដិវសតិ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ[1] ។ អថខោ ភគវតោ ឯតទហោសិ អតិប្បគោ ខោ តាវ រាជគហេ[2] បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន មោរនិវាបោ បរិព្វាជការាមោ យេន សកុលុទាយិ បរិព្វាជកោ តេនុបសង្កមេយ្យន្តិ ។ អថខោ ភគវា យេន មោរនិវាបោ បរិព្វាជការាមោ តេនុបសង្កមិ ។

១ ឱ. ម. បត្តចីវរំ អាទាយ រាជគហំ បិណ្ឌាយ បាវិសីតិ ទិស្សតិ ។ ២ ឱ. រាជគហេ ។

## ចូឡសកុលុទាយិសូត្រ ទី ៩

(១៦៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង បរិព្វាជកឈ្មោះសកុលុទាយិ នៅអាស្រ័យក្នុងបរិព្វាជការាម ឈ្មោះមោរនិវាបៈ ជាមួយនឹងបរិព្វាជកបរិស័ទច្រើននាក់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ស្តេចចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគទ្រង់មានសេចក្តីត្រិះរិះ ក្នុងវេលានោះយ៉ាងនេះថា ការត្រាច់ទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត នៅព្រឹកណាស់នៅឡើយ បើដូច្នោះ គួរតែតថាគត ចូលទៅរកសកុលុទាយិបរិព្វាជក ឯបរិព្វាជការាមឈ្មោះមោរនិវាបៈសិន ។ ព្រះមានព្រះភាគ ក៏ទ្រង់ស្តេចចូលទៅរកបរិព្វាជការាម ឈ្មោះមោរនិវាបៈ ។

[១៦៩] តេន ខោ បន សមយេន សកុលុទាយិ បរិព្វាជកោ មហតិយា បរិព្វាជកបរិសាយ សទ្ធឹ និសិន្នោ ហោតិ ឧន្នាទិនិយា ឧច្ចាសទ្ទមហាសទ្ទាយ អនេកវិហិតំ តិរច្ឆានកថំ កថេន្តិយា សេយ្យថីទំ រាជកថំ ។ បេ ។ ឥតិភវាភវកថំ ឥតិ វា ។ អទ្ទសា ខោ សកុលុទាយិ បរិព្វាជកោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន សកំ បរិសំ សណ្ឋបេសិ អប្បសទ្ទា ភោន្តោ ហោន្តុ មា ភោន្តោ សទ្ទមកត្ថ អយំ សមណោ គោតមោ អាគច្ឆតិ អប្បសទ្ទកាមោ ខោ បន សោ អាយស្មា អប្បសទ្ទស្ស វណ្ណវាទី អប្បេវ នាម អប្បសទ្ទំ បរិសំ វិទិត្វា ឧបសង្កមិតព្វំ មញ្ញេយ្យាតិ ។ អថខោ តេ បរិព្វាជកា តុណ្ហី អហេសុំ ។ អថខោ ភគវា យេន សកុលុទាយិ បរិព្វាជកោ តេនុបសង្កមិ ។ អថខោ សកុលុទាយិ បរិព្វាជកោ ភគវន្តំ ឯតទវោច ឯតុ ខោ ភន្តេ ភគវា ស្វាគតំ(១) ភន្តេ ភគវតោ ចិរស្សំ ខោ ភន្តេ

១ ម. សាគតំ ។



[១៦៩] សម័យនោះឯង សកុលុទាយិបរិព្វាជក អង្គុយជាមួយនឹងបរិព្វាជកបរិស័ទច្រើននាក់ ដែលកំពុងបន្លឺសំឡេងខ្ពស់ សំឡេងខ្លាំង និយាយតិរច្ឆានកថា ជាច្រើនប្រការគឺ និយាយអំពីស្តេច ។ បេ ។ និយាយអំពីសេចក្តីវិនាសនឹងសេចក្តីចំរើន ដែលជាហេតុឥតប្រយោជន៍ ជាដូច្នេះខ្លះ ដូច្នោះខ្លះ ។ សកុលុទាយិបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏បញ្ឈប់បរិស័ទរបស់ខ្លួនថា ចូរអ្នកដ៏ចំរើនទាំងឡាយមានសំឡេងតិច ។ ចូរអ្នកដ៏ចំរើនទាំងឡាយកុំហក់អ៊ឹងឡើយ ព្រោះព្រះសមណគោតមនេះ និមន្តមក ឯព្រះសមណគោតម មានអាយុនោះ ជាអ្នកត្រេកអរតែនឹងសំឡេងតិច ពោលសរសើរសំឡេងតិច ធ្វើដូចម្តេចឲ្យតែលោកដឹងថា បរិស័ទមានសំឡេងតិច ហើយសំគាល់ថា គួរចូលមក ។ ពួកបរិព្វាជកទាំងនោះក៏នៅស្ងៀម ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅរកសកុលុទាយិបរិព្វាជក ។ សកុលុទាយិបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ស្តេចមកចុះ បពិត្រព្រះអង្គដ៏ចំរើន ដំណើរស្តេចមកនៃព្រះមានព្រះភាគជាការប្រពៃហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគបានបម្រុងនឹងធ្វើដំណើរមក គង់ទីនេះអស់កាលយូរហើយ បពិត្រព្រះអង្គ

ភគវា ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភន្តេ ភគវា ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ សកុលុទាយីបិ ខោ បរិព្វាជកោ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សកុលុទាយឹ បរិព្វាជកំ ភគវា ឯតទវោច កាយ នុត្ថ-ឧទាយិ ឯតរហិ កថាយ សន្និសិន្នា កា ច បន តេ អន្តរាកថា វិប្បកតាតិ ។

(១៣០) តិដ្ឋតេសា ភន្តេ កថា យាយ មយំ ឯតរហិ កថាយ សន្និសិន្នា នេសា ភន្តេ កថា ភគវតោ ទុល្លភា ភវិស្សតិ បច្ឆាបិ សវនាយ យទាហំ ភន្តេ ឥមំ បរិសំ អនុបសង្កន្តោ ហោមិ អថាយំ បរិសា អនេកវិហិតំ តិរច្ឆានកថំ កថេន្តី និសិន្នា ហោតិ យទា ច ខោ អហំ ភន្តេ ឥមំ បរិសំ ឧបសង្កន្តោ ហោមិ អថាយំ បរិសា មមំយេវ មុខំ ឧល្លោកេន្តី និសិន្នា ហោតិ



ដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់គង់ចុះ អាសនៈនេះខ្ញុំព្រះអង្គបានក្រាលហើយ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ សកុលុទាយិបរិព្វាជកកាន់យកអាសនៈដ៏ទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។ លុះសកុលុទាយិបរិព្វាជកអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលឧទាយិ អ្នកអង្គុយប្រជុំគ្នានិយាយពីរឿងអ្វីអម្បាញ់មិញនេះ ចុះពាក្យដូចម្តេចដែលអ្នកទាំងឡាយធ្វើឲ្យដាច់ពាក់កណ្តាលទៅ ។

(១៣០) សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលខ្ញុំព្រះអង្គទាំងឡាយប្រជុំគ្នានិយាយអម្បាញ់មិញនេះ លើកទុកសិន បពិត្រព្រះអង្គដ៏ចំរើន ពាក្យនុ៎ះមិនមែនជាការក្រដល់ព្រះអង្គទេ សូមទ្រង់ព្រះសណ្តាប់ជាខាងក្រោយចុះ បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គមិនទាន់ចូលទៅជិតបរិស័ទនេះ បរិស័ទនេះ ក៏អង្គុយនិយាយតែតិរច្ឆានកថាច្រើនប្រការ បពិត្រព្រះអង្គដ៏ចំរើន លុះតែកាលដែលខ្ញុំព្រះអង្គចូលទៅជិតបរិស័ទនេះ ទើបបរិស័ទនេះ អង្គុយមើលមុខខ្ញុំព្រះអង្គ

យន្នោ សមណោ គោតមោ ឧទាយិ ធម្មំ ទេសិស្សតិ តន្នោ(១) សោស្សាមាតិ ។ យតោ បន ភន្តេ ភគវា ឥមំ បរិសំ ឧបសង្កន្តោ ហោតិ អថ ច អហាញោ(២) អយំ បរិសា ភគវតោ មុខំ ឧល្លោកេន្តី និសិន្នា ហោតិ(៣) យន្នោ ភគវា ធម្មំ ភាសិស្សតិ តន្នោ សោស្សាមាតិ ។ តេនហិ ឧទាយិ តញ្ញេវេត្ថ(៤) បដិភាតុ យថា មំ បដិភាសេយ្យាតិ ។

(១៣១) បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានមានោ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ សោ មយា បុព្វន្តំ អារព្ភ បញ្ហំ បុដ្ឋោ សមានោ អញ្ញេនញ្ញំ បដិចរិ ពហិទ្ធាកថំ អបនាមេសិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសិ

១ ម. តំ ។ ២ ម. អថ អហាញោ ។ ម. អហាហាតោ ។ ៣ ម. ហោម ។ ៤ ម. តេនហុទាយិ តំយេវេត្ថ ។



និយាយថា បពិត្រឧទាយិ យើងទាំងឡាយចាំស្តាប់ធម៌ដែលព្រះសមណ-គោតមនឹងសំដែង ដល់យើងទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចំរើន កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចូលមកកាន់បរិស័ទនេះ ខ្ញុំព្រះអង្គនឹងចូលទៅដែរ ឯបរិស័ទនេះ ក៏គង់តែអង្គុយមើលព្រះភក្ត្រព្រះមានព្រះភាគដោយគិតថា យើងទាំងឡាយចាំស្តាប់ធម៌ ដែលព្រះមានព្រះភាគនឹងសំដែង ដល់យើងទាំងឡាយ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ បើដូច្នោះ ចូរអ្នកគាត់នឹងផ្តើមប្រស្នានោះមក តថាគតនឹងសំដែងតបតាមហេតុក្នុងប្រស្នានុ៎ះ ។

(១៣១) សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពីថ្ងៃមុនៗ មានបុគ្គលជាអ្នកដឹងសព្វ ឃើញសព្វ ដឹងច្បាស់នូវញាណ-ទស្សនៈឥតសេសសល់ និយាយថា កាលខ្ញុំដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ក្តី ញាណទស្សនៈប្រាកដឡើងរឿយៗ មិនដាច់ បុគ្គលនោះ កាលដែលខ្ញុំព្រះអង្គសួរប្រស្នាប្រារព្ធចំពុះខាងដើម ត្រឡប់ជាគេចកែពាក្យដទៃដោយពាក្យដទៃ យកពាក្យខាងក្រៅមកបន្ទុំបន្ទប់ ហើយសំដែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីតាក់អន់ចិត្តឲ្យប្រាកដឡើង

តស្ស មយ្ហំ ភន្តេ ភគវន្តំយេវ អារព្ភ សតិ ឧទបាទិ អហោ នូន ភគវា អហោ នូន សុគតោ យោ ឥមេសំ ធម្មានំ កុសលោតិ ។ កោ បនេសោ ឧទាយិ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានមានោ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ សោ តយា បុព្វន្តំ អារព្ភ បញ្ហំ បុដ្ឋោ សមានោ អញ្ញេនញ្ញំ បដិចរិ ពហិទ្ធា កថំ អបនាមេសិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាត្វាកាសីតិ ។ និគណ្ឋោ ភន្តេ នាដបុត្តោតិ ។

(១៣៦) យោ ខោ ឧទាយិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យ សោ វា មំ បុព្វន្តំ អារព្ភ បញ្ហំ បុច្ឆេយ្យ តំ វាហំ បុព្វន្តំ អារព្ភ បញ្ហំ បុច្ឆេយ្យំ សោ វា មេ បុព្វន្តំ អារព្ភ



បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គក៏កើតសតិឡើង ព្រោះប្រារព្ធចំពោះព្រះមានព្រះភាគថា ឲមានតែព្រះមានព្រះភាគ ឲមានតែព្រះសុគត ទើបព្រះអង្គឈ្លាសវៃចំពោះធម៌ទាំងនេះ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ចុះបុគ្គលណាជាអ្នកដឹងសព្វ ឃើញសព្វ ដឹងច្បាស់នូវញាណ-ទស្សនៈឥតសេសសល់ និយាយថា កាលខ្ញុំដើរក្តី ឈរក្តី ដេកលក់ក្តី របើកក្តី ញាណទស្សនៈក៏ប្រាកដឡើងហើយ ៗ មិនដាច់ បុគ្គលនោះ កាលដែលអ្នកបានសួរប្រស្នាប្រារព្ធទីបំផុតខាងដើម ក៏ត្រឡប់ជាគេចតែពាក្យដទៃដោយពាក្យដទៃ យកពាក្យខាងក្រៅមកបន្លំខ្ទប់ ហើយសំដែងនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង ។ សកុលុទាយិក្រាបបង្គំទូលថា និគ្រន្ថនាដបុត្រ ព្រះអង្គ ។

(១៣៦) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ បុគ្គលណាមួយ រលឹកឃើញ បុព្វេនិវាសមានច្រើនប្រការគឺ រលឹកឃើញជាតិ ១ ជាតិ ២ ។ បេ ។ រលឹកឃើញបុព្វេនិវាស មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ (បើ) បុគ្គលនោះសួរប្រស្នានឹងតថាគត ប្រារព្ធទីបំផុតខាងដើម តថាគតក៏សួរប្រស្នានឹងបុគ្គលនោះប្រារព្ធទីបំផុតខាងដើមដែរ បុគ្គលនោះប្រារព្ធទីបំផុតខាងដើម ធ្វើ

បញ្ហស្ស វេយ្យាករណេន ចិត្តំ អារាធេយ្យ តស្ស វាហំ បុព្វន្តំ អារព្ភ បញ្ហស្ស វេយ្យាករណេន ចិត្តំ អារាធេយ្យំ យោ(១) វា ឧទាយិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។បេ។ យថាកម្មូបគេ សត្តេ បជានេយ្យ សោ វា មំ អបរន្តំ អារព្ភ បញ្ហំ បុច្ឆេយ្យ តំ វាហំ អបរន្តំ អារព្ភ បញ្ហំ បុច្ឆេយ្យំ សោ វា មេ(២) អបរន្តំ អារព្ភ បញ្ហស្ស វេយ្យាករណេន ចិត្តំ អារាធេយ្យ តស្ស វាហំ អបរន្តំ អារព្ភ បញ្ហស្ស វេយ្យាករណេន ចិត្តំ អារាធេយ្យំ អបិច ឧទាយិ តិដ្ឋតុ បុព្វន្តោ តិដ្ឋតុ អបរន្តោ ធម្មំ តេ ទេសេស្សាមិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ

១ ឱ. សោ ។ ២ ឱ. មំ ។



ចិត្តតថាគតឲ្យត្រេកអរ ដោយការដោះប្រស្នាបាន តថាគតក៏ប្រារព្ធទីបំ-ផុតខាងដើម ធ្វើចិត្តបុគ្គលនោះឲ្យត្រេកអរ ដោយការដោះប្រស្នាបានដែរ បុគ្គលណាមួយ មានទិព្វចក្ខុបរិសុទ្ធកន្លងចក្ខុរបស់មនុស្សសាមញ្ញ ឃើញសត្វទាំងឡាយដែលច្យុត ដែលកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ។បេ។ ក៏ដឹងច្បាស់នូវពួកសត្វដែលទៅតាមយថាកម្ម (បើ) បុគ្គលនោះ សួរប្រស្នានឹងតថាគតប្រារព្ធទីបំផុតខាងចុង តថាគតក៏សួរប្រស្នានឹងបុគ្គលនោះប្រារព្ធទីបំផុតខាងចុងដែរ បុគ្គលនោះប្រារព្ធទីបំផុតខាងចុងធ្វើចិត្តតថាគតនោះឲ្យត្រេកអរ ដោយការដោះប្រស្នាបានដែរ ប៉ុន្តែណ្ហើយចុះ ឧទាយិ ទីបំផុតខាងដើមលើកទុក ទីបំផុតខាងចុងក៏លើកទុកចុះ តថាគតនឹងសំដែងធម៌ដល់អ្នក កាលបើទីបំផុតខាងដើមនេះមាន ទីបំផុតខាងចុងនេះក៏មាន ទីបំផុតខាងចុងនេះកើតឡើងបាន ព្រោះទីបំផុតខាងដើមនេះកើតឡើង

ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតីតិ ។ អហញ្ហិ[១] ភន្តេ យាវតកម្បិ មេ ឥមិនា អត្តភាវេន បច្ចនុភូតំ តម្បិ ន បហោមិ ឥតិ សាការំ សឧទ្ទេសំ អនុស្សរិតុំ កុតោ បនាហំ អនេក-វិហិតំ បុព្វេនិវាសំ អនុស្សរិស្សាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្ស-រិស្សាមិ សេយ្យថាបិ ភគវា អហញ្ហិ ភន្តេ ឯតរហិ បំសុបិសាចកម្បិ ន បស្សាមិ កុតោ បនាហំ ទិព្វេ-ន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សិស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូ-បគេ សត្តេ បជានិស្សាមិ សេយ្យថាបិ ភគវា យម្បន មំ ភន្តេ ភគវា ឯវមាហ អបិចុទាយិ តិដ្ឋតុ បុព្វន្តោ

---
១ ឱ. អហំ ។



កាលបើទីបំផុតខាងដើមនេះមិនមាន ទីបំផុតខាងចុងនេះក៏មិនមាន ទីបំផុតខាងចុងនេះរលត់ទៅ ព្រោះទីបំផុតខាងដើមនេះរលត់ទៅ ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនអាចរលឹកឃើញបុព្វេនិវាសនោះ តាមកំណត់ដែលខ្ញុំព្រះអង្គត្រាប់ឃើញច្បាស់ដោយអត្ត-ភាពនេះ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះបានទេ ខ្ញុំព្រះអង្គនឹងរលឹកឃើញបុព្វេនិវាសច្រើនប្រការ គឺ រលឹកឃើញជាតិ ១ ជាតិ ២ ជាតិ ៣ ។ បេ ។ នឹងរលឹកឃើញបុព្វេនិវាសមានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ដូចជាព្រះមានព្រះភាគដូចម្ដេចបាន បពិត្រព្រះអង្គដ៏ចំរើន សព្វថ្ងៃនេះ សូម្បីតែបង្សុបិសាច (បិសាចដែលកើតក្នុងទីស្មោកគ្រោក) ក៏ខ្ញុំព្រះអង្គមើលមិនឃើញផង ចុះនឹងឲ្យខ្ញុំព្រះអង្គរលឹកឃើញពួកសត្វដែលច្យុត ដែលកើតថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ។ បេ ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលទៅតាមយថាកម្ម ដោយទិព្វចក្ខុបរិសុទ្ធ កន្លងចក្ខុរបស់មនុស្សសាមញ្ញ ដូចជាព្រះមានព្រះភាគដូចម្ដេចបាន បពិត្រព្រះអង្គដ៏ចំរើន ពាក្យដែលព្រះអង្គបានត្រាស់នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលឧទាយិ ណ្ហើយចុះ ទីបំផុតខាងដើមលើកទុក

តិដ្ឋតុ អបរន្តោ ធម្មន្តេ ទេសេស្សាមិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតីតិ តញ្ច បន មេ ភិយ្យោសោ មត្តាយ ន បក្ខាយតិ អប្បេវ នាម[១] ភន្តេ សកេ អាចរិយកេ ភគវតោ ចិត្តំ អារាធេយ្យំ បញ្ហស្ស វេយ្យាក-រណេនាតិ ។

(១៣៣) កិន្តិ បន តេ ឧទាយិ សកេ អាច-រិយកេ ហោតីតិ ។ អម្ហាកំ ភន្តេ សកេ អាចរិយកេ ឯវំ ហោតិ អយំ បរមោ វណ្ណោ អយំ បរមោ វណ្ណោតិ ។ យម្បនេតំ[២] ឧទាយិ សកេ អាចរិយកេ ឯវំ ហោតិ អយំ បរមោ វណ្ណោ អយំ បរមោ វណ្ណោតិ កតមោ បន[៣] សោ បរមោ វណ្ណោតិ ។ យស្មា ភន្តេ វណ្ណា

១ ឱ. ម. អប្បេវ នាមាហំ ។ ២ ឱ. ឯតំ ។ ៣ បនសទ្ទោ ន ទិស្សតិ ។



ទីបំផុតខាងចុងក៏លើកទុកចុះ តថាគតនឹងសំដែងធម៌ដល់អ្នក កាលបើទីបំផុតខាងដើមនេះមាន ទីបំផុតខាងចុងនេះក៏មាន ទីបំផុតខាងចុងនេះកើតឡើងបាន ព្រោះទីបំផុតខាងដើមនេះកើតឡើង កាលបើទីបំផុតខាងដើមនេះមិនមាន ទីបំផុតខាងចុងនេះក៏មិនមាន ទីបំផុតខាងចុងនេះរលត់ទៅ ព្រោះទីបំផុតខាងដើមនេះរលត់ទៅ ដូច្នេះ ឥឡូវពាក្យនោះមិនទាន់ប្រាកដដល់ខ្ញុំព្រះអង្គ ដោយលើសលន់ពន់ប្រមាណនៅឡើយទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាកដជានឹងធ្វើព្រះហឫទ័យនៃព្រះមានព្រះភាគឲ្យត្រេកអរ ដោយសារការដោះប្រស្នា ក្នុងលទ្ធិអាចារ្យ ជារបស់ខ្លួនបាន ។

(១៣៣) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ហេតុដូចម្តេច ដែលមានក្នុងលទ្ធិអាចារ្យ ជារបស់ខ្លួននៃអ្នក ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ឧត្តម នេះជាពន្លឺដ៏ឧត្តម ។ ព្រះអង្គត្រាស់ថា ការណ៍ដែលអ្នកត្រិះរិះក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ឧត្តម នេះជាពន្លឺដ៏ឧត្តម ចុះពន្លឺដ៏ឧត្តមនោះតើដូចម្តេច ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពន្លឺណាដែល

អញ្ញោ វណ្ណោ ឧក្កដ្ឋតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ ។ កតមោ បន សោ ឧទាយិ វណ្ណោ យស្មា វណ្ណា អញ្ញោ វណ្ណោ ឧក្កដ្ឋតរោ វា បណីតតរោ វា នត្ថីតិ ។ យស្មា ភន្តេ វណ្ណា អញ្ញោ វណ្ណោ ឧក្កដ្ឋតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ ។

(១៣៦) ទីឃាបិ ខោ តេ ឯសា ឧទាយិ ផរេយ្យ យស្មា ភន្តេ វណ្ណា អញ្ញោ វណ្ណោ ឧក្កដ្ឋតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ វទេសិ តញ្ច វណ្ណំ ន បញ្ញបេសិ ។ សេយ្យថាបិ ឧទាយិ បុរិសោ ឯវំ វទេយ្យ អហំ យា ឥមស្មឹ ជនបទេ ជនបទកល្យាណី តំ ឥច្ឆាមិ តំ កាមេមីតិ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ខត្តិយី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតិ(១) ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ

១ ឱ. ម. ខត្តិយី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតិ ។



រកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះជាពន្លឺដ៏ឧត្តម ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ពន្លឺដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន នោះតើដូចម្ដេច ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ពន្លឺណាដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តម ។

(១៣៦) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ពាក្យរបស់អ្នកនុ៎ះផ្សាយទៅវែងពេកណាស់ ព្រោះអ្នកពោលថា ពន្លឺដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តម ដូច្នេះផង តែមិនកំណត់នូវពន្លឺនោះផង ។ ម្នាលឧទាយិ ដូចបុរសនិយាយយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននាងជនបទកល្យាណី ក្នុងជនបទនេះ ។ ពួកអ្នកផងសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកប្រាថ្នាចង់បាននាងជនបទកល្យាណីណា អ្នកស្គាល់នាងជនបទកល្យាណីនោះ ថាជាក្សត្រីឬព្រាហ្មណី ជាវេស្សីឬសុទ្ទីដែរឬ ។ បុរសនោះ ដែលអ្នកផងសួរដូច្នេះ គាត់ឆ្លើយតបវិញថា ខ្ញុំមិនស្គាល់ទេ ។ អ្នកផងសួរបុរសនោះទៀតថា នែបុរសដ៏ចំរើន អ្នកប្រាថ្នាចង់បាននាងជនបទកល្យាណីណា

កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ឯវំវណ្ណា(១) ឯវំគោត្តា ឥតិ វាតិ ។បេ។ ទីឃា វា រស្សា វា មជ្ឈិមា វា កាឡី វា សាមា វា មង្គុរច្ឆវី វាតិ អមុកស្មិំ ឆាម(២) គាមេ វា និគមេ វា នគរេ វាតិ ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តំ ត្វំ ឥច្ឆសិ កាមេសីតិ ។ ឥតិ បុដ្ឋោ អាមាតិ វទេយ្យ ។ តំ កឹ មញ្ញសិ ឧទាយិ ននុ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហីរកតំ ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហីរកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ ត្វំ ឧទាយិ យស្មា ភន្តេ វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ វទេសិ តញ្ច វណ្ណំ ន បញ្ញាបេសីតិ ។

១ ម. ឯវំនាមា ។ ២ ឱ. ម. ឆាមកំ ឆវិស្សតិ ។



អ្នកស្គាល់នាងជនបទកល្យាណីនោះថា មានជាតិយ៉ាងនេះ មានគោត្រយ៉ាងនេះ ។បេ។ ខ្ពស់ឬទាប ឬកណ្ដាល សម្បុរខ្មៅ ឬខ្មៅស្រអែម ឬសម្បុរសៅល្អកញាយ នៅក្នុងស្រុក និគម និងនគរឯណោះដែរឬទេ ។ បុរសនោះដែលគេសួរដូច្នេះ ក៏ឆ្លើយតបថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា នែបុរសដ៏ចំរើន អ្នកមិនដែលស្គាល់ មិនដែលឃើញនាងជនបទកល្យាណីណានោះ ហើយស្រលាញ់ត្រូវចិត្តចង់បាននាងនោះឬ ។ បុរសនោះដែលអ្នកផងសួរដូច្នេះ ក៏ឆ្លើយតបថា បាទ ។ ម្នាលឧទាយិ អ្នកយល់សេចក្ដីនោះដូចម្ដេច កាលបើយ៉ាងនេះ ពាក្យរបស់បុរសនោះ ក្រែងយកជាការមិនបានទេដឹង ។ សកុលុទាយិក្រាបបង្គំទូលថា ពិតមែនហើយព្រះអង្គ កាលបើយ៉ាងនេះ ពាក្យរបស់បុរសនោះយកជាការពុំបានទេ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកនិយាយថា បពិត្រព្រះអង្គដ៏ចំរើន ពន្លឺណាដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តម ដូច្នេះផង តាំងមិនកំណត់នូវពន្លឺនោះផង គឺយ៉ាងនោះឯង ។

សេយ្យថាបិ ភន្តេ មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ បណ្ឌុកម្ពលេ និក្ខិត្តោ ភាសតេ តបតេ វិរោចតេ[១] ឯវំវណ្ណោ អត្តា ហោតិ អរោគោ បរម្មរណាតិ ។

(១៣៨) តំ កិំ មញ្ញសិ ឧទាយិ យោ វា មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ បណ្ឌុកម្ពលេ និក្ខិត្តោ ភាសតេ តបតេ វិរោចតេ យោ វា រត្តន្ធការតិមិសាយ កិមិខជ្ជោបនកោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភន្តេ រត្តន្ធការតិមិសាយ កិមិខជ្ជោបនកោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៣៩) តំ កិំ មញ្ញសិ ឧទាយិ យោ វា រត្តន្ធការតិមិសាយ កិមិខជ្ជោបនកោ យោ វា រត្តន្ធការតិមិសាយ តេលប្បទីបោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច

១ ម. ភាសតិ ច តបតិ ច វិរោចតិ ច ។



សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កែវមណីទឹកកែវពៃទូរ្យ មានពន្លឺល្អ មានជ្រុង ៨ ដែលជាងនិម្មិតល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺព្រាលរន្ទាល យ៉ាងណា អត្តាបន្ទាប់អំពីមរណៈទៅ ក៏មានពន្លឺ ឥតមានរោគ យ៉ាងនោះដែរ ។

(១៣៨) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ពិតសេចក្តីនោះដូចម្តេច កែវមណីទឹកកែវពៃទូរ្យ ដែលមានពន្លឺល្អ មានជ្រុង ៨ ដែលជាងនិម្មិតល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺព្រាលរន្ទាល ចំណែកអម្ពិលអម្ពែកដែលជាកិមិជាតិ ក្នុងវេលាយប់ងងឹតអព្ទ បណ្តាពន្លឺទាំងពីរនេះ តើពន្លឺណា ភ្លឺជាងប្រសើរជាង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលាយប់ងងឹតអព្ទ បណ្តាពន្លឺទាំងពីរនេះ ពន្លឺអម្ពិលអម្ពែកដែលជាកិមិជាតិ ភ្លឺជាង ប្រសើរជាង ។

(១៣៩) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ពិតសេចក្តីនោះដូចម្តេច អម្ពិលអម្ពែកដែលជាកិមិជាតិ ក្នុងវេលាយប់ងងឹតអព្ទ ចំណែកប្រទីបប្រេងក្នុងវេលាយប់ងងឹតអព្ទ បណ្តាពន្លឺទាំងពីរនេះ ពន្លឺណា ភ្លឺជាង

បណីតតរោ ចាតិ ។ យ្វាយំ ភន្តេ រត្តន្ធការតិមិសាយ តេលប្បទីបោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៣៧) តំ កឹ មញ្ញសិ ឧទាយិ យោ វា រត្តន្ធការតិមិសាយ តេលប្បទីបោ យោ វា រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភន្តេ រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៣៨) តំ កឹ មញ្ញសិ ឧទាយិ យោ វា រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ យា វា រត្តិយា បច្ចូសសមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា



ប្រសើរជាង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលាយប់ងងឹតអន្ធ បណ្ដាពន្លឺទាំងពីរនេះ ប្រទីបប្រេងភ្លឺជាង ប្រសើរជាង ។

(១៣៧) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ចិត្តសេចក្ដីនោះដូចម្ដេច ប្រទីបប្រេង ក្នុងវេលាយប់ងងឹតអន្ធ និងគំនរភ្លើងធំក្នុងវេលាយប់ងងឹតអន្ធ បណ្ដាពន្លឺទាំងពីរនេះ ពន្លឺណាភ្លឺជាង ប្រសើរជាង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងវេលាយប់ងងឹតអន្ធ បណ្ដាពន្លឺទាំងពីរនេះ ពន្លឺគំនរភ្លើងធំ ភ្លឺជាង ប្រសើរជាង ។

(១៣៨) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ចិត្តសេចក្ដីនោះដូចម្ដេច គំនរភ្លើង ក្នុងវេលាយប់ងងឹតអន្ធ និងផ្កាយព្រឹកក្នុងកាលដែលមេឃស្ងាត់ភ្លៀង ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រី

ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យាយំ ភន្តេ រត្តិយា បច្ចូស-សមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៣៨) តំ កិំ មញ្ញសិ ឧទាយិ យា វា រត្តិយា បច្ចូសសមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា យោ វា តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ (១) អឌ្ឍរត្តសមយំ ចន្ទោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភន្តេ តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ អឌ្ឍរត្តសមយំ ចន្ទោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

១ ម. ចន្ទុបោសថេសុ អភិទោគត្តំ ទិស្សតិ ។



បណ្តាពន្លឺទាំងពីរនេះ ពន្លឺណា ភ្លឺផង ប្រសើរផង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បណ្តាពន្លឺទាំងពីរនេះ ពន្លឺផ្កាយព្រឹកក្នុងកាលដែលមេឃស្វាងភ្លឺ ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រីនេះ ភ្លឺផង ប្រសើរផង ។

(១៣៨) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ចិត្តសេចក្តីនោះដូចម្តេច ផ្កាយព្រឹកក្នុងកាលដែលមេឃស្វាងភ្លឺ ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រី នឹងព្រះចន្ទ្រក្នុងវេលាពាក់កណ្តាលអធ្រាត្រមិនតាន់ប្រែ ក្នុងកាលដែលមេឃស្វាងភ្លឺ ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត បណ្តាពន្លឺទាំងពីរនេះ ពន្លឺណាភ្លឺផង ប្រសើរផង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បណ្តាពន្លឺទាំងពីរនេះ ពន្លឺព្រះចន្ទ្រ ក្នុងវេលាពាក់កណ្តាលអធ្រាត្រ មិនតាន់ប្រែ ក្នុងកាលដែលមេឃស្វាងភ្លឺ ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត នេះភ្លឺផង ប្រសើរផង ។

(១៤០) តំ កឹ មញ្ញសិ ឧទាយិ យោ វា តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ អឌ្ឍរត្តសមយំ ចន្ទោ យោ វា វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ មជ្ឈន្តិកសមយំ សុរិយោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភន្តេ វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ មជ្ឈន្តិកសមយំ សុរិយោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ តតោ ខោ(១) តេ ឧទាយិ ពហូ ហិ ពហុតរា ទេវា យេ ឥមេសំ ចន្ទិមសុរិយានំ អាភា នានុភោន្តិ ត្យាហំ បជានាមិ អថ ច បនាហំ ន វទាមិ យស្មា វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថីតិ អថ ច បន ត្វំ ឧទាយិ យ្វាយំ វណ្ណោ កីដេន ខជ្ជោបនកេន និហីនតរោ ច បតិកិដ្ឋតរោ ច(២) សោ បរមោ វណ្ណោតិ វទេសិ

១ ម. អតោ ខោ ចិ តស្ស ។ ២ ម. ហីនតរោ ច បតិកិដ្ឋតរោ ច ។



(១៤០) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់សេចក្តីនោះដូចម្តេច ព្រះចន្ទក្នុងវេលាពាក់កណ្តាលអធ្រាត្រ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្ងាត់ភ្លៀង ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត នឹងព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្ងាត់ភ្លៀង ខ្ពស់ស្រឡះអំពីពពកក្នុងសរទសម័យ នាខែខាងចុងនៃវស្សានរដូវ បណ្តាពន្លឺទាំងពីរនេះ ពន្លឺណាក្លាជាង ប្រសើរជាង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន បណ្តាពន្លឺទាំងពីរនោះ ពន្លឺព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្ងាត់ភ្លៀង ខ្ពស់ស្រឡះអំពីពពកក្នុងសរទសម័យ នាខែជាខាងចុងនៃវស្សានរដូវ ពន្លឺនេះក្លាជាង ប្រសើរជាង ។ ម្នាលឧទាយិ ពួកទេវតា ដែលមិនបាច់ប្រើពន្លឺព្រះចន្ទនឹងព្រះអាទិត្យនេះ មានច្រើនក្រៃលែងច្រើន តថាគតក៏ស្គាល់ច្បាស់នូវទេវតាទាំងនោះដែរ តែតថាគតមិនពោលថា ពន្លឺណាដទៃមានពន្លឺដទៃ ប្រសើរជាង ឧត្តមជាង ដូច្នេះទេ ម្នាលឧទាយិ ចំណែកខាងអ្នកឯង ពោលថា ពន្លឺណាដែលថោកទាបជាង អន់ជាង ពន្លឺអំពិលអំពែក ជាតិកិមិជាតិ ពន្លឺនោះជាពន្លឺប្រសើរ

តញ្ច វណ្ណំ ន បញ្ញាបេសីតិ ។ អច្ឆិទិ(១) ភគវា កថំ អច្ឆិទិ សុគត(២) កថន្តិ ។ កឹ បន ត្វំ ឧទាយិ ឯវំ វទេសិ អច្ឆិទិ ភគវា កថំ អច្ឆិទិ សុគត កថន្តិ ។ អម្ហាកំ ភន្តេ សកេ អាចរិយកេ ឯវំ ហោតិ អយំ បរមោ វណ្ណោ អយំ បរមោ វណ្ណោតិ ។ តេ មយំ ភន្តេ ភគវតា សកេ អាចរិយកេ សមនុយុញ្ជិយមានា សមនុគ្គាហិយមានា សមនុភាសិយមានា រិត្តា តុច្ឆា អបរទ្ធាតិ ។

[១៤១] កឹ បនុទាយិ អត្ថិ ឯកន្តសុខោ លោកោ អត្ថិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ អម្ហាកំ ភន្តេ សកេ អាចរិយកេ ឯវំ ហោតិ អត្ថិ ឯកន្តសុខោ លោកោ

១ អច្ឆិទ្ទំ អច្ឆិទ្ទិ ឯតេ ទិស្សន្តិ ។ ២ ឱ. ម. សុគតោ ។



ដូច្នេះផង តែមិនបានកំណត់ពន្លឺនោះផង ។ បពិត្រព្រះមានព្រះភាគ សូមទ្រង់ស្ងៀមពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់ស្ងៀមពាក្យនេះទុកចុះ ។ ម្នាលឧទាយិ ម្តេចក៏អ្នកឯងនិយាយថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ស្ងៀមពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់ស្ងៀមពាក្យនេះទុកចុះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ប្រសើរ នេះជាពន្លឺដ៏ប្រសើរ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ កាលបើព្រះមានព្រះភាគសាកសួរ ដេញដោល ក្នុងលទ្ធិអាចារ្យជារបស់ខ្លួន (យ៉ាងនេះ) ក៏ជាបុគ្គលសោះសូន្យ ទទេ ឥតបានការសោះ ។

[១៤១] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ លោកមានសេចក្តីសុខដោយចំណែកមួយ ចុះបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានសេចក្តីសុខ ដោយចំណែកមួយ មានដែរឬទេ ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានតែសេចក្តីសុខដោយចំណែក

អត្ថិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ កតមា បន សា ឧទាយិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ ឥធ ភន្តេ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារំ បហាយ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ អញ្ញតរំ វា បន តបោគុណំ សមាទាយ វត្តតិ អយំ ខោ សា ភន្តេ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។

(១៤២) តំ កឹ មញ្ញសិ ឧទាយិ យស្មឹ សមយេ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ ឯកន្តសុខី វា តស្មឹ សមយេ អត្តា ហោតិ សុខទុក្ខី វាតិ ។ សុខទុក្ខី ភន្តេតិ (១) ។ តំ កឹ មញ្ញសិ ឧទាយិ

១ ឱ. ម. ផលិសន្តេ ត្តិ ។



មួយក៏មាន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខ ដោយចំណែកមួយក៏មាន ។ ម្នាលឧទាយិ ចុះបដិបទា ប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខដោយចំណែកមួយ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកមួយ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត លះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន លះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ មួយទៀត បានប្រព្រឹត្តសមាទាននូវតបៈ-គុណណាមួយ បពិត្រព្រះអង្គដ៏ចំរើន នេះហៅថា បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខដោយចំណែកមួយ ។

(១៤២) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកយល់ចិត្តសេចក្តីនោះដូចម្តេច (បើ)បុគ្គលលះបង់បាណាតិបាត វៀរស្រឡះចាកបាណា-តិបាត ក្នុងសម័យណា សម័យនោះតើ អត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ សកុលុទាយិ ក្រាបបង្គំទូលថា មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកយល់ចិត្តសេចក្តី

យស្មឹ សមយេ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ឯកន្តសុខី វា តស្មឹ សមយេ អត្តា ហោតិ សុខទុក្ខី វាតិ ។ សុខទុក្ខី ភន្តេតិ ។ តំ កឹ មញ្ញសិ ឧទាយិ យស្មឹ សមយេ កាមេសុមិច្ឆាចារំ បហាយ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ ឯកន្តសុខី វា តស្មឹ សមយេ អត្តា ហោតិ សុខទុក្ខី វាតិ ។ សុខទុក្ខី ភន្តេតិ ។ តំ កឹ មញ្ញសិ ឧទាយិ យស្មឹ សមយេ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ ឯកន្តសុខី វា តស្មឹ សមយេ អត្តា ហោតិ សុខទុក្ខី វាតិ ។ សុខទុក្ខី ភន្តេតិ ។ តំ កឹ មញ្ញសិ ឧទាយិ យស្មឹ សមយេ អញ្ញតរំ តបោគុណំ សមាទាយ វត្តតិ ឯកន្តសុខី វា តស្មឹ សមយេ អត្តា ហោតិ សុខទុក្ខី វាតិ ។ សុខទុក្ខី ភន្តេតិ ។ តំ កឹ មញ្ញសិ ឧទាយិ អបិ នុ ខោ វោកិណ្ណសុខទុក្ខំ បដិបទំ អាគម្ម ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយា ហោតីតិ(១) ។

១ ម. សច្ឆិកិរិយាយាតិ ។



នោះដូចម្តេច (បើ) បុគ្គលលះបង់អទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច (បើ) បុគ្គលលះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច (បើ) បុគ្គលលះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច (បើ) បុគ្គលសមាទានប្រព្រឹត្តតបគុណណាមួយ ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះ ដូចម្តេច ការធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានតែសេចក្តីសុខដោយចំណែកមួយ ព្រោះអាស្រ័យបដិបទា ដែលមានសុខនិងទុក្ខលាយឡំគ្នា បានដែរឬ ។

អច្ឆិនំ ភគវា កថំ អច្ឆិនំ សុគត កថន្តិ ។ កឹ បន ត្វំ ឧទាយិ ឯវំ វទេសិ អច្ឆិនំ ភគវា កថំ អច្ឆិនំ សុគត កថន្តិ ។ អម្ហាកំ ភន្តេ សកេ អាចរិយកេ ឯវំ ហោតិ អត្ថិ ឯកន្តសុខោ លោកោ អត្ថិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ តេ មយំ ភន្តេ ភគវតា សកេ អាចរិយកេ សមនុយុញ្ជិយមានា សមនុគ្គាហិយមានា សមនុភាសិយមានា រិត្តា តុច្ឆា អបរទ្ធាបិ កឹ បន ភន្តេ អត្ថិ ឯកន្តសុខោ លោកោ អត្ថិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ អត្ថិ ខោ ឧទាយិ



បពិត្រព្រះមានព្រះភាគ សូមទ្រង់លើកពាក្យនេះទុក បពិត្រព្រះសុគត សូមទ្រង់លើកពាក្យនេះទុក ។ ម្នាលឧទាយិ ម្តេចក៏អ្នកនិយាយថា បពិត្រព្រះមានព្រះភាគ សូមទ្រង់លើកពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់លើកពាក្យនេះទុកចុះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា លោកដែលមានសេចក្តីសុខ ដោយចំណែកមួយក៏មាន បដិបទាដែលប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះកាលបើព្រះមានព្រះភាគសាកសួរ ដេញដោលក្នុងលទ្ធិអាចារ្យជារបស់ខ្លួន (យ៉ាងនេះ) ក៏ជាបុគ្គលសោះសូន្យទទេ មិនបានការសោះ បពិត្រព្រះអង្គដ៏ចំរើន ចុះលោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយ បដិបទាដែលប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយមានដែរឬ ។ ម្នាលឧទាយិ

ឯកន្តសុខោ លោកោ អត្ថិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ កតមា បន សា ភន្តេ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។

[១៤៣] ឥធុទាយិ ភិក្ខុ វិវិច្ចេវ កាមេហិ ។បេ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។បេ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។បេ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ ខោ សា ឧទាយិ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។ កិន្នុ ខោ[១] សា ភន្តេ អាការវតី បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយ សច្ឆិកតោ ហិស្ស ភន្តេ ឯត្តាវតា ឯកន្តសុខោ លោកោ ហោតីតិ ។ ន ខ្វស្ស ឧទាយិ ឯត្តាវតា ឯកន្តសុខោ លោកោ

១ ម. ន ខោ ។



លោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយក៏មាន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ចុះបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ តើដូចម្តេច ។

(១៤៣) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលបឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ចូលទុតិយជ្ឈាន ក៏សម្រេចនៅដោយឥរិយាបថតាំង ៤ ព្រោះប្រាសចាកបីតិ ។បេ។ ចូលតតិយជ្ឈាន សម្រេចនៅ ដោយឥរិយាបថតាំង ៤ ម្នាលឧទាយិ នេះឯងហៅថា បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខ ដោយចំណែកមួយ ។ បពិត្រព្រះអង្គដ៏ចំរើន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ តើដូចម្តេច បពិត្រព្រះអង្គដ៏ចំរើន ចុះលោកមានតែសេចក្តីសុខ ដោយចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ តើមានតែប៉ុណ្ណេះឬ ។ ម្នាលឧទាយិ លោកមានតែសេចក្តីសុខដោយ

សច្ឆិកតោ ហោតិ អាការវតី នុ ខោ សា បដិបទា ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាយាតិ ។

[១៦៦] ឯវំ វុត្តេ សកុលុទាយិស្ស បរិព្វាជកស្ស បរិសា ឧន្នាទិនី ឧច្ចាសទ្ទមហាសទ្ទា[១] អហោសិ[២] ឯត្ថ មយំ អនស្សាម សាចរិយកា ឯត្ថ មយំ អនស្សាម សាចរិយកា ន មយំ ឥតោ ភិយ្យោ ឧត្តរិតរំ បជានាមាតិ ។ អថ ខោ សកុលុទាយិ បរិព្វាជកោ តេ បរិព្វាជកេ អប្បសទ្ទេ កត្វា ភគវន្តំ ឯតទវោច កិត្តាវតា បនស្ស ភន្តេ ឯកន្តសុខោ លោកោ សច្ឆិកតោ ហោតីតិ ។

[១៦៧] ឥធុទាយិ ភិក្ខុ សុខស្ស ច បហាណា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ យា តា ទេវតា ឯកន្តសុខំ លោកំ ឧបបន្នា តាហិ ទេវតាហិ សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ

១. ឧច្ចាសទ្ទា មហាសទ្ទា ។ ២. អហេសុំ ។



ចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ទាំងបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវលោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយនោះ ក៏មិនមានត្រឹមតែប៉ុណ្ណោះដែរទេ ។

(១៦៦) កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ ពួកបរិស័ទរបស់សកុលុទាយិបរិព្វាជក ក៏បន្លឺសំឡេងខ្ពស់ សំឡេងខ្លាំងថា ពួកយើងព្រមទាំងអាចារ្យ មិនគាប់ពេញចិត្តក្នុងហេតុនេះទេ ពួកយើងព្រមទាំងអាចារ្យមិនគាប់ពេញចិត្តក្នុងហេតុនេះទេ ពួកយើងមិនគាប់ដឹងច្បាស់នូវគុណជាតដ៏ក្រៃលែងជាងនេះទៅទៀតឡើយ ។ ខណៈនោះ សកុលុទាយិបរិព្វាជក ធ្វើពួកបរិព្វាជកទាំងនោះ ឲ្យមានសំឡេងតិច ហើយក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ចុះលោកមានតែសេចក្តីសុខដោយចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ តើមានប៉ុន្មាន ។

(១៦៧) ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខ ។ បេ ។ ចូលចតុត្ថជ្ឈាន ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ទេវតាទាំងប៉ុន្មាន បានកើតក្នុងលោកដែលមានតែសេចក្តីសុខដោយចំណែកមួយ ភិក្ខុនោះរមែងឋិតនៅ រមែងចរចា រមែងសាកច្ឆា មួយអន្លើដោយទេវតា

ឯត្តាវតា ខ្វស្ស ឧទាយិ ឯកន្តសុខោ លោកោ សច្ឆិកតោ ហោតីតិ ។ ឯតស្ស ខ្វន ភន្តេ ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាហេតុ ភិក្ខូ ភគវតិ ព្រហ្មចរិយំ ចរន្តីតិ ។ ន ខោ ឧទាយិ ឯតស្ស ឯកន្តសុខស្ស លោកស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ អត្ថិ ខោ ឧទាយិ អញ្ញេវ ធម្មា ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តីតិ ។ កតមេ បន តេ ភន្តេ ធម្មា ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ ភគវតិ ព្រហ្មចរិយំ ចរន្តីតិ ។

(១៤៦) ឥធុទាយិ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា



ត្រឹមប៉ុណ្ណោះ ម្នាលឧទាយិ លោកមានតែសេចក្តីសុខដោយចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់មានតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់របស់ព្រះមានព្រះភាគ ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ តែប៉ុណ្ណោះទេឬ ។ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត មិនមែនព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខ ដោយចំណែកមួយនុះទេ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវពួកធម៌ដទៃ ដែលប្រសើរជាង ឧត្តមជាងនោះទៀត ។ បពិត្រព្រះអង្គដ៏ចំរើន ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង នោះតើដូចម្តេច ។

(១៤៦) ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ព្រះតថាគតទ្រង់កើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយគុណ រកបុគ្គលស្មើគ្មាន ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្តា

ទេវមនុស្សានំ ពុទ្ធោ ភគវា ។ បេ ។ សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ អយម្បិ ខោ ឧទាយិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។ បុន ចបរំ ឧទាយិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយម្បិ ខោ ឧទាយិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។

(២៤៧) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញាណាយ ចិត្តំ អភិនិន្នាមេតិ សោ



របស់ទេវតា នឹងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច មិនវិលត្រឡប់មកកាន់ភពថ្មីទៀត ។ បេ ។ ព្រះអង្គលះបង់នូវនីវរណធម៌ទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ទ្រង់ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ចូលបឋមជ្ឈាន ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង នេះឯង ។ ម្នាលឧទាយិ ន័យមួយទៀត ព្រោះរម្ងាប់វិតក្កៈនឹងវិចារៈ ។ បេ ។ ចូលទុតិយជ្ឈាន... តតិយជ្ឈាន... ចតុត្ថជ្ឈាន ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលប្រសើរជាង ឧត្តមជាង នេះឯង ។

(២៤៧) កាលបើចិត្តតម្កល់នឹង ជាចិត្តបរិសុទ្ធផូរផង់ ឥតមានទីទួលគោលនៃកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះវែងបង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរំលឹក

អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ អយម្បិ ខោ ឧទាយិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ អយម្បិ ខោ ឧទាយិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ



ឃើញនូវបុព្វេនិវាស មានច្រើនប្រការ គឺជាតិ ១ ជាតិ ២ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាសមានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលប្រសើរជាង ខ្ពង់ជាង នេះឯង ។ កាលបើចិត្ត (របស់ភិក្ខុនោះ) តម្កល់នៅល្អ ជាចិត្តបរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារ ជាចិត្តនឹងធឹង ដល់នូវភាពមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្ត ដើម្បីចុតូបបាតញ្ញាណនៃសត្វទាំងឡាយ ភិក្ខុនោះរមែងមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ ភិក្ខុនោះរមែងឃើញពួកសត្វដែលទៅតាមយថាកម្ម ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ខ្ពង់ជាង នេះឯង ។ កាលបើចិត្ត (របស់ភិក្ខុនោះ) តម្កល់នៅនឹង ជាចិត្តបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់

កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ ។ បេ ។ អយំ ទុក្ខនិរោធោតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ ។ បេ ។ អយំ អាសវនិរោធោតិ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ(១) ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ អយំ ខោ ឧទាយិ ធម្មោ ឧត្តរិតរោ ច បណីតតរោ ច យស្ស សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តិ ។ ឥមេ ខោ ឧទាយិ ធម្មា ឧត្តរិតរា ច បណីតតរា ច យេសំ សច្ឆិកិរិយាហេតុ ភិក្ខូ មយិ ព្រហ្មចរិយំ ចរន្តីតិ ។

---

១ ម. វិមុត្តម្ហីតិ ។



គួរដល់ការនៃកម្ម ជាចិត្តនឹងធឹង ដល់នូវភាពមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាអាសវៈ ។ បេ ។ នេះជាហេតុឲ្យកើតអាសវៈ ។ បេ ។ នេះជាទីរលត់អាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់អាសវៈ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរមែងរួចស្រឡះចាកកាមាសវៈ ចិត្តរមែងរួចស្រឡះចាកភវាសវៈ ចិត្តរមែងរួចស្រឡះចាកអវិជ្ជាសវៈ កាលបើចិត្តរួចស្រឡះហើយ ក៏មានសេចក្តីដឹងថា ចិត្តរួចស្រឡះហើយ ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅរួចហើយ សោឡសកិច្ចក៏អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង នេះឯង ។ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង ទាំងនេះឯង ។

(១៤៨) ឯវំ វុត្តេ សកុលុទាយិ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ(១) ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។

(១៤៩) ឯវំ វុត្តេ សកុលុទាយិស្ស បរិព្វាជកស្ស បរិសា សកុលុទាយឹ បរិព្វាជកំ ឯតទវោច(២)

១ ម. ឯវមេវ ។ ២ ម. ឯតទវោច ។



(១៤៨) កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ សកុលុទាយិបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ភ្លឺណាស់ បពិត្រព្រះអង្គដ៏ចំរើន ភ្លឺណាស់ ព្រោះថា ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយនេះឯង ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ឬដូចជាបុគ្គលប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកនឹងមើលឃើញនូវរូបបាន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។

(១៤៩) កាលសកុលុទាយិបរិព្វាជក និយាយយ៉ាងនេះហើយ បរិស័ទរបស់សកុលុទាយិបរិព្វាជក ក៏និយាយនឹងសកុលុទាយិបរិព្វាជក

មា កិំ ឧទាយិ សមណោ គោតមេ ព្រហ្មចរិយំ ចរិ មា កិំ ឧទាយិ អាចរិយោ ហុត្វា អន្តេវាសិកំ វសិ សេយ្យថាបិ នាម ឧទកមណិកោ(១) ហុត្វា ឧទញ្ចនិកោ អស្ស ឯវំ សម្បទមិទំ(២) ហោតោ ឧទាយិស្ស ករិស្សតិ មា កិំ ឧទាយិ សមណោ គោតមេ ព្រហ្មចរិយំ ចរិ មា កិំ ឧទាយិ អាចរិយោ ហុត្វា អន្តេវាសិកំ វសីតិ ។ ឥតិ ហិទំ សកុលុទាយិស្ស បរិព្វាជកស្ស បរិសា សកុលុទាយិំ បរិព្វាជកំ អន្តរាយមកាសិ ភគវតិ ព្រហ្មចរិយេតិ ។

ចូឡសកុលុទាយិសុត្តំ នវមំ និដ្ឋិតំ ។

---

១ ម. ម. មណិកោ ។ ២ ម. សម្បទមេតំ ។



ដូច្នេះថា បពិត្រលោកឧទាយិដ៏ចំរើន លោកកុំប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម សូមលោកឧទាយិដ៏ចំរើននៅជាអាចារ្យ កុំជាអន្តេវាសិកគេឡើយ ឱ្យដូចជាក្អមទឹកនៅពេញដោយទឹកដែល សូមលោកឧទាយិដ៏ចំរើន កុំប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម សូមលោកឧទាយិដ៏ចំរើន នៅជាអាចារ្យដដែល កុំជាអន្តេវាសិកគេឡើយ ។ បរិស័ទរបស់សកុលុទាយិបរិព្វាជក ធ្វើសេចក្តីអន្តរាយ យ៉ាងនេះ ដល់សកុលុទាយិបរិព្វាជក ក្នុងការប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចូឡសកុលុទាយិសូត្រ ទី ៩ ។

## ទសមំ វេខណសសុត្តំ[១]

[១៨០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ វេខណសោ បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។

[១៨១] ឯកមន្តំ ឋិតោ ខោ វេខណសោ បរិព្វាជកោ ភគវតោ សន្តិកេ ឧទានំ ឧទានេសិ អយំ បរមោ វណ្ណោ អយំ បរមោ វណ្ណោតិ ។ កឹ បន ត្វំ កច្ចាន ឯវំ វទេសិ អយំ បរមោ វណ្ណោ អយំ បរមោ វណ្ណោតិ កតមោ បរមោ វណ្ណោតិ ។ យស្មា ភោ គោតម វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ ។

១ ម. វេខនស្សសុត្តំ ។ ឱ. វេខនសសុត្តំ ។

## វេខណសសូត្រ ទី ១០

[១៨០] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង វេខណសបរិព្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

[១៨១] លុះវេខណសបរិព្វាជក ឋិតនៅក្នុងទីសមគួរហើយ ក៏បន្លឺឧទាន ក្នុងសំណាក់ព្រះមានព្រះភាគថា ពណ៌នេះថ្លៃថ្លាណាស់ ពណ៌នេះថ្លៃថ្លាណាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលកច្ចានៈ[១] ចុះហេតុអ្វីបានជាអ្នកនិយាយយ៉ាងនេះថា ពណ៌នេះថ្លៃថ្លាណាស់ ពណ៌នេះថ្លៃថ្លាណាស់ ចុះពណ៌ដូចម្តេច ដែលថ្លៃថ្លា ។ វេខណសបរិព្វាជក ក្រាបទូលថា បពិត្រព្រះគោតមដ៏ចំរើន ពណ៌ណាដែលរកពណ៌ឯទៀត ក្រៃលើសលុបជាង ឬប្រសើរជាងគ្មាន ពណ៌នោះឈ្មោះថា ពណ៌ថ្លៃថ្លា ។

១ ហៅតាមគោត្ររបស់បរិព្វាជកនោះ ។ កច្ចានៈ ប្រែថា ជនជាពូជពង្សនៃកច្ចានគោត្រ ។

កតមោ សោ(១) កច្ចាន វណ្ណោ យស្មា វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថីតិ ។ យស្មា ភោ គោតម វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ ។

(១៩៦) ទីឃាបិ ខោ តេ ឯសា កច្ចាន ផរេយ្យ យស្មា ភោ គោតម វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ វទេសិ តញ្ច វណ្ណំ ន បញ្ញាបេសិ ។ សេយ្យថាបិ កច្ចាន បុរិសោ ឯវំ វទេយ្យ អហំ យា ឥមស្មឹ ជនបទេ ជនបទកល្យាណី តំ ឥច្ឆាមិ តំ កាមេមីតិ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ តំ ជនបទកល្យាណឹ ខត្តិយី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតិ(២) ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ជនបទកល្យាណឹ ឥច្ឆសិ កាមេសិ ជានាសិ

១ ឱ. ម. កតមោ បន សោ ។ ២ ឱ. ម. ខត្តិយី វា ព្រាហ្មណី វា វេស្សី វា សុទ្ទី វាតីតិ ទិស្សន្តិ ។



ព្រះអង្គត្រាស់សួរថា ម្នាលកច្ចានៈ ចុះពន្លឺដែលគេពន្លឺឯទៀតក្តីលើសលុបជាងឬប្រសើរជាងគ្មាន ពន្លឺនោះតើដូចម្តេច ។ វេខណសបរិព្វាជក ក្រាបទូលថា បពិត្រព្រះគោតមដ៏ចំរើន ពន្លឺណាដែលគេពន្លឺឯទៀតក្តី លើសលុបជាងឬប្រសើរជាងគ្មាន ពន្លឺនោះឯងឈ្មោះថាពន្លឺថ្លៃថ្លា ។

[១៩៦] ម្នាលកច្ចានៈ ពាក្យរបស់អ្នកនុ៎ះ ផ្សាយទៅវែង(១) ណាស់ ព្រោះអ្នកនិយាយថា បពិត្រព្រះគោតមដ៏ចំរើន ពន្លឺណាដែល គេពន្លឺឯទៀតក្តីលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះឯងឈ្មោះថា ពន្លឺថ្លៃថ្លា ដូច្នេះផង តែមិនកំណត់នូវពន្លឺនោះផង ។ ម្នាលកច្ចានៈ ដូច បុរសនិយាយយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននាងជនបទកល្យាណី (ដែល នៅ) ក្នុងជនបទនេះ ។ ជនទាំងឡាយក៏សួរបុរសនោះយ៉ាងនេះថា នែ បុរសចំរើន អ្នកប្រាថ្នាចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់ នាងជនបទកល្យាណីនោះថា ជាស្ត្រីក្សត្រិយ៍ ឬព្រាហ្មណ៍ ជាស្ត្រីវេស្សៈ ឬសុទ្ទៈដែរឬទេ ។ បុរសនោះ លុះមានគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយក៏សួរបុរសនោះយ៉ាងនេះថា នែបុរស ដ៏ចំរើន អ្នកប្រាថ្នាចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់

១ ក្នុងអដ្ឋកថា ពន្យល់ថា កាលបើនិយាយបែបនេះ អស់ ១ រយឆ្នាំក្តី ១ ពាន់ឆ្នាំក្តី ក៏គេ ប្រយោជន៍គ្មាន ។

តំ ជនបទកល្យាណឹ ឯវំវណ្ណា ឯវំគោត្តា ឥតិ វាតិ ។ បេ ។ ទីឃា វា រស្សា វា មជ្ឈិមា វា កាឡី វា សាមា វា មង្គុរច្ឆវី វាតិ អមុកស្មិំ នាម(១) គាមេ វា និគមេ វា នគរេ វាតិ ។ ឥតិ បុដ្ឋោ នោតិ វទេយ្យ ។ តមេនំ ឯវំ វទេយ្យុំ អម្ភោ បុរិស យំ ត្វំ ន ជានាសិ ន បស្សសិ តំ ត្វំ ឥច្ឆសិ កាមេសីតិ ។ ឥតិ បុដ្ឋោ អាមាតិ វទេយ្យ ។ តំ កឹ មញ្ញសិ កច្ចាន ននុ ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហីរកតំ(២) ភាសិតំ សម្បជ្ជតីតិ ។ អទ្ធា ខោ ភោ គោតម ឯវំ សន្តេ តស្ស បុរិសស្ស អប្បាដិហីរកតំ ភាសិតំ សម្បជ្ជតីតិ ។ ឯវមេវ ខោ ត្វំ កច្ចាន យស្មា ភោ គោតម វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា បណីតតរោ វា នត្ថិ សោ បរមោ វណ្ណោតិ វទេសិ តញ្ច វណ្ណំ ន បញ្ញាបេសីតិ ។ សេយ្យថាបិ ភោ គោតម មណិ វេឡុរិយោ សុភោ ជាតិមា

១ ម. ឱ. [illegible] ។ ២ ម. ម. អប្បដិហីរកំ ។



នាងជនបទកល្យាណីនោះថា មានសម្បុរយ៉ាងនេះ មានគោត្រយ៉ាងនេះ ។ បេ ។ ជាស្រីខ្ពស់ឬទាប ឬក៏កណ្ដាល ជាស្រីសម្បុរខ្មៅឬខ្មៅស្រអែម ឬក៏ខ្មៅស្រស់ (ខៅ) ក្នុងស្រុក ឬនិគម ឬក៏នគរឯណោះ ដូច្នេះដែរឬទេ ។ បុរសនោះលុះគេសួរដូច្នេះហើយ ក៏ប្រាប់ថា ខ្ញុំមិនស្គាល់ទេ ។ ពួកជនក៏សួរបុរសនោះយ៉ាងនេះទៀតថា នែបុរសដ៏ចំរើន អ្នកមិនស្គាល់ មិនឃើញនូវស្ត្រីណា អ្នកប្រាថ្នា ចង់បាននូវស្ត្រីនោះឬអ្វី ។ បុរសនោះ លុះគេសួរដូច្នេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលកច្ចានៈ អ្នកសំគាល់នូវសេចក្ដីនោះថាដូចម្ដេច កាលបើដូច្នោះ សំដីរបស់បុរសនោះក្រែងយកជាការមិនបានទេដឹង ។ ពិតមែនហើយ ព្រះគោតមដ៏ចំរើន កាលបើដូច្នោះ សំដីរបស់បុរសនោះនឹងយកជាការមិនបានទេ ។ ម្នាលកច្ចានៈ អ្នកនិយាយថា បពិត្រព្រះគោតមដ៏ចំរើន ពន្លឺណាដែលរកពន្លឺឯទៀតក្រៃលើសលុបជាង ឬ ប្រសើរជាងគ្មាន ពន្លឺនោះឈ្មោះថាពន្លឺថ្លៃថ្លាដូច្នេះផង តែមិនតែងតាំងនូវពន្លឺនោះផង ក៏យ៉ាងនោះឯង ។ បពិត្រព្រះគោតមដ៏ចំរើន កែវពិទូរ្យ ស្អាតល្អ មានពន្លឺ

អដ្ឋំសោ សុបរិកម្មកតោ បណ្ឌុកម្ពលេ និក្ខិត្តោ ភាសតេ តបតេ វិរោចតេ(១) ឯវំវណ្ណោ អត្តា ហោតិ អរោគោ បរម្មរណាតិ ។

(១៨៣) តំ កឹ មញ្ញសិ កច្ចាន យោ វា មណិ វេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ បណ្ឌុកម្ពលេ និក្ខិត្តោ ភាសតេ តបតេ វិរោចតេ យោ វា រត្តន្ធការតិមិសាយ កិមិ ខជ្ជោបនកោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភោ គោតម រត្តន្ធការតិមិសាយ កិមិ ខជ្ជោបនកោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

---

១ ភាសតេ ច វិរោចតិ ចតិ [illegible] ។



មានជ្រុង ៨ ដែលជាងច្នៃល្អហើយ ដាក់លើសំពត់កម្ពល មានពណ៌លឿង រមែងភ្លឺរុងរឿង ដូចម្តេចមិញ អត្តាស្លាប់ហើយជាសភាពមិនមានរោគ រមែងមានពណ៌ ដូច្នោះឯង ។

(១៨៣) ម្នាលកច្ចានៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច កែវពិទូរ្យណាស្អាតល្អ មានពន្លឺ មានជ្រុង ៨ ដែលជាងច្នៃល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺរុងរឿង និងអំពិលអំពែក ជាកិមិជាតិណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់វត្ថុពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចំរើន បណ្តាពន្លឺវត្ថុពីរនេះ ពន្លឺអំពិលអំពែក ជាកិមិជាតិ ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង ប្រសើរជាងផង ។

(១៨៦) តំ កិំ មញ្ញសិ កច្ចាន យោ វា រត្តន្ធការតិមិសាយ កិមិ ខជ្ជោបនកោ យោ វា រត្តន្ធការតិមិសាយ តេលប្បទីបោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភោ គោតម រត្តន្ធការតិមិសាយ តេលប្បទីបោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៨៧) តំ កិំ មញ្ញសិ កច្ចាន យោ វា រត្តន្ធការតិមិសាយ តេលប្បទីបោ យោ វា រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភោ គោតម រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។



(១៨៦) ម្នាលកច្ចានៈ អ្នកសំគាល់សេចក្តីនោះដូចម្តេច អំពិលអំពែក ជាកិមិជាតិណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ និងប្រទីបប្រេងណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់វត្ថុទាំងពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចំរើន បណ្តាពន្លឺរបស់វត្ថុទាំងពីរនេះ ពន្លឺប្រទីបប្រេង ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង ប្រសើរជាងផង ។

(១៨៧) ម្នាលកច្ចានៈ អ្នកសំគាល់សេចក្តីនោះ ដូចម្តេច ប្រទីបប្រេងណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ និងគំនរភ្លើងធំណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់វត្ថុទាំងពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចំរើន បណ្តាពន្លឺរបស់វត្ថុទាំងពីរនេះ ពន្លឺគំនរភ្លើងធំ ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង ប្រសើរជាងផង ។

[១៩៦] តំ កឹ មញ្ញសិ កច្ចាន យោ វា រត្តន្ធការតិមិសាយ មហាអគ្គិក្ខន្ធោ យោ វា រត្តិយា បច្ចូសសមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យ្វាយំ ភោ គោតម រត្តិយា បច្ចូសសមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា អយំ ឥមេសំ ឧភិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

[១៩៧] តំ កឹ មញ្ញសិ កច្ចាន យោ វា រត្តិយា បច្ចូសសមយំ វិទ្ធេ វិគតវលាហកេ ទេវេ ឱសធិតារកា យោ វា តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិទោ(១) អឌ្ឍរត្តសមយំ ចន្ទោ ឥមេសំ ឧភិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

១ អត្ថិ ពោត្ថកេ អភិទោសន្តិ ទិស្សតិ ។



[១៩៦] ម្នាលកច្ចានៈ អ្នកសំគាល់សេចក្ដីនោះ ដូចម្ដេច គំនរភ្លើងធំណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ ឆេះឬផ្កាយព្រឹកណា ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង បណ្ដាពន្លឺរបស់វត្ថុពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចំរើន បណ្ដាពន្លឺរបស់វត្ថុពីរនេះ ពន្លឺផ្កាយព្រឹក ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

[១៩៧] ម្នាលកច្ចានៈ អ្នកសំគាល់សេចក្ដីនោះ ដូចម្ដេច ផ្កាយព្រឹកណា ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង ឬព្រះចន្ទ្រណាក្នុងវេលាអធ្រាត្រមិនខានត្រៀង ត្រង់ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង បណ្ដាពន្លឺរបស់វត្ថុពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។

យថាយំ ភោ គោតម តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិតោ អឌ្ឍរត្តសមយំ ចន្ទោ អយំ ឥមេសំ ទ្វិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

(១៨៨) តំ កឹ មញ្ញសិ កច្ចាន យោ វា តទហុបោសថេ បណ្ណរសេ វិទ្ធេ វិគតវលាហកេ ទេវេ អភិតោ អឌ្ឍរត្តសមយំ ចន្ទោ យោ វា វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អភិតោ មជ្ឈន្តិកសមយំ សុរិយោ ឥមេសំ ទ្វិន្នំ វណ្ណានំ កតមោ វណ្ណោ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ យថាយំ ភោ គោតម វស្សានំ បច្ឆិមេ មាសេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អភិតោ មជ្ឈន្តិកសមយំ សុរិយោ អយំ ឥមេសំ ទ្វិន្នំ វណ្ណានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។



បពិត្រព្រះគោតមដ៏ចំរើន បណ្តាពន្លឺរបស់ទាំងពីរនេះ ពន្លឺព្រះចន្ទ្រ ក្នុងវេលាយប់អធ្រាត្រមិនទាន់ជ្រៀនជ្រេ ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

(១៨៨) ម្នាលកច្ចានៈ អ្នកសំគាល់សេចក្តីនោះ ដូចម្តេច ព្រះចន្ទ្រណា ក្នុងវេលាអធ្រាត្រមិនទាន់ជ្រៀនជ្រេ ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង និងព្រះអាទិត្យណា ក្នុងសម័យថ្ងៃត្រង់មិនទាន់ជ្រៀនជ្រេ ក្នុងសារទសម័យ ខែខាងចុងនៃវស្សានរដូវ ដែលស្រឡះប្រាសចាកពពកភ្លៀង បណ្តាពន្លឺរបស់ទាំងពីរនេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចំរើន បណ្តាពន្លឺរបស់ទាំងពីរនេះ ពន្លឺព្រះអាទិត្យ ក្នុងសម័យថ្ងៃត្រង់មិនទាន់ជ្រៀនជ្រេ ក្នុងសារទសម័យ ខាងចុងនៃវស្សានរដូវ ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

(១៨៤) តតោ ខោ(១) តេ កច្ចាន ពហូ ហិ ពហុតរា ទេវា យេ ឥមេសំ ចន្ទិមសុរិយានំ អាភា នានុភោន្តិ ត្យាហំ បជានាមិ អថ ច បនាហំ ន វទាមិ យស្មា វណ្ណា អញ្ញោ វណ្ណោ ឧត្តរិតរោ វា(២) បណីតតរោ វា(៣) នត្ថីតិ អថ ច បន ត្វំ កច្ចាន យ្វាយំ វណ្ណោ កិមិនា ខជ្ជោបនកេន និហីនតរោ ច បតិកិដ្ឋតរោ ច សោ បរមោ វណ្ណោតិ វទេសិ តញ្ច វណ្ណំ ន បញ្ញបេសិ(៤) ។ បញ្ច ខោ ឥមេ កច្ចាន កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ កច្ចាន បញ្ច កាមគុណា ។ យំ ខោ កច្ចាន

១ ម. ឱ. តតោ ខោ ។ ២-៣ ម. ឱ. វា ។ ៤ ម. បញ្ញាបេសីតិ ។

២៣៨



(១៨៤) ម្នាលកច្ចានៈ ទេវតាទាំងឡាយណា មិនបានប្រើប្រាស់នូវពន្លឺព្រះចន្ទ្រនិងព្រះអាទិត្យ(១) ទាំងពីរនេះ ទេវតាទាំងនោះ មានច្រើនក្រៃលែងជាងនោះទៅទៀត តថាគតក៏ស្គាល់ច្បាស់នូវទេវតាទាំងនោះដែរ ប៉ុន្តែតថាគតមិនបានពោលថា ពន្លឺណាដែលរកពន្លឺឯទៀតលើសលុបជាង ឬប្រសើរជាងគ្មានផ្សេងទៀតឡើយ ម្នាលកច្ចានៈ ចំណែកអ្នកពោលថា ពន្លឺណាដែលថោកទាបជាងផង សៅហ្មងជាងផង ជាងពន្លឺអំពិលអំពែកជាកិមិជាតិ ពន្លឺនោះឈ្មោះថា ពន្លឺថ្លៃថ្លាផ្ទុះផង ទាំងមិនកំណត់នូវពន្លឺនោះផង ។ ម្នាលកច្ចានៈ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការតើដូចម្តេចខ្លះ គឺរូបដែលគួរដឹងបានដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតម្រេក ១ សំឡេងដែលគួរដឹងបានដោយត្រចៀក... ១ ក្លិនដែលគួរដឹងបានដោយច្រមុះ... ១ រសដែលគួរដឹងបានដោយអណ្តាត... ១ ផោដ្ឋព្វៈដែលគួរដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតម្រេក ១ ម្នាលកច្ចានៈ នេះឯងឈ្មោះថា កាមគុណ ៥ ប្រការ ។ ម្នាលកច្ចានៈ

១ ទេវតាដែលមានរស្មីលុបពន្លឺព្រះចន្ទនិងព្រះអាទិត្យ ។

ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ ។ ឥតិ កាមេហិ កាមសុខំ កាមសុខា កាមគ្គសុខំ តត្ថ អគ្គមក្ខាយតីតិ ។

[១៦០] ឯវំ វុត្តេ វេខណសោ បរិព្វាជកោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ ភោតា គោតមេន កាមេហិ កាមសុខំ កាមសុខា កាមគ្គសុខំ តត្ថ អគ្គមក្ខាយតីតិ ។ ទុជ្ជានំ ខោ ឯតំ កច្ចាន តយា អញ្ញទិដ្ឋិកេន អញ្ញខន្តិកេន អញ្ញរុចិកេន អញ្ញត្រយោគេន(១) អញ្ញាចរិយកេន កាមំ(២) វា កាមសុខំ វា កាមគ្គសុខំ វា(៣) យេ ខោ តេ កច្ចាន ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា

១ ឱ. ម. អញ្ញត្រ យោគេន ។ ២ ម. កាមេ វា ។ ៣ ឱ. ម. វា ។



ត្រង់ដែលសេចក្តីសុខនឹងសោមនស្ស កើតឡើង ព្រោះអាស្រ័យកាមគុណទាំង៥ ប្រការនេះ នេះឯងគេហៅថា កាមសុខគឺសុខក្នុងកាម ។ កាមសុខដោយកាមទាំងឡាយដូច្នេះឯង បណ្តាសុខទាំងនោះ សុខជាកំពូលនៃកាម ( ព្រះនិព្វាន ) ប្រាកដជាប្រសើរជាងកាមសុខ ។

[១៦០] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខណសបរិព្វាជក ក៏សសើរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន អស្ចារ្យពេកណាស់ បពិត្រព្រះគោតមដ៏ចំរើន ចំឡែកពេកណាស់ ដែលព្រះគោតមដ៏ចំរើន ទ្រង់ត្រាស់សំដែងដូច្នេះថា កាមសុខដោយកាមទាំងឡាយ បណ្តាសុខទាំងនោះ សុខដ៏ជាកំពូលនៃកាម ប្រាកដជាប្រសើរជាងកាមសុខ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចានៈ ខ្លួនអ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តីពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីផ្សេង មានអាចារ្យផ្សេង កម្រនឹងដឹងថា នុះជាកាម ឬជាកាមសុខ ឬក៏ជាកាមគ្គសុខ (ព្រះនិព្វាន) ដូច្នេះ ម្នាលកច្ចានៈ លុះតែពួកភិក្ខុណា ដែលជាអរហន្ត ខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌ គ្រប់គ្រាន់ហើយ ធ្វើសោឡសកិច្ចរួចស្រេចហើយ ដាក់ចុះភារៈហើយ សម្រេច

អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញាវិមុត្តា តេ ខោ ឯតំ ជានេយ្យុំ កាមំ វា កាមសុខំ វា កាមគ្គសុខំ វាតិ ។

(១៦១) ឯវំ វុត្តេ វេខណសោ បរិព្វាជកោ កុបិតោ អនត្តមនោ ភគវន្តំយេវ ខុំសេន្តោ ភគវន្តំយេវ វម្ភេន្តោ ភគវន្តំយេវ វទមានោ សមណោ គោតមោ(១) បាបិតោ ភវិស្សតីតិ ភគវន្តំ ឯតទវោច ឯវមេវ បនិធេកច្ចេ(២) សមណព្រាហ្មណា អជានន្តា បុព្វន្តំ អជានន្តា អបរន្តំ អថ ច បន ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ បដិជានន្តិ. តេសមិទំ ភាសិតំ ហស្សកំយេវ សម្បជ្ជតិ នាមកំយេវ(៣) សម្បជ្ជតិ រិត្តកំយេវ សម្បជ្ជតិ តុច្ឆកំយេវ សម្បជ្ជតីតិ ។

១ ម. សមណោ ច គោតមោ ។ ២ ម. បនិធេកេ ។ ៣ ឱ, ម. នាមកំយេវ ។



ប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ចំពាក់ក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះឯង ទើបដឹងថា នុ៎ះជាកាម ឬជាកាមសុខ ឬក៏ជាកាមគ្គសុខ ដូច្នេះបាន ។

(១៦១) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខណសបរិព្វាជក ក្រោធខឹងអាក់អន់ចិត្ត ជេរប្រមាថព្រះមានព្រះភាគ បន្តុះបង្អាប់ព្រះមានព្រះភាគ ស្តីបន្ទោសព្រះមានព្រះភាគថា ព្រះសមណគោតម ពេញជាមនុស្សលាមក ជាហើយ ក៏និយាយទៅនឹងព្រះមានព្រះភាគដូច្នេះថា ដំណើរនេះដូចគ្នានឹងសមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ មិនដឹងនូវទីបំផុតខាងដើម មិនដឹងនូវទីបំផុតខាងចុងទេ ប៉ុន្តែប្រកាសថា អាត្មាអញដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ឯពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះ សម្រេចបានត្រឹមតែឲ្យអ្នកដទៃសើចចំអកលេង សម្រេចបានត្រឹមតែជាពាក្យទថយលាមក ជាពាក្យឥតប្រយោជន៍ ជាពាក្យសោះសូន្យ ដោយពិត ។

[១៦៤] យេ ហិ កេចិ កច្ចាន សមណព្រាហ្មណា អជានន្តា បុព្វន្តំ អជានន្តា អបរន្តំ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ បដិជានន្តិ តេសំ សោយេវ សហធម្មិកោ និគ្គហោ ហោតិ អបិច កច្ចាន តិដ្ឋតុ បុព្វន្តោ តិដ្ឋតុ អបរន្តោ ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានោ នចិរស្សេវ សាមញ្ញេវ ញស្សតិ សាមំ ទក្ខិតិ ឯវំ កិរ សម្មា ពន្ធនា វិប្បមោក្ខោ ហោតិ យទិទំ អវិជ្ជាពន្ធនា ។ សេយ្យថាបិ កច្ចាន ទហរោ កុមារោ មន្ទោ ឧត្តានសេយ្យកោ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពទ្ធោ(១) អស្ស សុត្តកពន្ធនេហិ តស្ស វុឌ្ឍិមន្វាយ

១ ម. ពទ្ធោ ។



[១៦៤] ព្រះមានព្រះភាគត្រាស់ថា ម្នាលកច្ចានៈ ពួកសមណ-ព្រាហ្មណ៍ណា មិនដឹងនូវទីបំផុតខាងដើម មិនដឹងនូវទីបំផុតខាងចុង តែប្ដេជ្ញាថា អាត្មាអញដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គ-ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃទៀតប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយដូច្នេះ សមណព្រាហ្មណ៍នោះរមែងមានការសង្កត់សង្កិនប្រកបដោយធម៌នោះឯង ម្នាលកច្ចានៈ ទីបំផុតខាងដើមនឹងទីបំផុតខាងចុងចូរលើកទុកសិនចុះ បើវិញ្ញូបុរសដែលជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាត្រង់មែន ចូរមកចុះ តថាគតនឹងប្រៀនប្រដៅ តថាគតនឹងសំដែងធម៌ វិញ្ញូបុរសនោះ កាលបើបានប្រតិបត្តិ តាមពាក្យប្រៀនប្រដៅដូច្នោះហើយ មិនយូរឡើយ គង់នឹងដឹងដោយខ្លួនឯង នឹងឃើញដោយខ្លួនឯង ព្រោះថា ការរួចស្រឡះចាកចំណងគឺអវិជ្ជាដោយប្រពៃបាន យ៉ាងនេះឯង ។ ម្នាលកច្ចានៈ ក្មេងតូចខ្ចី កំពុងដេកផ្ងារ ដែលគេចងដោយចំណងអំបោះមានកជាគំរប់ ៥ ចំណងទាំងនោះនឹងរបូតចេញទៅ ព្រោះអាស្រ័យសេចក្ដីចំរើន ព្រោះ

បរិបាកមន្វាយ ឥន្ទ្រិយានំ តានិ ពន្ធនានិ មុញ្ចេយ្យុំ សោ មោក្ខោម្ហីតិ ខោ ជានេយ្យ នោ ច ពន្ធនំ ឯវមេវ ខោ កច្ចាន ឯតុ វិញ្ញូ បុរិសោ អសឋោ អមាយាវី ឧជុជាតិកោ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានោ នចិរស្សេវ សាមញ្ញេវ ញស្សតិ សាមំ ទក្ខតិ ឯវំ កិរ សម្មា ពន្ធនា វិប្បមោក្ខោ ហោតិ យទិទំ អវិជ្ជាពន្ធនាតិ ។

(១៦៣) ឯវំ វុត្តេ វេខណសោ បរិព្វាជកោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម ។បេ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

វេខណសសុត្តំ ទសមំ និដ្ឋិតំ ។

បរិព្វាជកវគ្គោ តតិយោ ។

---



អាស្រ័យការចាស់ទុំនៃឥន្ទ្រិយទាំងឡាយរបស់គេ ក៏ដឹងថា អាត្មាអញរួចចាកចំណងហើយ តែមិនស្គាល់នូវចំណង (នោះ) ទេ មានឧបមា យ៉ាងណាមិញ ម្នាលកច្ចានៈ (បើ) វិញ្ញូបុរសជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិជាត្រង់មែន ចូរមកចុះ តថាគតនឹងប្រៀនប្រដៅ តថាគតនឹងសំដែងធម៌ វិញ្ញូបុរសនោះ កាលបើបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅដូច្នោះហើយ មិនយូរប៉ុន្មាន នឹងដឹងដោយខ្លួនឯង នឹងឃើញដោយខ្លួនឯង ព្រោះថា ការរួចស្រឡះចាកចំណងគឺអវិជ្ជាដោយប្រពៃបានយ៉ាងនេះ មានឧបមេយ្យយ៉ាងនោះឯង ។

(១៦៣) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខណសបរិព្វាជក ក៏សសើរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ ។ បេ ។ សូមព្រះគោតមដ៏ចំរើនជ្រាបថា ខ្ញុំព្រះអង្គជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ ។

ចប់ វេខណសសូត្រ ទី ១០ ។

ចប់ បរិព្វាជកវគ្គ ទី ៣ ។

តស្ស វគ្គស្ស ឧទ្ទានំ

បុណ្ណោរិ អគ្គិ សហកាជិយាមោ

ទីឃនខោ បុន កណ្ណកោត្តោ

សន្ទកុទាយិ មុណ្ឌិកបុត្តោ

មណិកោ តថា កច្ចានោ វេវេគ្គោ (១) ។

១ ឱវំ ខត្តាទំ ឧ. យោគ្គកោ ៥ ទិស្សតិ ។





ឧទ្ទាននៃបរិព្វាជកវគ្គ ជាវគ្គទី៣ ប្រសើរតិ

ចូឡវច្ឆគោត្តសូត្រ ១ អគ្គិវច្ឆគោត្តសូត្រ ១ មហាវច្ឆគោត្តសូត្រ ១ ទីឃនខសូត្រ ១ មាគណ្ឌិយសូត្រ ១ សន្ទកសូត្រ ១ មហាសកុលុទាយិសូត្រ ១ សមណមុណ្ឌិកសូត្រ ១ ចូឡសកុលុទាយិសូត្រ ១ វេខណសសូត្រ ១ ។

## រាជវគ្គោ

### បឋមំ ឃដិការសុត្តំ

(១៦៤) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ ។ អថខោ ភគវា មគ្គា ឱក្កម្ម អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ន អការណេន តថាគតា សិតំ បាតុករោន្តីតិ ។ អថខោ អាយស្មា អានន្ទោ ឯកំសំ ឧត្តរាសង្គំ(១) ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ន អការណេន តថាគតា សិតំ បាតុករោន្តីតិ ។

១ ឧត្តរំ ឃោត្តរា ចីវរន្តិ ទិស្សតិ ។

## រាជវគ្គ

### ឃដិការសូត្រ ទី ១

(១៦៤) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃច្រើនអង្គ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ងាក (ព្រះភក្ត្រ) បែរចេញអំពីផ្លូវ ហើយបានធ្វើនូវការញញឹម ត្រង់ទីប្រទេសមួយឲ្យប្រាកដ ។ វេលានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគ ធ្វើនូវការញញឹមឲ្យប្រាកដឡើង (ព្រោះថា) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុទេ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ធ្វើនូវឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសួរចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគធ្វើនូវការញញឹមឲ្យប្រាកដឡើង (ព្រោះថា) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដដោយឥតហេតុទេ ។

[១៩៨] ភូតបុព្វំ អានន្ទ ឥមស្មិំ បទេសេ វេភឡិង្គំ(១) នាម និគមោ(២) អហោសិ ឥទ្ធោ ចេវ ផីតោ ច ពហុជនោ អាកិណ្ណមនុស្សោ ។ វេភឡិង្គំ ខោ អានន្ទ និគមំ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឧបនិស្សាយ វិហាសិ ។ ឥធ សុទំ អានន្ទ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អារាមោ អហោសិ ។ ឥធ សុទំ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ និសិន្នកោ(៣) ភិក្ខុសង្ឃំ ឱវទតីតិ ។

[១៩៩] អថខោ អាយស្មា អានន្ទោ ចតុគ្គុណំ សង្ឃាដឹ បញ្ញាបេត្វា ភគវន្តំ ឯតទវោច តេនហិ ភន្តេ ភគវា និសីទតុ ឯវាយំ ភូមិប្បទេសោ ទ្វីហិ អរហន្តេហិ សម្មាសម្ពុទ្ធេហិ បរិភុត្តោ ភវិស្សតីតិ ។ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ ភូតបុព្វំ អានន្ទ ឥមស្មិំ បទេសេ វេភឡិង្គំ នាម និគមោ អហោសិ

១ ឱ. វេភឡិង្គំ ។ ម. វេគឡិង្គំ ។ ២ ឱ. ម. នាមនិគមោ ។ ៣ ឱ. ម. និសិន្នកោ ។



(១៩៨) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ រឿងដែលធ្លាប់មានមកហើយ ក្នុងប្រទេសនេះ មាននិគមមួយឈ្មោះវេភឡិង្គៈ ជានិគមស្តុកស្តម្ភ ចំរុង មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមកសម្រេច សម្រាន្តឥរិយាបថ ក្នុងវេភឡិង្គនិគមនោះឯង ។ ម្នាលអានន្ទ អារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាននៅក្នុងទីនេះ ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់ ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ ។

(១៩៩) គ្រានោះឯង ព្រះអានន្ទមានអាយុ ក្រាលសង្ឃាដិមានជាន់ ៤ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន បើដូច្នោះ សូមព្រះមានព្រះភាគទ្រង់គង់ចុះ កាលបើព្រះអង្គគង់ហើយ ភូមិប្រទេសនេះ នឹងបានឈ្មោះថា មានព្រះអរហន្តសម្មាសម្ពុទ្ធពីរព្រះអង្គប្រើប្រាស់ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស្រេចហើយ ក៏ត្រាស់ហៅនឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ រឿងដែលធ្លាប់មានមកហើយ ក្នុងប្រទេសនេះ មាននិគមមួយឈ្មោះ វេភឡិង្គៈ ជា

ឥទ្ធា ចេវ ផីតា ច ពហុជនោ អាកិណ្ណ-មនុស្សា ។ វេគឡិង្គំ ខោ អានន្ទ និគមំ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឧបនិស្សាយ វិហាសិ ។ តត្រ សុទំ អានន្ទ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អារាមោ អហោសិ ។ តត្រ សុទំ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ និសិន្នោ ភិក្ខុសង្ឃំ ឱវទតិ ។ វេគឡិង្គេ ខោ អានន្ទ និគមេ ឃដិការោ នាម កុម្ភការោ កស្ស-បស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ឧបដ្ឋា-កោ អហោសិ អគ្គុបដ្ឋាកោ ។ ឃដិការស្ស ខោ អានន្ទ កុម្ភការស្ស ជោតិបាលោ នាម មាណវោ សហាយោ អហោសិ បិយសហាយោ ។ អថខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ អាមន្តេសិ អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។



និគមស្តុកស្តម្ភមាំមួន មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមកសម្រេចសម្រាន្តអាស្រ័យបថគន៍វេគឡិង្គនិគមនេះឯង ។ ម្នាលអានន្ទ អារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បាននៅក្នុងទីនេះឯង ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែងគង់ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ ។ ម្នាលអានន្ទ ក្នុងវេគឡិង្គនិគម មានសូនដាំងឆ្នាំងម្នាក់ឈ្មោះឃដិការ ជាឧបដ្ឋាក ជាអ្នកបំរើដ៏ប្រសើរ របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ សូនដាំងឈ្មោះឃដិការនោះឯង មានមាណពម្នាក់ ឈ្មោះជោតិបាល ជាមិត្តសំឡាញ់ពេញចិត្ត (របស់គាត់) ។ ម្នាលអានន្ទ គ្រានោះ ឃដិការសូនដាំងឆ្នាំងនិយាយនឹងជោតិបាលមាណពថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នាទៅគាល់ព្រះកស្សបមានព្រះភាគ ជាអរហន្ត-សម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញនូវព្រះមានព្រះភាគ ជាអរហន្ត-សម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។

(៣២៧) ឯវំ វុត្តេ អានន្ទ ជោតិបាលោ មាណវោ ឃដិការំ កុម្ភការំ ឯតទវោច អលំ សម្ម ឃដិការ កឹ បន តេន មុណ្ឌកេន សមណកេន ទិដ្ឋេនាតិ ។ ទុតិយម្បិ ខោ អានន្ទ ។ បេ ។ តតិយម្បិ ខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ ឯតទវោច អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ តតិយម្បិ ខោ អានន្ទ ជោតិបាលោ មាណវោ ឃដិការំ កុម្ភការំ ឯតទវោច អលំ សម្ម ឃដិការ កឹ បន តេន មុណ្ឌកេន សមណកេន ទិដ្ឋេនាតិ ។ តេនហិ សម្ម ជោតិបាល សោត្តិសិនានិំ(១) អាទាយ នទឹ គមិស្សាម សិនាយិតុន្តិ ។ ឯវំ សម្មាតិ ខោ អានន្ទ ជោតិបាលោ មាណវោ ឃដិការស្ស កុម្ភការស្ស បច្ចស្សោសិ ។

១ ម. សោត្តិ សិនានិំ ។



(៣២៧) ម្នាលអានន្ទ កាលដែលឃដិការស្មូនឆ្នាំងនិយាយយ៉ាងនេះ ជោតិបាលមាណពក៏ឃាត់ឃដិការស្មូនឆ្នាំងដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងនឹងបានគាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយអស់វារៈ ២ ដង ។ បេ ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយនឹងជោតិបាលមាណពអស់វារៈ ៣ ដងដូច្នេះថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ ឯជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដង ដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងនឹងបានគាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។ ឃដិការស្មូនឆ្នាំងតបថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត បើដូច្នោះ យើងនឹងកាន់យកខ្សែរំដោះសាត្តី(១) សម្រាប់ងូតទឹក ទៅកាន់ស្ទឹងដើម្បីងូតទឹក ។ ម្នាលអានន្ទ ជោតិបាលមាណព បានទទួលពាក្យឃដិការស្មូនឆ្នាំងថា យ៉ាងហ្នឹងហើយ សំឡាញ់ស្មោះស្មើចិត្ត ។

១ ខ្សែរំដោះដែលគេយកសំពត់ដិតធ្ងន់ឈ្មោះក្បាលខ្លែង មកលាយនឹងសំពត់ ហើយយកខ្សែចាក់ត្រង់កណ្តាល (ខ្សែរំដោះ) ទុកដែលត្រង់ចុងខ្សែទាំងសងខាង សម្រាប់កាន់ជុសកាយក្នុងវេលាដែលងូតទឹក ។

(១៦៨) អថខោ អានន្ទ ឃដិការោ ច កុម្ភការោ ជោតិបាលោ ច មាណវោ សោត្ថិសិនានិំ អាទាយ នទឹ អគមំសុ សិនាយិតុំ ។ អថខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ អាមន្តេសិ អយំ សម្ម ជោតិបាល កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អវិទូរេ អារាមោ អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

(១៦៩) ឯវំ វុត្តេ អានន្ទ ជោតិបាលោ មាណវោ ឃដិការំ កុម្ភការំ ឯតទវោច អលំ សម្ម ឃដិការ កឹ បន តេន មុណ្ឌកេន សមណកេន ទិដ្ឋេនាតិ ។ ទុតិយម្បិ ខោ អានន្ទ ។ បេ ។



(១៦៨) ម្នាលអានន្ទ លំដាប់នោះ ឃដិការស្មូនឆ្នាំងផង ជោតិបាលមាណព ក៏នាំគ្នាយកខ្សែរជ្រះសោត្តិ ទៅកាន់ស្ទឹង ដើម្បីងូតទឹក ។ ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងនិយាយនឹងជោតិ-បាលមាណពថា ម្នាលជោតិបាល សំឡាញ់ស្មោះស្ម័គ្រ នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ នែជោតិបាលសំឡាញ់ស្មោះស្ម័គ្រ មក យើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំ សន្មតថាជាការប្រពៃ ។

(១៦៩) ម្នាលអានន្ទ កាលបើឃដិការស្មូនឆ្នាំង និយាយយ៉ាងនេះ ជោតិបាលមាណពក៏ឃាត់ឃដិការស្មូនឆ្នាំងទៀតដូច្នេះថា កុំឡើយឃដិ-ការសំឡាញ់ស្មោះស្ម័គ្រ ចុះអ្នកឯងនឹងទៅគាល់ស្រមណ៍កំណោលនោះបានជាការអ្វី ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយអស់វារៈ ២ ដង ។ បេ ។

តតិយម្បិ ខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ ឯតទវោច អយំ សម្ម ជោតិបាល កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អវិទូរេ អារាមោ អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ តតិយម្បិ ខោ អានន្ទ ជោតិបាលោ មាណវោ ឃដិការំ កុម្ភការំ ឯតទវោច អលំ សម្ម ឃដិការ កឹ បន តេន មុណ្ឌកេន សមណកេន ទិដ្ឋេនាតិ ។

(១៧០) អថខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ ឱវដ្ដិកាយំ បរាមសិត្វា ឯតទវោច អយំ សម្ម ជោតិបាល កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អវិទូរេ អារាមោ



ម្នាលអានន្ទ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពអស់វារៈ ៣ ដងដូច្នេះថា ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត នែះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត មក យើងនឹងនាំគ្នា ចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ ជោតិបាលមាណពក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដងដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯង ចង់គាល់ស្រមណ៍ត្រងោលនោះបានជាការអ្វី ។

(១៧០) ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង ក៏ចាប់ទាញថ្នក់ជោតិបាលមាណព និយាយពោលដូច្នេះថា ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត នែះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្ត-សម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សំឡាញ់ស្មោះស្មើ

អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ អថខោ អានន្ទ ជោតិបាលោ មាណវោ ឱវដ្ដិកំ វិនិវេឋេត្វា(១) ឃដិការំ កុម្ភការំ ឯតទវោច អលំ សម្ម ឃដិការ កឹ បន តេន មុណ្ឌកេន សមណកេន ទិដ្ឋេនាតិ ។ អថខោ អានន្ទ ឃដិការោ កុម្ភការោ ជោតិបាលំ មាណវំ សីសំនហាតំ កេសេសុ បរាមសិត្វា ឯតទវោច អយំ សម្ម ជោតិបាល កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អវិទូរេ អារាមោ អាយាម សម្ម ជោតិបាល កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ ឧបសង្កមិស្សាម សាធុសម្មតញ្ហិ មេ តស្ស ភគវតោ ទស្សនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ អថខោ អានន្ទ ជោតិបាលស្ស មាណវស្ស

១ ម. វិនិវេត្វា ។



ចិត្ត មក យើងទាំង២នាំគ្នាចូលទៅ ដើម្បីគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថាការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ ទើបជោតិបាលមាណព ឲ្យឃដិការស្រាយខ្នាត់ដែលកាន់ជាប់ ហើយនិយាយដូច្នេះថា កុំឡើយ ឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងដល់ឃើញស្រមណ៍កំណោរនោះបានជាការអ្វី ។ ម្នាលអានន្ទ លំដាប់នោះ ឃដិការស្មូនឆ្នាំង ក៏ចាប់ចាញ់សក់ជោតិបាលមាណព ដែលទើបនឹងងូតរួច ហើយ និយាយលោមដូច្នេះថា ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត មក យើងទាំង២នាំគ្នា ចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថាការបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ គ្រានោះ ជោតិបាល-

ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ យត្រ ហិ នាមាយំ ឃដិការោ កុម្ភការោ ឥត្តរជច្ចោ សមានោ អម្ហាកំ សីសន្ហាតានំ កេសេសុ បរាមសិតព្ពំ មញ្ញិស្សតិ ន វតិទំ ឱរកំ មញ្ញេ ភវិស្សតីតិ ។ ឃដិការំ កុម្ភការំ ឯតទវោច យាវេតទោហិបិ សម្ម ឃដិការាតិ ។ យាវេតទោហិបិ សម្ម ជោតិបាល គច្ឆា ហិ បន មេ សាធុសម្មតំ តស្ស ភគវតោ ទស្សនំ អរហតោ សម្មា- សម្ពុទ្ធស្សាតិ ។ តេនហិ សម្ម ឃដិការ ឧញ្ញ គមិស្សាមាតិ ។

[៤៧០] អថខោ អានន្ទ ឃដិការោ ច កុម្ភ- ការោ ជោតិបាលោ ច មាណវោ យេន កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ



មាណពមានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ អស្ចារ្យណាស់ អើអើ ចំឡែកណាស់ មិនសមបើឃដិការស្មូនឆ្នាំង ជាមនុស្សមានកំណើតថោកទាបនេះ មកហ៊ានមើលងាយ ចាប់ទាញសក់របស់អញ ដែលទើបនឹងងូតហើយដូច្នេះសោះ ប្រហែលជាដំណើរ របស់អញដែលនឹងទៅនេះ មិនមែនជាដំណើរថោកទាបឡើយ ។ ទើបជោតិបាលមាណពសួរឃដិការស្មូនឆ្នាំងដូច្នេះថា ម្នាលឃដិការ សំឡាញ់ស្មោះស្មើចិត្ត អ្នកឯងចាប់ទាញសក់ខ្ញុំដល់ត្រឹមណាទៅទៀត ។ ឃដិការស្មូនឆ្នាំងតបថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត ខ្ញុំចាប់ទាញសក់អ្នកឯង គ្រាន់តែឲ្យបានទៅគាល់ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ដែលសន្មតថាជាការប្រពៃ ។ ជោតិបាលមាណពតបថា នែឃដិការសំឡាញ់ស្មោះស្មើចិត្ត បើយ៉ាងនេះ យើងនឹងទៅដែរ ។

(៤៧០) ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងនឹងជោតិបាលមាណព នាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មា-

ទុបសង្កមិត្វា ឃដិការោ កុម្ភការោ កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ជោតិបាលោ បន មាណវោ កស្សបេន ភគវតា អរហតា សម្មាសម្ពុទ្ធេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ[១] ឃដិការោ កុម្ភការោ កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អយំ មេ ភន្តេ ជោតិបាលោ មាណវោ សហាយោ បិយសហាយោ ឥមស្ស ភគវា ធម្មំ ទេសេតូតិ ។

[២៨២] អថខោ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឃដិការញ្ច កុម្ភការំ ជោតិបាលញ្ច មាណវំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

១ ម. ឧ. ខោ អានន្ទ ។



សម្ពុទ្ធ លុះចូលទៅដល់ហើយ ឃដិការៈស្មូនឆ្នាំង ក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ឯជោតិបាលមាណព ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅតែព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះឃដិការៈស្មូនឆ្នាំង អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ជោតិបាលមាណពនេះ ជាមិត្តសំឡាញ់ពេញចិត្តនៃខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគ សំដែងធម៌ប្រោសជោតិបាលមាណពនេះផង ។

[២៨២] ម្នាលអានន្ទ គ្រានោះ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ បានពន្យល់ឃដិការៈស្មូនឆ្នាំងនឹងជោតិបាលមាណពឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។

អថ ខោ អានន្ទ ឃដិការោ ច កុម្ភការោ ជោតិបាលោ ច មាណវោ កស្សបេន ភគវតា អរហតា សម្មាសម្ពុទ្ធេន ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។

(១៧៣) អថ ខោ អានន្ទ ជោតិបាលោ មាណវោ ឃដិការំ កុម្ភការំ ឯតទវោច ឥមំ នុ ត្វំ សម្ម ឃដិការ ធម្មំ សុណន្តោ អថ ច បន អគារស្មា[១] អនគារិយំ បព្វជីសតិ[២] ។ ននុ ច មំ សម្ម ជោតិបាល ជានាសិ អន្ធេ ជិណ្ណេ មាតាបិតរោ បោសេមីតិ ។ តេនហិ សម្ម ឃដិការ អហំ អគារស្មា អនគារិយំ បព្វជិស្សាមីតិ ។

១ ម. ឆ អគារស្មា ។ ២ ម. ឆ បព្វជិស្សសីតិ ។



ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនឹងជោតិបាលមាណព លុះព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ពន្យល់ឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអររីករាយចំពោះភាសិត របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួចក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយក៏ចៀសចេញទៅ ។

[១៧៣] ម្នាលអានន្ទ លំដាប់នោះ ជោតិបាលមាណពសួរឃដិការស្មូនឆ្នាំងដូច្នេះថា ម្នាលឃដិការសំឡាញ់ស្មោះស្មើចិត្ត អ្នកឯងកាលបើស្តាប់ធម៌នេះហើយ តើអ្នកឯងនឹងចេញចាកផ្ទះបួសទៅកាន់ផ្នួសឬទេ ។ ឃដិការស្មូនឆ្នាំងតបថា ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត អ្នកឯងមិនក្រែងដឹងថា ខ្ញុំចិញ្ចឹមមាតាបិតា ដែលចាស់ជរាងងឹតភ្នែកទេឬ ។ ជោតិបាលមាណពតបថា ម្នាលឃដិការសំឡាញ់ស្មោះស្មើចិត្ត បើដូច្នោះ ខ្ញុំនឹងចេញចាកផ្ទះបួសទៅកាន់ផ្នួស ។

[១៧៤] អថខោ អានន្ទ ឃដិការោ ច កុម្ភការោ ជោតិបាលោ ច មាណវោ យេន កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អានន្ទ ឃដិការោ កុម្ភការោ កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អយំ មេ ភន្តេ ជោតិបាលោ មាណវោ សហាយោ បិយសហាយោ ឥមំ ភគវា បព្វាជេតូតិ ។ អលត្ថ ខោ អានន្ទ ជោតិបាលោ មាណវោ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អថខោ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ អចិរូបសម្បន្នេ ជោតិបាលេ មាណវេ អឌ្ឍមាសូបសម្បន្នេ វេភឡិង្គេ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី តទវសរិ ។



(១៧៤) ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងនឹងជោតិបាលមាណព នាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះឃដិការស្មូនឆ្នាំងអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ជោតិបាលមាណពនេះ ជាមិត្តសំឡាញ់ពេញចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគ បំបួសជោតិបាលមាណពនេះឲ្យបាន ។ ម្នាលអានន្ទ ជោតិបាលមាណពក៏បានបួសបព្វជ្ជា បានឧបសម្បទាក្នុងសំណាក់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ គ្រាកាលដែលជោតិបាលមាណព បានឧបសម្បទាមិនយូរប៉ុន្មាន ទើបនឹងឧបសម្បទាបានកន្លះខែប៉ុណ្ណោះ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្រេចសម្រាន្តឥរិយាបថក្នុងវេភឡិង្គនិគម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិក សំដៅទៅកាន់ក្រុងពារាណសី កាលពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ក្រុងពារាណសីនោះ ។

(១៧៨) តត្រ សុទំ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ អស្សោសិ ខោ អានន្ទ កិកិ(១) កាសិរាជា កស្សបោ កិរ ភគវា អរហំ សម្មាសម្ពុទ្ធោ ពារាណសឹ អនុប្បត្តោ ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេតិ ។ អថខោ អានន្ទ កិកិ កាសិរាជា ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ ពារាណសិយា និយ្យាសិ មហច្ចរាជានុភាវេន(២) កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ទស្សនាយ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេន កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ តេនុបសង្កមិ ឧបសង្កមិត្វា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

១ ឱ. ម. កិកី ។ ២ ម. មហតា រាជានុភាវេន ។



(១៧៨) ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីនោះ ។ ម្នាលអានន្ទ ព្រះរាជាផែនកាសី ទ្រង់ព្រះនាមកិកិ បានឮដំណឹងថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពុទ្ធដំណើរមកដល់ក្រុងពារាណសីហើយ ឥឡូវទ្រង់គង់នៅ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ម្នាលអានន្ទ វេលានោះ ព្រះរាជាផែនកាសី ទ្រង់ព្រះនាមកិកិ បង្គាប់ពួកបុរសឲ្យរៀបចំយានដ៏ល្អ ៗ ហើយឡើងគង់យានដ៏ល្អ ស្តេចចេញទៅអំពីក្រុងពារាណសី ដោយយានដ៏ល្អៗ ដោយព្រះរាជានុភាពដ៏ប្រសើរ ដើម្បីគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះបរយានទៅទល់ត្រឹមទីដែលល្មមឈប់យានហើយ ក៏ចុះអំពីយាន ទ្រង់ស្តេចទៅដោយព្រះបាទទទេ ចូលសំដៅទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះស្តេចចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះកស្សប មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួចប្រថាប់គង់ក្នុងទីសមគួរ ។

[១៩៦ ឯកមន្តំ និសិន្នំ ខោ អានន្ទ កិកឹ កាសិរាជានំ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ អានន្ទ កិកី កាសិរាជា កស្សបេន ភគវតា អរហតា សម្មាសម្ពុទ្ធេន ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ខោ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ តុណ្ហីភាវេន ។ អថខោ អានន្ទ កិកី កាសិរាជា កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ អានន្ទ កិកី កាសិរាជា តស្សា រត្តិយា អច្ចយេន



[១៩៦] ម្នាលអានន្ទ លុះព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ប្រថាប់ ក្នុងទីសមគួរហើយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ ម្នាលអានន្ទ លំដាប់នោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ លុះព្រះកស្សបមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏និមន្តព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ទ្រង់ជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយស្តេចចេញទៅ ។ ម្នាលអានន្ទ គាលនោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ លុះកន្លងរាត្រីនោះ

សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា បណ្ឌុបុដកស្ស សាលិនោ វិចិតកាឡកំ[១] អនេកសូបំ អនេកព្យញ្ជនំ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស កាលំ អារោចាបេសិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។

[១៧៧] អថ ខោ អានន្ទ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កិកិស្ស កាសិរញ្ញោ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថ ខោ អានន្ទ កិកី កាសិរាជា ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថ ខោ អានន្ទ កិកី កាសិរាជា

១ ម. វិគតកាឡកំ ។



ហើយ ក៏ត្រាស់បង្គាប់រាជបុរស ឲ្យតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយស្រូវសាលីបានតណាំលឿង ជាអង្ករបាយទន់ ជាក្តុច្រាស ចាកកណ្ដៀ មានចំនួនសំឡដ៏ច្រើន នឹងម្ហូបគ្រឿងដ៏ច្រើន ក្នុងព្រះរាជដំណាក់របស់ព្រះអង្គ រួចហើយបង្គាប់រាជបុរស ឲ្យក្រាបទូលភត្តកាល ចំពោះព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន កាលដល់ហើយ ភត្តក៏សម្រេចហើយ ។

[១៧៧] ម្នាលអានន្ទ វេលានោះ ជាវេលាបុព្វណ្ហសម័យ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្បង់ប្រដាប់បាត្រនឹងចីវរ ស្តេចចូលទៅកាន់ព្រះរាជដំណាក់នៃព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ ម្នាលអានន្ទ សម័យនោះ ព្រះរាជាដែនកាសីទ្រង់ព្រះនាមកិកិ ទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយព្រះហស្តនៃព្រះអង្គឯង ឲ្យឆ្អែតស្កប់ស្កល់ ។ ម្នាលអានន្ទ កាលបើព្រះរាជាដែនកាសីព្រះនាម

កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អានន្ទ កិកិ កាសិរាជា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ពារាណសិយំ វស្សាវាសំ ឯវរូបំ សង្ឃស្ស ឧបដ្ឋានំ ភវិស្សតីតិ ។ អលំ មហារាជ អធិវុដ្ឋោ មេ វស្សាវាសោតិ ។ ទុតិយម្បិ ខោ អានន្ទ ។ បេ ។ តតិយម្បិ ខោ អានន្ទ កិកិ កាសិរាជា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ពារាណសិយំ វស្សាវាសំ ឯវរូបំ សង្ឃស្ស ឧបដ្ឋានំ ភវិស្សតីតិ ។ អលំ មហារាជ អធិវុដ្ឋោ មេ វស្សាវាសោតិ ។ អថខោ អានន្ទ



កិកិជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ សោយស្រេចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈមួយទាបជាង ហើយប្រថាប់ក្នុងទីសមគួរ ។ ម្នាលអានន្ទ លុះព្រះរាជាដែនកាសីព្រះនាមកិកិ ប្រថាប់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ទទួលគង់ចាំវស្សាក្នុងក្រុងពារាណសី របស់ខ្ញុំព្រះអង្គ ឯការបំរើសង្ឃមានសភាពដូច្នេះ នឹងមានមិនដាច់ ។ ព្រះកស្សបមានព្រះភាគត្រាស់ថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថា ការនៅចាំវស្សា តថាគតនៅចាំរួចហើយ ។ ម្នាលអានន្ទ ព្រះបាទកិកិក្រាបបង្គំទូលអស់វារៈពីរដង ។ បេ ។ ម្នាលអានន្ទ ព្រះរាជាដែនកាសីព្រះនាមកិកិ ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអស់វារៈ៣ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារាណសី របស់ខ្ញុំព្រះអង្គ ឯការបំរើសង្ឃមានសភាពដូច្នេះ នឹងមានមិនដាច់ ។ ព្រះកស្សបមានព្រះភាគត្រាស់តបថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថា ការនៅចាំវស្សា តថាគតនៅចាំរួចហើយ ។ ម្នាលអានន្ទ គ្រានោះ

កិកិស្ស កាសិរញ្ញោ ន មេ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ អធិវាសេសិ ពារាណសិយំ វស្សាវាសន្តិ អហុទេវ អញ្ញថត្តំ អហុ ទោមនស្សំ ។ អថខោ អានន្ទ កិកិ កាសិរាជា កស្សបំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធំ ឯតទវោច អត្ថិ នុ ខោ (១) ភន្តេ អញ្ញោ កោចិ មយា (២) ឧបដ្ឋាកតរោតិ ។

(១៣៨) អត្ថិ មហារាជ វេកឡិង្គំ នាម និគមោ តត្ថ ឃដិការោ នាម កុម្ភការោ សោ មេ ឧបដ្ឋាកោ អគ្គុបដ្ឋាកោ តុយ្ហំ ខោ បន មហារាជ ន មេ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ អធិវាសេសិ ពារាណសិយំ វស្សាវាសន្តិ អត្ថេវ អញ្ញថត្តំ អត្ថិ ទោមនស្សំ តយិទំ ឃដិការេ កុម្ភការេ នត្ថិ ន ច ភវិស្សតិ ឃដិការោ ខោ មហារាជ កុម្ភ-ការោ ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ

១ ឱ. ឆ ។ ២ ឱ. មយ្ហំ ។



ព្រះរាជាដែនកាសីព្រះនាមកិកិក្រាបថា ព្រះកស្សបមានព្រះភាគ អរ-ហន្តសម្មាសម្ពុទ្ធ មិនទ្រង់ទទួលនៅចាំវស្សា ក្នុងក្រុងពារាណសីរបស់អញដូច្នេះហើយ ទ្រង់ក៏មានព្រះចិត្តរាយមាយ ទ្រង់តូចព្រះហឫទ័យ ។ ម្នាលអានន្ទ វេលានោះ ព្រះរាជាដែនកាសីព្រះនាមកិកិ ក្រាបបង្គំទូល ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ចុះបុគ្គលដទៃណាមួយ ដែលជាអ្នកបំរើសេសជាងខ្ញុំព្រះអង្គទៅទៀត តើមានដែរឬទេ ។

(១៣៨) ថ្វាយព្រះពរមហារាជ មាន និគមមួយឈ្មោះវេកឡិង្គៈ ក្នុងនិគមនោះមានស្មូនឆ្នាំងម្នាក់ឈ្មោះឃដិការៈ ឯឃដិការស្មូនឆ្នាំងនោះ ឯង ជាឧបដ្ឋាក ជាអ្នកបំរើដ៏ប្រសើររបស់តថាគត បពិត្រព្រះមហារាជ មហាបពិត្រទ្រង់ក្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មិនទ្រង់ទទួលនៅចាំវស្សាក្នុងក្រុងពារាណសី របស់ព្រះអង្គដូច្នេះហើយ ក៏មានព្រះចិត្តរាយមាយ ទ្រង់តូចព្រះហឫទ័យ ចំណែកសេចក្តីរាយមាយចិត្ត នឹងការតូចចិត្តរបស់ឃដិការស្មូនឆ្នាំងនោះ មិនមានក្នុងកាលឥឡូវនេះផង នឹងមិនមានតទៅផង បពិត្រមហារាជ ព្រោះថាឃដិការស្មូនឆ្នាំងជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់

សង្ឃំ សរណំ គតោ ឃដិការោ ខោ មហារាជ កុម្ភការោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ឃដិការោ ខោ មហារាជ កុម្ភការោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ អរិយកន្តេហិ សីលេហិ សមន្នាគតោ ឃដិការោ ខោ មហារាជ កុម្ភការោ ទុក្ខេ និក្កង្ខោ ទុក្ខសមុទយេ និក្កង្ខោ ទុក្ខនិរោធេ និក្កង្ខោ ទុក្ខនិរោធគាមិនិយា បដិបទាយ និក្កង្ខោ ឃដិការោ ខោ មហារាជ កុម្ភការោ ឯកភត្តិកោ ព្រហ្មចារី សីលវា កល្យាណធម្មោ ឃដិការោ ខោ មហារាជ កុម្ភការោ និក្ខិត្តមណិសុវណ្ណោ អបេតជាតរូបរជតោ



ដល់ព្រះសង្ឃជាទីពឹង បពិត្រមហារាជ ឃដិការស្ទូនឆ្នាំង ជាអ្នកវៀរចាកការសំឡាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តិខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ បពិត្រព្រះមហារាជ ឃដិការស្ទូនឆ្នាំង ជាអ្នកប្រកបដោយសេចក្តីជ្រះថ្លា មិនកំរើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លា មិនកំរើកក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លា មិនកំរើកក្នុងព្រះសង្ឃ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ បពិត្រមហារាជ ឃដិការស្ទូនឆ្នាំង មិនមានសេចក្តីសង្ស័យក្នុងទុក្ខ មិនមានសេចក្តីសង្ស័យក្នុងហេតុជាគ្រឿងកើតឡើងនៃទុក្ខ មិនមានសេចក្តីសង្ស័យក្នុងធម៌ជាគ្រឿងរលត់ទុក្ខ មិនមានសេចក្តីសង្ស័យក្នុងសេចក្តីប្រតិបត្តិជាដំណើរ ដើម្បីទៅកាន់ទីរលត់ទុក្ខ បពិត្រមហារាជ ឃដិការស្ទូនឆ្នាំង ជាអ្នកបរិភោគភត្តតែ ១ ពេល ប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីល មានកល្យាណធម៌ បពិត្រមហារាជ ឃដិការស្ទូនឆ្នាំង ជាអ្នកលះបង់កែវមណីនិងមាស ជាអ្នកប្រាសចាកមាសនិងប្រាក់

ឃដិការោ ខោ មហារាជ កុម្ភការោ ន មុសលេន ន សហត្ថា បឋវឹ ខណតិ យំ ហោតិ កូលបលុគ្គំ(១) វា មូសិកុក្កុរោ(២) វា តំ កាជេន(៣) អាហរិត្វា ភាជនំ ករិត្វា ឯវមាហ ឯត្ថ យោ ឥច្ឆតិ តណ្ឌុលបដិភស្តានិ វា មុគ្គបដិភស្តានិ វា កឡាយបដិភស្តានិ វា(៤) និក្ខិបិត្វា យំ ឥច្ឆតិ តំ ហរតូតិ ។ ឃដិការោ ខោ មហារាជ កុម្ភការោ អន្ធេ ជិណ្ណេ មាតាបិតរោ បោសេតិ ។ ឃដិការោ ខោ មហារាជ កុម្ភការោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។

(១៧៨) ឯកមិទាហំ មហារាជ សមយំ វេភឡិង្គេ នាម និគមេ វិហរាមិ ។ អថខ្វាហំ មហារាជ

១ ម. កូលបលុគ្គំ ។ ២ ម. មូសិកុក្កុរេ ។ ៣ ឱ. ការេន ។ ៤ ឱ. តណ្ឌុលបដិភស្តានិ វា មុគ្គបដិភស្តានិ វា កឡាយបដិភស្តានិ វា ឥតិ បាឋោ ទិស្សតិ ។



បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកមិនជីកផែនដីដោយអង្រែ មិនកកាយផែនដីដោយដៃខ្លួនឯងផង តែងយកតែអាច្រេងកម្ទេចដីច្រាំង ធ្លាក់ ឬកំទេចដីដែលកណ្ដុរកកាយ មកធ្វើភាជន៍ហើយ ប្រកាស (សេចក្ដី) យ៉ាងនេះថា ជនណាចង់បាន (ភាជន៍) ចូរដាក់អង្ករមួយសំពៀត ឬក៏សណ្ដែកបាយមួយសំពៀតក្នុងទីនេះចុះ ហើយចង់បានភាជន៍បែបណា ចូរនាំយកភាជន៍នោះទៅចុះ ។ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង តែងចិញ្ចឹមមាតាបិតា ដែលចាស់ផងខ្វាក់ផង ។ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ទៀតសោតនឹងទៅកើតជាឱបបាតិកៈក្នុងលោក ហើយបរិនិព្វានក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់មកកាន់លោកនោះវិញ ជាធម្មតា ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ។

(១៧៨) បពិត្រមហារាជ សម័យមួយ តថាគតសម្រេចសម្រាន្ត នៅក្នុងវេភឡិង្គនិគម ។ បពិត្រមហារាជ គ្រានោះ តថាគត

បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន
ឃដីការស្ស កុម្ភការស្ស មាតាបិតរោ តេនុបសង្កមឹ
ឧបសង្កមិត្វា ឃដីការស្ស កុម្ភការស្ស មាតាបិតរោ
ឯតទវោចំ ហន្ទ កោ នុ ខោ អយំ ភគ្គវោ
គតោតិ ។ និក្ខន្តោ ខោ តេ ភន្តេ ឧបដ្ឋាកោ
អបិ ច កុម្ភិយា ឱទនំ គហេត្វា បរិយោគា សូបំ
គហេត្វា បរិភុញ្ជាតិ ។ អថ ខ្វាហំ មហារាជ កុម្ភិយា
ឱទនំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជិត្វា
ឧដ្ឋាយាសនា បក្កាមឹ ។ អថ ខោ មហារាជ ឃដី-
ការោ កុម្ភការោ យេន មាតាបិតរោ តេនុបសង្កមិ
ឧបសង្កមិត្វា មាតាបិតរោ ឯតទវោច កោ កុម្ភិយា
ឱទនំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជិត្វា
ឧដ្ឋាយាសនា បក្កន្តោតិ ។ កស្សបោ តាត ភគវា
អរហំ សម្មាសម្ពុទ្ធោ កុម្ភិយា ឱទនំ គហេត្វា បរិយោ-
គា សូបំ គហេត្វា បរិភុញ្ជិត្វា ឧដ្ឋាយាសនា បក្កន្តោ-
តិ ។ អថ ខោ មហារាជ ឃដីការស្ស កុម្ភការស្ស



ស្បៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ទីដែល
មាតាបិតារបស់ឃដិការស្មូនឆ្នាំងនៅ លុះចូលទៅដល់ហើយ ក៏និយាយ
នឹងមាតាបិតារបស់ឃដិការស្មូនឆ្នាំងដូច្នេះថា ចុះភគ្គវៈ[១] នេះចេញទៅ
ក្នុងទីណា ។ មាតាបិតារបស់ឃដិការស្មូនឆ្នាំងក៏ទូលថា បពិត្រព្រះអង្គដ៏
ចំរើន ឧបដ្ឋាករបស់ព្រះអង្គចេញទៅបាត់ហើយ សូមព្រះអង្គយកបាយ
អំពីឆ្នាំងនេះ យកសំឡអំពីភាជន៍នេះទៅឆាន់ចុះ ។ បពិត្រមហារាជ
គ្រានោះ តថាគតក៏យកបាយអំពីឆ្នាំង យកសំឡអំពីភាជន៍ឆាន់ រួចក៏
ក្រោកចាកអាសនៈហើយចៀសចេញទៅ ។ បពិត្រមហារាជ លំដាប់
នោះ ឃដិការស្មូនឆ្នាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ
ក៏សួរទៅមាតាបិតាដូច្នេះថា នរណាយកបាយអំពីឆ្នាំង យកសំឡអំពី
ភាជន៍ទៅបរិភោគ ហើយក្រោកចាកអាសនៈចៀសចេញទៅបាត់ ។
មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមានព្រះភាគ អរហន្តសម្មា-
សម្ពុទ្ធ យកបាយអំពីឆ្នាំង យកសំឡអំពីភាជន៍ទៅឆាន់ រួចហើយក្រោក
ចាកអាសនៈចៀសចេញទៅ ។ បពិត្រមហារាជ វេលានោះឃដិការស្មូន

១ ហៅតាមគោត្រ ព្រោះឃដិការស្មូនឆ្នាំងជាភគ្គវគោត្រ ។

ឯតទហោសិ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឯវំ អភិវិស្សដ្ឋោតិ ។ អថខោ មហារាជ ឃដិការំ កុម្ភការំ អឌ្ឍមាសំ បីតិសុខំ ន វិជហតិ សត្តាហំ មាតាបិតូនំ ។

(១៨០) ឯកមិទាហំ មហារាជ សមយំ តត្ថេវ វេភឡិង្គេ នាម និគមេ វិហរាមិ ។ អថខ្វាហំ មហារាជ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឃដិការស្ស កុម្ភការស្ស មាតាបិតរោ តេនុបសង្កមឹ ឧបសង្កមិត្វា ឃដិការស្ស កុម្ភការស្ស មាតាបិតរោ ឯតទវោចំ ហន្ទ ភោ ក្វ នុ ខោ អយំ ភគ្គវោ គតោតិ ។ និក្ខន្តោ ខោ តេ ភន្តេ ឧបដ្ឋាកោ អន្តោ កុម្ភិយា កុម្មាសំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជថាតិ ។ អថខ្វាហំ មហារាជ កុម្ភិយា កុម្មាសំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជិត្វា ឧដ្ឋាយាសនា បក្កាមឹ ។ អថខោ មហារាជ ឃដិការោ កុម្ភការោ



ឆ្នាំង មានសេចក្តីត្រិះរិះដូច្នេះថា អញពេញជាបានលាភ អត្តភាពជាមនុស្សរបស់អញពេញជាបានដោយល្អ (ព្រោះថា) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាលនឹងអញ ក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះ សេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្មូនឆ្នាំង អស់កន្លះខែ មិនលះបង់មាតាបិតា អស់៧ថ្ងៃ ។

(១៨០) បពិត្រមហារាជ សម័យនោះ តថាគតនៅក្នុងវេភឡិង្គនិគមនោះឯង ។ បពិត្រមហារាជ គ្រានោះ តថាគតស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ទីដែលមាតាបិតារបស់ឃដិការស្មូនឆ្នាំងនៅ លុះចូលទៅដល់ហើយ ក៏សួរមាតាបិតា របស់ឃដិការស្មូនឆ្នាំងដូច្នេះថា ចុះភគ្គវៈនេះ ចេញទៅក្នុងទីណា ។ មាតាបិតាទូលថា បពិត្រព្រះអង្គដ៏ចំរើន ឧបដ្ឋាករបស់ព្រះអង្គចេញទៅបាត់ហើយ សូមព្រះអង្គយកនំកុម្មាសអំពីឆ្នាំងនេះ យកសម្លអំពីផើងនេះឆាន់ចុះ ។ បពិត្រមហារាជ វេលានោះ តថាគតក៏យកនំកុម្មាសអំពីឆ្នាំង យកសម្លអំពីផើង ឆាន់រួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ បពិត្រមហារាជ លំដាប់នោះ ឃដិការស្មូនឆ្នាំង

យេន មាតាបិតរោ តេនុបសង្កមិ ឧបសង្កមិត្វា មាតាបិតរោ ឯតទវោច កោ កឡោបិយា កុម្មាសំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជិត្វា ឧដ្ឋាយាសនា បក្កន្តោតិ ។ កស្សបោ តាត ភគវា អរហំ សម្មាសម្ពុទ្ធោ កឡោបិយា កុម្មាសំ គហេត្វា បរិយោគា សូបំ គហេត្វា បរិភុញ្ជិត្វា ឧដ្ឋាយាសនា បក្កន្តោតិ ។ អថខោ មហារាជ ឃដិការស្ស កុម្ភការស្ស ឯតទហោសិ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ កស្សបោ ភគវា អរហំ សម្មាសម្ពុទ្ធោ ឯវំ អភិវិស្សដ្ឋោតិ ។ អថខោ មហារាជ ឃដិការំ កុម្ភការំ អឌ្ឍមាសំ បីតិសុខំ ន វិជហតិ សត្តាហំ មាតាបិតូនំ ។

(១៨១) ឯកមិទាហំ មហារាជ សមយំ តត្ថេវ វេភឡិង្គេ នាម និគមេ វិហរាមិ ។ តេន ខោ បន សមយេន កុដិ ឱវស្សតិ ។ អថខ្វាហំ មហារាជ ភិក្ខូ អាមន្តេសឹ គច្ឆថ ភិក្ខវេ



ចូលទៅរកមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរមាតាបិតាដូច្នេះថា នរណាយកនំកុម្មាសអំពីកឡោ យកសំឡអំពីភាជន៍ បរិភោគហើយ ក្រោកចាកអាសនៈចៀសចេញទៅបាត់ ។ មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ យកនំកុម្មាសអំពីកឡោ យកសំឡអំពីភាជន៍ឆាន់រួចហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។ បពិត្រមហារាជ វេលានោះ ឃដិការស្មូនឆ្នាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហើយមានលាភ អត្តភាពជាមនុស្សអញពេញហើយបានដោយល្អ (ព្រោះថា) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាលនឹងអញក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះ សេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្មូនឆ្នាំង អស់កន្លះខែ មិនលះបង់មាតាបិតាអស់ ៧ ថ្ងៃ ។

(១៨១) បពិត្រមហារាជ មានកាលសម័យមួយ តថាគតនៅក្នុងវេភឡិង្គនិគមនោះឯង ។ សម័យនោះ កុដិក៏លេចភ្លៀង ។ បពិត្រមហារាជ គ្រានោះតថាគតប្រាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ

ឃដិការស្ស កុម្ភការស្ស និវេសនេ តិណំ ឆាទន-ជាតិ ។ ឯវំ វុត្តេ មហារាជ តេ(១) ភិក្ខូ មំ ឯតទវោចុំ នត្ថិ ខោ ភន្តេ ឃដិការស្ស កុម្ភការស្ស និវេសនេ តិណំ អត្ថិ ច ខ្វាស្ស អាវេសនំ តិណច្ឆទនន្តិ ។ គច្ឆថ ភិក្ខវេ ឃដិការស្ស កុម្ភការស្ស អាវេសនំ ឧត្តិណំ ករោថាតិ ។ អថខោ តេ មហារាជ ភិក្ខូ ឃដិការស្ស កុម្ភការស្ស អាវេសនំ ឧត្តិណមកំសុ ។ អថខោ មហារាជ ឃដិការស្ស កុម្ភការស្ស មាតាបិតរោ តេ(២) ភិក្ខូ ឯតទវោចុំ កេ អាវេសនំ ឧត្តិណំ ករោន្តីតិ ។ ភិក្ខូ ភគិនិ កស្សបស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស កុដិ ឱវស្សតីតិ ។ ហរថ ភន្តេ ហរថ ភទ្រមុខាតិ ។ អថខោ មហារាជ ឃដិការោ កុម្ភការោ យេន មាតាបិតរោ តេនុបសង្កមិ ឧបសង្កមិត្វា មាតាបិតរោ ឯតទវោច កេ អាវេសនំ ឧត្តិណមកំសូតិ ។

១-២ ម, តេសទ្ទោ ន ទិស្សតិ ។



អ្នកទាំងឡាយចូរនាំគ្នាទៅ អ្នកទាំងឡាយចូររើនូវស្បូវគ្រងលំនៅនៃឃដិការស្មូនឆ្នាំងចុះ ។ បពិត្រមហារាជ កាលដែលតថាគតបង្គាប់យ៉ាងនេះ ភិក្ខុទាំងនោះក៏បានតបមកនឹងតថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ស្បូវគ្រងលំនៅនៃឃដិការស្មូនឆ្នាំង មិនមានទេ គាត់មានតែលំនៅដែលប្រក់ស្បូវប៉ុណ្ណោះ ។ តថាគតតបថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នាទៅរុះរើយកស្បូវ (ដែលប្រក់) ផ្ទះរបស់ឃដិការស្មូនឆ្នាំងមកចុះ ។ បពិត្រមហារាជ គ្រានោះ ភិក្ខុទាំងនោះក៏នាំគ្នារុះរើស្បូវ (ដែលប្រក់) ផ្ទះរបស់ឃដិការស្មូនឆ្នាំង ។ បពិត្រមហារាជ នៅវេលានោះ មាតាបិតារបស់ឃដិការស្មូនឆ្នាំង សួរភិក្ខុទាំងនោះដូច្នេះថា នរណារុះរើស្បូវ (ដែលប្រក់) ផ្ទះ ។ ភិក្ខុទាំងឡាយតបថា ម្នាលនាង កុដិរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធលេចភ្លៀង ។ មាតារបស់ឃដិការស្មូនឆ្នាំងទូលថា បពិត្រលោកទាំងឡាយដ៏ចំរើន ចូរលោកម្ចាស់ទាំងឡាយនាំយកទៅចុះ បពិត្រលោកមានគ្រឿងដ៏ចំរើនទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយនាំយកទៅចុះ ។ បពិត្រមហារាជ គ្រានោះ ឃដិការស្មូនឆ្នាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរមាតាបិតាដូច្នេះថា នរណារុះរើយកស្បូវដែលប្រក់ផ្ទះ (អស់ទៅ) ។

ភិក្ខូ តាន កស្សបស្ស តិណំ[១] ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស កុដឹ ឆាទេស្សន្តិ ។ អថខោ មហារាជ ឃដិការស្ស កុម្ភការស្ស ឯតទហោសិ លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ ភគវា អរហំ សម្មាសម្ពុទ្ធោ ឯវំ អភិវិស្សដ្ឋោតិ ។ អថខោ មហារាជ ឃដិការំ កុម្ភការំ អឌ្ឍមាសំ បីតិសុខំ ន វិជហតិ សត្តាហំ មាតាបិតូនំ ។ អថខោ តំ មហារាជ អាវេសនំ សព្វំ តេមាសំ អាកាសច្ឆទនំ អដ្ឋាសិ ន ទេវោតិវស្សិ ឯវរូបោ ច មហារាជ ឃដិការោ កុម្ភការោតិ ។ លាភា ភន្តេ ឃដិការស្ស កុម្ភការស្ស សុលទ្ធំ ភន្តេ ឃដិការស្ស កុម្ភការស្ស យស្ស ភគវា ឯវំ អភិវិស្សដ្ឋោតិ ។

(២៨៤) អថខោ អានន្ទ កិកី កាសិរាជា ឃដិការស្ស កុម្ភការស្ស បញ្ចមត្តានិ តណ្ឌុលវាហសតានិ បាហេសិ បណ្ឌុបុដកស្ស សាលិនោ តទុបិយញ្ច សូបេយ្យំ ។ អថខោ តេ អានន្ទ

១ ម. កិលញ្ជំ ន ទិស្សតិ ។



មាតាបិតាប្រាប់ថា ម្នាលកូន ឲ្យដឹងថា កុដិរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធលេចភ្លៀង ។ បពិត្រមហារាជ ទើបឃដិការស្មូនឆ្នាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហៅមានលាភ អត្តភាពជាមនុស្សអញពេញហៅបានដោយល្អ (ព្រោះថា) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ស្និទ្ធស្នាលនឹងអញក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះ សេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្មូនឆ្នាំងអស់កន្លះខែ មិនលះបង់មាតាបិតាអស់ ៧ ថ្ងៃ ។ បពិត្រមហារាជ គ្រានោះឯង លំនៅនោះមានអាកាសជាគ្រឿងប្រក់អស់ ៣ ខែគត់ ប៉ុន្តែមិនលេចភ្លៀងទេ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកមានសភាពដូច្នេះឯង ។ ព្រះរាជាទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ឃដិការស្មូនឆ្នាំងបានលាភហើយ អត្តភាពជាមនុស្ស ឃដិការស្មូនឆ្នាំងបានដោយល្អហើយ (ព្រោះថា) ព្រះមានព្រះភាគ ព្រះអង្គទ្រង់ស្និទ្ធស្នាលក្រៃពេកយ៉ាងនេះ ។

(២៨៤) ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសី ព្រះនាមកិកិ ក៏បញ្ជូនអង្ករនៃស្រូវសាលី មានពណ៌លឿង ជាអង្ករផុយទន់ ចំនួន ៥០០ រទេះ[១] នឹងគ្រឿងសំឡម្ហូបដ៏សមគួរដល់អង្ករនោះផង (ទៅឲ្យ) ដល់ឃដិការស្មូនឆ្នាំង ។ ម្នាលអានន្ទ គ្រានោះ

១ ចំនួន ២០០ រទេះ គ្រប់ជាមួយរទេះ ។ អដ្ឋកថា ។

រាជបុរិសោ យេន ឃដិការោ កុម្ភការោ ឧបសង្កមិត្វា ឯតទវោច ឥមានិ ភេ(១) ភន្តេ បញ្ចមត្តានិ តណ្ឌុលវាហសតានិ កិកិនា កាសិរាជេន បហិតានិ បណ្ឌុមុដិកស្ស សាលិនោ តទុបិយញ្ច សូបេយ្យំ តានិ ភន្តេ បដិគ្គណ្ហាតូតិ(២) ។ រាជា ខោ ពហុកិច្ចោ ពហុករណីយោ អលំ មេ រញ្ញោវ ហោតូតិ ។

[១៨៣] សិយា ខោ បន តេ អានន្ទ ឯវមស្ស អញ្ញោ នូន តេន សមយេន ជោតិបាលោ មាណវោ អហោសីតិ ។ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ អហំ តេន សមយេន ជោតិបាលោ មាណវោ អហោសិន្តិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ឃដិការសុត្តំ បឋមំ និដ្ឋិតំ ។

---

១ ម. ឥមេ ។ ម. ភោ ។ ២ ម. បដិគ្គណ្ហាតុ ។



កាលបុរសនោះ ក៏ចូលទៅរកឃដិការស្មូនឆ្នាំង ហើយនិយាយដូច្នេះថា បពិត្រអ្នកដ៏ចំរើន ព្រះរាជាដែនកាសីព្រះនាមកិកិ បានបញ្ជូនអង្ករនៃស្រូវសាលី មានពណ៌លឿង ជាអង្ករបោកទន់ ចំនួន ៥០០ រទេះផង គ្រឿងសំឡម្ពល្មមនឹងអង្ករនោះផង (មកឲ្យ) អ្នក បពិត្រអ្នកដ៏ចំរើន សូមអ្នកទទួលយកនូវវត្ថុទាំងនោះចុះ ។ ឃដិការស្មូនឆ្នាំងតបថា ព្រះរាជាព្រះអង្គមានកិច្ចច្រើន មានការងារដែលត្រូវធ្វើច្រើន ណ្ហើយ (កុំបាច់ព្រះរាជទាន) ដល់ខ្ញុំឡើយ វត្ថុទាំងនេះចូរឲ្យដល់ព្រះរាជាវិញចុះ ។

[១៨៣] ម្នាលអានន្ទ ប្រហែលជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលដទៃទេ ដែលកើតជាជោតិបាលមាណព ក្នុងសម័យនោះ ។ ម្នាលអានន្ទ ហេតុនេះ អ្នកកុំគប្បីយល់ឃើញយ៉ាងនេះឡើយ តថាគតហ្នឹងឯង ដែលកើតជាជោតិបាលមាណពក្នុងសម័យនោះ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តរីករាយត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ឃដិការសូត្រ ទី ១ ។

## ទុតិយំ រដ្ឋបាលសុត្តំ

(១៨៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ថុល្លកោដ្ឋិតំ(១) នាម កុរូនំ និគមោ តទវសរិ ។ អស្សោសុំ ខោ ថុល្លកោដ្ឋិតកា(២) ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កុរូសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ ថុល្លកោដ្ឋិតំ អនុប្បត្តោ តំ ខោ បន ភគវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា(៣) សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ

១ ម. ថុល្លកោដ្ឋិកោ ។ ២ ម. ថុល្លកោដ្ឋិកា ។ ៣ ឱ. ម. ភគវាតិ ។

## រដ្ឋបាលសូត្រ ទី ២

(១៨៦) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ត្រាច់ដើរទៅកាន់ដែនកុរុ ជាមួយនឹងពួកភិក្ខុច្រើន ទៅដល់ថុល្លកោដ្ឋិតនិគមរបស់អ្នកដែនកុរុទាំងឡាយ ។ ព្រាហ្មណ៍និងគហបតីទាំងឡាយ អ្នកស្រុកថុល្លកោដ្ឋិតៈបានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រ ទ្រង់ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស (ឥឡូវ) ទ្រង់ត្រាច់ដើរមកកាន់ដែនកុរុជាមួយនឹងពួកភិក្ខុច្រើន មកដល់ថុល្លកោដ្ឋិតនិគមហើយ កិត្តិសព្ទដ៏ល្អ នៃព្រះគោតម ដ៏ចំរើននោះឯង ឮខ្ចរខ្ចាយ យ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរបំផុត ព្រះអង្គជាសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្ដានៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងហើយ ទ្រង់ចែកនូវធម៌ទាំងពួង ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងទេវតានិងមនុស្សដ៏សេសនោះហើយ

សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

(១៨៥) អថខោ ថុល្លកោដ្ឋិកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលឹ បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នេ ខោ ថុល្លកោដ្ឋិកេ ព្រាហ្មណគហបតិកេ



ប្រាជ្ញាដ៏ក្រៃលែងដោយព្រះអង្គឯង ហើយទ្រង់ប្រកាស ( ឲ្យសេចក្តីនោះ ) ទ្រង់សំដែងធម៌មានលំអបទដើម បទកណ្តាលនិងបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធ ក៏ការបានឃើញព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ។

(១៨៥) លំដាប់នោះឯង ពួកព្រាហ្មណ៍និងគហបតី អ្នកថុល្លកោដ្ឋិកនិគមបានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែរាក់ទាក់ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលី ទៅរកព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាមនិងគោត្រ ក្នុងសំណាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ លុះពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុកថុល្លកោដ្ឋិកៈ អង្គុយក្នុងទីដ៏សមគួរហើយ

ភគវតា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

(១៨៦) តេន ខោ បន សមយេន រដ្ឋបាលោ នាម កុលបុត្តោ តស្មឹយេវ ថុល្លកោដ្ឋិកេ អគ្គកុ-លិកស្ស(១) បុត្តោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ រដ្ឋបាលស្ស កុលបុត្តស្ស ឯតទហោសិ យថា យថា ខ្វាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូ-នាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ អថខោ ថុល្លកោដ្ឋិកា ព្រាហ្មណគហបតិកា ភគ-វតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមឹសុ ។

១ ឱ. អគ្គកុលស្ស ។



ព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។

(១៨៦) ក្នុងជំនាន់នោះឯង មានកុលបុត្រម្នាក់ ឈ្មោះរដ្ឋបាល ជាកូនរបស់អ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនោះឯង បានអង្គុយក្នុងបរិស័ទនោះដែរ ។ គ្រានោះ រដ្ឋបាលកុលបុត្រមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញបានដឹងធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងហើយយ៉ាងណា ៗ តែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលដែលនៅគ្រប់គ្រងផ្ទះ នាំយកទៅប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យដូចជាស័ង្ខដែលគេខាត់ហើយយ៉ាងនោះ ៗ ទេ បើដូច្នោះ គួរតែអាត្មាអញកោរសក់ កោរពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ ចំណែកពួកព្រាហ្មណ៍និងគហបតី អ្នកថុល្លកោដ្ឋិតៈ ដែលព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយបានត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។

អថខោ រដ្ឋបាលោ កុលបុត្តោ អចិរបក្កន្តេសុ ថុល្លកោដ្ឋិតកេសុ ព្រាហ្មណគហបតិកេសុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រដ្ឋបាលោ កុលបុត្តោ ភគវន្តំ ឯតទវោច យថា យថាហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ ភន្តេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ បព្វជ្ជំ លភេយ្យំ ឧបសម្បទន្តិ ។ អនុញ្ញាតោសិ បន ត្វំ រដ្ឋបាល មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ន ខោហំ ភន្តេ អនុញ្ញាតោ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ន ខោ រដ្ឋបាល



កាលដែលពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកថុល្លកោដ្ឋិតៈថយចេញទៅ មិនយូរប៉ុន្មាន ទើបរដ្ឋបាលកុលបុត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះរដ្ឋបាលកុលបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ បានយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយយ៉ាងណា ៗ នែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យដូចជាស័ង្ខដែលគេខាត់ហើយយ៉ាងនោះទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គប្រាថ្នានឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចំរើន សូមឲ្យខ្ញុំព្រះអង្គបាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលរដ្ឋបាល មាតាបិតាបានអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះមកបួសហើយឬ ។ បពិត្រព្រះអង្គដ៏ចំរើន មាតាបិតាមិនទាន់អនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសទេ ។ ម្នាលរដ្ឋបាល

តថាគតា អននុញ្ញាតំ មាតាបិតូហិ បុត្តំ បព្វាជេន្តី-តិ ។ សោហំ ភន្តេ តថា ករិស្សាមិ យថា មំ មាតាបិតរោ អនុជានិស្សន្តិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។

[១៨៧] អថខោ រដ្ឋបាលោ កុលបុត្តោ ឧដ្ឋា-យាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា យេន មាតាបិតរោ តេនុបសង្កមិ ឧបសង្កមិត្វា មាតា-បិតរោ ឯតទវោច អម្មតាត(១) យថា យថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ អនុជានាថ មំ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។

[១៨៨] ឯវំ វុត្តេ រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ ត្វំ ខោសិ(២) តាត រដ្ឋបាល អម្ហាកំ ឯកបុត្តកោ បិយោ មនា-

១ ម. អម្មតាត ។ ២ ម. ត្វំ ។



ព្រះតថាគតទាំងឡាយ មិនបំបួសកូនដែលមាតាបិតា មិនទាន់អនុញ្ញាតទេ ។ បពិត្រព្រះអង្គដ៏ចំរើន មាតាបិតានឹងអនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។

[១៨៧] ខណៈនោះឯង រដ្ឋបាលកុលបុត្រ ក្រោកចាកអាសនៈហើយ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ចូលទៅរកមាតាបិតា លុះចូលទៅដល់ហើយ បាននិយាយនឹងមាតាបិតាយ៉ាងនេះថា បពិត្រលោកម្តាយលោកឪពុក ខ្ញុំបានយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយយ៉ាងណា តែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ដោយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យដូចជាស័ង្ខដែលគេខាត់ហើយយ៉ាងនោះ ។ បានទេ ខ្ញុំប្រាថ្នានឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស សូមលោកម្តាយលោកឪពុក អនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួសចុះ ។

[១៨៨] កាលបើរដ្ឋបាលកុលបុត្រនិយាយយ៉ាងនេះហើយ មាតាបិតាក៏និយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា ម្នាលរដ្ឋបាលកូន អ្នកឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់ចំរើនដោយ

បោ សុខេធិតោ(1) សុខបរិហតោ ន ត្វំ តាត រដ្ឋបាល កិញ្ចិ(2) ទុក្ខស្ស ជានាសិ ឯហិ ត្វំ តាត រដ្ឋបាល ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយ មរណេនបិ តេ មយំ អកាមកា វិនា ភវិស្សាម កឹ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ រដ្ឋបាលោ កុលបុត្តោ មាតាបិតរោ ឯតទវោច អម្មតាត យថា យថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ ឥច្ឆាមហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតុំ អនុជានាថ មំ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។

១ សុខេ ឋិតោតិបិ ។ ២ ឧ. ម. កស្សចិ ។



សេចក្តីសុខ ជាអ្នកដែលគេបីបាច់ថ្នាក់ថ្នមដោយសុខ នែរដ្ឋបាលកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ នែបារដ្ឋបាលកូន អ្នកចូរមកបរិភោគបាយផឹកទឹក ចាំងឲ្យគេបំរើចុះ កាលបើអ្នកបរិភោគបាយផឹកទឹក ចាំងឲ្យគេបំរើហើយ ចូរបរិភោគកាមចាំងធ្វើបុណ្យតាមស្រួលចិត្តចុះ យើងមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទុកជាដល់ស្លាប់ យើងក៏មិនចង់ឃ្លាតក៏បាដែរ ចំណង់បើបានៅរស់(យ៉ាងនេះ) តើយើងនឹងអនុញ្ញាតឲ្យចេញចាកផ្ទះទៅបួសដូចម្តេចបាន ។ រដ្ឋបាលកុលបុត្របាននិយាយនឹងមាតាបិតាជាគំរប់ពីរដងផង ។បេ។ ជាគំរប់បីដងផង យ៉ាងនេះថា បពិត្រមាតាបិតា ខ្ញុំយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សំដែងយ៉ាងណា នែព្រហ្មចរិយៈនេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យដូចផងដូចជាស័ង្ខដែលគេដុសខាត់ហើយយ៉ាងនោះទេ ខ្ញុំប្រាថ្នានឹងកោរសក់ពុកមាត់ពុកចង្កា ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅបួស ហេតុនេះ សូមមាតាបិតា អនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួសចុះ ។

តតិយម្បិ ខោ រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ ត្វំ ខោសិ តាត រដ្ឋបាល អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត រដ្ឋបាល កិញ្ចិ(១) ទុក្ខស្ស ជានាសិ ឯហិ ត្វំ តាត រដ្ឋបាល ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយ មរណេនបិ តេ មយំ អកាមកា វិនា ភវិស្សាម កិំ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។

[១៨៩] អថ ខោ រដ្ឋបាលោ កុលបុត្តោ ន មំ មាតាបិតរោ អនុជានន្តិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ តត្ថេវ អនន្តរហិតាយ ភូមិយា និបជ្ជិ ឥធ ហ(២) មេ មរណំ ភវិស្សតិ បព្វជ្ជា វាតិ ។ អថ ខោ រដ្ឋបាលោ កុលបុត្តោ ឯកម្បិ ភត្តំ ន ភុញ្ជិ ទ្វេបិ

១ ឱ. កត្ថចិ ។ ២ ឱសថិយបោត្ថកេ អថខោ រដ្ឋបាលោ កុលបុត្តោ មាតាបិតូសុ អននុជានន្តេសុ តត្ថេវ អនន្តរហិតាយ ភូមិយា និបជ្ជិ ឥធេវ មេ ភវិស្សតិ ។



មាតាបិតា របស់រដ្ឋបាលកុលបុត្រ បាននិយាយនឹងរដ្ឋបាលកុលបុត្រ ជាគំរប់បីដងយ៉ាងនេះថា នែរដ្ឋបាលកូន អាឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង អ្នកធ្លាប់ចំរើនដោយសេចក្តីសុខ គេបីបាច់រក្សាមកជាសុខ នែរដ្ឋបាលកូន អ្នកមិនទាន់ស្គាល់សេចក្តីលំបាកតិចតួចសោះ នែរដ្ឋបាលកូន អ្នកចូរមកបរិភោគបាយផឹកទឹក ទាំងឲ្យគេបំរើទៅ កាលបើអ្នកបរិភោគបាយផឹកទឹក ទាំងឲ្យគេបំរើ បរិភោគវត្ថុកាមហើយ ចូរធ្វើបុណ្យតាមស្រួលចិត្តចុះ យើងមិនអនុញ្ញាតឲ្យអាចេញចាកផ្ទះទៅបួសទេ ទោះណាជាដល់ស្លាប់ យើងក៏មិនប្រាថ្នាឲ្យឃ្លាតពីអ្នកដែរ ចំណង់បើអ្នកនៅរស់នៅ (យ៉ាងនេះ) តើយើងនឹងអនុញ្ញាតឲ្យចេញចាកផ្ទះទៅបួសដូចម្តេចបាន ។

[១៨៩] គ្រានោះឯង រដ្ឋបាលកុលបុត្រ គិតថា មាតាបិតាមិនអនុញ្ញាតឲ្យអាត្មាអញ ចេញចាកផ្ទះទៅបួសទេ ក៏ដួលដេកនៅលើទីវាលមិនបានក្រាលអ្វីៗ ត្រង់កន្លែងនោះឯង ដោយគិតថា អាត្មាអញនឹងស្លាប់ក្នុងទីនេះឬនឹងបានបួស ។ លំដាប់នោះឯង រដ្ឋបាលកុលបុត្រ មិនបានបរិភោគបាយអស់មួយពេល មិនបរិភោគអស់

ភត្តានិ ន ភុញ្ជិ តីណិបិ ភត្តានិ ន ភុញ្ជិ ចត្តារិបិ ភត្តានិ ន ភុញ្ជិ បញ្ចបិ ភត្តានិ ន ភុញ្ជិ ឆបិ ភត្តានិ ន ភុញ្ជិ សត្តបិ ភត្តានិ ន ភុញ្ជិ(១) ។

(១៩០) អថខោ រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ ត្វំ ខោសិ តាត រដ្ឋបាល អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ តាត រដ្ឋបាល កិញ្ចិ ទុក្ខស្ស ជានាសិ ឯហិ ត្វំ តាត រដ្ឋបាល ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយ មរណេនបិ តេ មយំ អកាមកា វិនា ភវិស្សាម កិំ បន មយំ(២) តំ ជីវន្តំ អនុជានិស្សាម អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ឯវំ វុត្តេ រដ្ឋបាលោ កុលបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ រដ្ឋបាលស្ស កុលបុត្តស្ស

១ ឧភយពោត្ថកេ អថខោ រដ្ឋបាលោ កុលបុត្តោ ឯកម្បិ ភត្តំ ន ភុញ្ជិ ..... សត្តបិ ភត្តានិ ន ភុញ្ជីតិ ឥទំ ន ទិស្សតិ ។ ២ ម. មយន្តំ ន ទិស្សតិ ។



២ ពេល មិនបរិភោគអស់ ៣ ពេល មិនបរិភោគអស់ ៤ ពេល មិនបរិភោគអស់ ៥ ពេល មិនបរិភោគអស់ ៦ ពេល មិនបរិភោគអស់ ៧ ពេល ។

(១៩០) ពេលនោះ មាតាបិតារបស់រដ្ឋបាលកុលបុត្រនិយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា ម្នាលរដ្ឋបាលកូន ឯងជាកូនតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង អ្នកធ្លាប់ចំរើនដោយសេចក្តីសុខ នៅថែរក្សាមកដោយសេចក្តីសុខ ម្នាលរដ្ឋបាលកូន អ្នកមិនដែលស្គាល់សេចក្តីលំបាកបន្តិចបន្តួចសោះ ម្នាលរដ្ឋបាលកូន អ្នកចូរក្រោកឡើង ចូរបរិភោគបាយផឹកទឹក តាំងឲ្យគេបំរើទៅ កាលបើអ្នកបរិភោគបាយផឹកទឹក តាំងឲ្យគេបំរើ បរិភោគកាមហើយ ចូរធ្វើបុណ្យតាមស្រួលចិត្តចុះ យើងមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទោះណាជាស្លាប់ យើងក៏មិនចង់ឲ្យព្រាត់ប្រាសឯងដែរ ចំណង់បើអ្នកនៅរស់ (យ៉ាងនេះ) តើយើងនឹងអនុញ្ញាតឲ្យឯងចេញចាកផ្ទះទៅបួសដូចម្តេចបាន ។ កាលដែលមាតាបិតានិយាយយ៉ាងយ៉ាងនេះហើយ រដ្ឋបាលកុលបុត្រក៏ស្ងៀម ។ មាតាបិតារបស់រដ្ឋបាល-

មាតាបិតរោ រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ
។ បេ ។ ទុតិយម្បិ ខោ រដ្ឋបាលោ កុលបុត្តោ
តុណ្ហី អហោសិ ។ តតិយម្បិ ខោ រដ្ឋបាលស្ស
កុលបុត្តស្ស មាតាបិតរោ រដ្ឋបាលំ កុលបុត្តំ
ឯតទវោចុំ ត្វំ ខោសិ តាត រដ្ឋបាល អម្ហាកំ
ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខ-
បរិហតោ ច ត្វំ តាត រដ្ឋបាល កិញ្ចិ ទុក្ខស្ស
ជានាសិ ឧដ្ឋេហិ តាត រដ្ឋបាល ភុញ្ជ ច បិវ ច
បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ
បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ
មយំ អនុជានាម អគារស្មា អនគារិយំ បព្វជ្ជាយ
មរណេនបិ តេ មយំ អកាមកា វិនា ភវិស្សាម
កឹ បន មយំ តំ ជីវន្តំ អនុជានិស្សាម អគារស្មា
អនគារិយំ បព្វជ្ជាយាតិ ។ តតិយម្បិ ខោ រដ្ឋបាលោ
កុលបុត្តោ តុណ្ហី អហោសិ ។



កុលបុត្រ និយាយនឹងរដ្ឋបាលកុលបុត្រ អស់វារៈពីរដងយ៉ាងនេះ ។ បេ ។
សូម្បីអស់វារៈទី ២ រដ្ឋបាលកុលបុត្រក៏នៅតែស្ងៀមទៀត ។ មាតាបិតា
របស់រដ្ឋបាលកុលបុត្រ និយាយនឹងរដ្ឋបាលកុលបុត្រ ជាគំរប់ ៣ ដង
យ៉ាងនេះថា ម្នាលរដ្ឋបាលកូន អ្នកជាកូនប្រុសតែមួយ ជាទីស្រឡាញ់
ពេញចិត្តរបស់យើង អ្នកធ្លាប់ចំរើនដោយសេចក្ដីសុខ មានគេថែរក្សា
ដោយសេចក្ដីសុខ នែរដ្ឋបាលកូន អ្នកមិនទាន់ស្គាល់ទុក្ខបន្តិចបន្តួចសោះ
នែរដ្ឋបាលកូន ចូរអ្នកក្រោកឡើង ចូរបរិភោគបាយផឹកទឹកឲ្យគេបំរើទៅ
កាលបើបរិភោគបាយផឹកទឹក តាំងឲ្យគេបំរើ បរិភោគកាមហើយ ចូរធ្វើ
បុណ្យតាមស្រេចចិត្តចុះ យើងមិនអនុញ្ញាតឲ្យបាឯង ចេញចាកផ្ទះទៅ
បួសទេ ទោះបីដល់ស្លាប់ យើងក៏មិនប្រាថ្នាឲ្យឃ្លាតអំពីបាដែរ ចំណង់
បើអ្នកនៅរស់ក្រឡង់ តើយើងនឹងអនុញ្ញាតឲ្យបា ចេញចាកផ្ទះទៅបួស
ដូចម្ដេចបាន ។ សូម្បីអស់វារៈទី ៣ រដ្ឋបាលកុលបុត្រ ក៏នៅតែស្ងៀម ។

(១៩១) អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា យេន រដ្ឋបាលោ កុលបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ(១) ត្វំ ខោសិ សម្ម រដ្ឋបាល មាតាបិតូនំ ឯកបុត្តកោ បិយោ មនាបោ សុខេធិតោ សុខបរិហតោ ន ត្វំ សម្ម រដ្ឋបាល កិញ្ចិ ទុក្ខស្ស ជានាសិ ឧដ្ឋេហិ សម្ម រដ្ឋបាល ភុញ្ជ ច បិវ ច បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ មាតាបិតរោ អនុជានន្តិ អគារស្មា អនគារិយំ បព្វជ្ជាយ មរណេនបិ តេ មាតាបិតរោ អកាមកា វិនា ភវិស្សន្តិ កឹ បន តេ តំ ជីវន្តំ អនុជានិស្សន្តិ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ ឯវំ វុត្តេ រដ្ឋបាលោ កុលបុត្តោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។បេ។

១ ម. អថខោ រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ យេន រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា តេនុបសង្កមឹសុ ឧបសង្កមិត្វា រដ្ឋបាលស្ស កុលបុត្តស្ស សហាយកេ ឯតទវោចុំ ។ ឯសោ តាតា រដ្ឋបាលោ កុលបុត្តោ អនន្តរហិតាយ ភូមិយា និបន្នោ ។ ឯត្ថ មេ មរណំ វា ភវិស្សតិ បព្វជ្ជា វាតិ ។ ឯថ តាតា យេន រដ្ឋបាលោ កុលបុត្តោ តេនុបសង្កមថ ឧបសង្កមិត្វា រដ្ឋបាលំ កុលបុត្តំ ឯវំ វទេថាតិ ទិស្សន្តិ ។



(១៩១) គ្រានោះឯង ពួកសំឡាញ់ របស់រដ្ឋបាលកុលបុត្រនាំគ្នាចូលទៅរករដ្ឋបាលកុលបុត្រ លុះចូលទៅដល់ហើយ ក៏និយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា នែរដ្ឋបាលសំឡាញ់ អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា អ្នកឯងចំរើនដោយសេចក្តីសុខ មានគេថែរក្សាដោយសេចក្តីសុខ នែរដ្ឋបាលសំឡាញ់ អ្នកមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះ នែរដ្ឋបាលសំឡាញ់ អ្នកចូរក្រោកឡើង ចូរបរិភោគផងផឹកផង ចាំផ្សេងបំរើទៅ កាលបើអ្នកបរិភោគផង ផឹកផង ចាំផ្សេងបំរើ បរិភោគនូវកាមហើយ ចូរធ្វើបុណ្យតាមស្រួលចិត្តចុះ មាតាបិតាមិនអនុញ្ញាតឲ្យអ្នក ចេញចាកផ្ទះទៅបួសទេ ទោះណាជាដល់ស្លាប់ ក៏មាតាបិតាមិនប្រាថ្នាឲ្យឃ្លាតពីអ្នកដែរ ចំណង់បើអ្នកនៅរស់ (យ៉ាងនេះ) តើមាតាបិតានឹងអនុញ្ញាតឲ្យចេញចាកផ្ទះទៅបួសដូចម្តេចបាន ។ កាលដែលពួកសំឡាញ់ និយាយយ៉ាងនេះហើយ រដ្ឋបាលកុលបុត្រក៏នៅស្ងៀមទៀត ។ សូម្បីសំណេះជាគំរប់ ២ ដង ។បេ។

តតិយម្បិ ខោ រដ្ឋបាលស្ស កុលបុត្តស្ស សហា-
យកា រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ ត្វំ ខោសិ
សម្ម រដ្ឋបាល មាតាបិតូនំ ឯកបុត្តកោ បិយោ
មនាបោ សុខេធិតោ សុខបរិហតោ ។ បេ ។
ឧដ្ឋេហិ សម្ម រដ្ឋបាល ភុញ្ជ ច បិវ ច
បរិចារេហិ ច ភុញ្ជន្តោ បិវន្តោ បរិចារេន្តោ កាមេ
បរិភុញ្ជន្តោ បុញ្ញានិ ករោន្តោ អភិរមស្សុ ន តំ
មាតាបិតរោ អនុជានន្តិ អគារស្មា អនគារិយំ បព្ព-
ជ្ជាយ មរណេនបិ តេ មាតាបិតរោ អកាមកា
វិនា ភវិស្សន្តិ កឹ បន តេ តំ ជីវន្តំ អនុជានិស្សន្តិ
អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ តតិយម្បិ
ខោ រដ្ឋបាលោ កុលបុត្តោ តុណ្ហី អហោសិ ។
អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា
យេន រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ
តេនុបសង្កមឹសុ ឧបសង្កមិត្វា រដ្ឋបាលស្ស កុល-
បុត្តស្ស មាតាបិតរោ ឯតទវោចុំ អម្មតាត
ឯសោ រដ្ឋបាលោ កុលបុត្តោ តត្ថេវ អនន្តរហិតាយ



ពួកសំឡាញ់របស់រដ្ឋបាលកុលបុត្រ បាននិយាយនឹងរដ្ឋបាលកុលបុត្រ
ជាគំរប់បីដងយ៉ាងនេះថា នែរដ្ឋបាលសំឡាញ់ អ្នកឯងជាកូនប្រុសតែមួយ
ជាទីស្រឡាញ់គាប់ចិត្តរបស់មាតាបិតា អ្នកធ្លាប់ចំរើនដោយសេចក្តីសុខ
គេបីបាច់មកដោយសេចក្តីសុខ ។ បេ ។ នែរដ្ឋបាលសំឡាញ់ អ្នកចូរក្រោក
ឡើង ចូរបរិភោគបាយផឹកទឹកតាំងឲ្យគេបំរើទៅ កាលបើអ្នកបរិភោគបាយ
ផឹកទឹក ឲ្យគេបំរើ បរិភោគកាមហើយ ចូរធ្វើបុណ្យតាមស្រេចចិត្តចុះ
មាតាបិតាមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទុកជាដល់ស្លាប់ក៏
មាតាបិតាមិនចង់ព្រាត់ប្រាសចាកអ្នកទេ ចំណង់បើអ្នកនៅរស់ (យ៉ាង
នេះ) តើមាតាបិតានឹងអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសដូចម្តេចបាន ។
សូម្បីគំរប់បីដងដែរ រដ្ឋបាលកុលបុត្រក៏នៅតែស្ងៀម ។ លំដាប់នោះ
ពួកសំឡាញ់របស់រដ្ឋបាលកុលបុត្រ ចូលទៅរកមាតាបិតា របស់រដ្ឋបាល
កុលបុត្រ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតាបិតា របស់រដ្ឋ-
បាលកុលបុត្រយ៉ាងនេះថា បពិត្រអ្នកជាម្តាយឪពុក រដ្ឋបាលកុលបុត្រ
នុ៎ះ នៅតែដេកលើទីដែលគ្មានក្រាលកម្រាលអ្វី ។ [illegible]

ភូមិយា និបន្នោ ឥធេវ មេ មរណំ ភវិស្សតិ បព្វជ្ជា វាតិ សចេ តុម្ហេ រដ្ឋបាលំ កុលបុត្តំ នានុជានិស្សថ អគារស្មា អនគារិយំ បព្វជ្ជាយ តត្ថេវ មរណំ ភវិស្សតិ សចេ បន តុម្ហេ រដ្ឋបាលំ កុលបុត្តំ អនុជានិស្សថ អគារស្មា អនគារិយំ បព្វជ្ជាយ បព្វជិតម្បិ នំ ទក្ខិស្សថ សចេ រដ្ឋបាលោ កុលបុត្តោ នាភិរមិស្សតិ អគារស្មា អនគារិយំ បព្វជ្ជាយ កា តស្ស អញ្ញា គតិ ភវិស្សតិ ឥធេវ បច្ចាគមិស្សតិ អនុជានាថ រដ្ឋបាលំ កុលបុត្តំ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។

(១៩២) អនុជានាម តាតា រដ្ឋបាលំ កុលបុត្តំ អគារស្មា អនគារិយំ បព្វជ្ជាយ បព្វជិតេន ច បន តេ មាតាបិតរោ ឧទ្ទស្សេតព្វាតិ អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា យេន រដ្ឋបាលោ កុលបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា រដ្ឋបាលំ កុលបុត្តំ ឯតទវោចុំ អនុញ្ញាតោសិ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយ បព្វជិតេន ច បន តេ មាតាបិតរោ ឧទ្ទស្សេតព្វាតិ ។



ដោយតាំងចិត្តថា កាត្តាអញនឹងស្លាប់ក្នុងទីនេះឬនឹងបានបួស បើអ្នកទាំងឡាយមិនយល់ព្រមឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួសទេ រដ្ឋបាលកុលបុត្រ មុខជានឹងស្លាប់ក្នុងទីនោះមិនខានឡើយ ពួកយើងទុំយល់ថា បើអ្នកទាំងឡាយ យល់ព្រម ឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួស គង់តែនឹងបានឃើញរដ្ឋបាលកុលបុត្រ ដែលទៅជាអ្នកបួសតទៅ បើរដ្ឋបាលកុលបុត្រមិនត្រេកអរក្នុងភេទជាអ្នកបួសហើយ រដ្ឋបាលកុលបុត្រនោះ នឹងមានគតិឯណាទៅទៀត ដូចម្ដេចបាន មុខជានឹងត្រឡប់មកក្នុងទីនេះវិញមិនខាន សូមអ្នកទាំងឡាយ អនុញ្ញាតឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួសចុះ ។

[១៨៦] មាតាបិតា របស់រដ្ឋបាលកុលបុត្រ និយាយថា នែអ្នកទាំងឡាយ យើងយល់ព្រមឲ្យរដ្ឋបាលកុលបុត្រ ចេញចាកផ្ទះទៅបួសហើយ តែថារដ្ឋបាលបួសរួចហើយ ត្រូវឲ្យមាតាបិតាបានឃើញផង ។ លំដាប់នោះឯង ពួកសំឡាញ់របស់រដ្ឋបាលកុលបុត្រ ចូលទៅរករដ្ឋបាលកុលបុត្រ លុះចូលទៅដល់ហើយ និយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា មាតាបិតារបស់អ្នក យល់ព្រមឲ្យអ្នកចេញចាកផ្ទះទៅបួសហើយ តែថា បើអ្នកបួសរួចហើយ ត្រូវឲ្យមាតាបិតាបានឃើញផង ។

(១៨៣) អថខោ រដ្ឋបាលោ កុលបុត្តោ ឧដ្ឋហិត្វា ពលំ គាហេត្វា(១) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រដ្ឋបាលោ កុលបុត្តោ ភគវន្តំ ឯតទវោច អនុញ្ញាតោម្ហិ អហំ(២) ភន្តេ មាតាបិតូហិ អគារស្មា អនគារិយំ បព្វជ្ជាយ បព្វាជេតុ មំ ភគវាតិ ។ អលត្ថ ខោ រដ្ឋបាលោ កុលបុត្តោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ ។ អថខោ ភគវា អចិរូបសម្បន្នេ អាយស្មន្តេ រដ្ឋបាលេ អឌ្ឍមាសូបសម្បន្នេ ថុល្លកោដ្ឋិតេ យថាភិរន្តំ វិហរិត្វា យេន សាវត្ថី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។

(១៨៤) តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា រដ្ឋបាលោ ឯកោ វូបកដ្ឋោ អប្បមត្តោ

១ ឱ. ម. គាហេត្វា ។ ២ ឱ. ម. អនុញ្ញាតោ អហំ ។



(១៨៣) គ្រានោះ រដ្ឋបាលកុលបុត្រ ក្រោកឡើង ហើយសម្រាកកំឡាំង រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះរដ្ឋបាលកុលបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាបុគ្គលដែលមាតាបិតា យល់ព្រម ឲ្យចេញចាកផ្ទះមកបួសហើយ សូមព្រះមានព្រះភាគទ្រង់បំបួសខ្ញុំព្រះអង្គ ។ រដ្ឋបាលកុលបុត្រក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ លំដាប់នោះឯង កាលបើរដ្ឋបាលមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន បានឧបសម្បទាត្រឹមកន្លះខែ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងថុល្លកោដ្ឋិតនិគម សមគួរតាមព្រះអធ្យាស្រ័យ ហើយទ្រង់ស្តេចចេញទៅក្រុងសាវត្ថី កាលទ្រង់ព្រះពុទ្ធដំណើរទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថី ។

(១៨៤) បានឮសេចក្តីដំណាលថា ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរដ្ឋបាលមានអាយុ បានចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនធ្វេសប្រហែស មានព្យាយាមដុតបង់ គឺ

អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ខោ បនាយស្មា រដ្ឋបាលោ អរហតំ អហោសិ ។

(២៩៨) អថខោ អាយស្មា រដ្ឋបាលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា រដ្ឋបាលោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ មាតាបិតរោ ឧទ្ទស្សេតុំ សចេ មំ ភគវា អនុជានាតីតិ ។ អថខោ[១] អាយស្មតោ រដ្ឋបាលស្ស ចេតសា ចេតោ បរិច្ច មនសាកាសិ យទា[២] ភគវា អញ្ញាសិ អភព្វោ ខោ រដ្ឋបាលោ កុលបុត្តោ សិក្ខំ បច្ចក្ខាយ

១ ឱ. ម. អថខោ ភគវា ។ ២ ឱ. យតោ ។



កិលេស បញ្ជូនចិត្តទៅ (កាន់ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ទៅបួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា (ព្រះរដ្ឋបាល) ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយបញ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយកិរិយាបថទាំង ៤ ដោយមិនយូរប៉ុន្មានទេ លោកបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចារ្យបាននៅចប់ហើយ កិច្ចដែលត្រូវធ្វើ ក៏បានធ្វើហើយ គ្មានកិច្ចដទៃក្រៅពីនេះតទៅទៀតទេ ។ ព្រះរដ្ឋបាលមានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។

(២៩៨) លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយអង្គុយ ក្នុងទីដ៏សមគួរ ។ ព្រះរដ្ឋបាលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើព្រះមានបុណ្យ ទ្រង់អនុញ្ញាតខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នានឹងទៅឲ្យមាតាបិតាបានឃើញផង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្ទង់មើលចិត្ត របស់រដ្ឋបាលមានអាយុ ដោយព្រះទ័យរបស់ព្រះអង្គ ហើយទ្រង់ធ្វើទុកក្នុងព្រះទ័យ តាមន័យដែលទ្រង់បានជ្រាបថា រដ្ឋបាលកុលបុត្រជាបុគ្គលមិនគួរនឹងលះបង់សិក្ខា

ហីនាយាវត្តិតុន្តិ ។ អថខោ ភគវា អាយស្មន្តំ រដ្ឋបាលំ អាមន្តេសិ យស្សទានិ(១) ត្វំ រដ្ឋបាល កាលំ មញ្ញសីតិ ។ អថខោ អាយស្មា រដ្ឋបាលោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន ថុល្លកោដ្ឋិតំ(២) តេន ចារិកំ បក្កាមិ ។ អនុបុព្វេន ចារិកំ ចរមានោ យេន ថុល្លកោដ្ឋិតំ(៣) តទវសរិ ។

(៤៨៦) តត្រ សុទំ អាយស្មា រដ្ឋបាលោ ថុល្លកោដ្ឋិតេ វិហរតិ រញ្ញោ កោរព្យស្ស(៤) មិគាចីរេ(៥) ។ អថខោ អាយស្មា រដ្ឋបាលោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ថុល្លកោដ្ឋិតំ បិណ្ឌាយ បាវិសិ ។ ថុល្លកោដ្ឋិតេ សបទានំ បិណ្ឌាយ ចរមានោ យេន សកបិតុ និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន អាយស្មតោ រដ្ឋបាលស្ស បិតា មជ្ឈិមាយ ទ្វារសាលាយ ឧល្លិខាបេតិ ។

១ ឱ. ម. យស្សទានិ ត្វំ ។ ២-៣ ម. ថុល្លកោដ្ឋិតោ ។ ៤ ឱ. កោរព្យស្ស ។ ៥ ម. មិគចីរេ ។



ហើយត្រឡប់ទៅកាន់ហីនភេទវិញទេ ។ ទើបព្រះមានជោគ ទ្រង់ត្រាស់ទៅនឹងរដ្ឋបាលមានអាយុយ៉ាងនេះថា ម្នាលរដ្ឋបាល អ្នកសំគាល់នូវកាលដ៏សមគួរក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ក្រោកចាកអាសនះហើយថ្វាយបង្គំព្រះមានជោគ ធ្វើប្រទក្សិណហើយ ក៏ទុកដាក់សេនាសនះស្រេចហើយ កាន់យកបាត្រនឹងចីវរចេញតម្រង់ទៅថុល្លកោដ្ឋិតនិគម ត្រាច់ទៅកាន់ចារិកតាមលំដាប់ ហើយក៏បានដល់ទៅថុល្លកោដ្ឋិតនិគមនោះ ។

(៤៨៦) មានសេចក្តីដំណាលថា ព្រះរដ្ឋបាលដ៏មានអាយុនៅសំណាក់ក្នុងឧទ្យានឈ្មោះមិគាចីរៈ របស់ព្រះបាទកោរព្យៈ ជិតថុល្លកោដ្ឋិតនិគមនោះ ។ ក្នុងលំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រនឹងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងថុល្លកោដ្ឋិតនិគម ។ កាលលោកត្រាច់ទៅបិណ្ឌបាតតាមលំដាប់ត្រកូល ក្នុងថុល្លកោដ្ឋិតនិគម រៀងទៅដល់ទីនៅអាស្រ័យរបស់បិតានៃខ្លួន ។ ចុះក្នុងសម័យនោះឯង បិតារបស់ព្រះរដ្ឋបាលមានអាយុ ក៏កំពុងតែឲ្យជាងកោរកោរ ក្នុងរោងទ្វារកណ្តាល ។

អទ្ទសា ខោ អាយស្មតោ រដ្ឋបាលស្ស បិតា អាយស្មន្តំ រដ្ឋបាលំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ឯតទវោច ឥមេហិ មុណ្ឌកេហិ សមណកេហិ អម្ហាកំ ឯកបុត្តកោ បិយោ មនាបោ បព្វាជិ-តោតិ ។ អថខោ អាយស្មា រដ្ឋបាលោ សកបិតុ និវេសនេ នេវ ទានំ អលត្ថ ន បច្ចក្ខានំ អញ្ញទត្ថុ(១) អក្កោសមេវ អលត្ថ ។

[១៩៧] តេន ខោ បន សមយេន អាយស្មតោ រដ្ឋបាលស្ស ញាតិទាសី អាភិទោសិកំ កុម្មាសំ(២) ឆឌ្ឌេតុកាមា ហោតិ ។ អថខោ អាយស្មា រដ្ឋបាលោ តំ ញាតិទាសឹ ឯតទវោច សចេ តំ ភគិនិ ឆឌ្ឌនីយ-ធម្មំ ឥធ មេ បត្តេ អាកិរាតិ ។ អថខោ អាយស្មតោ រដ្ឋបាលស្ស ញាតិទាសី តំ អាភិទោសិកំ កុម្មាសំ អាយស្មតោ រដ្ឋបាលស្ស បត្តេ អាកិរន្តី ហត្ថានញ្ច បាទានញ្ច សរស្ស ច និមិត្តំ អគ្គហេសិ ។

១ ឱ. ប. អញ្ញទត្ថុ ។ ២ ម. បូតិកុម្មាសំ ។



បិតារបស់ព្រះរដ្ឋបាល មានអាយុ បានឃើញព្រះរដ្ឋបាលមានអាយុ កំពុងតែនិមន្តមកអំពីចម្ងាយ លុះឃើញហើយ ក៏និយាយពាក្យយ៉ាងនេះថា ពួកស្រមណ៍ត្រងោលទាំងនេះហើយ ដែលបំបួសកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្ត របស់យើង ។ គ្រានោះឯង ព្រះរដ្ឋបាលមានអាយុ មិនបាននូវទាន ទាំងមិនបាននូវពាក្យប្រាប់មកវិញ ក្នុងលំនៅរបស់បិតានៃខ្លួនសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះឯង ។

[១៩៧] ទទួលបួនសម័យនោះឯង នាងទាសីរបស់ញាតិនៃរដ្ឋបាល មានអាយុ កំពុងមានបំណងនឹងចាក់ចោលនំកុម្មាសផ្អូម ។ គ្រានោះ ព្រះរដ្ឋបាលមានអាយុ និយាយនឹងខ្ញុំស្រីរបស់ញាតិនោះ យ៉ាងនេះថា នែនាង បើរបស់នោះជារបស់ត្រូវចោល ចូរនាងចាក់មកក្នុងបាត្ររបស់អាត្មានេះចុះ ។ លំដាប់នោះ ខ្ញុំស្រីរបស់ញាតិរបស់ព្រះរដ្ឋបាលមានអាយុ កំពុងចាក់នំកុម្មាសផ្អូមនោះ ទៅក្នុងបាត្ររបស់ព្រះរដ្ឋបាលមានអាយុ ហើយបានស្គាល់ជាក់នូវដៃជើងនិងសំឡេង របស់ព្រះរដ្ឋបាលនោះច្បាស់ ។

អថខោ អាយស្មតោ រដ្ឋបាលស្ស ញាតិទាសី យេនាយស្មតោ រដ្ឋបាលស្ស មាតា តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ រដ្ឋបាលស្ស មាតរំ ឯតទវោច យគ្ឃយ្យេ ជានេយ្យាសិ អយ្យបុត្តោ រដ្ឋបាលោ អនុប្បត្តោតិ ។ សចេ ជេ សច្ចំ ភណសិ អទាសឹ តំ ករោមីតិ(១) ។ អថខោ អាយស្មតោ រដ្ឋបាលស្ស មាតា យេនាយស្មតោ រដ្ឋបាលស្ស បិតា តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតោ រដ្ឋបាលស្ស បិតរំ ឯតទវោច យគ្ឃេ គហបតិ ជានេយ្យាសិ រដ្ឋបាលោ កិរ កុលបុត្តោ អនុប្បត្តោតិ ។

(១៩៨) តេន ខោ បន សមយេន អាយស្មា រដ្ឋបាលោ តំ អាភិទោសិកំ កុម្មាសំ អញ្ញតរំ កុដ្ឌំ និស្សាយ បរិភុញ្ជតិ ។ អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា យេនាយស្មា រដ្ឋបាលោ តេនុបសង្កមិ

១ ឧ. សេសិ អទាសី ភវសីតិ ។ ម. សេសិ អទាសី ភវិស្សតិ ។



ពេលនោះ ទាសីបម្រើរបស់ញាតិ នៃព្រះរដ្ឋបាលមានអាយុ ចូលទៅរកមាតា របស់ព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងមាតា របស់ព្រះរដ្ឋបាលមានអាយុថា បពិត្រអ្នកម្ចាស់ សូមអ្នកជ្រាប ព្រោះព្រះរដ្ឋបាលជាអយ្យបុត្រ និមន្តមកដល់ហើយ ។ មាតារបស់ព្រះរដ្ឋបាលនិយាយថា នែហង បើឯងនិយាយពាក្យពិតមែន អញនឹងលែងឯងរួចជាអ្នកជា ។ ទើបមាតារបស់ព្រះរដ្ឋបាល មានអាយុ ចូលទៅរកបិតា របស់ព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងបិតា របស់ព្រះរដ្ឋបាលមានអាយុ យ៉ាងនេះថា បពិត្រគហបតី សូមអ្នកជ្រាប ឮថារដ្ឋបាលកុលបុត្រ និមន្តមកដល់ហើយ ។

(១៩៨) សម័យនោះឯង ព្រះរដ្ឋបាលមានអាយុ កំពុងឆាន់នំកុម្មាសផ្អូមនោះ ប្រែបជញ្ជាំងសាលាមួយ ។ លំដាប់នោះ បិតារបស់ព្រះរដ្ឋបាលមានអាយុ ចូលទៅរកព្រះរដ្ឋបាលមានអាយុ លុះចូល

ឧបសង្កមិត្វា អាយស្មន្តំ រដ្ឋបាលំ ឯតទវោច អត្ថិ នាម តាត រដ្ឋបាល អាភិទោសិកំ កុម្មាសំ បរិភុញ្ជិស្សសិ ននុ តាត រដ្ឋបាល សកំ គេហំ គន្តព្វន្តិ ។ កុតោ នោ គហបតិ អម្ហាកំ គេហំ អគារស្មា អនគារិយំ បព្វជិតានំ អនគារា(១) មយំ គហបតិ អគមម្ហា(២) ខោ តេ គហបតិ គេហំ តត្ថ នេវ ទានំ អលត្ថម្ហា ន បច្ចក្ខានំ អញ្ញទត្ថុ អក្កោសមេវ អលត្ថម្ហាតិ ។ ឯហិ តាត រដ្ឋបាល ឃរំ គមិស្សាមាតិ ។ អលំ គហបតិ កតំ មេ អជ្ជ ភត្តកិច្ចន្តិ(៣) ។ តេនហិ តាត រដ្ឋបាល អធិវាសេហិ ស្វាតនាយ ភត្តន្តិ ។ អធិវាសេសិ ខោ អាយស្មា រដ្ឋបាលោ តុណ្ហីភាវេន ។

(១៩៩) អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា អាយស្មតោ រដ្ឋបាលស្ស អធិវាសនំ វិទិត្វា យេន សកំ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា មហន្តេន គោមយេន បឋវិយា ឧបលិម្បេត្វា

១ ម. អនគារា ។ ២ ម. អគមម្ហ ។ ៣ ម. ភត្តកិច្ចំ ។



ទៅដល់ហើយ ក៏និយាយនឹងរដ្ឋបាលមានអាយុយ៉ាងនេះថា នែរដ្ឋបាលកូន មានដែរឬ លោកមកឆាន់នំកុម្មាសផ្អូមវិញ រដ្ឋបាលកូន គួរតែទៅឯផ្ទះរបស់ខ្លួនវិញ ។ ព្រះរដ្ឋបាលឆ្លើយថា នែគហបតី ពួកយើងអ្នកបួសដែលចេញចាកផ្ទះទៅបួសហើយ នឹងមានផ្ទះមកពីណា នែគហបតី ព្រោះពួកយើងគ្មានផ្ទះទេ នែគហបតី អាត្មាបានទៅដល់ផ្ទះរបស់អ្នកហើយ តែមិនបានទូវទានផង មិនបានទូវការនិយាយប្រាប់វិញផង ក្នុងផ្ទះរបស់អ្នកនោះសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះឯង ។ រដ្ឋបាលកូន លោកចូរមក យើងនឹងទៅផ្ទះ ។ ម្នាលគហបតី ថ្ងៃនេះអាត្មាឆាន់រួចហើយ ។ រដ្ឋបាលកូន បើដូច្នោះ សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។ ព្រះរដ្ឋបាលមានអាយុ ក៏ទទួលនិមន្តដោយតុណ្ហីភាព ។

(១៩៩) គ្រានោះ បិតារបស់ព្រះរដ្ឋបាលមានអាយុ ដឹងច្បាស់ថា ព្រះរដ្ឋបាលមានអាយុ ទទួលនិមន្តហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួនដែលធ្លាប់នៅ លុះចូលទៅដល់ហើយ ប្រើមនុស្សឲ្យលាបដី ដោយ

មហន្តំ ហិរញ្ញសុវណ្ណស្ស បុញ្ជំ ការាបេត្វា ទ្វេ បុញ្ជេ ការាបេត្វា ឯកំ ហិរញ្ញស្ស ឯកំ សុវណ្ណស្ស មហន្តា បុញ្ជា អហេសុំ ។ ឱរតោ ឋិតោ បុរិសោ បារតោ ឋិតំ បុរិសំ ន បស្សតិ តថា បារតោ ឋិតោ ឱរតោ ឋិតំ ។ តេ បុញ្ជេ កិលញ្ជេហិ បដិច្ឆាទាបេត្វា មជ្ឈេ អាសនំ បញ្ញាបេត្វា តិរោករណីយំ បរិក្ខិបិត្វា អាយស្មតោ រដ្ឋបាលស្ស បុរាណទុតិយិកេ អាមន្តេសិ(១) ឯថ តុម្ហេ វធុកេ យេន អលង្ការេន អលង្កតា បុព្វេ បុត្តស្ស រដ្ឋបាលស្ស(២) បិយា ហោថ មនាបា តេន អលង្ការេន អលង្ករោថាតិ ។ អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា អាយស្មតោ រដ្ឋបាលស្ស កាលំ អារោចេសិ កាលោ តាត រដ្ឋបាល និដ្ឋិតំ ភត្តន្តិ ។

---

១ ពោធិយមញ្ញាយត្ថកេសុ អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា អាយស្មតោ រដ្ឋបាលស្ស ឥធិវសនំ វិទិត្វា យេន សកំ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា មហន្តំ ហិរញ្ញសុវណ្ណស្ស បុញ្ជំ ការាបេត្វា កិលញ្ជេហិ បដិច្ឆាទាបេត្វា អាយស្មតោ រដ្ឋបាលស្ស បុរាណទុតិយិកេ អាមន្តេសីតិ ឈាបក្ខរេ ទិស្សតិ ។ ២ ម. បុត្ត រដ្ឋបាលស្ស កុលបុត្តស្ស ។



រកបម៉ាតាស្រស់ រួចឲ្យគរគំនរប្រាក់និងមាសធំ ១ ធ្វើឲ្យជាពីរគំនរគឺ ប្រាក់ ១ គំនរ មាស ១ គំនរ ជាគំនរធំ ៗ ។ បុរសដែលឈរខាងអាយ មើលទៅបុរសឈរខាងនាយមិនឃើញ បុរសដែលឈរខាងនាយមើលមកបុរសឈរខាងអាយក៏មិនឃើញដូចគ្នា ហើយឲ្យបិទបាំងគំនរទាំងពីរនោះដោយកន្ទេល ឲ្យក្រាលអាសនៈទុកត្រង់កណ្ដាល រួចឲ្យព័ទ្ធព័ទ្ធដោយរបស់ ដែលត្រូវធ្វើពីខាងក្រៅ ហើយហៅពួកស្រីជាគូពីមុនរបស់ព្រះរដ្ឋបាលមានអាយុមកបង្គាប់ថា នែកូនស្រី ឯងរាល់គ្នាចូលមកនេះ គ្រឿងប្រដាប់ណាដែលឯងរាល់គ្នាស្អិតស្អាង ហើយជាទីស្រឡាញ់ពេញចិត្តរបស់រដ្ឋបាលកូនអញកាលពីដើម ត្រូវឯងរាល់គ្នាស្អិតស្អាងគ្រឿងប្រដាប់នោះចុះ ។ លំដាប់តទៅ លុះកន្លងរាត្រីនោះទៅ បិតារបស់ព្រះរដ្ឋបាលមានអាយុ ឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ក្នុងលំនៅរបស់ខ្លួនហើយ ប្រាប់នូវកាលដល់ព្រះរដ្ឋបាលមានអាយុថា រដ្ឋបាលកូន កាលគួរហើយ ភត្តសម្រេចហើយ ។

អថខោ អាយស្មា រដ្ឋបាលោ បុព្វណ្ហសមយំ និវា-
សេត្វា បត្តចីវរមាទាយ យេន សកបិតុ និវេសនំ
តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។
អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា តំ ហិរញ្ញ-
សុវណ្ណស្ស បុញ្ជំ វិវរាបេត្វា អាយស្មន្តំ រដ្ឋបាលំ
ឯតទវោច ឥទំ តេ តាត រដ្ឋបាល មត្តិកំ(១) ធនំ
អញ្ញំ បេត្តិកំ(២) អញ្ញំ បេតាមហំ(៣) សក្កា តាត
រដ្ឋបាល ភោគេ ច ភុញ្ជិតុំ បុញ្ញានិ ច កាតុំ ឯហិ ត្វំ
តាត រដ្ឋបាល សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ភោ-
គេ ច ភុញ្ជស្សុ បុញ្ញានិ ច ករោហីតិ ។ សចេ មេ ត្វំ
គហបតិ វចនំ ករេយ្យាសិ ឥទំ ហិរញ្ញសុវណ្ណស្ស
បុញ្ជំ សកដេសុ(៤) អារោបេត្វា និព្វាហាបេត្វា មជ្ឈេ
គង្គាយ នទិយា សោតេ ឱសីទាបេយ្យាសិ(៥) តំ
កិស្ស ហេតុ(៦) ឧប្បជ្ជិស្សន្តិ ហិ តេ គហបតិ តតោ-
និទានំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។
អថខោ អាយស្មតោ រដ្ឋបាលស្ស បុរាណទុតិយិកា
បច្ចេកំ បាទេសុ គហេត្វា អាយស្មន្តំ រដ្ឋបាលំ ឯតទ-

១ ម. អត្តុមត្តិកំ ។ ២ ម. បិត្តិកំ ។ ៣ ឱ. ម. បិតាមហំ ។ ៤ ម. សកដេ ។
៥ ឱ. ម. ឱបិលាបេយ្យាសិ ។ ៦ ម. ហេតុ ឃេ ។



ចំណែកខាងព្រះរដ្ឋបាលមានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រនិង
ចីវរក្នុងបុព្វណ្ហសម័យ ហើយនិមន្តចូលទៅត្រង់លំនៅរបស់បិតានៃខ្លួន
លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក ។
ទើបបិតារបស់ព្រះរដ្ឋបាលមានអាយុ ក៏ឲ្យបើកគំនរប្រាក់និងមាសនោះ
ហើយនិយាយនឹងព្រះរដ្ឋបាលមានអាយុ យ៉ាងនេះថា នែរដ្ឋបាលកូន
ទ្រព្យនេះជារបស់ខាងមាតាលោក ទ្រព្យជារបស់ខាងបិតាដោយឡែក
នៅមានរបស់ខាងជីតា ដោយឡែកទៀត រដ្ឋបាលកូន លោកអាច
ប្រើប្រាស់ភោគៈទាំងឡាយផង ធ្វើបុណ្យផង នែរដ្ឋបាលកូន ចូរ
លោកមក ចូរលាសិក្ខាវិលត្រឡប់មកភេទទាប ហើយប្រើប្រាស់
ភោគៈទាំងឡាយផង ធ្វើបុណ្យទាំងឡាយផងចុះ ។ បពិត្រគហបតី
បើញោមធ្វើតាមពាក្យរបស់អាត្មា ញោមគួរប្រើមនុស្ស ឲ្យដឹកគំនរ
ប្រាក់មាសនេះ ដាក់ក្នុងរទេះ ហើយយកទៅដាក់ចោល ក្នុងកណ្ដាល
ខ្សែទឹកទន្លេគង្គា ហេតុអ្វីបានជាអាត្មាថាដូច្នោះ គហបតី ព្រោះថា
សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីចង្អៀត
ចង្អល់ មុខជានឹងកើតឡើងដល់ញោម ព្រោះតែទ្រព្យទាំងនោះជា
ហេតុ ។ ពេលនោះ ពួកស្រីជាគូពីមុន របស់ព្រះរដ្ឋបាលមាន
អាយុ ចាប់ព្រះបាទម្នាក់ៗ ហើយនិយាយនឹងព្រះរដ្ឋបាល មាន

វោចុំ កីទិសា នាម តា អយ្យបុត្ត អច្ឆរាយោ យាសំ ត្វំ ហេតុ ព្រហ្មចរិយំ ចរសីតិ ។ ន ខោ មយំ ភគិនិ អច្ឆរានំ ហេតុ ព្រហ្មចរិយំ ចរាមាតិ ។ ភគិនិវាទេន នោ អយ្យបុត្តោ រដ្ឋបាលោ សមុទាចរតីតិ តត្ថេវ មុច្ឆិតា បបតឹសុ ។ អថខោ អាយស្មា រដ្ឋបាលោ បិតរំ ឯតទវោច សចេ គហបតិ ភោជនំ ទាតព្វំ ទេថ មា នោ វិហេឋេថាតិ ។ ភុញ្ជ តាត រដ្ឋបាល និដ្ឋិតំ ភត្តន្តិ ។ អថខោ អាយស្មតោ រដ្ឋបាលស្ស បិតា អាយស្មន្តំ រដ្ឋបាលំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។

[៦០០] អថខោ អាយស្មា រដ្ឋបាលោ ភុត្តាវី ឱនីតបត្តបាណី ឋិតកោវ ឥមា គាថា អភាសិ

បស្ស ចិត្តកតំ ពិម្ពំ
អរុកាយំ សមុស្សិតំ



អាយុយ៉ាងនេះថា បពិត្រព្រះអយ្យបុត្រ លោកប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុ(ចង់បាន)ពួកស្រីអប្សរណា ពួកស្រីអប្សរទាំងនោះ តើល្អដូចម្ដេចទៅ ។ ម្នាលនាង អាត្មាមិនមែនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុ(ចង់បាន)ពួកស្រីអប្សរទេ ។ ពួកស្រីជាគូគីមុនគិតថា រដ្ឋបាលជាអយ្យបុត្រហៅពួកយើង ដោយពាក្យថា នាង ដូច្នេះ ក៏ជ្រប់ដួលត្រង់ទីនោះឯង ។ ទើបព្រះរដ្ឋបាលមានអាយុ និយាយនឹងបិតាថា បពិត្រគហបតី បើញោមត្រូវឲ្យភោជន(ក៏ឲ្យមក) កុំបៀតបៀនអាត្មាឡើយ ។ រដ្ឋបាលកូន សូមលោកនិមន្តឆាន់ចុះ ភត្តសម្រេចហើយ ។ គ្រានោះ បិតារបស់ព្រះរដ្ឋបាលមានអាយុ បានតាក់តែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ឲ្យព្រះរដ្ឋបាលមានអាយុឆាន់ដោយដៃខ្លួនឯងត្រាតែឆ្អែត ។

(៦០០) លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ឆាន់រួចលាងដៃហើយ ឈរសំដែងគាថាទាំងឡាយនេះថា

ញោមចូរមើលនូវអត្តភាព ដែលសត្វតាក់តែងវិចិត្រហើយ ជាទី
ប្រជុំនៃដំបៅ (៩ ទ្វារ) ផ្គុំឡើង (ដោយឆ្អឹង ៣០០ កំណាត់)

អាតុរំ ពហុសង្កប្បំ
យស្ស នត្ថិ ធុវំ ឋិតិ
បស្ស ចិត្តកតំ រូបំ
មណិនា កុណ្ឌលេន ច
អដ្ឋិតចេន ឱនទ្ធំ
សហ វត្ថេភិ(១) សោភតិ
អលត្តកកតា បាទា
មុខំ ចុណ្ណកមក្ខិតំ
អលំ ពាលស្ស មោហាយ
នោ ច បារគវេសិនោ
អដ្ឋាបទកតា កេសា
នេត្តា អញ្ជនមក្ខិតា
អលំ ពាលស្ស មោហាយ
នោ ច បារគវេសិនោ

១. វត្ថេហិ ។





ក្តៅក្រហាយ ដែលជនច្រើនគ្នាតែងត្រេកអរ ជាកាយមិនទៀងទាត់ឋិតថេរឡើយ ។ ចូរមើលរូប ដែលសង្ហារវិចិត្រហើយ (ប្រកប)ដោយកុណ្ឌលមណី ដែលរួបរឹតហើយដោយឆ្អឹងនឹងស្បែក ល្អដោយសារតែសំពត់ ជើងទាំងឡាយវិចិត្រហើយដោយទឹកល័ខ មុខលាបហើយដោយគ្រឿងលំអិត អាចឲ្យមនុស្សពាលវង្វេងបាន តែមិនអាចបំភាន់ដល់អ្នកស្វែងរកត្រើយ គឺព្រះនិព្វានបានឡើយ សក់ទាំងឡាយ ដែលវិចិត្រហើយឲ្យមានសណ្ឋានដូចជាក្រឡាបទ្រន្ត នែត្រទាំងឡាយ លាបហើយដោយថ្នាំសម្រាប់បន្តក់ ល្មមឲ្យបុគ្គលពាលភាន់ច្រឡំបាន តែមិនអាចបំភាន់អ្នកស្វែង

អញ្ជនីវ នវា ចិត្តា

បូតិកាយោ អលង្កតោ

អលំ ពាលស្ស មោហាយ

នោ ច បារគវេសិនោ

ឱទហិ មិគវោ បាសំ

នាសទា វាគុរំ មិគោ

ភុត្វា និវាបំ គច្ឆាមិ(១)

កន្ទន្តេ មិគពន្ធកេតិ ។

អថខោ អាយស្មា រដ្ឋបាលោ ឋិតកោវ ឥមា គាថា ភាសិត្វា យេន រញ្ញោ កោរព្យស្ស មិគាចីរំ តេនុបសង្កមិ ឧបសង្កមិត្វា អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសីទិ ។

[៦០១] អថខោ រាជា កោរព្យោ មិគវំ អាមន្តេសិ សោធេហិ មិគវ មិគាចីរំ ឧយ្យានភូមឹ គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ទេវាតិ ខោ មិគវោ រញ្ញោ កោរព្យស្ស បដិស្សុត្វា មិគាចីរំ សោធេន្តោ អទ្ទស អាយស្មន្តំ រដ្ឋបាលំ អញ្ញតរស្មឹ រុក្ខមូលេ ទិវាវិហារំ និសិន្នំ

១ ម. គច្ឆាម ។



ទៅត្រើយបានឡើយ កាយស្អុយដែលបានប្រដាប់ហើយដូចជាបំពង់ថ្នាំដាក់ភ្នែកយ៉ាងថ្មីវិចិត្រ អាចបំភាន់បុគ្គលពាលបាន តែមិនអាចបំភាន់អ្នកស្វែងរកត្រើយបានឡើយ ព្រានម្រឹគដាក់ខ្សែបន្ទាត់ជាអន្ទាក់ តែម្រឹគមិនជាប់បណ្តាក់ កាលបើព្រានអ្នកចងម្រឹគ កំពុងកន្ទក់កន្ទេញ យើងបរិភោគចំណីរួចហើយ ត្រឡប់ទៅវិញ(១) ។

លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ឈរសំដែងគាថាទាំងនេះហើយ ក៏និមន្តត្រង់ទៅឧទ្យានឈ្មោះមិគាចីរៈ របស់ព្រះបាទកោរព្យៈ លុះចូលទៅដល់ហើយ ក៏អង្គុយសម្រាក ក្នុងវេលាថ្ងៃ ក្បែរគល់ឈើ ១ ដើម ។

[៦០១] គ្រានោះ ព្រះរាជាកោរព្យៈ ត្រាស់ហៅឧយ្យានបាលឈ្មោះមិគវៈថា ម្នាលមិគវៈ ឯងចូររៀបចំឧយ្យានភូមិ ឈ្មោះមិគាចីរៈ យើងនឹងទៅមើលទីដ៏សប្បាយ ។ ឧយ្យានបាលឈ្មោះមិគវៈ ទទួលព្រះរាជឱង្ការព្រះបាទកោរព្យៈថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចហើយក៏រៀបចំឧទ្យានមិគាចីរៈ បានឃើញព្រះរដ្ឋបាលមានអាយុ កំពុងគង់សម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើ ១ ដើម លុះ

១ ព្រះរដ្ឋបាលពោលដោយប្រៀបមាតាបិតាជាដូចព្រានម្រឹគ... ។

ទិស្វាន យេន រាជា កោរព្យោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ កោរព្យំ ឯតទវោច សុទ្ធំ ខោ តេ ទេវ មិគាចីរំ អត្ថិ ចេត្ថ រដ្ឋបាលោ នាម កុល-បុត្តោ ឥមស្មិំយេវ ថុល្លកោដ្ឋិកេ អគ្គកុលិកស្ស បុត្តោ យស្ស ត្វំ អភិណ្ហំ កិត្តយមានោ អហោសិ សោ អញ្ញតរស្មិំ រុក្ខមូលេ ទិវាវិហារំ និសិន្នោតិ ។ តេនហិ សម្ម មិគវ អលន្ទានជ្ជ(១) ឧយ្យានភូមិយា តមេវ ទានិ មយំ ភវន្តំ រដ្ឋបាលំ បយិរុបាសិស្សាមាតិ ។ អថ ខោ រាជា កោរព្យោ យំ តត្ថ ខាទនីយំ ភោជនីយំ បដិយត្តំ តំ សព្វំ វិស្សជ្ជេថាតិ វត្វា ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ ថុល្លកោដ្ឋិកម្ហា និយ្យាសិ មហច្ចរាជានុភាវេន អាយស្មន្តំ រដ្ឋបាលំ ទស្សនាយ ។ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា

---

១ ឱ. ម. អលំ ទានជ្ជ ។



ឃើញហើយ ក៏ចូលទៅគាល់ព្រះបាទកោរព្យៈ លុះចូលទៅដល់ហើយ ក្រាបទូលព្រះបាទកោរព្យៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ឧទ្យានមិគាចីរៈរបស់ព្រះអង្គស្អាតបាតហើយ ប៉ុន្តែក្នុងឧទ្យាននោះ មានកុលបុត្រឈ្មោះរដ្ឋបាលជាកូនរបស់ត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិកនិគមនេះឯង ដែលព្រះអង្គតែងទ្រង់សរសើរដល់រឿយ ៗ នោះ (ឥឡូវ) លោកគង់សម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើ ១ ដើម ។ ព្រះបាទកោរព្យៈត្រាស់ថា ម្នាលមិគវៈសំឡាញ់ ល្មើយចុះ ដំណើរទៅកាន់ទីឧទ្យានថ្ងៃនេះ ឥឡូវនេះ គួរឈប់សិនចុះ ឥឡូវនេះ យើងនឹងទៅអង្គុយជិតព្រះរដ្ឋបាលដ៏ចំរើននោះវិញ ។ ទើបព្រះបាទកោរព្យៈត្រាស់ថា ចូរអ្នកទាំងឡាយចំណាយនូវខាទនីយភោជនីយាហារ ដែលបានតាក់តែងហើយ ទាំងអស់នោះចុះ ហើយព្រះអង្គទ្រង់ឲ្យទឹមយានដ៏ល្អ ៗ ឡើងកាន់យានល្អ បរចេញអំពីថុល្លកោដ្ឋិកនិគម ដោយយានល្អ ៗ ដោយរាជានុភាព នៃស្តេចជាធំ ដើម្បីទ្រង់ទតព្រះរដ្ឋបាលមានអាយុ ។ ទីដែលយានទៅបានត្រឹមណា

យានា បច្ចោរោហិត្វា បត្តិកោវ ឧស្សដាយ ឧស្សដាយ បរិសាយ យេនាយស្មា រដ្ឋបាលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា រដ្ឋបាលេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រាជា កោរព្យោ អាយស្មន្តំ រដ្ឋបាលំ ឯតទវោច ឥធ ភវំ រដ្ឋបាលោ ហត្ថត្ថរេ(១) និសីទតូតិ ។ អលំ មហារាជ និសីទ ត្វំ និសិន្នោ អហំ សកេ អាសនេតិ ។ និសីទិ ខោ រាជា កោរព្យោ បញ្ញត្តេ អាសនេ ។

(៦០២) និសជ្ជ ខោ រាជា កោរព្យោ អាយស្មន្តំ រដ្ឋបាលំ ឯតទវោច ចត្តារិមានិ ភោ រដ្ឋបាល បារិជុញ្ញានិ យេហិ បារិជុញ្ញេហិ សមន្នាគតា ឥធេកច្ចេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជន្តិ កតមានិ ចត្តារិ ជរាបារិជុញ្ញំ ព្យាធិបារិជុញ្ញំ ភោគបារិជុញ្ញំ ញាតិបារិជុញ្ញំ ។

១ ឱ. ម. ហត្ថត្ថរេ ។



ក៏ទ្រង់យានទៅដោយយានត្រឹមនោះ ហើយទ្រង់ចុះអំពីយាន យាងដោយព្រះបាទទទេ ដោយបរិស័ទដ៏ឧត្តម ចូលសំដៅទៅរកព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់រីករាយជាមួយនឹងព្រះរដ្ឋបាលមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទ្រង់ឈរក្នុងទីដ៏សមគួរ ។ លុះព្រះបាទកោរព្យៈទ្រង់ព្រះសណ្ឋិត ក្នុងទីដ៏សមគួរហើយ ទ្រង់មានព្រះឱង្ការនឹងព្រះរដ្ឋបាលមានអាយុ យ៉ាងនេះថា ព្រះរដ្ឋបាលដ៏ចំរើន និមន្តគង់លើកម្រាលដំរីនេះចុះ ។ ព្រះរដ្ឋបាលថ្វាយព្រះពរថា កុំឡើយមហារាជ សូមព្រះអង្គទ្រង់គង់ចុះ អាត្មាភាពអង្គុយលើអាសនៈជារបស់ខ្លួនហើយ ។ ព្រះបាទកោរព្យៈ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយហើយ ។

(៦០២) លុះព្រះបាទកោរព្យៈ ទ្រង់គង់ស្រួលហើយ ក៏មានព្រះរាជឱង្ការនេះ នឹងព្រះរដ្ឋបាលមានអាយុថា បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្តីសាបសូន្យ ៤ យ៉ាងនេះ ដែលពួកមនុស្សខ្លះ ក្នុងលោកនេះជួបប្រទះហើយ ក៏កោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស សេចក្តីសាបសូន្យ ៤ យ៉ាងតើដូចម្តេច គឺសេចក្តីសាបសូន្យព្រោះជរា ១ សេចក្តីសាបសូន្យព្រោះព្យាធិ ១ សេចក្តីសាបសូន្យភោគៈ ១ សេចក្តីសាបសូន្យញាតិ ១ ។

[៦០៣] កតមំ(១) ភោ វឌ្ឍមាន ជាតិបារិជុញ្ញំ ។ ឥធ ភោ វឌ្ឍមាន ឯកច្ចោ ជិណ្ណោ ហោតិ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ ន ខោ បន មយា សុករំ អនធិគតំ វា ភោគំ(២) អធិគន្តុំ អធិគតំ វា ភោគំ ផាតិំ កាតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ តេន ជាតិបារិជុញ្ញេន សមន្នាគតោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ឥទំ វុច្ចតិ ភោ វឌ្ឍមាន ជាតិបារិជុញ្ញំ ។ កថំ ខោ បន វឌ្ឍមានោ ឯតរហិ ទហរោ យុវា សុសុកាឡកេសោ

១ ម. កតមញ្ញ ។ ២ ម. ភោគ



[៦០៣] បពិត្រព្រះវឌ្ឍមានដ៏ចំរើន សេចក្តីសាបសូន្យព្រោះជាតតើដូចម្តេច ។ បពិត្រព្រះវឌ្ឍមានដ៏ចំរើន មនុស្សពួកខ្លះក្នុងលោកនេះ ជាមនុស្សដែលចំរើនហើយដោយវ័យ មានអាយុច្រើន ដល់នូវសេចក្តីថមថយដោយលំដាប់ ។ មនុស្សនោះពិចារណាឃើញច្បាស់ជាពិតថា ឥឡូវនេះអាត្មាអញ ចាស់គ្រាំគ្រា ចំរើនដោយវ័យ ចាស់មានអាយុច្រើន ដល់នូវសេចក្តីថមថយដោយលំដាប់ អាត្មាអញមិនងាយនឹងធ្វើឲ្យបាននូវភោគៈដែលមិនទាន់បានផង មិនអាចនឹងធ្វើភោគៈដែលគេបានហើយ ឲ្យចំរើនឡើងផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះសេចក្តីសាបសូន្យព្រោះជាតនោះហើយ ទើបបានកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស បពិត្រព្រះវឌ្ឍមានដ៏ចំរើន នេះហៅថាសេចក្តីសាបសូន្យព្រោះជាត ។ ដូចយ៉ាងព្រះវឌ្ឍមានដ៏ចំរើន ឥឡូវនេះនៅក្មេងកំឡោះ មានសក់ខ្មៅរលើប

ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា តំ ភោតោ រដ្ឋបាលស្ស ជរាបារិជុញ្ញំ នត្ថិ ។ កឹ ភវំ រដ្ឋបាលោ ញត្វា វា ទិស្វា វា សុត្វា វា អគារស្មា អនគារិយំ បព្វជិតោ ។

(៦០៥) កតមញ្ច ភោ រដ្ឋបាល ព្យាធិ-បារិជុញ្ញំ ។ ឥធ ភោ រដ្ឋបាល ឯកច្ចោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ឯតរហិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ ន ខោ បន មយា សុករំ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតឹ កាតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ តេន ព្យាធិបារិជុញ្ញេន សមន្នា-គតោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ឥទំ វុច្ចតិ ភោ រដ្ឋបាល ព្យាធិបារិជុញ្ញំ ។ ភវំ ខោ បន រដ្ឋបាលោ



ក៏គង់ប្រកបដោយវ័យដ៏ចំរើន ដែលជាបឋមវ័យ ព្រះរដ្ឋបាលដ៏ចំរើន មិនឈ្មោះថាមានសេចក្ដីសាបសូន្យព្រោះជរានោះទេ ។ ព្រះរដ្ឋបាលដ៏ចំរើន ដឹងហើយ ឃើញហើយ ឬឮហើយ បានជាចេញចាកផ្ទះទៅបួស ។

(៦០៦) បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្ដីសាបសូន្យព្រោះព្យាធិ តើដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន មនុស្សខ្លះក្នុងលោកនេះ ជាអ្នកមានអាពាធ ដល់នូវសេចក្ដីទុក្ខឈឺធ្ងន់ ។ មនុស្សនោះពិចារណាឃើញច្បាស់ថា ឥឡូវនេះ អាត្មាអញមានអាពាធ ដល់នូវសេចក្ដីទុក្ខឈឺធ្ងន់ថៃមពន់ អាត្មាអញមិនងាយនឹងធ្វើភោគៈ ដែលមិនទាន់បានឲ្យបានផង មិនអាចនឹងធ្វើភោគៈដែលបានហើយ ឲ្យបានចំរើនឡើងផង បើដូច្នោះគួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះសេចក្ដីសាបសូន្យព្រោះព្យាធិនោះហើយ ក៏កោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចំរើន នេះហៅថាសេចក្ដីសាបសូន្យព្រោះព្យាធិ ។ ចំណែកខាងព្រះរដ្ឋបាលដ៏ចំរើន

ឯតរហិ អប្បាពាធោ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ ត្ថិ ភោតោ រដ្ឋបាលស្ស ព្យាធិបារិជុញ្ញំ ឥតិ ។ កឹ ភវំ រដ្ឋបាលោ ញត្វា វា ទិស្វា វា សុត្វា វា អគារស្មា អនគារិយំ បព្វជិតោ ។

(២០៩) កតមញ្ច ភោ រដ្ឋបាល ភោគបារិជុញ្ញំ ។ ឥធ ភោ រដ្ឋបាល ឯកច្ចោ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ តស្ស តេ ភោគា អនុបុព្វេន បរិក្ខយំ គច្ឆន្តិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោ បុព្វេ អឌ្ឍោ អហោសឹ មហទ្ធនោ មហាភោគោ តស្ស មេ តេ ភោគា អនុបុព្វេន បរិក្ខយំ គតា ន ខោ បន មយា សុករំ អនធិគតេ វា ភោគេ អធិគន្តុំ អធិគតេ វា ភោគេ(១) ផាតឹ កាតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆា-ទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ

១ ម. អនធិគតា វា ភោគា អធិគន្តុំ អធិគតា វា ភោគា ។ ម. អនធិគតំ ... ភោគំ ។



ឥឡូវនេះ គ្មានអាពាធ ឥតទុក្ខ ប្រកបដោយគហណីធាតុ គឺកម្មជ-តេជោធាតុ(១) ក៏ក្ដៅល្មមស្មើ គឺមិនត្រជាក់ពេក មិនក្ដៅពេក ព្រះរដ្ឋបាលដ៏ចំរើន មិនមានសេចក្ដីសាបសូន្យព្រោះព្យាធិនោះទេ ។ ព្រះរដ្ឋបាលដ៏ចំរើន បានដឹង បានឃើញ ឬបានឮអ្វីហើយ បានជាចេញចាកផ្ទះទៅបួស ។

(២០៩) បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្ដីសាបសូន្យភោគៈ តើដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន មនុស្សខ្លះក្នុងលោកនេះ ជាមនុស្សស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើន តែភោគៈទាំងនោះ របស់អ្នកនោះ ក៏ដល់នូវការអស់ទៅ ដោយលំដាប់ ។ អ្នកនោះពិចារណាឃើញថា អាត្មាអញ ធ្លាប់ជាអ្នកស្ដុកស្ដម្ភ មានទ្រព្យច្រើន មានភោគៈច្រើនមកអំពីមុនហើយ តែភោគៈទាំងនោះរបស់អាត្មាអញនោះ បានដល់នូវការអស់ទៅ ដោយលំដាប់ហើយ ថែមទាំងអាត្មាអញមិនងាយនឹងធ្វើភោគៈដែលមិនទាន់បាន ឲ្យបានដោយងាយឡើយផង មិនងាយនឹងធ្វើភោគៈដែលបានហើយ ឲ្យចំរើនឡើងបានផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយ ចេញចាកផ្ទះទៅបួស ។ អ្នកនោះ ជួប

១ ភ្លើងធាតុ ដែលកើតអំពីកម្ម ។

តេន ភោគបារិជុញ្ញេន សមន្នាគតោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ឥទំ វុច្ចតិ ភោ រដ្ឋបាល ភោគបារិជុញ្ញំ ភវំ ខោ បន រដ្ឋបាលោ ឥមស្មិំ-យេវ ថុល្លកោដ្ឋិតេ អគ្គកុលិកស្ស បុត្តោ តំ ភោតោ រដ្ឋបាលស្ស ភោគបារិជុញ្ញំ នត្ថិ ។ កឹ ភវំ រដ្ឋបាលោ ញត្វា វា ទិស្វា វា សុត្វា វា អគារស្មា អនគារិយំ បព្វជិតោ ។

(៦០៦) កតមញ្ច ភោ រដ្ឋបាល ញាតិបារិជុញ្ញំ ។ ឥធ ភោ រដ្ឋបាល ឯកច្ចស្ស ពហូ ហោន្តិ មិត្តាមច្ចា ញាតិសាលោហិតា តស្ស តេ ញាតកា អនុបុព្វេន បរិក្ខយំ គច្ឆន្តិ ។ សោ ឥតិ បដិសញ្ចិក្ខតិ មមំ ខោ បុព្វេ ពហូ អហេសុំ មិត្តាមច្ចា ញាតិសាលោហិតា តស្ស មេ តេ(១) ញាតកា អនុបុព្វេន បរិក្ខយំ គតា ន ខោ បន មយា សុករំ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតិំ កាតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។

១ ម. តេតិ បទំ នត្ថិ ។



ប្រទះសេចក្ដីសាបសូន្យភោគៈនោះហើយ ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចំរើន នេះហៅថា សេចក្ដីសាបសូន្យភោគៈ ។ ចំណែកព្រះរដ្ឋបាលដ៏ចំរើន ជាកូនអ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនេះឯង ព្រះរដ្ឋបាលដ៏ចំរើន មិនឈ្មោះថា មានសេចក្ដីសាបសូន្យភោគៈទេ ។ ព្រះរដ្ឋបាលដ៏ចំរើន ដឹងហើយ ឃើញហើយ ឮហើយ បានជាចេញចាកផ្ទះទៅបួស ។

(៦០៦) បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្ដីសាបសូន្យញាតិតើដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន មនុស្សខ្លះក្នុងលោកនេះ មានពួកមិត្រ អាមាត្យ ញាតិសាលោហិតច្រើន ដល់ជាញាតិទាំងនោះរបស់អ្នកនោះ ក៏ដល់នូវសេចក្ដីព្រាត់ប្រាសទៅដោយលំដាប់ ។ អ្នកនោះពិចារណាឃើញច្បាស់ថា ពីដើម អាត្មាអញមានពួកមិត្រ អាមាត្យ ញាតិសាលោហិតច្រើន តែពួកដល់ជាញាតិទាំងនោះរបស់អាត្មាអញនោះ ក៏ដល់នូវសេចក្ដីព្រាត់ប្រាសទៅដោយលំដាប់ ដែលពិតអាត្មាអញ មិនងាយនឹងធ្វើភោគៈ ដែលមិនទាន់បានឲ្យបានផង មិនអាចនឹងធ្វើភោគៈ ដែលបានហើយឲ្យចំរើនឡើងបានផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។

សោ តេន ញាតិបារិជុញ្ញេន សមន្នាគតោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ឥទំ វុច្ចតិ ភោ រដ្ឋបាល ញាតិបារិជុញ្ញំ ។ ភោតោ ខោ បន រដ្ឋបាលស្ស ឥមស្មិំយេវ ថុល្លកោដ្ឋិតេ ពហូ មិត្តាមច្ចា ញាតិសាលោហិតា ភោតោ រដ្ឋបាលស្ស ញាតិបារិជុញ្ញំ នត្ថិ ។ កឹ ភវំ រដ្ឋបាលោ ញត្វា វា ទិស្វា វា សុត្វា វា អគារស្មា អនគារិយំ បព្វជិតោ ។ ឥមានិ ខោ(១) រដ្ឋបាល ចត្តារិ បារិជុញ្ញានិ យេហិ បារិជុញ្ញេហិ សមន្នាគតា ឥធេកច្ចេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជន្តិ ។ តានិ ភោតោ រដ្ឋបាលស្ស នត្ថិ ។ កឹ ភវំ រដ្ឋបាលោ ញត្វា វា ទិស្វា វា សុត្វា វា អគារស្មា អនគារិយំ បព្វជិតោតិ ។

[៤០៨] អត្ថិ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ធម្មុទ្ទេសា ឧទ្ទិដ្ឋា យេយាហំ(២) ញត្វា ច ទិស្វា ច សុត្វា ច

១ ម. ខោ ភោ រដ្ឋបាល ។ ២ ម. យេ អហំ ។



អ្នកនោះជួបប្រទះសេចក្តីសាបសូន្យញាតិនោះ ក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចំរើន នេះហៅថា សេចក្តីសាបសូន្យញាតិ ។ ចំណែកព្រះរដ្ឋបាលដ៏ចំរើន មានពួកមិត្រ អាមាត្យ ញាតិសាលោហិតច្រើនក្នុងថុល្លកោដ្ឋិកនិគមនេះឯង ព្រះរដ្ឋបាលដ៏ចំរើន មិនឈ្មោះថាមានសេចក្តីសាបសូន្យញាតិទេ ។ ព្រះរដ្ឋបាលដ៏ចំរើន ដឹងហើយ ឃើញហើយ ឬឮហើយ បានជាចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្តីសាបសូន្យទាំង ៤ យ៉ាងនេះហើយ ជាហេតុឲ្យមនុស្សក្នុងលោកនេះ ដែលជួបប្រទះហើយក៏កោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។ ព្រះរដ្ឋបាលដ៏ចំរើន មិនមានសេចក្តីសាបសូន្យទាំងនោះទេ ។ ព្រះរដ្ឋបាលដ៏ចំរើនដឹងហើយ ឃើញហើយ ឬឮហើយ បានជាចេញចាកផ្ទះទៅបួស ។

[៤០៧] ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហាពរ មានធម្មុទ្ទេស ៤ ប្រការ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយ ដែលអាត្មាភាព បានដឹងផង ឃើញផង ឮហើយផង ទើបចេញ

អគារស្មា អនគារិយំ បព្វជិតោ ។ កតមេ ចត្តារោ ។ ឧបនិយ្យតិ លោកោ អទ្ធុវោតិ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមោ ធម្មុទ្ទេសោ ឧទ្ទិដ្ឋោ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោ អតាណោ លោកោ អនភិស្សរោតិ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយោ ធម្មុទ្ទេសោ ឧទ្ទិដ្ឋោ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោ អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តតិយោ ធម្មុទ្ទេសោ ឧទ្ទិដ្ឋោ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោ ឩនោ លោកោ អតិត្តោ តណ្ហាទាសោតិ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចតុត្ថោ ធម្មុទ្ទេសោ ឧទ្ទិដ្ឋោ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោ ។



ចាកផ្ទះទៅបួស ។ ធម្មុទ្ទេស ៤ យ៉ាងតើដូចម្តេច ។ បពិត្រមហារាជ ធម្មុទ្ទេសទី ១ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ (រកមរណៈ) ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ២ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ៣ ព្រះមានបុណ្យព្រះអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួង ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ៤ ព្រះមានភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។

ឥមេ ខោ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ធម្មុទ្ទេសា ឧទ្ទិដ្ឋា យេ មហំ(១) ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោតិ ។

[៦០៨] ឧបនីយតិ លោកោ អទ្ធុវោតិ ខោ រដ្ឋបាលោ អាហ ឥមស្ស បន ភោ រដ្ឋបាល ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។ តំ កិំ មញ្ញសិ មហារាជ អហោសិ ត្វំ វីសតិវស្សុទ្ទេសិកោបិ បណ្ណវីសតិវស្សុទ្ទេសិកោបិ ហត្ថិស្មឹបិ កតាវី អស្សស្មឹបិ កតាវី រថស្មឹបិ កតាវី ធនុស្មឹបិ កតាវី ថរុស្មឹបិ កតាវី ឩរុពលី ពាហុពលី អលមត្តោ សង្គាមាវចរោតិ ។ អហោសិមហំ(២) ភោ រដ្ឋបាល វីសតិវស្សុទ្ទេសិកោបិ បណ្ណវីសតិវស្សុទ្ទេសិកោបិ ហត្ថិស្មឹបិ កតាវី អស្សស្មឹបិ កតាវី រថស្មឹបិ កតាវី ធនុស្មឹបិ កតាវី ថរុស្មឹបិ កតាវី ឩរុពលី

១ ម. យេ អហំ ។ ២ ម. អហោសិំ អហំ ។



បពិត្រមហារាជ ធម្មុទ្ទេសទាំង ៤ យ៉ាងនេះឯង ដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយ ជាធម៌ដែលអាត្មាភាពបានដឹង បានឃើញ បានស្ដាប់ ហើយចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[៦០៨] ព្រះបាទកោរព្យៈត្រាស់សួរថា ព្រះរដ្ឋបាលដ៏ចំរើន សំដែងថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ (កាន់មរណៈ) បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្ដីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្ដេច ។ ថ្វាយព្រះពរមហារាជ កាលដែលមហាបពិត្រមានព្រះជន្មចូលក្នុងវ័យ ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរីផង ស្ទាត់ខាងវិជ្ជាសេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាដងដាវផង បរិបូណ៌ដោយកំឡាំងព្រះឩរុ (ភ្លៅ) បរិបូណ៌ដោយកំឡាំងព្រះពាហុ (ដើមដៃ) អាចចុះសង្គ្រាមបាន តើព្រះអង្គសំគាល់សេចក្ដីក្នុងកាលនោះថាដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន កាលដែលខ្ញុំមានអាយុចូលក្នុងវ័យ ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរីផង ស្ទាត់ខាងវិជ្ជាសេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាដងដាវផង មានកំឡាំង

ពាហុពលី អលមត្តោ សង្គាមាវចរោ អប្បេកទាហំ ភោ រដ្ឋបាល ឥទ្ធិមា[១] មញ្ញេ ន អត្តនោ ពលេន សមសមំ សមនុបស្សាមីតិ ។ តំ កឹ មញ្ញសិ មហារាជ ឯវមេវ ត្វំ ឯតរហិបិ[២] ឩរុពលី ពាហុពលី អលមត្តោ សង្គាមាវចរោតិ ។ នោ ហិទំ ភោ រដ្ឋបាល ឯតរហិ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ អសីតិកោ មេ[៣] វយោ វត្តតិ អប្បេកទាហំ ភោ រដ្ឋបាល ឥធ បាទំ ករិស្សាមីតិ អញ្ញេនេវ បាទំ ករោមិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ ឧបនីយតិ លោកោ អទ្ធុវោតិ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្ពជិតោតិ ។

១ ឱ. ឥទ្ធិមាវ មញ្ញេតិ ទិស្សតិ ។ ២ ឱ. ម. ឯតរហិ ។ ៣ ឱ. ម. មេតិ បទំ ន ទិស្សតិ ។



ទៅ មានកំឡាំងដៃ អង់អាចបុះស្រ្គាមបាន បពិត្រព្រះរដ្ឋបាលដ៏ចំរើន ជួនកាលខ្ញុំសំគាល់ហាក់ដូចជាអ្នកមានឫទ្ធិ មិនសំគាល់ឃើញអ្នកណាជាស្មើដោយកំឡាំងរបស់ខ្លួនបាន ។ មហាបពិត្រ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ឥឡូវនេះ ព្រះអង្គបរិបូណ៌ដោយកំឡាំងព្រះឩរុ បរិបូណ៌ដោយកំឡាំងព្រះពាហុ អង់អាចបុះស្រ្គាមបាន ដូចកាលពីដើមយ៉ាងនោះដែរឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ហេតុនោះមិនដូច្នោះទេ ឥឡូវនេះខ្ញុំជរាហើយ ចំរើនដោយវ័យចាស់ មានអាយុច្រើន ដល់នូវសេចក្តីថមថយតាមលំដាប់ វ័យខ្ញុំដល់ ៨០ ឆ្នាំហើយ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ជួនកាលខ្ញុំគិតថា នឹងដាក់ជើងនេះ ខ្ញុំត្រឡប់ជាដាក់កន្លែងឯទៀតវិញ ។ បពិត្រមហារាជ ពាក្យថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ (រកមរណៈ) នេះឯង ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់សំដៅដល់ហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮ ហើយចេញចាកផ្ទះទៅបួស ។

អច្ឆរិយំ ភោ រដ្ឋបាល អព្ភុតំ ភោ រដ្ឋបាល យាវ សុភាសិតញ្ចិទំ(១) តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឧបនីយតិ លោកោ អទ្ធុវោតិ ឧបនីយតិ ហិ ភោ រដ្ឋបាល លោកោ អទ្ធុវោ សំវិជ្ជន្តេ ខោ ភោ រដ្ឋបាល ឥមស្មិំ រាជកុលេ ហត្ថិកាយាបិ អស្សកាយាបិ រថកាយាបិ បត្តិកាយាបិ យេ អម្ហាកំ អាបទាសុ បរិយោធាយ វត្តិស្សន្តិ ។

(៦០៤) អត្តាណោ លោកោ អនភិស្សរោតិ កឹ រដ្ឋបាលោ អាហ ឥមស្ស បន ភោ រដ្ឋបាល ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។ តំ កឹ មញ្ញសិ មហារាជ អត្ថិ តេ កោចិ អនុសាយិកោ អាពាធោតិ ។ អត្ថិ មេ ភោ រដ្ឋបាល អនុសាយិកោ អាពាធោ(២) អបេ្យកទា មំ ភោ រដ្ឋបាល មិត្តាមច្ចា ញាតិសាលោហិតា បរិវារេត្វា ឋិតា ហោន្តិ

១ ម. ប. សុភាសិតំ ចិទំ ។ ២ ម. វាតាពាធោ ។



បពិត្រព្រះរដ្ឋបាលដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ហេតុដែលមិនដែលកើត លោកកើតបាន ពាក្យថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ (កេមរណៈ) ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់ហើយនេះ ប្រាកដជាទ្រង់សំដែងត្រូវពិតហើយ បពិត្រព្រះរដ្ឋបាលដ៏ចំរើន សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ (កេមរណៈ) ពិតមែន បពិត្រព្រះរដ្ឋបាលដ៏ចំរើន ក្នុងរាជត្រកូលនេះ មានពួកពលដំរីផង ពួកពលសេះផង ពួកពលរថផង ពួកពលថ្មើរជើងផង ជាការពារសេចក្ដីអន្តរាយដល់ខ្ញុំដែរ ។

(៦០៤) ព្រះរដ្ឋបាលដ៏ចំរើនសំដែងថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹង បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្ដីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្ដេច ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ព្រះអង្គធ្លាប់មានអាពាធ ចាល់តែផ្ទំងាប់លើទីបន្ទំនរដែរឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ខ្ញុំធ្លាប់មានអាពាធ ចាល់តែងាប់នៅលើបន្ទំដែរ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ជួនណាពួកមិត្រ អាមាត្យ ញាតិសាលោហិត ឈរចោមរោមខ្ញុំនិយាយថា

ឥទានិ រាជា កោរព្យោ កាលំ ករិស្សតិ ឥទានិ រាជា កោរព្យោ កាលំ ករិស្សតីតិ ។ តំ កឹ មញ្ញសិ មហារាជ លភសិ ត្វំ តេ មិត្តាមច្ចេ ញាតិសាលោហិតេ អាយន្តុ មេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតា សព្វេវ សន្តា ឥមំ វេទនំ សំវិភជថ(១) យថាហំ លហុកតរិកំ(២) វេទនំ វេទិយេយ្យន្តិ ឧទាហុ ត្វំយេវ វេទនំ វេទិយសីតិ ។ នាហំ ភោ រដ្ឋបាល លភាមិ តេ មិត្តាមច្ចេ ញាតិសាលោហិតេ(៣) សព្វេវ សន្តា ឥមំ វេទនំ សំវិភជថ យថាហំ លហុកតរិកំ វេទនំ វេទិយេយ្យន្តិ អថខោ អហមេវ តំ វេទនំ វេទិយាមីតិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ អត្តាណោ លោកោ អនភិស្សរោតិ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោតិ ។ អច្ឆរិយំ ភោ រដ្ឋបាល អព្ភុតំ ភោ រដ្ឋបាល

១ ឱ. សំវិភជេថ ។ ២ ម. លហុកំ ឈរិ ។ ៣ ឱ. ម. ឥតោ បរំ អាយន្តុ មេ ភោន្តោ មិត្តាមច្ចា ញាតិសាលោហិតាតិ ទិស្សតិ ។



ព្រះបាទកោរព្យៈ ទ្រង់នឹងទិវង្គតឥឡូវនេះ ព្រះបាទកោរព្យៈ ទ្រង់នឹងទិវង្គត ឥឡូវនេះ ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ព្រះអង្គបានពួកមិត្រ អាមាត្យ ញាតិសាលោហិតទាំងនោះ ដោយការអង្វរជួយថា ពួកមិត្រ អាមាត្យ ញាតិសាលោហិតដ៏ចំរើន របស់អញ ចូរនាំគ្នាមក សូមឲ្យអ្នកទាំងអស់គ្នា រំលែកយកវេទនានោះ ដែលជាហេតុឲ្យខ្ញុំសោយវេទនាបានស្រាលបន្តិចដូច្នេះបានទេ ឬក៏ព្រះអង្គសោយវេទនាតែមួយព្រះអង្គឯងទេ ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ខ្ញុំមិនបានពួកមិត្រ អាមាត្យ ញាតិសាលោហិតទាំងនោះ ដោយសេចក្តីអង្វរថា សូមឲ្យអ្នកទាំងអស់គ្នា រំលែកយកវេទនានេះ ដែលជាហេតុឲ្យខ្ញុំបានសោយវេទនាស្រាលបន្តិច ដូច្នេះទេ មានតែខ្ញុំត្រូវសោយវេទនានោះតែឯងប៉ុណ្ណោះ ។ បពិត្រមហារាជ ត្រង់ពាក្យថា សត្វលោកឥតមានគ្រឿងការពារ ឥតទីពឹង នេះឯង ដែលព្រះមានភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ហេតុដែលមិនដែលកើត លោតែកើតមាន

យាវ សុភាសិតញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អតាណោ លោកោ អនភិស្សរោតិ អតាណោ ហិ ភោ រដ្ឋបាល លោកោ អនភិស្សរោ សំវិជ្ជតិ ខោ ភោ រដ្ឋបាល ឥមស្មិំ រាជកុលេ បហូតំ ហិរញ្ញសុវណ្ណំ ភូមិគតញ្ច វេហាសគតញ្ច (១) ។

[៦១០] អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ ភវំ រដ្ឋបាលោ អាហ ឥមស្ស បន ភោ រដ្ឋបាល ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។ តំ កិំ មញ្ញសិ មហារាជ យថា ត្វំ ឯតរហិ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេសិ លច្ឆសិ ត្វំ (២) បរត្ថាបិ ឯវមេវាហំ ឥមេហេវ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេមីតិ ឧទាហុ អញ្ញេ ឥមំ ភោគំ បដិបជ្ជិស្សន្តិ ត្វំ បន យថាកម្មំ គមិស្សសីតិ ។ យថាហំ ភោ រដ្ឋបាល ឯតរហិ

១ ម. វេហាសដ្ឋញ្ច ។ ២ ម. ត្វំ ន លច្ឆតិ ។



ពាក្យថា សត្វលោក មិនមានគ្រឿងការពារ មិនមានទីពឹង ដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយនេះ ពេញជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចំរើន ព្រោះថាសត្វលោក មិនមានគ្រឿងការពារ មិនមានទីពឹងពិតមែន បពិត្រព្រះរដ្ឋបាលដ៏ចំរើន តែក្នុងរាជត្រកូលនេះ មានមាសប្រាក់ច្រើន តាំងនៅលើផែនដីខ្លះ តាំងនៅលើធ្នើខ្ពស់ខ្លះ ។

[៦១០] ព្រះរដ្ឋបាលដ៏ចំរើន សំដែងថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅ ដូច្នេះ បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ។ បពិត្រព្រះរាជសម្ភារ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ។ ឥឡូវនេះ ព្រះអង្គបានឆ្អែតស្កប់ស្កល់ទ្រង់សព្វ ឲ្យគេបម្រើដោយកាមគុណទាំង៥ យ៉ាងណា តទៅលោកខាងមុខទៀត ព្រះអង្គនឹងបានដូចបំណងថា អាត្មាអញ នឹងបានឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង៥នេះឯង យ៉ាងនោះទៀតដែរឬ ឬក៏ពួកជនដទៃនឹងគ្រប់គ្រងភោគសម្បត្តិនេះ (ជំនួស) ចំណែកព្រះអង្គនឹងទ្រង់ស្តេចទៅតាមយថាកម្ម ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ឥឡូវខ្ញុំបាន

បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេមិ នាហំ លច្ឆាមិ បរត្ថាបិ ឯវមេវហំ ឥមេហេវ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេមីតិ អថខោ អញ្ញេ ឥមំ ភោគំ បដិបជ្ជិស្សន្តិ អហំ បន យថាកម្មំ គមិស្សាមីតិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោតិ ។ អច្ឆរិយំ ភោ រដ្ឋបាល អព្ភុតំ ភោ រដ្ឋបាល យាវ សុភាសិតញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន អស្សកោ លោកោ សព្វំ បហាយ គមនីយន្តិ អស្សកោ ហិ ភោ រដ្ឋបាល លោកោ សព្វំ បហាយ គមនីយំ ។



ឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង៥ យ៉ាងណា ដល់ទៅខាងមុខ ខ្ញុំនឹងមិនបានដូចបំណងថា ខ្ញុំគង់បានឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ នេះឯង យ៉ាងនោះទៀតទេ តាមពិត ពួកជនដទៃ គ្រប់គ្រងភោគសម្បត្តិ (ជំនួស) ចំណែកខាងខ្ញុំនឹងទៅតាមយថាកម្ម ។ បពិត្រមហារាជ ត្រង់ពាក្យថា សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងអស់ នេះឯង ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹងផង បានឃើញផង បានឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ហេតុដែលមិនដែលកើត លោកតែកើតបាន ពាក្យថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅ ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយនេះ ពេញទីជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចំរើន ព្រោះថា សត្វលោកសុទ្ធតែមិនមានអ្វី ជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅមែន ។

[៦១១] ឩនោ លោកោ អតិត្តោ តណ្ហាទាសោតិ អាហ ឥមស្ស ភោ រដ្ឋបាល ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។ តំ កឹ មញ្ញសិ មហារាជ ផីតំ កុរុំ អជ្ឈាវសសីតិ ។ ឯវំ ភោ រដ្ឋបាល ផីតំ កុរុំ អជ្ឈាវសាមីតិ ។ តំ កឹ មញ្ញសិ មហារាជ ឥធ តេ បុរិសោ អាគច្ឆេយ្យ បុរត្ថិមាយ ទិសាយ សទ្ធាយិកោ បច្ចយិកោ ។ សោ តំ ឧបសង្កមិត្វា ឯវំ វទេយ្យ យគ្ឃេ មហារាជ ជានេយ្យាសិ អហំ អាគច្ឆាមិ បុរត្ថិមាយ ទិសាយ តត្ថទ្ទសំ មហន្តំ ជនបទំ ឥទ្ធញ្ចេវ ផីតញ្ច ពហុជនំ អាកិណ្ណមនុស្សំ ពហូ តត្ថ ហត្ថិកាយា អស្សកាយា រថកាយា បត្តិកាយា ពហុ តត្ថ ទន្តាជិនំ ពហុ តត្ថ ហិរញ្ញសុវណ្ណំ អកតញ្ចេវ កតញ្ច ពហុ តត្ថ ឥត្ថីបរិគ្គហោ សក្កា ច តាវត្តកេន ពលមត្តេន អភិវិជិនិតុំ អភិវិជិន(១) មហារាជាតិ កិន្តិ នំ ករេយ្យាសីតិ ។

១ ម. អភិវិជិតតំ ន វិស្សជិ ។



[៦១១] ព្រះរដ្ឋបាលដ៏ចំរើន សំដែងថា សត្វលោកសព្វកាលមាន សេចក្តីខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា បពិត្រព្រះរដ្ឋបាលដ៏ចំរើន សេចក្តីនៃភាសិតនេះ តើគួរយល់ដោយប្រការដូចម្តេច ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះថាដូចម្តេច ព្រះអង្គគ្រប់គ្រងដែនកុរុ ដែលជាដែនស្តុកស្តម្ភហើយឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ខ្ញុំគ្រប់គ្រង ដែនកុរុដែលជាដែនស្តុកស្តម្ភមែន ។ បពិត្រមហារាជ ព្រះអង្គសំគាល់ សេចក្តីនោះដូចម្តេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរទទួលស្តាប់ពាក្យបាន មកអំពីទិសខាងកើត ។ បុរសនោះចូល មកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពី ទិសខាងកើត បានឃើញជនបទធំក្នុងទិសនោះ ជាជនបទមាំមួន ស្តុក ស្តម្ភ មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះ មានពួកពល ដំរី ពលសេះ ពលរថ នឹងពលថ្មើរជើងជាច្រើន ក្នុងជនបទនោះមាន ភ្លុកនឹងស្បែកជាច្រើន ក្នុងជនបទនោះ មានមាសប្រាក់ដែលគេមិនទាន់ ធ្វើខ្លះ ធ្វើរួចហើយខ្លះជាច្រើន ក្នុងជនបទនោះមានបរិវារស្ត្រីជាច្រើន ព្រះអង្គអាចនឹងច្បាំងយកបាន ដោយកំឡាំងពលត្រឹមប៉ុណ្ណោះ បពិត្រ មហារាជ សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះដូចម្តេច ។

តម្បិ មយំ ភោ រដ្ឋបាល អភិវិជិយ អជ្ឈាវសេយ្យា-មាតិ ។ តំ កិំ មញ្ញសិ មហារាជ ឥធ តេ(១) បុរិសោ អាគច្ឆេយ្យ បច្ឆិមាយ ទិសាយ... ឧត្តរាយ ទិសាយ... ទក្ខិណាយ ទិសាយ... បរសមុទ្ទតោ(២) សទ្ធាយិកោ បច្ចយិកោ ។ សោ តំ ឧបសង្កមិត្វា ឯវំ វទេយ្យ យគ្ឃេ មហារាជ ជានេយ្យាសិ អហំ អាគច្ឆាមិ បរសមុទ្ទតោ តត្ថទ្ទសំ មហន្តំ ជនបទំ ឥទ្ធញ្ចេវ ផីតញ្ច ពហុជនំ អាកិណ្ណមនុស្សំ ពហូ តត្ថ ហត្ថិកាយា អស្សកាយា រថកាយា បត្តិកាយា ពហុ តត្ថ ទន្តាជិនំ ពហុ តត្ថ ហិរញ្ញសុវណ្ណំ អកតញ្ចេវ កតញ្ច ពហុ តត្ថ ឥត្ថីបរិគ្គហោ សក្កា ច តាវត្តកេន ពលមត្តេន អភិវិជិតុំ អភិវិជិន មហារាជាតិ កិន្តិ នំ ករេយ្យាសីតិ ។ តម្បិ មយំ ភោ រដ្ឋបាល អភិវិជិយ អជ្ឈាវសេយ្យាមាតិ ។ ឥទំ ខោ តំ មហារាជ

---
១ ម. ហេតិ ន ចិរស្សតិ ។ ២ ម. ប. បារសមុទ្ទតោ ។



បពិត្រព្រះរដ្ឋបាលដ៏ចំរើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះ មកគ្រប់គ្រងឲ្យបាន ។ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះថា ដូចម្តេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរស្តាប់ពាក្យ បាន មកអំពីទិសខាងលិច... អំពីទិសខាងជើង... អំពីទិសខាងត្បូង... អំពីប្រទេសខាងនាយសមុទ្រ ។ បុរសនោះ ចូលមកគាល់ព្រះអង្គ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមក អំពីប្រទេសខាងនាយសមុទ្រ បានឃើញជនបទធំនៅក្បែរសមុទ្រនោះ ជាជនបទស្តុកស្តម្ភមាំមួន មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះមាន ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើងច្រើន ក្នុងជនបទនោះ មានភ្លុកនឹងស្បែកច្រើន ក្នុងជនបទនោះ មានមាសប្រាក់ដែលគេធ្វើហើយផង មិនទាន់ធ្វើផងជាច្រើន ក្នុងជនបទនោះមានបរិគ្គហស្ត្រីច្រើន ព្រះអង្គអាចច្បាំងយក ដោយពលត្រឹមប៉ុណ្ណោះ បពិត្រមហារាជ សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះ ដូចម្តេច ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះ គ្រប់គ្រងឲ្យបាន ។ ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហារាជ ពាក្យ

តេន ភគវតា ជានតា បស្សតា អរហតា សម្មា-សម្ពុទ្ធេន សន្ធាយ កថិតំ ឩនោ លោកោ អតិត្តោ តណ្ហាទាសោតិ យមហំ ញត្វា ច ទិស្វា ច សុត្វា ច អគារស្មា អនគារិយំ បព្វជិតោតិ ។ អច្ឆរិយំ ភោ រដ្ឋបាល អព្ភុតំ ភោ រដ្ឋបាល យាវ សុភាសិតមិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឩនោ លោកោ អតិត្តោ តណ្ហាទាសោតិ ឩនោ ហិ ភោ រដ្ឋបាល លោកោ អតិត្តោ តណ្ហាទាសោតិ ។

[៦១៦] ឥទមវោច អាយស្មា(១) រដ្ឋបាលោ ឥទំ វត្វា អថាបរំ ឯតទវោច

បស្សាមិ លោកេ សធនេ មនុស្សេ
លទ្ធាន វិត្តំ ន ទទន្តិ មោហា
លុទ្ធា(២) ធនំ សន្និចយំ ករោន្តិ
ភិយ្យោ ច(៣) កាមេ អភិបត្ថយន្តិ

១ ឱ. ឥទមវោចាយស្មា ។ ២ ម. លុទ្ធា ។ ៣ ឱ. ម. វ ។



ថា សត្វលោកសព្វថ្ងៃខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា នេះឯងដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮហើយចេញចាកផ្ទះមកបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចំរើន មិនដែលមានឡើយ ពាក្យដែលថា សត្វលោក សព្វថ្ងៃមានសេចក្តីខ្វះខាត មិនចេះឆ្អែត សព្វថ្ងៃជាខ្ញុំនៃតណ្ហា ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយនេះ ពេញជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចំរើន ព្រោះថាសត្វលោក សព្វថ្ងៃមានសេចក្តីខ្វះខាត មិនចេះឆ្អែត សព្វថ្ងៃជាខ្ញុំនៃតណ្ហាមែន ។

[៦១៦] ព្រះរដ្ឋបាលមានអាយុ បានសំដែងធម្មទេសនានេះ លុះសំដែងធម្មទេសនានេះរួចហើយ ទើបបានសំដែងគាថាព័ន្ធនេះតទៅទៀតថា

អាត្មាភាពឃើញ ពួកមនុស្សអ្នកមានទ្រព្យក្នុងលោក បាន
ទ្រព្យគាប់ចិត្តហើយ មិនឲ្យ (ទាន) ព្រោះតែសេចក្តីវង្វេង
រមែងធ្វើនូវការសន្សំ ព្រោះជាប់ចំពាក់នឹងទ្រព្យ រឹងរឹត
តែប្រាថ្នានូវកាមទាំងឡាយ ឲ្យក្រៃលែងទៅទៀត ព្រះ

រាជា បសយ្ហ(១) បឋវី វិជិត្វា
សសាគរន្តំ មហិមាវសន្តោ
ឱរំ សមុទ្ទស្ស អតិត្តរូបោ
បារំ សមុទ្ទស្សបិ បត្ថយេថ
រាជា ច អញ្ញេ ច ពហូ មនុស្សា
អវីតតណ្ហា មរណំ ឧបេន្តិ
ឩនាវ ហុត្វា ន ជហន្តិ ទេហំ
កាមេហិ លោកម្ហិ ន ហត្ថិ តិត្តិ
កន្ទន្តិ នំ ញាតី បកិរិយ(២) កេសេ
អហោ វតា នោ(៣) អមរាតិ ចាហុ
វត្ថេន នំ បារុតំ នីហរិត្វា
ចិតំ សមាទាយ តតោ ឌហន្តិ
សោ ឌយ្ហតិ(៤) សូលេហិ តុជ្ជមានោ
ឯកេន វត្ថេន បហាយ ភោគេ
ន មិយ្យមានស្ស ភវន្តិ តាណា
ញាតី ច មិត្តា អថវ សហា.

---

១ ឱ. បសយ្ហ ។ ២ ឱ. ញាតី បកិរិយ ។ ម. ញាតី បកិរាយ ។ ៣ ឱ. វតានេ ។ ៤ ម. ឌយ្ហតិ ។



រាជាក្រាបក្រាម ឈ្នះមនុស្សលើផែនដី ហើយគ្រប់គ្រងសម្បត្តិលើផែនដី មានសមុទ្រជាទីបំផុត នៅតែមិនស្កប់នឹងប្រទេសខាងអាយសមុទ្រ តែងប្រាថ្នានូវប្រទេសខាងនាយសមុទ្រទៀត ព្រះរាជាក្តី មនុស្សទាំងឡាយដទៃច្រើនក្តី តែមិនទាន់អស់តណ្ហាហើយ រមែងចូលទៅកាន់សេចក្តីស្លាប់ មានសភាពជាអ្នកមានសេចក្តីខ្វះខាត តែងមិនលះបង់នូវកាយឡើយ ឈ្មោះថាសេចក្តីឆ្អែតឆ្អន់ដោយកាមទាំងឡាយ រមែងមិនមានក្នុងលោកជាដាច់ខាត ពួកញាតិ រំសាយសក់ទាំងឡាយ ហើយកន្ទក់កន្ទេញ ចំអ្នកស្លាប់នោះថា ឱហ្ន៎ ញាតិរបស់យើងស្លាប់ហើយ យកបុគ្គលស្លាប់នោះ ដែលរុំដោយសំពត់ នាំទៅដល់ជើងថ្ករហើយដុត ក្នុងទីនោះ បុគ្គលស្លាប់នោះ លះបង់ភោគៈទាំងឡាយ នៅតែសំពត់មួយ ត្រូវគេចាក់ដោយឈើស្រួច ត្រូវភ្លើងឆេះ គ្រឿងការពារទាំងឡាយ រមែងមិនមានដល់បុគ្គលស្លាប់ទេ មានតែពួកញាតិមិត្រ ឬ

យា ទាយាទកា តស្ស ធនំ ហរន្តិ
សត្តោ បន គច្ឆតិ យេន កម្មំ
ន មិយ្យមានំ ធនមន្វេតិ កិញ្ចិ
បុត្តា ច ទារា ច ធនញ្ច រដ្ឋំ
ន ទីឃមាយុំ លភតេ ធនេន
ន ចាបិ វិត្តេន ជរំ វិហន្តិ
អប្បកញ្ហិទំ ជីវិតមាហុ(១) ធីរា
អសស្សតំ វិប្បរិណាមធម្មំ
អឌ្ឍា ទលិទ្ទា ច ផុសន្តិ ផស្សំ
ពាលោ ច ធីរោ ច តថេវ ផុដ្ឋោ
ពាលោ ហិ ពាល្យា វធិតោវ(២) សេតិ
ធីរោ ច(៣) ន វេធតិ ផស្សផុដ្ឋោ
តស្មា ហិ បញ្ញា ច ធនេន សេយ្យា
យាយ វោសានំ ឥធាធិគច្ឆតិ(៤)
អព្យោសិតត្តា(៥) ហិ ភវាភវេសុ
បាបានិ កម្មានិ ករោន្តិ មោហា

---

១ ឱ. អប្បំ ហិទំ ជីវិតំ អាហុ ។ ម. អប្បញ្ហិទំ ជីវិតមាហុ ។ ២ [illegible] ។ ៣ ម. ន ។ ៤ ឱ. វោសានំ ឥធាធិគច្ឆតិ ។ ម. វោសានមិធា-ធិគច្ឆតិ ។ ៥ ឱ. អព្យោសិតត្តា ។



ពួកសំឡាញ់ជាទាយាទ(១) តែងយកទ្រព្យរបស់បុគ្គលស្លាប់នោះទៅ ចំណែកសត្វក៏ទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួចរមែងមិនទៅតាមបុគ្គលស្លាប់ឡើយ ពួកកូនប្រពន្ធ ទ្រព្យនិងផែន ក៏មិនជាប់តាមទៅទេ បុគ្គលមិនបានអាយុវែងព្រោះទ្រព្យទេ ទាំងមិនរមែងលះបង់ជរាបាន ព្រោះទ្រព្យដែរ អ្នកប្រាជ្ញពោលថា ជីវិតនេះ តិចពេកណាស់ មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា ពួកអ្នកស្តុកស្តម្ភក្តី អ្នកកំសត់ក្តី តែងពាល់ត្រូវនូវសម្ផស្សស្លាប់ ទាំងពាលទាំងប្រាជ្ញ ក៏ពាល់ត្រូវដូច្នោះដែរ តែថា មនុស្សពាល រមែងដេកទាំងតក់ស្លុត ព្រោះសេចក្តីល្ងង់ ចំណែកអ្នកប្រាជ្ញ បើទុកជាពាល់ត្រូវសម្ផស្សស្លាប់ ក៏មិនញាប់ញ័រឡើយ ព្រោះហេតុនោះ បុគ្គលបានដល់អរហត្តផលជាទីបំផុតកិច្ច ក្នុងលោកនេះដោយបញ្ញាណា បញ្ញានោះប្រសើរលើសជាងទ្រព្យ ព្រោះតែខ្លួនមិនទាន់ដល់កិច្ចជាទីបំផុត ពួកជនរមែងធ្វើអំពើអាក្រក់ក្នុងភពតូចនិងភពធំទាំងឡាយ ព្រោះតែសេចក្តីវង្វេង

---

១ អ្នកទទួលទ្រព្យមត៌ក ។

ឧបេតិ គព្ភញ្ច បរញ្ច លោកំ
សំសារមាបជ្ជ បរម្បរាយ
តស្សប្បបញ្ញោ អភិសទ្ទហន្តោ
ឧបេតិ គព្ភញ្ច បរញ្ច លោកំ
ចោរោ យថា សន្ធិមុខេ គហីតោ
សកម្មុនា ហញ្ញតិ បាបធម្មោ
ឯវំ បជា បេច្ច បរម្ហិ លោកេ
សកម្មុនា ហញ្ញតិ បាបធម្មា
កាមា ហិ ចិត្រា មធុរា មនោរមា
វិរូបរូបេន មថេន្តិ ចិត្តំ
អាទីនវំ កាមគុណេសុ ទិស្វា
តស្មា ហំ បព្វជិតោម្ហិ រាជ
ទុមប្ផលានេវ បតន្តិ មាណវា
ទហរា ច វុឌ្ឍា ច សរីរភេទា
ឯតំ វិទិត្វា បព្វជិតោម្ហិ រាជ
អបណ្ណកំ សាមញ្ញមេវ សេយ្យោតិ ។

រដ្ឋបាលសុត្តំ ទុតិយំ និដ្ឋិតំ ។

---



បុគ្គល រមែងចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ព្រោះដល់នូវការអន្ទោលទៅតៗគ្នា បុគ្គលអប្បប្រាជ្ញ ជឿបុគ្គលនោះ ក៏ចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ចោរកាន់ធមិគាក្រក់ ដែលគេចាប់បាន ត្រង់កន្លែងទ័-ត ត្រូវគេបៀតបៀន ព្រោះកម្មរបស់ខ្លួន តើយ៉ាងណា ពួកសត្វកាន់ធមិគាក្រក់ លះលោកនេះទៅហើយ រមែងក្តៅក្រហាយ ព្រោះកម្មរបស់ខ្លួន ក្នុងលោកខាងមុខ យ៉ាងនោះដែរ ព្រោះតែកាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ ទីជាទីរីករាយដល់ចិត្ត តែងញាំញីនូវចិត្ត ដោយសភាវៈផ្សេងៗ បពិត្រមហារាជ ព្រោះហេតុនោះ អាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយហើយ បានជាបួស មនុស្សទាំងឡាយ ទាំងក្មេង ទាំងចាស់ លុះបែកធ្លាយសរីរៈហើយ រមែងជ្រុះចុះ ដូចជាផ្លែឈើទាំងឡាយ បពិត្រមហារាជ អាត្មាភាព បានឃើញច្បាស់ នូវហេតុនេះផង សមណភាព ជាការប្រតិបត្តិមិនខុស ប្រសើរជាងទីបំផុត ដូច្នេះបានជាបួស ។

ចប់ រដ្ឋបាលសូត្រ ទី ២ ។

## តតិយំ មឃទេវសុត្តំ[១]

[៦១៣] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា មិថិលាយំ វិហរតិ មឃទេវម្ពវនេ[២] ។ អថ ខោ ភគវា អញ្ញតរស្មឹ បទេសេ សិតំ បាត្វាកាសិ ។ អថ ខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ កោ នុ ខោ ហេតុ កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ន អការណេន តថាគតា សិតំ បាតុករោន្តីតិ ។ អថ ខោ អាយស្មា អានន្ទោ ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ ភគវតោ សិតស្ស បាតុកម្មាយ ន អការណេន តថាគតា សិតំ បាតុករោន្តីតិ ។

១ ឱ. មឃាទេវសុត្តំ ។ ម. មខាទេវសុត្តំ ។ ២ ឱ. មឃាទេវម្ពវនេ ។ ម. មខាទេវម្ពវនេ ។

## មឃទេវសូត្រ ទី ៣

[៦១៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមឃទេវម្ពវ័ន[១] ជិតក្រុងមិថិលា ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះទស្សន៍ប្រាកដ ក្នុងប្រទេសមួយ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ បានត្រិះរិះដូច្នេះថា ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះទស្សន៍ប្រាកដ ព្រះតថាគតទាំងឡាយ ទ្រង់មិនធ្វើអាការញញឹមព្រះទស្សន៍ប្រាកដ ដោយឥតហេតុឡើយ ។ ខណៈនោះ ព្រះអានន្ទមានអាយុ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះទស្សន៍ប្រាកដ ព្រះតថាគតទាំងឡាយ ទ្រង់មិនធ្វើអាការញញឹមព្រះទស្សន៍ប្រាកដ ដោយឥតហេតុឡើយ ។

១ ព្រៃស្វាយរបស់ព្រះរាជា ទ្រង់ព្រះនាម មឃទេវៈ ។

(២០៦) ភូតបុព្វំ អានន្ទ ឥមិស្សាយេវ មិថិលាយំ រាជា អហោសិ មឃទេវោ(១) នាម ធម្មិកោ ធម្មរាជា ធម្មេ ឋិតោ មហារាជា ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសឹ បញ្ចទសឹ អដ្ឋមិញ្ច បក្ខស្ស ។ អថខោ អានន្ទ រាជា មឃទេវោ ពហូនំ វស្សានំ ពហូនំ វស្សសតានំ ពហូនំ វស្សសហស្សានំ អច្ចយេន កប្បកំ អាមន្តេសិ យទា មេ សម្ម កប្បក បស្សេយ្យាសិ សិរស្មឹ ផលិតានិ(២) ជាតានិ អថ មេ អារោចេយ្យាសីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ រញ្ញោ មឃទេវស្ស បច្ចស្សោសិ ។ អទ្ទសា ខោ អានន្ទ កប្បកោ ពហូនំ វស្សានំ ពហូនំ វស្សសតានំ ពហូនំ វស្សសហស្សានំ អច្ចយេន រញ្ញោ មឃទេវស្ស សិរស្មឹ ផលិតានិ ជាតានិ ទិស្វាន

១ ម. មខាទេវោ ។ ២ ម. បលិតានិ ។



(២០៦) ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ រឿងធ្លាប់មានមកហើយ ក្នុងនគរមិថិលានេះឯង មានព្រះរាជាទ្រង់ព្រះនាមថា មឃៈ-ទេវៈ ជាធម្មិក ប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ ទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនិងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ ថែរក្សាឧបោសថ ក្នុងថ្ងៃ ១៤ ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ កន្លងទៅហើយ ទើបព្រះបាទមឃទេវរាជ ទ្រង់ត្រាស់ហៅខ្ញុំព្រះកេសមកថា ម្នាលខ្ញុំព្រះកេសសំឡាញ់ បើអ្នកឃើញសក់ស្កូវលើក្បាលរបស់អញ ក្នុងកាលណាហើយ អ្នកគប្បីប្រាប់អញ ក្នុងកាលនោះ ។ ម្នាលអានន្ទ ខ្ញុំព្រះកេសបានទទួលព្រះបន្ទូលនៃព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបខ្ញុំព្រះកេស បានឃើញសក់ស្កូវលើព្រះសិរ នៃព្រះបាទមឃទេវរាជ លុះឃើញ

រាជានំ មឃទេវំ ឯតទវោច បាតុភូតា ខោ(១) ទេវស្ស ទេវទូតា ទិស្សន្តិ សិរស្មឹ បលិតានិ ជាតានីតិ ។ តេនហិ សម្ម កប្បក តានិ បលិតានិ សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា មម(២) អញ្ជលិស្មឹ បតិដ្ឋាបេហីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ រញ្ញោ មឃទេវស្ស បដិស្សុត្វា តានិ បលិតានិ សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា រញ្ញោ មឃទេវស្ស អញ្ជលិស្មឹ បតិដ្ឋាបេសិ ។ អថខោ អានន្ទ រាជា មឃទេវោ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ អាមន្តាបេត្វា ឯតទវោច បាតុភូតា ខោ មេ តាត កុមារ ទេវទូតា ទិស្សន្តិ សិរស្មឹ បលិតានិ ជាតានិ ភុត្តា ខោ បន មេ មានុសកា កាមា សមយោ ទិព្វេ កាមេ បរិយេសិតុំ ឯហិ ត្វំ តាត កុមារ ឥមំ រជ្ជំ បដិ-បជ្ជ អហំ បន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមិ

---
១ ម. ទេវទូតា ខ ទិស្សតិ ។ ២ ម. មមំ ។



ហើយ ទើបក្រាបទូលព្រះបាទមឃទេវរាជ ដូច្នេះថា ទេវទូតប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសាស្កូវកើតលើព្រះសិរហើយ ។ ព្រះបាទមឃទេវរាជត្រាស់ថា ម្នាលឆ្មាំព្រះកេសសំឡាញ់ បើដូច្នោះ ចូរអ្នកដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើប្រអប់ដៃនៃអញមើល ។ ម្នាលអានន្ទ ឆ្មាំព្រះកេស បានទទួលព្រះបន្ទូលនៃព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ហើយបានដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើប្រអប់ព្រះហស្ត នៃព្រះបាទមឃទេវរាជ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកមួយ ដល់ឆ្មាំព្រះកេស ហើយទ្រង់ឲ្យហៅព្រះរាជកុមារជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតាហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតានឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅ

តេនហិ តាត កុមារ យទា ត្វំ(១) បស្សេយ្យាសិ សិរស្មឹ បលិតានិ ជាតានិ អថ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យាសិ យេន មេ ឥទំ កល្យាណំ វត្តំ(២) និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិមបុរិសោ អហោសិ យស្មឹ ខោ តាត កុមារ បុរិសយុគេ វត្តមានេ ឯវរូបស្ស កល្យាណស្ស វត្តស្ស សមុច្ឆេទោ ហោតិ សោ តេសំ អន្តិមបុរិសោ ហោតិ ។ តន្តាហំ(៣) តាត កុមារ ឯវំ វទាមិ យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិមបុរិសោ អហោសីតិ ។

● ១. ឱ. ត្វញ្ច ។ ម. ឱ. ត្វំ ។ ២ ឱ វត្តំ ។ ៣ ម. តន្តាហំ ។



កាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវ លើក្បាលកូន កាលណាហើយ កូនគប្បីឲ្យស្រុកសួយដល់ជាងកោរសក់ ហើយប្រដៅឲ្យព្រះរាជកុមារដែលជាបុត្រច្បង ក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ កោរពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសក្នុងកាលនោះចុះ ព្រោះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសជាកន្ទុយជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរស(១) ណាមានហើយ កល្យាណវត្តមានសភាពយ៉ាងនេះ ដែលដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថាបុរសជាកន្ទុយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កុំកូនធ្វើជាបុរសជាកន្ទុយ ជាងបិតាឡើយ ។

● ១ បុរសដែលញ៉ាំងវង្សត្រកូលឲ្យកើតទៅ ហៅថា គូនៃបុរសក្នុងទីនេះ ។

[២១៨] អថខោ អានន្ទ រាជា មឃទេវោ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា ឥមស្មឹយេវ មឃទេវម្ពវនេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន(១) ផរិត្វា វិហាសិ ។ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ

១ ម. អព្យាបជ្ឈេន ។



[២១៩] ម្នាលអានន្ទ គ្រានោះ ព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកសួយដល់ជាងកោរព្រះកេសស្រេចហើយ ទ្រង់ប្រដៅព្រះរាជកុមារជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃហើយ ទ្រង់កោរសក់ ពុកមាត់ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ ព្រះបាទមឃទេវរាជនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង(១) មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម

១ បានដល់ទិសតូចទាំង ៤ គឺទិសឦសាន អាគ្នេយ៍ និរតី ពាយព្យ ។

តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ។ រាជា ខោ បនានន្ទ មឃទេវោ ចតុរាសីតិវស្សសហស្សានិ កុមារកីឡិតំ កីឡិ ចតុរាសីតិវស្សសហស្សានិ ឧបរជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ រជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ ឥមស្មឹយេវ មឃទេវម្ពវនេ អគារស្មា អនគារិយំ បព្វជិតោ ព្រហ្មចរិយំ ចរិ ។ សោ ចត្តារោ ព្រហ្មវិហារេ ភាវេត្វា កាយស្ស ភេទា បរម្មរណា ព្រហ្មលោកូបគោ អហោសិ ។

[៤១៦] អថខោ អានន្ទ រញ្ញោ(១) មឃទេវស្ស បុត្តោ ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ អច្ចយេន កប្បកំ អាមន្តេសិ យទា មេ សម្ម កប្បក បស្សេយ្យាសិ

១ ម. រញ្ញោ អានន្ទ ។



ទីទទឹងសព្វទិស មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់ទៅសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលអានន្ទ ក៏ឯព្រះបាទមឃទេវរាជ នៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ។ ព្រះបាទមឃទេវរាជនោះ ចំរើនព្រហ្មវិហារទាំង ៤ លុះខន្ធកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។

[៤១៦] ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបបុត្ររបស់ព្រះបាទមឃទេវរាជ ត្រាស់ហៅជាងកោរសក់មកថា ម្នាលជាងកោរសក់សំឡាញ់ បើអ្នកបានឃើញ

សិរស្មឹ បលិតានិ ជាតានិ អថ មេ(១) អារោចេយ្យា-
សីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ រញ្ញោ
មឃទេវស្ស បុត្តស្ស បច្ចស្សោសិ ។ អទ្ទសា ខោ
អានន្ទ កប្បកោ ពហូនិ វស្សានិ ពហូនិ វស្សសតានិ
ពហូនិ វស្សសហស្សានិ អច្ចយេន រញ្ញោ មឃទេវស្ស
បុត្តស្ស សិរស្មឹ បលិតានិ ជាតានិ ទិស្វាន(២)
រញ្ញោ មឃទេវស្ស បុត្តំ ឯតទវោច បាតុភូតា ខោ
ទេវស្ស ទេវទូតា ទិស្សន្តិ សិរស្មឹ បលិតានិ
ជាតានីតិ ។ តេនហិ សម្ម កប្បក តានិ បលិតានិ
សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា មម អញ្ជលិស្មឹ
បតិដ្ឋាបេហីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ
រញ្ញោ មឃទេវស្ស បុត្តស្ស បដិស្សុត្វា តានិ
បលិតានិ សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា រញ្ញោ
មឃទេវស្ស បុត្តស្ស អញ្ជលិស្មឹ បតិដ្ឋាបេសិ ។
អថខោ អានន្ទ រញ្ញោ មឃទេវស្ស បុត្តោ កប្ប-
កស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ អាមន្តាបេត្វា

---
១ ម. ភោ ១៤, ៥, ទិស្វា ។



សក់ស្កូវលើក្បាលរបស់អញ ក្នុងកាលណាហើយ អ្នកឯងប្រាប់អញ ក្នុង
កាលនោះ ។ ម្នាលអានន្ទ ជាងកោរសក់ទទួលព្រះបន្ទូលនៃបុត្ររបស់
ព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើន
ឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ កន្លងទៅហើយ ជាងកោរសក់បាន
ឃើញសក់ស្កូវ លើព្រះសិរនៃបុត្ររបស់ព្រះបាទមឃទេវរាជ លុះឃើញ
ហើយទើបក្រាបទូលបុត្រ របស់ព្រះបាទមឃទេវរាជដូច្នេះថា ទេវទូត
ប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសស្កូវក៏កើតលើព្រះសិរហើយ ។
ព្រះរាជបុត្រត្រាស់ថា ម្នាលជាងកោរសក់ជាសំឡាញ់ បើដូច្នោះ អ្នកចូរ
ដកសក់ស្កូវនោះដោយសណ្ដាសឲ្យស្រួល ហើយដាក់លើបាតដៃអញ
មើល ។ ម្នាលអានន្ទ ជាងកោរសក់បានទទួលព្រះបន្ទូលនៃបុត្ររបស់
ព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ហើយបានដកសក់ស្កូវនោះ
ដោយសណ្ដាសឲ្យស្រួល ដាក់លើបាតព្រះហស្តនៃបុត្ររបស់ព្រះបាទ
មឃទេវរាជ ។ ម្នាលអានន្ទ លំដាប់នោះ បុត្រនៃព្រះបាទមឃទេវរាជ
ទ្រង់ព្រះរាជទានស្រុកសួយដល់ជាងកោរសក់ ហើយឲ្យហៅព្រះរាជកុមារ

ឯតទវោច ឧបដ្ឋិតា ខោ មេ តាត កុមារ ទេវ-ទូតា ទិស្សន្តិ សិរស្មឹ បលិតានិ ជាតានិ ភុត្តា ខោ បន មេ មានុសកា កាមា សមយោ ទិព្វេ កាមេ បរិយេសិតុំ ឯហិ ត្វំ តាត កុមារ ឥមំ រជ្ជំ បដិបជ្ជ អហំ បន កេសមស្សុំ ឱហារេត្វា កាសា-យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមិ តេនហិ តាត កុមារ យទា ត្វម្បិ បស្សេយ្យាសិ សិរស្មឹ បលិតានិ ជាតានិ អថ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា កេសមស្សុំ ឱហារេត្វា កាសា-យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យាសិ យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិម-បុរិសោ អហោសិ យស្មឹ ខោ តាត កុមារ បុរិស-យុគេ វត្តមានេ ឯវរូបស្ស កល្យាណស្ស វត្តស្ស សមុច្ឆេទោ ហោតិ សោ តេសំ អន្តិមបុរិសោ ហោតិ ។ តន្តាហំ(១) តាត កុមារ ឯវំ វទាមិ

១ ម. តន្តាហំ ។



ជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតាហើយ សក់ស្កូវក៏កើតមាន លើក្បាលហើយ មួយទៀតកាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតានឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវកើតលើក្បាល ក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកសួយដល់ជាងព្រះកេស ហើយប្រដៅព្រះរាជកុមារដែលជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថាកល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសជាកន្ទុយ ជាងបិតាឡើយ ម្នាលកុមារកូន កាលបើនូវបុរសណាមានហើយ កល្យាណវត្ត មានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្ដាបុរសទាំងនោះ នូវបុរសនោះឯង ហៅថាបុរសជាកន្ទុយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាង

យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិមបុរិសោ អហោសីតិ ។

[៦១៧] អថខោ អានន្ទ រញ្ញោ មឃទេវស្ស បុត្តោ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា ឥមស្មឹយេវ មឃទេវម្ពវនេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ។ ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ



នេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសជាងក្រោយ ជាទីបំផុតឡើយ ។

[៦១៧] ម្នាលអានន្ទ គ្រានោះ បុត្តរបស់ព្រះបាទមឃទេវរាជ ព្រះរាជទានស្រុកសួយ ដល់ភ្នាក់ព្រះកេសស្រេចហើយ ប្រដៅព្រះរាជកុមារជាបុត្រច្បង ក្នុងរាជសម្បត្តិដោយប្រពៃហើយ កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ លុះបុត្តនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាង

តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហាសិ ។ រញ្ញោ ខោ បនានន្ទ មឃទេវស្ស បុត្តោ ចតុរាសីតិវស្សសហស្សានិ កុមារកីឡិតំ កីឡិ ចតុរាសីតិវស្សសហស្សានិ ឧបរជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ រជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ ឥមស្មឹយេវ មឃទេវម្ពវនេ អគារស្មា អនគារិយំ បព្វជិតោ ព្រហ្មចរិយំ ចរិ ។ សោ ចត្តារោ ព្រហ្មវិហារេ ភាវេត្វា កាយស្ស ភេទា បរម្មរណា ព្រហ្មលោកូបគោ អហោសិ ។

[៦១៨] រញ្ញោ ខោ បនានន្ទ មឃទេវស្ស បុត្តបបុត្តកា(១) តស្ស បរំបរា ចតុរាសីតិសហស្សានិ ឥមស្មឹយេវ មឃទេវម្ពវនេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជឹសុ ។ តេ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរឹសុ តថា ទុតិយំ តថា តតិយំ

១ ម. បុត្តបបុត្តកា ។



ក្រោមទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលអានន្ទ ក៏ឯបុត្ត នៃព្រះបាទមឃទេវរាជ នៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះបួសមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ។ ព្រះរាជបុត្តនោះ ចំរើនព្រហ្មវិហារទាំង ៤ លុះរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។

[៦១៨] ម្នាលអានន្ទ ក៏ឯបុត្តនឹងនត្តា របស់ព្រះបាទមឃទេវរាជនោះ ត ៗ ព្រះវង្ស តស់ចំនួនប្រាំបីហ្មឺនបួនពាន់អង្គ ក៏កោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ ចេញចាកផ្ទះបួសមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ ឥសីទាំងអម្បាលនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣

តថា ចតុត្ថិំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរីសុ ។ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរីសុ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថិំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរីសុ ។ តេ[1] ចតុរាសីតិវស្សសហស្សានិ កុមារកីឡិតំ កីឡីសុ ចតុរាសីតិវស្សសហស្សានិ ឧបរជ្ជំ ការេសុំ ចតុរាសីតិវស្សសហស្សានិ រជ្ជំ ការេសុំ ចតុរាសីតិវស្សសហស្សានិ ឥមស្មិំយេវ មឃទេវម្ពវនេ អគារស្មា អនគារិយំ បព្វជិតា ព្រហ្មចរិយំ ចរឹសុ ។ តេ ចត្តារោ ព្រហ្មវិហារេ ភាវេត្វា

១ តេតិ បទំ ន កត្ថចិ ទិស្សតិ ។



ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទីទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទីទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅ កាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ឥសីទាំងអម្បាលនោះ នៅលេងល្បែងក្មេង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះ បួសមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ។ ឥសីទាំងអម្បាលនោះ ចំរើនព្រហ្មវិហារ

កាយស្ស ភេទា បរម្មរណា ព្រហ្មលោកូបគា អហេសុំ ។ និមិ តេសំ រាជា(១) បច្ឆិមកោ អហោសិ ធម្មិកោ ធម្មរាជា ធម្មេ ឋិតោ មហារាជា ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសិំ បញ្ចទសិំ អដ្ឋមី ច បក្ខស្ស ។

(៦០៨) ភូតបុព្វំ អានន្ទ ទេវានំ តាវតិំសានំ សុធម្មាយំ សភាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ លាភា វត ភោ វិទេហានំ សុលទ្ធំ វត ភោ វិទេហានំ យេសំ និមិ រាជា ធម្មិកោ ធម្មរាជា ធម្មេ ឋិតោ មហារាជា ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសិំ បញ្ចទសិំ អដ្ឋមី ច បក្ខស្សាតិ ។

១ ឱ. ភតិ ។



ទាំង ៦ លុះទំលាយរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។ បណ្ដាព្រះរាជាទាំងអម្បាលនោះ ព្រះបាទនិមិរាជ ជាស្ដេចក្រោយបំផុត ជាធម្មិករាជ ប្រកបដោយធម៌ ជាមហារាជ ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនិងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។

(៦០៨) ម្នាលអានន្ទ រឿងនេះធ្លាប់មានមកហើយគឺ ពាក្យជាចន្លោះនេះ បានកើតឡើងដល់ពួកទេវតាជាន់តាវត្តិង្ស ដែលគង់ប្រជុំគ្នាក្នុងរោងសុធម្មា ថា ឱហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញជាមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញជាបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មិករាជ ប្រកបដោយធម៌ ជាមហារាជ ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនិងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។

[២៦០] អថខោ អានន្ទ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ ឥច្ឆេយ្យាថ នោ តុម្ហេ មារិសា និមិរាជានំ ទដ្ឋុន្តិ ។ ឥច្ឆាម មយំ មារិសា និមិរាជានំ ទដ្ឋុន្តិ ។ តេន ខោ បនានន្ទ(១) សមយេន និមិ រាជា តទហុបោសថេ បណ្ណរសេ សីសំនហាតោ(២) ឧបោសថិកោ ឧបរិ បាសាទវរគតោ និសិន្នោ ហោតិ ។ អថខោ អានន្ទ សក្កោ ទេវានមិន្ទោ សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ទេវេសុ តាវតឹសេសុ អន្តរហិតោ និមិស្ស រញ្ញោ សម្មុខេ(៣) បាតុរហោសិ ។ អថខោ អានន្ទ សក្កោ ទេវានមិន្ទោ និមិំ រាជានំ ឯតទវោច លាភា តេ មហារាជ សុលទ្ធំ តេ មហារាជ ទេវា មហារាជ តាវតឹសា សុធម្មាយំ សភាយំ កិត្តយមានរូបា សន្និសិន្នា លាភា វត ភោ វិទេហានំ សុលទ្ធំ វត ភោ វិទេហានំ យេសំ និមិ រាជា ធម្មិកោ ធម្មរាជា ធម្មេ ឋិតោ មហារាជា

១ ម. អានន្ទសទ្ទោ នត្ថិ ។ ២ ឱ. ម. សីសំ នហាតោ ។ ៣ ឱ. មុខេ ។ ម. បមុខេ ។





[២៦០] ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជជាធំជាងទេវតា បានហៅពួកទេវតាជាន់តាវត្តិង្សមកថា ម្នាលគ្នាយើងទាំងឡាយ អ្នកទាំងឡាយចង់ឃើញព្រះបាទនិមិរាជឬទេ ។ ពួកទេវតាក្រាបទូលថា បពិត្រព្រះអង្គនិទុក្ខ យើងទាំងឡាយចង់ឃើញព្រះបាទនិមិរាជដែរ ។ ម្នាលអានន្ទ សម័យនោះឯង ព្រះបាទនិមិរាជទ្រង់ស្រង់ព្រះសិរ្ស ហើយសមាទានឧបោសថ ក្នុងថ្ងៃឧបោសថទី ១៥ ហើយចូលទៅកាន់ប្រាសាទដ៏ប្រសើរ គង់នៅក្នុងជាន់លើ ។ ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជជាធំជាងទេវតា ក៏បាត់ខ្លួនអំពីពួកទេវតាជាន់តាវត្តិង្ស ហើយមកប្រាកដចំពោះព្រះភក្ត្រព្រះបាទនិមិរាជ ដូចជាបុរសមានកំឡាំង លាតដៃដែលបត់ចូល ឬបត់ដៃដែលលាចេញដូច្នោះ ។ ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជជាធំជាងទេវតា មានព្រះបន្ទូលពាក្យនេះ នឹងព្រះបាទនិមិរាជថា បពិត្រមហារាជ ព្រះអង្គពេញហៅជាមានលាភ បពិត្រមហារាជ អត្តភាពជាមនុស្ស ព្រះអង្គពេញហៅបានដោយល្អ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្សបានអង្គុយប្រជុំគ្នានិយាយសរសើរ ក្នុងរោងសុធម្មាថា អើហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ អើហ្ន៎ អត្តភាពជាមនុស្សពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជ ប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុង

ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសឹ បញ្ចទសឹ អដ្ឋមឹ ច បក្ខស្សាតិ ។ ទេវា តេ មហារាជ តាវត្តិំសា ទស្សនកាមា តស្ស តេ អហំ មហារាជ សហស្សយុត្តំ អាជញ្ញរថំ បហិណិស្សាមិ អភិរុហេយ្យាសិ មហារាជ ទិព្វំ យានំ អវិកម្បមានោតិ ។ អធិវាសេសិ ខោ អានន្ទ និមិ រាជា តុណ្ហីភាវេន ។ អថខោ អានន្ទ សក្កោ ទេវានមិន្ទោ និមិស្ស រញ្ញោ អធិវាសនំ វិទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ និមិស្ស រញ្ញោ សម្មុខេ អន្តរហិតោ ទេវេសុ តាវត្តិំសេសុ បាតុរហោសិ ។

(៦៦១) អថខោ អានន្ទ សក្កោ ទេវានមិន្ទោ មាតលឹ សង្គាហកំ អាមន្តេសិ ឯហិ ត្វំ សម្ម មាតលិ សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា



ធម៌ តែងប្រព្រឹត្តធម៌ចំពោះពួកអ្នកនិគមនិងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃ ១៤ ទី១៥ និងទី៨នៃបក្ស ដូច្នេះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស មានសេចក្តីប្រាថ្នាដើម្បីឃើញព្រះអង្គ បពិត្រមហារាជ ខ្ញុំព្រះអង្គនឹងបញ្ជូនរថសម្រាប់ទឹមសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់មក ដើម្បីព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញាប់ញ័រ គង់ឡើងកាន់ទិព្វយាន ។ ម្នាលអានន្ទ ព្រះបាទនិមិរាជ ទ្រង់ទទួលអញ្ជើញដោយតុណ្ហីភាព ។ ម្នាលអានន្ទ គ្រានោះ សក្កទេវរាជជាធំជាងទេវតា ទ្រង់ជ្រាបថាព្រះបាទនិមិរាជទទួលអញ្ជើញហើយ ក៏បាត់ខ្លួនអំពីទីចំពោះព្រះភក្ត្រនៃព្រះបាទនិមិរាជ ទៅប្រាកដក្នុងពួកទេវតាជាន់តាវត្តិង្សវិញ ដូចជាបុរសមានកំឡាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះ ។

(៦៦១) ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជជាធំជាងទេវតា បានត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្គ្រោះថា ម្នាលមាតលិសំឡាញ់ អ្នកចូរមករៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះ

ឥមំ រាជានំ ឧបសង្កមិត្វា ឯវំ វទេហិ អយន្តេ មហារាជ សហស្សយុត្តោ អាជញ្ញរថោ សក្កេន ទេវានមិន្ទេន បេសិតោ អភិរុហ មហារាជ ទិព្វំ យានំ អវិកម្បមានោតិ ។ ឯវំ ភទ្ទន្តវាតិ ខោ អានន្ទ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ បយោជេត្វា ឥមំ រាជានំ ឧបសង្កមិត្វា ឯតទវោច អយំ តេ មហារាជ សហស្សយុត្តោ អាជញ្ញរថោ សក្កេន ទេវានមិន្ទេន បេសិតោ អភិរុហ មហារាជ ទិព្វំ យានំ អវិកម្បមានោ អបិច មហារាជ កតមេន តំ នេមិ យេន វា បាបកម្មា បាបកានំ កម្មានំ វិបាកំ បដិសំវេទេន្តិ យេន វា កល្យាណកម្មា កល្យាណកម្មានំ(១) វិបាកំ បដិសំវេទេន្តីតិ ។ ឧភយេនេវ មំ មាតលិ នេហីតិ ។ សំបវេសិ(២) ខោ អានន្ទ មាតលិ សង្គាហកោ ឥមំ រាជានំ សុធម្មាយំ សភាយំ(៣) ។ អទ្ទសា ខោ អានន្ទ សក្កោ

១. កល្យាណានំ កម្មានំ ។ ២. ម. សម្បាបេសិ ។ ៣. ឱ. ម. សុធម្មំ សភំ ។



មួយពាន់ ហើយចូលទៅគាល់ព្រះបាទនិមិរាជ ក្រាបទូលយ៉ាងនេះថា បពិត្រមហារាជ រថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ នេះ សក្កទេវរាជជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ មើល៎ព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញាប់ញ័រ គប្បីឡើងកាន់ទិព្វយានចុះ ។ ម្នាលអានន្ទ មាតលិទេវបុត្តជាអ្នកសារថី ក៏ទទួលព្រះបន្ទូលនៃសក្កទេវរាជជាធំជាងទេវតាថា ព្រះករុណា សេចក្ដីចំរើន ចូរមានដល់ព្រះអង្គ ហើយរៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ នាំចូលទៅគាល់ព្រះបាទនិមិរាជ ហើយទូលសេចក្ដីនេះថា បពិត្រមហារាជ រថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ នេះ សក្កទេវរាជជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ មើល៎ព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញាប់ញ័រ ចូរឡើងកាន់ទិព្វយានចុះ បពិត្រមហារាជ មួយទៀត ពួកសត្វ ដែលមានកម្មអាក្រក់ តែងទទួលនូវផលនៃកម្មអាក្រក់ ដោយផ្លូវណាក្ដី ពួកសត្វ ដែលមានកម្មល្អ តែងទទួលនូវផលនៃកម្មល្អ ដោយផ្លូវណាក្ដី បណ្ដាផ្លូវទាំងពីរនោះ ខ្ញុំនឹងនាំព្រះអង្គទៅតាមផ្លូវណា ។ ម្នាលមាតលិទេវបុត្ត អ្នកចូរនាំយើងទៅតាមផ្លូវទាំងពីរនោះចុះ ។ ម្នាលអានន្ទ មាតលិទេវបុត្តជាអ្នកសារថី បាននាំព្រះបាទនិមិរាជ ឲ្យទៅដល់រោងសុធម្មា ។ ម្នាលអានន្ទ សក្ក-

ទេវានមិន្ទោ និមឹ រាជានំ ទូរតោវ អាគច្ឆន្តំ ទិស្វាន (១) និមឹ រាជានំ ឯតទវោច ឯហិ ខោ មហារាជ ស្វាគតំ មហារាជ ទេវា តេ មហារាជ តាវតិំសា សុធម្មាយំ សភាយំ កិត្តយមានរូបា សន្និសិន្នា លាភា វត ភោ វិទេហានំ សុលទ្ធំ វត ភោ វិទេហានំ យេសំ និមិ រាជា ធម្មិកោ ធម្មរាជា ធម្មេ ឋិតោ មហារាជា ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសឹ បញ្ចទសឹ អដ្ឋមឹ ច បក្ខស្សាតិ ទេវា តេ មហារាជ តាវតិំសា ទស្សនកាមា អភិរម មហារាជ ទេវេសុ ទេវានុភាវេតិ ។ អលំ មារិស តត្ថេវ មំ មិថិលំ បដិនេតុ តថាហំ ធម្មំ ចរិស្សាមិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសិស្សាមិ ចាតុទ្ទសឹ

១ ឱ. ម. ទិស្វាន ។



ទេវរាជជាធំជាងទេវតា បានឃើញព្រះបាទនិមិរាជ ស្ដេចមកអំពីចម្ងាយ លុះឃើញហើយ ទើបនិយាយពាក្យនេះ នឹងព្រះបាទនិមិរាជថា បពិត្រមហារាជ សូមព្រះអង្គមកចុះ បពិត្រមហារាជ ព្រះអង្គស្ដេចមកប្រពៃហើយ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស បានប្រជុំគ្នានិយាយក្នុងរោងសុធម្មាថា ឱហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជ ប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនឹងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី១៤ ទី១៥ និងទី៨ នៃបក្ស ម្ល៉ោះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្សមានសេចក្ដីប្រាថ្នា ដើម្បីឃើញព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គត្រេកអរ ចំពោះពួកទេវតា ដោយទេវានុភាពចុះ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ល្មមហើយ សូមព្រះអង្គនាំខ្ញុំទៅ កាន់ក្រុងមិថិលា ក្នុងដែនវិទេហៈនោះវិញ ខ្ញុំនឹងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនឹងអ្នកជនបទ ជាព្រាហ្មណជាតិនិងគហបតិជាតិ នឹងរក្សាឧបោសថក្នុងថ្ងៃទី ១៤

បញ្ចទសី អដ្ឋមី ច បក្ខស្សាតិ ។ អថខោ អានន្ទ សក្កោ ទេវានមិន្ទោ មាតលឹ សង្គាហកំ អាមន្តេសិ ឯហិ ត្វំ សម្ម មាតលិ សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា និមឹ រាជានំ គន្ត្វា មិថិលំ បដិនេហីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ អានន្ទ មាតលិ សង្គាហកោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា សហស្សយុត្តំ អាជញ្ញរថំ យោជេត្វា និមឹ រាជានំ គន្ត្វា មិថិលំ បដិនេសិ ។

(៦៦៦) តត្រ សុទំ អានន្ទ មហារាជា ធម្មំ ចរតិ ព្រាហ្មណគហបតិកេសុ នេគមេសុ ចេវ ជានបទេសុ ច ឧបោសថញ្ច ឧបវសតិ ចាតុទ្ទសី បញ្ចទសី អដ្ឋមី ច បក្ខស្សាតិ ។ អថខោ អានន្ទ និមិ រាជា ពហូនំ វស្សានំ ពហូនំ វស្សសតានំ ពហូនំ វស្សសហស្សានំ អច្ចយេន កប្បកំ អាមន្តេសិ យទា មេ សម្ម កប្បក បស្សេយ្យាសិ សិរស្មឹ បលិតានិ ជាតានិ



ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ គ្រានោះឯង សក្កទេវរាជ ជាធំជាងទេវតា ទ្រង់ត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្គ្រោះមកថា ម្នាលមាតលិទេវបុត្តសំឡាញ់ អ្នកចូរមកនៀមរថសេះអាជានេយ្យដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជទៅកាន់ក្រុងមិថិលាក្នុងផែនដីមនុស្សនោះវិញ ។ ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្គ្រោះ បានទទួលព្រះបន្ទូល នៃសក្កទេវរាជ ជាធំជាងទេវតាថា ព្រះករុណា សេចក្តីចំរើនចូរមានដល់ព្រះអង្គ ហើយនៀមរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជទៅកាន់ក្រុងមិថិលា ក្នុងផែនដីមនុស្សនោះវិញ ។

(៦៦៦) ម្នាលអានន្ទ បានឮថា មហារាជក្នុងក្រុងមិថិលានោះ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគមនិងអ្នកជនបទ ជាព្រាហ្មណ៍ជាគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបព្រះបាទនិមិរាជត្រាស់ហៅជាងព្រះកេសមកថា ម្នាលជាងព្រះកេស ជាសំឡាញ់ បើអ្នកបានឃើញសក់ស្កូវកើតមានលើក្បាលនៃអញ ក្នុង

អថ មេ អារោចេយ្យាសីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ និមិស្ស រញ្ញោ បច្ចស្សោសិ ។ អទ្ទសា ខោ អានន្ទ កប្បកោ ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ អច្ចយេន និមិស្ស រញ្ញោ សិរស្មឹ បលិតានិ ជាតានិ ទិស្វាន និមឹ រាជានំ ឯតទវោច បាតុភូតា ខោ ទេវស្ស ទេវទូតា ទិស្សន្តិ សិរស្មឹ បលិតានិ ជាតានីតិ ។ តេនហិ សម្ម កប្បក តានិ បលិតានិ សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា មម អញ្ជលិស្មឹ បតិដ្ឋាបេហីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ កប្បកោ និមិស្ស រញ្ញោ បដិស្សុត្វា តានិ បលិតានិ សាធុកំ សណ្ឌាសេន ឧទ្ធរិត្វា និមិស្ស រញ្ញោ អញ្ជលិស្មឹ បតិដ្ឋាបេសិ ។ អថខោ អានន្ទ និមិ រាជា កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ អាមន្តាបេត្វា ឯតទវោច បាតុភូតា ខោ មេ តាត កុមារ ទេវទូតា ទិស្សន្តិ សិរស្មឹ បលិតានិ ជាតានិ ភុត្តា ខោ បន មេ មានុសកា កាមា សមយោ ទិព្វេ កាមេ បរិយេ-



កាលណាហើយ អ្នកចូរប្រាប់អញក្នុងកាលនោះ ។ ម្នាលអានន្ទ ឆ្មាន់ព្រះកេសទទួលព្រះបន្ទូលព្រះបាទនិមិរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ឆ្មាន់ព្រះកេសបានឃើញសក់ស្កូវ កើតមានលើព្រះសិរ្សនៃព្រះបាទនិមិរាជ លុះឃើញហើយ ទើបក្រាបទូលព្រះបាទនិមិរាជដូច្នេះថា ទេវទូតប្រាកដច្បាស់ ដល់ព្រះអង្គហើយ ព្រះកេសស្កូវកើតមានលើព្រះសិរ្សហើយ ។ ម្នាលឆ្មាន់ព្រះកេសជាទីស្រឡាញ់ បើដូច្នោះ អ្នកចូរដកសក់ស្កូវទាំងនោះដោយសណ្តាសឲ្យស្រួល ហើយដាក់លើបាតដៃនៃអញមើល ។ ម្នាលអានន្ទ ឆ្មាន់ព្រះកេស បានទទួលព្រះបន្ទូលនៃព្រះបាទនិមិរាជថា ព្រះករុណាព្រះអង្គ ហើយដកសក់ស្កូវនោះ ដោយសណ្តាសឲ្យស្រួល រួចដាក់លើបាតព្រះហស្តនៃព្រះបាទនិមិរាជ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទនិមិរាជទ្រង់ព្រះរាជទានស្រុកសួយដល់ឆ្មាន់ព្រះកេសហើយ ឲ្យហៅព្រះរាជកុមារជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ ដល់បិតាហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ

សិតុំ ឯហិ ត្វំ តាត កុមារ ឥមំ រជ្ជំ បដិបជ្ជ អហំ បន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិស្សាមិ តេនហិ តាត កុមារ យទា ត្វម្បិ បស្សេយ្យាសិ សិរស្មឹ បលិតានិ ជាតានិ អថ កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យាសិ យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិមបុរិសោ អហោសិ យស្មឹ ខោ តាត កុមារ បុរិសយុគេ វត្តមានេ ឯវរូបស្ស កល្យាណស្ស វត្តស្ស សមុច្ឆេទោ ហោតិ សោ តេសំ អន្តិមបុរិសោ ហោតិ ។ តន្តាហំ តាត កុមារ ឯវំ វទាមិ យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាសិ មា ខោ មេ ត្វំ អន្តិមបុរិសោ អហោសីតិ ។



ម្នាលកុមារកូន អ្នកចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតានឹងកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវ កើតមានលើក្បាលក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកសួយដល់ជាងកោរកេស ហើយប្រដៅឲ្យព្រះរាជកុមារ ដែលជាបុត្រច្បងក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថាកល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសជាកន្ទុយជាន់បិតាឡើយ ម្នាលកុមារកូន កាលបើក្នុងបុរសណានៅមានហើយ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ ក្នុងបុរសនោះឯង ហៅថាបុរសជាកន្ទុយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសជាកន្ទុយជាន់បិតាឡើយ ។

(៦៦៣) អថខោ អានន្ទ និមិ រាជា កប្បកស្ស គាមវរំ ទត្វា ជេដ្ឋបុត្តំ កុមារំ សាធុកំ រជ្ជេ សមនុសាសិត្វា ឥមស្មិំយេវ មឃទេវម្ពវនេ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។ សោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ។ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ



(៦៦៣) ម្នាលអានន្ទ គ្រានោះ ព្រះបាទនិមិរាជទ្រង់ព្រះរាជទានស្រុកសួយដល់ឆ្មាំព្រះកេសស្រេចហើយ ប្រគល់ព្រះរាជកុមារជាបុត្រច្បង ក្នុងរាជសម្បត្តិឲ្យស្រួល ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវនេះឯង ។ ព្រះបាទនិមិរាជនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយ

ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ។ និមិ ខោ បនានន្ទ រាជា ចតុរាសីតិវស្សស-ហស្សានិ កុមារកីឡិតំ កីឡិ ចតុរាសីតិវស្សស-ហស្សានិ ឱបរជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ រជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ ឥមស្មិំយេវ មឃទេវម្ពវនេ អគារស្មា អនគារិយំ បព្វជិតោ ព្រហ្មចរិយំ ចរិ ។ សោ ចត្តារោ ព្រហ្មវិហារេ ការេត្វា កាយស្ស ភេទា បរម្មរណា ព្រហ្មលោកូ-បគោ អហោសិ ។

(៦៦) និមិស្ស ខោ បនានន្ទ រញ្ញោ កឡារជនកោ នាម បុត្តោ អហោសិ ។ សោ ន អគារស្មា អនគារិយំ បព្វជិ ។ សោ តំ កល្យាណំ វត្តំ សមុច្ឆិន្ទិ ។ សោ តេសំ អន្តិមបុ-



ទៅកាន់ទិសខាងលើ ទិសខាងក្រោម ទីទំទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអានន្ទ ព្រះបាទនិមិរាជនៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជកំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំកំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះបួសមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ ។ ព្រះបាទនិមិរាជនោះ ចំរើនព្រហ្មវិហារទាំង ៤ លុះបែកធ្លាយរាងកាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។

(៦៦) ម្នាលអានន្ទ ក៏ឯព្រះបាទនិមិរាជ ព្រះអង្គមានព្រះរាជបុត្តមួយអង្គ ព្រះនាមជា កឡារជនកៈ ។ ព្រះរាជបុត្តនោះ មិនចេញចាកផ្ទះបួសកាន់ផ្នួសឡើយ ។ ព្រះរាជបុត្តនោះ ក៏ផ្តាច់នូវកល្យាណ-វត្តនោះហើយ ។ បណ្តាក្សត្រិយ៍ទាំងនោះ ព្រះរាជបុត្តនោះជាបុរស

រិសោ អហោសិ ។ សិយា ខោ បន តេ អានន្ទ ឯវមស្ស អញ្ញោ នូន តេន សមយេន រាជា មឃទេវោ អហោសិ យេន តំ កល្យាណំ វត្តំ និហិតន្តិ ។ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ ។ អហំ តេន សមយេន រាជា មឃទេវោ អហោសិំ ។ អហំ តំ កល្យាណំ វត្តំ និហិនិំ មយា តំ កល្យាណំ វត្តំ និហិតំ បច្ឆិមា ជនតា អនុប្បវត្តេសិ ។ តំ ខោ បនានន្ទ កល្យាណំ វត្តំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ យាវទេវ ព្រហ្មលោកូបបត្តិយា ។ ឥទំ ខោ បនានន្ទ ឯតរហិ មយា កល្យាណំ វត្តំ និហិតំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតមញ្ចានន្ទ ឯតរហិ មយា កល្យាណំ វត្តំ និហិតំ ឯកន្តនិព្វិទាយ



ជាកថយជាងគេ ។ ម្នាលអានន្ទ ប្រហែលជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះបាទមឃទេវៈដទៃណា ដែលបានតាំងទុកនូវកល្យាណវត្តនោះ ព្រះបាទមឃទេវៈដទៃនោះឯង គឺបុគ្គលដទៃក្នុងសម័យនោះទេដឹង ។ ម្នាលអានន្ទ រឿងនុ៎ះអ្នកកុំគប្បីយល់យ៉ាងនេះឡើយ ។ តថាគតឯងជាមឃទេវៈ ក្នុងសម័យនោះ ។ តថាគតបានតាំងទុកនូវកល្យាណវត្តនោះហើយ ប្រជុំជនជាខាងក្រោយ បានប្រព្រឹត្តតាមកល្យាណវត្តនោះដែលតថាគត បានតាំងទុកស្រេចហើយ ។ ម្នាលអានន្ទ តែថាកល្យាណវត្តនោះ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ បានត្រឹមតែកើតក្នុងព្រហ្មលោកប៉ុណ្ណោះឯង ។ ម្នាលអានន្ទ ចំណែកខាងកល្យាណវត្តនេះ ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ម្នាលអានន្ទ កល្យាណវត្តដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដោយពិត

វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោ-
ធាយ និព្វានាយ សំវត្តតិ ។ អយមេវ អរិយោ
អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មា-
សង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ
សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ឥទំ ខោ
អានន្ទ ឯតរហិ មយា កល្យាណំ វត្តំ ឋបិតំ
ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ
អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។
តំ វោ អហំ អានន្ទ ឯវំ វទាមិ យេន មេ ឥទំ
កល្យាណំ វត្តំ ឋបិតំ អនុប្បវត្តេយ្យាថ មា ខោ
មេ តុម្ហេ បច្ឆិមបុរិសា អហុវត្ថ យស្មឹ ខោ អានន្ទ
បុរិសយុគេ វត្តមានេ ឯវរូបស្ស កល្យាណស្ស
វត្តស្ស សមុច្ឆេទោ ហោតិ សោ តេសំ
បច្ឆិមបុរិសោ ហោតិ ។ តំ វោ អហំ អានន្ទ



ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់
ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តើដូចម្តេច ។ មគ្គប្រកបដោយ
អង្គ ៨ ដ៏ប្រសើរនេះឯង គឺសេចក្តីយល់ឃើញប្រពៃ ១ សេចក្តីត្រិះរិះប្រពៃ ១
វាចាប្រពៃ ១ ការងារប្រពៃ ១ ការចិញ្ចឹមជីវិតប្រពៃ ១ សេចក្តីព្យាយាម
ប្រពៃ ១ សេចក្តីរលឹកប្រពៃ ១ ការតាំងចិត្តប្រពៃ ១ ម្នាលអានន្ទ
កល្យាណវត្តនេះឯង ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ
តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដោយពិត ដើម្បីប្រាសចាក
រាគៈ ដើម្បីរលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង
ដើម្បីព្រះនិព្វាន ។ ម្នាលអានន្ទ តថាគតពោលនូវកល្យាណវត្តនោះ
ដល់អ្នកទាំងឡាយថា កល្យាណវត្តនេះ តថាគតបានតាំងទុកហើយ អ្នក
ទាំងឡាយគប្បីប្រព្រឹត្តតាមចុះ អ្នកទាំងឡាយ កុំជាបុរសជាកថយផង
តថាគតឡើយ ម្នាលអានន្ទ កាលបើក្នុងបុរសណាមាននៅ កល្យាណ-
វត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅ បណ្តាបុរសទាំងនោះ
ក្នុងបុរសនោះឯង ហៅថាបុរសជាកថយ ។ ម្នាលអានន្ទ តថាគត

យំ វទាមិ យេន មេ ឥទំ កល្យាណំ វត្តំ និហិតំ អនុប្បវត្តេយ្យាថ មា ខោ មេ តុម្ហេ អន្តិមបុរិសា អហុវត្ថាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មឃាទេវសុត្តំ តតិយំ និដ្ឋិតំ ។

---



ពោលនូវកល្យាណវត្តនោះ ដល់អ្នកទាំងឡាយយ៉ាងនេះថា កល្យាណវត្តនេះ តថាគតបានតាំងទុកហើយ អ្នកទាំងឡាយគប្បីប្រព្រឹត្តតាមចុះ អ្នកទាំងឡាយ កុំជាបុរសជាកថយជាទីបំផុតឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់សូត្រនេះចប់ហើយ ព្រះអានន្ទដ៏មានអាយុ ជាអ្នកមានសេចក្តីត្រេកអរ ក៏បានត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មឃាទេវសូត្រ ទី ៣ ។

---

## ចតុត្ថំ មធុរសុត្តំ[1]

[៤៤៨] ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា មហាកច្ចានោ មធុរាយំ[2] វិហរតិ គុន្ទាវនេ[3] ។ អស្សោសិ ខោ រាជា មធុរោ អវន្តិបុត្តោ សមណោ ខលុ ភោ កច្ចានោ មធុរាយំ វិហរតិ គុន្ទាវនេ តំ ខោ បន ភវន្តំ កច្ចានំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ បណ្ឌិតោ វិយត្តោ[4] មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណបដិភាណោ វុឌ្ឍោ ចេវ អរហា ច សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ រាជា មធុរោ អវន្តិបុត្តោ ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ មធុរាយ និយ្យាសិ មហច្ចរាជានុភាវេន អាយស្មន្តំ មហាកច្ចានំ ទស្សនាយ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា

១ ឱ. មធុរិយសុត្តំ ។ ២ ឱ. ម. មធុរាយំ ។ ៣ ឱ. ម. គុន្ទាវនេ ។ ៤ ឱ. ព្យត្តោ ។

## មធុរសូត្រ ទី ៤

[៤៤៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកច្ចានៈមានអាយុ សម្រេចឥរិយាបថនៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា ។ ព្រះបាទមធុរាជអវន្តិបុត្ត បានឮដំណឹងថា ម្នាលគ្នាយើងដ៏ចំរើន សមណៈឈ្មោះកច្ចានៈ ឥឡូវនេះគង់នៅក្នុងគុន្ទាវ័ន ទៀបក្រុងមធុរា កិត្តិសព្ទដ៏ប្រពៃយ៉ាងនេះ របស់ព្រះកច្ចានៈដ៏ចំរើននោះឯង តែងផ្សាយទៅសព្វទិសថា លោកជាបណ្ឌិតឈ្លាសវៃ មានបញ្ញា ជាពហុស្សូត មានសំដីវិចិត្រ មានបញ្ញាដ៏ល្អ ជាអ្នកចាស់ព្រឹទ្ធផង ជាព្រះអរហន្តផង ការបានឃើញព្រះអរហន្តមានសភាពយ៉ាងនោះ ជាការញុំាងប្រយោជន៍ឲ្យសម្រេចដោយពិត ។ គ្រានោះ ព្រះបាទមធុរាជអវន្តិបុត្ត ទ្រង់ឲ្យរៀបចំយានទាំងឡាយដែលល្អ ៗ ទ្រង់ឡើងគង់យានដែលល្អ ៗ ហើយទ្រង់ស្តេចចេញចាកក្រុងមធុរា ដោយយានទាំងឡាយដែលល្អ ៗ ដើម្បីចូលទៅគាល់ព្រះមហាកច្ចានៈមានអាយុ ដោយរាជានុភាពដ៏ធំ ទ្រង់ស្តេចទៅដោយយាន កំណត់ត្រឹមផែនដី ដែលបរយានទៅបាន ហើយ

យានា បច្ចោរោហិត្វា បត្តិកោ វ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មធុរោ អវន្តិបុត្តោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច ព្រាហ្មណា ភោ កច្ចាន ឯវមាហំសុ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា វ(១) ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ឥធ(២) ភវំ កច្ចានោ កិមក្ខាយីតិ(៣) ។

[៦៦៦] ឃោសោយេវ ខោ ឯសោ មហារាជ លោកស្មឹ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ

១ ឱ. ព្រាហ្មណា ។ ២ ឱ. ម. ឥធ ។ ៣ ឱ. កិមាហាតិ ។



ទ្រង់យាងចុះអំពីយាន ទ្រង់ព្រះដំណើរទៅដោយព្រះបាទ ចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយ នឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏គង់នៅ ក្នុងទីដ៏សមគួរ ។ ព្រះបាទមធុររាជអវន្តិបុត្ត លុះគង់នៅ ក្នុងទីដ៏សមគួរហើយ មានព្រះបន្ទូលពាក្យនេះ នឹងព្រះមហាកច្ចានៈមានអាយុថា បពិត្រព្រះកច្ចានៈដ៏ចំរើន ពួកព្រាហ្មណ៍ នាំគ្នាពោលយ៉ាងនេះថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈថោក ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍ មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្ររបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ សេចក្តីនេះព្រះកច្ចានៈដ៏ចំរើន នឹងពោលដូចម្តេចទៅវិញ ។

(៦៦៦) ព្រះមហាកច្ចានៈថ្វាយព្រះពរថា បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់

អញ្ញោ វណ្ណោ ព្រាហ្មណោវ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណាវ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណាវ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ឥមិនាបិ ខោ ឯតំ(១) មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ តំ កឹ មញ្ញសិ មហារាជ ខត្តិយស្ស ចេបិ ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា ខត្តិយោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការប្បដិស្សាវី មនាបចារី បិយវាទី ។ ព្រាហ្មណោបិស្សាស្ស... វេស្សោបិស្សាស្ស... សុទ្ទោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការប្បដិស្សាវី មនាបចារី បិយវាទីតិ ។ ខត្តិយស្ស ចេបិ ភោ កច្ចាន ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា ខត្តិយោបិស្សាស្ស

១ ម. ឆ. ឥមិនាបេតំ ។



ជនដទៃជាវណ្ណៈថោក ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្តរបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងនិម្មិតកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មផង ។ បពិត្រមហារាជ ឯសំឡេងសុះសាយនេះគ្រាន់តែប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈថោក ។ បេ ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មផង ដោយហេតុណា ហេតុនុ៎ះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយ ដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច បើក្សត្រិយ៍ គប្បីសម្រេច (ផលានុភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ក្សត្រិយ៍ (ដទៃ) គប្បីជាអ្នកក្រោកឡើងមុន ផ្ទំក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឬទេ ។ ព្រាហ្មណ៍ក្ដី... វេស្សៈក្ដី... សុទ្ទៈក្ដី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្ដាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃក្សត្រិយ៍នោះឬទេ ។ ព្រះបាទមធុររាជត្រាស់ថា បពិត្រព្រះកច្ចានៈដ៏ចំរើន បើក្សត្រិយ៍ គប្បីសម្រេច (ផលានុភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស

បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទី ។ ព្រាហ្មណោបិស្សាស្ស... វេស្សោបិស្សាស្ស... សុទ្ទោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទីតិ ។

(៤៤៧) តំ កិំ មញ្ញសិ មហារាជ ព្រាហ្មណស្ស ចេបិ ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា ព្រាហ្មណោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទី ។ វេស្សោបិស្សាស្ស... សុទ្ទោបិស្សាស្ស... ខត្តិយោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទីតិ ។ ព្រាហ្មណស្ស ចេបិ ភោ កច្ចាន ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា ព្រាហ្មណោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទី ។ វេស្សោបិស្សាស្ស...សុទ្ទោបិស្សាស្ស...ខត្តិយោបិស្សាស្ស



ក្សត្រិយ៍ (នោះ) ក៏ជាអ្នកត្រូវតើនឡើងមុន ផ្ទុំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឯង ។ ព្រាហ្មណ៍ក្តី... វេស្សៈក្តី... សុទ្ទៈក្តី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឯង ។

(៤៤៧) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច បើព្រាហ្មណ៍សម្បូរសម្រេច (វត្ថុកាម) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើព្រាហ្មណ៍ (នោះ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីគាប់ចិត្ត នៃព្រាហ្មណ៍នោះ ឬទេ ។ វេស្សៈក្តី... សុទ្ទៈក្តី... ក្សត្រិយ៍ក្តី គប្បីជាអ្នកតើនឡើងមុន ផ្ទុំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃព្រាហ្មណ៍នោះ ឬទេ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន បើព្រាហ្មណ៍សម្បូរសម្រេច (វត្ថុកាម) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ព្រាហ្មណ៍ (នោះ) ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃព្រាហ្មណ៍នោះឯង ។ វេស្សៈក្តី... សុទ្ទៈក្តី... ក្សត្រិយ៍ក្តី

បុព្វុដ្ឋាយី បច្ឆានិបាតី កិង្ការបដិស្សាវី មនាបចារី បិយវាទីតិ ។

(៦២៨) តំ កិំ មញ្ញសិ មហារាជ វេស្សស្ស ចេបិ ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា វេស្សោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិង្ការបដិស្សាវី មនាបចារី បិយវាទី ។ សុទ្ទោបិស្សាស្ស... ខត្តិយោបិស្សាស្ស... ព្រាហ្មណោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិង្ការបដិស្សាវី មនាបចារី បិយវាទីតិ ។ វេស្សស្ស ចេបិ ភោ កច្ចាន ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា វេស្សោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិង្ការបដិស្សាវី មនាបចារី បិយវាទី ។ សុទ្ទោបិស្សាស្ស.. ខត្តិយោបិស្សាស្ស... ព្រាហ្មណោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កិង្ការបដិស្សាវី មនាបចារី បិយវាទីតិ ។



ក៏ជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វី ៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃព្រាហ្មណ៍នោះឯង ។

(៦២៨) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច បើវេស្សៈ គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើវេស្សៈ (ដទៃ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឬទេ ។ សូទ្ទៈក្តី... ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឬទេ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន បើវេស្សៈ គប្បីសម្រេច (ឥទ្ធានុភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស វេស្សៈ (ដទៃ) ក៏ជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឯង ។ សូទ្ទៈក្តី... ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី ក៏ជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឯង ។

[៦៦៨] តំ កឹ មញ្ញសិ មហារាជ សុទ្ទស្ស ចេបិ ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា សុទ្ទោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី មនាបចារី បិយវាទី ។ ខត្តិយោបិស្សាស្ស... ព្រាហ្មណោបិស្សាស្ស... វេស្សោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី មនាបចារី បិយវាទីតិ ។ សុទ្ទស្ស ចេបិ ភោ កច្ចាន ឥជ្ឈេយ្យ ធនេន វា ធញ្ញេន វា រជតេន វា ជាតរូបេន វា សុទ្ទោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី មនាបចារី បិយវាទី ។ ខត្តិយោបិស្សាស្ស... ព្រាហ្មណោបិស្សាស្ស.. វេស្សោបិស្សាស្ស បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី មនាបចារី បិយវាទីតិ ។



(៦៦៨) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច បើសុទ្ទៈគប្បីសម្រេច (សម្បុណ្ណភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើសុទ្ទៈ (ដទៃ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វី ៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃសុទ្ទៈនោះ ឬទេ ។ ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី... វេស្សៈក្តី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វី ៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះ ឬទេ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន បើសុទ្ទៈគប្បីសម្រេច (សម្បុណ្ណភាព) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស សុទ្ទៈ (ដទៃ) ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វី ៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃសុទ្ទៈនោះឯង ។ ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី.. វេស្សៈក្តី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វី ៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃសុទ្ទៈនោះឯង ។

[៤៣០] តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ អទ្ធា ខោ ភោ កច្ចាន ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នាហំ(១) ឯត្ថ កិញ្ចិ នានាករណំ សមនុបស្សាមីតិ ។

[៤៣១] ឥមិនាបិ ខោ ឯតំ មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណោ វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។បេ។ ព្រហ្មទាយាទាតិ តំ កឹ មញ្ញសិ មហារាជ ឥធាស្ស ខត្តិយោ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋី កាយស្ស ភេទា

១ ឱ. សំ ។ ម. ស្រំ ។



[៤៣០] បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើ ៗ គ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្ដេច ក្នុងវណ្ណៈទាំង៤ នុះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន ពិតមែនណាស់ហើយ កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើ ៗ គ្នាទេ ខ្ញុំមិនឃើញកំណើតផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នុះឡើយ ។

[៤៣១] បពិត្រមហារាជ សំឡេងសុះសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុះអាត្មាអញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ក្សត្រិយ៍ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាញុះញង់ ជាអ្នកមានវាចាទ្រគោះ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានសេចក្ដីលោភជាប្រក្រតី ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមានសេចក្ដីយល់ខុស លុះមានរាងកាយបែក

បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ ខត្តិយោបិ ហិ ភោ កច្ចាន បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចោ ផរុសវាចោ សម្ផប្បលាបី អភិជ្ឈាលុ ព្យាបន្នចិត្តោ មិច្ឆាទិដ្ឋិ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឯវំ មេ ឯត្ថ ហោតិ ឯវញ្ច បន មេ ឯតំ អរហតំ សុតន្តិ ។

(៦៣៦) សាធុ សាធុ មហារាជ សាធុ ខោ តេ ឯតំ មហារាជ ឯវំ ហោតិ សាធុ ច បន តេ ឯតំ អរហតំ សុតំ តំ កឹ មញ្ញសិ មហារាជ ឥធស្ស ព្រាហ្មណោ... ឥធស្ស វេស្សោ... ឥធស្ស សុទ្ទោ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋិ



ធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្តេច ក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន សូម្បីក្សត្រិយ៍ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាញុះញង់ ជាអ្នកមានវាចាទ្រគោះ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានសេចក្តីលោភជាប្រក្រតី ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមានសេចក្តីឃើញខុស លុះខន្ធកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះ ក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

(៦៣៦) បពិត្រមហារាជ ត្រូវហើយ ៗ បពិត្រមហារាជ រឿងនុ៎ះព្រះអង្គយល់ឃើញ យ៉ាងនេះ ជាការប្រពៃហើយ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ។ បេ ។ ជាអ្នកមានសេចក្តីឃើញខុស លុះ

កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ សុទ្ទោបិ ហិ ភោ កច្ចាន បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ ឯវំ មេ ឯត្ថ ហោតិ ឯវញ្ច បន មេ ឯតំ អរហតំ សុតន្តិ ។

(៦៣៣) សាធុ សាធុ មហារាជ សាធុ ខោ តេ ឯតំ មហារាជ ឯវំ ហោតិ សាធុ ច បន តេ ឯតំ អរហតំ សុតំ តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ អទ្ធា ខោ កច្ចាន(១) ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នាហំ ឯត្ថ កិញ្ចិ នានាករណំ សមនុបស្សាមីតិ ។

១ ម. ឧ. ភោ កច្ចាន ។



មានខន្ធកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្តេចក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន សូម្បីសុទ្ទៈជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ។ បេ ។ ជាអ្នកមានសេចក្តីឃើញខុស លុះមានខន្ធកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ នឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ខ្ញុំមានសេចក្តីនេះយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមក អំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

(៦៣៣) បពិត្រមហារាជ ត្រូវហើយៗ បពិត្រមហារាជ រឿងនុ៎ះព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្តេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា មិនមែនមិនស្មើគ្នាទេ ខ្ញុំមិនឃើញសេចក្តីផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

(៦៣៤) ឥមិនាបិ ខោ ឯតំ មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណាវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ តំ កឹ មញ្ញសិ មហារាជ ឥធស្ស ខត្តិយោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុមិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ(១) បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ ខត្តិយោបិ ហិ ភោ កច្ចាន បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ កាមេសុមិច្ឆា- ចារា បដិវិរតោ មុសាវាទា បដិវិរតោ បិសុណាយ វាចាយ បដិវិរតោ ផរុសាយ វាចាយ បដិវិរតោ សម្ផប្បលាបា បដិវិរតោ អនភិជ្ឈាលុ អព្យាបន្នចិត្តោ

១. បិសុណាវាចាយ ។



(៦៣៤) បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈថោក ។ បេ ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មនេះ ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ក្សត្រិយ៍ក្នុងលោកនេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ វៀរចាកពាក្យកុហក វៀរចាកពាក្យញុះញង់ វៀរចាកពាក្យទ្រគោះ វៀរចាកពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមិនមានសេចក្ដីលោភជាប្រក្រតី ជាអ្នកមានចិត្តមិនមានព្យាបាទ ជាអ្នកមានសេចក្ដីឃើញត្រូវ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬមួយមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្ដេច ក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន សូម្បីក្សត្រិយ៍ដែលវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ វៀរចាកពាក្យកុហក វៀរចាកពាក្យញុះញង់ វៀរចាកពាក្យទ្រគោះ វៀរចាកពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមិនមានសេចក្ដីលោភជាប្រក្រតី ជាអ្នកមានចិត្តមិនព្យាបាទ ជា

សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឯវំ មេ ឯត្ថ ហោតិ ឯវញ្ច បន មេ ឯតំ អរហតំ សុតន្តិ ។

(៤៣៩) សាធុ សាធុ មហារាជ សាធុ ខោ តេ ឯតំ មហារាជ ឯវំ ហោតិ សាធុ ច បន តេ ឯតំ អរហតំ សុតំ តំ កឹ មញ្ញសិ មហារាជ ឥធាស្ស ព្រាហ្មណោ... ឥធាស្ស វេស្សោ.. ឥធាស្ស សុទ្ទោ បាណាតិបាតា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ សុទ្ទោបិ ហិ ភោ កច្ចាន បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជេយ្យ ឯវំ មេ ឯត្ថ ហោតិ ឯវញ្ច បន មេ ឯតំ អរហតំ សុតន្តិ ។



អ្នកមានសេចក្តីឃើញត្រូវ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

(៤៣៩) បពិត្រមហារាជ ត្រូវហើយ ៗ បពិត្រមហារាជ រឿងនុ៎ះព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះដែលវៀរចាកការសម្លាប់សត្វ ។បេ។ ជាអ្នកមានសេចក្តីឃើញត្រូវ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្តេច ក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន សូម្បីសុទ្ទៈដែលវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ ។បេ។ ជាអ្នកមានសេចក្តីឃើញត្រូវ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ខ្ញុំមានសេចក្តីនេះយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

(២៣៦) សាធុ សាធុ មហារាជ សាធុ ខោ តេ ឯតំ មហារាជ ឯវំ ហោតិ សាធុ ច បន តេ ឯតំ អរហតំ សុតំ តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ អទ្ធា ខោ ភោ កច្ចាន ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នាហំ ឯត្ថ កិញ្ចិ នានាករណំ សមនុបស្សាមីតិ ។

(២៣៧) ឥធបន ខោ ឯតំ មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ តំ កឹ មញ្ញសិ មហារាជ ឥធ ខត្តិយោ សន្ធិំ វា ឆិន្ទេយ្យ និល្លោបំ វា ហរេយ្យ ឯកាគារិកំ វា ករេយ្យ បរិបន្ថេ វា តិដ្ឋេយ្យ បរទារំ វា គច្ឆេយ្យ តញ្ចេ តេ បុរិសា គហេត្វា ទស្សេយ្យុំ



(២៣៦) បពិត្រមហារាជ ត្រូវហើយ ៗ បពិត្រមហារាជ រឿងនុ៎ះព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើ ៗ គ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្តេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើ ៗ គ្នាពិតមែន ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

(២៣៧) បពិត្រមហារាជ សំឡេងសុសសាយនេះ កែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ។ បេ ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មផង ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច ក្សត្រិយ៍ក្នុងលោកនេះ កាត់ផ្ទាំងផ្ទះរបស់គេក្តី ប្លន់គេក្តី ធ្វើអំពើចោរលួចយកទ្រព្យរបស់ក្នុងផ្ទះតែមួយក្តី ចាំស្ទាក់ផ្លូវក្តី សេពភរិយារបស់គេក្តី បើពួកសេវកទាំងឡាយចាប់ក្សត្រិយ៍នោះបានហើយ នាំយកមកថ្វាយព្រះរាជ

អយំ តេ ទេវ ចោរោ អាគុំ(១) ចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ កិន្តិ នំ ករេយ្យាសីតិ ។ ឃាតេយ្យាម វា ភោ កច្ចាន ជាលេយ្យាម(២) វា បព្វាជេយ្យាម វា យថាបច្ចយំ វា ករេយ្យាម តំ កិស្ស ហេតុ យា ហិស្ស ភោ កច្ចាន បុព្វេ ខត្តិយោតិ សមញ្ញា សាស្ស អន្តរហិតា ចោរោត្វេវ សង្ខំ(៣) គច្ឆតីតិ ។

(៤៣៨) តំ កិំ មញ្ញសិ មហារាជ ឥធ ព្រាហ្មណោ... ឥធ វេស្សោ... ឥធ សុទ្ទោ សន្ធិំ វា ឆិន្ទេយ្យ និល្លោបំ វា ហរេយ្យ ឯកាគារិកំ វា ករេយ្យ បរិបន្ថេ វា តិដ្ឋេយ្យ បរទារំ វា គច្ឆេយ្យ តញ្ចេ តេ បុរិសា គហេត្វា ទស្សេយ្យុំ អយំ តេ ទេវ ចោរោ អាគុំ ចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ កិន្តិ នំ ករេយ្យាសីតិ ។ ឃាតេយ្យាម វា ភោ កច្ចាន

១ ឱ. ម. អាគុ ។ ២ ឱ. ម ជាបេយ្យាម ។ ៣ ម. សង្ខ្យំ ។



ថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍នេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តនូវអំពើអាក្រក់ បើព្រះអង្គប្រាថ្នានឹងដាក់ព្រះរាជអាជ្ញាណា សូមទ្រង់ដាក់ព្រះរាជអាជ្ញានោះ ដល់ចោរនេះចុះ តើព្រះអង្គគប្បីធ្វើនូវក្សត្រិយ៍នោះដូចម្ដេចទៅ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន យើងខ្ញុំគប្បីសម្លាប់ក៏បាន ដុតក៏បាន បណ្ដេញចេញក៏បាន ធ្វើឲ្យសមគួរតាមហេតុក៏បាន ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈដ៏ចំរើន ព្រោះថាឈ្មោះណា ដែលគេហៅថាក្សត្រិយ៍ដូច្នេះអំពីមុន ឈ្មោះនោះរបស់ក្សត្រិយ៍នោះ ក៏បាត់ទៅហើយ ឥឡូវនេះ ក្សត្រិយ៍នោះដល់នូវឈ្មោះថាជាចោរវិញ ។

(៤៣៨) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ព្រាហ្មណ៍ ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ គប្បីកាត់នូវជញ្ជាំងផ្ទះរបស់គេក្ដី ប្លន់គេក្ដី ធ្វើអំពើបៀតបៀនយកទ្រព្យរបស់ ក្នុងផ្ទះតែមួយក្ដី ចាំស្ទាក់ផ្លូវក្ដី សេពភរិយារបស់គេក្ដី បើបុរសទាំងឡាយចាប់សុទ្ទៈនោះបានហើយ នាំយកមកថ្វាយព្រះអង្គថា បពិត្រព្រះសម្មតិទេព សុទ្ទៈនេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តនូវអំពើអាក្រក់ បើព្រះអង្គប្រាថ្នានឹងដាក់ព្រះរាជអាជ្ញាណា សូមទ្រង់ដាក់ព្រះរាជអាជ្ញានោះ ដល់ចោរនេះចុះ តើព្រះអង្គគប្បីធ្វើនូវចោរនោះដូចម្ដេចទៅ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន យើងខ្ញុំគប្បីសម្លាប់ក៏បាន

ឃាតេយ្យាម វា បព្វាជេយ្យាម វា យថាបច្ចយំ វា ករេយ្យាម តំ កិស្ស ហេតុ យា ហិស្ស ភោ កច្ចាន បុព្វេ សុទ្ទោតិ សមញ្ញា សាស្ស អន្តរហិតា ចោរោត្វេវ សង្ខំ គច្ឆតីតិ ។

(៦៣៩) តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ អទ្ធា ខោ ភោ កច្ចាន ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នាហំ ឯត្ថ កិញ្ចិ នានាករណំ សមនុបស្សាមីតិ ។

(៦៤០) ឥមិនាបិ ខោ ឯតំ មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណោវ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ។ បេ ។ ព្រហ្មទាយាទាតិ តំ កឹ មញ្ញសិ មហារាជ ឥធ ខត្តិយោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ អស្ស វិរតោ បាណាតិបាតា វិរតោ អទិន្នាទានា វិរតោ មុសា-



កុំវះក៏បាន បណ្ដេញចេញក៏បាន ធ្វើឲ្យសមគួរតាមហេតុក៏បាន ដំណើរនោះ ព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈដ៏ចំរើន ព្រោះថាឈ្មោះណា ដែលគេហៅថា សុទ្ទៈដូច្នេះអំពីមុន ឈ្មោះរបស់សុទ្ទៈនោះក៏បាត់ទៅហើយ ឥឡូវនេះ សុទ្ទៈនោះដល់នូវឈ្មោះថាចោរវិញ ។

(៦៣៩) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗ គ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្ដេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗ គ្នាពិតមែន ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

(៦៤០) បពិត្រមហារាជ សំឡេងសុសសាយនេះតែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ។ បេ ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ក្សត្រិយ៍ក្នុងលោកនេះ បើកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកពាក្យ

ភវោ ឯកភត្តិកោ ព្រហ្មចារី សីលវា កល្យាណធម្មោ កិន្តិ នំ ករេយ្យាសីតិ ។ អភិវាទេយ្យាម វា ភោ បច្ចុដ្ឋេយ្យាម វា អាសនេន វា និមន្តេយ្យាម អភិនិមន្តេយ្យាម វា(១) នំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ធម្មិកំ វា អស្ស រក្ខាវរណគុត្តិំ សំវិទហេយ្យាម តំ កិស្ស ហេតុ យា ហិស្ស ភោ បុព្វេ ខត្តិយោតិ សមញ្ញា សាស្ស អន្តរហិតា សមណោត្វេវ សង្ខំ គច្ឆតីតិ ។

(៦៦១) តំ កិំ មញ្ញសិ មហារាជ ឥធ ព្រាហ្មណោ... ឥធ វេស្សោ... ឥធ សុទ្ទោ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ អស្ស វិរតោ បាណាតិបាតា វិរតោ អទិន្នាទានា វិរតោ មុសាវាទា ឯកភត្តិកោ ព្រហ្មចារី សីលវា កល្យាណធម្មោ កិន្តិ នំ ករេយ្យាសីតិ ។

១ ម. ម. បិ ។



កុហក ជាអ្នកបរិភោគភត្តតែម្ដង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីល មានកល្យាណធម៌ តើព្រះអង្គគប្បីធ្វើក្សត្រិយ៍នោះដូចម្ដេច ។ បពិត្រព្រះគោតមៈដ៏ចំរើន យើងខ្ញុំគប្បីថ្វាយបង្គំ គប្បីក្រោកឡើងទទួល គប្បីនិមន្តដោយអាសនៈ គប្បីទំនុកបំរុងបព្វជិតនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ឬគប្បីចាត់ចែងនូវការរក្សា ការពារ គ្រប់គ្រងប្រកបដោយធម៌ ដល់បព្វជិតនោះ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះគោតមៈដ៏ចំរើន ព្រោះថា ឈ្មោះណាដែលគេហៅថា ក្សត្រិយ៍ដូច្នេះអំពីមុន ឈ្មោះរបស់ក្សត្រិយ៍នោះក៏បាត់ទៅហើយ ឥឡូវនេះ ក្សត្រិយ៍នោះដល់នូវឈ្មោះថា សមណៈវិញ ។

(៦៦១) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះដូចម្ដេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ បើកោរសក់ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកពាក្យកុហក ជាអ្នកបរិភោគភត្តតែម្ដង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ មានសីល មានកល្យាណធម៌ តើព្រះអង្គគប្បីធ្វើសុទ្ទៈនោះដូចម្ដេច ។

អភិវាទេយ្យាម វា ភោ កច្ចាន បច្ចុដ្ឋេយ្យាម វា អាសនេន វា និមន្តេយ្យាម អភិនិមន្តេយ្យាម វា នំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ធម្មិកំ វា អស្ស រក្ខាវរណគុត្តឹ សំវិទហេយ្យាម តំ កិស្ស ហេតុ យា ហិស្ស ភោ កច្ចាន បុព្វេ ចោរោតិ សមញ្ញា សាស្ស អន្តរហិតា សមណោត្វេវ សង្ខំ គច្ឆតីតិ ។

(៤៤៤) តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ អទ្ធា ខោ ភោ កច្ចាន ឯវំ សន្តេ ឥមេ ចត្តារោ វណ្ណា សមសមា ហោន្តិ នាហំ ឯត្ថ កិញ្ចិ នានាករណំ សមនុបស្សាមីតិ ។



បពិត្រព្រះកច្ចានៈដ៏ចំរើន ខ្ញុំគប្បីថ្វាយបង្គំ គប្បីក្រោកឡើងទទួល គប្បីនិមន្តដោយអាសនៈ គប្បីទំនុកបំរុងបព្វជិតនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ឬគប្បីចាត់ចែងនូវការរក្សាការពារ គ្រប់គ្រងដ៏ប្រកបដោយធម៌ ដល់បព្វជិតនោះ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈដ៏ចំរើន ព្រោះថាឈ្មោះណាដែលគេហៅថាសុទ្ធៈអំពីមុន ឈ្មោះរបស់សុទ្ធៈនោះក៏បាត់ទៅហើយ ឥឡូវនេះសុទ្ធៈនោះដល់នូវឈ្មោះថាសមណៈវិញ ។

(៤៤៤) បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើ ៗ គ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្តេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង៤នេះ ជាវណ្ណៈស្មើ ៗ គ្នាពិតមែន ខ្ញុំមិនបានឃើញដំណើរផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

[៦៦៣] ឥមិនាបិ ខោ ឯតំ មហារាជ បរិយាយេន វេទិតព្វំ យថា ឃោសោយេវេសោ លោកស្មឹ ព្រាហ្មណា វ សេដ្ឋោ វណ្ណោ ហីនោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុក្កោ វណ្ណោ កណ្ហោ អញ្ញោ វណ្ណោ ព្រាហ្មណា វ សុជ្ឈន្តិ នោ អព្រាហ្មណា ព្រាហ្មណា វ ព្រហ្មុនោ បុត្តា ឱរសា មុខតោ ជាតា ព្រហ្មជា ព្រហ្មនិម្មិតា ព្រហ្មទាយាទាតិ ។

[៦៦៤] ឯវំ វុត្តេ រាជា មធុរោ អវន្តិបុត្តោ អាយស្មន្តំ មហាកច្ចានំ ឯតទវោច អភិក្កន្តំ ភោ កច្ចាន អភិក្កន្តំ ភោ កច្ចាន សេយ្យថាបិ ភោ កច្ចាន(១) និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា កច្ចានេន អនេកបរិយាយេន ធម្មោ បកាសិតោ

១ ម. ភោ កច្ចាន ។



[៦៦៣] បពិត្រមហារាជ សំឡេងសុះសាយនេះកើតក្រោកក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈថោក ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍ បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍មិនបរិសុទ្ធទេឡើយ ពួកព្រាហ្មណ៍ជាបុត្តរបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបាន តាក់តែងឡើង ជាអ្នកទទួលមត៌ករបស់ព្រហ្មផង ដោយហេតុណា ហេតុនុ៎ះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយនេះឯង ។

[៦៦៤] កាលបើព្រះកច្ចានៈបានសំដែងយ៉ាងនេះហើយ ព្រះបាទមធុររាជ អវន្តិបុត្ត បានពោលសេចក្តីនេះទៅនឹងព្រះមហាកច្ចានៈដ៏មានអាយុវិញថា បពិត្រព្រះកច្ចានៈដ៏ចំរើន ពីរោះណាស់ បពិត្រព្រះកច្ចានៈដ៏ចំរើន ពីរោះណាស់ បពិត្រព្រះកច្ចានៈដ៏ចំរើន ធម៌ដែលព្រះកច្ចានៈដ៏ចំរើនសំដែងហើយ ដោយអនេកបរិយាយនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេកាន់ប្រទីបប្រេងព្រោល បំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានចក្ខុ បានឃើញរូបទាំងឡាយ

ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

(៦៦៨) មា ខោ មំ ត្វំ មហារាជ សរណំ អគមាសិ តមេវ(១) ត្វំ ភគវន្តំ សរណំ គច្ឆ យមហំ សរណំ គតោតិ ។ កហំ បន ភោ កច្ចាន ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ បរិនិព្វុតោ ខោ មហារាជ ឯតរហិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោតិ ។

(៦៦៩) សចេ ហិ(២) មយំ ភោ កច្ចាន សុណេយ្យាម តំ ភគវន្តំ ទសសុ យោជនេសុ ទសហិ មយំ យោជនានិ គច្ឆេយ្យាម តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ សចេ ហិ(៣) មយំ ភោ កច្ចាន សុណេយ្យាម តំ ភគវន្តំ វីសតិយា យោជនេសុ... តឹសាយ(៤) យោជនេសុ... ចត្តាឡីសាយ

១ ម. តមេវ ។ ២-៣ ម. បិ ។ ៤ ម. តឹសតិយា ។



ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះកច្ចានៈដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹកចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះកច្ចានៈដ៏ចំរើន ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសក ដល់នូវសរណគមន៍ស្មើដោយជីវិត ។

(៦៦៨) បពិត្រមហារាជ ព្រះអង្គកុំយកអាត្មាភាព ជាទីពឹងទីរលឹកឡើយ អាត្មាភាពដល់ព្រះមានព្រះភាគណា ជាទីពឹង ទីរលឹក សូមព្រះអង្គ ដល់នូវព្រះមានព្រះភាគនោះ ជាទីពឹងទីរលឹកចុះ ។ បពិត្រព្រះកច្ចានៈដ៏ចំរើន ចុះឥឡូវនេះ តើព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គគង់នៅក្នុងទីណា ។ បពិត្រមហារាជ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គបរិនិព្វានហើយ ។

(៦៦៩) បពិត្រព្រះកច្ចានៈ ដ៏ចំរើន បើប្រសិនជាយើងខ្ញុំឮដំណឹងថា ព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ១០ យោជន៍ យើងខ្ញុំគប្បីទៅកាន់ទី ប្រមាណ ១០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះឲ្យបាន បពិត្រព្រះកច្ចានៈ ដ៏ចំរើន បើប្រសិនជា យើងខ្ញុំឮដំណឹងថា ព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ២០ យោជន៍... ៣០ យោជន៍... ៤០ យោជន៍...

យោជនេសុ... បញ្ញាសាយ យោជនេសុ បញ្ញាសម្បិ មយំ យោជនានិ គច្ឆេយ្យាម តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ យោជនសតេ ចេបិ មយំ ភោ កច្ចាន សុណេយ្យាម តំ ភគវន្តំ យោជនសតម្បិ មយំ គច្ឆេយ្យាម តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធំ យតោ ច ខោ ភោ កច្ចាន បរិនិព្វុតោ សោ ភគវា បរិនិព្វុតម្បិ មយំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ កច្ចានោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

មធុរសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---



៥០ យោជន៍សោត យើងខ្ញុំគប្បីទៅកាន់ទី ប្រមាណ ៥០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះឡើយ បពិត្រព្រះកច្ចានៈដ៏ចំរើន បើប្រសិនជាយើងខ្ញុំ ឮដំណឹងថា ព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ១០០ យោជន៍ យើងខ្ញុំគប្បីទៅកាន់ទីប្រមាណ ១០០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធនោះឡើយ បពិត្រព្រះកច្ចានៈដ៏ចំរើន កាលបើព្រះមានព្រះភាគអង្គនោះ ទ្រង់បរិនិព្វានហើយ យើងខ្ញុំសូមដល់នូវព្រះមានព្រះភាគ ដែលទ្រង់បរិនិព្វានហើយ ទាំងព្រះធម៌ទាំងព្រះភិក្ខុសង្ឃ ជាទីពឹង ទីរលឹក សូមព្រះកច្ចានៈដ៏ចំរើន ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ។

ចប់ មធុរសូត្រ ទី ៤ ។

# បញ្ចមំ ពោធិរាជកុមារសុត្តំ

(៤៦៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន ពោធិស្ស រាជកុមារស្ស កោកនុទោ(១) នាម បាសាទោ អចិរការិតោ ហោតិ អនជ្ឈាវុដ្ឋោ សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន ។ អថខោ ពោធិ រាជកុមារោ សញ្ជិកាបុត្តំ មាណវំ អាមន្តេសិ ឯហិ ត្វំ សម្ម សញ្ជិកាបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ ពោធិ ភន្តេ រាជកុមារោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ

១. ម. កោកនទោ ។

# ពោធិរាជកុមារសូត្រ ទី ៥

(៤៦៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងភេសកឡាវន(១) ជាទីឲ្យអភ័យដល់ម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ សម័យនោះឯង ពោធិរាជកុមារ មានការកសាងប្រាសាទ ឈ្មោះកោកនុទ(២) ទើបនឹងនឹងហើយថ្មី ៗ ដែលសមណព្រាហ្មណ៍ ឬបុគ្គលណាមួយ ជាតិជាមនុស្សមិនដែលធ្លាប់បាននៅអាស្រ័យ ។ លំដាប់នោះ ពោធិរាជកុមារ ទ្រង់ហៅសញ្ជិកាបុត្តមាណពមកប្រាប់ថា នែសញ្ជិកាបុត្រសំឡាញ់ អ្នកចូរមក អ្នកចូរទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះបាទយុគលព្រះមានព្រះភាគដោយត្បូង ទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពលនិងធម៌ជាគ្រឿងនៅសប្បាយ តាមពាក្យអញថា បពិត្រព្រះអង្គដ៏ចំរើន ពោធិរាជកុមារសូមថ្វាយបង្គំ នូវព្រះបាទយុគលព្រះអង្គដោយត្បូង ទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពល និងធម៌ជាគ្រឿងនៅសប្បាយ ហើយទូលយ៉ាងនេះទៀតថា

១ ព្រៃឈើហិង្គុ ឬជាព្រៃយក្សីឈ្មោះភេសកឡាតែងរក្សាគ្រប់គ្រង ។ ២ បានជាឈ្មោះថា កោកនុទៈ ព្រោះប្រាសាទនោះ មានការយោង មានសណ្ឋានដូចជាផ្កាឈូកក្រហម ។

អធិវាសេតុ កិរ ភន្តេ ភគវា ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ ឯវំ ភោតិ ខោ សញ្ជិកាបុត្តោ មាណវោ ពោធិស្ស រាជកុមារស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

(៦៤៨) ឯកមន្តំ និសិន្នោ ខោ សញ្ជិកាបុត្តោ មាណវោ ភគវន្តំ ឯតទវោច ពោធិ ភោ គោតម រាជកុមារោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភវំ គោតមោ ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សញ្ជិកាបុត្តោ មាណវោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា យេន ពោធិ រាជកុមារោ តេនុបសង្កមិ ឧបសង្កមិត្វា ពោធឹ រាជកុមារំ ឯតទវោច អវោចុម្ហា ខោ មយំ



បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ សញ្ជិកាបុត្តមាណព ទទួលព្រះបន្ទូលពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

(៦៤៨) សញ្ជិកាបុត្តមាណព លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចំរើន ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទយុគលព្រះគោតមដ៏ម្ចាស់ដោយត្បូង ក្រាបទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពលនឹងធម៌ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង សញ្ជិកាបុត្តមាណពដឹងថា ព្រះមានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈ ចូលទៅគាល់ពោធិរាជកុមារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលពោធិរាជកុមារ យ៉ាងនេះថា ខ្ញុំព្រះអង្គបានក្រាបបង្គំទូល

ភោតោ វចនេន តំ ភវន្តំ គោតមំ ពោធិ ភោ គោតម រាជកុមារោ ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អធិវាសេតុ កិរ ភវំ គោតមោ ពោធិស្ស រាជកុមារស្ស ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ អធិវុត្ថញ្ច បន សមណេន គោតមេនាតិ ។ អថខោ ពោធិ រាជកុមារោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ[១] បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា កោកនទញ្ច បាសាទំ ឱទាតេហិ ទុស្សេហិ សន្ថរាបេត្វា[២] យាវ បច្ឆិមសោបានកឡេវរា សញ្ចិកាបុត្តំ មាណវំ អាមន្តេសិ ឯហិ ត្វំ សម្ម សញ្ចិកាបុត្ត យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា ភគវតោ កាលំ អារោចេហិ កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ ឯវំ ភោតិ ខោ សញ្ចិកាបុត្តោ មាណវោ ពោធិស្ស រាជកុមារស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ កាលំ អារោចេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។

១ ឱ. ម. អច្ចយេន សកេ និវេសនេ ។ ២ ម. សន្ថរាបេត្វា ។



ព្រះគោតមដ៏ចំរើននោះ តាមបន្ទូល របស់ទ្រង់ហើយថា បពិត្រព្រះគោតមដ៏ចំរើន ពោធិរាជកុមារសូមថ្វាយបង្គំនូវព្រះបាទយុគលព្រះគោតមដ៏ចំរើនដោយត្បូង ទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពលនិងធម៌ជាទីនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ព្រះគោតមជាម្ចាស់ក៏បានទទួលនិមន្តហើយ ។ លុះព្រឹកឡើង ពោធិរាជកុមារតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គហើយ ឲ្យក្រាលកោកនុទប្រាសាទ ដោយសំពត់សទាំងឡាយ ដរាបដល់កាំជណ្តើរជាន់ខាងក្រោមបំផុត ហើយត្រាស់ហៅសញ្ចិកាបុត្តមាណពមកថា ម្នាលសញ្ចិកាបុត្តសំឡាញ់ អ្នកចូរមក អ្នកចូរទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលភត្តកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។ សញ្ចិកាបុត្តមាណព ទទួលព្រះបន្ទូលរបស់ពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំទូលភត្តកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

[២៦៨] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ពោធិស្ស រាជកុមារស្ស និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន ពោធិ រាជកុមារោ ពហិទ្វារកោដ្ឋកេ ឋិតោ ហោតិ ភគវន្តំ អាគមយមានោ ។ អទ្ទសា ខោ ពោធិ រាជកុមារោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន បច្ចុគ្គន្ត្វា ភគវន្តំ អភិវាទេត្វា បុរក្ខិត្វា យេន កោកនទោ បាសាទោ តេនុបសង្កមិ ។ អថខោ ភគវា បច្ឆិមំ សោបាណកឡេវរំ(១) និស្សាយ អដ្ឋាសិ ។ អថខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អភិរុហតុ ភន្តេ ភគវា ទុស្សានិ អភិរុហតុ សុគតោ ទុស្សានិ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អភិរុហតុ ភន្តេ ភគវា ទុស្សានិ អភិរុហតុ សុគតោ ទុស្សានិ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

១ ម. សោបានកឡេវរំ ។



(២៦៨) គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ចូលដំណើរទៅកាន់និវេសនដ្ឋានរបស់ពោធិរាជកុមារ ។ សម័យនោះឯង ពោធិរាជកុមារ ឋិតនៅខាងក្រៅក្លោងទ្វារដើម្បីចាំព្រះមានព្រះភាគ ។ ពោធិរាជកុមារ បានឃើញព្រះមានព្រះភាគស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រោកទៅទទួល ក្រាបថ្វាយបង្គំព្រះមានព្រះភាគ នាំស្តេចទៅកាន់កោកនុទប្រាសាទ ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ឈប់ផ្អឹងនៅត្រង់ជណ្តើរជាន់ខាងក្រោមបំផុត ។ លំដាប់នោះ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគតទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីប្រយោជន៍និងសេចក្តីសុខ ដល់ខ្ញុំព្រះអង្គអស់កាលជាយូរអង្វែង ។ កាលពោធិរាជកុមារ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់នៅស្ងៀម ។ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះ អស់វារៈពីរដងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគតទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីប្រយោជន៍និងសេចក្តីសុខដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។

ឯវំ វុត្តេ(១) ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អធិវាសេតុ ភន្តេ ភគវា ទុស្សានិ អភិរុហតុ សុគតោ ទុស្សានិ យំ មម អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អបលោកេសិ ។ អថខោ អាយស្មា អានន្ទោ ពោធី រាជកុមារំ ឯតទវោច សំហរតុ រាជកុមារ ទុស្សានិ ន ភគវា ចេលបដិកំ អក្កមិស្សតិ បច្ឆិមំ ជនតំ តថាគតោ អបលោកេតីតិ ។ អថខោ ពោធិ រាជកុមារោ ទុស្សានិ សំហរាបេត្វា ឧបរិ កោកនទេ បាសាទេ អាសនានិ(២) បញ្ញាបេសិ ។ អថខោ ភគវា កោកនទំ បាសាទំ អភិរុហិត្វា បញ្ញត្តេ អាសនេ និ-សីទិ សទ្ធិំ ភិក្ខុសង្ឃេន ។ អថខោ ពោធិ រាជកុមារោ

១. ទុតិយម្បិ ខោតិ ទិស្សតិ ។ ២. អាសនន្តិ យុត្តំ ។



កាលពោធិរាជកុមារ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់នៅស្ងៀម ។ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះ អស់វារៈជាគំរប់ ៣ ដងថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគតទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីប្រយោជន៍ដល់សេចក្ដីសុខដល់ខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បែរព្រះភក្ត្រទៅរកព្រះអានន្ទមានអាយុ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ក៏មានថេរវាចាទៅនឹងពោធិរាជកុមារយ៉ាងនេះថា បពិត្រព្រះរាជកុមារ សូមទ្រង់សាសំពត់ចេញ ព្រះមានព្រះភាគ ព្រះអង្គមិនទ្រង់ជាន់ផ្ទាំងសំពត់ទេ ព្រះសុគតព្រះអង្គទ្រង់ប្រមើលមើលនូវប្រជុំជនជាខាងក្រោយ ។ គ្រានោះ ពោធិរាជកុមារ ទ្រង់ឲ្យសាសំពត់ចេញហើយ ទ្រង់ឲ្យក្រាលអាសនៈខាងលើកោកនុទប្រាសាទ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ឡើងកាន់កោកនុទប្រាសាទ ហើយគង់លើអាសនៈ ដែលគេក្រាលស្រេចហើយ ព្រមទាំងភិក្ខុសង្ឃ ។ លំដាប់នោះ ពោធិរាជកុមារ បាន

ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។ អថខោ ពោធិ រាជកុមារោ ភគវន្តំ ភុត្តាវឹ ឱនីតបត្ត-បាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច មយ្ហំ ខោ ភន្តេ ឯវំ ហោតិ ន ខោ សុខេន សុខំ អធិគន្តព្វំ ទុក្ខេន ខោ សុខំ អធិគន្តព្វន្តិ ។

(៦៨០) មយ្ហម្បិ ខោ រាជកុមារ បុព្វេវ សម្ពោធា អនភិសម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ ន ខោ សុខេន សុខំ អធិគន្តព្វំ ទុក្ខេន ខោ សុខំ អធិគន្តព្វន្តិ ។ សោ ខោ អហំ រាជកុមារ អបរេន សមយេន ទហរោវ សមានោ សុសុ-កាឡកេសោ ភទ្រេន យោព្វនេន សមន្នា-គតោ បឋមេន វយសា អកាមកានំ មាតាបិតូនំ



អង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសា ថ្វាយដោយព្រះហស្តព្រះអង្គឯង ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ត្រាតែទ្រង់ហាមឃាត់ ។ ទើបពោធិរាជកុមារ កំណត់ដឹងថា ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ គង់ក្នុងទីដ៏សមគួរ ។ ពោធិរាជកុមារ លុះគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះ យ៉ាងនេះថា សេចក្ដីសុខ បុគ្គលមិនគប្បីបាន ដោយសេចក្ដីសុខទេ សេចក្ដីសុខ បុគ្គលត្រូវបាន ដោយសេចក្ដីទុក្ខ ។

(៦៨០) ម្នាលរាជកុមារ ក៏កាលតថាគត នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីការត្រាស់ដឹង មានសេចក្ដីត្រិះរិះ យ៉ាងនេះថា សេចក្ដីសុខ បុគ្គលមិនគប្បីបាន ដោយសេចក្ដីសុខទេ សេចក្ដីសុខ បុគ្គលត្រូវបានដោយសេចក្ដីទុក្ខ ។ ម្នាលរាជកុមារ សម័យខាងក្រោយមក តថាគតនោះនៅជាកំលោះ មានសក់ខ្មៅស្រិល ប្រកបព្រមដោយវ័យដ៏ចំរើន គឺនៅក្នុងបឋមវ័យនៅឡើយ កាលមាតានឹង

អស្សុមុខានំ រោទន្តានំ កេសមស្សុំ ឱហារេត្វា កាសា-
យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជឹ ។
សោ ឯវំ បព្វជិតោ សមានោ កឹកុសលគវេសី អនុត្តរំ
សន្តិវរបទំ បរិយេសមានោ យេន អាឡារោ កាលា-
មោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ
ឯតទវោចំ ឥច្ឆាមហំ អាវុសោ កាលាម ឥមស្មឹ
ធម្មវិនយេ ព្រហ្មចរិយំ ចរិតុំ ។ ឯវំ វុត្តេ រាជកុមារ
អាឡារោ កាលាមោ មំ ឯតទវោច វិហរតាយស្មា
តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិ-
រស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា
ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ រាជកុមារ
នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ
អហំ រាជកុមារ តាវតកេនេវ ឱដ្ឋបហតមត្តេន លបិ-
តលាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជា-
នាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។



បិតាមិនចង់ (ឲ្យបួស) មានមុខទទឹកដោយទឹកភ្នែក កំពុងទួញ
យំ ក៏បានកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ
ចេញចាកផ្ទះចូលមកបួស ។ កាលតថាគតនោះ បានបួសយ៉ាងនេះហើយ
ក៏ស្វែងរក នូវគឺកុសលសន្តិវរបទដ៏ប្រសើរ ក៏បានចូលទៅរកអាឡារ-
តាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បានពោលសេចក្តីនេះ
ទៅនឹងអាឡារតាបសកាលាមគោត្រថា ម្នាលអាវុសោកាលាមៈ យើង
ប្រាថ្នានឹងមកប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះផង ។ ម្នាល
រាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ អាឡារតាបសកាលា-
មគោត្រ បានពោលតបនឹងតថាគតយ៉ាងនេះថា អ្នកដ៏មានអាយុ ចូរ
នៅចុះ ធម៌នេះក៏ប្រាកដដូច្នោះ បើជាបុរសអ្នកដឹងនូវសេចក្តីហើយ មិនយូរ
ឡើយ គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញា
ដ៏ឧត្តមដោយខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ដោយនិយាយថា
ចាំង៤ បាន ។ ម្នាលរាជកុមារ តថាគតនោះ ក៏បានរៀនធម៌នោះឆាប់
រហ័សមិនយូរឡើយ ។ ម្នាលរាជកុមារ តថាគតនោះ ពោលបាន
ដល់ទៅញាណវាទនឹងថេរវាទ ដោយការគ្រាន់តែទន្ទេញ ដោយ
បបូរមាត់ នឹងដោយការគ្រាន់តែចរចាទៅមកប៉ុណ្ណោះឯង មួយទៀត
តថាគតក្តី បុគ្គលដទៃក្តី ប្តេជ្ញាថា យើងដឹង យើងឃើញដូច្នេះ ។

តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ អាឡារោ កាលាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា អាឡារោ កាលាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។ អថខ្វាហំ រាជកុមារ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ កិត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ[១] ។ ឯវំ វុត្តេ រាជកុមារ អាឡារោ កាលាមោ អាកិញ្ចញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ វិរិយំ មយ្ហំបត្ថិ វិរិយំ ន ខោ អាឡារស្សេវ កាលាមស្ស អត្ថិ សតិ... សមាធិ... បញ្ញា មយ្ហំបត្ថិ បញ្ញា

១ ម. ឧបសម្បជ្ជ វិហរាមីតិ បវេទេសីតិ ទិស្សតិ ។



ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបសកាលាមគោត្រ នឹងញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌នេះថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ដូច្នេះ នឹងគង់ប្រាប់ដោយត្រឹមតែសទ្ធាប៉ុណ្ណោះនោះក៏ទេ ដោយពិតមែននោះ អាឡារតាបសកាលាមគោត្រ គ្រាន់តែដឹង គ្រាន់តែឃើញធម៌នេះប៉ុណ្ណោះ ។ ម្នាលរាជកុមារ កាលនោះតថាគត បានចូលទៅរកអាឡារតាបសកាលាមគោត្រទៀត លុះចូលទៅដល់ហើយ បាននិយាយនឹងអាឡារតាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ លោកធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេឬ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ អាឡារតាបសកាលាមគោត្រ ទើបបានប្រកាសប្រាប់នូវអាកិញ្ចញ្ញាយតនជ្ឈាន ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មិនមែនមានសទ្ធាតែអាឡារតាបសកាលាមគោត្រម្នាក់ឯងទេ សូម្បីយើង ក៏មានសទ្ធាដូច្នោះដែរ មិនមែនមានវីរិយៈតែអាឡារតាបសកាលាមគោត្រម្នាក់ឯងទេ សូម្បីយើង ក៏មានវីរិយៈដូច្នោះដែរ សតិ...សមាធិ... បញ្ញា សូម្បីយើងក៏មានបញ្ញាដូច្នោះដែរ

យន្នូនាហំ យំ ធម្មំ អាឡារោ កាលាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ តស្ស ធម្មស្ស សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ រាជកុមារ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថខ្វាហំ រាជកុមារ យេន អាឡារោ កាលាមោ តេនុបសង្កមឹ ឧបសង្កមិត្វា អាឡារំ កាលាមំ ឯតទវោចំ ឯត្តាវតា នោ អាវុសោ កាលាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។ អហម្បិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម



តែខ្ញុំគិតយ៉ាងដូចម្ដេច យើងគ្រាន់តែកាន់សេចក្ដីព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលអាឡារតាបសកាលាមគោត្រ ញ៉ាំងអ្នកដទៃឲ្យដឹងថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ដូច្នេះទៀតនឹងកើតបាន ។ ម្នាលរាជកុមារ មិនយូរប៉ុន្មាន ឥតអាក់អោរ បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងយ៉ាងឆាប់រហ័ស ។ ម្នាលរាជកុមារ លំដាប់នោះ តថាគតបានចូលទៅរកអាឡារតាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បានពោលនឹងអាឡារតាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណេះឬ ។ ម្នាលអាវុសោ យើងបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងបាន ត្រឹមតែប៉ុណ្ណេះឯង ។ អាឡារតាបស ឆ្លើយតបថា ម្នាលអាវុសោ ខ្ញុំឯងក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងតែប៉ុណ្ណេះដែរ ។ ម្នាលអាវុសោ យើងពេញជាមានលាភហើយ ម្នាលអាវុសោ ភាពជាមនុស្ស យើងបានដោយល្អហើយ ព្រោះពួកយើងបានឃើញសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នកមាន

ឥតិ យោហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តមហំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមិ ឥតិ យាហំ ធម្មំ ជានាមិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តមហំ ធម្មំ ជានាមិ ឥតិ យាទិសោ អហំ តាទិសោ តុវំ យាទិសោ តុវំ តាទិសោ អហំ ។ ឯហិ ទានិ អាវុសោ ឧភោ វសន្តា ឥមំ គណំ បរិហរាមាតិ ។ ឥតិ ខោ រាជកុមារ អាឡារោ កាលាមោ អាចរិយោ មេ សមានោ អន្តេវាសឹ មំ សមានំ អត្តនោ សមសមំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ នាយំ ធម្មោ និព្វិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ



អាវុ ហេតុនោះ យើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់ធម៌ណា អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងដូច្នោះដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ធម៌ណា ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង យើងក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់ធម៌នោះដែរ ព្រោះហេតុនោះ យើងបានដឹងធម៌ណា អ្នកក៏ដឹងធម៌នោះដែរ អ្នកដឹងធម៌ណា យើងក៏ដឹងធម៌នោះដែរ ព្រោះហេតុនោះ យើងយ៉ាងណា អ្នកក៏យ៉ាងនោះដែរ អ្នកយ៉ាងណា យើងក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ ឥឡូវនេះ អ្នកចូរមកចុះ យើងទាំងពីរនាក់ នឹងនៅជួយគ្រប់គ្រងគណៈនេះ ។ ម្នាលរាជកុមារ ព្រោះហេតុនោះ អាឡារតាបសកាលាមគោត្រ កាលជាអាចារ្យរបស់តថាគត ក៏បានតាំងតថាគត កាលនៅជាអន្តេវាសិកឲ្យស្មើនឹងខ្លួន ហើយបូជាតថាគតដោយការបូជាដ៏លើសលុប ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌នេះមិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនមែនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹង មិនមែនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនមែន

ន និព្វានាយ សំវត្តតិ យាវទេវ អាកិញ្ចញ្ញាយតនូបប-ត្តិយាតិ ។ សោ ខោ អហំ រាជកុមារ តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ អបក្កមឹ ។

(៤៨១) សោ ខោ អហំ រាជកុមារ កឹកុសល-គវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ ឥច្ឆាមហំ អាវុសោ រាម ឥមស្មឹ ធម្មវិនយេ ព្រហ្មចរិយំ ចរិតុន្តិ ។ ឯវំ វុត្តេ រាជកុមារ ឧទ្ទកោ រាមបុត្តោ មំ ឯតទវោច វិហរតាយស្មា តាទិសោ អយំ ធម្មោ យត្ថ វិញ្ញូ បុរិសោ នចិរស្សេវ សកំ អាចរិយកំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ សោ ខោ អហំ រាជកុមារ នចិរស្សេវ ខិប្បមេវ តំ ធម្មំ បរិយាបុណឹ ។ សោ ខោ អហំ រាជកុមារ តាវតកេនេវ ឱដ្ឋបហតមត្តេន លបិត-លាបនមត្តេន ញាណវាទញ្ច វទាមិ ថេរវាទញ្ច ជា-នាមិ បស្សាមីតិ ច បដិជានាមិ អហញ្ចេវ អញ្ញេ ច ។



ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលរាជកុមារ តថាគតនោះ មិនបានពេញចិត្តនឹងធម៌នោះ បានគេចចេញចាកធម៌នោះ ហើយចៀសចេញទៅ ។

(៤៨១) ម្នាលរាជកុមារ តថាគតនោះ កំពុងស្វែងរក កឹកុសល សន្តិវរបទដ៏ប្រសើរ បានចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងឧទ្ទករាមបុត្រថា ម្នាលអាវុសោរាមៈ យើងប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះដែរ ។ ម្នាលរាជ-កុមារ កាលតថាគតពោលយ៉ាងនេះហើយ ឧទ្ទករាមបុត្របានពោលនឹងតថាគតយ៉ាងនេះថា អ្នកមានអាយុ ចូរនៅចុះ ធម៌នេះប្រាកដដូច្នោះ បើជាបុរសអ្នកដឹងសេចក្ដីហើយ មិនយូរប៉ុន្មាន គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងបាន ។ ម្នាលរាជកុមារ តថាគតនោះ ក៏បានរៀនធម៌នោះ យ៉ាងឆាប់រហ័ស មិនយូរប៉ុន្មាន ។ ម្នាលរាជកុមារ តថាគតនោះ បានដល់នូវញា-ណវាទនឹងថេរវាទ ដោយអាការគ្រាន់តែទះធ្មេញ ដោយបបូរមាត់ នឹងដោយអាការគ្រាន់តែពោលទៅមកប៉ុណ្ណោះឯង មួយទៀត តថាគតក្ដី បុគ្គលដទៃក្ដី ប្ដេជ្ញាថា យើងដឹង យើងឃើញដូច្នេះ ។

តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ រាមោ ឥមំ ធម្មំ កេវលំ សទ្ធាមត្តកេន សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេតិ អទ្ធា រាមោ ឥមំ ធម្មំ ជានំ បស្សំ វិហរតីតិ ។ អថ ខ្វាហំ រាជកុមារ យេន ឧទ្ទកោ រាមបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ ឯតទវោចំ កិត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។ ឯវំ វុត្តេ រាជកុមារ ឧទ្ទកោ រាមបុត្តោ នេវសញ្ញានា-សញ្ញាយតនំ បវេទេសិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ រាមស្សេវ អហោសិ សទ្ធា មយ្ហំបត្ថិ សទ្ធា ន ខោ រាមស្សេវ អហោសិ វីរិយំ ។បេ។ សតិ... សមាធិ... បញ្ញា មយ្ហំបត្ថិ បញ្ញា



ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា រាមបុត្រនេះ មិនញុំាងធម៌ឲ្យកើតទេ ឲ្យដឹងច្បាស់នូវធម៌នេះថា គាត់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងដូច្នេះ មិនមែនសម្រេចដោយត្រឹមតែសទ្ធាប៉ុណ្ណោះនោះទេ ដោយពិតមែននោះ រាមបុត្រនេះ ព្រោះតែដឹង ព្រោះតែឃើញធម៌នេះប៉ុណ្ណោះ ។ ម្នាលរាជកុមារ កាលនោះ តថាគតចូលទៅរកឧទ្ទកៈរាមបុត្រទៀត លុះចូលទៅដល់ហើយ ក៏បានពោលនឹងឧទ្ទកៈរាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងធម៌ឲ្យដល់ព្រមដឹងបានត្រឹមតែប៉ុណ្ណោះទេឬ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ ឧទ្ទកៈរាមបុត្រ ក៏បានប្រកាសប្រាប់ដល់ទៅនេវសញ្ញា-នាសញ្ញាយតនជ្ឈាន ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មិនមែនមានសទ្ធា តែរាមបុត្រម្នាក់ឯងទេ សូម្បីយើងក៏មានសទ្ធាដូចគ្នាដែរ មិនមែនមានវីរិយៈ តែរាមបុត្រម្នាក់ឯងទេ ។បេ។ សតិ...សមាធិ...បញ្ញា សូម្បីយើងក៏មានបញ្ញាដូចគ្នា

យន្នូនាហំ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិ-
កត្វា ឧបសម្បជ្ជ វិហរាមីតិ បវេទេសិ តស្ស ធម្មស្ស
សច្ឆិកិរិយាយ បទហេយ្យន្តិ ។ សោ ខោ អហំ
រាជកុមារ នចិរស្សេវ ខិប្បមេវ តំ ធម្មំ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសឹ ។ អថ-
ខ្វាហំ រាជកុមារ យេន ឧទ្ទកោ រាមបុត្តោ
តេនុបសង្កមឹ ឧបសង្កមិត្វា ឧទ្ទកំ រាមបុត្តំ
ឯតទវោចំ ឯត្តាវតា នោ អាវុសោ រាម ឥមំ ធម្មំ
សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសីតិ ។
ឯត្តាវតា ខោ អហំ អាវុសោ ឥមំ ធម្មំ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេមីតិ ។
អហំបិ ខោ អាវុសោ ឯត្តាវតា ឥមំ ធម្មំ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរាមីតិ ។
លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ យេ
មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ បស្សាម



ដែរ តែទុកជាយ៉ាងដូចម្ដេចក៏ដោយ យើងត្រូវតែតម្កល់ព្យាយាម ដើម្បី
ធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលឧទ្ទករាមបុត្រ ញុំាងអ្នកដទៃឲ្យដឹងថា
អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ដូច្នេះ
ឲ្យទាន់តែបាន ។ ម្នាលរាជកុមារ មិនយូរប៉ុន្មាន តថាគតនោះឆាប់
ធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងយ៉ាងឆាប់
រហ័ស ។ ម្នាលរាជកុមារ លំដាប់នោះ តថាគតបានចូលទៅរកឧទ្ទករាម-
បុត្រ លុះចូលទៅដល់ហើយ បានពោលនឹងឧទ្ទករាមបុត្រយ៉ាងនេះថា
ម្នាលអាវុសោរាមៈ លោកបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏
ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណេះទេឬ ។
ឧទ្ទករាមបុត្រឆ្លើយតបថា ម្នាលអាវុសោ យើងបានធ្វើឲ្យជាក់ច្បាស់នូវធម៌
នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងបាន
ត្រឹមតែប៉ុណ្ណេះទេ ។ ម្នាលអាវុសោ ខ្ញុំឯងក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ
ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងតែប៉ុណ្ណេះដែរ ។ ម្នាលអាវុសោ យើង
ពេញជាមានលាភហើយ ម្នាលអាវុសោ ការជាមនុស្សយើងបានដោយ
ល្អហើយ ព្រោះយើងបានឃើញសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នក

ឥតិ យំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសិ តំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ យំ ត្វំ ធម្មំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរសិ តំ ធម្មំ រាមោ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ បវេទេសិ ឥតិ យំ ធម្មំ រាមោ អភិញ្ញាសិ តំ ត្វំ ធម្មំ ជានាសិ យំ ត្វំ ធម្មំ ជានាសិ តំ ធម្មំ រាមោ អភិញ្ញាសិ ឥតិ យាទិសោ រាមោ អហោសិ តាទិសោ តុវំ យាទិសោ តុវំ តាទិសោ រាមោ អហោសិ ឯហិ ទានិ អាវុសោ តុវំ ឥមំ គណំ បរិហរាតិ ។ ឥតិ ខោ រាជកុមារ ឧទ្ទកោ រាមបុត្តោ សព្រហ្មចារី មេ សមានោ អាចរិយដ្ឋានេ មំ ឋបេសិ ឧឡារាយ ច មំ បូជាយ បូជេសិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ នាយំ ធម្មោ និព្ពិទាយ ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ



ដ៏មានអាយុ ព្រោះហេតុនោះ លោករាមបុត្រ បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌ណា អ្នកក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងដូច្នោះដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង លោករាមៈ ក៏បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌នោះដែរ ព្រោះហេតុនោះ លោករាមៈ បានដឹងនូវធម៌ណា អ្នកក៏ដឹងធម៌នោះដែរ អ្នកដឹងធម៌ណា លោករាមៈ ក៏ដឹងធម៌នោះដែរ ព្រោះហេតុនោះ លោករាមៈយ៉ាងណា អ្នកក៏យ៉ាងនោះដែរ អ្នកយ៉ាងណា លោករាមៈក៏យ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ អ្នកចូរមកចុះ ចូរអ្នកគ្រប់គ្រងគណៈនេះចុះ ។ ម្នាលរាជកុមារ ព្រោះហេតុនោះ ឧទ្ទករាមបុត្រ កាលជាសព្រហ្មចារីរបស់តថាគត បានតាំងតថាគតក្នុងតំណែងជាអាចារ្យ ហើយក៏បូជាតថាគតដោយការបូជាដ៏លើសលុប ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ធម៌នេះមិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ មិនមែនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្ដីរលត់ មិនមែនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្ដីចេះដឹង មិនមែនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង

ន និព្វានាយ សំវត្តតិ យាវទេវ នេវសញ្ញានាសញ្ញាយតនូបបត្តិយាតិ ។ សោ ខោ អហំ រាជកុមារ តំ ធម្មំ អនលង្ករិត្វា តស្មា ធម្មា និព្វិជ្ជ អបក្កមឹ ។

(២៨២) សោ ខោ អហំ រាជកុមារ កិំកុសលគវេសី អនុត្តរំ សន្តិវរបទំ បរិយេសមានោ មគធេសុ អនុបុព្វេន ចារិកំ ចរមានោ យេន ឧរុវេលា សេនានិគមោ តទវសរឹ ។ តត្ថទ្ទសំ រមណីយំ ភូមិភាគំ បាសាទិកញ្ច វនសណ្ឌំ នទិញ្ច សន្ទន្តឹ សេតកំ[១] សុបតិត្ថំ រមណីយំ សមន្តា ច គោចរគាមំ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ រមណីយោ វត ភូមិភាគោ បាសាទិកោ ច វនសណ្ឌោ នទី ច សន្ទតិ សេតកា សុបតិត្ថា រមណីយា សមន្តា ច គោចរគាមោ អលំ វតិទំ កុលបុត្តស្ស បធានត្ថិកស្ស បធានាយាតិ ។ សោ ខោ អហំ រាជកុមារ តត្ថេវ និសីទឹ អលមិទំ បធានាយាតិ ។

១ ម. សន្ទតឹ សេតកំ ។



មិនមែនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលរាជកុមារ តថាគតនោះឯង មិនពេញចិត្តនឹងធម៌នោះ ក៏នឿយណាយចេញចាកធម៌នោះ ហើយចៀសចេញទៅ ។

(២៨២) ម្នាលរាជកុមារ តថាគតនោះឯង កាលស្វែងរកនូវកុសលសន្តិវរបទដ៏ប្រសើរ ត្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈ ដោយលំដាប់ សំដៅទៅឯឧរុវេលាប្រទេសសេនានិគម ។ ក្នុងទីនោះ តថាគតបានឃើញនូវភូមិភាគគួរជាទីត្រេកអរផង នូវដងព្រៃដែលគួរជាទីជ្រះថ្លាផង នូវស្ទឹងកំពុងហូរមានទឹកថ្លាត្រជាក់ មានកំពង់ល្អ គួរជាទីរីករាយផង ព្រមទាំងគោចរគ្រាម ក៏តាំងនៅដោយជុំវិញ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ភូមិភាគគួរជាទីត្រេកអរហ្ន៎ ដងព្រៃគួរជ្រះថ្លា ស្ទឹងដែលកំពុងហូរមានទឹកត្រជាក់ មានកំពង់ល្អ គួរជាទីរីករាយ ព្រមទាំងគោចរគ្រាម ក៏តាំងនៅដោយជុំវិញ ទីនេះហ្ន៎ ល្មមតាំងសេចក្តីព្យាយាមរបស់កុលបុត្រអ្នកមានប្រយោជន៍ ដោយសេចក្តីព្យាយាម ។ ម្នាលរាជកុមារ តថាគតនោះ បានអង្គុយនៅក្នុងទីនោះ ដោយគិតថា ទីនេះល្មមតាំងសេចក្តីព្យាយាមបាន ។

[៤៨៣] អបិស្សុ មំ រាជកុមារ តិស្សោ ឧបមា បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ រាជកុមារ អល្លំ កដ្ឋំ សស្នេហំ ឧទកេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ រាជកុមារ អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ ឧទកេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ អទុញ្ហិ ភន្តេ អល្លំ កដ្ឋំ សស្នេហំ តញ្ច បន ឧទកេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ រាជកុមារ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ អវូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា



(៤៨៣) ម្នាលរាជកុមារ ឧបមា ៣ ប្រការ មិនអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្តាប់មកពីមុន ក៏បានកើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ប្រៀបដូចឈើស្រស់ ប្រកបដោយជ័រដែលបុគ្គលត្រាំទុកនៅក្នុងទឹក ។ កាលបុរសគិតថា យើងនឹងកាន់យកឈើពន្លកខាងលើ មកពួតឲ្យកើតភ្លើង នឹងធ្វើតេជៈឲ្យកើតប្រាកដឡើងបាន ។ ម្នាលរាជកុមារ អ្នកសំគាល់សេចក្តីនោះថាដូចម្តេច បុរសនោះកាលកាន់យកឈើពន្លកខាងលើ មកពួតនឹងឈើស្រស់ដែលប្រកបដោយជ័រ ដែលបុគ្គលត្រាំទុកនៅក្នុងទឹកឯណោះ នឹងពួតឲ្យកើតភ្លើង នឹងធ្វើតេជៈឲ្យកើតប្រាកដឡើងបានឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន មិនកើតទេ ។ រឿងនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះឈើឯណោះនៅស្រស់ប្រកបដោយជ័រ ថែមទាំងឈើនោះសោត ក៏ត្រាំនៅក្នុងទឹកផង ឯបុរសនោះ គ្រាន់តែបានចំណែកនៃសេចក្តីលំបាក នឹងសេចក្តីចង្អៀតចង្អល់តែប៉ុណ្ណោះ ។ ម្នាលរាជកុមារ សេចក្តីនេះ មានឧបមេយ្យដូច ពួកសមណព្រាហ្មណ៍ណាមួយ មិនបានចៀសចេញចាកកាមទាំងឡាយដោយកាយ សមណព្រាហ្មណ៍ទាំងនោះ ថែមទាំងមានសេចក្តីពេញចិត្តព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះ

កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ។ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ រាជកុមារ បឋមា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

(២៨២) អបរាបិ ខោ មំ រាជកុមារ ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ រាជកុមារ អល្លំ កដ្ឋំ សស្នេហំ



កាម សេចក្ដីស្រេកឃ្លាន ព្រោះកាម និងសេចក្ដីក្រហល់ក្រហាយ ព្រោះកាមក្នុងកាមទាំងឡាយ កាមនោះជារបស់ដែលសមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ដោយប្រពៃ ចិត្តមិនបានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃក្នុងចិត្តខ្លួន ។ ប្រសិនបើពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ បានទទួលវេទនា ជាទុក្ខ ដ៏ក្លៀវក្លា ខ្លាំងក្លា ដែលកើតអំពីសេចក្ដីព្យាយាម ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីដឹងដឹង ដើម្បីដឹងឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ បើទោះបីពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានទទួលទុក្ខវេទនា ដ៏ក្លៀវក្លា ខ្លាំងក្លា ដែលកើតអំពីសេចក្ដីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីដឹងដឹង ដើម្បីដឹងឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ម្នាលរាជកុមារ នេះឯងឧបមាជាដំបូង មិនស្ទើរជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកពីមុន មកប្រាកដដល់តថាគត ។

(២៨២) ម្នាលរាជកុមារ មានឧបមាទី ២ ដទៃទៀតដែលមិនស្ទើរជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកពីមុន ក៏បានកើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ដូចឈើស្រស់ប្រកបដោយជ័រ

អារកា ឧទកា ថលេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ រាជកុមារ អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សស្នេហំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ នោ ហេតំ ភន្តេ តំ កិស្ស ហេតុ អទុញ្ហិ ភន្តេ អល្លំ កដ្ឋំ សស្នេហំ កិញ្ចាបិ អារកា ឧទកា ថលេ និក្ខិត្តំ យាវទេវ ច បន សោ បុរិសោ កិលមថស្ស វិឃាតស្ស ភាគី អស្សាតិ ។ ឯវមេវ ខោ រាជកុមារ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ ន សុប្បហីនោ ហោតិ ន សុប្បដិប្បស្សទ្ធោ ។



ដែលគេដាក់លើគោកនៅឆ្ងាយពីទឹក ។ កាលបុរសនិកថា យើងនឹងកាន់យកឈើគំនួតខាងលើមកក្លួសឲ្យកើតភ្លើង នឹងធ្វើតេជៈធាតុឲ្យកើតប្រាកដឡើង ។ ម្នាលរាជកុមារ អ្នកសំគាល់សេចក្តីនោះដូចម្តេច បុរសនោះកាលកាន់យកឈើគំនួតខាងលើ មកក្លួសនឹងឈើស្រស់ប្រកបដោយជ័រ ដែលគេដាក់លើគោក នៅឆ្ងាយពីទឹកឯណោះ នឹងក្លួសឲ្យកើតភ្លើង នឹងធ្វើតេជៈធាតុឲ្យកើតប្រាកដឡើង ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុនុះមិនកើតទេ រឿងនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចំរើន ព្រោះឈើឯណោះនៅស្រស់ប្រកបដោយជ័រពិតមែន តែគេដាក់លើគោកនៅឆ្ងាយពីទឹក ឯបុរសនោះ គ្រាន់តែបានការនៃសេចក្តីលំបាក នឹងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះ ។ ម្នាលរាជកុមារ សេចក្តីនេះ មានឧបមេយ្យដូច ពួកសមណព្រាហ្មណ៍ណាមួយ ចៀសចេញចាកកាមទាំងឡាយដោយកាយហើយ តែសមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីពេញចិត្ត ព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះកាម សេចក្តីស្រេកឃ្លានព្រោះកាម នឹងសេចក្តីក្រហល់ក្រហាយព្រោះកាមក្នុងកាមទាំងឡាយ ទាំងកាមនោះ សមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ដោយប្រពៃ ទាំងមិនបានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ ។

ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិព្វា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ នោ ចេបិ តេ ភោន្តោ សមណព្រាហ្មណា ឱបក្កមិកា ទុក្ខា តិព្វា កដុកា វេទនា វេទិយន្តិ អភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ រាជកុមារ ទុតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

(៦៨៨) អបរាបិ ខោ មំ រាជកុមារ តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។ សេយ្យថាបិ រាជកុមារ សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញសិ រាជកុមារ



នោះបើពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ បានទទួលវេទនា ជាទុក្ខដ៏ក្លៀវក្លា ក្តៅផ្សា ដែលកើតអំពីសេចក្តីព្យាយាម ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីនឹងត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ បើទុកជាពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានសោយវេទនាជាទុក្ខដ៏ក្លៀវក្លាក្តៅផ្សា ដែលកើតអំពីសេចក្តីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីនឹងត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ម្នាលរាជកុមារ នេះឯងជាឧបមាទី ២ មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្តាប់មកអំពីមុន ក៏កើតប្រាកដដល់តថាគត ។

(៦៨៨) ម្នាលរាជកុមារ ឧបមាទី ៣ ដទៃទៀត ដែលមិនសូវជាអស្ចារ្យណាស់ណា ដែលតថាគត មិនធ្លាប់បានស្តាប់មកអំពីមុន ក៏កើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ដូចឈើស្ងួត ជាឈើពុក ដែលគេដាក់លើគោក ឆ្ងាយពីទឹក ។ កាលបុរសគិតថា យើងនឹងកាន់យកឈើគោលខាងលើមកដុសឲ្យកើតភ្លើង នឹងធ្វើភ្លើងឲ្យកើតប្រាកដឡើង ។ ម្នាលរាជកុមារ អ្នកសំគាល់សេចក្តីនោះដូចម្តេច

អបិ នុ សោ បុរិសោ អមុំ សុក្ខំ កដ្ឋំ កោឡាបំ អារកា ឧទកា ថលេ និក្ខិត្តំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ ឯវំ ភន្តេ តំ កិស្ស ហេតុ អមុញ្ហិ ភន្តេ សុក្ខំ កដ្ឋំ កោឡាបំ តញ្ច បន អារកា ឧទកា ថលេ និក្ខិត្តន្តិ ។ ឯវមេវ ខោ រាជកុមារ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា កាយេន ចេវ កាមេហិ វូបកដ្ឋា វិហរន្តិ យោ ច នេសំ កាមេសុ កាមច្ឆន្ទោ កាមស្នេហោ កាមមុច្ឆា កាមបិបាសា កាមបរិឡាហោ សោ ច អជ្ឈត្តំ សុប្បហីនោ ហោតិ សុប្បដិប្បស្សទ្ធោ ។ ឱបក្កមិកា ចេបិ តេ ភោន្តោ សមណព្រាហ្មណា ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយន្តិ



បុរសនោះ កាលកាន់យកឈើពិន្ទុតខាងលើ មកក្តិតនឹងឈើស្ងួត ជាឈើពុក ដែលគេដាក់លើគោក នៅឆ្ងាយពីទឹកឯណោះ នឹងក្តិតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតបានឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះមែនកើតបាន រឿងនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចំរើន ព្រោះឈើស្ងួតឯណោះ ជាឈើពុក ផងម្យ៉ាងឈើនោះ គេដាក់លើគោកនៅឆ្ងាយពីទឹកផង ។ ម្នាលរាជកុមារ សេចក្តីនេះ មានឧបមេយ្យដូច ពួកសមណព្រាហ្មណ៍ណាមួយ ចៀសចេញចាកកាមទាំងឡាយ ដោយកាយហើយ ទាំងសេចក្តីពេញចិត្តព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះកាម សេចក្តីស្រេកឃ្លានព្រោះកាម នឹងសេចក្តីក្រហល់ក្រហាយព្រោះកាម ក្នុងក្នុ-កាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ក៏បានលះបង់ដោយប្រពៃ បានរម្ងាប់ស្ងប់ដោយប្រពៃ នូវកាមនោះ ឲ្យដាច់ ។ ពោះបើពួកសមណព្រាហ្មណ៍ ដ៏ចំរើនទាំងនោះ បានទទួលវេទនា ជាទុក្ខ ដ៏ក្លៀវក្លា ក្តៅផ្សា ដែលកើតអំពីសេចក្តីព្យាយាម

ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ នោ ចេបិ តេ ភោន្តោ សមណ-ព្រាហ្មណា ឱបក្កមិកា ទុក្ខា តិព្វា កដុកា វេទនា វេទិយន្តិ ភព្វា វ តេ ញាណាយ ទស្សនាយ អនុត្តរាយ សម្ពោធាយ ។ អយំ ខោ មំ រាជកុមារ តតិយា ឧបមា បដិភាសិ អនច្ឆរិយា បុព្វេ អស្សុ-តបុព្វា ។ ឥមា ខោ មំ រាជកុមារ តិស្សោ ឧបមា បដិភំសុ អនច្ឆរិយា បុព្វេ អស្សុតបុព្វា ។

[៤៨៦] តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហេយ្យំ អភិនិប្បីឡេយ្យំ អភិ-សន្តាបេយ្យន្តិ ។ សោ ខោ អហំ រាជកុមារ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិ-និគ្គណ្ហាមិ អភិនិប្បីឡេមិ អភិសន្តាបេមិ ។ តស្ស មយ្ហំ រាជកុមារ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច



ពួកសមណព្រាហ្មណ៍ទាំងនេះ ក៏គួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបាន ។ បើទុកជាពួកសម-ណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ មិនបានទទួលវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លាំងក្លា ដែលកើតអំពីសេចក្ដីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបាន ។ ម្នាលរាជកុមារ នេះឯងជាឧបមាទី ៣ មិនគួរជាអស្ចារ្យណាស់ណា ដែលតថាគត មិនធ្លាប់បានស្ដាប់មកអំពីមុន ក៏កើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ឧបមាទាំង ៣ ប្រការនេះឯងហើយ មិនគួរជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្ដាប់មកអំពីមុន ក៏កើតប្រាកដដល់តថាគត ។

[៤៨៦] ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតថាគតអញទាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្ដាត សង្កត់សង្កិន បៀតបៀន ដុតកំដៅចិត្តដោយចិត្ត ។ ម្នាលរាជ-កុមារ តថាគតនោះឯង ទាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្ដាត សង្កត់សង្កិន បៀតបៀន ដុតកំដៅចិត្តដោយចិត្ត ។ ម្នាលរាជកុមារ កាលតថាគតនោះ ទាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្ដាត

ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ កច្ឆេហិ សេទា មុច្ចន្តិ ។ សេយ្យថាបិ រាជកុមារ ពលវា បុរិសោ ទុព្ពលតរំ បុរិសំ សីសេ វា គហេត្វា ខន្ធេ វា គហេត្វា អភិនិគ្គណ្ហេយ្យ អភិនិប្បីឡេយ្យ អភិសន្តាបេយ្យ ឯវមេវ ខោ មេ រាជកុមារ ទន្តេភិ ទន្តមាធាយ ជិវ្ហាយ តាលុំ អាហច្ច ចេតសា ចិត្តំ អភិនិគ្គណ្ហតោ អភិនិប្បីឡយតោ អភិសន្តាបយតោ កច្ឆេហិ សេទា មុច្ចន្តិ ។ អារទ្ធំ ខោ បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា[១] សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

(៦៨៧) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ អប្បាណកំ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ រាជកុមារ មុខតោ ច នាសតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ រាជកុមារ

១ ម. អសម្មុដ្ឋា ។



សង្កត់សង្កិន បៀតបៀន ផ្តន់ផ្តៅចិត្តដោយចិត្ត ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ។ ម្នាលរាជកុមារ បុរសដែលមានកំឡាំង គប្បីចាប់បុរសមានកំឡាំងខ្សោយជាង ត្រង់ក្បាលឬករហើយ សង្កត់សង្កិន បៀតបៀន ញាំញីយ៉ាងណា ម្នាលរាជកុមារ កាលតថាគតទាំធ្មេញដោយធ្មេញ ទល់ក្រអូមដោយអណ្តាត សង្កត់សង្កិន បៀតបៀន ផ្តន់ផ្តៅចិត្តដោយចិត្ត ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ សេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់ទាំមូនហើយ ក៏មិនភាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់ស្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏លំបាកនោះ មកបណ្តាលចាក់ដោត ។

(៦៨៧) ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរតែសំឡឹងឈាន ដ៏មិនដកដង្ហើមជាអារម្មណ៍ ។ ម្នាលរាជកុមារ តថាគតនោះឯង ក៏បានអត់ខ្យល់អស្សាស-បស្សាសៈតាមមុខទ្វារនឹងតាមនាសិក ។ ម្នាលរាជកុមារ កាលតថាគត

មុខតោ ច នាសតោ ច អស្សាសបស្សាសេសុ ឧប-
រុទ្ធេសុ កណ្ណសោតេហិ វាតានំ និក្ខមន្តានំ អធិមត្តោ
សទ្ទោ ហោតិ សេយ្យថាបិ នាម កម្មារគគ្គរិយា
ធមមានាយ អធិមត្តោ សទ្ទោ ហោតិ ឯវមេវ ខោ
មេ រាជកុមារ មុខតោ ច នាសតោ ច អស្សា-
សបស្សាសេសុ ឧបរុទ្ធេសុ កណ្ណសោតេហិ វាតានំ
និក្ខមន្តានំ អធិមត្តោ សទ្ទោ ហោតិ ។ អារទ្ធំ ខោ
បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា
សតិ អសម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ
ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន
បធានាភិតុន្នស្ស សតោ ។

(៦៨៨) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ
យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។
សោ ខោ អហំ រាជកុមារ មុខតោ ច
នាសតោ ច កណ្ណសោតតោ ច[១] អស្សា-
សបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ រាជកុមារ

១ ម. កណ្ណតោ ចាតិ សព្វត្ថ បាឋោ ។



អត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារនឹងនាសិក សំឡេងខ្យល់ដែល
ចេញតាមកណ្ណសោត ខ្លាំងលើសប្រមាណ ។ ដូចជាស្នប់របស់ជាង
ដែកដែលកំពុងសប់ រមែងមានសំឡេងខ្លាំងយ៉ាងណា ម្នាលរាជ-
កុមារ កាលតថាគតអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារនឹងនា-
សិក សំឡេងខ្យល់ដែលចេញតាមកណ្ណសោត ក៏ខ្លាំងលើសប្រមាណ
យ៉ាងនោះដែរ ។ ម្នាលរាជកុមារ តែសេចក្ដីព្យាយាមដែលតថាគត
បានប្រារព្ធហើយ មិនធូរថយ សតិដែលតថាគតតម្កល់មាំហើយ ក៏មិន
រាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់
ស្ងាត់ កើតព្រោះសេចក្ដីព្យាយាម ដោយសេចក្ដីព្យាយាមដ៏លំបាក
នោះឯង បានបណ្ដាលចាក់ដោត ។

(៦៨៨) ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា
បើដូច្នោះ គួរអាត្មាអញគួរសំងំឈានគឺមិនដកដង្ហើមជាអារម្មណ៍ទៀត ។
ម្នាលរាជកុមារ តថាគតនោះ អត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ
តាមនាសិកនិងកណ្ណសោត ។ ម្នាលរាជកុមារ កាលតថាគតនោះ

មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា មុទ្ធានំ ឩហនន្តិ(១) ។ សេយ្យថាបិ រាជកុមារ ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធានំ អភិមត្ថេយ្យ ឯវមេវ ខោ មេ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា មុទ្ធានំ ឩហនន្តិ ។ អារទ្ធំ ខោ បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អបម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

(៦៨៩) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេ ឧបរុន្ធិំ ។

១ ម. ឩហន្តិ ។



អត់ខ្យល់អស្សាសបស្សាសៈតាមមុខក្តី តាមនាសិកក្តីតាមកណ្ណសោត ខ្យល់យ៉ាងខ្លាំងលើសប្រមាណ ក៏បោកមកទាក់ដោតត្រង់ក្បាល ។ ម្នាលរាជកុមារ បុរសដែលមានកំឡាំង គប្បីគោះក្បាល ដោយដែកស្រួចដ៏មុត យ៉ាងណា ម្នាលរាជកុមារ កាលតថាគត អត់ខ្យល់អស្សាស-បស្សាសៈតាមមុខក្តី តាមនាសិកក្តីតាមកណ្ណសោត ខ្យល់យ៉ាងខ្លាំងលើសប្រមាណ ក៏បោកត្រឡប់មកទាក់ដោតក្បាល យ៉ាងនោះដែរ ។ ម្នាលរាជកុមារ ចំណែកសេចក្តីព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំហើយ ក៏មិនភាយឡើយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏លំបាកនោះ មកបណ្តាលទាក់ដោត ។

(៦៨៩) ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គាត្មាអញគួរតែសំឡឹងឈាន គឺមិនដកដង្ហើមជាអារម្មណ៍ទៀត ។ ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខក្តី តាមនាសិកក្តីតាមកណ្ណសោត ។

តស្ស មយ្ហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោន្តិ ។ សេយ្យថាបិ រាជកុមារ ពលវា បុរិសោ ទឡ្ហេន វរត្តក្ខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ មេ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា សីសេ សីសវេទនា ហោន្តិ ។ អារទ្ធំ ខោ បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

(៦៦០) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។ សោ ខោ អហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។



ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនឹងតាមកណ្ណសោតហើយ វេទនាកើតក្នុងក្បាលឰដ៏ក្បាល ខ្លាំងលើសប្រមាណ ។ ម្នាលរាជកុមារ ដូចបុរសមានកំឡាំងគប្បីចងក្រវែងខ្សែចំណងក្បាលឰដ៏ក្បាល ដោយព្រ័ត្រមាំ (យ៉ាងណា) ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនឹងតាមកណ្ណសោតហើយ វេទនាកើតក្នុងក្បាលឰដ៏ក្បាល ដ៏ខ្លាំងលើសប្រមាណ ក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ ចុះសេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំហើយ ក៏មិនរាយមាយ ចុះកាយរបស់តថាគតនៅតែក្រវល់ក្រវាយមិនទាន់ស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលចាក់ដោត ។

(៦៦០) ម្នាលរាជកុមារ តថាគតនោះឯង ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែតថាគតញុំាងសំឡឹងឈាន ដ៏មិនដកដង្ហើមជាការម្នាក់ទៀត ។ ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនឹងតាមកណ្ណសោត ។

តស្ស មយ្ហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ សេយ្យថាបិ រាជកុមារ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ។ អារទ្ធំ ខោ បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អសម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។

(៦៦១) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ អប្បាណកំយេវ ឈានំ ឈាយេយ្យន្តិ ។



ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនិងកណ្ណសោត ខ្យល់លើសប្រមាណក៏កាត់នូវផ្ទៃពោះ ។ ម្នាលរាជកុមារ ដូចជាបុរសជាអ្នកសម្លាប់គោក្តី អ្នកជំនួយរបស់បុរសសម្លាប់គោក្តី ជាអ្នកប្រសប់ពនិត កាត់ផ្ទៃពោះគោ ដោយកាំបិតសម្រាប់កាត់ពុះនូវសាច់គោដ៏មុត (យ៉ាងណា) ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនិងតាមកណ្ណសោត ខ្យល់ខ្លាំងលើសប្រមាណ ក៏កាត់នូវផ្ទៃពោះក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ មិនរួញរា សតិដែលតថាគតបានតំកល់ទុកហើយ ក៏មិនបានរាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ ព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏លំបាកនោះឯង មកបណ្តាលចាក់ដោត ។

(៦៦១) ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែតថាគតញុំាងនូវឈានដ៏មិនមានដង្ហើមជាអារម្មណ៍ទៀត ។

សោ ខោ អហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេ ឧបរុន្ធឹ ។ តស្ស មយ្ហំ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តោ កាយស្មឹ ទាហោ ហោតិ ។ សេយ្យថាបិ រាជកុមារ ទ្វេ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ សម្បរិតាបេយ្យុំ ឯវមេវ ខោ មេ រាជកុមារ មុខតោ ច នាសតោ ច កណ្ណសោតតោ ច អស្សាសបស្សាសេសុ ឧបរុទ្ធេសុ អធិមត្តោ កាយស្មឹ ទាហោ ហោតិ ។ អារទ្ធំ ខោ បន មេ រាជកុមារ វីរិយំ ហោតិ អសល្លីនំ ឧបដ្ឋិតា សតិ អសម្មុដ្ឋា សារទ្ធោ ច បន មេ កាយោ ហោតិ អប្បដិប្បស្សទ្ធោ តេនេវ ទុក្ខប្បធានេន បធានាភិតុន្នស្ស សតោ ។



ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនិងតាមកណ្ណសោត ។ ម្នាលរាជកុមារ កាលតថាគតអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារតាមនាសិកនិងតាមកណ្ណសោត សេចក្តីក្តៅក្រហាយដ៏ខ្លាំងលើសប្រមាណក៏កើតមានក្នុងកាយ ។ ម្នាលរាជកុមារ ដូចជាបុរសមានកំឡាំង ២ នាក់ ចាប់បុរសដែលមានកំឡាំងខ្សោយត្រង់ដើមដៃម្ខាងម្នាក់ ហើយគប្បីធ្វើឲ្យក្រហល់ក្រហាយក្នុងរណ្តៅរងើកភ្លើង ( យ៉ាងណា ) ម្នាលរាជកុមារ កាលតថាគតអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកនិងតាមកណ្ណសោតហើយ សេចក្តីក្តៅក្រហល់ក្រហាយ ខ្លាំងលើសប្រមាណក៏កើតមានក្នុងកាយដូច្នោះឯង ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតំកល់មាំហើយ ក៏មិនបានរាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ព្រោះសេចក្តីព្យាយាមដ៏ទាំងនោះឯង មកបណ្តាលចាក់ដោត ។

[២៦៦] អបិស្សុ មំ រាជកុមារ ទេវតា ទិស្វា ឯវមាហំសុ កាលង្កតោ សមណោ គោតមោតិ ។ ឯកច្ចា ទេវតា ឯវមាហំសុ ន កាលង្កតោ សមណោ គោតមោ អបិច កាលំ ករោតីតិ ។ ឯកច្ចា ទេវតា ឯវមាហំសុ ន កាលង្កតោ សមណោ គោតមោ នបិ កាលំ ករោតិ អរហំ សមណោ គោតមោ វិហារោ ត្វេវ សោ អរហតោ ឯវរូបោ ហោតីតិ ។

[២៦៧] តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជេយ្យន្តិ ។ អថខោ មំ រាជកុមារ តា ទេវតា ឧបសង្កមិត្វា ឯតទវោចុំ មា ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជិ ។ សចេ ខោ ត្វំ មារិស សព្វសោ អាហារុបច្ឆេទាយ បដិបជ្ជិស្សសិ តស្ស តេ មយំ ទិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារេស្សាម



[២៦៦] ម្នាលរាជកុមារ គ្រានោះ ពួកទេវតាឃើញតថាគត ហើយបាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមធ្វើមរណកាលទៅហើយ ។ ទេវតាពួកខ្លះបាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមមិនទាន់ធ្វើមរណកាលទេ តែព្រះសមណគោតម ជិតធ្វើមរណកាលឥឡូវនេះ ។ ទេវតាពួកខ្លះនិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមមិនទាន់ធ្វើមរណកាលទេ ទាំងមិនធ្វើមរណកាល ក្នុងកាលឥឡូវនេះផង ព្រះសមណគោតមជាព្រះអរហន្ត ទុំះជាវិហារធម៌ទេតើ សភាពយ៉ាងនេះ រមែងមានដល់ព្រះអរហន្ត ។

[២៦៧] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួង ។ ម្នាលរាជកុមារ លំដាប់នោះ ពួកទេវតាទាំងនោះ បានចូលមករកតថាគតហើយ នាំគ្នានិយាយយ៉ាងនេះថា បពិត្រអ្នកនិទ្ទុក្ខ អ្នកកុំប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួងឡើយ ។ បពិត្រអ្នកនិទ្ទុក្ខ ប្រសិនបើអ្នកនឹងប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួងហើយ ពួកយើងនឹងបញ្ចូលនូវឱជាទិព្វតាមរន្ធរោមរបស់អ្នក

តាយ ត្វំ យាបេស្សសីតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ អហំ ចេវ ខោ បន សព្វសោ អជជ្ជិតំ បដិជានេយ្យំ ឥមា ច មេ ទេវតា ទិព្វំ ឱជំ លោមកូបេហិ អជ្ឈោហារេយ្យុំ តាយ ចាហំ យាបេយ្យំ តំ មមស្ស មុសាតិ ។ សោ ខោ អហំ រាជកុមារ តា ទេវតា បច្ចាចិក្ខាមិ ហលន្តិ វទាមិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យន្នូនាហំ ថោកំ ថោកំ អាហារំ អាហារេយ្យំ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសន្តិ ។ សោ ខោ អហំ រាជកុមារ ថោកំ ថោកំ អាហារំ អាហារេសិំ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសន្តិ ។ តស្ស មយ្ហំ រាជកុមារ



នឹងញ៉ាំងអ្នកឲ្យរស់នៅដោយឱជាទិព្វនោះ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើអាត្មាអញនឹងប្ដេជ្ញាចំពោះពួកទេវតាថាជាអ្នកមិនបរិភោគ ដោយប្រការទាំងពួងទៅ ពួកទេវតាទាំងនេះនឹងបញ្ចូលឱជាទិព្វតាមរន្ធរោមរបស់អាត្មាអញ ចំណែកខាងអាត្មាអញ គប្បីញ៉ាំងជីវិតឲ្យរស់នៅដោយឱជាទិព្វនោះ ពាក្យនោះនឹងជាពាក្យកុហកនៃអាត្មាអញ ។ ម្នាលរាជកុមារ តថាគតនោះ ក៏ឃាត់ពួកទេវតាទាំងនោះហើយនិយាយថា ណ្ហើយ កុំឡើយ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញសម្រេចអាហារតិចម្ដង ៗ ចំនួនជាមួយចុកដៃ ៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកកន្ធខ្លះ ពុំនោះសោតប៉ុនសាច់រលីងឈ្មូកខ្លះ ។ ម្នាលរាជកុមារ តថាគតនោះក៏បានសម្រេចអាហារតិចម្ដង ៗ ចំនួនជាមួយចុកដៃ ៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកកន្ធខ្លះ ពុំនោះសោតប៉ុនសាច់រលីងឈ្មូកខ្លះ ។ ម្នាលរាជកុមារ កាលតថាគតនោះ

ថោកំ ថោកំ អាហារំ អាហារយតោ បសតំ បសតំ យទិ វា មុគ្គយូសំ យទិ វា កុលត្ថយូសំ យទិ វា កឡាយយូសំ យទិ វា ហរេណុកយូសំ អធិមត្តកសិមានំ បត្តោ កាយោ ហោតិ ។

[៦៦៥] សេយ្យថាបិ នាម អសីតិកបព្វានិ វា កាឡបព្វានិ វា ឯវមេវស្សុ មេ អង្គបច្ចង្គានិ ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ឱដ្ឋបទំ ឯវមេវស្សុ មេ អានិសទំ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម វដ្ដនាវឡិ ឯវមេវស្សុ មេ បិដ្ឋិកណ្ដកោ ឧណ្ណតាវនតោ ហោតិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម ជជ្ជរសាលាយ គោបានសិយោ ឱលុគ្គវិលុគ្គា ភវន្តិ ឯវមេវស្សុ មេ ផាសុឡិយោ ឱលុគ្គវិលុគ្គា ភវន្តិ តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម គម្ភីរេ ឧទបានេ ឧទកតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ ឯវមេវស្សុ មេ អក្ខិកូបេសុ អក្ខិតារកា គម្ភីរគតា ឱក្ខាយិកា ទិស្សន្តិ



សម្រេចអាហារតិចបន្ថយចុះបន្តិចម្ដងៗ ចំនួនមួយក្ដោបដៃៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកកន្ធីខ្លះ ពុំនោះសោតប៉ុនសាច់លើងល្ហុកខ្លះ កាយ (របស់តថាគត) ក៏ដល់នូវការស្គាំងស្គមខ្លាំងលើសប្រមាណ ។

[៦៦៥] អវយវៈតូចនិងអវយវៈធំ របស់តថាគត ប្រៀបដូចវល្លិមានថ្នាំងច្រើន ទំនងវល្លិមានថ្នាំងខ្មៅ ព្រោះហេតុដែលមានអាហារតិចនោះឯង ។ ត្រគាករបស់តថាគត (ក៏ស្រៀកចូលគ្នា) ដូចជាស្នាមជើងអូដ្ឋ ព្រោះហេតុដែលមានអាហារតិចនោះឯង ។ ឆ្អឹងខ្នងរបស់តថាគត ក៏រដិបរដុប ដូចខ្សែល្ពួសដែលគេក្រងចូលគ្នា ព្រោះហេតុដែលមានអាហារតិចនោះឯង ។ របៀបឆ្អឹងជំនីរបស់តថាគត ក៏រទឹមរទាមដូចចន្ទល់នៃសាលាចាស់ ដ៏រទឹមរទាម ព្រោះហេតុដែលមានអាហារតិចនោះឯង ។ ប្រស្រីភ្នែកទាំងឡាយ របស់តថាគត ក៏ជ្រៅចូលទៅក្នុងរណ្ដៅភ្នែក ដូចពន្លឺទឹក ដ៏ចុះជ្រៅចូលទៅ ក្នុងអណ្ដូងទឹកដ៏ជ្រៅ

តាយេវប្បាហារតាយ ។ សេយ្យថាបិ នាម តិត្តកា-
លាពុ អាមកច្ឆិន្នោ វាតាតបេន សំផុសិតោ ហោតិ
សម្មិលាតោ ឯវមេវស្សុ មេ សីសច្ឆវិ សំផុសិតា
ហោតិ សម្មិលាតា តាយេវប្បាហារតាយ ។ សោ
ខោ អហំ រាជកុមារ ឧទរច្ឆវឹ បរាមសិស្សាមីតិ
បិដ្ឋិកណ្ដកំយេវ បរិគ្គណ្ហាមិ បិដ្ឋិកណ្ដកំ បរាម-
សិស្សាមីតិ ឧទរច្ឆវឹយេវ បរិគ្គណ្ហាមិ ។ យាវស្សុ មេ
រាជកុមារ ឧទរច្ឆវិ បិដ្ឋិកណ្ដកំ អល្លីនា ហោតិ
តាយេវប្បាហារតាយ ។ សោ ខោ អហំ រាជកុមារ
វច្ចំ វា មុត្តំ វា ករិស្សាមីតិ តត្ថេវ អវកុជ្ជោ
បបតាមិ តាយេវប្បាហារតាយ ។ សោ ខោ អហំ
រាជកុមារ ឥមមេវ កាយំ អស្សាសេន្តោ បាណិនា
គត្តានិ អនុមជ្ជាមិ ។ តស្ស មយ្ហំ រាជកុមារ
បាណិនា គត្តានិ អនុមជ្ជតោ បូតិមូលានិ លោ-
មានិ កាយស្មា បបតន្តិ តាយេវប្បាហារតាយ ។
អបិស្សុ មំ រាជកុមារ មនុស្សា ទិស្វា
ឯវមាហំសុ កាឡោ សមណោ គោតមោតិ ។



ព្រោះទោសដែលមានអាហារតិចនោះឯង ។ សម្បុរស្បែកក្បាលសម្រាប់
ទទួលសម្ផស្សរបស់តថាគត ក៏ស្វិតជ្រីវទៅ ដូចផ្លែឃ្លោកខ្ទិះដែលគេ
កាត់ចេញអំពីទង ហើយក៏ស្វិតស្រពោនទៅ ដោយខ្យល់និងកំដៅ
ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគត
នោះឯងនឹកថា អាត្មាអញនឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវឆ្អឹងខ្នងវិញ នឹក
ថាអាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវស្បែកពោះវិញ ។ ម្នាលរាជកុមារ
ស្បែកពោះរបស់តថាគតជាប់ភ្ជាប់នឹងឆ្អឹងខ្នង ព្រោះទោសដែលមាន
អាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគតនោះឯងនឹកថា នឹង
បន្ទោបង់នូវវច្ចៈមូត្រ ក៏ដួលពោបទៅក្នុងទីនោះ ព្រោះទោសដែល
មានអាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគតនោះឯង កាលធ្វើ
កាយនេះឲ្យស្រួល ទើបស្ទាបខ្លួនដោយដៃ ។ ម្នាលរាជកុមារ កាល
តថាគតនោះស្ទាបខ្លួនដោយបាតដៃទៅ រោមទាំងឡាយ សុទ្ធតែមានឫស
ស្អុយធ្លាក់ចេញពីកាយ ព្រោះទោសដែលមានអាហារតិចនោះឯង ។
ម្នាលរាជកុមារ គ្រានោះ មនុស្សទាំងឡាយ ឃើញតថាគតហើយ
ក៏តំណាលនិយាយយ៉ាងនេះថា ព្រះសមណគោតមមានសម្បុរខ្មៅ ។

ឯកច្ចេ មនុស្សា ឯវមាហំសុ ន កាឡោ សមណោ គោតមោ សាមោ សមណោ គោតមោតិ ។ ឯកច្ចេ មនុស្សា ឯវមាហំសុ ន កាឡោ សមណោ គោតមោ នាបិ សាមោ មង្គុរច្ឆវី សមណោ គោតមោតិ ។ យាវស្សុ មេ រាជកុមារ តាយ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ ឧបហតោ ហោតិ តាយេវប្បាហារតាយ ។

(២៦៨) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ យេ ខោ កេចិ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិព្វា កដុកា វេទនា វេទយឹសុ ឯតាវបរមំ នយិតោ ភិយ្យោ ។ យេបិ ហិ កេចិ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិព្វា កដុកា វេទនា វេទយិស្សន្តិ ឯតាវបរមំ នយិតោ ភិយ្យោ ។ យេបិ ហិ កេចិ ឯតរហិ សមណា វា ព្រាហ្មណា វា ឱបក្កមិកា ទុក្ខា តិព្វា កដុកា វេទនា វេទយន្តិ ឯតាវបរមំ នយិតោ ភិយ្យោ ។



មនុស្សទាំងឡាយពួកខ្លះ តាំងគ្នានិយាយយ៉ាងនេះថា ព្រះសមណគោតម មិនមែនមានសម្បុរខ្មៅទេ ព្រះសមណគោតមមានសម្បុរស្រណ្ដកផុយទេតើ ។ មនុស្សទាំងឡាយពួកខ្លះ និយាយគ្នាយ៉ាងនេះថា ព្រះសមណ-គោតមមិនមែនមានសម្បុរខ្មៅទេ ទាំងមិនមែនមានសម្បុរស្រណ្ដកផុយ គឺព្រះសមណគោតមមានសម្បុរប្រផេះទេតើ ។ ម្នាលរាជកុមារ ឆវីវណ្ណ របស់តថាគត ដ៏បរិសុទ្ធផូរផង់ផល់ផ្ទាំង ហើយត្រឡប់ទៅជាកប់អន់ទៅវិញ ព្រោះតែសេចក្ដីមានអាហារតិចនោះឯង ។

(២៦៨) ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានទទួលវេទនាជាទុក្ខដ៏ក្លៀវក្លាក្ដៅផ្សា ដែលកើតអំពីសេចក្ដីព្យាយាម មានកំណត់ត្រឹមប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។ មួយទៀត ពួកសមណ-ព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងទទួលវេទនាជាទុក្ខដ៏ក្លៀវក្លាក្ដៅផ្សា ដែលកើតអំពីសេចក្ដីព្យាយាម មានកំណត់ត្រឹមប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។ ពួកសមណព្រាហ្មណ៍ណា ក្នុងបច្ចុប្បន្ន កំពុងទទួលវេទនា ជាទុក្ខដ៏ក្លៀវក្លាក្ដៅផ្សា ដែលកើតអំពីសេចក្ដីព្យា-យាម មានកំណត់ត្រឹមប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។

ន ខោ បនាហំ ឥមាយ កដុកាយ ទុក្ករការិកាយ អធិគច្ឆាមិ ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ សិយា នុ ខោ អញ្ញោ មគ្គោ ពោធាយាតិ(១) ។

[៦៦៦] តស្ស មយ្ហំ រាជកុមារ ឯតទហោសិ អភិជានាមិ ខោ បនាហំ បិតុ សក្កស្ស កម្មន្តេ សីតាយ ជម្ពុច្ឆាយាយំ(២) និសិន្នោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរិតា សិយា នុ ខោ ឯសោ មគ្គោ ពោធាយាតិ ។ តស្ស មយ្ហំ រាជកុមារ សតានុសារិវិញ្ញាណំ អហោសិ ឯសេវ មគ្គោ ពោធាយាតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ កិន្នុ ខោ អហំ តស្ស សុខស្ស ភាយាមិ យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ អហំ តស្ស សុខស្ស ភាយាមិ

១ ម. ពោធាយាតិ ។ ២ ជម្ពុច្ឆាយាយ [illegible] ។



តែការបំពេញនោះ តថាគតក៏នៅតែមិនបានត្រាស់ដឹង នូវឧត្តរិមនុស្សធម៌ ជាគុណវិសេសគួរដើម្បីឃើញ ដោយប្រាជ្ញារបស់ព្រះអរិយៈ ដោយទុក្ករកិរិយាដ៏ក្តៅក្រហាយនេះបានឡើយ ចំណែកផ្លូវត្រាស់ដឹង គឺនឹងមានជាយ៉ាងដទៃទេដឹង ។

[៦៦៦] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងនៅចាំបាន កាលការ (ច្រត់ព្រះនង្គ័ល) របស់សក្កៈជាបិតា យើងអង្គុយនៅក្រោមម្លប់ដើមព្រីងដ៏ត្រជាក់ បានស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន មានវិតក្កៈ និងវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ផ្លូវនេះទេដឹង ជាផ្លូវនៃកិរិយាត្រាស់ដឹង ។ ម្នាលរាជកុមារ វិញ្ញាណដែលស្ទុះទៅតាមសតិ ក៏កើតឡើងដល់តថាគតថា នេះហើយប្រាកដជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញខ្លាចសេចក្តីសុខ ដែលជាសុខក្រៅអំពីកាមទាំងឡាយ ដែលជាសុខក្រៅអំពីអកុសលធម៌ទាំងឡាយដែរឬ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនខ្លាចសេចក្តី

យន្តំ សុខំ អញ្ញត្រេវ កាមេហិ អញ្ញត្រ អកុសលេហិ ធម្មេហីតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ ន ខោ តំ សុករំ សុខំ អធិគន្តុំ ឯវំ អធិមត្តកសិមានំ បត្តកាយេន យន្នូនាហំ ឱឡារិកំ អាហារំ អាហារេយ្យំ ឱទនំ កុម្មាសន្តិ ។ សោ ខោ អហំ រាជកុមារ ឱឡារិកំ អាហារំ អាហារេសឹ ឱទនំ កុម្មាសំ ។ តេន ខោ បន មំ(១) រាជកុមារ សមយេន បញ្ចវគ្គិយា ភិក្ខូ បច្ចុបដ្ឋិតា ហោន្តិ យន្នោ(២) សមណោ គោតមោ ធម្មំ អធិគមិស្សតិ តំ នោ(៣) អារោចេស្សតីតិ ។ យតោ ខោ អហំ រាជកុមារ ឱឡារិកំ អាហារំ អាហារេសឹ ឱទនំ កុម្មាសំ អថ មេ តេ បញ្ចវគ្គិយា ភិក្ខូ និព្វិជ្ជ បក្កមឹសុ ពាហុល្លិកោ សមណោ គោតមោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយាតិ ។ សោ ខោ អហំ រាជកុមារ ឱឡារិកំ អាហារំ អាហារេត្វា ពលំ គហេត្វា វិវិច្ចេវ កាមេហិ

១ ឱ. មេ ។ ២ ម. យំ ខោ ។ ៣ ម. តំ ខោ ខោ ។



សុខ ដែលជាសុខ វៀរអំពីកាមទាំងឡាយ ដែលជាសុខ វៀរអំពីអកុសលធម៌ទាំងឡាយឡើយ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសុខនោះ ដែលបុគ្គលមានរាងកាយដល់នូវសេចក្តីស្គាំងស្គម លើសប្រមាណយ៉ាងនេះ មិនងាយនឹងធ្វើឲ្យសម្រេចបានឡើយ បើដូច្នោះ គួរតែតថាគតញុំាំងអាហារដ៏គ្រោតគ្រាតគឺបាយនឹងនំកុម្មាសឡើងវិញ ។ ម្នាលរាជកុមារ តថាគតនោះឯងក៏បានបរិភោគអាហារដ៏គ្រោតគ្រាតគឺបាយនឹងនំកុម្មាស ។ ម្នាលរាជកុមារ សម័យនោះឯង ពួកបញ្ចវគ្គិយភិក្ខុដែលបម្រើតថាគតដោយគិតថា ព្រះសមណគោតម បើត្រាស់ដឹងធម៌ណា នឹងសំដែងធម៌នោះប្រាប់ដល់យើងទាំងឡាយ ។ ម្នាលរាជកុមារ កាលនោះ តថាគតបានបរិភោគអាហារដ៏គ្រោតគ្រាតគឺបាយនឹងនំកុម្មាស គ្រានោះ ពួកបញ្ចវគ្គិយភិក្ខុទាំងឡាយនោះ ក៏នឿយណាយនឹងតថាគត ហើយចៀសចេញទៅដោយគិតថា ព្រះសមណគោតមជាអ្នកល្មោភ ឃ្លាតចាកសេចក្តីព្យាយាម ត្រឡប់មកដើម្បីល្មោភវិញ ។ ម្នាលរាជកុមារ លុះតថាគតបរិភោគអាហារដ៏គ្រោតគ្រាតហើយ ក៏បម្រុងកាយឲ្យមានកំឡាំង ហើយស្ងាត់ចាកកាមទាំងឡាយ

។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ... តតិយំ ឈានំ..ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសឹ ។

(៦៦៣) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្ស-តិញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ រាជកុមារ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថា តំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

(៦៦៤) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ



។ បេ ។ បានដល់បឋមជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រោះរម្ងាប់វិតក្កៈនឹងវិចារៈទាំងឡាយ ។ បេ ។ បានដល់ទុតិយជ្ឈាន... បានដល់តតិយជ្ឈាន... បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

(៦៦៣) តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម មិនបានញាប់ញ័រតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរលឹកបាន ១ ជាតិ ២ ជាតិ ។ បេ ។ តថាគតរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលរាជកុមារ នេះជាវិជ្ជាទី ១ ដែលតថាគតបានក្នុងបឋមយាមនៃរាត្រី អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយពន្លឺក៏កើតឡើងដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដោយពិត ។

(៦៦៤) តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់

កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាត-ញាណាយ ចិត្តំ អភិនិន្នាមេសិំ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ ។ បេ ។ យថាកម្មូបគេ សត្តេ បជានាមិ ។ អយំ ខោ មេ រាជកុមារ រត្តិយា មជ្ឈិមេ យាមេ ទុតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

(៦៦៩) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញា-ណាយ ចិត្តំ អភិនិន្នាមេសិំ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសិំ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសិំ



គួរដល់ការងារកម្ម មិនបានញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ។ តថាគតនោះ មានទិព្វចក្ខុកន្លងនូវចក្ខុរបស់មនុស្សធម្មតា បានឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានរូបល្អ រូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។ បេ ។ តថាគតឃើញច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលរាជកុមារ នេះឯងជាវិជ្ជាទី ២ ដែលតថាគតបានហើយ ក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាបាត់ហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេសឲ្យក្ដៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដោយពិត ។

(៦៦៩) តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម មិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះបានដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ បានដឹងច្បាស់តាមពិតថា នេះជាបដិបទាជាហេតុឲ្យរលត់សេចក្ដីទុក្ខ បានដឹងច្បាស់

ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ(១) ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ រាជកុមារ រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិ-តត្តស្ស វិហរតោ ។

(៦៧០) តស្ស មយ្ហំ រាជកុមារ ឯតទហោសិ អធិគតោ ខោ មេ អយំ ធម្មោ គម្ភីរោ ទុទ្ទសោ ទុរនុពោធោ សន្តោ បណីតោ អតក្កាវចរោ

---
១ វិមុត្តំតិ ។



តាមពិតថា នេះជាអាសវៈ ។ បេ ។ បានដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យដល់នូវសេចក្ដីរលត់អាសវៈ ។ កាលតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរបស់តថាគតក៏រួចចាកកាមាសវៈផង... ចិត្តរបស់តថាគតក៏រួចចាកភវាសវៈផង... ចិត្តរបស់តថាគតក៏រួចចាកអវិជ្ជាសវៈផង កាលចិត្តរួចស្រឡះហើយ សេចក្ដីដឹង ក៏កើតប្រាកដថា ចិត្តផុតស្រឡះហើយ ជាតិអស់ហើយ ព្រហ្មចរិយធម៌បានទៅចប់ហើយ កិច្ចដែលត្រូវធ្វើក៏ធ្វើស្រេចហើយ ឥតមានកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីកិច្ចនេះទៀតឡើយ ។ ម្នាលរាជកុមារ នេះឯងជាវិជ្ជាទី ៣ ដែលតថាគតបានហើយក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាបាត់ទៅហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកំដៅកិលេសឲ្យក្ដៅ បញ្ជូនចិត្តទៅកាន់ព្រះនិព្វានដោយពិត ។

(៦៧០) ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ជាធម៌ដែលសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ឧត្ដម មិនជាទីត្រាច់ទៅនៃតក្កៈ

និបុណោ បណ្ឌិតវេទនីយោ ។ អាលយរាមា ខោ បនាយំ បជា អាលយរតា អាលយសម្មុទិតា[១] ។ អាលយរាមាយ ខោ បន បជាយ អាលយរតាយ អាលយសម្មុទិតាយ ទុទ្ទសំ ឥទំ ឋានំ យទិទំ ឥទប្បច្ចយតាបដិច្ចសមុប្បាទោ ។ ឥទម្បិ[២] ខោ ឋានំ ទុទ្ទសំ យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានំ ។ អហញ្ចេវ ខោ បន ធម្មំ ទេសេយ្យំ បរេ ច មេ ន អាជានេយ្យុំ សោ មមស្ស កិលមថោ សា មមស្ស វិហេសាតិ ។ អបិស្សុ មំ រាជកុមារ ឥមា អនច្ឆរិយា គាថា បដិភំសុ បុព្វេ អស្សុតបុព្វា

១ ឱ. អាលយសម្មុទិតា ។ ២ ម. ឥទម្បិ ។



បាន ជាធម៌ល្អិត ជាធម៌ដែលអ្នកប្រាជ្ញគប្បីដឹងបាន ។ តែពួកសត្វនេះ សុទ្ធតែនៅកំពុងរីករាយក្នុងសេចក្ដីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្ដីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្ដីអាល័យ (ចំពោះកាមទាំងឡាយនៅឡើយ) ។ មួយទៀត បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃធម៌ទាំងឡាយណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុធ្វើឲ្យពួកសត្វដែលនៅរីករាយក្នុងសេចក្ដីអាល័យ នៅត្រេកត្រអាលក្នុងសេចក្ដីអាល័យ នៅស្រើបស្រាលក្នុងសេចក្ដីអាល័យ គេឃើញបានដោយក្រៃក្រពេកណាស់ ។ មួយទៀត ធម៌ណា សម្រាប់រម្ងាប់បង្អង់នូវសង្ខារទាំងពួង សម្រាប់លះបង់ចោលនូវឧបធិកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាកតម្រេក ជាទីរលត់នៃសេចក្ដីទុក្ខគឺព្រះនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុធ្វើឲ្យពួកសត្វ ឃើញបានដោយក្រៃក្រពេកណាស់ ។ បើតថាគតសំដែងធម៌ទៅ ក៏តែសត្វទាំងឡាយដទៃ មិនអាចដឹងច្បាស់នូវធម៌ របស់តថាគតបានឡើយ សេចក្ដីលំបាកនឹងសេចក្ដីនឿយព្រួយនោះ មុខជានឹងមានដល់តថាគតមិនខាន ។ ម្នាលរាជកុមារ កាលនោះ គាថាទាំងឡាយមិនអស្ចារ្យណាស់ណានេះ ដែលតថាគតមិនដែលបានឮ ក្នុងកាលមុន ក៏កើតប្រាកដ ដល់តថាគត

កិច្ឆេន មេ អធិគតំ
ហលំ ទានិ បកាសិតុំ
រាគទោសបរេតេហិ
នាយំ ធម្មោ សុសម្ពុធោ(១)
បដិសោតគាមឹ និបុណំ
គម្ភីរំ ទុទ្ទសំ អណុំ
រាគរត្តា ន ទក្ខន្តិ
តមោខន្ធេន អាវុតាតិ ។

ឥតិហ មេ រាជកុមារ បដិសញ្ចិក្ខតោ អប្បោស្សុក្កតាយ ចិត្តំ នមតិ នោ ធម្មទេសនាយ ។

(៦៧១) អថខោ រាជកុមារ ព្រហ្មុនោ សហម្បតិស្ស មម ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទហោសិ នស្សតិ វត ភោ លោកោ វិនស្សតិ វត ភោ លោកោ យត្រ ហិ នាម តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស អប្បោស្សុក្កតាយ ចិត្តំ នមតិ នោ ធម្មទេសនាយាតិ ។ អថខោ រាជកុមារ

១ ម. សុសម្ពុទ្ធោ ។



ល្ហើយចុះ ឥឡូវនេះ តថាគតគួរសំដែងធម៌ដែលតថាគតបានត្រាស់ដឹងហើយ ដោយសេចក្ដីលំបាកនោះចុះ សត្វទាំងឡាយ ដែលរាគៈទោសៈគ្របសង្កត់ហើយ មិនងាយនឹងត្រាស់ដឹងនូវធម៌នេះបានទេ សត្វទាំងឡាយ ដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹតគឺអវិជ្ជាកំពុងរួបរឹត មិនឃើញនូវធម៌ដែលនាំទៀងកសត្វ ដល់នូវព្រះនិព្វាន ជាធម៌ដ៏ល្អិត សុខុមជ្រាលជ្រៅ ដែលសត្វឃើញបានដោយកម្រនោះបានទេ ។

ម្នាលរាជកុមារ កាលដែលតថាគតពិចារណាឃើញ ដោយន័យដែលត្រិះរិះដូច្នេះហើយ ចិត្តក៏ឱនទៅ ដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនឱនទៅ ដើម្បីសំដែងធម៌ឡើយ ។

(៦៧១) ម្នាលរាជកុមារ លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្ដីត្រិះរិះ ក្នុងចិត្តរបស់តថាគត ដោយចិត្តរបស់ខ្លួនហើយ ទើបកើតគំនិតដូច្នេះថា ឱលោកនឹងវិនាសហើយ ឱលោកនឹងវិនាសហើយ ព្រោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ មានព្រះទ័យបង្អោនទៅ ដើម្បីសេចក្ដីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសំដែងធម៌ ។ ម្នាលរាជកុមារ គ្រានោះ

ព្រហ្មា សហម្បតិ[១] សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មម បុរតោ បាតុរហោសិ ។ អថខោ រាជកុមារ ព្រហ្មា សហម្បតិ ឯកំសំ ឧត្តរាសង្គំ ករិត្វា យេនាហំ តេនញ្ជលឹ បណាមេត្វា មំ ឯតទវោច ទេសេតុ ភន្តេ ភគវា ធម្មំ ទេសេតុ សុគតោ ធម្មំ សន្តិ សត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។ ឥទមវោច រាជកុមារ ព្រហ្មា សហម្បតិ ឥទំ វត្វា អថាបរំ ឯតទវោច

បាតុរហោសិ មគធេសុ បុព្វេ
ធម្មោ អសុទ្ធោ សមលេហិ ចិន្តិតោ
អបាបុរេតំ អមតស្ស ទ្វារំ
សុណន្តុ ធម្មំ វិមលេនានុពុទ្ធំ

១ ម. សហំបតិ ។



ឯង សហម្បតិព្រហ្ម ក៏បាត់ពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចបុរសមានកំឡាំង លាតចេញនូវដើមដៃដែលបត់ចូល ឬបត់ចូលនូវដើមដៃដែលលាតចេញ ។ ម្នាលរាជកុមារ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីថ្វាយបង្គំចំពោះតថាគត ពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ សំដែងធម៌ សូមព្រះសុគតសំដែងធម៌ (ផ្សេង) សត្វទាំងឡាយ ដែលមានភ្នែកមានធូលីគឺកិ-លេសដ៏ស្រាលក៏មាន តែខានស្តាប់ធម៌ មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយ ដែលបម្រុងនឹងត្រាស់ដឹងនូវធម៌ក៏នឹងមានដែរ ។ ម្នាលរាជកុមារ សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតដូច្នេះថា

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយ
មន្ទិលតែងគិត ជាធម៌មិនបរិសុទ្ធ កើតប្រាកដហើយក្នុង
ដែនមគធៈ សូមព្រះអង្គបើកនូវទ្វារនៃព្រះនិព្វានចុះ សត្វ
ទាំងឡាយប្រុងនឹងស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាក
មន្ទិល ត្រាស់ដឹង ( តាមលំដាប់នៃព្រះពុទ្ធគុណ )

សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ
យថាបិ បស្សេ ជនតំ សមន្តតោ
តថូបមំ ធម្មមយំ សុមេធ
បាសាទមារុយ្ហ សមន្តចក្ខុ
សោកាវតិណ្ណំ ជនតមបេតសោកោ
អវេក្ខស្សុ ជាតិជរាភិភូតំ
ឧដ្ឋេហិ វីរ វិជិតសង្គាម
សត្ថវាហ អនណ វិចរ លោកេ

ទេសេតុ[១] ភគវា ធម្មំ អញ្ញាតារោ ភវិស្សន្តីតិ ។

[២៧៦] អថខ្វាហំ ភិក្ខវេ ព្រហ្មុនោ ច អជ្ឈេសនំ វិទិត្វា សត្តេសុ ច ការុញ្ញតំ បដិច្ច ពុទ្ធចក្ខុនា លោកំ វោលោកេសឹ ។ អទ្ទសំ ខោ អហំ ភិក្ខវេ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ

១. ទេសស្សុ ទេស្សតិ ។



ដូចបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយថ្មសុទ្ធ ក្រឡេកមើលឃើញប្រជុំជនដោយជុំវិញ យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះអង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើងកាន់ប្រាសាទដ៏ហើយដោយធម៌ ពិចារណាមើលប្រជុំជនអ្នកប្រឡូកដោយសេចក្តីសោក ដែលជាតិជរា គ្របសង្កត់ មានឧបមេយ្យដូច្នោះដែរ បពិត្រព្រះអង្គអ្នកមានព្យាយាម អ្នកឈ្នះសង្គ្រាម អ្នកនាំពួកសត្វ អ្នកមិនជំពាក់បំណុលនិកាម សូមព្រះអង្គក្រោក សូមទ្រង់ត្រាច់ទៅក្នុងលោក សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ សត្វទាំងឡាយដែលបម្រុងត្រាស់ដឹងធម៌ក៏មាន ។

[២៧៦] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង តថាគតដឹងច្បាស់នូវសេចក្តីអារាធនា របស់សហម្បតិព្រហ្មផង អាស្រ័យនូវសេចក្តីករុណាដល់ពួកសត្វផង ទើបរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគតរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវសត្វទាំងឡាយមានភ្នែកមានធូលីគឺកិលេសតិច (ខ្លះ) មាន

មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ សេយ្យថាបិ នាម ឧប្បលិនិយំ វា បទុមិនិយំ វា បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ សមោទកដ្ឋិតានិ អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកា អច្ចុគ្គម្ម តិដ្ឋន្តិ អនុបលិត្តានិ ឧទកេន ឯវមេវ ខោ អហំ រាជកុមារ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ អទ្ទសំ សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ



ភ្នែកមានធូលីគឺរាគាទិក្កិលេសច្រើន (ខ្លះ) មានឥន្ទ្រិយក្លា (ខ្លះ) មានឥន្ទ្រិយខ្ទន់ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការអាក្រក់ (ខ្លះ) ជាសត្វដែលគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយក្រ (ខ្លះ) ជាអ្នកឃើញទោសនឹងភ័យក្នុងបរលោក (ខ្លះ) ។ ដូចជាផ្កាជលជាតិឈូកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ក្នុងត្រពាំងនៃព្រលិតក្ដី ក្នុងត្រពាំងនៃឈូកក្រហមក្ដី ក្នុងត្រពាំងនៃឈូកសក្ដី ដែលកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិឈូកខ្លះ គឺព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ដែលកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិឈូកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ដែលកើតឡើងក្នុងទឹក ចំរើនឡើងក្នុងទឹក ផុសខ្ពស់ឡើងជាន់ទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលរាជកុមារ កាលតថាគតរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ បានឃើញនូវសត្វទាំងឡាយ មានភ្នែកមានធូលីគឺរាគាទិក្កិលេសតិច (ខ្លះ) មានភ្នែកមានធូលីគឺរាគាទិកិលេសច្រើន (ខ្លះ) មានឥន្ទ្រិយក្លា (ខ្លះ) មានឥន្ទ្រិយខ្ទន់ (ខ្លះ) មានអាការល្អ (ខ្លះ) មានអាការអាក្រក់ (ខ្លះ) ជាសត្វដែលគួរឲ្យត្រាស់ដឹងបានដោយងាយ (ខ្លះ) ឲ្យត្រាស់ដឹងបានដោយក្រ

អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេ ។ អថ ខ្វាហំ រាជកុមារ ព្រហ្មានំ សហម្បតឹ គាថាយ បច្ចភាសឹ

អបារុតា តេ(១) អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ(២)
ធម្មំ បណីតំ មនុជេសុ ព្រហ្មេតិ ។

អថខោ រាជកុមារ ព្រហ្មា សហម្បតិ កតាវកាសោ ខោម្ហិ ភគវតា ធម្មទេសនាយាតិ មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។

[៤៧៣] តស្ស មយ្ហំ រាជកុមារ ឯតទហោសិ កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ អយំ ខោ អាឡារោ កាលាមោ បណ្ឌិតោ វិយត្តោ មេធាវី ទីឃរត្តំ អប្បរជក្ខ-

១ [illegible] ២ [illegible]



(ខ្លះ) សត្វពួកខ្លះ ឃើញទោសនិងភ័យក្នុងបរលោក មានឧបមេយ្យដូច្នោះឯង ។ ម្នាលរាជកុមារ គ្រានោះ តថាគតបានតបទៅវិញជាបទគាថា ចំពោះសហម្បតិព្រហ្មថា

ទ្វារនៃព្រះនិព្វានទាំងនោះ បើកហើយ សត្វទាំងឡាយណា
មានសោតបសាទ សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធា
ចុះ ។ ម្នាលមហាព្រហ្ម តថាគតសំគាល់ក្នុងការលំបាក
បានជាមិនសំដែងធម៌ដ៏ឧត្តម ដែលតថាគត ស្ទាត់ហើយ
ក្នុងសំណាក់មនុស្សទាំងឡាយ ។

ម្នាលរាជកុមារ គ្រានោះឯង សហម្បតិព្រហ្មគិតថា ខ្ញុំអញជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់យល់ព្រម ដើម្បីនឹងសំដែងធម៌ហើយ (លុះគិតហើយ) ក៏ថ្វាយបង្គំលាតថាគតធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[៤៧៣] ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះតទៅទៀតថា អាឡារកាលាមតាបសនេះ ជាបណ្ឌិតជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា មានភ្នែកមានធូលីតិចតាំង-

ជាតិកោ យន្នូនាហំ អាឡារស្ស កាលាមស្ស បឋមំ ធម្មំ ទេសេយ្យំ សោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ អថ ខោ មំ រាជកុមារ ទេវតា ឧបសង្កមិត្វា ឯតទវោច សត្តាហំ កាលកតោ ភន្តេ អាឡារោ កាលាមោតិ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ សត្តាហំ កាលកតោ អាឡារោ កាលាមោតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ មហាជានិយោ ខោ អាឡារោ កាលាមោ សចេ ហិ សោ ឥមំ ធម្មំ សុណេយ្យ ខិប្បមេវ អាជានេយ្យាតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ កស្ស នុ ខោ អហំ បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ តស្ស មយ្ហំ រាជកុមារ ឯតទហោសិ អយំ ខោ ឧទ្ទកោ រាមបុត្តោ បណ្ឌិតោ វិយត្តោ មេធាវី ទីឃរត្តំ អប្បរជក្ខជាតិកោ យន្នូនាហំ ឧទ្ទកស្ស រាមបុត្តស្ស បឋមំ ធម្មំ ទេសេយ្យំ



កិលេសតិចយូរមកហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ដល់អាឡារកាលាមគោត្រជាមុនចុះ អាឡារនោះអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ គ្រានោះ មានទេវតាចូលមកគាល់តថាគតហើយក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន អាឡារកាលាមគោត្រ ធ្វើកាលកិរិយាស្លាប់៧ថ្ងៃទៅហើយ ។ ឯញាណទស្សនៈក៏កើតឡើងដល់តថាគតថា អាឡារកាលាមគោត្រ ធ្វើកាលកិរិយាស្លាប់ទៅ៧ថ្ងៃហើយមែន ។ ម្នាលរាជកុមារ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា ៖ អាឡារកាលាមគោត្រ មានសេចក្តីខាតធំ ប្រសិនបើអាឡារកាលាមគោត្រនោះ បានស្តាប់ធម៌នេះ នឹងត្រាស់ដឹងធម៌បានមួយរំពេច ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគតនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា ឧទ្ទករាមបុត្រនេះឯង ជាបណ្ឌិតមានបញ្ញាឈ្លាសវៃ ជាមេធាវី មានភ្នែកមានធូលីគឺរាគាទិកិលេសតិចមកយូរហើយ បើដូច្នោះ គួរតថាគតសំដែងធម៌ដល់ឧទ្ទករាមបុត្រជាមុនចុះ

សោ ឥមំ ធម្មំ ខិប្បមេវ អាជានិស្សតីតិ ។ អថខោ
មំ រាជកុមារ ទេវតា ឧបសង្កមិត្វា ឯតទវោច
អភិទោសកាលកតោ ភន្តេ ឧទ្ទកោ រាមបុត្តោតិ ។
ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អភិទោស-
កាលកតោ ឧទ្ទកោ រាមបុត្តោតិ ។ តស្ស
មយ្ហំ រាជកុមារ ឯតទហោសិ មហាជានិយោ ខោ
ឧទ្ទកោ រាមបុត្តោ សចេ ហិ សោ ឥមំ ធម្មំ
សុណេយ្យ ខិប្បមេវ អាជានេយ្យាតិ ។ តស្ស មយ្ហំ
រាជកុមារ ឯតទហោសិ កស្ស នុ ខោ អហំ
បឋមំ ធម្មំ ទេសេយ្យំ កោ ឥមំ ធម្មំ ខិប្បមេវ
អាជានិស្សតីតិ ។ តស្ស មយ្ហំ រាជកុមារ
ឯតទហោសិ ពហុការា ខោ មេ(១) បញ្ចវគ្គិយា ភិក្ខូ
យេ មំ បធានបហិតត្តំ ឧបដ្ឋហិំសុ យន្នូនាហំ
បញ្ចវគ្គិយានំ ភិក្ខូនំ បឋមំ ធម្មំ ទេសេយ្យន្តិ ។

១ ម. ឥមេ ។



តាបសនោះនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ
គ្រានោះ មានពួកទេវតា ចូលមកកាន់តថាគត ហើយប្រាប់យ៉ាងនេះថា
បពិត្រព្រះអង្គដ៏ចំរើន ឧទ្ទករាមបុត្រ ធ្វើកាលកិរិយាស្លាប់អំពីពេលព្រ-
លប់ទៅហើយ ។ ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ឧទ្ទករាម-
បុត្រ ធ្វើកាលកិរិយាស្លាប់អំពីពេលព្រលប់ទៅហើយមែន ។ ម្នាលរាជកុមារ
តថាគតនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ៖ ឧទ្ទករាមបុត្រមានសេចក្តី
វិនាសធំ ប្រសិនបើតាបសនោះ បានស្តាប់ធម៌នេះ នឹងត្រាស់ដឹងដោយ
ឆាប់រហ័ស ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះតទៅទៀត
ថា តថាគតគួរសំដែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹង
ធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តី
ត្រិះរិះយ៉ាងនេះថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការៈច្រើនដល់
តថាគត ព្រោះបានបម្រើតថាគត កាលដែលកំពុងបញ្ជូនចិត្តទៅកាន់
ព្យាយាម បើដូច្នោះ គួរតថាគតសំដែងធម៌ដល់បញ្ចវគ្គិយភិក្ខុជាមុនចុះ ។

តស្ស មយ្ហំ រាជកុមារ ឯតទហោសិ កហំ នុ ខោ ឯតរហិ បញ្ចវគ្គិយា ភិក្ខូ វិហរន្តីតិ ។ អទ្ទសំ ខោ អហំ រាជកុមារ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន បញ្ចវគ្គិយេ ភិក្ខូ ពារាណសិយំ វិហរន្តេ ឥសិបតនេ មិគទាយេ ។ អថខោ អហំ រាជកុមារ ឧរុវេលាយំ យថាភិរន្តំ វិហរិត្វា យេន ពារាណសី តេន ចារិកំ អបក្កមឹ(១) ។

[៤៧៦] អទ្ទសា ខោ មំ រាជកុមារ ឧបកោ អាជីវកោ អន្តរា ច គយំ អន្តរា ច ពោធឹ អទ្ធានមគ្គប្បដិបន្នំ ទិស្វាន មំ ឯតទវោច វិប្បសន្នានិ ខោ តេ អាវុសោ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ កំសិ ត្វំ អាវុសោ ឧទ្ទិស្ស បព្វជិតោ កោ វា តេ សត្ថា កស្ស វា ត្វំ ធម្មំ រោចេសីតិ ។ ឯវំ វុត្តេ អហំ រាជកុមារ ឧបកំ អាជីវកំ គាថាហិ អជ្ឈភាសឹ

---

១ ម. បក្កមឹ ។



ម្នាលរាជកុមារ តថាគតនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះទៀតថា ឥឡូវនេះ ពួកបញ្ចវគ្គិយភិក្ខុនៅក្នុងទីណា ។ ម្នាលរាជកុមារ លុះតថាគតនោះបានឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាត កន្លងផុតលើសចក្ខុរបស់មនុស្ស ។ ម្នាលរាជកុមារ គ្រានោះ តថាគតនៅក្នុងឧរុវេលប្រទេស តាមសមគួរដល់អធ្យាស្រ័យ ទើបចុះចេញទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី ។

(៤៧៦) ម្នាលរាជកុមារ អាជីវកឈ្មោះឧបកៈ បានឃើញតថាគតទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយាប្រទេស និងចន្លោះនៃពោធិព្រឹក្ស លុះឃើញហើយក៏ពោលពាក្យនេះនឹងតថាគតថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយ របស់អ្នកជ្រះថ្លាណាស់ ឆវិវណ្ណរបស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។ ម្នាលរាជកុមារ កាលឧបកាជីវកសួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបដោយពាក្យជាគាថាទៅកាន់ឧបកាជីវកថា

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ
ន មេ អាចរិយោ អត្ថិ
សទិសោ មេ ន វិជ្ជតិ
សទេវកស្មិំ លោកស្មិំ
នត្ថិ មេ បដិបុគ្គលោ
អហំ ហិ អរហា លោកេ
អហំ សត្ថា អនុត្តរោ
ឯកោម្ហិ សម្មាសម្ពុទ្ធោ
សីតិភូតោស្មិ និព្វុតោ
ធម្មចក្កំ បវត្តេតុំ
គច្ឆាមិ កាសិនំ បុរំ
អន្ធភូតស្មិំ លោកស្មិំ
អាហញ្ញឹ អមតទុន្ទុភិន្តិ ។





តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់ដឹងនូវចតុភូមិកធម៌ទាំងអស់ បានលះបង់នូវតេភូមិកធម៌ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់តណ្ហា ដឹងច្បាស់នូវចតុភូមិកធម៌ដោយខ្លួនឯង (ចាំបាច់) ចំពោះបុគ្គលណា ។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគត ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត មានតែតថាគតមួយជាសម្មាសម្ពុទ្ធ តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់អស់ហើយ ថ្ងៃនេះតថាគត ទៅកាន់បុរីនគរក្នុងដែនកាសី ដើម្បីសំដែងធម្មចក្រ តថាគតនឹងទូងស្គរគឺអមតនិព្វាន ចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

យថា ខោ ត្វំ អាវុសោ បដិជានាសិ អរហសិ អនន្តជិនោតិ ។

មាទិសា វេ ជិនា ហោន្តិ
យេ បត្តា អាសវក្ខយំ
ជិតា មេ បាបកា ធម្មា
តស្មាហំ ឧបក ជិនោតិ ។

ឯវំ វុត្តេ រាជកុមារ ឧបកោ អាជីវកោ ហុវេយ្យាវុសោតិ(១) វត្វា សីសំ ឱក្កម្បេត្វា(២) ជិវ្ហំ និល្លាលេត្វា ឧម្មគ្គំ គហេត្វា បក្កាមិ ។

(២៧៨) អថខ្វាហំ រាជកុមារ អនុបុព្វេន ចារិកំ ចរមានោ យេន ពារាណសី ឥសិបតនំ មិគទាយោ យេន បញ្ចវគ្គិយា ភិក្ខូ តេនុបសង្កមឹ ។ អទ្ទសំសុ(៣) ខោ មំ រាជកុមារ បញ្ចវគ្គិយា ភិក្ខូ ទូរតោវ អាគច្ឆន្តំ ទិស្វាន អញ្ញមញ្ញំ កតិកំ(៤) សណ្ឋបេសុំ អយំ(៥) អាវុសោ សមណោ គោតមោ អាគច្ឆតិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ សោ

១ ឱ. ហុវេយ្យាវុសោតិ ។ ២ ឱ. ឱកម្បិត្វា ។ ៣ ម. អទ្ទសាសុំ ។ ៤ ឱ. កតិកំ ន ទិស្សតិ ។ ៥ ម. អយំ ខោ ។





ឧបកាជីវកតបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នក យ៉ាងណា អ្នកគួរ (ដើម្បីបាននូវឈ្មោះ) ថា អនន្តជិនៈ (យ៉ាងនោះឯង) ។ តថាគត ក៏តបយ៉ាងនេះទៀតថា

ជនទាំងឡាយណា បានដល់នូវអាសវក្ខយ ជនទាំងនោះ
ឈ្មោះជិនៈ ប្រាកដដូចតថាគតដែរ ។ តថាគតបានឈ្នះ
បាបធម៌ទាំងអស់ហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើប
តថាគតឈ្មោះថា ជិនៈ ។

ម្នាលរាជកុមារ កាលតថាគត តបយ៉ាងនេះហើយ ឧបកាជីវកក៏ពោលថា ម្នាលអាវុសោ ពាក្យយ៉ាងហ្នឹងក៏គឺមែនហើយ (ជាហើយ) ក៏ងក់ក្បាល បៀនអណ្តាតកាន់យកផ្លូវវៀង ចៀសចេញទៅ ។

(២៧៩) គ្រានោះ តថាគតត្រាច់ទៅកាន់ចារិក តាមលំដាប់ហើយ ក៏ចូលទៅក្រុងពារាណសី រួចហើយទៅឯឥសិបតនមិគទាយវ័ន សំដៅទៅរកទីដែលបញ្ចវគ្គិយភិក្ខុនៅ ។ ម្នាលរាជកុមារ ពួកបញ្ចវគ្គិយភិក្ខុ បានឃើញតថាគតមកអំពីចម្ងាយ លុះឃើញហើយក៏ប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះ ជាអ្នកប្រតិបត្តិដើម្បីលាភ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីការៈលាភ ផ្សេងៗ លោកនិមន្តមក

នេវ អភិវាទេតព្វោ ន បច្ចុដ្ឋាតព្វោ នាស្ស បត្តចីវរំ បដិគ្គហេតព្វំ អបិច ខោ អាសនំ ឋបេតព្វំ សចេ អាកង្ខតិ និសីទិស្សតីតិ ។ យថា យថា ខោ អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ ឧបសង្កមឹ តថា តថា បញ្ចវគ្គិយា ភិក្ខូ នាសក្ខឹសុ សកាយ កតិកាយ សណ្ឋាតុំ អប្បេកច្ចេ មំ បច្ចុគ្គន្ត្វា បត្តចីវរំ បដិគ្គហេសុំ អប្បេកច្ចេ អាសនំ បញ្ញបេសុំ អប្បេកច្ចេ បាទោទកំ ឧបដ្ឋបេសុំ អបិច ខោ មំ នាមេន ច អាវុសោវាទេន ច សមុទាចរន្តិ ។ ឯវំ វុត្តេ[១] អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ ភិក្ខវេ តថាគតំ នាមេន ច អាវុសោវាទេន ច សមុទាចរថ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ

១ ម. ឆ. វុត្តេ សតិ ។



យើងទាំងអស់គ្នា មិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលបាត្រចីវរលោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ ។ ម្នាលរាជកុមារ តថាគតចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណា ៗ បញ្ចវគ្គិយភិក្ខុទាំងនោះ ក៏មិនអាចដើម្បីឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការដូច្នោះ ៗ បានឡើយ ក៏ស្រាប់តែខ្លះក្រោកទទួលតថាគត ខ្លះទទួលបាត្រចីវររបស់តថាគត ខ្លះក្រាលអាសនៈឲ្យ ខ្លះតំកល់ទឹកលាងជើង ប៉ុន្តែពួកបញ្ចវគ្គិយភិក្ខុ ក៏នៅតែហៅតថាគតដោយចំឈ្មោះផង ដោយពាក្យថា អាវុសោផង ។ ម្នាលរាជកុមារ កាលពួកបញ្ចវគ្គិយភិក្ខុពោលពាក្យហៅតថាគតយ៉ាងនេះហើយ តថាគតពោលយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកកល់គ្នា កុំហៅតថាគតដោយចំឈ្មោះ នឹងពាក្យថា អាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្តាប់ចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ

តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សតីតិ ។ ឯវំ វុត្តេ រាជកុមារ បញ្ចវគ្គិយា ភិក្ខូ មំ ឯតទវោចុំ តាយបិ ខោ ត្វំ អាវុសោ គោតម ឥរិយាយ តាយ បដិបទាយ តាយ ទុក្ករការិកាយ ន អជ្ឈគមា ឧត្តរឹ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ កឹ បន ត្វំ ឯតរហិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ អធិគមិស្សសិ ឧត្តរឹ មនុស្ស-ធម្មា អលមរិយញាណទស្សនវិសេសន្តិ ។ ឯវំ វុត្តេ អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ ន ភិក្ខវេ តថាគតោ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ



ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបាន ប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់តថាគតហើយ កុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ ពួកបញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះនឹងតថាគតទៀតថា ម្នាលអាវុសោគោតម ព្រះអង្គមិនបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេសដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់នូវកិលេស ដោយការប្រព្រឹត្តនោះផង ដោយការប្រតិបត្តិនោះផង ដោយកំពើដែលអ្នកដទៃធ្វើបានដោយកម្រនោះផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បីលោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីភាពលោភច្រើនហើយ ក៏នឹងបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ដ៏វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់កិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ តថាគតក៏ពោលនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីលោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មកដើម្បីលោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាល

ឱទហេថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសា-
សាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា
បដិបជ្ជមានា ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា
សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ
ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ
អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។
ទុតិយម្បិ ខោ រាជកុមារ បញ្ចវគ្គិយា ភិក្ខូ មំ ឯត-
ទវោចុំ តាយបិ ខោ ត្វំ អាវុសោ គោតម ឥរិយាយ
តាយ បដិបទាយ តាយ ទុក្ករការិកាយ ន អជ្ឈគមា
ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ
កឹ បន ត្វំ ឯតរហិ ពាហុល្លិកោ បធានវិព្ភន្តោ
អាវត្តោ ពាហុល្លាយ អធិគមិស្សសិ ឧត្តរិ មនុស្សធម្មា
អលមរិយញាណទស្សនវិសេសន្តិ ។ ទុតិយម្បិ ខោ
អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ



ភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងដាក់សោតបសាទចុះ តថាគតនឹង
ប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវ
នេះ តថាគតនឹងសំដែងធម៌ កុលបុត្រទាំងឡាយ ចេញចាកផ្ទះ
ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់ឧត្តមធម៌ណា អ្នក
ទាំងឡាយ កាលបើប្រតិបត្តិតាមពាក្យប្រដៅរបស់តថាគតហើយ កុំ
យូរឡើយ មុខជានឹងធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុង
បច្ចុប្បន្ន នូវឧត្តមធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។
ម្នាលរាជកុមារ ពួកបញ្ចវគ្គិយភិក្ខុ បានពោលពាក្យនេះនឹងតថាគតជា
គំរប់ ២ ដងថា ម្នាលអាវុសោគោតម ព្រះអង្គមិនទាន់បានត្រាស់ដឹង
នូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាច
កំចាត់បង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយសេចក្តីប្រតិបត្តិ
នោះផង ដោយអំពើដែលជនដទៃ ធ្វើត្រាប់បានដោយកម្រផង ឥឡូវ
នេះ ព្រះអង្គប្រតិបត្តិ ដើម្បីលោភច្រើន ឃ្លាតចាកសេចក្តីព្យាយាម
ហើយ វិលត្រឡប់មក ដើម្បីភាពលោភច្រើនហើយ នឹងបានត្រាស់
ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេសដោយញាណទស្សនៈដ៏ឧត្តម អាច
កំចាត់បង់នូវកិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ ឯតថាគតក៏
បានពោលពាក្យនេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយ ជាគំរប់ ២ ដងថា

ន ភិក្ខវេ តថាគតោ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ ពាហុល្លាយ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ តតិយម្បិ ខោ រាជកុមារ បញ្ចវគ្គិយា ភិក្ខូ មំ ឯតទវោចុំ តាយបិ ខោ ត្វំ អាវុសោ ឥរិយាយ តាយ បដិបទាយ តាយ ទុក្ករការិកាយ ន អជ្ឈគមា ឧត្តរិ មនុស្សធម្មា អលមរិយញាណទស្សនវិសេសំ កឹ បន ត្វំ ឯតរហិ ពាហុល្លិកោ បធានវិព្ភន្តោ អាវត្តោ



ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រព្រឹត្ត ដើម្បីលោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់ ដើម្បីមកលោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្ដាប់សោតចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិនូវដល់ពាក្យប្រដៅរបស់តថាគតហើយ កុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ បញ្ចវគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងតថាគតអស់វារៈជាគំរប់ ៣ ដងទៀតថា ម្នាលអាវុសោ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេសដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់កិលេស ដោយការប្រព្រឹត្តិនោះផង ដោយសេចក្ដីប្រតិបត្តិនោះផង ដោយអំពើដែលជនដទៃធ្វើគ្រប់បានដោយកម្រនោះផង ឥឡូវនេះ ព្រះអង្គប្រព្រឹត្ត ដើម្បីលោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មក ដើម្បី

ពាហុល្លាយ អនធិគមិស្សសិ ឧត្តរឹ មនុស្សធម្មា អលមរិយញាណទស្សនវិសេសន្តិ ។ ឯវំ វុត្តេ អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ ឯតទវោចំ អភិជានាថ មេ នោ តុម្ហេ ភិក្ខវេ ឥតោ បុព្វេ ឯវរូបំ ភាសិតមេតន្តិ ។ នោ ហេតំ ភន្តេ ។ អរហំ ភិក្ខវេ តថាគតោ សម្មាសម្ពុទ្ធោ ឱទហថ ភិក្ខវេ សោតំ អមតមធិគតំ អហមនុសាសាមិ អហំ ធម្មំ ទេសេមិ យថានុសិដ្ឋំ តថា បដិបជ្ជមានា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ អសក្ខឹ ខោ អហំ រាជកុមារ បញ្ចវគ្គិយេ ភិក្ខូ



លោភច្រើន នឹងបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេសដោយញាណទស្សនៈដ៏ឧត្តម អាចកំចាត់បង់កិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ កាលបើបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ តថាគតក៏ពោលពាក្យនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចាំបានដែរឬ ពាក្យមានសភាពយ៉ាងនេះ ជាពាក្យដែលតថាគតធ្លាប់បានពោលមកពីមុនឬអី ។ បញ្ចវគ្គិយភិក្ខុទាំងឡាយ តបថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យហ្នឹងព្រះអង្គមិនដែលពោលទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតប្រសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតបានត្រាស់ដឹងហើយ ផង តថាគតនឹងសំដែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយ ប្រតិបត្តិតាមពាក្យប្រដៅរបស់តថាគត កុំយូរប៉ុន្មាន មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ តថាគតអាចញ៉ាំងបញ្ចវគ្គិយភិក្ខុ

សន្តប្បេតិ ។ ទ្វេបិ សុទំ រាជកុមារ ភិក្ខូ ឱវទាមិ តយោ ភិក្ខូ បិណ្ឌាយ ចរន្តិ ។ យំ តយោ ភិក្ខូ បិណ្ឌាយ ចរិត្វា អាហរន្តិ តេន ឆព្វគ្គា យាបេម ។ តយោបិ សុទំ រាជកុមារ ភិក្ខូ ឱវទាមិ ។ ទ្វេ ភិក្ខូ បិណ្ឌាយ ចរិត្វា អាហរន្តិ[១] តេន ឆព្វគ្គា យាបេម ។ អថខោ រាជកុមារ បញ្ចវគ្គិយា ភិក្ខូ មយា ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរឹសូតិ ។

(៤៧៦) ឯវំ វុត្តេ ពោធិរាជកុមារោ ភគវន្តំ ឯតទវោច កីវចិរេន នុ ខោ ភន្តេ ភិក្ខុ តថាគតំ វិនាយកំ លភមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ

១ ម. ទ្វេ ភិក្ខូ បិណ្ឌាយ ចរន្តិ ។ យំ ទ្វេ ភិក្ខូ បិណ្ឌាយ ចរិត្វា អាហរន្តីតិ ទិស្សតិ ។



តាំងឡាយឲ្យយល់ច្បាស់ (គឺពេលនោះ) បាន ។ ម្នាលរាជកុមារ តថាគតបានប្រៀនប្រដៅភិក្ខុទាំងឡាយតែ ២ រូប ។ ភិក្ខុ ៣ រូបនាំគ្នាត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុ ៣ រូបដែលត្រាច់ទៅបិណ្ឌបាត នាំមកនូវអាហារណា អាហារនោះ យើងទាំង ៦ នាក់ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ម្នាលរាជកុមារ តថាគតប្រដៅភិក្ខុ ៣ រូប ។ ពួកភិក្ខុ ២ រូប ត្រាច់ទៅបិណ្ឌបាត នាំមកនូវអាហារណា អាហារនោះ យើងទាំង ៦ នាក់ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ម្នាលរាជកុមារ គ្រានោះឯង ពួកបញ្ចវគ្គិយភិក្ខុ កាលបើតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា កុំយូរប៉ុន្មាន ក៏បានត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

(៤៧៦) កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ពោធិរាជកុមារ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ដោយកាលយូរប៉ុន្មានទៅ ភិក្ខុដែលបានព្រះតថាគតជាអ្នកណែនាំ (យ៉ាងនេះ) ហើយ កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា

ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យាតិ ។ តេនហិ រាជកុមារ តំយេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា តំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ រាជកុមារ កុសលោ ត្វំ ហត្ថារូឡ្ហេ អង្កុសគ្គណ្ហេ សិប្បេតិ ។ ឯវំ ភន្តេ កុសលោ អហំ ហត្ថារូឡ្ហេ(១) អង្កុសគ្គណ្ហេ សិប្បេតិ ។

[៤៧៧] តំ កឹ មញ្ញសិ រាជកុមារ ឥធ បុរិសោ អាគច្ឆេយ្យ ពោធិ រាជកុមារោ ហត្ថារូឡ្ហំ អង្កុសគ្គណ្ហំ សិប្បំ ជានាតិ តស្សាហំ សន្តិកេ ហត្ថារូឡ្ហំ អង្កុសគ្គណ្ហំ សិប្បំ សិក្ខិស្សាមីតិ ។ សោ ចស្ស អស្សទ្ធោ យាវតកំ សទ្ធេន បត្តព្វំ តំ ន សម្បាបុណេយ្យ ។ សោ ចស្ស ពវ្ហាពាធោ យាវតកំ អប្បាពាធេន បត្តព្វំ តំ ន សម្បា-បុណេយ្យ ។ សោ ចស្ស សឋោ មាយាវី

១ ម. ឱ. ហត្ថារុឡ្ហេ ។



នឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលមានមគ្គព្រហ្មចរិយៈជាទីបំផុត ។ ម្នាលរាជកុមារ បើដូច្នោះ តថាគតនឹងត្រឡប់សួរទ្រង់ក្នុងប្រស្នានោះវិញ ទ្រង់គប្បីដោះស្រាយប្រស្នានោះ តាមដែលទ្រង់ឃើញជាសមគួរចុះ ម្នាលរាជកុមារ ទ្រង់សំគាល់សេចក្តីនោះជាដូចម្តេច ទ្រង់ជាអ្នកឈ្លាស ក្នុងសិល្ប-សាស្ត្រ ក្នុងការឡើងជិះដំរីនិងការកាន់កង្វេរ ឬ ។ បពិត្រព្រះអង្គដ៏ចំរើន យ៉ាងនេះមែនហើយ ខ្ញុំព្រះអង្គជាអ្នកឈ្លាស ក្នុងសិល្បសាស្ត្រក្នុងការឡើងជិះដំរីនិងការចាប់កាន់កង្វេរ ។

[៤៧៧] ម្នាលរាជកុមារ ទ្រង់សំគាល់សេចក្តីនោះជាដូចម្តេច បុរសក្នុងលោកនេះគិតថា ពោធិរាជកុមារ ចេះសិល្បសាស្ត្រឡើងជិះដំរីនិងចាប់កាន់កង្វេរ គួរអាត្មាអញនឹងសូមរៀនសិល្បសាស្ត្រឡើងជិះដំរី និងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ពោធិរាជកុមារនោះ ។ តែជាបុរសនោះជាអ្នកមិនមានសទ្ធា សិល្បសាស្ត្រត្រឹមប៉ុន្មានដែលគេគប្បីបានដោយសទ្ធា សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមានអាពាធច្រើន សិល្បសាស្ត្រត្រឹមប៉ុន្មាន ដែលគេគប្បីបានដោយមិនមានអាពាធ សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកអួតអាង មានមាយា

យាវតកំ អសឋេន អមាយាវិនា បត្តព្វំ តំ ន សម្បាបុណេយ្យ ។ សោ ចស្ស កុសីតោ យាវតកំ អារទ្ធវីរិយេន បត្តព្វំ តំ ន សម្បាបុណេយ្យ ។ សោ ចស្ស ទុប្បញ្ញោ យាវតកំ បញ្ញវតា បត្តព្វំ តំ ន សម្បាបុណេយ្យ ។ តំ កិំ មញ្ញសិ រាជកុមារ អបិ នុ សោ បុរិសោ តវ សន្តិកេ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ សិក្ខេយ្យាតិ ។ ឯកមេកេនាបិ ភន្តេ អង្គេន សមន្នាគតោ សោ បុរិសោ ន មម សន្តិកេ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ សិក្ខេយ្យ កោ បន វាទោ បញ្ចហង្គេហីតិ ។

[៤៧៨] តំ កិំ មញ្ញសិ រាជកុមារ ឥធ បុរិសោ អាគច្ឆេយ្យ ពោធិ រាជកុមារោ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ ជានាតិ តស្សាហំ សន្តិកេ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ សិក្ខិស្សាមីតិ ។ សោ ចស្ស



សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយការមិនអួតអាង ទាំងមិនមានមាយា សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកខ្ជិលច្រអូស សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយមានព្យាយាមប្រារព្ធហើយ សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងវិញទៀត បុរសនោះជាអ្នកអប្រាជ្ញ សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយមានប្រាជ្ញ សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ ម្នាលរាជកុមារ ទ្រង់សំគាល់សេចក្ដីនោះដូចម្ដេច បុរសនោះគប្បីសិក្សាសិល្បសាស្ត្រឡើងជិះដំរីនិងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ព្រះអង្គបាន ឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសនោះ ដែលប្រកបដោយអង្គសូម្បីតែមួយ ៗ ក៏មិនគប្បីសិក្សាសិល្បសាស្ត្រ ឡើងជិះដំរីនិងចាប់កាន់កង្វេរ ក្នុងសំណាក់ខ្ញុំព្រះអង្គបានឡើយ ចាំបាច់ពោលទៅថ្វីដល់បុគ្គលដែលប្រកបដោយអង្គ ៥ នោះ ។

(៤៧៨) ម្នាលរាជកុមារ ទ្រង់សំគាល់សេចក្ដីនោះដូចម្ដេច បុរសក្នុងលោកនេះគិតថា ពោធិរាជកុមារ ចេះសិល្បសាស្ត្រឡើងជិះដំរីនិងចាប់កាន់កង្វេរ អាត្មាអញនឹងសូមសិក្សាសិល្បសាស្ត្រឡើងជិះដំរីនិងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ពោធិរាជកុមារនោះ ។ ឯបុរសនោះ ជា

សទ្ធោ យាវតកំ សទ្ធេន បត្តព្វំ តំ សម្បាបុណេយ្យ ។ សោ ចស្ស អប្បាពាធោ យាវតកំ អប្បាពាធេន បត្តព្វំ តំ សម្បាបុណេយ្យ ។ សោ ចស្ស អសឋោ អមាយាវី យាវតកំ អសឋេន អមាយាវិនា បត្តព្វំ តំ សម្បាបុណេយ្យ ។ សោ ចស្ស អារទ្ធវីរិយោ យាវតកំ អារទ្ធវីរិយេន បត្តព្វំ តំ សម្បាបុណេយ្យ ។ សោ ចស្ស បញ្ញវា យាវតកំ បញ្ញវតា បត្តព្វំ តំ សម្បាបុណេយ្យ ។ តំ កឹ មញ្ញសិ រាជកុមារ អបិ នុ សោ បុរិសោ មម សន្តិកេ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ សិក្ខេយ្យាតិ ។ ឯកមេកេនបិ ភន្តេ អង្គេន សមន្នាគតោ សោ បុរិសោ មម សន្តិកេ ហត្ថារូឡ្ហំ អង្កុសគយ្ហំ សិប្បំ សិក្ខេយ្យ កោ បន វាទោ បញ្ចហង្គេហីតិ ។



អ្នកមានសទ្ធា សិល្បសាស្ត្រតាំងប៉ុន្មាន ដែលគេគប្បីបានដោយសទ្ធា សិល្បសាស្ត្រនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមានអាពាធតិច សិល្បសាស្ត្រតាំងប៉ុន្មាន ដែលគេគប្បីបានដោយអាពាធតិច សិល្បសាស្ត្រនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមិនអួតអាង មិនមានមាយា សិល្បសាស្ត្រតាំងប៉ុន្មានដែលគេគប្បីបានដោយការមិនអួតអាង មិនមានមាយា សិល្បសាស្ត្រនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះ ជាអ្នកមានសេចក្ដីព្យាយាមប្រារព្ធហើយ សិល្បសាស្ត្រតាំងប៉ុន្មាន ដែលគេគប្បីបានដោយមានសេចក្ដីព្យាយាមប្រារព្ធហើយ សិល្បសាស្ត្រនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងវិញទៀត បុរសនោះជាអ្នកមានប្រាជ្ញា សិល្បសាស្ត្រតាំងប៉ុន្មានដែលគេគប្បីបានដោយមានប្រាជ្ញា សិល្បសាស្ត្រនោះ ក៏គប្បីសម្រេចបាន ។ ម្នាលរាជកុមារ ទ្រង់សំគាល់សេចក្ដីនោះដូចម្ដេច បុរសនោះ គប្បីសិក្សាសិល្បសាស្ត្រឡើងជិះដំរីនិងកាន់កង្វេរ ក្នុងសំណាក់របស់ទ្រង់បានឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន បុរសនោះដែលប្រកបដោយអង្គសូម្បីតែមួយ ៗ ក៏គប្បីសិក្សាសិល្បសាស្ត្រឡើងជិះដំរីនិងកាន់កង្វេរ ក្នុងសំណាក់របស់ខ្ញុំព្រះអង្គបាន ចាំបាច់ពោលទៅថ្វីដល់បុគ្គលប្រកបដោយអង្គ ៥ ។

(៦៧៨) ឯវមេវ ខោ រាជកុមារ បញ្ចិមានិ បធានិយង្គានិ ។ កតមានិ បញ្ច ។ ឥធ រាជកុមារ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ ។ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា(១) សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ។ អារទ្ធវីរិយោ ហោតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ

១ ម. អាវិកត្តា ។



(៦៧៨) ម្នាលរាជកុមារ អង្គនៃសេចក្ដីព្យាយាមរបស់ភិក្ខុ ៥ ប្រការ នេះគឺដូច្នេះឯង ។ អង្គទាំង ៥ ប្រការ តើដូចម្ដេចខ្លះ ។ ម្នាលរាជកុមារ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃដោយព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាន នូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ ភិក្ខុនោះជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកបដោយតេជោធាតុមានវិបាកដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្ដៅពេក ជាយ៉ាងកណ្ដាល ល្មមអត់ធន់ធ្វើសេចក្ដីព្យាយាមបាន ។ ភិក្ខុនោះជាអ្នកមិនអួតអាង មិនមានមាយា សំដែងខ្លួនឲ្យច្បាស់ក្នុងសាស្ដា ឬវិញ្ញូជនទាំងឡាយ ជាសព្រហ្មចារីបុគ្គលតាមសេចក្ដីពិត ។ ភិក្ខុនោះជាអ្នកមានសេចក្ដីព្យាយាមប្រារព្ធ ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ជាអ្នកមានកំឡាំង ដើម្បីធ្វើកុសលធម៌ទាំងឡាយ ឲ្យកើតឡើងបាន ជាអ្នកមានសេចក្ដីព្យាយាមដ៏មាំមួន

អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា ។ ឥមានិ ខោ រាជកុមារ បញ្ច បធានិយង្គានិ ។ ឥមេហិ(១) រាជកុមារ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនាយកំ លភមានោ យទត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ សត្ត វស្សានិ ។ តិដ្ឋន្តុ រាជកុមារ សត្ត វស្សានិ ។ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនាយកំ លភមានោ យទត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ

១. ឥមេហិ ខោ ។



មិនបោះបង់ធុរៈក្នុងកុសលធម៌ ។ ភិក្ខុនោះជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាជាគ្រឿងកំណត់ដឹងនូវការកើតឡើង និងសេចក្តីវិនាសទៅវិញ ប្រកបដោយប្រាជ្ញាដ៏ប្រសើរជាគ្រឿងទំលាយបង់នូវលោភៈជាដើម ជាគ្រឿងកំណត់នូវការក្ស័យទៅ នៃសេចក្តីទុក្ខដោយប្រពៃ ។ ម្នាលរាជកុមារ អង្គនៃសេចក្តីព្យាយាមទាំងឡាយរបស់ភិក្ខុមាន ៥ ប្រការនេះឯង ។ ម្នាលរាជកុមារ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ បាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយដែលចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា និងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៧ ឆ្នាំ ។ ម្នាលរាជកុមារ ៧ ឆ្នាំលើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ បាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា និងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤

ឆ វស្សានិ... បញ្ច វស្សានិ... ចត្តារិ វស្សានិ... តីណិ វស្សានិ... ទ្វេ វស្សានិ.. ឯកំ វស្សំ ។ តិដ្ឋតុ រាជកុមារ ឯកំ វស្សំ ។ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនា-យកំ លភមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយ-បរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ សត្ត មាសានិ ។ តិដ្ឋតុ រាជកុមារ សត្ត មាសានិ ។ ឥមេហិ បញ្ចហិ បធា-និយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនាយកំ លភមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយ-បរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ ឆ មាសានិ... បញ្ច មាសានិ... ចត្តារិ មាសានិ... តីណិ មាសានិ... ទ្វេ មាសានិ.. មាសំ.. អឌ្ឍមាសំ ។ តិដ្ឋតុ រាជកុមារ អឌ្ឍមាសោ ។ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ



អស់ ៦ ឆ្នាំ... អស់ ៥ ឆ្នាំ... អស់ ៤ ឆ្នាំ.. អស់ ៣ ឆ្នាំ... អស់ ២ ឆ្នាំ... អស់ ១ ឆ្នាំ ។ ម្នាលរាជកុមារ ១ ឆ្នាំក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះ កាលបាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា គង់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៧ ខែ ។ ម្នាលរាជកុមារ ៧ ខែក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ កាលបាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៦ ខែ... អស់ ៥ ខែ... អស់ ៤ ខែ... អស់ ៣ ខែ... អស់ ២ ខែ.. អស់ ១ ខែ.. អស់កន្លះខែ ។ ម្នាលរាជកុមារ កន្លះខែក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ កាល

តថាគតំ វិនាយកំ លភមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ សត្ត រត្តិន្ទិវានិ ។ តិដ្ឋន្តុ រាជកុមារ សត្ត រត្តិន្ទិវានិ ។ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនាយកំ លភមានោ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យ ឆ រត្តិន្ទិវានិ... បញ្ច រត្តិន្ទិវានិ... ចត្តារិ រត្តិន្ទិវានិ... តីណិ រត្តិន្ទិវានិ... ទ្វេ រត្តិន្ទិវានិ ឯកំ រត្តិន្ទិវំ ។ តិដ្ឋតុ រាជកុមារ ឯកោ រត្តិន្ទិវោ ។ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតោ ភិក្ខុ តថាគតំ វិនាយកំ លភមានោ សាយមនុសិដ្ឋោ បាតោ វិសេសំ អធិគមិស្សតិ



បាននូវតថាគតជាអ្នកណែនាំ គឺកុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា គង់នឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់យប់នឹងថ្ងៃ ៧ ។ ម្នាលរាជកុមារ យប់នឹងថ្ងៃ ៧ គឺលើកទុកចុះ ។ ម្នាលរាជកុមារ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ កាលបានតថាគត ជាអ្នកណែនាំ គឺកុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា គង់បានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គ-ព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់យប់នឹងថ្ងៃ ៦... អស់យប់នឹងថ្ងៃ ៥... អស់យប់នឹងថ្ងៃ ៤... អស់យប់នឹងថ្ងៃ ៣ ... អស់យប់នឹងថ្ងៃ ២... អស់យប់នឹងថ្ងៃ ១ ។ ម្នាលរាជកុមារ យប់មួយថ្ងៃមួយគឺលើកទុកចុះ ។ ភិក្ខុប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ កាលបាននូវតថាគតជាអ្នកណែនាំ តថាគតប្រៀនប្រដៅក្នុងវេលាល្ងាច លុះព្រឹកឡើងនឹងបានសម្រេចគុណវិសេសក៏មាន

បាតមនុសិដ្ឋោ សាយំ វិសេសំ អធិគមិស្សតីតិ ។ ឯវំ វុត្តេ ពោធិ រាជកុមារោ ភគវន្តំ ឯតទវោច អហោ ពុទ្ធោ អហោ ធម្មោ អហោ ធម្មស្ស ស្វាក្ខាតតា(១) យត្រ ហិ នាម សាយមនុសិដ្ឋោ បាតោ វិសេសំ អធិគមិស្សតិ បាតមនុសិដ្ឋោ សាយំ វិសេសំ អធិគមិស្សតីតិ ។

[៤៨០] ឯវំ វុត្តេ សញ្ជិកាបុត្តោ មាណវោ ពោធិំ រាជកុមារំ ឯតទវោច ឯវមេវ បនាយំ ភវំ ពោធិ អហោ ពុទ្ធោ អហោ ធម្មោ អហោ ធម្មស្ស ស្វាក្ខាតតាតិ បវេទេតិ(២) អថ ច បន ភវំ(៣) ន តំ ភវន្តំ គោតមំ សរណំ គច្ឆតិ(៤) ធម្មញ្ច ភិក្ខុសង្ឃញ្ចាតិ ។

[៤៨១] មា ហេវំ សម្ម សញ្ជិកាបុត្ត អវច មា ហេវំ សម្ម សញ្ជិកាបុត្ត អវច សម្មុខា មេតំ សម្ម សញ្ជិកាបុត្ត អយ្យាយ សុតំ សម្មុខា បដិគ្គហិតំ ឯកមិទំ សម្ម សញ្ជិកាបុត្ត សមយំ

១ ម. ស្វាក្ខាតតា ។ ២ ឱ. ភណតិ ។ ៣ ឱ. ម. ភវន្តំ ន ទិស្សតិ ។ ៤ ឱ. គច្ឆាមិ ។



តថាគតប្រដៅក្នុងវេលាព្រឹក លុះវេលាល្ងាចនឹងបានសម្រេចនូវគុណ-វិសេសក៏មាន ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ពោធិរាជកុមារបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា ព្រះពុទ្ធជាអស្ចារ្យ ព្រះធម៌ជាអស្ចារ្យ ចំណែកការនៃធម៌ដែលព្រះអង្គត្រាស់ហើយដោយប្រពៃក៏អស្ចារ្យ ព្រោះថា សត្វដែលព្រះអង្គប្រៀនប្រដៅក្នុងវេលាល្ងាច លុះព្រឹកឡើងនឹងបានសម្រេចគុណវិសេសក៏មាន ព្រះអង្គប្រដៅក្នុងវេលាព្រឹក វេលាល្ងាចនឹងបានសម្រេចគុណវិសេសក៏មាន ។

[៤៨០] កាលពោធិរាជកុមារក្រាបទូលយ៉ាងនេះហើយ សញ្ជិកា-បុត្តមាណព បានក្រាបទូលពោធិរាជកុមារយ៉ាងនេះវិញថា ពោធិរាជ-កុមារជាម្ចាស់នេះ គ្រាន់តែប្រកាសសេចក្ដីថា ព្រះពុទ្ធជាអស្ចារ្យ ព្រះធម៌ជាអស្ចារ្យ ការនៃធម៌ដែលព្រះអង្គត្រាស់ហើយ ក៏ជាអស្ចារ្យដូច្នេះ ប៉ុន្តែពោធិរាជកុមារជាម្ចាស់មិនទាន់ដល់ព្រះគោតមនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹកនៅឡើយ ។

[៤៨១] ម្នាលសញ្ជិកាបុត្រសំឡាញ់ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលសញ្ជិកាបុត្រសំឡាញ់ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលសញ្ជិកា-បុត្រសំឡាញ់ ពាក្យនោះខ្ញុំបានស្ដាប់ក្នុងទីចំពោះមុខ ខ្ញុំបានទទួលក្នុងទីចំពោះមុខនៃព្រះមាតាជាម្ចាស់ ម្នាលសញ្ជិកាបុត្រសំឡាញ់ សម័យមួយ

ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ អថ ខោ មេ អយ្យា កុច្ឆិមតី(១) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ឯកមន្តំ និសិន្នា ខោ មេ អយ្យា ភគវន្តំ ឯតទវោច យោ មេ អយំ ភន្តេ កុច្ឆិគតោ កុមារកោ វា កុមារិកា វា សោ ភគវន្តំ សរណំ គច្ឆតិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ នំ(២) ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ឯកមិទំ សម្ម សញ្ជិកាបុត្ត សមយំ ភគវា ឥធេវ ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ អថ ខោ មំ ធាតី អង្កេន ហរិត្វា(៣) យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតា ខោ ធាតី(៤) ភគវន្តំ ឯតទវោច អយំ ភន្តេ ពោធិ រាជកុមារោ ភគវន្តំ សរណំ គច្ឆតិ ធម្មញ្ច ភិក្ខុសង្ឃញ្ច

១ ឱ. គព្ភិនី ។ ២ ឱ. ឧបាសកន្តិ ។ ម. ឧបាសិកំ ។ ៣ ឱ. ភរិត្វា ។ ម. ហរិត្វា ។ ៤ ឱ. ខោ មម ធាតី ។ ម. ខោ មំ ធាតី ។



ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី សម័យនោះឯង ព្រះមាតាជាម្ចាស់របស់ខ្ញុំទ្រង់គភ៌ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ លុះព្រះមាតាជាម្ចាស់របស់ខ្ញុំគង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ទារកដែលនៅក្នុងគភ៌របស់ខ្ញុំម្ចាស់នេះ ទោះបីជាកុមារក្តី ជាកុមារីក្តី សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគចាំទុកនូវទារកនោះថា ជាឧបាសកអ្នកដល់នូវព្រះត្រៃសរណគមន៍ស្មើដោយជីវិត តាំងតែពីថ្ងៃនេះតទៅ ដូច្នេះ ម្នាលសញ្ជិកាបុត្តសំឡាញ់ សម័យមួយទៀត ព្រះមានព្រះភាគស្តេចគង់នៅភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ គ្រានោះឯង មេនំបានដាក់ខ្ញុំលើភ្លៅ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឈរនៅក្នុងទីដ៏សមគួរ លុះមេនំឈរក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូល ព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពោធិរាជកុមារនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក

ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ
សរណង្គតន្តិ ឯសាហំ សម្ម សញ្ជិកាបុត្ត តតិយម្បិ
ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច
ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ
សរណង្គតន្តិ ។

ពោធិរាជកុមារសុត្តំ បញ្ចមំ និដ្ឋិតំ ។

---





សូមព្រះមានព្រះភាគ ចាំទុកនូវពោធិរាជកុមារនោះ ថាជាឧបាសកអ្នក
ដល់នូវព្រះត្រៃសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះទៅ
ម្នាលសញ្ជិកាបុត្រសំឡាញ់ ខ្ញុំនុ៎ះ បានដល់នូវព្រះមានព្រះភាគផង
ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក អស់វារៈជាគំរប់ ៣ ដងផង
សូមព្រះមានព្រះភាគចាំនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវព្រះ
ត្រៃសរណគមន៍ ស្មើដោយជីវិត តាំងអំពីថ្ងៃនេះរៀងទៅ ។

ចប់ ពោធិរាជកុមារសូត្រ ទី ៥ ។

---

## ឆដ្ឋំ អង្គុលិមាលសុត្តំ

[៦៨៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រញ្ញោ បសេនទិស្ស កោសលស្ស វិជិតេ ចោរោ អង្គុលិមាលោ នាម ហោតិ លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ ។ តេន គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា ។ សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ[១] សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ សេនាសនំ សំសាមេត្វា បត្តចីវរំ អាទាយ យេន ចោរោ អង្គុលិមាលោ តេនទ្ធានមគ្គំ បដិបជ្ជិ ។ អទ្ទសំសុ[២] ខោ គោបាលកា បសុបាលកា កស្សកា

១ ម. សាវត្ថឹ បិណ្ឌាយ បាវិសីតិ ន ទិស្សតិ ។ ២ ម. អទ្ទសាសុំ ។

## អង្គុលិមាលសូត្រ ទី ៦

[៦៨៦] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ក្នុងដែនព្រះបាទបសេនទិកោសល មានចោរម្នាក់ឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ក្នុងការបៀតបៀននឹងការសម្លាប់ ឥតមានសេចក្តីករុណា ក្នុងពួកសត្វមានជីវិតឡើយ ។ ចោរនោះ ធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ។ ចោរនោះនៅតែសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ទើបស្តេចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់ពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្ត ទ្រង់ក៏រៀបចំសេនាសនៈ រួចប្រដាប់បាត្រនិងចីវរ ស្តេចទៅកាន់ផ្លូវឆ្ងាយសំដៅទៅត្រង់ទីដែលអង្គុលិមាលនោះនៅ ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ[១] អ្នកភ្ជួររាស់

១ ពួកសត្វដែលគេចិញ្ចឹម ។

បថាវិនោ ភគវន្តំ យេន ចោរោ អង្គុលិមាលោ តេនទ្ធានមគ្គប្បដិបន្នំ ទិស្វាន(១) ភគវន្តំ ឯតទវោចុំ មា សមណ ឯតំ មគ្គំ បដិបជ្ជិ ឯតស្មឹ សមណ មគ្គេ ចោរោ អង្គុលិមាលោ នាម លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ តេន គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ ឯតញ្ហិ សមណ មគ្គំ ទសបិ បុរិសា វីសម្បិ បុរិសា តឹសម្បិ បុរិសា ចត្តាឡីសម្បិ បុរិសា សង្គរិត្វា សង្គរិត្វា(២) បដិបជ្ជន្តិ តេបិ ចោរស្ស អង្គុលិមាលស្ស ហត្ថត្ថំ គច្ឆន្តីតិ ។ ឯវំ វុត្តេ ភគវា តុណ្ហីភូតោ អគមាសិ ។

(៤៨៣) ទុតិយម្បិ ខោ គោបាលកា បសុបាលកា កស្សកា បថាវិនោ ភគវន្តំ ឯតទវោចុំ

១ ម. តេនទ្ធានមគ្គំ បដិបន្នំ ទិស្វាន ទិស្វាតិ ។ ២ ម. សំហរិត្វា សំហរិត្វា ។ ឱ. សង្គរិត្វា... ។



នឹងអ្នកដើរផ្លូវ បានឃើញព្រះមានបុណ្យ កំពុងស្តេចទៅកាន់ផ្លូវឆ្ពោះសំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ លុះឃើញហើយក៏ក្រាបទូលព្រះមានបុណ្យថ្វាយថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅកាន់ផ្លូវនុះឡើយ បពិត្រព្រះសមណៈ ក្នុងផ្លូវនុះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ក្នុងការបៀតបៀននឹងការសម្លាប់ ឥតមានសេចក្តីករុណាក្នុងពួកសត្វមានជីវិតឡើយ ចោរនោះ តែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ៣០ នាក់ខ្លះ ៤០ នាក់ខ្លះ នាំគ្នាដើរជាពួក ៗ ទៅកាន់ផ្លូវនុះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាលចោរ (ទាំងអស់) ។ កាលបើពួកមនុស្សក្រាបទូលយ៉ាងនេះ ព្រះមានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

(៤៨៣) ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ នឹងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យជាគំរប់ពីរដងថ្វាយថា បពិត្រ

មា សមណ ឯតំ មគ្គំ បដិបជ្ជិ ឯតស្មឹ សមណ មគ្គេ ចោរោ អង្គុលិមាលោ នាម លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ តេន គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ ឯតញ្ហិ សមណ មគ្គំ ទសបិ បុរិសា វីសម្បិ បុរិសា តឹសម្បិ បុរិសា ចត្តាឡីសម្បិ បុរិសា សង្គរិត្វា សង្គរិត្វា បដិបជ្ជន្តិ តេបិ ចោរស្ស អង្គុលិមាលស្ស ហត្ថត្ថំ គច្ឆន្តីតិ ។ អថខោ(១) ភគវា តុណ្ហីភូតោ អគមាសិ ។

[៦៨៦] ទុតិយម្បិ ខោ គោបាលកា បសុបា-លកា កស្សកា បថាវិនោ ភគវន្តំ ឯតទវោចុំ មា សមណ ឯតំ មគ្គំ បដិបជ្ជិ ឯតស្មឹ សមណ មគ្គេ ចោរោ អង្គុលិមាលោ នាម លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ តេន

១ ម. [illegible] ។



ព្រះសមណៈ សូមព្រះអង្គកុំចៀសទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសម-ណៈ ផ្លូវត្រង់នុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ខ្លួនក្នុងការបៀតបៀននិងការសម្លាប់ ឥតមានសេចក្តីករុណាក្នុងពួកសត្វមានជីវិតឡើយ ចោរនោះ តែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ៣០ នាក់ខ្លះ ៤០ នាក់ខ្លះ នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាល-ចោរ (ទាំងអស់) ។ លំដាប់នោះឯង ព្រះមានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់នៅតែស្តេចទៅ ។

[៦៨៦] ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យ ជាគំរប់ ២ ដងទៀតដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំចៀសទៅ កាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ផ្លូវត្រង់នុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ខ្លួនក្នុងការបៀតបៀននិងការសម្លាប់ ឥតមានសេចក្តីករុណាក្នុងពួកសត្វមានជីវិតឡើយ ចោរនោះ តែង

គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ ឯតញ្ហិ សមណ មគ្គំ ទសបិ បុរិសា វីសម្បិ បុរិសា តឹសម្បិ បុរិសា ចត្តារីសម្បិ បុរិសា សង្ករិត្វា សង្ករិត្វា បដិបជ្ជន្តិ តេបិ ចោរស្ស អង្គុលិមាលស្ស ហត្ថត្ថំ គច្ឆន្តីតិ ។ អថខោ ភគវា តុណ្ហីភូតោ អគមាសិ ។

(៦៨៨) អទ្ទសា ខោ ចោរោ អង្គុលិមាលោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ។ ទិស្វានស្ស ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឥមញ្ហិ មគ្គំ ទសបិ បុរិសា វីសម្បិ បុរិសា តឹសម្បិ បុរិសា ចត្តារីសម្បិ បុរិសា សង្ករិត្វា សង្ករិត្វា បដិបជ្ជន្តិ តេបិ មម ហត្ថត្ថំ គច្ឆន្តិ អថ ច បនាយំ សមណោ ឯកោ អទុតិយោ បសយ្ហ មញ្ញេ អាគច្ឆតិ យន្នូនាហំ ឥមំ សមណំ ជីវិតា វោរោបេយ្យន្តិ ។ អថខោ ចោរោ អង្គុលិមាលោ អសិចម្មំ គហេត្វា ធនុកលាបំ សន្នយ្ហិត្វា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ អថខោ



ធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួក ៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាលចោរ (ទាំងអស់) ។ គ្រានោះឯង ព្រះមានព្រះភាគក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

(៦៨៨) ឯអង្គុលិមាលចោរ ក៏បានឃើញព្រះមានព្រះភាគកំពុងតែស្តេចមកអំពីចម្ងាយ ។ លុះឃើញហើយ ក៏គិតដូច្នេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួក ៗ មកកាន់ផ្លូវនេះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃរបស់អាត្មាអញ (ទាំងអស់) ចុះសមណៈនេះ តែម្នាក់ឯង ឥតមានគ្នាសោះ ក៏ហ៊ានដើរមក ហាក់ដូចជាមិនកោតញញើតឡើយ បើដូច្នោះ អាត្មាអញនឹងសម្លាប់សមណៈនេះឲ្យក្ស័យជីវិត ។ គ្រានោះ អង្គុលិមាលចោរ ក៏កាន់យកនូវដាវនឹងខែល សៀតធ្នូនឹងបំពង់ព្រួញ ដើរតាមព្រះមានព្រះភាគជាប់តាមក្រោយ ។ លំដាប់នោះ

ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ(១)
យថា ចោរោ អង្គុលិមាលោ ភគវន្តំ បកតិយា
គច្ឆន្តំ សព្វថាមេន គច្ឆន្តោ ន សក្កោតិ សម្បា-
បុណិតុំ ។ អថខោ ចោរស្ស អង្គុលិមាលស្ស
ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ
អហញ្ហិ បុព្វេ ហត្ថឹបិ ធាវន្តំ អនុបតិត្វា គណ្ហាមិ
អស្សម្បិ ធាវន្តំ អនុបតិត្វា គណ្ហាមិ រថម្បិ ធាវន្តំ
អនុបតិត្វា គណ្ហាមិ មិគម្បិ ធាវន្តំ អនុបតិត្វា
គណ្ហាមិ អថ ច បនាហំ ឥមំ សមណំ បកតិយា
គច្ឆន្តំ សព្វថាមេន គច្ឆន្តោ ន សក្កោមិ សម្បា-
បុណិតុន្តិ ។ ឋិតោវ ភគវន្តំ ឯតទវោច តិដ្ឋ
សមណ តិដ្ឋ សមណាតិ ។ ឋិតោ អហំ អង្គុលិមាល
ត្វញ្ច តិដ្ឋាតិ ។

១ ម. អភិសង្ខាសិ ។



ព្រះមានព្រះភាគ ទ្រង់សំដែងឫទ្ធិធ្វើឲ្យអង្គុលិមាលចោរ ដែលរត់ដេញ
ទំហឹងហើយ មិនទាន់តាមទាន់ព្រះអង្គ ដែលស្តេចដើរតាមដំណើរប្រ-
ក្រតី ។ គ្រានោះ អង្គុលិមាលចោរ មានសេចក្តីត្រិះរិះដូច្នេះថា យើងអើ
អស្ចារ្យណាស់ យើងអើ ចំឡែកណាស់ ព្រោះកាលពីមុន ៗ មក អញ
ស្ទុះដេញចាប់ដំរីកំពុងរត់ក៏បាន ស្ទុះដេញចាប់សេះកំពុងផាយក៏បាន
ស្ទុះដេញចាប់រថកំពុងលឿនក៏បាន ស្ទុះដេញចាប់ម្រឹគកំពុងរត់ក៏បាន
ចំណែកតែម្តងនេះ ហេតុអ្វីបានជាអញរត់ដេញទំហឹងហើយ ក៏នៅតែមិន
ទាន់សមណៈនេះ ដែលដើរតាមដំណើរប្រក្រតីដូច្នេះ ។ អង្គុលិមាលចោរ
ឈប់ឈរស្ងៀម ស្រែកឃាត់ព្រះមានបុណ្យថា ឈប់សិនសមណៈ
ឈប់សិនសមណៈ ។ ព្រះមានបុណ្យត្រាស់តបថា នែអង្គុលិមាល
តថាគតឈប់ហើយ អ្នកឯងចូរឈប់ដែរទៅ ។

[៤៨៦] អថខោ ចោរស្ស អង្គុលិមាលស្ស ឯតទហោសិ ឥមេ ខោ សមណា សក្យបុត្តិយា សច្ចវាទិនោ សច្ចបដិញ្ញា អថ ច បនាយំ សមណោ គច្ឆំយេវាហ ឋិតោ អហំ អង្គុលិមាល ត្វញ្ច តិដ្ឋាតិ យន្នូនាហំ ឥមំ សមណំ បុច្ឆេយ្យន្តិ ។ អថខោ ចោរោ អង្គុលិមាលោ ភគវន្តំ គាថាយ អជ្ឈភាសិ

គច្ឆំ វទេសិ សមណដ្ឋិតោម្ហិ
មមញ្ច ព្រូសិ ឋិតមដ្ឋិតោសិ
បុច្ឆាមិ តំ សមណ ឯតមត្ថំ
កថំ ឋិតោ ត្វំ អហមដ្ឋិតោម្ហិ ។
ឋិតោ អហំ អង្គុលិមាល សព្វទា
សព្វេសុ ភូតេសុ និធាយ ទណ្ឌំ
តុវញ្ច(១) បាណេសុ អសញ្ញតោសិ

១ ម. ត្វំ ច ។



[៤៨៦] គ្រានោះ អង្គុលិមាលចោរ គិតថា ពួកសមណៈនេះ ជាសក្យបុត្រ ធ្លាប់និយាយតែពាក្យពិត ប្តេជ្ញាតែពាក្យពិត ចំណែកតែសមណៈនេះ កំពុងដើរទៅ ម្តេចឡើយក៏និយាយថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកចូរឈប់ដែរទៅ បើដូច្នោះ អាត្មាអញគួរសួរ សមណៈនេះមើល ។ លំដាប់នោះ អង្គុលិមាលចោរ ក៏ពោលនឹង ព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

នែសមណៈ លោកកំពុងដើរទៅ ក្រឡប់និយាយថា
តថាគតឈប់ហើយ ថែមទាំងថាខ្ញុំដែលឈប់ហើយថា
អ្នកឯងទៅ មិនទាន់ឈប់ដូច្នេះវិញ នែសមណៈ ខ្ញុំសូម
សួរសេចក្តីនុ៎ះនឹងលោក លោកដែលឈប់ហើយ តើដូច
ម្តេច ខ្ញុំដែលមិនទាន់ឈប់តើដូចម្តេច ។ ព្រះអង្គតប
ថា នែអង្គុលិមាល តថាគតចុះ ឈ្មោះថា ឈប់ហើយ
(នោះ) ព្រោះដាក់ចុះនូវគ្រឿងបៀតបៀនដល់ពួកសត្វទាំង(១)
អស់ សព្វៗកាល ឯអ្នកឯងជាអ្នកមិនសង្រួមក្នុងពួកសត្វ

១ ក្នុងអដ្ឋកថា លោកពន្យល់ថា ព្រះអង្គទ្រង់ទំលាក់នូវគ្រឿងកាយនិងសទ្ទាពេលចេញហើយ ទ្រង់ត្រឡប់នៅក្នុងធម៌ ៥ យ៉ាងគឺ មេត្តា ១ ខន្តី ១ បដិសង្ខា (ការពិចារណា) ១ អវិហឹសា ១ សារាណីយធម៌ ១ ហេតុនោះព្រះអង្គទ្រង់ប្រាប់អង្គុលិមាលថា តថាគតឈប់ហើយ គឺឈប់ធ្វើអំពើអាក្រក់ ។

តស្មា ឋិតោហំ តុវមដ្ឋិតោសិ ។
ចិរស្សំ វត មេ មហិតោ មហេសី
មហាវនំ សមណោ បច្ចុបាទិ(១)
សោហំ ចរិស្សាមិ បជហិស្ស(២)បាបំ
សុត្វាន គាថំ តវ ធម្មយុត្តំ
ឥច្ចេវ ចោរោ អសិមាវុធញ្ច
សោព្ភេ បបាតេ នរកេ អន្វកិរិ
អវន្ទិ ចោរោ សុគតស្ស បាទេ
តត្ថេវ នំ បព្វជ្ជំ អយាចិ ។
ពុទ្ធោ ច ខោ ការុណិកោ មហេសី
យោ សត្ថា លោកស្ស សទេវកស្ស
តមេហិ ភិក្ខូតិ តទា អវោច
ឯសេវ តស្ស អហុ ភិក្ខុភាវោតិ ។

អថខោ ភគវា អាយស្មតា អង្គុលិមាលេន បច្ឆា-
សមណេន យេន សាវត្ថី តេន ចារិកំ បក្កាមិ ។
អនុបុព្វេន ចារិកំ ចរមានោ យេន សាវត្ថី តទវសរិ ។

---

១ ឱ. សមណោយំ បច្ចុបាទិ ។ ម. បាបុណិ សច្ចុបាទិ ។ ២ ឱ. ចិរស្សំ បហាស្សំ ។ ម. ចរិស្សាមិ បហាយ ។ ម. អកិរិ ។ អវកិរិ ។ អន្វកាសិ ។



ព្រោះហេតុនោះ តថាគតទើបឈ្មោះថា ជាអ្នកឈប់ហើយ អ្នកឯងឈ្មោះថា ជាអ្នកមិនទាន់ឈប់ ។ អង្គុលិមាលចោរតបថា នែសមណៈ លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតានឹងមនុស្សក៏បូជា លោកមកកាន់មហាវន (ដើម្បីសង្គ្រោះ) ដល់ខ្ញុំអស់កាលយូរហើយ ខ្ញុំនោះនឹងប្រព្រឹត្តតាម នឹងលះបង់នូវបាបទាំងឡាយចេញ ព្រោះបានស្តាប់នូវគាថារបស់ព្រះអង្គដែលប្រកបដោយធម៌ (នោះ) ជាមួយគ្នាហើយ ក៏ចោលនូវដាវនឹងអាវុធទាំងឡាយទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុងរណ្តៅ អង្គុលិមាលចោរក៏ថ្វាយបង្គំព្រះបាទានៃព្រះសុគត ហើយសូមផ្នួសនឹងព្រះអង្គ ក្នុងទីនោះឯង ។ ចំណែកព្រះពុទ្ធ ព្រះអង្គប្រកបដោយករុណា ទ្រង់ស្វែងរកនូវគុណដ៏ធំ ដែលជាគ្រូនៃមនុស្សលោកព្រមទាំងទេវលោក បានត្រាស់ហៅអង្គុលិមាលចោរនោះថា អ្នកចូរមកជាភិក្ខុចុះ ដូច្នេះក្នុងគ្រានោះ ភិក្ខុភាពនោះឯង ក៏កើតមានដល់អង្គុលិមាលចោរនោះ ។

គ្រានោះ ព្រះភគវន្តមុនី ទ្រង់យកអង្គុលិមាលភិក្ខុមានអាយុជាបច្ឆាសមណៈ ស្តេចទៅកាន់ដំណើរ សំដៅទៅក្រុងសាវត្ថី ។ ព្រះអង្គកាលស្តេចទៅតាមលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។

[២៨៧] តត្រ សុទំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រញ្ញោ បសេនទិស្ស កោសលស្ស អន្តេបុរទ្វារេ មហាជនកាយោ សន្និបតិត្វា ឧច្ចាសទ្ទោ មហាសទ្ទោ ហោតិ ចោរោ តេ ទេវ វិជិតេ អង្គុលិមាលោ នាម លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ តេន គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ តំ ទេវោ បដិសេធេតូតិ ។ អថខោ រាជា បសេនទិ កោសលោ បញ្ចមត្តេហិ អស្សសតេហិ សាវត្ថិយា និក្ខមិត្វា(១) ទិវាទិវស្ស យេន អារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

១ ម. ឧ. និក្ខមិ ។



[២៨៧] ដំណាលថា ព្រះភគវន្តមុនី ព្រះអង្គគង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គាប់ចួនសម័យនោះ ពួកមហាជនកំពុងតែប្រជុំគ្នាទៀបទ្វារខាងក្នុងបុរី របស់ព្រះបាទបសេនទិកោសល ស្រែកហ៊ោកឹកកងថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ក្នុងការបៀតបៀននិងការសម្លាប់ ឥតមានសេចក្តីករុណាក្នុងសត្វមានជីវិតឡើយ វាតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ សូមព្រះសម្មតិទេព កំចាត់អង្គុលិមាលចោរនោះចេញ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចេញអំពីក្រុងសាវត្ថី ដោយអស្សយានចំនួន ៥០០ ស្តេចចូលទៅកាន់អារាម ក្នុងវេលាទាំងថ្ងៃ បរយានទៅទល់ត្រឹមទីដែលឈប់យាន ហើយស្តេចចុះអំពីយាន ស្តេចទៅតែព្រះបាទទទេ ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។

[៤៨៨] ឯកមន្តំ និសិន្នំ ខោ រាជានំ បសេនទិកោសលំ(១) ភគវា ឯតទវោច កិន្នុ តេ មហារាជ រាជា មាគធោ សេនិយោ ពិម្ពិសារោ កុបិតោ វេសាលិកា វា លិច្ឆវី អញ្ញេ វា បដិរាជានោតិ ។ ន ខោ មេ ភន្តេ រាជា មាគធោ សេនិយោ ពិម្ពិសារោ កុបិតោ នបិ វេសាលិកា លិច្ឆវី នបិ អញ្ញេ បដិរាជានោ ចោរោ មេ ភន្តេ វិជិតេ អង្គុលិមាលោ នាម លុទ្ទោ លោហិតបាណី ហតបហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ តេន គាមាបិ អគាមា កតា និគមាបិ អនិគមា កតា ជនបទាបិ អជនបទា កតា សោ មនុស្សេ វធិត្វា វធិត្វា អង្គុលីនំ មាលំ ធារេតិ តាហំ ភន្តេ បដិសេធិស្សាមីតិ ។ សចេ បន ត្វំ មហារាជ អង្គុលិមាលំ បស្សេយ្យាសិ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតំ វិរតំ បាណាតិបាតា វិរតំ អទិន្នាទានា

១ ម. ម. បសេនទិំ កោសលំ ។



[៤៨៨] លុះព្រះបាទបសេនទិកោសល គង់ក្នុងទីដ៏សមគួរហើយ ព្រះមានបុណ្យ ទ្រង់ត្រាស់សួរថា បពិត្រមហារាជ ទំនងជាមហាបពិត្រខ្ញាល់នឹងព្រះបាទមាគធសេនិយពិម្ពិសារ ឬខ្ញាល់នឹងស្ដេចលិច្ឆវីអ្នកក្រុងវេសាលី ឬក៏ខ្ញាល់នឹងពួកស្ដេចដែលជាបច្ចាមិត្រឯទៀត ឬអ្វី ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនខឹងនឹងព្រះបាទមាគធសេនិយពិម្ពិសារ មិនខឹងនឹងស្ដេចលិច្ឆវីអ្នកក្រុងវេសាលី មិនខឹងនឹងពួកស្ដេច ដែលជាបច្ចាមិត្រឯទៀតទេ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនរបស់ខ្ញុំព្រះអង្គ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស៊ប់ក្នុងការបៀតបៀន នឹងការសម្លាប់ ឥតមានសេចក្ដីករុណាក្នុងសត្វមានជីវិតឡើយ ក៏តែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងកំចាត់អង្គុលិមាលចោរនោះចេញ ។ ព្រះមានបុណ្យត្រាស់ថា បពិត្រមហារាជ ចុះបើមហាបពិត្រទ្រង់បានឃើញអង្គុលិមាល កោរសក់ ពុកមាត់នឹងពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅកាន់ផ្នួស វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន

វិរតំ មុសាវាទា ឯកភត្តិកំ ព្រហ្មចារឹ សីលវន្តំ កល្យាណធម្មំ កិន្តិ តំ ករេយ្យាសីតិ ។ អភិវាទេយ្យាម វា បច្ចុដ្ឋេយ្យាម វា អាសនេន វា និមន្តេយ្យាម អភិនិមន្តេយ្យាម វា នំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ធម្មិកំ វា អស្ស រក្ខាវរណគុត្តឹ សំវិទហេយ្យាម កុតោ បនស្ស ភន្តេ ទុស្សីលស្ស បាបធម្មស្ស ឯវរូបោ សីលសំយមោ ភវិស្សតីតិ ។

(២៨៩) តេន ខោ បន សមយេន អាយស្មា អង្គុលិមាលោ ភគវតោ អវិទូរេ និសិន្នោ ហោតិ ។ អថខោ ភគវា ទក្ខិណពាហំ(១) បគ្គហេត្វា រាជានំ បសេនទិំ កោសលំ ឯតទវោច ឯសោ មហារាជ អង្គុលិមាលោតិ ។ អថខោ រញ្ញោ បសេនទិស្ស កោសលស្ស អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ ។ អថខោ ភគវា រាជានំ បសេនទិំ កោសលំ ភីតំ សំវិគ្គំ លោមហដ្ឋជាតំ វិទិត្វា រាជានំ បសេនទិំ កោសលំ ឯតទវោច

១ ម. ទក្ខិណំ ពាហុំ ។



វៀរចាកមុសាវាទ បរិភោគភត្តតែមួយពេល ប្រព្រឹត្តធម៌ដ៏ប្រសើរ មានសីល មានធម៌ដ៏ល្អវិញ តើមហាបពិត្រ ត្រូវធ្វើអង្គុលិមាលនោះដូចម្តេចទៅ ។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនឹងថ្វាយបង្គំ ឬក្រោកទទួល និមន្តដោយអាសនៈ ឬទំនុកបំរុងនូវអង្គុលិមាលនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សារោគជាបច្ច័យដល់អ្នកជម្ងឺ និងបរិក្ខារទាំងឡាយ ឬនឹងចាត់ចែងនូវការរក្សា សេចក្តីការពារ និងការគ្រប់គ្រង ប្រកបដោយធម៌ដល់អង្គុលិមាលនោះ បពិត្រព្រះអង្គដ៏ចំរើន បើអង្គុលិមាលចោរនោះ ធ្លាប់ជាមនុស្សទ្រុស្តសីល មានធម៌ដ៏លាមកហើយ ធ្វើម្តេចនឹងសង្រួមក្នុងសីលយ៉ាងនោះកើត ។

(២៨៩) ក្នុងសម័យនោះឯង អង្គុលិមាលភិក្ខុមានអាយុ កំពុងអង្គុយជិតព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ លើកព្រះហស្តខាងស្តាំ ចង្អុលបង្ហាញព្រះបាទបសេនទិកោសលថា បពិត្រមហារាជ នុ៎ះហើយអង្គុលិមាល ។ លំដាប់នោះ ព្រះបាទបសេនទិកោសលក៏មានសេចក្តីភ័យកើត តក់ស្លុត ព្រឺរោម ព្រឺស្យូតឡើងមួយរំពេច ។ គ្រានោះ ព្រះមានព្រះភាគជ្រាបថា ព្រះបាទបសេនទិកោសល ទ្រង់ភ័យញ័រ ចំប្រប់ព្រឺរោម ដូច្នោះហើយ ក៏ត្រាស់ទៅនឹងព្រះបាទបសេនទិកោសល

មា ភាយិ មហារាជ មា ភាយិ មហារាជ នត្ថិ តេ ឥតោ[១] ភយន្តិ ។ អថខោ រញ្ញោ បសេនទិស្ស កោសលស្ស យំ អហោសិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សោ បដិប្បស្សម្ភិ ។ អថខោ រាជា បសេនទិ កោសលោ យេនាយស្មា អង្គុលិមាលោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អង្គុលិមាលំ ឯតទវោច អយ្យោ នោ ភន្តេ អង្គុលិមាលោតិ ។ ឯវំ មហារាជាតិ ។ កថំគោត្តោ ភន្តេ អយ្យស្ស បិតា កថំគោត្តា អយ្យស្ស មាតាតិ ។ គគ្គោ[២] ខោ មហារាជ បិតា មន្តាណី[៣] មាតាតិ ។ អភិរមតុ ភន្តេ អយ្យោ គគ្គោ មន្តាណីបុត្តោ អហំ។

១ ម. អតោ ។ ២ ម. គគ្គោ ។ ៣ ម. មន្តានី ។



ដូច្នេះថា បពិត្រមហារាជ សូមមហាបពិត្រកុំភ័យឡើយ បពិត្រមហារាជ សូមមហាបពិត្រកុំភ័យឡើយ ភ័យអំពីសំណាក់អង្គុលិមាលនេះ មិនមានដល់មហាបពិត្រទេ ។ លំដាប់នោះ ភ័យណាក្តី សេចក្តីតក់ស្លុតណាក្តី សេចក្តីព្រឺរោម ព្រឺស្បែកណាក្តី បានកើតមានដល់ព្រះបាទបសេនទិកោសល ភ័យជាដើមនោះ ក៏ស្ងប់រម្ងាប់បាត់ទៅក្នុងលំដាប់នោះឯង ។ គ្រានោះ ព្រះបាទបសេនទិកោសល ក៏ចូលទៅជិតអង្គុលិមាលភិក្ខុមានអាយុ លុះចូលទៅដល់ហើយ ក៏មានព្រះតម្រាស់សួរអង្គុលិមាលភិក្ខុមានអាយុដូច្នេះថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ឈ្មោះអង្គុលិមាលឬ ។ អង្គុលិមាលមានអាយុតបថា ថ្វាយព្រះពរមហារាជ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ចុះបិតាលោកម្ចាស់គោត្រអ្វី មាតាលោកម្ចាស់គោត្រអ្វី ។ អង្គុលិមាលមានអាយុតបថា ថ្វាយព្រះពរមហារាជ បិតា (អាត្មាភាព) ជាគគ្គគោត្រ មាតា (អាត្មាភាព) ជាមន្តានីគោត្រ ។ ព្រះបាទបសេនទិកោសល មានព្រះរាជឱង្ការបើកណាថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គគ្គគោត្រ មន្តានីបុត្រ អភិរម្យចុះ ខ្ញុំព្រះករុណា

យស្ស តត្ថស្ស បព្វជិតស្ស ឧស្សុក្កំ ការិស្សាមិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ តេន ខោ បន សមយេន អាយស្មា អង្គុលិមាលោ អារញ្ញិកោ ហោតិ បិណ្ឌបាតិកោ បំសុកូលិកោ តេចីវរិកោ ។ អថខោ អាយស្មា អង្គុលិមាលោ រាជានំ បសេនទិំ កោសលំ ឯតទវោច អលំ មហារាជ បរិបុណ្ណំ មេ តិចីវរន្តិ ។

(៤៩០) អថខោ រាជា បសេនទិ កោសលោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវញ្ចិទំ ភន្តេ ភគវា អទន្តានំ ទមេតា អសមេន្តានំ(១) សមេតា អបរិនិព្ពុតានំ បរិនិព្ពាបេតា យំ ហិ មយំ ភន្តេ នាសក្ខិម្ហា ទណ្ឌេនបិ សត្ថេនបិ ទមេតុំ សោ ភគវតា

១ ម. អសន្តានំ ។



នឹងទំនុកបំរុងដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សាគ្រូន ជាបច្ច័យដល់អ្នកជម្ងឺ នឹងបរិក្ខារទាំងឡាយ ដល់លោកម្ចាស់ គគ្គគោត្រ មន្តានីបុត្រ ។ សម័យនោះឯង អង្គុលិមាលមានអាយុ ប្រព្រឹត្តនៅតែក្នុងព្រៃ ប្រព្រឹត្តនូវតែបិណ្ឌបាត ប្រើប្រាស់តែសំពត់បង្សុកូល ប្រើប្រាស់តែចីវរ ៣ ។ បានជាកាលនោះ អង្គុលិមាលភិក្ខុមានអាយុ ថ្វាយព្រះពរព្រះបាទបសេនទិកោសលថា ពុំបាច់ទេមហាបពិត្រ អាត្មាភាពមានត្រៃចីវរគ្រប់គ្រាន់ហើយ ។

(៤៩០) លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះមានព្រះភាគ ព្រះអង្គអាចទូន្មានបុគ្គលដែលគេទូន្មានមិនបាន អាចរម្ងាប់បុគ្គលដែលគេរម្ងាប់មិនបាន អាចរំលត់ទុក្ខនូវបុគ្គលដែលគេរំលត់មិនបាន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនអាចនឹងទូន្មានបុគ្គលណា ដោយអាជ្ញាក្តី ដោយគ្រឿងសស្ត្រាក្តី ព្រះមានព្រះភាគ អាចទូន្មានបុគ្គលនោះ

អទណ្ឌេន អសត្ថេន(១) ទន្តោ ហន្ទ ចទានិ(២) មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ(៣) មហារាជ កាលំ មញ្ញសីតិ ។ អថខោ រាជា បសេនទិ កោសលោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[៤៨១] អថខោ អាយស្មា អង្គុលិមាលោ បុព្វណ្ហ-សមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ អាយស្មា អង្គុលិមាលោ សាវត្ថិយំ សបទានំ បិណ្ឌាយ ចរមានោ អញ្ញតរំ ឥត្ថឹ មូឡ្ហគព្ភំ វិឃាតគព្ភំ ។ ទិស្វានស្ស ឯតទហោសិ កិលិស្សន្តិ វត ភោ សត្តា កិលិស្សន្តិ វត ភោ សត្តាតិ ។ អថខោ អាយស្មា អង្គុលិមាលោ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

១ ម. អសត្ថេន ។ ២ ម. ហន្ទ ចទានិ ។ ៣ ម. យស្សទានិ ត្វំ [illegible] ។



បានដោយមិនបាច់មានអាជ្ញា ដោយមិនបាច់មានគ្រឿងសស្ត្រាវុធ បពិត្រព្រះអង្គដ៏ចំរើន ក៏ឥឡូវនេះ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលាទៅវិញ ព្រោះខ្ញុំព្រះអង្គមានកិច្ចការច្រើន មានការរវល់ច្រើន ។ ព្រះអង្គត្រាស់ថា ថ្វាយព្រះពរមហារាជ សូមមហាបពិត្រទ្រង់ជ្រាបនូវកាលគួរនឹងស្ដេចយាងទៅ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិ-កោសល ក៏ក្រោកចាកអាសនៈហើយ ក្រាបថ្វាយបង្គំលាព្រះមានព្រះភាគហើយ ធ្វើប្រទក្សិណស្ដេចចេញទៅ ។

(៤៨១) លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ រួចចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ អង្គុលិមាលមានអាយុ កាលទៅតាមលំដាប់ច្រកដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី បានឃើញនូវស្ត្រីម្នាក់ វង្វើសសាក៏ព្រោះគភ៌ មិនសប្បាយព្រោះគភ៌(១) ។ លុះលោកឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ ពួកសត្វលំបាកណាស់ ។ លំដាប់នោះ អង្គុលិមាលមានអាយុ ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្តហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ

១ ឈឺពោះ សម្រាលកូន ។

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អង្គុលិមាលោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរំ អាទាយ សាវត្ថឹ បិណ្ឌាយ បាវិសឹ អទ្ទសំ ខោ អហំ ភន្តេ សាវត្ថិយំ សបទានំ បិណ្ឌាយ ចរមានោ អញ្ញតរំ ឥត្ថឹ មូឡ្ហគព្ភំ វិឃាតគព្ភំ ទិស្វាន មេ ឯតទហោសិ កិលិស្សន្តិ វត ភោ សត្តា កិលិស្សន្តិ វត ភោ សត្តាតិ ។

(៦៩៦) តេនហិ ត្វំ អង្គុលិមាល យេន សា ឥត្ថី តេនុបសង្កម ឧបសង្កមិត្វា តំ ឥត្ថឹ ឯវំ វទេហិ យតោហំ ភគិនិ ជាតោ នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា តេន សច្ចេន សោត្ថិ តេ ហោតុ សោត្ថិ គព្ភស្សាតិ ។ សោ ហិ នូន មេ ភន្តេ សម្បជានមុសាវាទោ ភវិស្សតិ មយា ហិ ភន្តេ ពហូ សញ្ចិច្ច បាណា ជីវិតា វោរោបិតាតិ ។ តេនហិ ត្វំ អង្គុលិមាល យេន សា ឥត្ថី តេនុបសង្កម ឧបសង្កមិត្វា តំ ឥត្ថឹ ឯវំ វទេហិ យតោហំ ភគិនិ



រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះអង្គុលិមាល មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានស្លៀកស្បង់ ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យក្នុងថ្ងៃនោះ រួចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គកំពុងដើរទៅតាមលំដាប់ច្រក ដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី បានជួបនឹងស្ត្រីម្នាក់ផ្ទៃស្លាប់តែព្រោះគភ៌ មិនសម្រាលព្រោះគភ៌ លុះខ្ញុំព្រះអង្គឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ ពួកសត្វលំបាកណាស់ ។

(៦៩៦) ព្រះអង្គត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្ត្រីនោះយ៉ាងនេះថា នែនាង តាំងអំពីអាត្មាកើតមកមិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់នាង សូមសិរីសួស្តី កើតមានដល់គភ៌ ។ អង្គុលិមាលទូលថា បពិត្រព្រះអង្គដ៏ចំរើន សម្បជានមុសាវាទ នឹងមានដល់ខ្ញុំព្រះអង្គដោយពិត បពិត្រព្រះអង្គដ៏ចំរើន ព្រោះខ្ញុំព្រះអង្គបានក្លែងផ្តាច់ផ្តិលជីវិតសត្វជាច្រើន ។ ព្រះអង្គត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្ត្រីនោះយ៉ាងនេះថា នែនាង តាំងពីអាត្មា

អរិយាយ ជាតិយា ជាតោ នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា តេន សច្ចេន សោត្ថិ តេ ហោតុ សោត្ថិ គព្ភស្សាតិ ។ ។ ឯវំ ភន្តេតិ ខោ អាយស្មា អង្គុលិមាលោ ភគវតោ បដិស្សុត្វា យេន សា ឥត្ថី តេនុបសង្កមិ ឧបសង្កមិត្វា តំ ឥត្ថឹ ឯតទវោច យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា តេន សច្ចេន សោត្ថិ តេ ហោតុ សោត្ថិ គព្ភស្សាតិ ។ អថខោ សោត្ថិត្ថិយា អហោសិ សោត្ថិ គព្ភស្ស ។

(៤៩៣) អថខោ អាយស្មា អង្គុលិមាលោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ



កើតហើយក្នុងអរិយជាតិ (បានជាអរិយបុគ្គល) មិនដែលក្លែងផ្ដាច់ជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដី កើតមានដល់នាង សូមសិរីសួស្ដី កើតមានដល់គភ៌ ។ អង្គុលិមាលមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ករុណាព្រះអង្គ ហើយក៏ចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងស្ត្រីនោះដូច្នេះថា នែនាង តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ មិនដែលក្លែងផ្ដាច់ជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្ដី កើតមានដល់នាង សូមសិរីសួស្ដី កើតមានដល់គភ៌ ។ គ្រានោះឯង សិរីសួស្ដី ក៏បានកើតដល់ស្ត្រីនោះ សិរីសួស្ដីក៏បានកើតដល់គភ៌ ។

(៤៩៣) លំដាប់នោះ អង្គុលិមាលមានអាយុ ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ឥតមានសេចក្ដីធ្វេសប្រហែស មានព្យាយាមដុតនូវកិលេស ប្រថុយលះបង់នូវអត្តភាព ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ក៏បានដឹងច្បាស់

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា អង្គុលិមាលោ អរហតំ អហោសិ ។

[៤៨៦] អថខោ អាយស្មា អង្គុលិមាលោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថិំ បិណ្ឌាយ បាវិសិ ។ តេន ខោ បន សមយេន អញ្ញេនបិ លេឌ្ឌុ ខិត្តោ អាយស្មតោ អង្គុលិមាលស្ស កាយេ និបតតិ អញ្ញេនបិ ទណ្ឌោ ខិត្តោ អាយស្មតោ អង្គុលិមាលស្ស កាយេ និបតតិ អញ្ញេនបិ សក្ខរា ខិត្តា អាយស្មតោ អង្គុលិមាលស្ស កាយេ និបតតិ ។ អថខោ អាយស្មា អង្គុលិមាលោ ភិន្នេន សីសេន លោហិតេន គឡន្តេន ភិន្នេន បត្តេន វិប្ផាលិតាយ សង្ឃាដិយា យេន ភគវា តេនុបសង្កមិ ។ អទ្ទសា ខោ ភគវា អាយស្មន្តំ អង្គុលិមាលំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ អង្គុលិមាលំ ឯតទវោច



ថា ជាតិក្កំណើតរបស់អាត្មាអស់ហើយ មគ្គព្រហ្មចរិយធម៌គាត្មាអាត្មាបានប្រព្រឹត្តរួចហើយ សោឡសកិច្ចគាត្មាអាត្មាបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្ដាព្រះអរហន្តទាំងឡាយ អង្គុលិមាលមានអាយុ ក៏បានជាព្រះអរហន្តមួយរូបដែរ ។

[៤៨៦] លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅ ដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី ។ សម័យនោះឯង មនុស្សដទៃយកដុំដីគ្រវែងពាលធ្លាក់ទៅលើកាយអង្គុលិមាល មានអាយុក៏មាន មនុស្សដទៃយកដំបងគ្រវែងពាលធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន មនុស្សដទៃយកក្រួសផង់ធ្លាក់ទៅ លើកាយអង្គុលិមាលមានអាយុក៏មាន ។ គ្រានោះ អង្គុលិមាលមានអាយុ (មានបេស) បែកសីស: ហូរឈាម បែកបាត្រ រហែកសង្ឃាដិ ក៏ដើរចូលទៅគាល់ព្រះមានបុណ្យ ។ ព្រះមានបុណ្យ បានទតឃើញអង្គុលិមាលមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ត្រាស់នឹងអង្គុលិមាលមានអាយុដូច្នេះថា

អធិវាសេហិ ត្វំ ព្រាហ្មណ អធិវាសេហិ ត្វំ ព្រាហ្មណ យស្ស ខោ ត្វំ កម្មស្ស វិបាកេន ពហូនិ វស្សានិ ពហូនិ វស្សសតានិ ពហូនិ វស្សសហស្សានិ និរយេ បច្ចេយ្យាសិ តស្ស ត្វំ ព្រាហ្មណ កម្មស្ស វិបាកំ ទិដ្ឋេវ ធម្មេ បដិសំវេទេសីតិ ។

(៦៤៨) អថខោ អាយស្មា អង្គុលិមាលោ រហោគតោ បដិសល្លីនោ វិមុត្តិសុខំ បដិសំវេទី តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

យោ ច បុព្វេ បមជ្ជិត្វា
បច្ឆា សោ នប្បមជ្ជតិ
សោមំ លោកំ បភាសេតិ
អព្ភា មុត្តោវ ចន្ទិមា
យស្ស បាបំ កតំ កម្មំ
កុសលេន បិធីយតិ
សោមំ លោកំ បភាសេតិ
អព្ភា មុត្តោវ ចន្ទិមា
យោ ហវេ ទហរោ ភិក្ខុ



ព្រាហ្មណ៍ ចូរអ្នកទំនត់ទ្រាំទៅ ព្រាហ្មណ៍ ចូរអ្នកទំនត់ធ្មត់ទៅ អ្នកគួរឆ្អិនឆេះក្នុងនរកជាច្រើនឆ្នាំ ជាច្រើនរយឆ្នាំ ជាច្រើនពាន់ឆ្នាំ ដោយវិបាកនៃកម្មណា ម្នាលព្រាហ្មណ៍ អ្នកបានទទួលនូវវិបាកនៃកម្មនោះ ក្នុងបច្ចុប្បន្ននេះ (តែប៉ុណ្ណោះ) ។

(៦៤៨) វេលានោះ អង្គុលិមាលមានអាយុ ទៅនៅក្នុងទីរហោស្ថានពួនសម្ងំនៅម្នាក់ឯង បានទទួលនូវវិមុត្តិសុខ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

បុគ្គលណា ធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះមិនធ្វេសប្រហែសវិញ បុគ្គលនោះឈ្មោះថាញុំាងលោក[១]នេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក បាបកម្មដែលបុគ្គលណាធ្វើហើយ តែបុគ្គលនោះគ្របបាំងបិទបាំង គឺមិនទទួលផលកម្មវិញ ដោយសារកុសលកម្ម បុគ្គលនោះឈ្មោះថា ញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក ភិក្ខុណា កំលោះ

១ ពាក្យថា លោក ក្នុងទីនេះ សំដៅយកខន្ធ ធាតុ អាយតនៈ របស់ខ្លួន ។ អដ្ឋកថា ។

យុញ្ជតិ ពុទ្ធសាសនេ
សោមំ លោកំ បភាសេតិ
អព្ភាមុត្តោវ ចន្ទិមា
ទិសា ហិ មេ ធម្មកថំ សុណន្តុ
ទិសា ហិ មេ យុញ្ជន្តុ ពុទ្ធសាសនេ
ទិសា ហិ មេ តេ មនុជា(១) ភជន្តុ
យេ ធម្មមេវាទបយន្តិ សន្តោ
ទិសា ហិ មេ ខន្តិវាទានំ(២)
អវិរោធប្បសំសិនំ(៣)
សុណន្តុ ធម្មំ កាលេន
តញ្ច អនុវិធីយន្តុ
ន ហិ ជាតុ សោ មមំ ហិំសេ
អញ្ញំ វា(៤) បន កិញ្ចិនំ
បប្បុយ្យ បរមំ សន្តិំ
រក្ខេយ្យ តសថាវរេ ។
ឧទកញ្ហិ នយន្តិ នេត្តិកា

១ ម. មនុស្សា ។ ២ ឱ. ខន្តិវាទីនំ ។ ម. ខន្តិវាទានំ ។ ៣ ឱ. អវិរោធប្បសំ-
សីនំ ។ ម. អវិរោធប្បសំសនំ ។ ៤ ម. វ ។



នៅឡើយ ប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯង ឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក

សូមពួកមនុស្សជាសត្រូវ ស្តាប់ធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ប្រកបព្យាយាមក្នុងពុទ្ធសាសនា ពួកសប្បុរសណា ដែលដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ សេពគប់ពួកសប្បុរសទាំងនោះចុះ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ស្តាប់ធម៌ជាទីផ្សះផ្សង់ គឺខន្តិ ទាំងជាទីសរសើរនូវការមិនទាស់ទែងគ្នា តាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ បំពេញនូវធម៌នោះផង មនុស្សណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់នូវសេចក្តីស្ងប់គឺព្រះនិព្វាន ហើយរក្សានូវមនុស្សដែលប្រកបដោយតណ្ហា និងមនុស្សដែលមិនមានតណ្ហា ។

ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹក (តាមប្រឡាយទឹក) ពួកអ្នក

ឧសុការា ទមយន្តិ តេជនំ
ទារុំ ទមយន្តិ តច្ឆកា
អត្តានំ ទមយន្តិ បណ្ឌិតា
ទណ្ឌេនេកេ ទមយន្តិ
អង្កុសេហិ កសាហិ ច
អទណ្ឌេន អសត្ថេន
អហំ ទន្តោម្ហិ តាទិនា
អហឹសកោតិ មេ នាមំ
ហឹសកស្ស បុរេ សតោ
អជ្ជាហំ សច្ចនាមោម្ហិ
ន នំ ហឹសាមិ កញ្ចិនំ
ចោរោ អហំ បុរេ អាសឹ
អង្គុលិមាលោតិ វិស្សុតោ
វុយ្ហមានោ មហោឃេន
ពុទ្ធំ សរណមាគមំ
លោហិតបាណី បុរេ អាសឹ
អង្គុលិមាលោតិ វិស្សុតោ



ធ្វើកូនសរ រមែងពត់កូនសរ ពួកអ្នកចាំងឈើ រមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយ រមែងទូន្មានខ្លួនបានដូចនោះដែរ ។ ពួកមនុស្សខ្លះទូន្មានដោយដំបង ដោយកង្វេរ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានអាត្មា ដែលព្រះមានបុណ្យ ជាតាទិបុគ្គល មិនបានយកដំបង ឬគ្រឿងសស្ត្រាវុធ (មកទូន្មានខ្ញុំទេ) កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ (ជាអ្នកមិនបៀតបៀនគេ) តែជាអ្នកបៀតបៀនគេ ដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់ គឺសមតាមឈ្មោះដើមខ្ញុំហើយ ព្រោះខ្ញុំមិនបៀតបៀនអ្នកណាមួយទៀតទេ កាលពីដើមខ្ញុំជាចោរ មានគេប្រាកដថា អង្គុលិមាល ដែលជំនន់ធំបន្សាត់ទៅ (តែឥឡូវនេះ) ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ កាលពីដើម ខ្ញុំមានដៃប្រឡាក់ឈាម មានគេប្រាកដថាអង្គុលិ

សរណាគមនំ បស្ស
ភវនេត្តិ សមូហតា
តាទិសំ កម្មំ កត្វាន
ពហុំ(១) ទុគ្គតិគាមិនំ
ផុដ្ឋោ កម្មវិបាកេន
អនណោ ភុញ្ជាមិ ភោជនំ
បមាទមនុយុញ្ជន្តិ
ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី
ធនំ សេដ្ឋំវ រក្ខតិ
មា បមាទមនុយុញ្ជេថ
មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ
បប្បោតិ វិបុលំ(២) សុខំ
ស្វាគតំ(៣) នាបគតំ(៤)

១ ឱ. ពហុ ។ ២ ម. បរមំ ។ ៣ ឱ. សាគតំ ។ ៤ ម. នាបគតំ ។





មាល (តែឥឡូវនេះ) សរណាគមន៍ខ្ញុំបានដល់ហើយ តណ្ហា
ជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំ
បានធ្វើអំពើដែលគួរនាំទៅកាន់ទុគ្គតិដ៏ច្រើនពិតមែន តែកម្ម-
វិបាកនិមន្តរបានមកពាល់ (ក្តីសង្គ្រោះខ្ញុំហើយ) ខ្ញុំជាអ្នក
ដែលចំពាក់បំណុលគឺកិលេស បរិភោគភោជន ពួកជនពាល
ឥតប្រាជ្ញា តែងប្រកបសេចក្តីប្រមាទ ឯអ្នកប្រាជ្ញតែងរក្សា
សេចក្តីមិនប្រមាទទុក ដូចរក្សាទ្រព្យដ៏ថ្លៃថ្លា សូមអ្នកទាំង
ឡាយ កុំប្រកបសេចក្តីប្រមាទឡើយ កុំប្រកបសេចក្តីត្រេកអរ
នឹងការរួមមិត្តនឹងកាមឡើយ ព្រោះថាបុគ្គលអ្នកមិនប្រ-
មាទ សម្លឹង ទំនុកបំផ្លាញ (នូវកិលេស) រមែងបានដល់នូវ
សេចក្តីសុខដ៏ទូលាយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ

នយិទំ ទុម្មន្តិតំ មម

សុវិភត្តេសុ(១) ធម្មេសុ

យំ សេដ្ឋំ តទុបាគមឹ

ស្វាគតំ នាបគតំ

នយិទំ ទុម្មន្តិតំ មម

តិស្សោ វិជ្ជា អនុប្បត្តា

កតំ ពុទ្ធស្ស សាសនន្តិ ។

អង្គុលិមាលសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

---

១ ម. បវិភត្តេសុ ។



គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្ដាធម៌ទាំងឡាយ ដែលព្រះអង្គចែកល្អហើយ ព្រះនិព្វានណាជាគុណជាតដ៏ប្រសើរ ខ្ញុំបានដល់នូវព្រះនិព្វាននោះហើយ ខ្ញុំមកល្អហើយ ខ្ញុំមិនទៅឥតប្រយោជន៍ទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ វិជ្ជា ៣ ប្រការ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើតាមហើយ ។

ចប់ អង្គុលិមាលសូត្រ ទី ៦ ។

## សត្តមំ បិយជាតិកសុត្តំ

(៤៤៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរស្ស គហបតិស្ស ឯកបុត្តកោ បិយោ មនាបោ កាល-កតោ ហោតិ ។ តស្ស កាលកិរិយាយ នេវ កម្មន្តា បដិភន្តិ ន ភត្តំ បដិភាតិ ។ សោ អាឡាហនំ គន្ត្វា កន្ទតិ កហំ ឯកបុត្តក កហំ ឯកបុត្តកាតិ ។ អថខោ សោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

(៤៤៧) ឯកមន្តំ និសិន្នំ ខោ តំ គហបតឹ ភគវា ឯតទវោច ន ខោ តេ គហបតិ សកេ ចិត្តេ ឋិតស្ស ឥន្ទ្រិយានិ អត្ថិ តេ ឥន្ទ្រិយានំ អញ្ញ-ថត្តន្តិ ។ កឹ ហិ មេ ភន្តេ ឥន្ទ្រិយានំ នាញ្ញ-ថត្តំ ភវិស្សតិ មយ្ហញ្ហិ ភន្តេ ឯកបុត្តកោ បិយោ

## បិយជាតិកសូត្រ ទី ៧

(៤៤៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងជេតវនារាម របស់អនា-ថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង គហបតីម្នាក់ មានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណ-កាលទៅ ។ ព្រោះកូននោះធ្វើកាលកិរិយាទៅ ការងារទាំងឡាយក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ (ដល់គាត់) ឡើយ ។ គាត់តែងតែទៅកាន់ឈាបនដ្ឋានយំថា ឱកូនតូចតែមួយ អ្នកនៅក្នុងទីណា ឱកូនតូចតែមួយ អ្នកនៅក្នុងទីណា ។ គ្រាក្រោយមក គហបតីនោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

(៤៤៧) លុះគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលគហបតី អ្នកតាំងនៅក្នុងចិត្តរបស់ខ្លួនគឺនៅរស់ទេ តែហាក់ដូចជាមិនមានឥន្ទ្រិយគឺមនោវិញ្ញាណ (ព្រោះ) ឥន្ទ្រិយរបស់អ្នកប្រែសម្បុរផ្សេង ។ គហបតី ទូលថា ឱព្រះអង្គដ៏ចំរើន ឥន្ទ្រិយរបស់ខ្ញុំព្រះអង្គ នឹងមិនប្រែពណ៌សម្បុរផ្សេងណាកើតបាន បពិត្រព្រះអង្គដ៏ចំរើន ព្រោះខ្ញុំព្រះអង្គមានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់

មនាបោ កាលកតោ តស្ស កាលកិរិយាយ នេវ កម្មន្តា បដិភន្តិ ន ភត្តំ បដិភាតិ សោហំ អាឡាហនំ គន្ត្វា គន្ត្វា កន្ទាមិ កហំ ឯកបុត្តក កហំ ឯកបុត្តកាតិ ។ ឯវមេតំ គហបតិ ឯវមេតំ គហបតិ បិយជាតិកា ហិ គហបតិ សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ(១) ។ កស្ស(២) ខោ នាមេតំ ភន្តេ ឯវំ ភវិស្សតិ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកា ។ បិយជាតិកា ហិ ខោ ភន្តេ អានន្ទសោមនស្សា បិយប្បភវិកាតិ ។ អថ ខោ សោ គហបតិ ភគវតោ ភាសិតំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ ។

១ ម. ម. បិយប្បភវិកាតិ ។ ២ ម. ម. កស្ស ។



គេញចិត្ត បានធ្វើមរណកាលទៅ ព្រោះតែធ្វើកាលកិរិយានោះ ការងារក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ (ដល់ខ្ញុំព្រះអង្គ) សោះ ខ្ញុំព្រះអង្គនោះ តែងទៅកាន់ឈាបនដ្ឋាន ហើយយំថា កូនតូចមាសថ្លៃ អ្នកទៅកន្លែងណា កូនតូចមាសថ្លៃ អ្នកទៅកន្លែងណា ។ ព្រះមានបុណ្យត្រាស់ថា ដំណើរនេះយ៉ាងនោះមែន គហបតី ដំណើរនេះ យ៉ាងនោះមែន គហបតី ពិតមែន គហបតី សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ គហបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ធម្មតាហេតុនៃសេចក្តីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដែរ បពិត្រព្រះអង្គដ៏ចំរើន តែបើតាមដែលពិតនោះ សេចក្តីត្រេកអរនឹងសេចក្តីរីករាយ តែងកើតមក អំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត(១) ។ ខណៈនោះ គហបតីនោះ មិនត្រេកអរ មិនឃាត់ឃាមនូវភាសិត របស់ព្រះមានបុណ្យទេ ក៏ក្រោកចាកអាសនៈចេញទៅ ។

១ ពាក្យនេះជាគហបតីនោះពោលនូវសេចក្តីដោយយល់ផ្ទុយនឹងព្រះពុទ្ធ ។

(២៤៨) តេន ខោ បន សមយេន សម្ពហុលា អក្ខធុត្តា ភគវតោ អវិទូរេ អក្ខេហិ ទិព្វន្តិ ។ អថ ខោ សោ គហបតិ យេន តេ អក្ខធុត្តា តេនុបសង្កមិ ឧបសង្កមិត្វា តេ អក្ខធុត្តេ ឯតទវោច ឥធាហំ ភោន្តោ យេន សមណោ គោតមោ តេនុបសង្កមឹ ឧបសង្កមិត្វា សមណំ គោតមំ អភិវាទេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នំ ខោ មំ ភោន្តោ សមណោ គោតមោ ឯតទវោច ន ខោ តេ គហបតិ សកេ ចិត្តេ ឋិតស្ស ឥន្ទ្រិយានិ អត្ថិ តេ ឥន្ទ្រិយានំ អញ្ញថត្តន្តិ ឯវំ វុត្តេ អហំ ភោន្តោ សមណំ គោតមំ ឯតទវោចំ កឹ ហិ មេ ភន្តេ ឥន្ទ្រិយានំ នាញ្ញថត្តំ ភវិស្សតិ យស្ស ហិ មេ ភន្តេ ឯកបុត្តកោ បិយោ មនាបោ កាល-កតោ តស្ស កាលកិរិយាយ នេវ កម្មន្តា បដិភន្តិ



(២៤៨) សម័យនោះ មានពួកអ្នកលេងល្បែងភ្នាល់ច្រើននាក់ កំពុងលេងដោយល្បែងភ្នាល់ទាំងឡាយ ក្នុងទីមិនឆ្ងាយប៉ុន្មានអំពីព្រះមានបុណ្យ ។ ចំណែកគហបតីនោះ ក៏ចូលទៅរកពួកអ្នកលេងល្បែងភ្នាល់នោះ លុះចូលទៅដល់ហើយ ក៏និយាយទៅនឹងអ្នកលេងល្បែងភ្នាល់នោះដូច្នេះថា នែអ្នកដ៏ចំរើនទាំងឡាយ អម្បាញ់មិញនេះ ខ្ញុំបានចូលទៅគាល់ព្រះសមណគោតម លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសមណគោតម រួចអង្គុយក្នុងទីដ៏សមគួរ នែអ្នកដ៏ចំរើនទាំងឡាយ លុះខ្ញុំអង្គុយក្នុងទីដ៏សមគួរហើយ ព្រះសមណគោតមទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកឋិតនៅក្នុងចិត្តរបស់ខ្លួនគឺរស់នៅទេ តែហាក់ដូចជាមិនមានឥន្ទ្រិយ (ព្រោះ) ឥន្ទ្រិយរបស់អ្នកប្រែសម្បុរប្លែកដូច្នេះ នែអ្នកដ៏ចំរើនទាំងឡាយ កាលព្រះសមណគោតមត្រាស់យ៉ាងនេះ ខ្ញុំក៏បានតបទៅនឹងព្រះសមណគោតមវិញថា ព្រះអង្គដ៏ចំរើន ឥន្ទ្រិយរបស់ខ្ញុំព្រះអង្គនឹងមិនប្រែ ណាំសម្បុរប្លែកណាក៏បាន បពិត្រព្រះអង្គដ៏ចំរើន ព្រោះខ្ញុំព្រះអង្គមានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្តបាន ធ្វើមរណកាលទៅ ព្រោះតែការធ្វើកាលកិរិយានោះ ការងារក៏មិនប្រាកដ

ន ភត្តំ បដិភាតិ សោហំ អាឡាហនំ គន្ត្វា កន្ទាមិ កហំ ឯកបុត្តក កហំ ឯកបុត្តកាតិ ។ ឯវមេតំ គហបតិ ឯវមេតំ គហបតិ បិយជាតិកា ហិ គហបតិ សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។ កស្ស ខោ នាមេតំ ភន្តេ ឯវំ ភវិស្សតិ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកា បិយជាតិកា ហិ ខោ ភន្តេ អានន្ទសោមនស្សា បិយប្បភវិកាតិ ។ អថខោហំ ភោន្តោ សមណស្ស គោតមស្ស ភាសិតំ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិន្តិ ។ ឯវមេតំ គហបតិ ឯវមេតំ គហបតិ



ភត្តាហារក៏មិនត្រូវគជ (ផល់ខ្ញុំ) សោះ ខ្ញុំព្រះអង្គនោះឯងតែងទៅកាន់ឈាបនដ្ឋានយំរកថា ឱកូនកូនចាស់ថ្លៃ អ្នកទៅក្នុងទីណា ឱកូនកូនចាស់ថ្លៃ អ្នកទៅក្នុងទីណា ដូច្នេះ ទើបព្រះសមណគោតមត្រាស់ថា ដំណើរនុ៎ះយ៉ាងនេះមែន គហបតី ដំណើរនុ៎ះយ៉ាងនេះមែន គហបតី ពិតមែន គហបតី សេចក្ដីសោកស្ដាយ ខ្សឹកខ្សួល សេចក្ដីទុក្ខ ទុក្ខចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ ជាដែនកើត (កាលបើព្រះមានបុណ្យទ្រង់ត្រាស់យ៉ាងនេះ ខ្ញុំក៏ទូលតបវិញ) ថា បពិត្រព្រះអង្គដ៏ចំរើន ធម្មតាហេតុនៃសេចក្ដីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្ដីសោកស្ដាយ ខ្សឹកខ្សួល សេចក្ដីទុក្ខ ទុក្ខចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើតមែន បពិត្រព្រះអង្គដ៏ចំរើន តែតាមដែលពិតនោះ សេចក្ដីត្រេកអរនឹងសេចក្ដីរីករាយ តែងកើតមកពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើតដូច្នេះ នែអ្នកដ៏ចំរើនទាំងឡាយ កាលនោះខ្ញុំមិនត្រេកអរ មិនឃាត់ឃាមនូវភាសិតរបស់ព្រះសមណគោតមទេ ខ្ញុំក្រោកចាកអាសនៈហើយក៏ចេញមក ។ ពួកអ្នកលេងល្បែងភ្នាល់ឆ្លើយតបថា បពិត្រលោកគហបតី ពាក្យដែលលោកបានប្រកាសនុ៎ះ ត្រូវហើយ បពិត្រលោកគហបតី ពាក្យដែលលោកបានប្រកាសនុ៎ះ ត្រូវហើយ

បិយជាតិកា ហិ គហបតិ អានន្ទសោមនស្សា បិយប្បភវិកាតិ ។ អថខោ សោ គហបតិ សបេតិ មេ អក្ខន្តុដ្ឋាយាតិ បក្កាមិ ។

(៦៩៩) អថខោ ឥទំ កថាវត្ថុំ អនុបុព្វេន រាជន្តេបុរំ បាវិសិ ។ អថខោ រាជា បសេនទិ កោសលោ មល្លិកំ ទេវឹ អាមន្តេសិ ឥទន្តេ មល្លិកេ សមណេន គោតមេន ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខ-ទោមនស្សុបាយាសា បិយប្បភវិកាតិ ។ សចេ តំ មហារាជ ភគវតា ភាសិតំ ឯវមេតន្តិ ។ ឯវមេវំ បនាយំ មល្លិកា យញ្ញទេវ សមណោ គោតមោ ភាសតិ តំ តទេវស្ស អព្ភនុមោទតិ សចេ តំ មហារាជ ភគវតា ភាសិតំ ឯវមេតន្តិ សេយ្យថាបិ នាម



បពិត្រគហបតី សេចក្តីត្រេកអរនិងសេចក្តីរីករាយ កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដោយពិត ។ ទើបគហបតីនោះគិតថា ពាក្យរបស់គ្នាអញ សមគ្នានឹងពួកអ្នកលេងល្បែងភ្នាល់ ដូច្នេះ រួចក៏ចេញទៅ ។

(៦៩៩) គ្រានោះឯង ដំណើរកថានេះ ក៏ឮខ្ចរខ្ចាយតាមលំដាប់ ហូតចូលទៅដល់ក្នុងព្រះរាជវាំង ។ វេលានោះ ព្រះបាទបសេន-ទិកោសល ទ្រង់ត្រាស់សួរទៅនាងមល្លិកាទេវីថា នែមល្លិកា ព្រះសមណគោតម (ជាគ្រូ) របស់នាងបានសំដែងព្រះកថានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះមែនឬអី ។ ព្រះនាងមល្លិកាទេវី ក្រាបបង្គំទូលថា បពិត្រព្រះមហារាជ បើពាក្យនោះ ព្រះមានបុណ្យទ្រង់សំដែងមែន ដំណើរនុះក៏ពិតយ៉ាងនោះឯង ។ ព្រះបាទបសេនទិកោសល ទ្រង់បន្ទោសថា មិនសមបើយ៉ាងនេះៗ សោះ ព្រះសមណគោតម ពោលនូវពាក្យណា មល្លិកានេះ ហ៊ាននិយាយតាមបណ្តោយតាមពាក្យនោះៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមហារាជ បើពាក្យនោះព្រះមានបុណ្យ ទ្រង់សំដែងមែន ដំណើរនុះក៏ពិតយ៉ាងនោះដូច្នេះសោះ ប្រៀប

អាចរិយោ យញ្ញទេវ អន្តេវាសិស្ស ភាសតិ តំ តទេវស្ស អន្តេវាសី អព្ភនុមោទតិ ឯវមេតំ អាចរិយ ឯវមេតំ អាចរិយាតិ ឯវមេវ ខោ ត្វំ មល្លិកេ យញ្ញទេវ សមណោ គោតមោ ភាសតិ តំ តទេវស្ស អព្ភនុមោទសិ សចេ តំ មហារាជ ភគវា ភាសតិ ឯវមេតន្តិ ចរ បិរេ មល្លិកេ វិនស្សាតិ ។

(៣០០) អថខោ មល្លិកា ទេវី នាឡិជង្ឃំ ព្រាហ្មណំ អាមន្តេសិ ឯហិ ត្វំ ព្រាហ្មណ យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ មល្លិកា ភន្តេ ទេវី ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ



ដូចអាចារ្យនិយាយពាក្យណា ៗ ដល់កូនសិស្ស ៗ ក៏និយាយតាក់បណ្ដោយតាមពាក្យនោះ ៗ របស់អាចារ្យនោះថា បពិត្រលោកអាចារ្យ ដំណើរនុ៎ះយ៉ាងហ្នឹងមែន បពិត្រលោកអាចារ្យ ដំណើរនុ៎ះយ៉ាងហ្នឹងមែន សេចក្ដីនេះ នាងឧបមាយ៉ាងណា នែមល្លិកា ព្រះសមណគោតមពោលនូវពាក្យណា ៗ នាងក៏និយាយតាក់បណ្ដោយតាមពាក្យនោះ ៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមហារាជ បើពាក្យនោះព្រះមានបុណ្យទ្រង់សំដែងមែន ដំណើរនុ៎ះកើតយ៉ាងនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ នែមល្លិកា ចូរនាងចៀសអំពីមុខអញចេញទៅ (ព្រោះ) នាងវិលខូចណាស់ ។

(៣០០) គ្រានោះ ព្រះនាងមល្លិកាទេវី មានព្រះសវនីយ៍ទៅកាន់នាឡិជង្ឃព្រាហ្មណ៍ថា នែព្រាហ្មណ៍ ចូរអ្នកមកអាយ ចូរអ្នកចូលទៅគាល់ព្រះភគវន្តមុនី លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះភគវន្តមុនីដោយត្បូង ក្រាបទូលសួរនូវសេចក្ដីមិនមានអាពាធ មិនមានពេធ ការក្រោកឡើងរហ័ស កំឡាំង ការគង់នៅជាសុខ តាមពាក្យខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមល្លិកាទេវី សូមថ្វាយបង្គំព្រះបាទ របស់ព្រះមានព្រះភាគដោយត្បូង ទាំងសូមទូលសួរនូវការមិនមានអាពាធ មិនមានពេធ ការក្រោកឡើងរហ័ស កំឡាំង

ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេហិ ភាសិតា នុ ខោ ភន្តេ ភគវតា ឯសា វាចា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ យថា តេ(១) ភគវា ព្យាករោតិ តំ សាធុកំ ឧគ្គហេត្វា មមារោចេយ្យាសិ(២) ន ហិ តថាគតា វិតថំ ភណន្តីតិ ។ ឯវំ ភោតីតិ ខោ នាឡិជង្ឃោ ព្រាហ្មណោ មល្លិកាយ ទេវិយា បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ នាឡិជង្ឃោ ព្រាហ្មណោ ភគវន្តំ ឯតទវោច មល្លិកា ភោ គោតម ទេវី ភោតោ គោតមស្ស បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ ភាសិតា នុ ខោ ភន្តេ ភគវតា

១ យថា ច តេ ។ ២ ម. មមំ អារោចេយ្យាសិ ។ ម. មប... ។



ការគង់នៅជាសុខផង រួចហើយទូលសួរយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ បានសំដែងព្រះពុទ្ធដីកានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត ដែលកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះ ឬអ្វី បើព្រះមានព្រះភាគ ទ្រង់ដោះស្រាយប្រាប់អ្នក យ៉ាងណា ចូរអ្នកចាំពាក្យនោះឲ្យល្អ ហើយមកប្រាប់ដល់ខ្ញុំវិញ ព្រោះព្រះតថាគតទាំងឡាយ មិនពោលពាក្យដែលមិនពិតប្រាកដឡើយ ។ នាឡិជង្ឃព្រាហ្មណ៍ ទទួលព្រះវាចារបស់ព្រះនាងមល្លិកាទេវីថា ទទួលព្រះសៅនីយ៍ករុណាវិសេស ដូច្នេះ រួចក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានបុណ្យ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនាឡិជង្ឃព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលពាក្យនុ៎ះ ចំពោះព្រះមានបុណ្យថា បពិត្រព្រះគោតមដ៏ចំរើន ព្រះនាងមល្លិកាទេវី សូមថ្វាយបង្គំព្រះបាទារបស់ព្រះគោតមដ៏ចំរើន ដោយត្បូង ព្រមទាំងសូមសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស កំឡាំង ការគង់នៅជាសុខ មួយទៀត ព្រះនាងសូមទូលសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ

ឯសា ហិ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។ ឯវមេតំ ព្រាហ្មណ ឯវមេតំ ព្រាហ្មណ បិយជាតិកា ហិ ព្រាហ្មណ សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។ តទិមិនាបេតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។

[៣០១] ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរស្សា ឥត្ថិយា មាតា កាលមកាសិ ។ សា តស្សា កាលកិរិយាយ ឧម្មត្តិកា ខិត្តចិត្តា រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ មាតរំ អទស្សថ



បានសំដែងព្រះពុទ្ធដីកានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ ទួលចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ដូច្នេះឬ ។ ព្រះអង្គត្រាស់ថា អើ ព្រាហ្មណ៍ ពាក្យនុ៎ះ តថាគតថាយ៉ាងនោះមែន អើព្រាហ្មណ៍ ពាក្យនុ៎ះ តថាគតថាយ៉ាងនោះមែន ម្នាលព្រាហ្មណ៍ ពិតមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ ទួលចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ គេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ ទួលចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះ ដោយបរិយាយនេះ ។

[៣០១] ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មាតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើកាលកិរិយាទៅ ។ តាំងអំពីកាលកិរិយា នៃមាតានោះ ស្ត្រីនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រកល្ហក សព្វផ្លូវក្រឡុងកែង ស្រែកសួរយ៉ាងនេះថា អ្នកទាំងឡាយ បានឃើញមាតាខ្ញុំដែរឬ អ្នកទាំងឡាយ បាន

អបិ មេ មាតរំ អទ្ទស្សថាតិ ។ ឥមិនាបិ ខោ ឯតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរិស្សា ឥត្ថិយា បិតា កាលមកាសិ... ភាតា កាលមកាសិ... ភគិនី កាលមកាសិ... បុត្តោ កាលមកាសិ... ធីតា កាលមកាសិ... សាមិកោ កាលមកាសិ ។ សា តស្ស កាលកិរិយាយ ឧម្មត្តិកា ខិត្តចិត្តា រថិកាយ រថិកំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ សាមិកំ អទ្ទស្សថ អបិ មេ សាមិកំ អទ្ទស្សថាតិ ។ ឥមិនាបិ ខោ ឯតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។



ឃើញមាតាខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ ទុក្ខចិត្ត ការចង្អៀតចង្អល់ចិត្ត កែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយគឺ មាតាបិតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាល.. បងប្អូនប្រុសបានធ្វើមរណកាល.. បងប្អូនស្រីបានធ្វើមរណកាល... កូនប្រុសបានធ្វើមរណកាល... កូនស្រីបានធ្វើមរណកាល... ស្វាមីបានធ្វើមរណកាល ។ កាលអំពីកាលកិរិយានៃស្វាមីនោះ ស្ត្រីនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រកល្ហក សព្វផ្លូវបែកបួនកែង ស្រែកសួរយ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញស្វាមីខ្ញុំដែរឬ ឱអ្នកទាំងឡាយ បានឃើញស្វាមីខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ ទុក្ខចិត្ត ការចង្អៀតចង្អល់ចិត្ត កែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

(៣០៦) ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរស្ស បុរិសស្ស មាតា កាលមកាសិ ។ សោ តស្សា កាលកិរិយាយ ឧម្មត្តកោ ចិត្តក្ខិត្តោ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ មាតរំ អទ្ទស្សថ អបិ មេ មាតរំ អទ្ទស្សថាតិ ។ ឥមិនាបិ ខោ ឯតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។ ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរស្ស បុរិសស្ស បិតា កាលមកាសិ... ភាតា កាលមកាសិ... ភគិនី កាលមកាសិ... បុត្តោ កាលមកាសិ... ធីតា កាលមកាសិ.. បជាបតិ កាលមកាសិ ។ សោ តស្សា កាលកិរិយាយ ឧម្មត្តកោ ចិត្តក្ខិត្តោ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ឧបសង្កមិត្វា ឯវមាហ អបិ មេ បជាបតឹ អទ្ទស្សថ អបិ មេ បជាបតឹ អទ្ទស្សថាតិ ។



(៣០៦) ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយគឺ មានមាតាបុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាលទៅ ។ តាំងអំពីមរណកាល នៃមាតានោះ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រកល្ហក សព្វផ្លូវក្រៀវឡូងកែង ស្រែកសួរយ៉ាងនេះថា អ្នកទាំងឡាយ បានឃើញម្តាយខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញម្តាយខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះហេតុនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយ មានបិតាបុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាល... បងប្អូនប្រុសបានធ្វើមរណកាល... បងប្អូនស្រីបានធ្វើមរណកាល... កូនប្រុសបានធ្វើមរណកាល... កូនស្រីបានធ្វើមរណកាល... ប្រពន្ធបានធ្វើមរណកាលទៅ ។ តាំងអំពីមរណកាលនៃភរិយានោះ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រកល្ហក សព្វផ្លូវក្រៀវឡូងកែង ស្រែកសួរយ៉ាងនេះថា អ្នកទាំងឡាយ បានឃើញប្រពន្ធខ្ញុំដែរឬ អ្នកទាំងឡាយ បានឃើញប្រពន្ធខ្ញុំដែរឬ ។

ឥមិនាបិ ខោ ឯតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។

(៣០៣) ភូតបុព្វំ ព្រាហ្មណ ឥមិស្សាយេវ សាវត្ថិយា អញ្ញតរា ឥត្ថី ញាតិកុលំ អគមាសិ ។ តស្សា តេ ញាតកា សាមិកំ អច្ឆិន្ទិត្វា អញ្ញស្ស ទាតុកាមា សា ច តំ ន ឥច្ឆតិ ។ អថខោ សា ឥត្ថី សាមិកំ ឯតទវោច ឥមេ មម អយ្យបុត្ត ញាតកា តំ(១) អច្ឆិន្ទិត្វា អញ្ញស្ស ទាតុកាមា អហញ្ច តំ ន ឥច្ឆាមីតិ ។ អថខោ សោ បុរិសោ តំ ឥត្ថឹ ទ្វិធា ឆេត្វា អត្តានំ ឧប្ផាលេសិ(២) ឧភោ បេច្ច ភវិស្សាមាតិ ។ ឥមិនាបិ ខោ ឯតំ ព្រាហ្មណ បរិយាយេន វេទិតព្វំ យថា បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។

---

១. ម. មំ ។ ២. ឱ. ឧប្ផាលេសីតិ ទិស្សតិ ។ ម. ឧប្បាលេសីតិ ទិស្សតិ ។



ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត ដែលកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

(៣០៣) ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយគឺ ក្នុងក្រុងសាវត្ថីនេះ មានស្ត្រីម្នាក់បានទៅកាន់ត្រកូលនៃញាតិ នឹងមានប្តី ។ ពួកញាតិទាំងនោះ របស់ស្ត្រីនោះ មានប្រាថ្នានឹងផ្តាច់ប្តីចេញ ហើយលើក (នាងនោះ) ឲ្យទៅបុរសឯទៀតវិញ តែនាងនោះមិនចង់បានបុរសនោះសោះ ។ ទើបស្ត្រីនោះនិយាយនឹងប្តីនូវពាក្យនេះថា បពិត្រអយ្យបុត្រ ពួកញាតិរបស់ខ្ញុំនេះ មានប្រាថ្នានឹងផ្តាច់អ្នកចេញ ហើយលើកខ្ញុំឲ្យទៅបុរសឯទៀតវិញ តែខ្ញុំមិនចង់បានបុរសនោះសោះ ។ គ្រានោះ បុរសនោះក៏កាប់ស្ត្រីនោះជាពីរកំណាត់ ហើយវះពោះខ្លួនឯង ដោយប្រាថ្នាថា សូមឲ្យយើងទាំងពីរនាក់បានជួបគ្នាទៅក្នុងបរលោក ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត ដែលកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[៣០៤] អថខោ នាឡិជង្ឃោ ព្រាហ្មណោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា យេន មល្លិកា ទេវី តេនុបសង្កមិ ឧបសង្កមិត្វា យាវតកោ អហោសិ ភគវតា សទ្ធឹ កថាសល្លាបោ(១) សព្វំ មល្លិកាយ ទេវិយា អារោចេសិ ។ អថខោ មល្លិកា ទេវី យេន រាជា បសេនទិ កោសលោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បសេនទិំ កោសលំ ឯតទវោច តំ កឹ មញ្ញសិ មហារាជ បិយា តេ វជិរី កុមារីតិ ។ ឯវំ មល្លិកេ បិយា មេ វជិរី កុមារីតិ ។ តំ កឹ មញ្ញសិ មហារាជ វជិរិយា តេ កុមារិយា វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ វជិរិយា មេ មល្លិកេ កុមារិយា វិបរិណាមញ្ញថាភាវា ជីវិតស្សបិ សិយា

១ ។ ម. ឯត្តកោ ឥតិ ទិស្សតិ ។



[៣០៤] គ្រានោះ នាឡិជង្ឃព្រាហ្មណ៍ ក៏ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះមានបុណ្យ រួចក្រោកអំពីអាសនៈ ចូលទៅគាល់ព្រះនាងមល្លិកាទេវី លុះចូលទៅដល់ហើយ ក៏ក្រាបទូលនូវពាក្យដែលខ្លួនបាននិយាយ ជាមួយនឹងព្រះមានបុណ្យ ដល់ព្រះនាងមល្លិកាទេវីដោយសព្វគ្រប់ ។ គ្រានោះ ព្រះនាងមល្លិកាទេវី ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ ក៏ក្រាបទូលសួរព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច រាជកុមារីព្រះនាមវជិរី ព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលតបថា អើមល្លិកា វជិរីកុមារី អញស្រឡាញ់ ។ នាងមល្លិកាទូលសួរថា បពិត្រមហារាជ ព្រះអង្គសំគាល់សេចក្តីនោះដូចម្តេច (បើ) វជិរីកុមារី ប្រែប្រួល ព្រាត់ប្រាសចាកទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលតបថា អើមល្លិកា (បើ) នាងវជិរីកុមារី ប្រែប្រួល ព្រាត់ប្រាសចាកទៅ សូម្បីជីវិតរបស់អញ ក៏ប្រែ

អញ្ញថត្តំ កឹ បន មេ ន ឧប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឯវំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។

(៣០៨) តំ កឹ មញ្ញសិ មហារាជ បិយា តេ វាសភខត្តិយាតិ ។ ឯវំ មល្លិកេ បិយា មេ វាសភខត្តិយាតិ ។ តំ កឹ មញ្ញសិ មហារាជ វាសភាយ តេ ខត្តិយាយ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ វាសភាយ មេ មល្លិកេ ខត្តិយាយ វិបរិណាមញ្ញថាភាវា ជីវិតស្សាបិ សិយា អញ្ញថត្តំ កឹ បន



ជាទីដ៏វិបត្តិប្រែប្រួលទៅដែរ ចំណាន់បើសេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងមានកើតឡើងដល់អញ ឯណាកំបាន ។ ព្រះនាងមល្លិកាពេលទៅទូលថា បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសំដែងថា សេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ។

(៣០៨) បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះថាដូចម្ដេច នាងវាសភខត្តិយា តើព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ អើមល្លិកា នាងវាសភខត្តិយា អញស្រឡាញ់ ។ បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះថាដូចម្ដេច (បើ) នាងវាសភខត្តិយា ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ តើសេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា (បើ) នាងវាសភខត្តិយា ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជាទីដ៏វិបត្តិប្រែប្រួលទៅដែរ ចំណាន់បើ

យេ ន ឧប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឯវំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។

(៣០៦) តំ កឹ មញ្ញសិ មហារាជ បិយោ តេ វិឌូឌភោ(១) សេនាបតីតិ ។ ឯវំ ភន្តេ បិយោ មេ វិឌូឌភោ សេនាបតីតិ ។ តំ កឹ មញ្ញសិ មហារាជ វិឌូឌភស្ស តេ សេនាបតិស្ស វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ វិឌូឌភស្ស មេ ភន្តេ សេនាបតិស្ស វិបរិណាមញ្ញថាភាវា ជីវិតស្សបិ សិយា អញ្ញថត្តំ កឹ បន មេ ន ឧប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ

១ វិឌូឌភោតិបិ បាឋោ ទិស្សតិ ។



សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត មិនមានកើតឡើងដល់អញឯណាកំពុង ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយ បានជាសំដែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត កែងកើតអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

(៣០៦) បពិត្រព្រះមហារាជ ព្រះអង្គសំគាល់នូវសេចក្តីនោះថាដូចម្តេច វិឌូឌភសេនាបតី តើព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ អើមល្លិកា វិឌូឌភសេនាបតី អញស្រឡាញ់ ។ បពិត្រព្រះមហារាជ ព្រះអង្គសំគាល់នូវសេចក្តីនោះថាដូចម្តេច បើវិឌូឌភសេនាបតី ប្រែប្រួល ព្រាត់ប្រាសនិកសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា(បើ) វិឌូឌភសេនាបតី ប្រែប្រួល ព្រាត់ប្រាសនិកសទៅ សូម្បីជីវិតរបស់អញ ក៏គួរជានឹងវិបត្តិប្រែប្រួលទៅដូចគ្នា ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត មិនមានកើតដល់អញ ឯណាកំពុង ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយ

ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុ-
បាយាសា បិយប្បភវិកាតិ ។

(៣០៧) តំ កិំ មញ្ញសិ មហារាជ បិយា តេ អហន្តិ ។ ឯវំ ភន្តេ បិយា មេ ត្វន្តិ ។ តំ កិំ មញ្ញសិ មហារាជ មយ្ហំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ តុយ្ហញ្ហិ មេ ភន្តេ វិបរិណាមញ្ញថាភាវា ជីវិតស្សបិ សិយា អញ្ញថត្តំ កិំ បន មេ ន ឧប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។



បានជាសំដែងថា សេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត កែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ។

(៣០៧) បពិត្រព្រះមហារាជ ព្រះអង្គសំគាល់នូវសេចក្ដីនោះជាដូចម្ដេច ចុះខ្ញុំម្ចាស់ តើព្រះអង្គសព្វព្រះរាជហឫទ័យដែរឬ ។ មល្លិកា ឯងក៏ជាទីស្រឡាញ់របស់អញដែរ ។ បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្ដីនោះជាដូចម្ដេច បើខ្ញុំម្ចាស់ប្រែប្រួល ព្រាត់ប្រាសនិកសទៅ តើសេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ម្នាលមល្លិកា (បើ) ឯងប្រែប្រួល ព្រាត់ប្រាសនិកសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងប្រែប្រួលទៅដែរ ចំណង់បើសេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត នឹងខានកើតឡើងដល់អញឯណាកើតបាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសំដែងថា សេចក្ដីសោក ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត សេចក្ដីចង្អៀតចង្អល់ចិត្ត កែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ។

[១០៨] តំ កិំ មញ្ញសិ មហារាជ បិយា តេ កាសិកោសលាតិ ។ ឯវំ ភន្តេ បិយា មេ កាសិកោសលា កាសិកោសលានំ ភន្តេ អានុភាវេន កាសិកចន្ទនំ បច្ចនុភោម មាលាគន្ធវិលេបនំ ធារេមាតិ ។ តំ កិំ មញ្ញសិ មហារាជ កាសិកោសលានំ តេ វិបរិណាមញ្ញថាភាវា ឧប្បជ្ជេយ្យុំ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ កាសិកោសលានំ ហិ មេ ភន្តេ វិបរិណាមញ្ញថាភាវា ជីវិតស្សបិ សិយា អញ្ញថត្តំ កិំ បន មេ ន ឧប្បជ្ជិស្សន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសាតិ ។ ឥទំ ខោ តំ មហារាជ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សន្ធាយ ភាសិតំ បិយជាតិកា សោកបរិទេវទុក្ខទោមនស្សុបាយាសា បិយប្បភវិកាតិ ។



(១០៨) បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្តីនោះថាដូចម្តេច ដែនកាសីនឹងដែនកោសល តើព្រះអង្គស្រឡាញ់ឬទេ ។ នែមល្លិកា ដែនកាសីនឹងដែនកោសល ជាទីស្រឡាញ់របស់អញ ម្នាលមល្លិកា (ព្រោះ) យើងប្រើប្រាស់ខ្លឹមចន្ទន៍ដែលបានមកអំពីដែនកាសី ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូបនឹងគ្រឿងលាបផ្សេងៗ ដោយអានុភាពនៃដែនកាសីនឹងដែនកោសល ។ បពិត្រព្រះមហារាជ ព្រះអង្គសំគាល់សេចក្តីនោះថាដូចម្តេច (បើ) ដែនកាសីនឹងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តនឹងកើតឡើងដល់ព្រះអង្គឬទេ ។ នែមល្លិកា បើដែនកាសីនឹងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ សូម្បីជីវិតរបស់អញ គង់នឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តនឹងខានកើតដល់អញឯណាបាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយ បានត្រាស់ថែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត កើតឡើងមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

(៣០៩) អច្ឆរិយំ មល្លិកេ អព្ភុតំ មល្លិកេ យាវញ្ច សោ ភគវា បញ្ញាយ អតិវិជ្ឈ មញ្ញេ បស្សតិ ឯហិ មល្លិកេ អាចមេហីតិ ។ អថខោ រាជា បសេនទិ កោសលោ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា តិក្ខត្តុំ ឧទានំ ឧទានេសិ

ន មោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
ន មោ តស្ស ។ បេ ។ សម្មាសម្ពុទ្ធស្សាតិ ។

បិយជាតិកសុត្តំ សត្តមំ និដ្ឋិតំ ។

---



(៣០៩) ព្រះបាទបសេនទិកោសលមានព្រះរាជឱង្ការថា អស្ចារ្យណាស់ មល្លិកា ចំឡែកណាស់ មល្លិកា ព្រោះព្រះមានព្រះភាគអង្គនោះ ប្រហែលជាទ្រង់ត្រាស់ដឹង ឃើញច្បាស់ដោយប្រាជ្ញាមែន ម្នាលមល្លិកា នាងចូរមកគាយ ចូរនាងឲ្យទឹក សម្រាប់លាងដៃ (ដល់អញ) ។ តពីនោះមក ព្រះបាទបសេនទិកោសល ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងព្រះអង្គម្ខាង ប្រណម្យអញ្ជលី ឆ្ពោះត្រង់ទីព្រះមានព្រះភាគគង់ បន្លឺឧទានអស់វារៈ៣ដងថា

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធអង្គ
នោះ ខ្ញុំសូមថ្វាយបង្គំ ។បេ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ ។

ចប់ បិយជាតិកសូត្រ ជាគំរប់ ៧ ។

# អដ្ឋមំ ពាហិតិយសុត្តំ[១]

[៣១០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន បុព្វារាមោ មិគារមាតុយា[២] បាសាទោ តេនុបសង្កមិ ទិវាវិហារាយ ។

[៣១១] តេន ខោ បន សមយេន រាជា បសេនទិ កោសលោ ឯកបុណ្ឌរីកំ នាគំ អភិរុហិត្វា សាវត្ថិយា និយ្យាតិ ទិវាទិវស្ស ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ អាយស្មន្តំ អានន្ទំ ទូរតោវ អាគច្ឆន្តំ ទិស្វា[៣] សិរិវឌ្ឍំ មហាមត្តំ អាមន្តេសិ អាយស្មា នោ ឯសោ សម្ម សិរិវឌ្ឍ អានន្ទោតិ ។ ឯវំ មហារាជ អាយស្មា ឯសោ អានន្ទោតិ ។

១ ឱ. ម. ពាហិតិកសុត្តំ ។ ២ ឱ. ម. មិគារមាតុ ។ ៣ ឱ. ទិស្វាន ។

# ពាហិតិយសូត្រ ទី ៨

(៣១០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ដល់ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅឯប្រាសាទ ឈ្មោះបុព្វារាម ជារបស់មិគារមាតា ដើម្បីទៅសម្រាកក្នុងវេលាថ្ងៃ ។

(៣១១) សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់ឡើងគង់ព្រះទីនាំងនាគេន្ទ្រ ឈ្មោះ ឯកបុណ្ឌរីកៈ បរទៅក្នុងក្រុងសាវត្ថី ទាំងថ្ងៃ ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញព្រះអានន្ទមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយទ្រង់ត្រាស់ទៅនឹងមហាមាត្រឈ្មោះសិរិវឌ្ឍៈថា ម្នាលសិរិវឌ្ឍៈសំឡាញ់ នុ៎ះព្រះអានន្ទមានអាយុរបស់យើងឬ ។ សិរិវឌ្ឍៈមហាមាត្រ ក្រាបបង្គំទូលថា ព្រះករុណាវិសេសមហាពរ នុ៎ះហើយព្រះអានន្ទមានអាយុ ។

រជទោ រាជា បសេនទិ កោសលោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេនាយស្មា អានន្ទោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទាហិ រាជា ភន្តេ បសេនទិ កោសលោ អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សចេ កិរ ភន្តេ អាយស្មតោ អានន្ទស្ស ន កិញ្ចិ អច្ចាយិកំ ករណីយំ អាគមេតុ កិរ ភន្តេ(១) អានន្ទោ មុហុត្តំ អនុកម្បំ ឧបាទាយាតិ ។ ឯវំ ទេវាតិ ខោ សោ បុរិសោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុត្វា យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ បុរិសោ អាយស្មន្តំ អានន្ទំ ឯតទវោច រាជា ភន្តេ បសេនទិ កោសលោ អាយស្មតោ អានន្ទស្ស បាទេ សិរសា វន្ទតិ(២) សចេ កិរ ភន្តេ

១ ម. ឧ. ឯត្ថន្តរេ អាយស្មាតិ ទិស្សតិ ។ ២ ម. ឧ. ឯត្ថន្តរេ ឯវញ្ច វទេតិ ទិស្សតិ ។



គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ហៅបុរសម្នាក់មកថា ម្នាលបុរសអើយ ចូរឯងមកណាយ ឯងចូរទៅ ឯព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទ នៃព្រះអានន្ទមានអាយុ ដោយត្បូង តាមពាក្យរបស់អញថា បពិត្រលោកដ៏ចំរើន ព្រះបាទបសេនទិកោសល សូមថ្វាយបង្គំព្រះបាទនៃព្រះអានន្ទមានអាយុ ដោយសិរ្សៈ រួចហើយ ចូរពោលយ៉ាងនេះ តទៅទៀតថា បពិត្រលោកដ៏ចំរើន បើព្រះអានន្ទមិនមានកិច្ចណាមួយ ដែលគួរធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចំរើន សូមព្រះអានន្ទ អនុគ្រោះនិមន្ត មួយភ្លែតសិន ។ បុរសនោះទទួលព្រះរាជឱង្ការព្រះបាទបសេនទិកោសលថា ព្រះករុណាវិសេសព្រះសម្មតិទេព ហើយចូលទៅរកព្រះអានន្ទមានអាយុ ត្រង់កន្លែងដែលលោកគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទមានអាយុដោយគោរព ហើយស្ថិតក្នុងទីដ៏សមគួរ ។ លុះបុរសនោះស្ថិតក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចំរើន ព្រះបាទបសេនទិកោសល សូមថ្វាយបង្គំព្រះបាទ នៃព្រះអានន្ទមានអាយុ ដោយសិរ្សៈ បពិត្រលោក

អាយស្មតោ អានន្ទស្ស ន កិញ្ចិ អច្ចាយិកំ ករណីយំ អាគមេតុ កិរ ភន្តេ អាយស្មា អានន្ទោ មុហុត្តំ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា អានន្ទោ តុណ្ហីភាវេន ។

(៣០៦) អថខោ រាជា បសេនទិ កោសលោ យាវតិកា នាគស្ស ភូមិ នាគេន គន្ត្វា នាគា បច្ចោរោហិត្វា បត្តិកោវ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រាជា បសេនទិ កោសលោ អាយស្មន្តំ អានន្ទំ ឯតទវោច សចេ ភន្តេ អាយស្មតោ អានន្ទស្ស ន កិញ្ចិ អច្ចាយិកំ ករណីយំ សាធុ ភន្តេ អាយស្មា អានន្ទោ យេន អចិរវតិយា នទិយា តីរំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា អានន្ទោ តុណ្ហីភាវេន ។ អថខោ អាយស្មា អានន្ទោ យេន អចិរវតិយា នទិយា តីរំ តេនុបសង្កមិ ឧបសង្កមិត្វា អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ អាសនេ និសីទិ ។



ដំណើរ បើព្រះអានន្ទមានអាយុ មិនមានកិច្ចណាមួយ ដែលត្រូវធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចំរើន សូមព្រះអានន្ទ មានអាយុ អនុគ្រោះនឹងចាំមួយភ្លែតសិន ។ ព្រះអានន្ទមានអាយុ ក៏ទទួលនិមន្ត ដោយតុណ្ហីភាព ។

(៣០៦) គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជដំណើរ ទៅដោយដំរីអស់ទីដែលដំរីគួរទៅបាន ហើយចុះអំពីព្រះទីនាំងដំរី យាងទៅដោយព្រះបាទ ចូលទៅត្រង់ទីដែលព្រះអានន្ទមានអាយុគង់នៅ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទមានអាយុដោយគោរព ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ទ្រង់ត្រាស់ពាក្យនេះ ទៅរកព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចំរើន បើព្រះអានន្ទមានអាយុមិនមានកិច្ចណាមួយដែលគួរធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចំរើន សូមព្រះអានន្ទមានអាយុ អនុគ្រោះនិមន្តទៅកាន់ឆ្នេរស្ទឹងអចិរវតី ។ ព្រះអានន្ទមានអាយុ ក៏ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះអានន្ទមានអាយុនិមន្តចូលទៅឯឆ្នេរស្ទឹងអចិរវតី លុះចូលទៅដល់ហើយ ទៅគង់លើអាសនៈដែលគេក្រាលបម្រុងទុក ក្រោមម្លប់ឈើមួយដើម ។

អថខោ រាជា បសេនទិ កោសលោ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯក-មន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រាជា បសេនទិ កោសលោ អាយស្មន្តំ អានន្ទំ ឯតទវោច ឥធ ភន្តេ អាយស្មា អានន្ទោ ហត្ថត្ថរេ(១) និសីទតូតិ ។ អលំ មហារាជ និសីទ ត្វំ និសិន្នោ អហំ សកេ អាសនេតិ ។ និសីទិ ខោ រាជា បសេនទិ កោសលោ បញ្ញត្តេ អាសនេ ។

(៣១៣) និសជ្ជ ខោ រាជា បសេនទិ កោ-សលោ អាយស្មន្តំ អានន្ទំ ឯតទវោច កិន្នុ ខោ ភន្តេ អានន្ទ សោ ភគវា តថារូបំ កាយស-មាចារំ សមាចរេយ្យ យ្វាស្ស(២) កាយសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។

១. ម. ហត្ថត្ថរេ ។ ២. ម. យ្វាស្ស ។



គ្រានោះឯង ព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជដំណើរទៅដោយព្រះទីនាំងនាគេន្ទ្រ ដរាបដល់ទីដែលគួរជិះទៅបាន ហើយទ្រង់ចុះអំពីព្រះទីនាំងនាគេន្ទ្រ ស្តេចទៅដោយព្រះបាទ ចូលទៅត្រង់ទីដែលព្រះអានន្ទមានអាយុ គង់នៅ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះអានន្ទមានអាយុ ដោយគោរព ហើយគង់នៅ ក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់នៅ ក្នុងទីដ៏សមគួរហើយ ទ្រង់ត្រាស់ពាក្យនេះ ទៅកាន់ព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទ មានអាយុ និមន្តគង់លើកម្រាលដំរីនេះចុះ ។ ព្រះអានន្ទមានអាយុ តបថា ថ្វាយព្រះពរមហារាជ សូមព្រះអង្គគង់ចុះ អាត្មាភាពគង់លើអាសនៈ របស់ខ្លួនបានហើយ ។ ព្រះបាទបសេនទិ-កោសល ទ្រង់គង់លើអាសនៈ ដែលគេក្រាលបម្រុងទុក ។

(៣១៣) លុះព្រះបាទបសេនទិកោសល គង់ស្រេចហើយ ទ្រង់ត្រាស់ពាក្យនេះ នឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន កាយសមាចារ ( ការប្រព្រឹត្តល្អដោយកាយ ) ណា ដែលគួរតែពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសបាន តើព្រះមានព្រះភាគអង្គនោះ ប្រព្រឹត្តកាយសមាចារ មានសភាពដូច្នោះដែរឬទេ ។

ន ខោ មហារាជ សោ ភគវា តថារូបំ កាយសមាចារំ សមាចរេយ្យ យ្វាយំ[១] កាយសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ កឹ បន ភន្តេ អានន្ទ សោ ភគវា តថារូបំ វចីសមាចារំ ។ បេ ។ មនោសមាចារំ សមាចរេយ្យ យ្វាយំ[២] មនោសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ ន ខោ មហារាជ សោ ភគវា តថារូបំ មនោសមាចារំ សមាចរេយ្យ យ្វាយំ មនោសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។

(៣១៤) អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យញ្ហិ មយំ ភន្តេ នាសក្ខិម្ហា[៣] បញ្ហេន បរិបូរេតុំ តំ ភន្តេ អាយស្មតា អានន្ទេន បញ្ហស្ស វេយ្យាករណេន បរិបូរិតំ យេ តេ ភន្តេ ពាលា

១-២ ឱ. ម. យ្វាស្ស ។ ៣ ឱ. នាសក្ខិម្ហ ។



ព្រះអានន្ទតបថា បពិត្រមហារាជ កាយសមាចារណាដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសបាន ព្រះមានព្រះភាគ អង្គនោះ ព្រះអង្គមិនប្រព្រឹត្តកាយសមាចារ មានសភាពដូច្នោះទេ ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះព្រះមានព្រះភាគ អង្គនោះ ព្រះអង្គប្រព្រឹត្តវចីសមាចារ (ការប្រព្រឹត្តល្អដោយវាចា) មានសភាពដូច្នោះដែរឬទេ ។ បេ ។ មនោសមាចារ (ការប្រព្រឹត្តល្អដោយចិត្ត) ណាដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញពោលទោសបាន ព្រះអង្គប្រព្រឹត្តមនោសមាចារ មានសភាពដូច្នោះដែរឬទេ ។ បពិត្រមហារាជ មនោសមាចារណា ដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសបាន ព្រះមានព្រះភាគ អង្គនោះ ព្រះអង្គមិនប្រព្រឹត្តមនោសមាចារ មានសភាពដូច្នោះទេ ។

(៣១៤) ព្រះរាជាត្រាស់ថា បពិត្រលោកដ៏ចំរើន អស្ចារ្យណាស់ បពិត្រលោកដ៏ចំរើន ចំឡែកណាស់ បពិត្រលោកដ៏ចំរើន ព្រោះថាយើងខ្ញុំមិនអាចនឹងបំពេញនូវពាក្យណាដោយប្រស្នាបាន បពិត្រលោកដ៏ចំរើន ពាក្យនោះ ក្រែងតែព្រះអានន្ទមានអាយុ ទើបអាចនឹងបំពេញដោយការដោះស្រាយនូវប្រស្នាបាន បពិត្រលោកដ៏ចំរើន ពួកបុគ្គលពាល

អព្យត្តា អននុវិច្ច អបរិយោគាហេត្វា បរេសំ វណ្ណំ វា អវណ្ណំ វា ភាសន្តិ ន មយន្តំ សារតោ បច្ចាគច្ឆាម ។ យេ ន ខោ តេ ភន្តេ បណ្ឌិតា ព្យត្តា វិយត្តា មេធាវិនោ អនុវិច្ច បរិយោគាហេត្វា បរេសំ វណ្ណំ វា អវណ្ណំ វា ភាសន្តិ តំ មយំ សារតោ បច្ចាគច្ឆាម កតមោ បន ភន្តេ អានន្ទ កាយសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ យោ ខោ មហារាជ កាយសមាចារោ អកុសលោ ។ កតមោ បន ភន្តេ កាយសមាចារោ អកុសលោ ។ យោ ខោ មហារាជ កាយសមាចារោ សាវជ្ជោ ។ កតមោ បន ភន្តេ កាយសមាចារោ សាវជ្ជោ ។ យោ ខោ មហារាជ កាយសមាចារោ សព្យាបជ្ឈោ ។ កតមោ បន ភន្តេ កាយសមាចារោ សព្យាបជ្ឈោ ។ យោ ខោ មហារាជ កាយសមាចារោ ទុក្ខវិបាកោ ។ កតមោ បន ភន្តេ កាយសមាចារោ ទុក្ខវិបាកោ ។ យោ ខោ មហារាជ



ដែលមិនឈ្លាសវៃ មិនបានពិចារណា មិនបានស្ទាបស្ទង់មើលហើយ ពោលនូវគុណនិងទោស របស់បុគ្គលទាំងឡាយដទៃ យើងខ្ញុំមិនប្រកាន់យកពាក្យនោះ (របស់បុគ្គលទាំងឡាយនោះ) ថា មានខ្លឹមសារទេ បពិត្រលោកដ៏ចំរើន បើបុគ្គលណា ឈ្លាស វៃឆ្លាត ជាអ្នកប្រាជ្ញ បានពិចារណា បានស្ទាបស្ទង់មើលហើយ ពោលនូវគុណនិងទោស របស់បុគ្គលទាំងឡាយដទៃ យើងខ្ញុំប្រកាន់យកពាក្យនោះ (របស់បុគ្គលទាំងឡាយនោះ) ថាមានខ្លឹមសារ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញពោលទោសបាន តើដូចម្តេច ។ ព្រះអានន្ទតបថា បពិត្រមហារាជ កាយសមាចារដែលជាអកុសល ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារ ដែលជាអកុសល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារដែលប្រកបដោយទោស ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារ ដែលប្រកបដោយទោសតើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារដែលប្រកបដោយសេចក្តីបៀតបៀន ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារដែលប្រកបដោយសេចក្តីបៀតបៀនតើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារដែលមានសេចក្តីទុក្ខជាផល ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារដែលមានសេចក្តីទុក្ខជាផល តើដូចម្តេច ។ បពិត្រមហារាជ

កាយសមាចារោ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពាធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ តស្ស អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ ខោ បន(១) មហារាជ កាយសមាចារោ គារយ្ហោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ កតមោ បន ភន្តេ អានន្ទ វចីសមាចារោ ។ បេ ។ មនោសមាចារោ គារយ្ហោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ យោ ខោ មហារាជ មនោសមាចារោ អកុសលោ ។ កតមោ បន ភន្តេ មនោសមាចារោ អកុសលោ ។ យោ ខោ មហារាជ មនោសមាចារោ សាវជ្ជោ ។ កតមោ បន ភន្តេ មនោសមាចារោ សាវជ្ជោ ។ យោ ខោ មហារាជ មនោសមាចារោ សព្យាបជ្ឈោ ។ កតមោ បន ភន្តេ មនោសមាចារោ សព្យាបជ្ឈោ ។ យោ ខោ មហារាជ មនោសមាចារោ ទុក្ខវិបាកោ ។ កតមោ បន ភន្តេ មនោសមាចារោ ទុក្ខវិបាកោ ។ យោ ខោ មហារាជ

១ ម. ឯវរូបោ ខោ ។



កាយសមាចារណា ប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរគឺខ្លួនឯងនិងបុគ្គលដទៃផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ រមែងចំរើន កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ បពិត្រមហារាជ កាយសមាចារ មានសភាពដូច្នេះ ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញពោលទោសបាន ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះវចីសមាចារ ។ បេ ។ មនោសមាចារដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញពោលទោសបានតើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារជាអកុសល ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះមនោសមាចារជាអកុសលតើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលប្រកបដោយទោស ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះមនោសមាចារ ដែលប្រកបដោយទោសតើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលប្រកបដោយសេចក្តីបៀតបៀន ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះមនោសមាចារដែលប្រកបដោយសេចក្តីបៀតបៀនតើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលមានសេចក្តីទុក្ខជាផល ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះមនោសមាចារដែលមានសេចក្តីទុក្ខជាផល តើដូចម្តេច ។ បពិត្រមហារាជ

មនោសមាចារោ អត្តព្យាពាធាយបិ សំវត្តតិ បរព្យាពា-ធាយបិ សំវត្តតិ ឧភយព្យាពាធាយបិ សំវត្តតិ តស្ស អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ ខោ មហារាជ មនោសមាចារោ ឱបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។

(១១៩) កិន្នុ ខោ ភន្តេ អានន្ទ សោ ភគវា សព្វេសំយេវ អកុសលានំ ធម្មានំ បហានំ វណ្ណេតីតិ ។ សព្វាកុសលធម្មបហីនោ ខោ មហារាជ តថាគតោ កុសលធម្មសមន្នាគតោ(១) ។ កតមោ បន ភន្តេ អានន្ទ កាយសមាចារោ អនុបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ យោ ខោ មហារាជ កាយសមាចារោ កុសលោ ។ កតមោ បន ភន្តេ កាយសមាចារោ កុសលោ ។ យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ ។

១. ម. កិលេសោ វិស្សតិ ។



មនោសមាចារណា ប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ រមែងចំរើនឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ បពិត្រមហារាជ មនោ-សមាចារ មានសភាពដូច្នោះឯង ដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសបាន ។

(១១៩) ព្រះរាជាត្រាស់ថា បពិត្រព្រះអានន្ទដ៏ចំរើន ចុះព្រះមានព្រះភាគអង្គនោះ ទ្រង់តែពោលសរសើរនូវការលះបង់នូវអកុសល-ធម៌ទាំងឡាយទាំងអស់តែម្យ៉ាងឬ ។ ព្រះអានន្ទទូលថា បពិត្រមហារាជ ព្រះតថាគតទ្រង់លះបង់ នូវអកុសលធម៌ទាំងឡាយទាំងអស់ហើយ ទ្រង់ប្រកបដោយកុសលធម៌តែម្យ៉ាង ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារ ដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញពោលទោសមិនបាន តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារជាកុសល ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះកាយសមាចារជាកុសល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមិនមានទោស ។

កតមោ បន កាយសមាចារោ អនវជ្ជោ ។ យោ ខោ មហារាជ កាយសមាចារោ អព្យាបជ្ជោ ។ កតមោ បន ភន្តេ កាយសមាចារោ អព្យាបជ្ជោ ។ យោ ខោ មហារាជ កាយសមាចារោ សុខវិបាកោ ។ កតមោ បន ភន្តេ កាយសមាចារោ សុខវិបាកោ ។ យោ ខោ មហារាជ កាយសមាចារោ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ តស្ស អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ ខោ មហារាជ កាយសមាចារោ អនោបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ កតមោ បន ភន្តេ វចីសមាចារោ ។ បេ ។ មនោសមាចារោ អនោបារម្ភោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ យោ ខោ មហារាជ មនោសមាចារោ កុសលោ ។ កតមោ បន ភន្តេ មនោសមាចារោ កុសលោ ។ យោ ខោ មហារាជ មនោសមាចារោ អនវជ្ជោ ។ កតមោ បន ភន្តេ មនោសមាចារោ អនវជ្ជោ ។ យោ ខោ មហារាជ មនោសមាចារោ



បពិត្រលោកដ៏ចំរើន ចុះកាយសមាចារ មិនមានទោស តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារ មិនមានសេចក្តីបៀតបៀន ។ បពិត្រលោកដ៏ចំរើន ចុះកាយសមាចារ មិនមានសេចក្តីបៀតបៀន តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមានសេចក្តីសុខជាផល ។ បពិត្រលោកដ៏ចំរើន ចុះកាយសមាចារមានសេចក្តីសុខជាផល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ រមែងចំរើនឡើង បពិត្រមហារាជ កាយសមាចារមានសភាពដូច្នេះឯង ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសមិនបាន ។ បពិត្រព្រះអានន្ទដ៏ចំរើន ចុះវចីសមាចារ ។ បេ ។ មនោសមាចារ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសមិនបាន តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារជាកុសល ។ បពិត្រលោកដ៏ចំរើន ចុះមនោសមាចារជាកុសល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ មិនមានទោស ។ បពិត្រលោកដ៏ចំរើន មនោសមាចារ មិនមានទោស តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ

អព្យាបជ្ឈោ ។ កតមោ បន ភន្តេ មនោសមាចារោ អព្យាបជ្ឈោ ។ យោ ខោ មហារាជ មនោសមាចារោ សុខុទ្រយោ ។ កតមោ បន ភន្តេ មនោសមាចារោ សុខុទ្រយោ ។ យោ ខោ មហារាជ មនោសមាចារោ នេវត្តព្យាពាធាយបិ សំវត្តតិ ន បរព្យាពាធាយបិ សំវត្តតិ ន ឧភយព្យាពាធាយបិ សំវត្តតិ តស្ស អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ ខោ មហារាជ មនោសមាចារោ អននុវជ្ជោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។

(៣១៦) កិន្នុ ខោ បន(១) ភន្តេ អានន្ទ សោ ភគវា សព្វេសំយេវ កុសលានំ ធម្មានំ ឧបសម្បទំ វណ្ណេតីតិ ។ សព្វាកុសលធម្មបហីនោ ខោ មហារាជ តថាគតោ កុសលធម្មសមន្នាគតោតិ ។

១ ឱ. ម. កិំ បនាតិ ទិស្សតិ ។



មិនមានសេចក្តីបៀតបៀន ។ បពិត្រលោកដ៏ចំរើន ចុះមនោសមាចារ មិនមានសេចក្តីបៀតបៀន តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ មានសេចក្តីសុខជាផល ។ បពិត្រលោកដ៏ចំរើន ចុះមនោសមាចារ មានសេចក្តីសុខជាផល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំងពីរផង អកុសលធម៌ទាំងឡាយរបស់បុគ្គលនោះ រមែងសាបសូន្យ កុសលធម៌ទាំងឡាយ រមែងចំរើនឡើង បពិត្រមហារាជ មនោសមាចារ មានសភាពដូច្នេះឯង ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសមិនបាន ។

(៣១៦) ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអានន្ទដ៏ចំរើន ចុះព្រះមានព្រះភាគ អង្គនោះ គ្រាន់តែពោលសរសើរនូវការបំពេញកុសលធម៌ទាំងអស់ តែម្យ៉ាងឬ ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ ព្រះតថាគតទ្រង់លះបង់នូវអកុសលធម៌ទាំងអស់ ហើយទ្រង់ប្រកបដោយកុសលធម៌តែម្យ៉ាង ។

[៣១៧] អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវ សុភាសិតញ្ចិទំ ភន្តេ អាយស្មតា អានន្ទេន ឥមិនា ច មយំ ភន្តេ អាយស្មតោ អានន្ទស្ស សុភាសិតេន អត្តមនាភិរទ្ធា ឯវំ អត្តមនាភិរទ្ធា(១) មយំ ភន្តេ អាយស្មតោ អានន្ទស្ស សុភាសិតេន សចេ ភន្តេ អាយស្មតោ អានន្ទស្ស ហត្ថិរតនំ កប្បេយ្យ ហត្ថិរតនម្បិ មយំ អាយស្មតោ អានន្ទស្ស ទទេយ្យាម សចេ ភន្តេ អាយស្មតោ អានន្ទស្ស អស្សរតនំ កប្បេយ្យ អស្សរតនម្បិ មយំ អាយស្មតោ អានន្ទស្ស ទទេយ្យាម សចេ ភន្តេ អាយស្មតោ អានន្ទស្ស គាមវរំ កប្បេយ្យ គាមវរម្បិ មយំ អាយស្មតោ អានន្ទស្ស ទទេយ្យាម អបិច ភន្តេ មយម្បេតំ(២) ជានាម នេតំ អាយស្មតោ អានន្ទស្ស កប្បតីតិ អយំ មេ ភន្តេ ពាហិតិកា រញ្ញា មាគធេន អជាតសត្តុនា វេទេហិបុត្តេន ឆត្តនាឡិយា(៣) បក្ខិបិត្វា បហិតា សោឡសសមា អាយាមេន អដ្ឋសមា វិត្ថារេន តំ ភន្តេ

១ ឱ. ម. ឯវត្តមនា ចសេទ្ធា ទិស្សតិ ។ ២ ឱ. មយម្បេតំ ។ ម. មយ នេតំ ។ ៣ ម. វត្ថនាឡិយា ។



[៣១៧] បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះពេញជាសុភាសិតដែលព្រះអានន្ទមានអាយុពោលហើយ បពិត្រព្រះអង្គដ៏ចំរើន ម្យ៉ាងទៀត យើងខ្ញុំជាអ្នកត្រេកអរពេញចិត្ត ដោយសុភាសិតរបស់ព្រះអានន្ទមានអាយុនេះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន លុះយើងខ្ញុំជាអ្នកត្រេកអរពេញចិត្ត ដោយសុភាសិតរបស់ព្រះអានន្ទមានអាយុ យ៉ាងនេះហើយ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើ ហត្ថិរតនៈ គួរដល់ព្រះអានន្ទមានអាយុ យើងខ្ញុំនឹងប្រគេនហត្ថិរតនៈ ដល់ព្រះអានន្ទមានអាយុ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើ អស្សរតនៈ គួរដល់ព្រះអានន្ទមានអាយុ យើងខ្ញុំនឹងប្រគេនអស្សរតនៈ ដល់ព្រះអានន្ទមានអាយុ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើ ស្រុកសួយ គួរដល់ព្រះអានន្ទមានអាយុ យើងខ្ញុំនឹងប្រគេនស្រុកសួយ ដល់ព្រះអានន្ទមានអាយុ បពិត្រព្រះអង្គដ៏ចំរើន ប៉ុន្តែយើងខ្ញុំ ដឹងច្បាស់ហេតុនេះថា វត្ថុមានហត្ថិរតនៈជាដើមនេះ មិនគួរដល់ព្រះអានន្ទមានអាយុទេ បពិត្រព្រះអង្គដ៏ចំរើន មានតែសំពត់ពាហិតិកា(១)របស់ខ្ញុំនេះ មានបណ្តោយ ១៦ ហត្ថ ទទឹង ៨ ហត្ថ ដែលព្រះបាទមាគធអជាតសត្តុវេទេហិបុត្ត ដាក់ក្នុងស្រោមព្រួញហើយផ្ញើមកឲ្យខ្ញុំ បពិត្រព្រះអង្គដ៏ចំរើន

១ សំពត់ដែលកើតក្នុងដែនឈ្មោះពាហិតិ ។ អដ្ឋកថា ។

អាយស្មា អានន្ទោ បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ អលំ មហារាជ បរិបុណ្ណំ មេ តិចីវរន្តិ ។

[៣១៨] អយំ ភន្តេ អចិរវតី នទី ទិដ្ឋា អាយស្មតា ចេវ អានន្ទេន អម្ហេហិ ច យទា ឧបរិ បព្វតេ មហាមេឃោ អភិប្បវុដ្ឋោ ហោតិ អថាយំ អចិរវតី នទី ឧភតោ កុល្លានិ(១) សំវិសន្ទន្តី គច្ឆតិ ឯវមេវ ខោ ភន្តេ អាយស្មា អានន្ទោ ឥមាយ ពាហិតិកាយ អត្តនោ តិចីវរំ ករិស្សតិ យំ បន(២) អាយស្មតោ អានន្ទស្ស បុរាណំ តិចីវរំ តំ សព្រហ្មចារីហិ សំវិភជិស្សតិ ឯវាយំ អម្ហាកំ ទក្ខិណា សំវិសន្ទន្តី មញ្ញេ គមិស្សតិ បដិគ្គណ្ហាតុ ភន្តេ អាយស្មា អានន្ទោ ពាហិតិកន្តិ ។ បដិគ្គហេសិ ខោ អាយស្មា អានន្ទោ ពាហិតិកំ ។ អថខោ រាជា បសេនទិ កោសលោ អាយស្មន្តំ អានន្ទំ ឯតទវោច ហន្ទ ចទានិ(៣) មយំ ភន្តេ អានន្ទ គច្ឆាម ពហុកិច្ចា មយំ

១ ឱ. កូលានិ ។ ២ ម. តិចីវរន្នាមេ អត្តនោតិ ទិស្សតិ ។ ៣ ឱ. ហ ម. ចទ ។



សូមព្រះអានន្ទមានអាយុ ទទួលយកនូវសំពត់នោះ ដើម្បីសេចក្ដីអនុគ្រោះដល់ខ្ញុំ ។ ព្រះអានន្ទតបថា ថ្វាយព្រះពរមហារាជ ត្រៃចីវររបស់អាត្មាភាពគ្រប់គ្រាន់ហើយ ។

[៣១៨] ព្រះរាជាត្រាស់ថា បពិត្រលោកដ៏ចំរើន ស្ទឹងអចិរវតីនេះ ព្រះអានន្ទមានអាយុក្ដី យើងខ្ញុំក្ដី បានឃើញស្រាប់ហើយ មហាមេឃ ដែលបង្អុរភ្លៀងធំចុះមកខាងលើភ្នំ កាលបើយ៉ាងនេះ ស្ទឹងអចិរវតីនេះ ក៏នឹងហូរហៀរលើកទៅកាន់មាត់ច្រាំងទាំងពីរខាង យ៉ាងណាមិញ បពិត្រលោកដ៏ចំរើន ព្រះអានន្ទមានអាយុ នឹងធ្វើនូវត្រៃចីវររបស់ខ្លួន ដោយសំពត់ពាហិតិកានេះ ចំណែកត្រៃចីវរណា ដែលជាចីវរចាស់របស់ព្រះអានន្ទមានអាយុ ព្រះអានន្ទ នឹងចែករំលែកត្រៃចីវរចាស់នោះ ឲ្យដល់ពួកសព្រហ្មចារី ក៏យ៉ាងនោះដែរ កាលបើមានការណ៍យ៉ាងនេះ ទក្ខិណាទានរបស់យើងខ្ញុំនេះ ទំនងជានឹងហូរហៀរទៅបាន បពិត្រលោកម្ចាស់ដ៏ចំរើន សូមព្រះអានន្ទមានអាយុ ទទួលយកនូវសំពត់ពាហិតិកាចុះ ។ ព្រះអានន្ទមានអាយុ ក៏ទទួលយកសំពត់ពាហិតិកា ។ លំដាប់នោះ ព្រះបាទបសេនទិកោសល បានត្រាស់ពាក្យនេះ នឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចំរើន យើងខ្ញុំសូមលាទៅឥឡូវនេះហើយ ព្រោះយើងខ្ញុំមានកិច្ចច្រើន

ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ កាលំ មញ្ញសីតិ ។ អថខោ រាជា បសេនទិ កោសលោ អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទិត្វា(១) ឧដ្ឋាយាសនា អាយស្មន្តំ អានន្ទំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[៣១៩] អថខោ អាយស្មា អានន្ទោ អចិរបក្កន្តស្ស(២) បសេនទិស្ស កោសលស្ស យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ យាវតកោ អហោសិ រញ្ញា បសេនទិនា កោសលេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ តញ្ច ពាហិតិកំ ភគវតោ អទាសិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ

១ ឱ. ម. អភិនន្ទិត្វា អនុមោទិត្វាតិ ទិស្សតិ ។ ២ ឱ. ម. អចិរបក្កន្តេ រញ្ញោតិ ទិស្សតិ ។



មានការងារច្រើន ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ សូមមហាបពិត្រ សំគាល់កាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រេកអរទទួលភាសិត របស់ព្រះអានន្ទដ៏មានអាយុ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះអានន្ទមានអាយុដោយគោរព ធ្វើប្រទក្សិណរួចចៀសចេញទៅ ។

(៣១៩) គ្រាកាលដែលព្រះបាទបសេនទិកោសល ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលកថាសល្លាបៈ ដែលលោកបានជាមួយនឹងព្រះបាទបសេនទិកោសលតាំងប៉ុន្មាន ដល់ព្រះមានព្រះភាគទាំងអស់ រួចថ្វាយសំពត់ពាហិតិកានោះ ទៅព្រះមានព្រះភាគ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា

ភវវគ្គស្ស កាឡិគិយសុត្តំ អានន្ទទស្សនលាភោ

លាភា ភិក្ខវេ រញ្ញោ បសេនទិស្ស កោសលស្ស សុលទ្ធំ ភិក្ខវេ រញ្ញោ បសេនទិស្ស កោសលស្ស យំ រាជា បសេនទិ កោសលោ លភតិ អានន្ទំ ទស្សនាយ លភតិ បយិរុបាសនាយាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កាឡិគិយសុត្តំ អដ្ឋមំ និដ្ឋិតំ ។

---



ភវវគ្គ កាឡិគិយសូត្រ ការបានឃើញព្រះអានន្ទ

ម្នាលភិក្ខុទាំងឡាយ ព្រះបាទបសេនទិកោសល ឈ្មោះថាមានលាភហើយ ម្នាលភិក្ខុទាំងឡាយ អត្តភាពជាមនុស្ស ព្រះបាទបសេនទិ-កោសល ឈ្មោះថា បានដោយប្រពៃហើយ ព្រោះហេតុដែលព្រះបាទបសេនទិកោសល ទ្រង់បានជួបអានន្ទ ទ្រង់បានចូលទៅជិតអានន្ទ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយមានចិត្តត្រេកអរ រីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ កាឡិគិយសូត្រ ទី៨ ។

---

## នវមំ ធម្មចេតិយសុត្តំ

(៣៦០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ មេទឡុម្បំ(១) នាម សក្យានំ និគមោ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ នគរកំ(២) អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។ អថខោ រាជា បសេនទិ កោសលោ ទីឃំ ការាយនំ អាមន្តេសិ យោជេហិ សម្ម ការាយន ភទ្រានិ ភទ្រានិ យានានិ ឧយ្យានភូមឹ(៣) គច្ឆាម សុភូមឹ ទស្សនាយាតិ ។ ឯវំ ទេវាតិ ខោ ទីឃោ ការាយនោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុត្វា ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា រញ្ញោ បសេនទិស្ស កោសលស្ស បដិវេទេសិ យុត្តានិ ខោ តេ ទេវ ភទ្រានិ ភទ្រានិ យានានិ យស្សទានិ កាលំ មញ្ញសីតិ ។

១ ឱ. មេទឡុម្បំ ។ ២ ឱ. នង្គរកំ ។ ៣ ឱ. ម. ឧយ្យានភូមឹ ។

## ធម្មចេតិយសូត្រ ទី ៩

(៣៦០) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមេទឡុម្បនិគម(១)របស់ពួកសក្យៈ ក្នុងសក្កជនបទ ។ សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់បានមកដល់នគរកៈដោយកិច្ចនីមួយ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់បង្គាប់នាមាត្យឈ្មោះទីឃការាយនៈថា ម្នាលការាយនៈសំឡាញ់ អ្នកចូរទឹមយានល្អៗ យើងនឹងទៅកាន់ទីឧទ្យាន ដើម្បីមើលទីដែលល្អ ។ ទីឃការាយនាមាត្យ ទទួលព្រះរាជឱង្ការ របស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយប្រើឲ្យគេទឹមយានល្អៗ ស្រេចហើយក្រាបបង្គំទូលព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព យានល្អៗ បានទឹមរួចស្រេចហើយ សូមព្រះអង្គសំគាល់កាលគួរសម ក្នុងកាលឥឡូវនេះ ។

១ អដ្ឋកថាពន្យល់ថា បាននិគមឈ្មោះថា មេទឡុម្បៈខ្លះ ព្រោះនិគមនោះ មានដើមឈើដូចឫស្សីកាំ ១ ស្លឹកខ្លាញ់ចង ។

(៣៦១) អថ ខោ រាជា បសេនទិ កោសលោ ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ នគរកម្ហា[១] និយ្យាសិ មហច្ចរាជានុភាវេន យេន អារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ អារាមំ បាវិសិ ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ អារាមេ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ រុក្ខមូលានិ បាសាទិកានិ បសាទនីយានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហស្សេយ្យកានិ បដិសល្លានសារុប្បានិ ទិស្វាន ភគវន្តំយេវ អារព្ភ សតិ ឧទបាទិ ឥមានិ ខោ តានិ រុក្ខមូលានិ បាសាទិកានិ បសាទនីយានិ អប្បសទ្ទានិ អប្បនិគ្ឃោសានិ វិជនវាតានិ មនុស្សរាហស្សេយ្យកានិ បដិសល្លានសារុប្បានិ យត្ថ សុទំ មយំ តំ ភគវន្តំ បយិរុបាសាម អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អថ ខោ រាជា បសេនទិ កោសលោ ទីឃំ ការាយនំ អាមន្តេសិ ឥមានិ ខោ សម្ម ការាយន តានិ រុក្ខមូលានិ

១. នង្គរកម្ហា ។



(៣៦១) លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ឡើងកាន់យានដ៏ល្អ ទ្រង់ព្រះរាជដំណើរទៅដោយយានល្អ ៗ ឆ្ពោះទៅកាន់សួនច្បារដោយអានុភាពជាស្តេចធំ ស្តេចទៅដោយយាន ដរាបដល់ទីដែលគួរបរយាននៅបាន ទើបទ្រង់ចុះអំពីយាន ស្តេចទៅដោយព្រះបាទចូលទៅកាន់សួនច្បារ ។ ព្រះបាទបសេនទិកោសល ទ្រង់យាងចង្ក្រមទៅមកក្នុងសួនច្បារបន្តិច ដើម្បីសម្រាកព្រះជង្ឃា បានទតឃើញម្លប់ឈើទាំងឡាយ គាប់គួរជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិច ៗ ឥតមានសំឡេងគឹកកង ប្រាសចាកខ្យល់បក់មក អំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ លុះឃើញហើយក៏មានសតិកើតឡើង ប្រារព្ធចំពោះព្រះមានព្រះភាគថា ម្លប់ឈើទាំងនេះ គាប់គួរជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិច ៗ ឥតមានសំឡេងគឹកកង ប្រាសចាកខ្យល់បក់មក អំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់ នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ ដូចជាទីដែលយើងធ្លាប់ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះដែរ ។ ទើបព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ទៅនឹងទីឃការាយនាមាត្យថា ម្នាលការាយនៈសំឡាញ់ ម្លប់ឈើ

ពាសាទិកានិ បាសាទនីយានិ អប្បសទ្ទានិ អប្ប-និគ្ឃោសានិ វិជនវាតានិ មនុស្សរាហស្សេយ្យកានិ បដិសល្លានសារុប្បានិ យត្ថ សុទំ មយំ តំ ភគវន្តំ បយិរុបាសាម អរហន្តំ សម្មាសម្ពុទ្ធំ កហំ នុ ខោ សម្ម ការាយន ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ អត្ថិ មហារាជ មេទឡុម្បំ នាម សក្យានំ និគមោ តត្ថ សោ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ កីវទូរេ(១) បន សម្ម ការាយន នគរកម្ហា មេទឡុម្បំ នាម សក្យានំ និគមោ ហោតីតិ ។ ន ទូរេ មហារាជ តីណិ យោជនានិ សក្កា ទិវាវសេសេន គន្តុំ ។ តេនហិ សម្ម ការាយន យោជេហិ ភទ្រានិ ភទ្រានិ យានានិ គមិស្សាម មយំ តំ ភគវន្តំ ទស្សនាយ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯវំ ទេវាតិ ខោ ការាយនោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុត្វា ភទ្រានិ ភទ្រានិ យានានិ យោជាបេត្វា រញ្ញោ បសេនទិស្ស កោសលស្ស បដិវេទេសិ

១ ម. កីវទូរោ ។



ពាំងឡាយនេះនាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិច ។ ឥតមានសំឡេងកងរំពង ប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ ដូចជាទីដែលយើងធ្លាប់ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធដែរ ម្នាលការាយនៈសំឡាញ់ ចុះឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គគង់ក្នុងទីណា ។ ទីឃការាយនាមាត្យក្រាបបង្គំទូលថា បពិត្រមហារាជ ឥឡូវនេះ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ គង់នៅក្នុងមេទឡុម្បនិគមរបស់ពួកសក្យៈ ។ ព្រះរាជាត្រាស់ថា ម្នាលការាយនៈសំឡាញ់ ចុះមេទឡុម្បនិគមរបស់ពួកសក្យៈនៅអំពីនគរក្បែរនេះទៅតើចម្ងាយប៉ុន្មាន ។ ទីឃការាយនាមាត្យក្រាបបង្គំទូលថា បពិត្រមហារាជ មិនជាឆ្ងាយណាស់ណាទេ ប្រហែលជា ៣ យោជន៍ប៉ុណ្ណោះ ព្រះអង្គអាចស្តេចទៅដល់ មិនពេញមួយថ្ងៃទេ ។ ព្រះរាជាត្រាស់ថា ម្នាលការាយនៈសំឡាញ់ បើដូច្នោះ អ្នកឯងចូរទឹមយានល្អ ៗ យើងនឹងទៅដើម្បីគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មា-សម្ពុទ្ធអង្គនោះ ។ ទីឃការាយនាមាត្យ ទទួលយកព្រះរាជឱង្ការរបស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស រួចប្រើគេឲ្យទឹមយានល្អ ៗ ស្រេចហើយ ក្រាបបង្គំទូលព្រះបាទបសេនទិកោសលថា

យុត្តានិ ខោ តេ ទេវ ភទ្រានិ ភទ្រានិ យានានិ យស្សទានិ កាលំ មញ្ញសីតិ ។

(៣៦៦) អថខោ រាជា បសេនទិ កោសលោ ភទ្រំ យានំ អភិរុហិត្វា ភទ្រេហិ ភទ្រេហិ យានេហិ នគរកម្ហា យេន មេទឡុបំ នាម សក្យានំ និគមោ តេន បាយាសិ តេនេវ ទិវសាវសេសេន មេទឡុបំ នាម សក្យានំ និគមំ សម្បាបុណិ យេន អារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ អារាមំ បាវិសិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថ រាជា បសេនទិ កោសលោ យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កហំ នុ ខោ ភន្តេ ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោ ទស្សនកាមា ហិ មយន្តំ ភគវន្តំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯសោ មហារាជ វិហារោ សំវុតទ្វារោ តេន



បពិត្រព្រះសម្មតិទេព យានល្អៗ បានទឹមបម្រុងព្រះអង្គរួចស្រេចហើយ សូមព្រះអង្គសំគាល់នូវកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។

(៣៦៦) គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ឡើងកាន់យានដ៏ល្អហើយ ស្តេចចេញអំពីនគរក្តួចទៅដោយយានល្អៗ យាងសំដៅទៅក្រុងមេទឡុបនិគមរបស់ពួកសក្យៈ ទៅមិនពេញ ១ ថ្ងៃប៉ុណ្ណោះឯង ក៏បានដល់ទៅមេទឡុបនិគមរបស់ពួកសក្យៈ ហើយឆ្ពោះទៅកាន់សួនច្បារ ទ្រង់យាងទៅដោយយាន ដរាបដល់ទីដែលគួរបរយានទៅបាន ហើយទ្រង់ចុះអំពីយាន ស្តេចទៅដោយព្រះបាទ ចូលទៅកាន់សួនច្បារ ។ សម័យនោះឯង ពួកភិក្ខុច្រើនរូបកំពុងចង្រ្កមក្នុងទីវាល ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ចូលសំដៅទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ មានព្រះរាជឱង្ការនេះទៅកាន់ពួកភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចំរើន ឥឡូវនេះ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គគង់នៅក្នុងទីណា ព្រោះយើងទាំងឡាយ ចង់ចួបនឹងព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ភិក្ខុទាំងនោះថ្វាយព្រះពរថា បពិត្រមហារាជ វិហារនុះបិទទ្វារជិតទៅហើយ ព្រោះហេតុនោះ

អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេហិ វិវរិស្សតិ តេ ភគវា ទ្វារន្តិ ។ អថខោ រាជា បសេនទិ កោសលោ តត្ថេវ ខគ្គញ្ច ឧណ្ហីសញ្ច ទីឃស្ស ការាយនស្ស បាទាសិ ។ អថខោ ទីឃស្ស ការាយនស្ស ឯតទហោសិ រហាយតិ ខោ ទានិ មហារាជា ឥធេវ ទានិ មយា ឋាតព្វន្តិ ។ អថខោ រាជា បសេនទិ កោសលោ យេន សោ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេសិ ។ វិវរិ ភគវា ទ្វារំ ។ អថខោ រាជា បសេនទិ កោសលោ វិហារំ បវិសិត្វា ភគវតោ បាទេសុ សិរសា និបតិត្វា(១) ភគវតោ បាទានិ មុខេន ច បរិចុម្ពតិ បាណីហិ ច បរិសម្ពាហតិ នាមញ្ច សាវេតិ រាជាហំ ភន្តេ បសេនទិ កោសលោ រាជាហំ ភន្តេ បសេនទិ កោសលោតិ ។ កឹ បន ត្វំ មហារាជ

១ ម. បតិត្វា ។



សូមព្រះអង្គធ្វើព្រះសូរសៅតិច ៗ ស្តេចចូលទៅសន្សឹម ៗ លុះចូលទៅដល់របៀង ធ្វើព្រះទកាសិត (ក្រហែម) រួចគោះសន្ទះទ្វារ ព្រះមានព្រះភាគ នឹងបើកទ្វារថ្វាយព្រះអង្គ ។ ទើបព្រះបាទបសេនទិកោសល ទ្រង់ហុចព្រះខាន់និងមកុដឲ្យទៅទីឃការាយនាមាត្យ ក្នុងទីនោះឯង ។ លំដាប់នោះ ទីឃការាយនាមាត្យ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ មហារាជទ្រង់ស្តេចចូលទៅតែមួយព្រះអង្គឯងទេ ឥឡូវនេះ អាត្មាអញនៅចាំក្នុងទីនេះចុះ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅត្រង់វិហារ ដែលមានទ្វារបិទនោះ ធ្វើព្រះសូរសៅតិច ៗ ស្តេចចូលទៅសន្សឹម ៗ លុះចូលទៅដល់របៀងហើយ ក៏ទ្រង់ធ្វើព្រះទកាសិតហើយគោះសន្ទះទ្វារ ។ ព្រះមានព្រះភាគក៏ទ្រង់បើកទ្វារ ។ ទើបព្រះបាទបសេនទិកោសល ចូលទៅកាន់វិហារហើយ ក្រាបចុះទៀបព្រះបាទយុគល នៃព្រះមានព្រះភាគដោយសិរ្សៈផង ទ្រង់ព្រះចុម្ពិត (ផ្ញក់) ព្រះបាទយុគលនៃព្រះមានព្រះភាគដោយព្រះឱស្ឋផង ច្របាច់ដោយព្រះហស្តទាំងឡាយផង ប្រកាសនាមផងថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះបសេនទិកោសល បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះបសេនទិកោសល ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ចុះមហាបពិត្រ

១ ពិស្សស់ក្បែង ស្បៀមយកទៅធ្វើក្បាយក ស្បាស្បៀង ។

អត្ថវសំ សម្បស្សមានោ ឥមស្មឹ សរីរេ ឯវរូបំ បរមនិបច្ចការំ ករោសិ មិត្តូបហារំ ឧបទំសេសីតិ ។

[៣៦៣] អត្ថិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។ ឥធាហំ ភន្តេ ភគវ បស្សាមិ ឯកេ សមណព្រាហ្មណេ បរិយន្តកតំ ព្រហ្មចរិយំ ចរន្តេ ទសបិ វស្សានិ វីសម្បិ វស្សានិ តឹសម្បិ វស្សានិ ចត្តាឡីសម្បិ វស្សានិ ។ តេ អបរេន សមយេន សុន្ហាតា សុវិលិត្តា កប្បិតកេសមស្សូ បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេន្តិ[១] ។ ឥធ បនាហំ ភន្តេ ភិក្ខូ បស្សាមិ យាវជីវំ

១. បរិចរន្តិ ។



បានឃើញនូវអំណាចនៃប្រយោជន៍ដូចម្តេច បានជាទ្រង់ធ្វើសេចក្តីឱនលំទោនយ៉ាងក្រៃលែងមានសភាពយ៉ាងនេះ ក្នុងសរីរៈនេះ ហើយសំដែងនូវការបូជាដោយសេចក្តីរាប់អាន ( ដល់ម៉្លេះ ) ។

[៣៦៣] ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានយល់ធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ថា ព្រះមានព្រះភាគទ្រង់ត្រាស់ដឹង ដោយប្រពៃ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយដោយប្រពៃ ព្រះសង្ឃជាសាវ័ក របស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។ បពិត្រព្រះមានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញសមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តព្រហ្មចរិយធម៌មានកំណត់ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ។ លុះដល់មកសម័យខាងក្រោយ ក៏ស្រាប់តែពួកសមណព្រាហ្មណ៍នោះ លាងលាបខ្លួនឲ្យស្អាត កោរសក់ពុកមាត់ពុកចង្កា ហើយឆ្អែតស្កប់ស្កល់មូលមិត្ត ផ្គត់ផ្គង់ដោយកាមគុណទាំង ៥ ទៅវិញ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឃើញភិក្ខុទាំងឡាយ ក្នុងសាសនានេះ

អាបាណកោដិកំ បរិបុណ្ណំ(១) បរិសុទ្ធំ ព្រហ្មចរិយំ ចរន្តេ ។ ន ខោ បនាហំ ភន្តេ ឥតោ ពហិទ្ធា អញ្ញំ ឯវំ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ សមនុបស្សាមិ ។ អយម្បិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៦៤) បុន ចបរំ ភន្តេ រាជានោបិ រាជូហិ វិវទន្តិ ខត្តិយាបិ ខត្តិយេហិ វិវទន្តិ ព្រាហ្មណាបិ ព្រាហ្មណេហិ វិវទន្តិ គហបតយោបិ(២) គហបតីហិ វិវទន្តិ មាតាបិ បុត្តេន វិវទតិ បុត្តោបិ មាតរា វិវទតិ បិតាបិ បុត្តេន វិវទតិ បុត្តោបិ បិតរា វិវទតិ ភាតាបិ ភគិនិយា វិវទតិ ភគិនីបិ ភាតរា វិវទតិ សហាយោបិ សហាយេន វិវទតិ ។ ឥធ បនាហំ ភន្តេ ភិក្ខូ បស្សាមិ សមគ្គេ សម្មោទមានេ

១ ម. បរិយន្តំ ។ ២ ម. គហបតី ។



បានប្រព្រឹត្តព្រហ្មចរិយធម៌ មានជីវិតជាទីបំផុត ឲ្យបរិបូណ៌ បរិសុទ្ធ ដរាបដល់អស់ជីវិត ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាគេ មើលមិនឃើញមានបុគ្គលដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះ ប្រព្រឹត្ត ព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គ ដ៏ចំរើន នេះហើយដែលនាំឲ្យខ្ញុំព្រះអង្គបានយល់ធម៌ គួរសំណាក់ព្រះ មានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹង ដោយប្រពៃ ព្រះធម៌ គឺព្រះមានព្រះភាគ ត្រាស់សំដែងហើយ ដោយប្រពៃ ព្រះសង្ឃជា សាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។

(៣៦៤) បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត ច្រើនមាន តែពួកព្រះរាជាទាស់ទែងគ្នានឹងពួកព្រះរាជាក៏មាន ពួកក្សត្រទាស់ទែង គ្នានឹងពួកក្សត្រក៏មាន ពួកព្រាហ្មណ៍ ទាស់ទែងគ្នានឹងពួកព្រាហ្មណ៍ក៏ មាន ពួកគហបតីទាស់ទែងគ្នានឹងពួកគហបតីក៏មាន មាតាទាស់ទែង នឹងបុត្រក៏មាន បុត្រទាស់ទែងនឹងមាតាក៏មាន បិតាទាស់ទែងនឹងបុត្រ ក៏មាន បុត្រទាស់ទែងនឹងបិតាក៏មាន បងប្អូនប្រុសទាស់ទែងនឹងបងប្អូន ស្រីក៏មាន បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសក៏មាន សំឡាញ់ទាស់ ទែងនឹងសំឡាញ់ក៏មាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញតែពួក ភិក្ខុក្នុងសាសនានេះហើយ ដែលមានសេចក្តីព្រមព្រៀង ស្រស់ស្រាយ

អវិវទមានេ ខីរោទកីភូតេ អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តេ វិហរន្តេ ។ ន ខោ បនាហំ ភន្តេ ឥតោ ពហិទ្ធា អញ្ញំ ឯវំ សមគ្គំ បរិសំ សមនុបស្សាមិ ។ អយម្បិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៦៨) បុន ចបរាហំ ភន្តេ អារាមេន អារាមំ ឧយ្យានេន ឧយ្យានំ អនុចង្កមាមិ អនុវិចរាមិ សោហំ តត្ថ បស្សាមិ ឯកេ សមណព្រាហ្មណេ កិសេ លូខេ ទុព្វណ្ណេ ឧប្បណ្ឌុប្បណ្ឌុកជាតេ ធមនិសន្ថតគត្តេ ន វិយ មញ្ញេ ចក្ខុំ ពន្ធន្តេ ជនស្ស ទស្សនាយ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អទ្ធា ឥមេ អាយស្មន្តោ អនភិរតា វា ព្រហ្មចរិយំ ចរន្តិ អត្ថិ វា តេសំ កិញ្ចិ បាបំ(១) កតំ បដិច្ឆន្នំ(២) តថា ឥមេ អាយស្មន្តោ

---

១ ម. បាបំ កម្មំ ។ ២ ម. កតា បដិច្ឆន្នា ។



មិនទាស់ទែងគ្នា ដូចជាទឹកដែលលាយជាមួយទឹកដោះស្រស់ សំឡឹងមើលគ្នានឹងគ្នាដោយចក្ខុជាទីស្រឡាញ់ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណារកមើល មិនឃើញមានបរិស័ទឯទៀត ខាងក្រៅព្រះពុទ្ធសាសនានេះ ឲ្យមានសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន នេះហើយដែលនាំឲ្យខ្ញុំព្រះអង្គមានសេចក្តីយល់ធម៌ ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងដោយប្រពៃ ព្រះធម៌ក៏ព្រះមានព្រះភាគ ត្រាស់សំដែងហើយដោយប្រពៃ ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។

(៣៦៨) បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត ខ្ញុំព្រះអង្គដើរត្រឡឹងមើលអំពីសួនច្បារ ១ ទៅសួនច្បារ ១ អំពីឧទ្យាន ១ ទៅឧទ្យាន ១ ឃើញសមណព្រាហ្មណ៍ពួកមួយក្នុងទីនោះ ស្គាំងស្គម សៅហ្មង អាប់សម្បុរ កើតពពកលឿងស្លេកស្លាំង មានខ្លួនពាសដោយសរសៃ មិនទំនងឲ្យពួកជនមិនរវល់មើលជាប់ភ្នែកបាន ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងនេះ ទំនងជាប្រព្រឹត្តព្រហ្មចរិយធម៌ទាំងមិនត្រេកអរ ពុំនោះសោត លោកមានអាយុទាំងនោះ ធ្វើបាបកម្មណាមួយដ៏កំបាំង ព្រោះថាលោកមានអាយុទាំងនេះ

កិសោ លូខោ ទុព្វណ្ណោ ឧប្បណ្ឌុប្បណ្ឌុកជាតោ ធមនិសន្ថតគត្តោ ន វិយ មញ្ញេ ចក្ខុំ ពន្ធន្តិ ជនស្ស ទស្សនាយាតិ ។ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ កិំ នុ ខោ តុម្ហេ អាយស្មន្តោ(១) កិសា លូខា ទុព្វណ្ណា ឧប្បណ្ឌុប្បណ្ឌុកជាតា ធមនិសន្ថតគត្តា ន វិយ មញ្ញេ ចក្ខុំ ពន្ធថ ជនស្ស ទស្សនាយាតិ ។ តេ ឯវមាហំសុ ពន្ធុករោគោ នោ មហារាជាតិ ។ ឥធ បនាហំ ភន្តេ ភិក្ខូ បស្សាមិ ហដ្ឋប្បហដ្ឋេ ឧទគ្គុទគ្គេ អភិរតរូបេ បីណិន្ទ្រិយេ អប្បោស្សុក្កេ បន្នលោមេ បរទវុត្តេ មិគភូតេន ចេតសា វិហរន្តេ(២) ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ(៣) អទ្ធា ឥមេ អាយស្មន្តោ តស្ស ភគវតោ សាសនេ ឧឡារំ បុព្វេនាបរំ វិសេសំ ជានន្តិ(៤) តថា(៥) ឥមេ អាយស្មន្តោ ហដ្ឋប្បហដ្ឋា ឧទគ្គុទគ្គា អភិរតរូបា បីណិន្ទ្រិយា(៦)

---

១ ម. អាយស្មន្តោ ។ ២ ឱ. ហដ្ឋប្បហដ្ឋេ ឧទគ្គុទគ្គេ អភិរតរូបេ បីណិន្ទ្រិយេ អប្បោស្សុក្កេ បន្នលោមេ បរទវុត្តេ មិគភូតេន ចេតសា វិហរន្តេ ទិស្វាន ។ ៣ ម. ឯវំ ហោតិ ។ ៤ ម. សញ្ជានន្តិ ។ ៥ ម. តថា ហិ ។ ៦ ឱ. បីណិន្ទ្រិយា ។



ស្គម សៅហ្មង តប់សម្បុរ កើតរោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ មិនទំនងឲ្យជាប់ភ្នែកដល់ជនអ្នកមើល ។ ខ្ញុំព្រះអង្គក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ដូចម្តេច បានជាលោកមានអាយុទាំងឡាយ ស្គម សៅហ្មង តប់សម្បុរ កើតរោគលឿងស្លេកស្លាំង មានខ្លួនរវាមដោយសរសៃ មិនទំនងឲ្យជាប់ភ្នែកដល់ជនអ្នកមើលដូច្នេះ ។ សមណព្រាហ្មណ៍ទាំងនោះនិយាយយ៉ាងនេះថា បពិត្រមហារាជ យើងទាំងឡាយមានរោគជាប់តាមពូជមក ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញពួកភិក្ខុក្នុងសាសនានេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ មានសេចក្តីខ្វល់ខ្វាយតិច មានរោមស្ងប់ ហើយចិញ្ចឹមជីវិតដោយសារទានរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងឡាយនេះ ដឹងនូវគុណវិសេសដ៏ទៃៗក្រៃលែងជាងកាលមុនក្នុងសាសនារបស់ព្រះមានបុណ្យនោះ ដោយពិតហើយ បានជាលោកមានអាយុទាំងនេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ

អប្បោស្សុក្កា បន្នលោមា បរទវុត្តា មិគភូតេន ចេតសា វិហរន្តិ ។ អយម្បិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

[៣៦៦] បុន ចបរាហំ ភន្តេ រាជា ខត្តិយោ មុទ្ធាវសិត្តោ បហោមិ ឃាតេតាយំ វា ឃាតេតុំ ជាបេតាយំ វា ជាបេតុំ បព្វាជេតាយំ វា បព្វាជេតុំ ។ តស្ស មយ្ហំ ភន្តេ អឌ្ឌករណេ(១) និសិន្នស្ស អន្តរន្តរា កថំ ឱបាតេន្តិ ។ សោហំ ន លភាមិ មា មេ ភោន្តោ អឌ្ឌករណេ និសិន្នស្ស អន្តរន្តរា កថំ ឱបាតេថ កថាបរិយោសានំ មេ ភវន្តោ(២) អាគមេន្តូតិ ។ តស្ស មយ្ហំ ភន្តេ អន្តរន្តរា កថំ ឱបាតេន្តិ ។ ឥធ បនាហំ ភន្តេ

១ ម. អឌ្ឌការណេ ។ ២ ម. ភោន្តោ ។



មានសេចក្ដីខ្វល់ខ្វាយតិច មានរោមស្ងប់ហើយ ចិញ្ចឹមជីវិតដោយរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គ បានយល់ធម៌ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគ ត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌ព្រះមានព្រះភាគ សំដែងហើយដោយប្រពៃមែន ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃមែន ។

[៣៦៦] បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ខ្ញុំព្រះអង្គជារាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ ល្មមសម្លាប់មនុស្សដែលគួរសម្លាប់ក៏បាន មនុស្សគួរបំរើនក៏ឲ្យបំរើនបាន មនុស្សគួរបណ្ដេញក៏ឲ្យបណ្ដេញបាន ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គនោះកំពុងអង្គុយក្នុងកន្លែងសម្រាប់កាត់ក្ដី ហើយមានពួកជនហ៊ាននិយាយស្កាត់សំដី ត្រង់ពាក់កណ្ដាល ខ្ញុំព្រះអង្គនោះក៏បាននិយាយឃាត់ថា អ្នកដ៏ចំរើនទាំងឡាយ កុំទូសំដីរបស់ខ្ញុំដែលកំពុងអង្គុយ ក្នុងកន្លែងសម្រាប់កាត់ក្ដី ឲ្យដាច់ពាក់កណ្ដាលឡើយ អ្នកដ៏ចំរើនទាំងឡាយចាំស្ដាប់ខ្ញុំនិយាយឲ្យចប់សិន ។ បពិត្រព្រះអង្គដ៏ចំរើន ពួកមនុស្សក៏នៅតែនិយាយស្កាត់សំដី របស់ខ្ញុំព្រះអង្គត្រង់ពាក់កណ្ដាលដដែល ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ

ភិក្ខូ បស្សាមិ យស្មឹ សមយេ ភគវា អនេក-
សតាយ បរិសាយ ធម្មំ ទេសេតិ នេវ តស្មឹ
សមយេ ភគវតោ សាវកានំ ខិបិតសទ្ទោ វា
ហោតិ ឧក្កាសិតសទ្ទោ វា ។ ភូតបុព្វំ ភន្តេ
ភគវា អនេកសតាយ បរិសាយ ធម្មំ ទេសេសិ
តត្រ អញ្ញតរោ[១] ភគវតោ សាវកោ ឧក្កាសិ ។
តមេនំ អញ្ញតរោ សព្រហ្មចារី ជណ្ណុកេន ឃដ្ដេសិ
អប្បសទ្ទោ អាយស្មា ហោតុ មា អាយស្មា[២]
សទ្ទមកាសិ សត្ថា នោ ភគវា ធម្មំ ទេសេតីតិ ។
តស្ស មយ្ហំ ភន្តេ ឯតទហោសិ អច្ឆរិយំ វត ភោ
អព្ភុតំ វត ភោ អទណ្ឌេន វត កិរ ភោ អសត្ថេន
ឯវំ សុវិនីតា បរិសា ភវិស្សតីតិ ។ ន ខោ
បនាហំ ភន្តេ ឥតោ ពហិទ្ធា អញ្ញំ ឯវំ សុវិនីតំ
បរិសំ សមនុបស្សាមិ ។ អយម្បិ ខោ មេ ភន្តេ
ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា

១ ម. វញ្ញតរោ ។ ២ ឱ. ម. មាយស្មា ។



ឃើញតែពួកភិក្ខុក្នុងសាសនានេះ បើព្រះមានព្រះភាគ កំពុងសំដែង
ធម៌ដល់បរិស័ទច្រើនរយក្នុងសម័យណា សម័យនោះ ពួកសាវ័ករបស់
ព្រះមានព្រះភាគ ក៏ឥតមានសំឡេងកណ្តាស់ ឬសំឡេងក្អកគ្រហែម
ឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុធ្លាប់មានពីមុនមក បើព្រះ
មានព្រះភាគ កំពុងសំដែងធម៌ដល់បរិស័ទច្រើនរយ ហើយមានសាវ័ក
របស់ព្រះមានព្រះភាគណាមួយ ក្អកឡើងក្នុងទីនោះ ។ នឹងមានស-
ព្រហ្មចារីបុគ្គលណាមួយ គោះនូវសាវ័កនោះដោយជង្គង់ថា លោកមាន
អាយុ ចូរធ្វើសំឡេងតិច លោកមានអាយុ កុំធ្វើសំឡេងខ្លាំងឡើយ
ដ្បិតព្រះមានព្រះភាគជាគ្រូយើង កំពុងសំដែងធម៌ ។ បពិត្រព្រះអង្គ
ដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អើអស្ចារ្យណាស់ហ្ន៎
ចំឡែកណាស់ហ្ន៎ បរិស័ទដែលព្រះអង្គទូន្មានបានល្អ យ៉ាងនេះ
ដោយមិនបាច់កាន់អាជ្ញា មិនបាច់កាន់គ្រឿងសស្ត្រាឡើយ ។ បពិត្រ
ព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គពិចារណាមើល មិនឃើញបរិស័ទដទៃក្រៅ
ពីព្រះពុទ្ធសាសនា ទូន្មានបានដោយល្អ យ៉ាងនេះឡើយ ។ បពិត្រ
ព្រះអង្គដ៏ចំរើន នេះឯង (ដែលជាខ្ញុំ) ខ្ញុំព្រះអង្គបានយល់ធម៌ក្នុង
សំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃមែន

ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៦៧) បុន ចបរាហំ ភន្តេ បស្សាមិ ឥធេកច្ចេ ខត្តិយបណ្ឌិតេ និបុណេ កតបរប្បវាទេ វាលវេធិរូបេ ។ តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អមុកំ នាម គាមំ វា និគមំ វា ឱសរិស្សតីតិ ។ តេ បញ្ហំ អភិសង្ខរោន្តិ ឥមំ មយំ បញ្ហំ សមណំ គោតមំ ឧបសង្កមិត្វា បុច្ឆិស្សាម ឯវញ្ចេ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវមស្ស មយំ វាទំ អារោបេស្សាម ឯវញ្ចេបិ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវម្បិស្ស មយំ វាទំ អារោបេស្សាមាតិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អមុកំ នាម គាមំ វា និគមំ វា ឱសដោតិ ។ តេ យេន ភគវា តេនុបសង្កមន្តិ ។ តេ ភគវា ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ



ព្រះធម៌ ព្រះមានព្រះភាគសំដែងទុកហើយដោយប្រពៃមែន ព្រះសង្ឃ ជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃមែន ។

(៣៦៧) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ខ្ញុំព្រះអង្គបាន ឃើញខត្តិយបណ្ឌិតពួកខ្លះក្នុងលោកនេះ ជាអ្នកមានប្រាជ្ញាល្អិត ធ្លាប់ ញ៉ាំងនូវបរប្បវាទ មានសភាពដូចជាអ្នកបាញ់ម្រឹគសាហារ ។ ពួក ខត្តិយបណ្ឌិតទាំងនោះ ហាក់ដូចជាទំលាយនូវទិដ្ឋិដោយប្រាជ្ញាបាន ។ ខត្តិយបណ្ឌិតទាំងនោះបានឮថា ព្រះសមណគោតម និមន្តចូលមកកាន់ ស្រុកឬនិគមឯណោះ ។ ខត្តិយបណ្ឌិតទាំងនោះក៏តាក់តែងប្រស្នាហើយ និតគ្នាថា យើងនឹងចូលទៅសួរប្រស្នានេះនឹងព្រះសមណគោតម កាល យើងសួរទៅហើយ បើព្រះសមណគោតម ដោះស្រាយមិនត្រូវយ៉ាងនេះ ទេ យើងនឹងលើកវាទៈពោលទោស របស់ព្រះសមណគោតមយ៉ាង នេះ មួយទៀត កាលយើងសួរយ៉ាងនេះហើយ បើព្រះសមណគោតម ដោះស្រាយមិនត្រូវយ៉ាងនេះទេ យើងនឹងលើកវាទៈរបស់ព្រះសមណ- គោតមនោះយ៉ាងនេះវិញទៀត ។ ខត្តិយបណ្ឌិតទាំងនោះ បានឮថា ព្រះសមណគោតម និមន្តចូលមកកាន់ស្រុកឬនិគមឯណោះ ។ ខត្តិយ- បណ្ឌិតទាំងនោះ ក៏ចូលមករកព្រះមានព្រះភាគ ។ ព្រះមានព្រះ ភាគទ្រង់ពន្យល់ខត្តិយបណ្ឌិតទាំងនោះឲ្យយល់ច្បាស់ ឲ្យកាន់យកតាម

សមុត្តេជេតិ សម្បហំសេតិ ។ តេ ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ន ចេវ ភគវន្តំ បញ្ហំ បុច្ឆន្តិ កុតស្ស(១) វាទំ អារោបេស្សន្តិ អញ្ញទត្ថុំ(២) ភគវតោ សាវកា សម្បជ្ជន្តិ ។ អយម្បិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៦៩) បុន ចបរាហំ ភន្តេ បស្សាមិ ឥធេកច្ចេ ព្រាហ្មណបណ្ឌិតេ ។បេ។ គហបតិបណ្ឌិតេ... សមណបណ្ឌិតេ និបុណេ កតបរប្បវាទេ វាលវេធិ-រូបេ ។ តេ ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន ទិដ្ឋិគតានិ ។ តេ សុណន្តិ សមណោ ខលុ

១ ម. ប. កុតោ ។ ២ ម. ប. អញ្ញទត្ថុ ។



ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ល។ ព្រះមានព្រះភាគបានពន្យល់ពួកខត្តិយបណ្ឌិតឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏មិនហ៊ានទាំងតាំងសួរប្រស្នានឹងព្រះមានព្រះភាគ មិនដឹងជានឹងលើកវាទៈពីណាកើត តាមពិត ត្រឡប់សម្រេចជាសាវ័ករបស់ព្រះមានព្រះភាគវិញ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គយល់ធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌គឺព្រះមានព្រះភាគសំដែងហើយ ដោយប្រពៃមែន ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគប្រតិបត្តិដោយប្រពៃមែន ។

(៣៦៩) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ខ្ញុំព្រះអង្គបានឃើញព្រាហ្មណបណ្ឌិតពួកខ្លះក្នុងលោកនេះ ។បេ។ គហបតិបណ្ឌិត... សម-ណបណ្ឌិត មានប្រាជ្ញាល្អិត អាចញាំញីនូវបរប្បវាទបាន មានសភាពដូចជាអ្នកសម្លាប់ម្រឹគសាហាវ ។ សមណបណ្ឌិតទាំងនោះហាក់ដូចជាទំលាយនូវទិដ្ឋិដោយប្រាជ្ញាបាន ។ បណ្ឌិតទាំងនោះបានឮថា ព្រះសមណ-

ភោ គោតមោ អសុកំ នាម គាមំ វា និគមំ វា ឱសរិស្សតីតិ ។ តេ បញ្ហំ អភិសង្ខរោន្តិ ឥមំ មយំ បញ្ហំ សមណំ គោតមំ ឧបសង្កមិត្វា បុច្ឆិស្សាម ឯវញ្ចេ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវមស្ស មយំ វាទំ អារោបេស្សាម ឯវញ្ចេបិ នោ បុដ្ឋោ ឯវំ ព្យាករិស្សតិ ឯវម្បិស្ស មយំ វាទំ អារោបេស្សាមាតិ ។ តេ សុណន្តិ សមណោ ខលុ ភោ គោតមោ អសុកំ នាម គាមំ វា និគមំ វា ឱសដោតិ ។ តេ យេន ភគវា តេនុបសង្កមន្តិ ។ តេ ភគវា ធម្មិយា កថាយ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ តេ ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ន ចេវ ភគវន្តំ បញ្ហំ បុច្ឆន្តិ កុតស្ស វាទំ អារោបេស្សន្តិ អញ្ញទត្ថុ ភគវន្តំយេវ ឱកាសំ យាចន្តិ អគារស្មា អនគារិយំ បព្វជ្ជាយ ។ តេ ភគវា បព្វាជេតិ ។ តេ តថា បព្វជិតា សមានា វូបកដ្ឋា



គោតម និមន្តចូលមកកាន់ស្រុកឬនិគមឯណោះ ៗ គេក៏នាំគ្នាតែងប្រស្នា ដោយគិតថា យើងទាំងឡាយ នឹងចូលទៅសួរប្រស្នានេះនឹងព្រះសមណគោតម កាលយើងសួរ យ៉ាងនេះទៅហើយ បើព្រះសមណគោតមដោះស្រាយមិនរួចយ៉ាងនេះៗ យើងនឹងលើកវាទៈរបស់ព្រះសមណគោតមនោះយ៉ាងនេះ មួយទៀត កាលយើងសួរ យ៉ាងនេះទៅហើយ បើព្រះសមណគោតមដោះស្រាយមិនរួចយ៉ាងនេះៗ យើងទាំងឡាយ នឹងលើកវាទៈរបស់ព្រះសមណគោតមនោះ យ៉ាងនេះថែមទៀត ។ បណ្ឌិតទាំងនោះបានឮថា ព្រះសមណគោតម និមន្តចូលមកកាន់ស្រុកឬនិគមឯណោះ ៗ គេក៏នាំគ្នាចូលមកគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកបណ្ឌិតទាំងនោះ ឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លុះព្រះមានព្រះភាគ ទ្រង់ពន្យល់បណ្ឌិតទាំងនោះ ឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏មិនហ៊ានទាំងសួរប្រស្នាចំពោះព្រះមានព្រះភាគឡើយ នឹងលើកវាទៈមកពីណាកើត តាមពិត ទៅជាសូមឱកាសនឹងព្រះមានព្រះភាគ ដើម្បីចេញចាកផ្ទះ ចូលទៅកាន់ភាពមិនមានផ្ទះដោយបព្វជ្ជាវិញ ។ ព្រះមានព្រះភាគក៏បំបួសបណ្ឌិតទាំងនោះ ៗ បណ្ឌិតទាំងនោះ លុះបួសរួចហើយក៏ចៀសចេញទៅ [illegible]

អប្បមត្តា អាតាបិនោ បហិតត្តា វិហរន្តា នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ តេ ឯវមាហំសុ មយំ(១) វត ភន្តេ ភោ អនស្សាម(២) មយំ ហិ បុព្វេ អស្សមណា វ សមានា សមណាម្ហាតិ បដិជានិម្ហា អព្រាហ្មណា វ សមានា ព្រាហ្មណាម្ហាតិ បដិជានិម្ហា អនរហន្តោ វ សមានា អរហន្តោម្ហាតិ បដិជានិម្ហា ឥទានិ ខោម្ហ(៣) សមណា ឥទានិ ខោម្ហ ព្រាហ្មណា ឥទានិ ខោម្ហ អរហន្តោតិ ។ អយម្បិ ខោ មេ ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

---

១ ម. យ. មនំ ។ ២ ម. ឯត្ថន្តរេ មនំ វត ភោ អនស្សាមាតិ ទិស្សតិ ។ យ. មនំ វត ភោ បនស្សាមាតិ ទិស្សតិ ។ ៣ ម. ខោម្ហ ។



សេចក្តីប្រមាទ មានព្យាយាម មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្រដែលចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ផលអនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដ៏ជាទីបំផុតនៃមគ្គព្រហ្មចរិយ ក្នុងបច្ចុប្បន្ននេះ ដោយប្រាជ្ញារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅដោយអរិយាបថទាំង ៤ ។ បណ្ឌិតទាំងនោះក៏ពោលយ៉ាងនេះថា អើយើងទាំងឡាយ មិនវិនាសទេ ព្រោះថាកាលពីដើម យើងទាំងឡាយមិនមែនជាសមណៈប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រាហ្មណ៍ ប្តេជ្ញាខ្លួនថាជាព្រាហ្មណ៍ មិនមែនជាព្រះអរហន្ត ប្តេជ្ញាខ្លួនថាជាព្រះអរហន្ត ឥឡូវនេះ យើងទាំងឡាយ បានជាសមណៈពិតហើយ ឥឡូវនេះ យើងទាំងឡាយ បានជាព្រាហ្មណ៍ពិតហើយ ឥឡូវនេះ យើងទាំងឡាយបានជាអរហន្តពិតហើយ ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គយល់ធម៌ ក្នុងសំណាក់ នៃព្រះមានព្រះភាគថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ដឹង ដោយប្រពៃមែន ព្រះធម៌ ព្រះមានព្រះភាគ សំដែងហើយ ដោយប្រពៃមែន ព្រះសង្ឃជាសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃមែន ។

[៣៤៩] បុន ចបរំ(១) ភន្តេ ឥមេ ឥសិទត្តបុរាណា(២) ថបតយោ មមភត្តា មមយានា អហំ នេសំ ជីវិតំ ទាតា យសស្ស អាហត្តា អថ ច បន នោ តថា មយិ និបច្ចការំ ករោន្តិ យថា ភគវតិ ។ ភូតបុព្វាហំ ភន្តេ សេនំ អព្ភុយ្យាតោ សមានោ ឥមេ(៣) ឥសិទត្តបុរាណេ ថបតយោ វីមំសមានោ អញ្ញតរស្មឹ សម្ពាធេ អាវសថេ វាសំ ឧបគច្ឆឹ ។ អថ ខោ ភន្តេ ឥមេ ឥសិទត្តបុរាណា ថបតយោ ពហុទេវ រត្តឹ ធម្មិយា កថាយ វីតិនាមេត្វា យតោ អស្សោសុំ ភគវន្តំ តតោ សីសំ កត្វា មំ បាទតោ កត្វា និបជ្ជឹសុ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឥមេ ឥសិទត្តបុរាណា ថបតយោ មមភត្តា មមយានា អហំ នេសំ ជីវិតំ ទាតា យសស្ស អាហត្តា អថ ច បន នោ តថា មយិ និបច្ចការំ ករោន្តិ

---

១ ឱ. ម. ចបរកំ ។ ២ ឱ. ឥសិទត្តបុរាណា ។ ៣ ឱ. ឥមេ ។ ម. ឥមេ ច ។



(៣៤៩) បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ពួកជាងឈើ (ពីនាក់) គឺឥសិទត្តៈ ១ បុរាណៈ ១ ទាំងនេះ មានបាយរបស់ខ្ញុំព្រះអង្គ ដូចជាបាយនេះ មានយានរបស់ខ្ញុំព្រះអង្គ ក៏ដូចជាយាននេះ ខ្ញុំព្រះអង្គបានឲ្យជីវិត បានតាំងយសដល់ជាងឈើទាំងនោះ តែពួកជាងឈើមិនធ្វើសេចក្តីទន់ទាបមកកាន់ខ្ញុំព្រះអង្គ ដូចជាធ្វើចំពោះព្រះមានព្រះភាគឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានលើកពួកសេនាចេញទៅ ដើម្បីល្បងមើលនូវពួកជាងឈើ ឈ្មោះឥសិទត្តៈនិងបុរាណៈទាំងនេះ ហើយឈប់សម្រាកក្នុងទីកន្លែងចង្អៀតមួយ ។ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ពួកជាងឈើឈ្មោះឥសិទត្តៈនិងបុរាណៈទាំងនេះ ញុំាងកាលឲ្យកន្លងទៅដោយធម្មីកថា អស់រាត្រីជាច្រើន បើក្នុងទិសណាជា ព្រះមានព្រះភាគ គង់នៅក្នុងទិសណា ក៏បែរក្បាលទៅត្រង់ទិសនោះ ហើយផ្តេកសណ្តូកជើងមកលើខ្ញុំព្រះអង្គវិញ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកពេកណាស់ ជាងឈើឈ្មោះឥសិទត្តៈនិងបុរាណៈនេះ មានបាយរបស់អញ ក៏ដូចជាបាយនេះ មានយានរបស់អញ ក៏ដូចជាយាននេះ អញបានឲ្យជីវិត បានតាំងយសដល់ជាងឈើទាំងនោះ តែជាងឈើទាំងនោះមិនធ្វើសេចក្តីទន់ទាបមកកាន់អញ ដូចជាធ្វើចំពោះព្រះមានព្រះភាគសោះ ។

អទ្ធា ឥមេ អាយស្មន្តោ តស្ស ភគវតោ សាសនេ ឧឡារំ បុព្វាបរំ វិសេសំ ជានន្តីតិ(១) ។ អយម្បិ ខោ(២) ភន្តេ ភគវតិ ធម្មន្វយោ ហោតិ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោតិ ។

(៣៣០) បុន ចបរំ ភន្តេ ភគវាបិ ខត្តិយោ អហម្បិ ខត្តិយោ ភគវាបិ កោសលោ អហម្បិ កោសលោ ភគវាបិ អាសីតិកោ អហម្បិ អាសីតិកោ យម្បិ ខោ(៣) ភន្តេ ភគវាបិ ខត្តិយោ អហម្បិ ខត្តិយោ ភគវាបិ កោសលោ អហម្បិ កោសលោ ភគវាបិ អាសីតិកោ អហម្បិ អាសីតិកោតិ ។ ឥមិនា អរហាមេវហំ(៤) ភន្តេ ភគវតិ បរមនិបច្ចការំ កាតុំ មិត្តូបហារំ ឧបទំសេតុំ ហន្ទ ចទានិ មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ

១ ឱ. សញ្ជានន្តីតិ ។ ២ ម. ខោ មេ ។ ៣ ឱ. កោសលោ ខត្តិ ។ ៤ ម. ឥមិនាយហំ ។



លោកមានអាយុទាំងនេះ ដឹងនូវគុណវិសេសដ៏ក្រៃលែង តាំងពីដើមមានចុង ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះដោយពិត ។ បពិត្រព្រះអង្គដ៏ចំរើន នេះឯងដែលនាំខ្ញុំព្រះអង្គ ឲ្យយល់ធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃ ព្រះធម៌នៃព្រះមានព្រះភាគ សំដែងហើយដោយប្រពៃ ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃ ។

(៣៣០) បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត ព្រះមានព្រះភាគក៏ជាក្សត្រិយ៍ ខ្ញុំព្រះអង្គក៏ជាក្សត្រិយ៍ ព្រះមានព្រះភាគ ក៏ជាអ្នកកោសល ខ្ញុំព្រះអង្គក៏ជាអ្នកកោសល ព្រះមានព្រះភាគមានព្រះជន្ម ៨០ ខ្ញុំព្រះអង្គក៏មានអាយុ ៨០ បពិត្រព្រះអង្គដ៏ចំរើន ត្រង់ដែលព្រះមានព្រះភាគជាក្សត្រិយ៍ ខ្ញុំព្រះអង្គក៏ជាក្សត្រិយ៍ ព្រះមានព្រះភាគក៏ជាអ្នកកោសល ខ្ញុំព្រះអង្គក៏ជាអ្នកកោសល ព្រះមានព្រះភាគក៏មានព្រះជន្ម ៨០ ខ្ញុំព្រះអង្គក៏មានអាយុ ៨០ ។ បពិត្រព្រះអង្គដ៏ចំរើន តែត្រឹមប៉ុណ្ណេះ ខ្ញុំព្រះអង្គគួរដើម្បីធ្វើនូវសេចក្តីគោរពដ៏ក្រៃលែង ក្នុងព្រះមានព្រះភាគ ដើម្បីសំដែងនូវការបូជាដោយសេចក្តីរាប់អាន ចំពោះព្រះអង្គវិញ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានកិច្ចច្រើន មានការរវល់ច្រើន ចង់ត្រឡប់ទៅវិញឆាប់ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ

កាលំ មញ្ញសីតិ ។ អថខោ រាជា បសេនទិ កោសលោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(៣៣១) អថខោ ភគវា អចិរបក្កន្តស្ស រញ្ញោ បសេនទិស្ស កោសលស្ស ភិក្ខូ អាមន្តេសិ ឯសោ ភិក្ខវេ រាជា បសេនទិ កោសលោ ធម្មចេតិយានិ ភាសិត្វា ឧដ្ឋាយាសនា បក្កន្តោ ឧគ្គណ្ហថ ភិក្ខវេ ធម្មចេតិយានិ បរិយាបុណាថ ភិក្ខវេ ធម្មចេតិយានិ ធារេថ ភិក្ខវេ ធម្មចេតិយានិ អត្ថសញ្ហិតានិ ភិក្ខវេ ធម្មចេតិយានិ អាទិព្រហ្មចរិយកានីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ធម្មចេតិយសុត្តំ និដ្ឋិតំ ។

---



សូមព្រះអង្គសំគាល់នូវកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។ ទើបព្រះរាជាបសេនទិកោសល ក្រោកអំពីអាសនៈ ហើយថ្វាយបង្គំលាព្រះមានព្រះភាគដោយគោរព ធ្វើប្រទក្សិណហើយស្តេចចេញទៅ ។

(៣៣១) កាលព្រះរាជាបសេនទិកោសល ស្តេចចេញទៅមិនទាន់បានយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ត្រាស់ទៅនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាបសេនទិកោសលនេះ ទ្រង់សំដែងនូវពាក្យដែលធ្វើការគោរព ក្នុងធម៌ទាំងឡាយ ហើយក្រោកអំពីអាសនៈ ស្តេចចេញទៅ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររៀននូវពាក្យដែលធ្វើនូវសេចក្តីគោរព ក្នុងធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ចូរទន្ទេញពាក្យដែលធ្វើការគោរពក្នុងធម៌ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ចូរចាំទុកពាក្យ ដែលធ្វើការគោរពក្នុងធម៌ ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យដែលធ្វើការគោរពក្នុងធម៌ ដ៏ប្រកបដោយប្រយោជន៍ ជាអាទិព្រហ្មចរិយកៈ ។ លុះព្រះមានព្រះភាគទ្រង់សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ធម្មចេតិយសូត្រ ទី ៩ ។

## ទសមំ កណ្ណកត្ថលសុត្តំ

(៣៣៦) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ឧជុញ្ញាយំ(១) វិហរតិ កណ្ណកត្ថលេ មិគទាយេ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ ឧជុញ្ញំ អនុប្បត្តោ ហោតិ កេនចិទេវ ករណីយេន ។ អថខោ រាជា បសេនទិ កោសលោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ រាជា ភន្តេ បសេនទិ កោសលោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតីតិ ឯវញ្ច វទេហិ អជ្ជ កិរ ភន្តេ រាជា បសេនទិ កោសលោ បច្ឆាភត្តំ ភុត្តបាតរាសោ

១ ឱ. ឧទុញ្ញាយំ ។ ម. ឧញ្ញាយំ ។

## កណ្ណកត្ថលសូត្រ ទី ១០

(៣៣៦) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រទេស ឈ្មោះកណ្ណកត្ថលៈ ជាទីឲ្យអភ័យដល់ពួកម្រឹគ ជិតក្រុងឧជុញ្ញា ។ សម័យនោះឯង ព្រះបាទបសេនទិកោសល បានមកដល់ឧជុញ្ញានគរ ដោយកិច្ចនីមួយ ។ គ្រានោះ ព្រះបាទបសេនទិកោសល ត្រាស់ហៅបុរសម្នាក់ថា ម្នាលបុរសដ៏ចំរើន អ្នកឯងចូរមកនេះ ចូរអ្នកឯងចូលទៅកាន់ព្រះមានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមានព្រះភាគ ដោយក្បាល តាមពាក្យរបស់យើង រួចហើយចូរសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទបសេនទិកោសល ថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយសិរ្សៈ ហើយទ្រង់សួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខ រួចអ្នកឯងចូរពោលយ៉ាងនេះ តទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ឮថាថ្ងៃនេះព្រះបាទបសេនទិកោសលទ្រង់សោយព្រះ-ស្ងោយក្នុងវេលាព្រឹករួចហើយ ក្នុងកាលជាខាងក្រោយភត្ត ទ្រង់នឹង

ភគវន្តំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ ឯវំ ទេវាតិ ខោ សោ បុរិសោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ ភគវន្តំ ឯតទវោច រាជា ភន្តេ បសេនទិ កោសលោ ភគវតោ បាទេ សិរសា វន្ទតិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆតិ ឯវញ្ច វទេតិ អជ្ជ កិរ ភន្តេ រាជា បសេនទិ កោសលោ បច្ឆាភត្តំ ភត្តបដិក្កន្តោ ភគវន្តំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

(៣៣៣) អស្សោសុំ ខោ សោមា ច ភគិនី សកុលា ច ភគិនី អជ្ជ កិរ រាជា បសេនទិ កោសលោ បច្ឆាភត្តំ ភត្តបដិក្កន្តោ ភគវន្តំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ អថខោ សោមា ច



ចូលមកគាល់ព្រះមានព្រះភាគ ។ បុរសនោះទទួលព្រះឱង្ការ របស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះបាទបសេនទិកោសល ថ្វាយបង្គំព្រះបាទទាំងទ្វេ របស់ព្រះមានព្រះភាគដោយសិរ្សៈ ហើយទ្រង់សួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការនៅជាសុខ ហើយទ្រង់ក្រាស់យ៉ាងនេះទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ឮថា ថ្ងៃនេះព្រះបាទបសេនទិកោសល កាលបើទ្រង់សោយព្រះក្រយាស្ងោយក្នុងវេលាព្រឹករួចហើយ វេលាខាងក្រោយភត្ត ទ្រង់នឹងចូលមកគាល់ព្រះមានព្រះភាគ ។

(៣៣៣) ព្រះភគិនី (ជាបងប្អូន) ព្រះនាមសោមា នឹងព្រះនាមសកុលា បានឮថា ថ្ងៃនេះ ព្រះបាទបសេនទិកោសល កាលទ្រង់សោយព្រះក្រយាស្ងោយក្នុងវេលាព្រឹករួចហើយ ខាងក្រោយភត្ត ទ្រង់នឹងស្ដេចទៅគាល់ព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះនាងសោមា

ភគិនី សកុលា ច ភគិនី រាជានំ បសេនទឹ កោសលំ ភត្តាភិហារេ ឧបសង្កមិត្វា ឯតទវោចុំ តេនហិ មហារាជ អម្ហាកំបិ វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សោមា ច ភន្តេ ភគិនី សកុលា ច ភគិនី ភគវតោ បាទេ សិរសា វន្ទន្តិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆន្តីតិ ។

(៣៣៤) អថខោ រាជា បសេនទិ កោសលោ បច្ឆាភត្តំ ភុត្តបាតរាសោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច សោមា ច ភន្តេ ភគិនី សកុលា ច ភគិនី ភគវតោ បាទេ សិរសា វន្ទន្តិ អប្បាពាធំ



នឹងព្រះនាងសកុលា ចូលទៅគាល់ព្រះបាទបសេនទិកោសល ក្នុងកន្លែងសម្រាប់សោយ ហើយបាននាំពាក្យនេះថា បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគ ដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំម្ចាស់ទាំងឡាយផង សូមទ្រង់សួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខផងថា បពិត្រព្រះអង្គដ៏ចំរើន នាងសោមា និងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូ នៃព្រះមានព្រះភាគដោយសិរ្សៈ ហើយសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខសាន្ត ។

(៣៣៤) គ្រានោះ ព្រះបាទបសេនទិកោសល សោយព្រះក្រយាស្ងោយ ក្នុងវេលាព្រឹករួចហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន នាងសោមានិងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូ នៃព្រះមានព្រះភាគដោយសិរ្សៈ ទូលសួរនូវការមិនមានអាពាធ

អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆន្តីតិ ។ កិំ បន មហារាជ សោមា ច ភគិនី សកុលា ច ភគិនី អញ្ញំ ទូតំ នាលត្ថុន្តិ ។ អស្សោសុំ ខោ ភន្តេ សោមា ច ភគិនី សកុលា ច ភគិនី អជ្ជ កិរ រាជា បសេនទិ កោសលោ បច្ឆាភត្តំ ភុត្តបាតរាសោ ភគវន្តំ ទស្សនាយ ឧបសង្កមិស្សតីតិ អថខោ ភន្តេ សោមា ច ភគិនី សកុលា ច ភគិនី មំ ភត្តាភិហារេ ឧបសង្កមិត្វា ឯតទវោចុំ តេនហិ មហារាជ អម្ហាកម្បិ វចនេន ភគវតោ បាទេ សិរសា វន្ទាហិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆ សោមា ច[1] ភគិនី សកុលា ច ភគិនី ភគវតោ បាទេ សិរសា វន្ទន្តិ អប្បាពាធំ អប្បាតង្កំ លហុដ្ឋានំ ពលំ ផាសុវិហារំ បុច្ឆន្តីតិ ។ សុខិនិយោ ហោន្តុ[2] មហារាជ សោមា ច ភគិនី សកុលា ច ភគិនីតិ ។

១ ម. ច ភគិនី វន្ទតិ ។ ២ ម. សុខិនិយោ ហោតិ វន្ទតិ ។



ការមិនមានទុក្ខ ការក្រោកឡើងមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខសាន្ត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជ ចុះនាងសោមានឹងនាងសកុលា រកអ្នកបម្រើដទៃមិនបានឬ ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា នាងសោមានឹងនាងសកុលាបានឮថា ក្នុងថ្ងៃនេះ ព្រះបាទបសេនទិកោសល កាលទ្រង់សោយព្រះក្រយាស្ងោយក្នុងវេលាព្រឹករួចហើយ ក្នុងវេលាខាងក្រោយភត្ត នឹងយាងចូលទៅដើម្បីគាល់ព្រះមានព្រះភាគដូច្នេះ បពិត្រព្រះអង្គដ៏ចំរើន គំលំដាប់នោះ នាងសោមានឹងនាងសកុលា ចូលមកគាល់ខ្ញុំព្រះអង្គ ត្រង់កន្លែងសម្រាប់ទទួលភត្ត ហើយពោលពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ សូមព្រះអង្គថ្វាយបង្គំព្រះបាទទាំងគូ នៃព្រះមានព្រះភាគដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំម្ចាស់ទាំងឡាយផង ទូលសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកឡើងមកបានរហ័សរហួន ព្រះកាយពល ការទ្រង់គង់នៅជាសុខថា នាងសោមានឹងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូដោយសិរ្សៈ ទូលសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកឡើងមកបានរហ័សរហួន ព្រះកាយពល ការទ្រង់គង់នៅជាសុខ ។ ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ សូមឲ្យនាងសោមានឹងនាងសកុលា បានសេចក្ដីសុខទាំងអស់គ្នា ។

[៣៣៩] អថខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច សុតំ មេតំ ភន្តេ សមណោ គោតមោ ឯវមាហ នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានិស្សតិ នេតំ ឋានំ វិជ្ជតីតិ យេ តេ ភន្តេ ឯវមាហំសុ សមណោ គោតមោ ឯវមាហ នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានិស្សតិ នេតំ ឋានំ វិជ្ជតីតិ កច្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ច ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតីតិ ។ យេ តេ មហារាជ ឯវមាហំសុ សមណោ គោតមោ ឯវមាហ នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ សព្វញ្ញូ សព្វទស្សាវី



[៣៣៩] គ្រានោះ ព្រះបាទបសេនទិកោសល បានក្រាបទូលពាក្យនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ពោលយ៉ាងនេះថា គ្មានសមណព្រាហ្មណ៍ណា ដែលជាអ្នកដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈដោយឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុទេ បពិត្រព្រះអង្គដ៏ចំរើន ជនទាំងឡាយណា ពោលយ៉ាងនេះថា ព្រះសមណគោតម និយាយយ៉ាងនេះថា គ្មានសមណព្រាហ្មណ៍ណា ដែលដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈ ដោយឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុទេ បពិត្រព្រះអង្គដ៏ចំរើន ជនទាំងឡាយនោះ ពោលតាមពាក្យរបស់ព្រះមានព្រះភាគ មិនមែនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតទេ ឈ្មោះថាព្យាករនូវធម៌ដ៏សមគួរដល់នវលោកុត្តរធម៌ ទាំងពាក្យតូចពាក្យធំប្រកបដោយធម៌ណាមួយ ក៏មិនដល់នូវទីគួរតិះដៀលទេឬ ។ ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ ជនទាំងឡាយណា ពោលយ៉ាងនេះថា ព្រះសមណគោតម និយាយយ៉ាងនេះថា គ្មានសមណៈឬព្រាហ្មណ៍ ដែលដឹងសព្វ ឃើញសព្វ

អបរិសេសំ ញាណទស្សនំ បដិជានិស្សតិ នេតំ ឋានំ វិជ្ជតីតិ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ច បន មំ តេ អសតា អភូតេនាតិ ។

[៣៧៦] អថខោ រាជា បសេនទិ កោសលោ វិឌូឌភំ(១) សេនាបតិំ អាមន្តេសិ កោ នុ ខោ សេនាបតិ ឥមំ កថាវត្ថុំ រាជន្តេបុរេ អព្ភុទាហាសីតិ ។ សញ្ជយោ មហារាជ ព្រាហ្មណោ អាកាសគោត្តោតិ ។ អថខោ រាជា បសេនទិ កោសលោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស មម វចនេន សញ្ជយំ ព្រាហ្មណំ អាកាសគោត្តំ អាមន្តេហិ រាជា តំ ភន្តេ បសេនទិ កោសលោ អាមន្តេតីតិ ។ ឯវំ ទេវាតិ ខោ សោ បុរិសោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុត្វា យេន សញ្ជយោ ព្រាហ្មណោ អាកាសគោត្តោ តេនុបសង្កមិ ឧបសង្កមិត្វា សញ្ជយំ ព្រាហ្មណំ អាកាសគោត្តំ ឯតទវោច រាជា តំ ភន្តេ បសេនទិ កោសលោ អាមន្តេតីតិ ។

១ វិដដូភន្តិ បាឋោ ទិស្សតិ ។ វិឌូឌភន្តិ យុត្តិ ។



ប្តេជ្ញានូវញាណទស្សនៈ ដោយឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុឡើយ ជនទាំងឡាយនេះ ពោលតាមពាក្យដែលតថាគតពោលហើយ ទាំងមិនឈ្មោះថា ពោលបង្កាច់តថាគត ដោយពាក្យមិនទៀងមិនពិតទេ ។

[៣៧៦] លំដាប់នោះ ព្រះបាទបសេនទិកោសល ត្រាស់ហៅសេនាបតីឈ្មោះវិឌូឌភៈមកហើយសួរថា ម្នាលសេនាបតី នរណាហ្ន៎ នាំអាថ៌ពោលកថានេះ ក្នុងទីក្នុងនៃព្រះបរមរាជវាំងបាន ។ វិឌូឌភៈសេនាបតី ក្រាបបង្គំទូលថា បពិត្រមហារាជ គឺសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ។ ទើបព្រះបាទបសេនទិកោសល ត្រាស់ហៅបុរសម្នាក់មកហើយប្រាប់ថា ម្នាលបុរសអើយ អ្នកឯងចូរមកនាយ អ្នកចូរទៅហៅសញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រ តាមពាក្យរបស់យើងថា បពិត្រលោកដ៏ចំរើន ព្រះបាទបសេនទិកោសល ទ្រង់មានព្រះបន្ទូលហៅលោក ។ បុរសនោះទទួលព្រះបន្ទូលរបស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅរកសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ លុះចូលទៅដល់ហើយ ក៏បានពោលពាក្យនេះទៅរកសញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រថា បពិត្រលោកដ៏ចំរើន ព្រះបាទបសេនទិកោសល ទ្រង់មានព្រះរាជឱង្ការហៅលោក ។

អថខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច សិយា នុ ខោ ភន្តេ ភគវតា អញ្ញទេវ កិញ្ចិ សន្ធាយ ភាសិតំ តញ្ច ជនោ អញ្ញថាបិ បច្ចាគច្ឆេយ្យ យថាកថំ បន ភន្តេ ភគវា អភិជានាតិ វាចំ ភាសិតាតិ ។ ឯវំ ខោ អហំ មហារាជ អភិជានាមិ វាចំ ភាសិត នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ សកិទេវ សព្វំ ញស្សតិ សព្វំ ទក្ខិតិ នេតំ ឋានំ វិជ្ជតីតិ ។ ហេតុរូបំ ភន្តេ ភគវា អាហ សហេតុរូបំ បន ភន្តេ ភគវា អាហ នត្ថិ សោ សមណោ វា ព្រាហ្មណោ វា យោ សកិទេវ សព្វំ ញស្សតិ សព្វំ ទក្ខិតិ នេតំ ឋានំ វិជ្ជតីតិ ចត្តារោមេ ភន្តេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ឥមេសំ នុ ខោ ភន្តេ ចតុន្នំ វណ្ណានំ សិយា វិសេសោ សិយា នានាករណន្តិ ។



លំដាប់នោះ ព្រះបាទបសេនទិកោសល បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ បានពោលពាក្យឯទៀត ព្រោះសំដៅហេតុណាមួយ អ្នកដទៃចូលចិត្តពាក្យនោះ ដោយប្រការដទៃវិញ បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះមានព្រះភាគ ជ្រាបនូវពាក្យតាមសមគួរហើយ ទើបពោលពាក្យ ។ ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ តថាគតដឹងយ៉ាងនេះហើយ ទើបពោលថា គ្មានសមណព្រាហ្មណ៍ណា ដែលដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួងតែម្តង សេចក្តីនេះមិនសមហេតុឡើយ ។ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ថា បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ សំដែងពាក្យសមហេតុ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ សំដែងពាក្យដែលប្រព្រឹត្តទៅមួយអន្លើដោយហេតុថា គ្មានសមណៈឬព្រាហ្មណ៍ណា ដែលដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួងតែម្តង រឿងដូច្នេះ មិនសមហេតុឡើយ បពិត្រព្រះអង្គដ៏ចំរើន វណ្ណៈមាន ៤ គឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រព្រះអង្គដ៏ចំរើន ត្រកូលទាំង ៤ នេះ មានសេចក្តីវិសេស ទាំងមានសេចក្តីផ្សេងគ្នាដែរឬទេ ។

[៣៣៧] ចត្តារោមេ មហារាជ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ឥមេសំ ខោ មហារាជ ចតុន្នំ វណ្ណានំ ទ្វេ វណ្ណា អគ្គមក្ខាយន្តិ ខត្តិយា ច ព្រាហ្មណា ច យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មន្តិ ។ នាហំ ភន្តេ ភគវន្តំ ទិដ្ឋធម្មិកំ បុច្ឆាមិ សម្បរាយិកាហំ ភន្តេ ភគវន្តំ បុច្ឆាមិ ចត្តារោមេ ភន្តេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ឥមេសំ នុ ខោ ភន្តេ ចតុន្នំ វណ្ណានំ សិយា វិសេសោ សិយា នានាករណន្តិ ។

[៣៣៨] បញ្ចិមានិ មហារាជ បធានិយង្គានិ ។ កតមានិ បញ្ច ។ ឥធ មហារាជ ភិក្ខុ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ



(៣៣៧) បពិត្រមហារាជ វណ្ណៈទាំង ៤ នេះគឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រមហារាជ បណ្តាវណ្ណៈទាំង ៤ នេះ មានតែវណ្ណៈពីរគឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ ដែលប្រាកដជាប្រសើរជាងគេ ព្រោះវណ្ណៈទាំងពីរនេះ គួរដល់ការថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម នឹងសាមីចិកម្ម ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនទូលសួរនូវគុណក្នុងបច្ចុប្បន្ន នឹងព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទូលសួរនូវគុណ ដែលប្រព្រឹត្តទៅក្នុងបរលោក នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ត្រង់វណ្ណៈទាំង ៤ នេះគឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រព្រះអង្គដ៏ចំរើន វណ្ណៈទាំង ៤ នេះ មានសេចក្តីវិសេសនឹងសេចក្តីផ្សេងគ្នាដែរឬទេ ។

(៣៣៨) បពិត្រមហារាជ អង្គនៃសេចក្តីព្យាយាមនេះ មាន ៥ ។ ចុះអង្គនៃសេចក្តីព្យាយាម មាន ៥ តើដូចម្តេចខ្លះ ។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿនូវការត្រាស់ដឹង របស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រមដោយវិជ្ជានឹងចរណៈ ព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក

អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ អប្បាពាធោ ហោតិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ មជ្ឈិមាយ បធានក្ខមាយ ។ អសឋោ ហោតិ អមាយាវី យថាភូតំ អត្តានំ អាវិកត្តា សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ ។ អារទ្ធវិរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មា ទុក្ខក្ខយគាមិនិយា ។ ឥមានិ ខោ មហារាជ បញ្ច បធានិយង្គានិ ។ ចត្តារោមេ មហារាជ វណ្ណា ខត្តិយា



ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ១ ។ ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយការពប់បង់សន្និ មានវិបាកដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្តៅពេក ជាកណ្តាល អត់ទ្រាំនូវសេចក្តីព្យាយាមបាន ១ ។ ជាអ្នកមិនអួតអាង មិនមានមាយា ធ្វើនូវខ្លួនឲ្យជាក់ច្បាស់តាមសេចក្តីពិតក្នុងព្រះសាស្តាក្តី ក្នុងសព្រហ្មចារីជាអ្នកប្រាជ្ញទាំងឡាយក្តី ១ ។ ជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ដើម្បីបំពេញនូវធម៌ទាំងឡាយជាកុសល មានកំឡាំងចិត្ត មានព្យាយាមដ៏មាំមួន មិនដាក់ចុះនូវធុរៈ ក្នុងធម៌ទាំងឡាយជាកុសលឡើយ ១ ។ ជាអ្នកមានប្រាជ្ញា ប្រកបដោយបញ្ញាដ៏ប្រសើរ ស្គាល់សេចក្តីកើតឡើងនិងវិនាសទៅ ជាបញ្ញាដល់នូវសេចក្តីអស់ទៅនៃទុក្ខ ដែលជាគ្រឿងធ្លុះធ្លាយ ១ ។ បពិត្រមហារាជ នេះឯង ជាអង្គនៃសេចក្តីព្យាយាម ទាំង ៥ ។ បពិត្រមហារាជ វណ្ណៈទាំង ៤ នេះ គឺ ក្សត្រិយ៍ ១

ព្រាហ្មណា វេស្សា សុទ្ទា តេ ចស្សុ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតា តំ តេសំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

(៣៣៥) ចត្តារោមេ ភន្តេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ ចស្សុ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតា ឯត្ថ បន តេសំ ភន្តេ សិយា វិសេសោ សិយា នានាករណន្តិ ។ ឯត្ថ ខោ តេសាហំ មហារាជ បធានវេមត្តតំ(១) វទាមិ ។ សេយ្យថាបស្សុ(២) មហារាជ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា សុទន្តា សុវិនីតា ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា អទន្តា អវិនីតា តំ កឹ មញ្ញសិ មហារាជ យេ តេ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា សុទន្តា សុវិនីតា អបិ នុ តេ ទន្តា វ

១. សមានវេមត្តំ ។ ២. កត្ថចិ បោត្ថកេ សេយ្យថា វា បទំ ទិស្សតិ ។



ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំង ៤ នោះ បើបានប្រកប ដោយអង្គ នៃសេចក្ដីព្យាយាម ទាំង ៥ នេះហើយ ការប្រកបនោះ នៃវណ្ណៈទាំងនោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ សេចក្ដីចំរើន អស់ កាលជាយូរអង្វែង ។

(៣៣៥) បពិត្រព្រះអង្គដ៏ចំរើន វណ្ណៈទាំង ៤ គឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះ បើប្រកបដោយអង្គ នៃសេចក្ដីព្យាយាមទាំង ៥ នេះ បពិត្រព្រះអង្គដ៏ចំរើន តើវណ្ណៈទាំង នោះ មានសេចក្ដីវិសេសផ្សេងគ្នា ផ្សេងគ្នា ក្នុងហេតុនុ៎ះដែរឬ ។ បពិត្រមហារាជ នេះហើយដែលតថាគតពោលថា សេចក្ដីព្យាយាម ខុសគ្នា ក្នុងហេតុនុ៎ះឯង ។ បពិត្រមហារាជ ដូចសត្វពីរពួក គឺដំរី គួរទូន្មាន ឬសេះគួរទូន្មាន ឬគោគួរទូន្មាន ១ ពួក គេបានទូន្មានប្រដៅ ល្អហើយ សត្វពួកទីពីរទៀត គឺដំរីគួរទូន្មាន ឬសេះគួរទូន្មាន ឬគោ គួរទូន្មាន ១ ពួក តែគេមិនបានទូន្មាន មិនបានប្រៀនប្រដៅទេ បពិត្រ មហារាជ ព្រះអង្គសំគាល់សេចក្ដីនោះ ដូចម្ដេច សត្វពីរពួកណា គឺដំរីគួរទូន្មាន ឬសេះគួរទូន្មាន ឬគោគួរទូន្មាន ១ ពួក គេបាន ទូន្មានល្អ ប្រៀនប្រដៅល្អហើយ តើសត្វទាំងនោះ លុះគេទូន្មានហើយ

ទន្តការណំ គច្ឆេយ្យុំ ទន្តា វា ទន្តភូមឹ សម្បា-
បុណេយ្យុន្តិ ។ ឯវមេតំ(១) ភន្តេ ។ យេ បន តេ ទ្វេ
ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា អទន្តា
អវិនីតា អបិ នុ តេ អទន្តា វា ទន្តការណំ គច្ឆេយ្យុំ
អទន្តា វា ទន្តភូមឹ សម្បាបុណេយ្យុំ សេយ្យថាបិ
តេ ទ្វេ ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា
សុទន្តា សុវិនីតាតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ
ខោ មហារាជ យន្តំ សទ្ធេន បត្តព្វំ អប្បាពាធេន
អសឋេន អមាយាវិនា អារទ្ធវីរិយេន បញ្ញវតា តំ
វត(២) អស្សទ្ធោ ពវ្ហាពាធោ សឋោ មាយាវី កុសីតោ
ទុប្បញ្ញោ បាបុណិស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។

[៣៦០] ហេតុរូបំ ភន្តេ ភគវា អាហ
សហេតុរូបំ បន ភន្តេ ភគវា អាហ ។ ចត្តារោមេ
ភន្តេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា ។ តេ

១ ឱ. ម. ឯវំ ។ ២ ម. ឥទំ វត ។



បានដល់នូវហេតុតាមដែលទូន្មាន លុះតែទូន្មានហើយ ក៏បានដល់នូវ
ទីតាមដែលទូន្មាន ដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន សេចក្ដីនុ៎ះយ៉ាងនេះ
ហើយ ។ សត្វពួកទាំងណា គឺដំរីទូន្មាន ឬសេះទូន្មាន ឬគោទូ-
ន្មាន ២ ពួក តែគេមិនបានទូន្មាន មិនបានប្រៀនប្រដៅទេ សត្វទាំងនោះ
កាលបើគេមិនបានទូន្មានហើយ តើបានដល់នូវហេតុតាមដែលទូន្មាន
កាលបើគេមិនបានទូន្មានហើយ តើបានដល់នូវទីតាមដែលទូន្មាន ដូចជា
ពួកសត្វទាំងនោះ គឺដំរីទូន្មាន ឬសេះទូន្មាន ឬគោទូន្មាន ដែល
គេបានទូន្មានល្អ ប្រដៅល្អហើយដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន សេចក្ដី
នុ៎ះមិនដូច្នោះទេ ។ បពិត្រមហារាជ សេចក្ដីនេះ បានទំនងយ៉ាងដូចបុគ្គល
មានសទ្ធា មិនមានអាពាធ ជាអ្នកមិនអួតអាង មិនមានមាយា ប្រារព្ធនូវ
សេចក្ដីព្យាយាម មានប្រាជ្ញា រមែងដល់នូវហេតុណា បុគ្គលគ្មានសទ្ធា
មានអាពាធច្រើន ជាអ្នកអួតអាង មានមាយា ខ្ជិលច្រអូស ឥតប្រាជ្ញា
នឹងដល់នូវហេតុនោះដូចគ្នា ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

(៣៦០) បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ពោលនូវពាក្យ
ដ៏សមគួរដល់ហេតុ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ពោលនូវ
ពាក្យប្រព្រឹត្តទៅមួយអន្លើដោយហេតុ បពិត្រព្រះអង្គដ៏ចំរើន វណ្ណៈទាំង ៤
នេះគឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះ

ចស្សុ ឥមេហិ បញ្ចហិ បធានិយង្គេហិ សមន្នាគតា
តេ ចស្សុ សម្មប្បធានា ឯត្ថ បន តេសំ ភន្តេ
សិយា វិសេសោ សិយា នានាករណន្តិ ។ ឯត្ថ
ខោ នេសាហំ មហារាជ ន កិញ្ចិ នានាករណំ
វទាមិ យទិទំ វិមុត្តិយា វិមុត្តឹ ។ សេយ្យថាបិ
មហារាជ(១) បុរិសោ សុក្ខំ សាលកដ្ឋំ អាទាយ
អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យ(២) ។
អថ អបរោ(៣) បុរិសោ សុក្ខំ អម្ពកដ្ឋំ អាទាយ
អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យ ។ អថ
ប(៤) អបរោ បុរិសោ សុក្ខំ ឧទុម្ពរកដ្ឋំ អាទាយ អគ្គឹ
អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យ ។ តំ កិំ
មញ្ញសិ មហារាជ សិយា នុ ខោ តេសំ អគ្គីនំ
នានាទារុតោ អភិនិព្វត្តានំ កិញ្ចិ នានាករណំ អច្ចិយា
វា អច្ចឹ(៥) វណ្ណេន វា វណ្ណំ អាភាយ វា អាភន្តិ ។

---

១ ឱ. ឯត្ថន្តរេ បុរិសោ សុក្ខំ សាកកដ្ឋំ អាទាយ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យ ។ អថ អបរោតិ ។ អតិរេកបាឋោ ទិស្សតិ ។ ២ ម. ជាតុំ ។ ៣ ម. អបរោបិ ។ ៤ ឱ. ម. បនាបរោ ន ទិស្សតិ ។ ៥ ឱ. ម. អច្ចិ ។





បើប្រកបដោយអង្គនៃសេចក្ដីព្យាយាម ៥ នេះ វណ្ណៈទាំង៤នោះឈ្មោះថា
មានសេចក្ដីព្យាយាមដោយពិត បពិត្រព្រះអង្គដ៏ចំរើន វណ្ណៈទាំង៤នោះ
មានសេចក្ដីវិសេសជាងគ្នា ផ្សេងគ្នាក្នុងហេតុនុ៎ះឯង ។ បពិត្រមហារាជ
តថាគតមិនពោលនូវភាពផ្សេង ១ ចន្លោះចន្លងក្នុងហេតុនុ៎ះ គឺវិមុត្តិដោយ
វិមុត្តិទេ ។ បពិត្រមហារាជ ដូចបុរសយកឧសសាលព្រឹក្សដែលស្ងួត មក
បង្កាត់ភ្លើង ភ្លើងក៏កើតឡើង ។ មានបុរសម្នាក់ទៀត យកឧសស្វាយ
ដែលស្ងួតមកបង្កាត់ភ្លើង ភ្លើងក៏កើតឡើងដែរ ។ បុរសម្នាក់ទៀត យក
ឧសល្វាដែលស្ងួតមកបង្កាត់ភ្លើង ភ្លើងក៏កើតភ្លើងឡើងដែរ ។ បពិត្រម-
ហារាជ ព្រះអង្គសំគាល់នូវសេចក្ដីនោះ ថាដូចម្ដេច តើមានចន្លោះចន្លងផ្សេងៗ
របស់ភ្លើងទាំង៤នោះ ដែលកើតអំពីឧសផ្សេង ៗ គឺអណ្ដាតភ្លើងដោយ
អណ្ដាតភ្លើងក្ដី ពណ៌ដោយពណ៌ក្ដី ពន្លឺដោយពន្លឺក្ដី ទុកជាមានដែរឬ ។

នោហេតំ ភន្តេ ។ ឯវមេវ ខោ មហារាជ យំ តំ តេជំ វីរិយាភិមន្ថិតំ បធានាភិនិព្វត្តំ(១) នាហំ ឯត្ថ កិញ្ចិ នានាករណំ វទាមិ យទិទំ វិមុត្តិយា វិមុត្តិន្តិ ។

[៣៦១] ហេតុរូបំ ភន្តេ ភគវា អាហ សហេតុរូបំ បន ភន្តេ ភគវា អាហ កឹ បន ភន្តេ អត្ថិ ទេវាតិ ។ កឹ បន ត្វំ មហារាជ ឯវំ វទេសិ កឹ បន ភន្តេ អត្ថិ ទេវាតិ ។ យទិ វា តេ ភន្តេ ទេវា អាគន្តារោ ឥត្ថត្តំ យទិ វា អនាគន្តារោ ឥត្ថត្តន្តិ ។ យេ តេ មហារាជ ទេវា សព្យាបជ្ឈា តេ ទេវា អាគន្តារោ ឥត្ថត្តំ យេ តេ ទេវា អព្យាបជ្ឈា តេ ទេវា អនាគន្តារោ ឥត្ថត្តន្តិ ។

[៣៦២] ឯវំ វុត្តេ វិឌូឌភោ សេនាបតិ ភគវន្តំ ឯតទវោច យេ តេ ភន្តេ ទេវា សព្យាបជ្ឈា

១ ម. វីរិយាភិមន្ថិតំ បធានាភិនិព្វត្តំ ទិស្សតិ ។



សេចក្តីនេះ មិនដូចគ្នាទេព្រះអង្គ ។ បពិត្រមហារាជ តេជះណា ដែលបុគ្គលមិនបានញាំញី ដោយព្យាយាម ដែលកើតអំពីព្យាយាម តថាគត មិនពោលនូវសេចក្តីបែកប្លែកគ្នាថា ផ្សេងគ្នាក្នុងតេជះនោះ គឺវិមុត្តិ ដោយវិមុត្តិយ៉ាងនេះទេ ។

[៣៦១] បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគ ពោលពាក្យប្រព្រឹត្តទៅមួយអន្លើដោយហេតុ បពិត្រព្រះអង្គដ៏ចំរើន ចុះទេវតាមានដែរឬ ។ បពិត្រមហារាជ ចុះហេតុដូចម្តេចបានជាទ្រង់ត្រឡប់សួរយ៉ាងនេះវិញថា បពិត្រព្រះអង្គដ៏ចំរើន ចុះទេវតាមានដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ប្រសិនបើទេវតាមានមែន ទេវតាពួកនោះ មុខជានឹងមកកាន់អត្តភាពជាមនុស្សនេះពុំខាន ថ្វីបើមិនមានទេ (ទេវតាពួកនោះ) នឹងមិនមកកាន់អត្តភាពជាមនុស្សនេះឡើយ ។ បពិត្រមហារាជ ពួកទេវតាណា មានសេចក្តីព្យាបាទ ទេវតាពួកនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្តីព្យាបាទ ទេវតាពួកនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ ។

[៣៦២] កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ វិឌូឌភសេនាបតី ក៏បានពោលតបទៅនឹងព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពួកទេវតាណា មានសេចក្តីព្យាបាទ ទេវតា

អាគន្តារោ ឥត្ថត្តំ តេ ទេវា យេ តេ ទេវា អព្យាបជ្ឈា អនាគន្តារោ ឥត្ថត្តំ តេ ទេវេ តម្ហា ឋានា ចាវេស្សន្តិ វា បព្វាជេស្សន្តិ វាតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អយំ ខោ វិឌូឌភោ សេនាបតិ រញ្ញោ បសេនទិស្ស កោសលស្ស បុត្តោ អហំ ភគវតោ បុត្តោ អយំ ខោ កាលោ យំ បុត្តោ បុត្តេន មន្តេយ្យាតិ ។ អថខោ អាយស្មា អានន្ទោ វិឌូឌភំ សេនាបតិំ អាមន្តេសិ តេនហិ សេនាបតិ តញ្ញេវេត្ថ(១) បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ សេនាបតិ យាវតា រញ្ញោ បសេនទិស្ស កោសលស្ស វិជិតំ យត្ថ ច រាជា បសេនទិ កោសលោ ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ បហោតិ តត្ថ រាជា បសេនទិ កោសលោ សមណំ វា ព្រាហ្មណំ វា បុញ្ញវន្តំ វា អបុញ្ញវន្តំ វា ព្រហ្មចរិយវន្តំ វា អព្រហ្មចរិយវន្តំ វា តម្ហា ឋានា ចាវេតុំ វា បព្វាជេតុំ វាតិ ។ យាវតា ភោ

១ ឱ. ម. តំយេវេត្ថ ។



ទាំងនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្តីព្យាបាទ ទេវតាទាំងនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ ហើយញ៉ាំងទេវតាដែលមានព្យាបាទទាំងនោះ ឲ្យកម្រើកចាកទីនោះ ឬបណ្តេញចេញ ។ លំដាប់នោះ ព្រះអានន្ទមានសេចក្តីត្រិះរិះយ៉ាងនេះថា វិឌូឌភសេនាបតីនេះ ជាបុត្ររបស់ព្រះបាទបសេនទិកោសល ឯអាត្មាអញជាបុត្រ របស់ព្រះមានព្រះភាគ កាលនេះជាកាលឲ្យបុត្រប្រឹក្សាជាមួយនឹងបុត្រ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ហៅវិឌូឌភសេនាបតីមកថា បពិត្រសេនាបតី បើដូច្នោះ អាត្មាភាពនឹងសួរប្រស្នាចំពោះទ្រង់ក្នុងដំណើរនេះវិញ ប្រស្នាគួរដល់ទ្រង់យ៉ាងណា សូមទ្រង់ដោះស្រាយយ៉ាងនោះចុះ បពិត្រសេនាបតី ចុះទ្រង់សំគាល់សេចក្តីនោះ ជាដូចម្តេច ដែនរបស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល សោយរាជសម្បត្តិជាឥស្សរាធិបតីក្នុងដែនណា ព្រះបាទបសេនទិកោសលអាចធ្វើឲ្យកម្រើក ឬបណ្តេញនូវសមណព្រាហ្មណ៍ ដែលមានបុណ្យក្តី ឥតបុណ្យក្តី មានសេចក្តីប្រព្រឹត្តិល្អក្តី មិនមានសេចក្តីប្រព្រឹត្តិល្អក្តី ឲ្យចេញចាកដែនទីនោះក្នុងដែននោះ បានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចំរើន ដែន

រញ្ញោ បសេនទិស្ស កោសលស្ស វិជិតំ យត្ថ ច រាជា បសេនទិ កោសលោ ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ បហោតិ តត្ថ រាជា បសេនទិ កោសលោ សមណំ វា ព្រាហ្មណំ វា បុញ្ញវន្តំ វា អបុញ្ញវន្តំ វា ព្រហ្មចរិយវន្តំ វា អព្រហ្មចរិយវន្តំ វា តម្ហា ឋានា ចាវេតុំ វា បព្វាជេតុំ វាតិ ។ តំ កិំ មញ្ញសិ សេនាបតិ យាវតា រញ្ញោ បសេនទិស្ស កោសលស្ស អវិជិតំ យត្ថ ច រាជា បសេនទិ កោសលោ ន ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ តត្ថ បហោតិ រាជា បសេនទិ កោសលោ សមណំ វា ព្រាហ្មណំ វា បុញ្ញវន្តំ វា អបុញ្ញវន្តំ វា ព្រហ្មចរិយវន្តំ វា អព្រហ្មចរិយវន្តំ វា តម្ហា ឋានា ចាវេតុំ វា បព្វាជេតុំ វាតិ ។ យាវតា ភោ រញ្ញោ បសេនទិស្ស កោសលស្ស អវិជិតំ យត្ថ ច រាជា បសេនទិ កោសលោ ន ឥស្សរិយាធិបច្ចំ រជ្ជំ ការេតិ ន តត្ថ បហោតិ



របស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល សោយរាជសម្បត្តិជាឥស្សរាធិបតី ក្នុងដែនណា ព្រះបាទបសេនទិកោសល អាចដើម្បីធ្វើឲ្យកក្រើក បណ្តេញចេញនូវសមណព្រាហ្មណ៍ ដែលមានបុណ្យឬឥតបុណ្យ ប្រព្រឹត្តល្អឬប្រព្រឹត្តអាក្រក់ ឲ្យចេញចាកតំណែងនោះ ក្នុងដែននោះបាន ។ បពិត្រសេនាបតី ទ្រង់សំគាល់នូវសេចក្តីនោះ ជាដូចម្តេច ទីដែលមិនមែនជាដែនរបស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល មិនបានសោយរាជសម្បត្តិជាឥស្សរាធិបតីក្នុងដែនណា ព្រះបាទបសេនទិកោសល អាចដើម្បីធ្វើឲ្យកក្រើក បណ្តេញនូវសមណព្រាហ្មណ៍ ដែលមានបុណ្យឬឥតបុណ្យ ប្រព្រឹត្តល្អឬប្រព្រឹត្តអាក្រក់ ឲ្យចេញចាកតំណែងនោះបានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចំរើន ទីដែលមិនមែនជាដែនរបស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល មិនបានសោយរាជសម្បត្តិជាឥស្សរាធិបតីក្នុងដែនណា

រាជា បសេនទិ កោសលោ សមណំ វា ព្រាហ្មណំ វា បុញ្ញវន្តំ វា អបុញ្ញវន្តំ វា ព្រហ្មចរិយវន្តំ វា អព្រហ្មចរិយវន្តំ វា តម្ហា ឋានា ចាវេតុំ វា បព្វាជេតុំ វា ភន្តេ ។ តំ កឹ មញ្ញសិ សេនាបតិ សុតា តេ ទេវា តាវត្តិំសាតិ ។ ឯវំ ភោ សុតា មេ ទេវា តាវត្តិំសា ឥធាទិបិ(១) ភោតា រញ្ញា បសេនទិនា កោសលេន សុតា ទេវា តាវត្តិំសាតិ ។ តំ កឹ មញ្ញសិ សេនាបតិ បហោតិ រាជា បសេនទិ កោសលោ ទេវេ តាវត្តិំសេ តម្ហា ឋានា ចាវេតុំ វា បព្វាជេតុំ វា ភន្តេ ។ ទស្សនាយបិ ភោ រាជា បសេនទិ កោសលោ ទេវេ តាវត្តិំសេ នប្បហោតិ កុតោ បន តម្ហា ឋានា ចាវេស្សតិ វា បព្វាជេស្សតិ វាតិ ។ ឯវមេវ ខោ សេនាបតិ យេ តេ ទេវា សព្យាបជ្ឈា អាគន្តារោ ឥត្ថត្តំ តេ ទេវា យេ តេ ទេវា អព្យាបជ្ឈា អនាគន្តារោ

---

១ ម. ឥធាបិ ។



ព្រះបាទបសេនទិកោសល មិនអាចដើម្បីធ្វើឲ្យឃ្លាតច្រាក ឬបណ្ដេញនូវសមណៈឬព្រាហ្មណ៍ ដែលមានបុណ្យឬឥតបុណ្យ មានព្រហ្មចរិយធម៌ឬមិនមានព្រហ្មចរិយធម៌ ឲ្យចេញចាកតំណែងនោះ កន្លែងនោះបានទេ ។ បពិត្រសេនាបតី ចុះទ្រង់សំគាល់នូវសេចក្ដីនោះ ដូចម្ដេច ទ្រង់បានឮថា ពួកទេវតាជាន់តាវត្តិង្សមានដែរឬ ។ ព្រះករុណា យ៉ាងហ្នឹងហើយ ខ្ញុំបានឮថា ពួកទេវតាជាន់តាវត្តិង្សមាន តែឥឡូវនេះ ព្រះបាទបសេនទិកោសលដ៏ចំរើន ក៏ទ្រង់ឮថា ពួកទេវតាជាន់តាវត្តិង្សមានដែរ ។ បពិត្រសេនាបតី ចុះទ្រង់សំគាល់សេចក្ដីនោះ ដូចម្ដេច ព្រះបាទបសេនទិកោសល អាចដើម្បីធ្វើឲ្យឃ្លាតច្រាកឬបណ្ដេញពួកទេវតាជាន់តាវត្តិង្ស ឲ្យចេញចាកទីនោះបានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះបាទបសេនទិកោសល មិនអាចដើម្បីមើលពួកទេវតាជាន់តាវត្តិង្សឃើញទេ នឹងទៅបំបរបង់ឬបណ្ដេញ (ទេវតាទាំងនោះ) ឲ្យចេញចាកទីនោះឯណាបាន ។ បពិត្រសេនាបតី យ៉ាងនោះពិតហើយ ពួកទេវតាណា មានសេចក្ដីព្យាបាទ ទេវតាទាំងនោះ មកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្ដីព្យាបាទ ទេវតាទាំងនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ (ទេវតាទាំងនោះ)

ឥត្ថត្តំ តេ ទេវេ ទស្សនាយបិ នប្បហោន្តិ កុតោ បន តម្ហា ឋានា ចាវេស្សន្តិ វា បព្វាជេស្សន្តិ វាតិ អថខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច កោនាមាយំ[១] ភន្តេ ភិក្ខូតិ ។ អានន្ទោ នាម មហារាជាតិ ។

(៣៦៣) អានន្ទោ វត ភោ អានន្ទរូបោ វត ភោ ហេតុរូបំ ភន្តេ អាយស្មា អានន្ទោ អាហ សហេតុរូបំ បន ភន្តេ អាយស្មា អានន្ទោ អាហ កឹ បន ភន្តេ អត្ថិ ព្រហ្មាតិ ។ កឹ បន ត្វំ មហារាជ ឯវំ វទេសិ កឹ បន ភន្តេ អត្ថិ ព្រហ្មាតិ ។ យទិ វា សោ ភន្តេ ព្រហ្មា អាគន្តា ឥត្ថត្តំ យទិ វា អនាគន្តា ឥត្ថត្តន្តិ ។ យោ សោ មហារាជ ព្រហ្មា សព្យាបជ្ឈោ សោ អាគន្តា ឥត្ថត្តំ យោ សោ ព្រហ្មា អព្យាបជ្ឈោ សោ ព្រហ្មា អនាគន្តា ឥត្ថត្តន្តិ ។

១ ម. យ. កោ នាមោ អយំ ។



មិនអាចដើម្បីមើលឃើញ នូវពួកទេវតាទាំងនោះឃើញទេ ចំណង់ទៅបើ បង់ចុះបណ្តេញ (ទេវតាទាំងនោះ) ឲ្យចេញចាកទីឯណាបាន ។ គ្រានោះ ព្រះបាទបសេនទិកោសល ទូលសួរទៅព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះឈ្មោះអ្វី ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ឈ្មោះអានន្ទ ។

(៣៦៣) ព្រះរាជាមានព្រះឱង្ការថា អើហ្ន៎ ព្រះអានន្ទទេតើ អើហ្ន៎ រូបព្រះអានន្ទទេតើ បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះអានន្ទមានអាយុ លោះសំដែងពាក្យសមគួរដល់ហេតុ បពិត្រលោកម្ចាស់ដ៏ចំរើន ព្រះអានន្ទមានអាយុ លោះសំដែងពាក្យប្រព្រឹត្តទៅ មួយអន្លើដោយហេតុ បពិត្រលោកម្ចាស់ដ៏ចំរើន ចុះព្រហ្មមានដែរឬ ។ ព្រះអានន្ទឆ្លើយក្រាបទូលថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គមានព្រះឱង្ការសួរ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន ព្រហ្មមានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចំរើន បើព្រហ្មនោះមានមែន មុខជានឹងមកកាន់អត្តភាពជាមនុស្សនេះ មិនមានទេ បើមិនមានទេ មិនបានមកកាន់អត្តភាពជាមនុស្សនេះឡើយ ។ បពិត្រមហារាជ បើព្រហ្មណា មានសេចក្តីព្យាបាទ ព្រហ្មនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ព្រហ្មណា មិនមានសេចក្តីព្យាបាទទេ ព្រហ្មនោះ មិនបានមកកាន់អត្តភាពជាមនុស្សនេះទេ ។

អថខោ អញ្ញតរោ បុរិសោ រាជានំ បសេនទឹ កោសលំ ឯតទវោច សញ្ជយោ មហារាជ ព្រាហ្មណោ អាកាសគោត្តោ អាគតោតិ ។ អថខោ រាជា បសេនទិ កោសលោ សញ្ជយំ ព្រាហ្មណំ អាកាសគោត្តំ ឯតទវោច កោ នុ ខោ ព្រាហ្មណ ឥមំ កថាវត្ថុំ រាជន្តេបុរេ អព្ភុទាហាសីតិ ។ វិឌូឌភោ មហារាជ សេនាបតីតិ ។ វិឌូឌភោ សេនាបតិ ឯវមាហ សញ្ជយោ មហារាជ ព្រាហ្មណោ អាកាសគោត្តោតិ ។ អថខោ អញ្ញតរោ បុរិសោ រាជានំ បសេនទឹ កោសលំ ឯតទវោច យានកាលោ មហារាជាតិ ។

(៣៦៦) អថខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច សព្វញ្ញុតំ មយំ ភន្តេ ភគវន្តំ អបុច្ឆិម្ហា សព្វញ្ញុតំ ភគវា ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា ចាតុវណ្ណឹ សុទ្ធឹ មយំ ភន្តេ ភគវន្តំ អបុច្ឆិម្ហា ចាតុវណ្ណឹ សុទ្ធឹ ភគវា ព្យាកាសិ



លំដាប់នោះ មានបុរសម្នាក់ ក្រាបបង្គំទូលព្រះបាទបសេនទិកោសល ដូច្នេះថា បពិត្រមហារាជ សញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រមកដល់ហើយ ។ ទើបព្រះបាទបសេនទិកោសល មានព្រះឱង្ការទៅនឹងសញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រដូច្នេះថា ម្នាលព្រាហ្មណ៍ នរណាហ្ន៎ នាំពោលឡូកថាវត្ថុនេះ ក្នុងទីក្នុងវាំងរបស់ស្តេចបាន ។ សញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ក្រាបបង្គំទូលថា បពិត្រមហារាជ មានវិឌូឌភសេនាបតី ។ វិឌូឌភសេនាបតី ពោលយ៉ាងនេះថា បពិត្រមហារាជ មានតែសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ។ គ្រានោះ មានបុរសម្នាក់ទៀត បានក្រាបបង្គំទូលព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រមហារាជ កាលនេះគួរស្តេចយាងហើយ ។

(៣៦៦) លំដាប់នោះ ព្រះបាទបសេនទិកោសល បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំបានទូលសួរនូវសព្វញ្ញុតញ្ញាណ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវសព្វញ្ញុតញ្ញាណ ការព្យាករនោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករនោះ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំ បានទូលសួរនូវសេចក្តីស្អាតនៃវណ្ណៈទាំង ៤ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវសេចក្តីស្អាត

តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា អធិទេវេ មយំ ភន្តេ ភគវន្តំ អបុច្ឆិម្ហា អធិទេវេ ភគវា ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា អធិព្រហ្មានំ មយំ ភន្តេ ភគវន្តំ អបុច្ឆិម្ហា អធិព្រហ្មានំ ភគវា ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា យំ យទេវ ច បន មយំ ភគវន្តំ អបុច្ឆិម្ហា តំ តទេវ ភគវា ព្យាកាសិ តញ្ច បនម្ហាកំ រុច្ចតិ ចេវ ខមតិ ច តេន ចម្ហា អត្តមនា ហន្ទ ចទានិ មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ កាលំ មញ្ញសីតិ ។



នៃវណ្ណៈទាំង ៤ ហើយ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំរីករាយដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំបានសួរនូវពួកទេវតាជាធំ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវពួកទេវតាជាធំ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំបានទូលសួរនូវព្រហ្មជាធំ នឹងព្រះមានព្រះភាគ ហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវព្រហ្មជាធំ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំបានទូលសួរនូវហេតុណា ៗ នឹងព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏បានព្យាករនូវហេតុនោះ ៗ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវយើងខ្ញុំមានកិច្ចច្រើន មានការងារដែលត្រូវធ្វើច្រើន យើងខ្ញុំសូមថ្វាយបង្គំលាត្រឡប់ទៅវិញ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សូមព្រះអង្គសំគាល់នូវកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។

អថខោ រាជា បសេនទិ កោសលោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមីតិ ។

កណ្ណកត្ថលសុត្តំ ទសមំ និដ្ឋិតំ ។

រាជវគ្គោ ចតុត្ថោ ។

តស្ស វគ្គស្ស ឧទ្ទានំ

ជោតិសហាយការដ្ឋបាលោ ច
រាជា មឃទេវមធុរាពោធិ
អង្គុលិមាលោ ធម្មចេតិយសមោ
កណ្ណកត្ថលោ ទសមោ[១] ។

១. ម. តស្ស វគ្គស្ស ឧទ្ទានំ ជោតិ... ទសមោតិ ន ទិស្សតិ ។



លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់សព្វព្រះរាជហឫទ័យ រីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ហើយក្រោកចាកអា-សនៈ ថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ធ្វើប្រទក្សិណហើយ ស្ដេចចេញទៅ ។

ចប់ កណ្ណកត្ថលសូត្រ ទី ១០ ។

ចប់ រាជវគ្គ ទី ៤ ។

## ឧទ្ទាននៃរាជវគ្គនោះគឺ

ជោតិសហាយក[១]សូត្រ ១ រដ្ឋបាលសូត្រ ១ មឃទេវ-សូត្រ ១ មធុរសូត្រ ១ ពោធិរាជកុមារសូត្រ ១ អង្គុលិមា-លសូត្រ ១ (បិយជាតិកសូត្រ ១ ពាហិតិយសូត្រ ១) ធម្ម-ចេតិយសូត្រ ១ កណ្ណកត្ថលសូត្រ ១ គ្រប់ជា ១០ សូត្រ ។

១ ក្នុងសូត្រឈ្មោះជា ឃដិការសូត្រ តែនិយាយក្នុងឧទ្ទានឈ្មោះជា ជោតិសហាយកសូត្រវិញ លោកឡើងឈ្មោះតាមរឿង ព្រោះសូត្រនោះមានឈ្មោះឃដិការ ជាសំឡាញ់របស់ជោតិបាល-មាណព ។

សុត្តន្តបិដកេ

# មជ្ឈិមនិកាយស្ស មជ្ឈិមបណ្ណាសកំ

## បឋមោ ភាគោ

---

## បរិព្វាជកវគ្គោ

### បឋមំ ចូឡវច្ឆគោត្តសុត្តំ


អង្កោ

បរិព្វាជកវគ្គស្ស ចូឡវច្ឆគោត្តសុត្តេ អភូតេន អព្ភាចិក្ខនំ . . . . . ៣

តេវិជ្ជោ សមណោ . . . . . ៤

សព្ពញ្ញុព្យាករណំ . . . . . . ៧


### ទុតិយំ អគ្គិវច្ឆគោត្តសុត្តំ


បរិព្វាជកវគ្គស្ស អគ្គិវច្ឆគោត្តសុត្តេ ទសទិដ្ឋិគតំ . . . . . . . ៩

ទិដ្ឋិគតាទីនវព្យាករណំ . . . . . ១៥

វិមុត្តិបញ្ហា . . . . . . . ១៧

អគ្គិជលនិភុតបញ្ហា . . . . . ១៩

ខន្ធប្បហានំ . . . . . . . ២១

ធម្មទេសនាបសំសា . . . . . ២៣


សុត្តន្តបិដក

# មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ

## បឋមភាគ

---

## បរិព្វាជកវគ្គ

### ចូឡវច្ឆគោត្តសូត្រទី ១


លេខទំព័រ

បរិព្វាជកវគ្គ ចូឡវច្ឆគោត្តសូត្រ ការពោលបង្កាច់ដោយពាក្យមិនពិត . . . ៣

តេវិជ្ជសមណៈ . . . . . . . . ៤

ការប្រាប់ព្យាករណ៍សម្ពុទ្ធរបស់ត្រៃយថាសូន្យ . . ៧


### អគ្គិវច្ឆគោត្តសូត្រទី ២


បរិព្វាជកវគ្គ អគ្គិវច្ឆគោត្តសូត្រ ទិដ្ឋិ ១០ ប្រការ . . . . . . . ៩

ការប្រាប់ទោសនៃសេចក្តីឃើញយ៉ាងថ្លៃ

ស្អាតជាដើម . . . . . . . ១៥

ការសួរអំពីវិមុត្តិ . . . . . . ១៧

ការសួរអំពីការឆេះនិងការរលត់ភ្លើង . . . ១៩

ការលះបង់នូវខន្ធ . . . . . . . ២១

ការពោលសរសើរព្រះធម្មទេសនា . . . ២៣

## តតិយំ មហាវច្ឆគោត្តសុត្តំ


អង្ក

បរិញ្ញាតវត្ថុស្ស មហាវច្ឆគោត្តសុត្តេ ទស ធម្មា . . . . . . ២៧

ឧបាសកបុច្ឆា . . . . . ២៩

ឧបាសិកាបុច្ឆា . . . . . ៣១

ធម្មាភិកតា . . . . . . ៣៣

ធម្មទេសនាបសំសា . . . . ៣៧

ឥទ្ធានុភាវោ . . . . . . ៣៩

បព្វជ្ជា . . . . . . ៤១

ឧត្តរិបព្វជ្ជា . . . . . ៤៣

ភគវន្តទស្សនាយគមនំ . . . ៤៥

វច្ឆគោត្តប្បសំសា . . . . ៤៧


## ចតុត្ថំ ទីឃនខសុត្តំ


បរិញ្ញាតវត្ថុស្ស ទីឃនខសុត្តេ ឯកេសំ ទិដ្ឋិ . . . . ៤៩

ទិដ្ឋិប្បហានំ . . . . . . ៥១

កាយានុបស្សនា . . . . . ៥៥




## មហាវច្ឆគោត្តសូត្រ ទី ៣


លេខទំព័រ

បរិញ្ញាតវត្ថុ មហាវច្ឆគោត្តសូត្រ ធម៌ ១០ ប្រការ . . . . . . ២៧

ការសួរអំពីឧបាសក . . . . . ២៩

ការសួរអំពីឧបាសិកា . . . . . ៣១

ការទូលខបំពេញធម៌ . . . . . ៣៣

ការពោលសរសើរព្រះធម្មទេសនា . . ៣៧

អានុភាពនៃឫទ្ធិ . . . . . . ៣៩

បព្វជ្ជា . . . . . . . . ៤១

ឧត្តរិបព្វជ្ជា . . . . . . . ៤៣

ការចូលទៅគាល់ព្រះមានព្រះភាគ . . . ៤៥

ការជ្រះសរសើរវច្ឆគោត្តភិក្ខុ . . . ៤៧


## ទីឃនខសូត្រ ទី ៤


បរិញ្ញាតវត្ថុ ទីឃនខសូត្រ កំណើតទិដ្ឋិរបស់សមណព្រាហ្មណ៍

ពួកខ្លះ . . . . . . . . ៤៩

ការលះបង់ទិដ្ឋិ . . . . . ៥១

ការពិចារណាឃើញកាយ . . . . ៥៥

បិដ្ឋ

បរិព្វាជកវគ្គស្ស ទីឃនខសុត្តំ តិវេទនាទិកថា . . . . . ៤៧

ឧបាសកត្តបវេទនា . . . . ៤៩


## បញ្ចមំ មាគណ្ឌិយសុត្តំ


បរិព្វាជកវគ្គស្ស មាគណ្ឌិយសុត្តំ ភគវតោ កិត្តិសទ្ទោ . . . . ៦១

អត្តនោ បុរិសភូមិ . . . . . ៦៣

ចក្ខាយតនាទិកថា . . . . . ៦៥

រូបាយតនាទិកថា . . . . . ៦៧

ទិព្វកាមូបមា . . . . . . ៦៩

បឋមកុដ្ឋូបមា . . . . . ៧៣

ទុតិយកុដ្ឋូបមា . . . . . ៧៥

តតិយកុដ្ឋូបមា . . . . . ៧៧

កាមតណ្ហា . . . . . . ៧៩

ជច្ចន្ធូបមា . . . . . . ៨១

បច្ឆិមគាថា . . . . . . ៨៣





លេខទំព័រ

បរិព្វាជកវគ្គ ទីឃនខសូត្រ ការឃើញលោកយោគនៃវេទនា ៣ . . . ៤៧

ការសំដែងខ្លួនជាឧបាសក . . . ៤៩


## មាគណ្ឌិយសូត្រ ទី ៥


បរិព្វាជកវគ្គ មាគណ្ឌិយសូត្រ កិត្តិសព្ទរបស់ព្រះមានព្រះភាគ . . . ៦១

សេចក្តីលះទៅកាន់កាមគុណ . . . ៦៣

ការគាបសង្កត់អាយតនៈមានអាយតនៈគឺ

ចក្ខុជាដើម . . . . . . . ៦៥

ការគាបសង្កត់អាយតនៈមានរូបាយតនៈ

ជាដើម . . . . . . . . ៦៧

សេចក្តីប្រៀបដូចកាមជាទិព្វ . . ៦៩

សេចក្តីប្រៀបដូចបុរសកើតឃ្លង់ទី ១ ៧៣

សេចក្តីប្រៀបដូចបុរសកើតឃ្លង់ទី ២ ៧៥

សេចក្តីប្រៀបដូចបុរសកើតឃ្លង់ទី ៣ ៧៧

កាមតណ្ហា . . . . . . . ៧៩

សេចក្តីប្រៀបដូចបុរសខ្វាក់តាំងពីកំណើត ៨១

គាថាសម្រាប់បច្ឆិម . . . . ៨៣

អង្ក

បរិញ្ញាណកវគ្គស្ស មាគណ្ឌិយសុត្តំ មាគណ្ឌិយាភណិតា . . . . . . . ៨៥

ធម្មទេសនាបសំសា . . . . . ៨៩

មាគណ្ឌិយោ អរហត្តប្បត្តោ . . . ៩១


## ឆដ្ឋំ សន្ទកសុត្តំ


បរិញ្ញាណកវគ្គស្ស សន្ទកសុត្តំ និវាបកថា . . . . . . . ៩៣

ធម្មីកថា . . . . . . . . ៩៥

ថេរទិដ្ឋិកថា . . . . . ៩៧

បឋមព្រហ្មចរិយវាសោ . . . . ៩៩

ទុតិយព្រហ្មចរិយវាសោ . . . . ១០៣

តតិយព្រហ្មចរិយវាសោ . . . . ១០៥

ចតុត្ថព្រហ្មចរិយវាសោ . . . . ១០៩

បឋមព្រហ្មចរិយំ . . . . . . ១១៥

តតិយព្រហ្មចរិយំ . . . . . ១១៩

ចតុត្ថព្រហ្មចរិយំ . . . . . . ១២១

ពុទ្ធគុណកថា . . . . . . . ១២៣





ទំព័រ

បរិញ្ញាណកវគ្គ មាគណ្ឌិយសូត្រ សេចក្តីភាសនានៃមាគណ្ឌិយបរិព្វាជក . . ៨៥

ការពោលសរសើរព្រះធម្មទេសនា . . ៨៨

មាគណ្ឌិយនិក្ខមនបួសព្រះអរហត្ត . . ៩១


## សន្ទកសូត្រ ទី ៦


បរិញ្ញាណកវគ្គ សន្ទកសូត្រ និវាបកថា . . . . . . . . ៩៣

ធម្មីកថា . . . . . . . . . . ៩៥

ការពោលអំពីទសវត្ថុកទិដ្ឋិ . . . . . ៩៧

អព្រហ្មចរិយវាសទី ១ . . . . . . ៩៩

អព្រហ្មចរិយវាសទី ២ . . . . . . . ១០៣

អព្រហ្មចរិយវាសទី ៣ . . . . . . ១០៥

អព្រហ្មចរិយវាសទី ៤ . . . . . . ១០៩

ព្រហ្មចរិយធម៌ទី ១ . . . . . . ១១៥

ព្រហ្មចរិយធម៌ទី ៣ . . . . . . ១១៩

ព្រហ្មចរិយធម៌ទី ៤ . . . . . . ១២១

ពុទ្ធគុណកថា . . . . . . . ១២៣

ទំព័រ


បរិព្វាជកវគ្គស្ស សន្ទកសុត្តំ តិស្សោ វិជ្ជា . . . . . ១៦៥

បញ្ចង្គានុសយបហានំ . . . ១៦៧

ហត្ថបាទច្ឆិន្នូបមា . . . . ១៦៩

សុត្តបរិយោសានំ . . . ១៧១


## សត្តមំ មហាសកុលុទាយិសុត្តំ


បរិព្វាជកវគ្គស្ស មហាសកុលុទាយិសុត្តំ និទានកថា . . . . . ១៧៣

អន្តរកថាភេទំ . . . ១៧៥

៥ សត្ថុគារវតា . . . . ១៧៧

សត្ថុគារវតា . . . . . . ១៨១

បញ្ចសុ បឋមធម្មោ . . . ១៨៣

តតិយចតុត្ថធម្មោ . . . ១៨៥

អប្បាហារោ . . . . ១៨៧

សន្តុដ្ឋិតា . . . . . . ១៨៩

បឋមធម្មោ . . . . . . ១៩៣

តតិយធម្មោ . . . . . . ១៩៥




លេខទំព័រ


បរិព្វាជកវគ្គ សន្ទកសូត្រ វិជ្ជា ៣ ប្រការ . . . . . . ១៦៥

ការមិនប្រព្រឹត្តិល្មើសនូវហេតុ

៥ ប្រការ . . . . . . . ១៦៧

សេចក្តីប្រៀបដូចបុរសកំបុតដៃជើង . ១៦៩

ទីបំផុតនៃសូត្រ . . . . . ១៧១


## មហាសកុលុទាយិសូត្រ ទី ៧


បរិព្វាជកវគ្គ មហាសកុលុទាយិសូត្រ និទានកថា . . . . . . . ១៧៣

ការក្រោកបន្តិចពីអន្តរកថា . . . ១៧៥

សេចក្តីមិនគោរពដល់គ្រូទាំង ៥ . . . ១៧៧

សេចក្តីគោរពដល់ព្រះសាស្តា . . . ១៨១

ការគោរពសំខាន់ធម៌ទី ១ ក្នុងធម៌ ៥ . ១៨៣

ការគោរពសំខាន់ធម៌ទី ៣-៤ . . . ១៨៥

ការមានអាហារតិច . . . . ១៨៧

សេចក្តីសន្តោស . . . . ១៨៩

ធម៌ទី ១ . . . . . . . ១៩៣

ធម៌ទី ៣ . . . . . . . ១៩៥

អង្ក

បរិញ្ញេយ្យវគ្គស្ស មហាសកុលុទាយិសុត្តេ

ចតុត្ថធម្មោ . . . . ១៥៧

ចត្តារោ សម្មប្បធានា . . ១៥៩

សត្ត ពោជ្ឈង្គានិ . . ១៦១

អដ្ឋ វិមោក្ខា . . . . ១៦៣

អដ្ឋាភិភាយតនានិ . . . ១៦៥

ចត្តារិ ឈានានិ . . . ១៦៩

ទុតិយដ្ឋានំ . . . . ១៧១

ចតុត្ថដ្ឋានំ . . . . ១៧៣

មនោមយិទ្ធិ . . . . ១៧៥

ឥទ្ធិវិធញាណំ . . . . ១៧៧

ទិព្វសោតធាតុញាណំ . . ១៧៩

ចេតោបរិយញាណំ . . . ១៨១

បុព្វេនិវាសានុស្សតិញាណំ . ១៨៣

ទិព្វចក្ខុញាណំ . . . . ១៨៥

បញ្ចមធម្មោ . . . . ១៨៧





លេខទំព័រ

បរិញ្ញេយ្យវគ្គ មហាសកុលុទាយិសូត្រ

ធម៌ទី ៤ . . . . . . . ១៥៧

សម្មប្បធាន ៤ . . . . . ១៥៩

ពោជ្ឈង្គធម៌ ៧ ប្រការ . . . ១៦១

វិមោក្ខ ៨ ប្រការ . . . . ១៦៣

អភិភាយតនៈតាំង ៨ . . . . ១៦៥

ឈានតាំង ៤ . . . . . ១៦៩

ទុតិយដ្ឋាន . . . . . ១៧១

ចតុត្ថដ្ឋាន . . . . . . ១៧៣

មនោមយិទ្ធិ . . . . . . ១៧៥

ឥទ្ធិវិធញាណ . . . . . ១៧៧

ទិព្វសោតធាតុញាណ . . . . ១៧៩

ចេតោបរិយញាណ . . . . ១៨១

បុព្វេនិវាសានុស្សតិញាណ . . . ១៨៣

ទិព្វចក្ខុញាណ . . . . . ១៨៥

ធម៌ទី ៥ . . . . . . . ១៨៧

## អដ្ឋមំ សមណមុណ្ឌិកសុត្តំ


អង្កេ

បរិច្ឆេទវគ្គស្ស សមណមុណ្ឌិកសុត្តេ និទានកថា . . . . . . ១៨៩

បរិព្វាជកកថា . . . . . ១៩១

តថាគតកថា . . . . . ១៩៣

ទស ធម្មា . . . . . ១៩៥

អកុសលសីលកថា . . . . ១៩៧

កុសលសីលកថា . . . . ១៩៩

កុសលសង្កប្បកថា . . . . ២០១

ទសាសេក្ខធម្មា . . . . ២០៣


## នវមំ ចូឡសកុលុទាយិសុត្តំ


បរិច្ឆេទវគ្គស្ស ចូឡសកុលុទាយិសុត្តេ បរិសាបត្តាកេចនំ . . . . ២០៧

បុព្វាបរន្តកថា . . . . ២០៩

ជនបទកល្យាណិការូបមា . . . ២១៣

គម្ភីរដ្ឋបនោបមា . . . . ២១៥




## សមណមុណ្ឌិកសូត្រ ទី ៨


លេខទំព័រ

បរិច្ឆេទនៃវគ្គ សមណមុណ្ឌិកសូត្រ និទានកថា . . . . . . . ១៨៩

កថារបស់បរិព្វាជក . . . . . . ១៩១

កថារបស់ព្រះមានព្រះភាគ . . . . ១៩៣

ធម៌ ១០ ប្រការ . . . . . . ១៩៥

ការពោលអំពីសីលជាអកុសល . . ១៩៧

ការពោលអំពីសីលជាកុសល . . ១៩៩

ការពោលអំពីសង្កប្បៈជាកុសល . . ២០១

អសេខធម៌ ១០ ប្រការ . . . ២០៣


## ចូឡសកុលុទាយិសូត្រ ទី ៩


បរិច្ឆេទនៃវគ្គ ចូឡសកុលុទាយិសូត្រ ការក្រាបបង្គំទូលអំពីរឿងកាលនៃបរិស័ទ ២០៧

ការពោលអំពីប្រស្នាព្រោះធ្វើបំផុតខាង

ដើមនិងខាងចុង . . . . . ២០៩

សេចក្តីប្រៀបដូចបុរសស្នេហាស្ត្រីជាទី

ជនបទកល្យាណី . . . . ២១៣

សេចក្តីប្រៀបដូចពន្លឺកែវមណីឥតខ្ចោះ

ដែលជាតិមណី . . . . . ២១៥

[illegible]


| | | | |
|---|---|---|---|
| បរិព្វាជកវគ្គស្ស | ចូឡសកុលុទាយិសុត្តំ | បណ្ណាសេទន្ទវណ្ណាបមា . | ៦១៧ |
| | | ឯកន្តសុខបញ្ហា . . . . | ៦១៩ |
| | | សុខទុក្ខបញ្ហា . . . . | ៦២១ |
| | | ឯកន្តសុខបញ្ហា . . . . | ៦២៣ |
| | | ចតុរូបជ្ឈានំ . . . . | ៦២៥ |
| | | តិវិជ្ជាញាណំ . . . . | ៦២៧ |
| | | បព្ពជ្ជាយាចនំ . . . . | ៦២៩ |


## ទសមំ វេខណសសុត្តំ


| | | | |
|---|---|---|---|
| បរិព្វាជកវគ្គស្ស | វេខណសសុត្តំ | បរមវណ្ណបញ្ហា . . . . | ៦៣៣ |
| | | ទតយវណ្ណបញ្ហា . . . . | ៦៣៥ |
| | | កាមគ្គសុខបសំសា . . . | ៦៣៧ |
| | | បុព្វាបរន្តកថា . . . . | ៦៤១ |
| មជ្ឈិមនិកាយស្ស | មជ្ឈិមបណ្ណាសកេ | បរិព្វាជកវគ្គាវសានំ . . . | ៦៤៣ |




ទំព័រ


| | | | |
|---|---|---|---|
| បរិព្វាជកវគ្គ | ចូឡសកុលុទាយិសូត្រ | សេចក្ដីប្រៀបដូចពណ៌ព្រះចន្ទ្រ | |
| | | ក្នុងថ្ងៃ ១៥ កើត . . . . . . | ៦១៧ |
| | | ការសួរអំពីសេចក្ដីសុខដោយចំ- | |
| | | ណែកមួយ . . . . . . | ៦១៩ |
| | | ការសួរអំពីសេចក្ដីសុខនិងទុក្ខ . . | ៦២១ |
| | | ការសួរអំពីលោកដែលមានសេចក្ដីសុខ | |
| | | ដោយចំណែកមួយ . . . . | ៦២៣ |
| | | រូបជ្ឈាន ៤ . . . . . . . | ៦២៥ |
| | | ញាណ ៣ ប្រការ . . . . . | ៦២៧ |
| | | ការក្រាបបង្គំទូលសូមបួស . . . | ៦២៩ |


## វេខណសសូត្រ ទី ១០


| | | | |
|---|---|---|---|
| បរិព្វាជកវគ្គ | វេខណសសូត្រ | ការសួរអំពីពន្លឺដែលថ្លៃថ្លា . . . | ៦៣៣ |
| | | ការសួរអំពីពន្លឺដ៏ធំធេង . . . | ៦៣៥ |
| | | ការពោលសរសើរសេចក្ដីសុខដែល | |
| | | ជាកំពូលនៃកាម . . . . . | ៦៣៧ |
| | | ការពោលអំពីទីបំផុតខាងដើមនិង | |
| | | ខាងចុង . . . . . . . . | ៦៤១ |
| មជ្ឈិមនិកាយ | មជ្ឈិមបណ្ណាសកៈ | ទីបំផុតនៃបរិព្វាជកវគ្គ . . . . . | ៦៤៣ |

# រាជវគ្គ

## បឋមំ ឃដិការសុត្តំ


អង្គ

ភគវន្តស្ស ឃដិការសុត្តេ ភូតបុព្វកថា . . . . . . . . ៤៤៥

ជោតិបាលសមាទបនំ . . . . . . ៤៤៧

សម្មាសម្ពុទ្ធុបសង្កមនំ . . . . . . ៤៥១

ជោតិបាលស្ស អភិបព្វជ្ជា . . . . ៤៥៣

កិកិកាសិរាជវត្ថុ . . . . . . . ៤៥៥

កិកិនិវេសនូបសង្កមនំ . . . . . . ៤៥៧

ឃដិការប្បសំសា . . . . . . ៤៥៨

កាសិតាភិខន្ទនំ . . . . . . . ៤៦៧


## ទុតិយំ រដ្ឋបាលសុត្តំ


ភគវន្តស្ស រដ្ឋបាលសុត្តេ គតូបសង្កមនំ . . . . . . . . ៤៦៩

បព្វជ្ជាយាចនំ . . . . . . . . ៤៧១

មាតាបិតាបុច្ឆា . . . . . . . . ៤៧៣

រដ្ឋបាលាយាចនំ . . . . . . . ៤៧៥




# រាជវគ្គ

## ឃដិការសូត្រ ទី ១


លេខទំព័រ

ភគវត្ថុ ឃដិការសូត្រ រឿងធ្លាប់មានមកហើយ . . . . ៤៤៥

ការបបួលជោតិបាលមាណព . . . ៤៤៧

ការចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ . . . ៤៥១

បំណងរបស់ជោតិបាលមាណព . . . ៤៥៣

រឿងព្រះរាជាដែនកាសីទ្រង់ព្រះនាមកិកិ . . ៤៥៥

ស្ដេចចូលទៅកាន់ព្រះរាជដំណាក់ព្រះ

បាទកិកិ . . . . . . . . . ៤៥៧

ការទ្រង់សរសើរឃដិការឲ្យខ្លាំង . . . ៤៥៨

ការផ្ញើគ្រឿងអង្ករកាសិក . . . . ៤៦៧


## រដ្ឋបាលសូត្រ ទី ២


ភគវត្ថុ រដ្ឋបាលសូត្រ ការចូលទៅគាល់ព្រះមានព្រះភាគ . . ៤៦៩

ការទូលសុំបព្វជ្ជា . . . . . ៤៧១

ការពោលលាមាតាបិតា . . . . . ៤៧៣

ការពោលអង្វររដ្ឋបាលកុលបុត្រ . . . ៤៧៥

ទំព័រ

រាជវគ្គស្ស រដ្ឋបាលសុត្តំ មាតាបិតាយាចនំ . . . . . . . . ២៧៧
បព្វជ្ជានុជាននំ . . . . . . . . ២៧៩
អរហត្តប្បត្តការណំ . . . . . . . ២៨១
រដ្ឋបាលប្បវត្តិការណំ . . . . . . ២៨៣
បិតុនិវេសនុបសង្កមនំ . . . . . . ២៨៥
សំវិគ្គគាថា . . . . . . . . ២៨៩
រដ្ឋបាលុបសង្កមនំ . . . . . . . ២៩១
ជរាបារិជុញ្ញកថា . . . . . . . ២៩៣
រោគបារិជុញ្ញកថា . . . . . . . ២៩៥
ចត្តារោ ធម្មុទ្ទេសា . . . . . . ២៩៧
បឋមធម្មុទ្ទេសកថា . . . . . . ២៩៩
ទុតិយធម្មុទ្ទេសកថា . . . . . . ៣០១
តតិយធម្មុទ្ទេសកថា . . . . . . ៣០៣
ចតុត្ថធម្មុទ្ទេសកថា . . . . . . . ៣០៥
និគមគាថា . . . . . . . . ៣០៧





ទំព័រ

រាជវគ្គ រដ្ឋបាលសូត្រ ការពោលអង្វរមាតាបិតា . . . . . ២៧៧
ការអនុញ្ញាតឲ្យទៅបួស . . . . . ២៧៩
ការបានសម្រេចព្រះអរហត្ត . . . . . ២៨១
ការប្រព្រឹត្តនៃព្រះរដ្ឋបាល . . . . ២៨៣
ការចូលទៅកាន់លំនៅរបស់បិតា . . . ២៨៥
គាថាជាទីសង្វេគ . . . . . . . ២៨៩
ស្តេចចូលទៅរកព្រះរដ្ឋបាល . . . . . ២៩១
ការពោលអំពីសេចក្តីសាបសូន្យព្រោះជរា . . ២៩៣
ការពោលអំពីសេចក្តីសាបសូន្យព្រោះរោគ . . ២៩៥
ធម្មុទ្ទេស ៤ ប្រការ . . . . . ២៩៧
ការពោលអំពីធម្មុទ្ទេសទី ១ . . . . ២៩៩
ការពោលអំពីធម្មុទ្ទេស ទី ២ . . . . ៣០១
ការពោលអំពីធម្មុទ្ទេស ទី ៣ . . . . ៣០៣
ការពោលអំពីធម្មុទ្ទេស ទី ៤ . . . . ៣០៥
និគមគាថា . . . . . . . . ៣០៧

## ទុតិយំ មហាបទានសុត្តំ

អង្គ


ពុទ្ធវគ្គស្ស មហាបទានសុត្ត មហាបទានកថា . . . . . . ៣១៣

មហាបទានបុច្ឆា . . . . . . ៣១៥

ទេវបុត្តសមនុសាសនី . . . . ៣១៧

មហាបទានបុគ្គលបុច្ឆា . . . . . ៣១៩

ចតុព្រហ្មវិហារកថា . . . . ៣២១

និមិត្តផស្សកថា . . . . . ៣២៣

សុព្រហ្មស្សបវេសនំ . . . . ៣២៥

កប្បកាមគុណំ . . . . . ៣២៧

ទេវបុត្តសមនុសាសនី . . . . ៣២៩

អត្ថិមបុរិសគ្គកាលេ . . . . ៣៣១

កល្យាណវត្តំ . . . . . . ៣៣៣




## មហាបទានសូត្រ ទី ៣

លេខទំព័រ


ភណវារៈ មហាបទានសូត្រ រឿងព្រះធាតុមហាបទានៈ . . . . . . ៣១៣

បញ្ហានៃព្រះធាតុមហាបទានៈ . . . . . ៣១៥

ការប្រជុំប្រៀនប្រដៅព្រះរាជបុត្រច្បង . . . ៣១៧

បញ្ហានៃព្រះរាជបុត្រព្រះធាតុមហាបទានៈ . . . ៣១៩

ការចំរើនព្រហ្មវិហារ ៤ . . . . . ៣២១

ព្រះឥន្ទ្រមានព្រះរាជបំណងចង់ឃើញព្រះធាតុ និមិត្ត . . . . . . . . . . ៣២៣

ការនាំចូលទៅកាន់ពួកសុព្រហ្ម . . . . ៣២៥

ទ្រង់មានព្រះបណ្ដាំនឹងពួកព្រះកេស . . . ៣២៧

ការប្រជុំប្រៀនប្រដៅព្រះរាជបុត្រច្បង . . . ៣២៩

ការដាំបុរសជាកសិករ . . . . . . ៣៣១

កល្យាណវត្ត . . . . . . . . . ៣៣៣

## ចតុត្ថំ មធុរសុត្តំ

| | | អង្គ |
|---|---|---|
| កថាវត្ថុស្ស មធុរសុត្ត | ចតុវណ្ណបញ្ហា . . . . . . | ៣៣៧ |
| | ចតុវណ្ណសមសមភាវោ . . . | ៣៤១ |
| | ចោរកូតចតុវណ្ណបញ្ហា . . . | ៣៤៧ |
| | សមណកូតចតុវណ្ណបញ្ហា . . . | ៣៤៩ |
| | មហាកច្ចានប្បសំសា . . . . | ៣៥១ |
| | ឧបាសកត្តប្បវេទនំ . . . . | ៣៥៣ |

## បញ្ចមំ ពោធិរាជកុមារសុត្តំ

| | | |
|---|---|---|
| កថាវត្ថុស្ស ពោធិរាជកុមារសុត្ត | ស្វាគតាយាចិកសនំ . . . . | ៣៥៥ |
| | និវេសនូបសង្កមនំ . . . . . | ៣៥៧ |
| | អាឡារូបសង្កមនំ . . . . . | ៣៥៩ |
| | ឧទ្ទកូបសង្កមនំ . . . . . | ៣៦៥ |
| | បឋមូបមា . . . . . . . | ៣៦៩ |
| | ទុតិយូបមា . . . . . . . | ៣៧១ |

## មធុរសូត្រ ទី ៤

| | | លេខទំព័រ |
|---|---|---|
| កថាវត្ថុ មធុរសូត្រ | ប្រស្នាប្រាជ្ញវណ្ណៈទាំង ៤ . . . . | ៣៣៧ |
| | ការនៃវណ្ណៈទាំង ៤ ស្មើៗគ្នា . . . | ៣៤១ |
| | ប្រស្នាប្រាជ្ញវណ្ណៈទាំង ៤ ដែលជាចោរ . . | ៣៤៧ |
| | ប្រស្នាប្រាជ្ញវណ្ណៈទាំង៤ដែលជាសមណៈ | ៣៤៩ |
| | ការក្រេវក្រាស់សរសើរព្រះមហាកច្ចានៈ . . | ៣៥១ |
| | ការប្រកាសខ្លួនជាឧបាសក . . . | ៣៥៣ |

## ពោធិរាជកុមារសូត្រ ទី ៥

| | | |
|---|---|---|
| កថាវត្ថុ ពោធិរាជកុមារសូត្រ | ការប្រើខ្លួនមិនគួរដើម្បីជាន់កន្ទៀលសំពត់. | ៣៥៥ |
| | ស្ដេចចូលទៅកាន់និវេសនរបស់ព្រះរាជ- | |
| | កុមារ . . . . . . . . . . | ៣៥៧ |
| | ស្ដេចចូលទៅរកអាឡារតាបស . . . | ៣៥៩ |
| | ស្ដេចចូលទៅរកឧទ្ទកតាបស . . . | ៣៦៥ |
| | ឧបមាទី ១ . . . . . . . . | ៣៦៩ |
| | ឧបមាទី ២ . . . . . . . . | ៣៧១ |

| | | ទំព័រ |
|---|---|---|
| កន្សែងស្បូ ពោធិកពីកុមារស្មោគ | គតិយូបមា . . . . . . . | ៣៧៣ |
| | សម្បុទកដ្ឋុខ . . . . . . | ៣៧៦ |
| | អាហារប្បញ្ញាត . . . . . | ៣៨១ |
| | សម្បូហារេត . . . . . . . | ៣៨៣ |
| | គន្ធាវេទនា . . . . . . . | ៣៨៦ |
| | ទន្លាកោហារក្តុញខ . . . . | ៣៨៧ |
| | សាសាតុយញ្ញាណាំ . . . . | ៣៨៩ |
| | សម្បូស្តុកការេ . . . . . . | ៣៩១ |
| | ព្រហ្មវេស្សនា . . . . . . | ៣៩៣ |
| | គិរិគុម្ពល្លបមសក្ត . . . . . | ៣៩៦ |
| | បបុមធម្មទេសនាហេតុ . . . . | ៣៩៧ |
| | ទុបការដំរែកទេស្បូវ . . . . . | ៣៩៩ |
| | បញ្ញាតិយបសក្តិមន . . . . | ៤០១ |
| | ព្រហ្មចារិយបញ្ញា . . . . . | ៤០៧ |





| | | ទំព័រ |
|---|---|---|
| កវិត្ត ពោធិកពកុមារស្ម័គ្រ | ទបនាទិ ៣ . . . . . . | ៣៧៣ |
| | សម្បូទកដ្ឋុខ . . . . . . | ៣៧៨ |
| | ការតាំងអាហារ . . . . . . | ៣៨២ |
| | ការមានអាហារតិច . . . . | ៣៨៣ |
| | វេទនាដំរាបផ្សូរ . . . . | ៣៨៥ |
| | ការប្រើសអាហារដើម្បីត្រៀមត្រាត | ៣៨៧ |
| | សាសាតុយញ្ញាណ . . . . | ៣៨៩ |
| | ការតាំងអ្នកមានសេចក្តីខ្វល់ខ្វាយតិច .. | ៣៩១ |
| | ព្រហ្មត្រាបត្តិខ្វលអាកនា . . | ៣៩៣ |
| | ពត្តកសត្វមានសេចក្តីប្រៀបធៀប | |
| | ទម្រល ៣ យ៉ាង . . . . | ៣៩៥ |
| | ការប្រើប្រាស់ព្រៀកដិបបមធម្មទេសនា .. | ៣៩៧ |
| | ការប្រើដួបទឹងទបការដែក . . . | ៣៩៩ |
| | ស្តេចចូលដាក់គេបញ្ញាតិយតិក . . | ៤០១ |
| | ប្រស្នាប្រាជ្ញគ្គព្រហ្មចារិយៈ . . | ៤០៧ |

អង្គ

កណ្ឌវត្ថុស្ស ពោធិរាជកុមារសុត្ត — រាជកុមារបុច្ឆា . . . . . ៦០៨

បញ្ច បធានិយង្គានិ . . . . . ៦១១

ឧបាសកត្តបវេទនំ . . . . . ៦១៥

ឆដ្ឋំ អង្គុលិមាលសុត្តំ

កណ្ឌវត្ថុស្ស អង្គុលិមាលសុត្ត — ភគវន្តនិវារណំ . . . . . ៦១៨

ឥទ្ធាភិសង្ខារំ . . . . . ៦២១

អង្គុលិមាលបរិតោសា . . . . ៦២៣

បសេនទិស្ស ភគវន្តុបសង្កមនំ . . ៦២៥

អង្គុលិមាលសន្ទស្សនំ . . . . ៦២៧

ភគវន្តបូជា . . . . . ៦២៨

អង្គុលិមាលស្ស សច្ចកិរិយា . . . . ៦៣១

លេឌ្ឌុទណ្ឌាទិឃាតនំ . . . . ៦៣៣

អង្គុលិមាលុទានំ . . . . . ៦៣៥





លេខទំព័រ

កណ្ឌវត្ថុ ពោធិរាជកុមារសូត្រ — ការទ្រង់សាកសួរអំពីការសម្រេចនិព្វាន . . ៦០៨

អង្គនៃសេចក្ដីព្យាយាម ៥ ប្រការ . . ៦១១

ការប្រកាសព្រះអង្គជាឧបាសក . . ៦១៥

## អង្គុលិមាលសូត្រ ទី ៦

កណ្ឌវត្ថុ អង្គុលិមាលសូត្រ — ការទូលឃាត់ព្រះមានព្រះភាគ . . ៦១៨

ការទ្រង់សំដែងឫទ្ធិ . . . . . ៦២១

សេចក្ដីត្រេកអរនៃអង្គុលិមាលចោរ . . ៦២៣

ព្រះបាទបសេនទិស្ដេចចូលទៅគាល់ ព្រះមានបុណ្យ . . . . . ៦២៥

ការទ្រង់ចង្អុលបង្ហាញអង្គុលិមាលភិក្ខុ . . ៦២៧

ការក្រាបបង្គំលាព្រះមានព្រះភាគ . . ៦២៨

សច្ចកិរិយារបស់អង្គុលិមាលភិក្ខុ . . . ៦៣១

ការត្រូវដុំដីនិងដំបងជាដើម . . . ៦៣៣

ឧទានរបស់ព្រះអង្គុលិមាល . . . ៦៣៥

អង្គ

## សត្តមំ បិយជាតិកសុត្តំ


កថាវត្ថុ បិយជាតិកសុត្ត អត្ថុប្បត្តិ . . . . . . . . ៤៤១

មល្លិកាមន្តនំ . . . . . . ៤៤៣

ករខេបសន្តមន្តនំ . . . . . . ៤៤៥

គុណបុគ្គលថា . . . . . . . ៤៤៧

បិយបុញ្ញា . . . . . . . ៤៥១

បរសទ្ធិកោសល្យតានំ . . . . ៤៥៥


## អដ្ឋមំ ពាហិតិយសុត្តំ


កថាវត្ថុ ពាហិតិយសុត្ត បសេនទិស្ស អញ្ញាតបុរិសាមន្តនំ ៤៥៧

កាយវចីមនោសមាចារបុញ្ញា . ៤៥៩

សត្តាកុសលធម្មប្បហានំ . . ៤៦៣

សត្តកុសលធម្មប្បហានំ . . . ៤៦៥

ពាហិតិកបដិគ្គហណំ . . . . ៤៦៧

អានន្ទស្សុនលោកោ . . . . ៤៦៩




## បិយជាតិកសូត្រ ទី ៧

លេខទំព័រ


កថាវត្ថុ បិយជាតិកសូត្រ ក្មួយក្មេងសេដ្ឋីស្លាប់ . . . . ៤៤១

ព្រះរាជាមានព្រះបន្ទូលហៅព្រះនាងមល្លិកា . . ៤៤៣

ការទូលទៅគាល់ព្រះមានព្រះភាគ . . ៤៤៥

ការពោលតាមរឿងក្តីមានមកហើយ . . ៤៤៧

ប្រស្នាព្រោះស្នេហ៍ស្គាល់ដល់ទីស្រឡាញ់ . . ៤៥១

ទានរបស់ព្រះបាទបសេនទិកោសល . . ៤៥៥


## ពាហិតិយសូត្រ ទី ៨


កថាវត្ថុ ពាហិតិយសូត្រ ព្រះបាទបសេនទិទ្រង់មានព្រះបន្ទូល

និងបុរសម្នាក់ . . . . . . . ៤៥៧

ប្រស្នាព្រោះកាយវចីមនោសមាចារ . . ៤៥៩

ការលះបង់នូវអកុសលធម៌ទាំងពួង . . ៤៦៣

ប្រស្នាព្រោះកុសលធម៌ទាំងពួង . . . ៤៦៥

ការទទួលសំពត់ពាហិតិកា . . . . ៤៦៧

ការថ្វាយព្រះអានន្ទ . . . . ៤៦៩

## នវមំ ធម្មចេតិយសុត្តំ


| | | អង្ក |
|---|---|---|
| កថាវត្ថុស្ស ធម្មចេតិយសុត្តេ | នគរកមបរិសទំ | ៤៧១ |
| | ភគវន្តុបសង្កមនំ | ៤៧៣ |
| | ធម្មន្វយកថា | ៤៧៤ |
| | ធម្មចេតិយភាសិតំ | ៤៨៣ |


## ទសមំ កណ្ណកត្ថលសុត្តំ


| | | |
|---|---|---|
| កថាវត្ថុស្ស កណ្ណកត្ថលសុត្តេ | ចតុវណ្ណវិសេសបុច្ឆា | ៤៨៩ |
| | បញ្ច បធានិយង្គានិ | ៤៩៣ |
| | ទេវបុច្ឆា | ៥០១ |
| | បសេនទិកោសលបុច្ឆា | ៥០៤ |
| | ទូតានំ | ៥០៧ |




## ធម្មចេតិយសូត្រ ទី ៩


| | | លេខទំព័រ |
|---|---|---|
| កថាវត្ថុ ធម្មចេតិយសូត្រ | ស្តេចចូលទៅកាន់ស្រុកនគរ | ៤៧១ |
| | ស្តេចចូលទៅគាល់ព្រះមានព្រះភាគ | ៤៧៣ |
| | ការពោលអំពីការយល់ធម៌ | ៤៧៤ |
| | ធម្មចេតិយភាសិត | ៤៨៣ |


## កណ្ណកត្ថលសូត្រ ទី ១០


| | | |
|---|---|---|
| កថាវត្ថុ កណ្ណកត្ថលសូត្រ | ចតុវណ្ណវិសេសបុច្ឆា | ៤៨៩ |
| | អង្គនៃសេចក្តីព្យាយាម ៥ | ៤៩៣ |
| | ទេវបុច្ឆា | ៥០១ |
| | បសេនទិកោសលបុច្ឆា | ៥០៤ |
| | ទូតាន | ៥០៧ |

| វិរុទ្ធបាឋៈ | អវិរុទ្ធបាឋៈ | អង្គ | ជួរលេខាទី |
|---|---|---|---|
| កាយស ភេទា | កាយស្ស ភេទា | ៥ | ១៣ |
| ទុប ដ្ឋតិ | ទុប្បដ្ឋតិ | ១៧ | ១០ |
| ញាំ | ញា៍ | ១៨ | ៥ |
| ភូមសិ | ភុមសិ | ១៣៥ | ” |
| មារេយ្យ | មារេយ្យំ | ១៦៩ | ” |
| សន្ទិដ្ឋា | សន្ទិដ្ឋា | ១៨១ | ១ |
| បគ្គរោ | បគ្គធរោ | ១៨៧ | ” |
| អតិក្កន្តមានុសកេន | អតិក្កន្តមានុសកេន | ១៨៦ | ៩ |
| ឧដ្ឋិតិ | ខិដ្ឋិក | ១៨៧ | ១៦ |
| បតិកិដ្ឋកាកេ ច | បតីកិដ្ឋកាកេ ច | ២១៨ | ១៨ |
| រាទ្ធ | រិទ្ធ | ២៣៧ | ៣ |
| កត្តុសង្ឃ | កត្តុសង្ឃំ | ២៦៥ | ១០ |
| ផាតិបាលោ | ជោតិបាលោ | ២៦៧ | ១១ |
| វេដ្ឋបាលស្សតេ | វេដ្ឋបាលស្សតេ | ២៧៩ | ៤ |
| មហា | មោហា | ៣០៩ | ១៧ |
| គហ្ហុន | គហូន | ៣១៦ | ៩ |
| ទិស្សុន | ទិស្វាន | ” | ១៦ |

# វិរុទ្ធាវិរុទ្ធបត្ត

| វិរុទ្ធបាឋៈ | អវិរុទ្ធបាឋៈ | អង្គ | បន្ទាត់លេខ |
|---|---|---|---|
| (៤៨២) | (២៥២) | ៣៦៩ | ៩ |
| អញ្ញាះ តរ | អញ្ញាះត្រូវ | ៣៨៦ | ១៩ |
| ទំ | តទំ | ៣៩៣ | ១១ |
| អលមរិយញ្ញាណ | អលមរិយញ្ញាណ | ៤០៤ | " |
| បក្កាម្មន្តិ | បក្កាម្មន្តិ | ៤៤២ | ១២ |
| (៣២៣) | (៣៤៣) | ៥០៤ | ៧ |

---



# តារាងកែប្រែពាក្យខុស ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ទូវិជ្ជា | ទូវិជ្ជា | ៤ | ៨ |
| ដំរិត | ដំរិត | ១២ | ១៩ |
| ទិដ្ឋ | ទិដ្ឋិ | ១៦ | ១៨ |
| ជួបប្រះបុគ្គលមិនគួរ | ជួបប្រះគំមិនគួរ | ១៧ | ៦ |
| ទូវកិរិយា | ទូវកិរិយា | ២០ | ៧ |
| ដៅដូច | ដៅដូចៈ | ៧៣ | ១៩ |
| មិនបានដឹង | មិនបានដឹង | ៨២ | ១៣ |
| ព្រះអរហន្ត | ព្រះអរហន្ត | ៩១ | ១ |
| ផ្ដួលដើម | ផ្ដួលដើម | ១៣៩ | ១៩ |
| ប្រាប់ហៅថា | ប្រាប់ហៅថា | " | " |
| សង្គាយបេលដ្ឋបុគ្គ | សង្គាយបេលដ្ឋបុគ្គ | ១៣៦ | ៤ |
| កំពង់ប្បុក | កំពុង់ប្បុក | ១៨៩ | ១៦ |
| (១៨២) | (១៩២) | ២៧៩ | ១១ |
| ចូលមកនេះ | ចូរមកនេះ | ២៨៦ | ៩ |
| សំពត់កាសាយ | សំពត់កាសាយៈ | ២៩៩ | ១៧ |
| វេមផ្តៅ | វែមផ្តៅ | ៣១០ | ៧ |
| ក្រាប់បីហ៊ានបួនពាន់ឆ្នាំ | ក្រាប់បីហ៊ានបួនពាន់ឆ្នាំ | ៣១៦ | ៦ |

# សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ខែបុត្គ | ខែបុត្ត | ៣១៧ | ១៣ |
| ប្រាំបីម៉ឺនបួនពាន់ឆ្នាំ | ប្រាំបីម៉ឺនបួនពាន់ឆ្នាំ | ៣២០ | ៨ |
| ឯសំឡេងសុះសាយ | ឯសំឡេងសុសសាយ | ៣៣៧ | ៦ |
| ជាទីគាប់ចិត | ជាទីគាប់ចិត្ត | ៣៣៨ | ១៣ |
| ក្រះយាបល | ក្រះយាបល់ | ៣៤១ | ៤ |
| សំឡេងសុះសាយ | សំឡេងសុសសាយ | ״ | ៨ |
| អ្នកចូរទៅ | អ្នកចូរចូលទៅ | ៣៥៤ | ״ |
| ״ | ״ | ៣៥៦ | ១៦ |
| សាឡូកោបស | គជាគគ | ៣៦៤ | ១៣ |
| យើងកមបុត្រ | យើងកម: | ៣៦៧ | ៦ |
| មិនមាគណ្ហា | មិនមានគណ្ហា | ៤៣៥ | ១៥ |
| ឈោះវេ៉ម | ឈ្មោះវេ៉ម | ៤៣៦ | ៩ |
| ប្រស្នាប្រាក្ត | ប្រស្នាប្រាជ្ញ | ៤៥១ | ១ |